# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៥៦

បាលីប្រែ ៦៩

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# សទ្ធម្មប្បកាសិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

## បឋមភាគ

# ៥៦

## បាលីប្រែ ៦៩



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៦
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
## បឋមភាគ

*សូមនមស្ការ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## មាតិកា

*បញ្ញា ( ការដឹងច្បាស់ ) ក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ បញ្ញាក្នុងការស្តាប់ ហើយសង្រួម ឈ្មោះថា សីលមយញ្ញាណ បញ្ញាក្នុងការសង្រួម ហើយតម្កល់ទុក ឈ្មោះថា សមាធិភាវនាមយញ្ញាណ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ បញ្ញាក្នុងការបង្រួញនូវពួកធម៌ជាអតីត អនាគត និងបច្ចុប្បន្ន ហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ បញ្ញាក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថា ឧទយព្វយា-នុបស្សនាញាណ បញ្ញាក្នុងការឃើញនូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឈ្មោះថា អាទីនវញ្ញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណា ឬការព្រងើយកន្តើយ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថា គោត្រភូញាណ បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំងពីរ ឈ្មោះថា មគ្គញ្ញាណ បញ្ញាដែលសម្រាប់រម្ងាប់នូវព្យាយាម ឈ្មោះថា ផលញ្ញាណ បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ បញ្ញាក្នុងការឃើញនូវធម៌ដែលតាំងឡើង ក្នុងខណៈមគ្គផលនោះ*

ឈ្មោះថា បច្ចវេក្ខណញ្ញាណ បញ្ញាក្នុងការកំណត់នូវអាយតនៈខាងក្នុង ឈ្មោះថា វត្ថុនានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវអារម្មណ៍ខាងក្រៅ ឈ្មោះថា គោចរនានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវការត្រាច់ទៅ ( នៃវិញ្ញាណ ) ឈ្មោះថា ចរិយានានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវធម៌ ៤ ឈ្មោះថា ភូមិនានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវធម៌ ៩ ឈ្មោះថា ធម្មនានត្តញ្ញាណ បញ្ញាដែលជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថា ញាតដ្ឋញ្ញាណ បញ្ញាដែលជាគ្រឿងដឹងជ្រួតជ្រាប ឈ្មោះថា តីរណដ្ឋញ្ញាណ បញ្ញាដែលជាគ្រឿងលះ ឈ្មោះថា បរិច្ចាគដ្ឋញ្ញាណ បញ្ញាជាគ្រឿងអប់រំ ឈ្មោះថា ឯករសដ្ឋញ្ញាណ បញ្ញាជាគ្រឿងធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ផស្សនដ្ឋញ្ញាណ បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញ្ញាណ បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញ្ញាណ បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញ្ញាណ បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញ្ញាណ បញ្ញាក្នុងវិបស្សនាវិហារផ្សេងៗ ឈ្មោះថា វិហារដ្ឋញ្ញាណ បញ្ញាក្នុងផលសមាបត្តិផ្សេងៗ ឈ្មោះថា សមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងវិហារសមាបត្តិផ្សេងៗ ឈ្មោះថា វិហារសមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះសេចក្តីបរិសុទ្ធដោយសេចក្តីមិនរាយមាយ ឈ្មោះថា អានន្តរិកសមាធិញ្ញាណ បញ្ញា គឺទស្សនាធិបតេយ្យផង ការបានន្ធូវវិហារដ៏ស្ងប់ផង សេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថា អរណវិហារញ្ញាណ បញ្ញាដែលមានភាពស្ទាត់ជំនាញព្រោះហេតុប្រកបដោយកម្លាំងសមថៈ និងវិបស្សនាទាំង ២ ផង ព្រោះការ

រម្ងាប់នូវសង្ខារទាំង ៣ ផង ព្រោះញាណចរិយា ១៦ ផង ព្រោះសមាធិចរិយា ៩ ផង ឈ្មោះថា និរោធសមាបត្តិញាណ បញ្ញាក្នុងការបង្អស់នូវការប្រព្រឹត្តទៅ ( នៃកិលេស និងខន្ធ ) របស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថា បរិនិព្វានញាណ បញ្ញាដែលមិនប្រាកដ ក្នុងការផ្តាច់ផ្តិលដោយប្រពៃនូវធម៌ទាំងពួងផង ក្នុងការរម្ងត់ផង ឈ្មោះថា សមសីសដ្ឋញាណ បញ្ញាក្នុងការរម្ងត់នូវភ្លើងដ៏ក្រាស់មានភាពផ្សេងៗ និងមានភាពតែមួយ ឈ្មោះថា សល្លេខដ្ឋញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថា វីរិយារម្ភញាណ បញ្ញា គឺការប្រកាសនូវធម៌ផ្សេងៗ ឈ្មោះថា អត្ថសន្ទស្សនញាណ បញ្ញាក្នុងការត្រាស់ដឹងនូវការសង្គ្រោះធម៌ទាំងពួង ឲ្យមានតែមួយ និងកិលេសមានភាពផ្សេងៗ ទាំងគុណធម៌មានសភាពតែមួយ ឈ្មោះថា ទស្សនវិសុទ្ធិញាណ បញ្ញាព្រោះការដឹង ឈ្មោះថា ខន្តិញាណ បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញាណ បញ្ញាក្នុងការប្រមូល ឈ្មោះថា បទេសវិហារញាណ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញាណ បញ្ញាក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្តញាណ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញាណ បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថា ញាណវិវដ្តញាណ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្តញាណ បញ្ញាក្នុងសេចក្តីពិត ឈ្មោះថា សច្ចវិវដ្តញាណ បញ្ញាក្នុងអត្ថថា សម្រេចដោយអំណាចនៃការអធិដ្ឋាននូវសុខសញ្ញា និងលហុសញ្ញា ព្រោះកំណត់នូវកាយ និងចិត្តថាតែមួយ ឈ្មោះថា ឥទ្ធិវិធញាណ បញ្ញាក្នុងការស្ទង់នូវសទ្ទនិមិត្ត មាន

ភាពផ្សេងៗ ទាំងមានភាពតែមួយ ដោយអំណាចនៃកិរិយាផ្សាយទៅនៃវិតក្ក ឈ្មោះថា សោតធាតុវិសុទ្ធិញាណ បញ្ញាក្នុងការស្ទង់នូវការត្រាច់ទៅនៃវិញ្ញាណ ដែលមានសភាពផ្សេងៗ ទាំងមានសភាពតែមួយ ដោយអំណាចនៃបសាទរបស់ឥន្ទ្រិយទាំងឡាយ ព្រោះផ្សាយទៅនៃចិត្តទាំង ៣ ឈ្មោះថា ចេតោបរិយញ្ញាណ បញ្ញាក្នុងការស្ទង់នូវពួកធម៌ ដែលប្រព្រឹត្តទៅបានព្រោះបច្ច័យ ដោយអំណាចនៃកិរិយាផ្សាយទៅនៃកម្ម ដែលមានសភាពផ្សេងៗ គ្នា ទាំងមានសភាពតែមួយ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ បញ្ញាក្នុងអត្ថថា ឃើញនូវរូបនិមិត្តមានសភាវៈផ្សេងៗ ទាំងមានសភាពតែមួយ ដោយអំណាចនៃពន្លឺ ឈ្មោះថា ទិព្វចក្ខុញ្ញាណ បញ្ញាដែលស្ទាត់ជំនាញនៃឥន្ទ្រិយ ៣ ដោយអាការ ៦៤ ឈ្មោះថា អាសវក្ខយញ្ញាណ បញ្ញាក្នុងអត្ថថា កំណត់ដឹង ឈ្មោះថា ទុក្ខញ្ញាណ បញ្ញាក្នុងអត្ថថា លះ ឈ្មោះថា សមុទយញ្ញាណ បញ្ញាក្នុងអត្ថថា ធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា និរោធញ្ញាណ បញ្ញាក្នុងអត្ថថា ចម្រើន ឈ្មោះថា មគ្គញ្ញាណ ទុក្ខញ្ញាណ ទុក្ខសមុទយញ្ញាណ ទុក្ខនិរោធញ្ញាណ ទុក្ខនិរោធគា-មិនីបដិបទាញាណ អត្ថប្បដិសម្ភិទាញាណ ធម្មប្បដិសម្ភិទាញាណ និរុត្តិប្ប-ដិសម្ភិទាញាណ បដិភាណប្បដិសម្ភិទាញាណ ឥន្ទ្រិយបរោបរិយត្តញ្ញាណ សត្តាសយានុសយញ្ញាណ យមកប្បាដិហិរញ្ញាណ មហាករុណាសមាបត្តិញ្ញាណ សព្វញ្ញុតញ្ញាណ អនាវរណញ្ញាណ នេះញាណ ៧៣ បណ្ដាញាណ ៧៣ នេះ ញាណ ៦៧ ជាសាធារណៈដល់ពួកសាវ័ក ញាណ ៦ មិនសាធារណៈដល់ពួកសាវ័កទេ ។

**មាតិកា ចប់**

# សទ្ធម្មប្បកាសិនី

# អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# ភាគទី ១

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## គន្ថារម្ភកថា

*ព្រះមានព្រះភាគជាម្ចាស់អង្គណា ទ្រទ្រង់ព្រះគុណគ្រប់សព្វ ហើយ ដោយសេចក្តីល្អគ្រប់យ៉ាង កន្លងនូវសេចក្តីល្អរបស់ លោកទាំងពួង ទ្រង់ផុតអំពីមន្ទិល គឺកិលេសដែលជាគ្រឿង ប្រទូសរ៉ាយ ព្រមទាំងវាសនា ទ្រង់ប្រទានវិមុត្តិធម៌ដ៏ឧត្តុងឧត្តម ទ្រង់មានព្រះហឫទ័យត្រជាក់ ដូចជាភាពត្រជាក់នៃខ្លឹមច័ន្ទន៍ ពោល គឺព្រះករុណាជានិច្ច ទ្រង់មានព្រះបញ្ញាភ្លឺស្វាង ដូចរស្មីព្រះ អាទិត្យ មានធម៌ជាគ្រឿងដឹកនាំសត្វ ខ្ញុំសូមក្រាបថ្វាយបង្គំ ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ដែលជាបុគ្គលដ៏ឧត្តមប្រសើរ លើសលុប ក្នុងពពួកសត្វ ដែលជាទីពឹងក្នុងវដ្ត ដែលជា ប្រយោជន៍ដល់សត្វទាំងពួង ដោយសិរសា គឺត្បូង ។*

*បណ្តាព្រះមហាថេរៈ ជាពុទ្ធជិនោរសមានចំនួនជាអនន្ត ព្រះ មហាថេរៈអង្គណា ដែលប្រដូចនឹងព្រះមុនី អ្នកប្រសើរលើស លុបក្នុងពពួកសត្វទាំងពួង បានជាអ្នកធ្វើតាមលីលា នៃព្រះ*

សាស្តា ក្នុងការបំពេញប្រយោជន៍ដល់ប្រជុំជន ដោយគុណពោល គឺករុណា និងបញ្ញាញាណ ។ ខ្ញុំសូមនមស្ការ ព្រះថេរៈអង្គនោះ ដែលមានឈ្មោះថា សារីបុត្ត ជាមុនីរាជបុត្ត អ្នកត្រេកអរក្រៃលែងក្នុងស្នេរគុណជាអនេក ជាអ្នករុងរឿងដោយពន្លឺនៃបញ្ញា មានកិត្តិយសល្អ ផ្សាយខ្ចរខ្ចារទៅ និងមានចរិយាវត្តស្ងប់ល្អ វិសិដ្ឋបាឋៈ គឺព្រះបាលីណា ដែលព្រះសាវកជាធម្មសេនាបតី អ្នកប្រកាសព្រះធម្មចក្ក អ្នកចូលដល់សេចក្តីយល់ច្បាស់ក្នុងអត្ថ តាមសេចក្តីពិត ក្នុងព្រះសូត្រទាំងឡាយដែលព្រះតថាគត បានត្រាស់ហើយ ដែលឈ្មោសក្នុងភាសិតជានាយក ក្នុងការញ៉ាំងធម្មប្រទីបឲ្យភ្លឺស្វាង ពោលដោយនាមដ៏វិសេសថា **បដិសម្ភិទាមគ្គ** ជាបាឋៈវិសេស ដែលជាបករណ៍ដ៏ល្អិត ដោយអត្ថ និងន័យផ្សេងៗ យ៉ាងវិចិត្រដែលបណ្ឌិត អ្នកប្រាថ្នាបំពេញអត្តត្ថ គឺប្រយោជន៍របស់ខ្លួន និងលោកត្ថ គឺប្រយោជន៍ដល់សត្វលោក មានបញ្ញាជ្រាលជ្រៅគប្បីយល់ឈមចុះបានសព្វកាល ដែលសាធុជនទាំងឡាយគប្បីសេពជានិច្ច ។

ខ្ញុំនឹងពណ៌នាអត្ថដែលមិនស្មុគស្មាញ ទៅតាមលំដាប់អនុលោមតាមព្រះសូត្រ និងយុត្តិនៃបដិសម្ភិទាមគ្គប្បករណ៍នោះ ដែលនាំមកនូវប្រភេទនៃញាណ ដែលព្រះយោគាវចរទាំងឡាយជា

អនេកសេពហើយ មិនឈានកន្លងលទ្ធិរបស់ខ្លួន និងមិនឈាន
កន្លងលទ្ធិរបស់អ្នកដទៃ តែរួបរួមយកឧទ្ទេស និងន័យរបស់
អដ្ឋកថាបុរាណមកសម្ដែងតាមសមគួរ នឹងពោលអដ្ឋកថាឈ្មោះ
**សទ្ធម្មប្បកាសិនី** នោះ ដោយគោរព ដើម្បីប្រយោជន៍ដល់
មហាជន ដើម្បីសេចក្ដីតាំងមាំនៃព្រះសទ្ធម្មអស់កាលយូរ សូម
សាធុសប្បុរសតាំងចិត្តស្ដាប់ ទទួលទុកចុះ ។

កាលដែលបដិសម្ភិទាមគ្គ ជាមាតិកានៃបដិសម្ភិទា ខ្ញុំត្រូវពោលមុន ព្រោះបានពោលហើយក្នុងគន្ថារម្ភកថា ថាដោយនាមដ៏វិសេស ថាបដិសម្ភិទាមគ្គ ។

**ចតស្សោ ហិ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។**

បដិសម្ភិទាមាន ៤ គឺ

អត្ថប្បដិសម្ភិទា បញ្ញាបែកធ្លាយក្នុងអត្ថ ១ ធម្មប្បដិសម្ភិទា បញ្ញាបែកធ្លាយក្នុងធម៌ ១ និរុត្តិប្បដិសម្ភិទា បញ្ញាបែកធ្លាយក្នុងភាសា ១ បដិភាណប្បដិសម្ភិទា បញ្ញាបែកធ្លាយក្នុងបដិភាណ ១ ។

ផ្លូវ គឺឧបាយជាគ្រឿងសម្រេចបដិសម្ភិទាទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា បដិសម្ភិទាមគ្គ មានពាក្យអធិប្បាយថា ជាហេតុនៃការបានចំពោះនូវបដិសម្ភិទា ។

ប្រសិនបើមានពាក្យសួរថា ផ្លូវនេះជាផ្លូវនៃបដិសម្ភិទាបាន ព្រោះហេតុអ្វី ក៏គប្បីមានវិសជ្ជនាថា ព្រោះផ្លូវ គឺទេសនាដែលព្រះមានព្រះភាគទ្រង់សម្ដែង

ដោយប្រភេទជាហេតុនាំមកនូវបដិសម្ភិទាញាណ ។

ពិតហើយ ធម៌ទាំងឡាយមានប្រភេទផ្សេងៗ ទេសនាក៏មានប្រភេទផ្សេងៗ រមែងឲ្យកើតប្រភេទនៃបដិសម្ភិទាញាណ ដល់ព្រះអរិយបុគ្គលទាំងឡាយដែលជាអ្នកស្តាប់ និងជាបច្ច័យដល់ការបែកធ្លាយក្នុងបដិសម្ភិទាញាណ ដល់បុថុជ្ជនតទៅអនាគត លោកពោលពាក្យនេះថា ទេសនាដោយប្រភេទ រមែងនាំមកនូវបដិសម្ភិទាញាណដែលជាគ្រឿងទម្លាយយនសញ្ញាចេញបាន ។ ទេសនាមានប្រភេទផ្សេងៗ នេះមាន ព្រោះហេតុនោះ ទើបទេសនានោះ ជាទេសនាឲ្យសម្រេចជាផ្លូវនៃបដិសម្ភិទាទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **ចតស្សោ** ជាបទកំណត់ចំនួន ។

បទថា **បដិសម្ភិទា** បានដល់ បញ្ញាជាគ្រឿងបែកធ្លាយ ។ មិនមែនជាការបែកធ្លាយវត្ថុណាមួយដទៃឡើយ ជាការបែកធ្លាយរបស់ញាណប៉ុណ្ណោះ ព្រោះលោកពោលថា ការដឹងក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ការដឹងក្នុងធម៌ឈ្មោះថា **ធម្មប្បដិសម្ភិទា** ការដឹងក្នុងវោហារនៃភាសាដែលពោលដល់អត្ថនិងធម៌ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ ព្រោះហេតុនោះ ទើបពាក្យថា បដិសម្ភិទា ៤ មានសេចក្តីថា ប្រភេទនៃញាណ ៤ ប្រការ ។

ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថ អាចធ្វើការកំណត់ដឹង ធ្វើឲ្យជាក់ច្បាស់ និងធ្វើការចែកប្រភេទនៃអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

ញាណដែលដល់នូវការបែកធ្លាយក្នុងធម៌ អាចធ្វើការកំណត់ដឹង ធ្វើឲ្យ

*ជាក់ច្បាស់ និងធ្វើការចែកប្រភេទនៃហេតុ ឈ្មោះថា* **ធម្មប្បដិសម្ភិទា** ។

*ញាណដែលដល់នូវការបែកធ្លាយក្នុងនិរុត្តិ អាចធ្វើការកំណត់ដឹង ធ្វើឲ្យជាក់ច្បាស់ និងធ្វើការចែកប្រភេទនៃនិរុត្តិ ( ភាសា ) ឈ្មោះថា* **និរុត្តិប្បដិសម្ភិទា** ។

*ញាណដែលដល់នូវការបែកធ្លាយក្នុងបដិភាណ អាចធ្វើការកំណត់ដឹង ធ្វើឲ្យជាក់ច្បាស់ និងធ្វើការចែកប្រភេទនៃបដិភាណ ( ភាពឈ្លាសវៃ ) ឈ្មោះថា* **បដិភាណប្បដិសម្ភិទា** ។

*បណ្តាបទទាំងនោះ បទថា* **អត្ថ** *ពោលដោយសង្ខេប បានដល់ ផលដែលកើតអំពីហេតុ ។ ពិតហើយ ផលដែលកើតអំពីហេតុនោះ ដែលបុគ្គលរមែងទៅ គឺសម្រេច បានដល់ ដល់តាមគន្លងនៃហេតុ ដូច្នោះ ទើបហៅថា* **អត្ថ** ។ *តែកាលណាពោលដោយប្រភេទហើយ ធម៌ទាំង ៥ ប្រការនេះ គឺ ធម៌ដែលកើតអំពីបច្ច័យណាមួយ ១ និព្វាន ១ អត្ថនៃព្រះបាលីដែលព្រះមានព្រះភាគត្រាស់ហើយ ១ វិបាក ១ កិរិយា ១ បណ្ឌិតគប្បីជ្រាបថា* **អត្ថ** ។ *ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថនុះ របស់ព្រះអរិយបុគ្គល ដែលពិចារណាអត្ថនោះឯង ឈ្មោះថា* **អត្ថប្បដិសម្ភិទា** ។

*បទថា* **ធម្ម** *ពោលដោយសង្ខេប បានដល់ បច្ច័យ ។ ពិតហើយ ព្រោះបច្ច័យនោះរមែងតាក់តែង គឺរមែងឲ្យប្រព្រឹត្តទៅ បានដល់ រមែងឲ្យដល់នូវផលនោះៗ ហេតុនោះ ទើបហៅថា* **ធម្ម** ។ *តែបើពោលដោយប្រភេទហើយ ធម៌ទាំង ៥ ប្រការនេះ គឺហេតុឲ្យកើតផលយ៉ាងណាមួយ ១ អរិយមគ្គ ១ ព្រះបាលីដែលព្រះមានព្រះភាគត្រាស់ហើយ ១ កុសល ១ អកុសល ១ បណ្ឌិតគប្បី*

*ជ្រាបថា* **ធម្ម** *។ ញាណដែលបែកធ្លាយក្នុងធម៌នុ៎ះ របស់ព្រះអរិយបុគ្គល អ្នកពិចារណាធម៌នោះ ឈ្មោះថា* **ធម្មប្បដិសម្ភិទា** *។*

*ពិតហើយ អត្ថដូចតទៅនេះ មកក្នុងព្រះអភិធម្មបិដក ( វិភង្គ ) ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងចែកដោយន័យជាដើមថា*

*សេចក្ដីដឹងក្នុងទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងការកើតឡើងនៃទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការរលត់ទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា ។*

*ធម៌ទាំងឡាយណា កើត ចម្រើន លូតលាស់ ដុះដាល ចម្រុងចម្រើន កើតប្រាកដហើយ សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះឈ្មោះថា អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយនោះកើត ចម្រើន លូតលាស់ ដុះដាល ចម្រុងចម្រើន កើតប្រាកដហើយ អំពីធម៌ទាំងឡាយណា សេចក្ដីដឹងក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា ធម្មប្បដិសម្ភិទា ។*

*សេចក្ដីដឹងក្នុងជរា និងមរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងការកើតឡើងនៃជរា និងមរណៈ ឈ្មោះថា ធម្ម-ប្បដិសម្ភិទា សេចក្ដីដឹងក្នុងការរលត់នៃជរា និងមរណៈ ឈ្មោះ*

ថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរា និងមរណៈ ឈ្មោះថា ធម្មប្បដិសម្ភិទា ។

សេចក្តីដឹងក្នុងជាតិ ។បេ។ សេចក្តីដឹងក្នុងភព ។បេ។ សេចក្តីដឹងក្នុងឧបាទាន ។បេ។ សេចក្តីដឹងក្នុងតណ្ហា ។បេ។ សេចក្តីដឹងក្នុងវេទនា ។បេ។ សេចក្តីដឹងក្នុងផស្សៈ ។បេ។ សេចក្តីដឹងក្នុងសឡាយតនៈ ។បេ។ សេចក្តីដឹងក្នុងនាមរូប ។បេ។ សេចក្តីដឹងក្នុងវិញ្ញាណ ។បេ។ សេចក្តីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា ។

សេចក្តីដឹងក្នុងជាតិ ។បេ។ សេចក្តីដឹងក្នុងភព ។បេ។ សេចក្តីដឹងក្នុងឧបាទាន ។បេ។ សេចក្តីដឹងក្នុងតណ្ហា ។បេ។ សេចក្តីដឹងក្នុងវេទនា ។បេ។ សេចក្តីដឹងក្នុងផស្សៈ ។បេ។ សេចក្តីដឹងក្នុងសឡាយតនៈ ។បេ។ សេចក្តីដឹងក្នុងនាមរូប ។បេ។ សេចក្តីដឹងក្នុងវិញ្ញាណ ។បេ។ សេចក្តីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់

ទីរលត់នៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា ។

ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយ នេះឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ដូច្នេះ ។

បទថា **តត្រ ធម្មនិរុត្តាភិលាបេ ញាណំ**[១] សេចក្តីថា បញ្ញាបែកធ្លាយក្នុងពាក្យនិយាយ ពាក្យពោល ពាក្យដែលបន្លឺឡើងដល់សភាវនិរុត្តិ ( ភាសា ) ដែលជាវោហារដែលមិនខុស ទាំងក្នុងអត្ថ និងក្នុងធម៌នោះ ក្នុងវាចាដែលជាសភាវនិរុត្តិ របស់ព្រះអរិយបុគ្គលអ្នកធ្វើសភាវនិរុត្តិសព្ទ ដែលគេនិយាយហើយ ពោលហើយ បន្លឺចេញហើយ ឲ្យជាអារម្មណ៍ ហើយពិចារណាក្នុងមូលភាសា ( មគធភាសា ) របស់សត្វទាំងឡាយ ដែលប្រើក្នុងដែនមគធៈជាសភាវនិរុត្តិ ដែលសន្មតថាជាធម្មនិរុត្តិយ៉ាងនេះថា នេះជាសភាវនិរុត្តិ នេះមិនមែនសភាវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទា ។

ដោយប្រការយ៉ាងនេះ និរុត្តិប្បដិសម្ភិទានេះ ឈ្មោះថា មានសំឡេងជា

---

១-បទនេះមានក្នុងបិដកលេខ ៨២ ឃ្លាប ១២ ដល់ ១៨ ឯណោះ ។

អារម្មណ៍ មិនមានបញ្ញត្តិជាអារម្មណ៍ឡើយ ព្រោះហេតុអ្វី ព្រោះព្រះអរិយ-បុគ្គលបានឮសំឡេងហើយ រមែងដឹងថា នេះជាសភាវនិរុត្តិ នេះមិនមែនសភាវ-និរុត្តិ ។ ពិតហើយ ព្រះអរិយបុគ្គលអ្នកសម្រេចនូវនិរុត្តិប្បដិសម្ភិទា កាលគេនិយាយថា **ផស្សោ** ក៏រមែងដឹងថា នេះជាសភាវនិរុត្តិ កាលបើគេនិយាយថា **ផស្សា** ឬ **ផស្សំ** ក៏រមែងដឹងថា នេះមិនមែនសភាវនិរុត្តិ សូម្បីក្នុងពាក្យថា **វេទនា** ជាដើមក៏ន័យនេះដូចគ្នា ។

សួរថា ក៏ព្រះអរិយបុគ្គលអ្នកសម្រេចនូវនិរុត្តិប្បដិសម្ភិទានេះ នឹងដឹង ឬមិនដឹងពាក្យដទៃ គឺសំឡេងនៃព្យញ្ជនៈដែលពោលដល់នាម អាខ្យាត ឧបសគ្គ និងនិបាត ។

ឆ្លើយថា ព្រះអរិយបុគ្គលអ្នកសម្រេចនូវនិរុត្តិប្បដិសម្ភិទានោះ កាលបើបានឮសំឡេងហើយ ក៏ដឹងថា នេះជាសភាវនិរុត្តិ នេះមិនមែនសភាវនិរុត្តិ ដោយហេតុសម្គាល់ឯណា ក៏នឹងដឹងពាក្យនោះ ដោយហេតុសម្គាល់នោះ តែក្នុងសេចក្តីនេះ មានអ្នកពោលបដិសេធថា នេះមិនមែនជាកិច្ចរបស់បដិសម្ភិទា ហើយពោលថា ធម្មតាភាសាសត្វទាំងឡាយ រមែងសិក្សាបាន ហើយលើកឧទាហរណ៍នេះមកសាធកៈថា

ពិតហើយ មាតា និងបិតា យកកុមារតូចក្នុងកាលនៅជាទារក ឲ្យដេកនៅលើគ្រែ ឬតាំង ហើយនិយាយភាសានោះៗ ធ្វើកិច្ចនោះៗ ទារកកំណត់ភាសានោះៗ របស់មាតា និងបិតាទាំងនោះថា ពាក្យនេះលោកអ្នកនេះនិយាយ ពាក្យនេះលោកអ្នកនេះនិយាយ កាលពេលវេលាកន្លងទៅ ក៏រមែងដឹងភាសាទាំង

អស់បាន ។ មាតាជាអ្នកស្រុកទមិឡ បិតាជាអ្នកស្រុកអន្ធកៈ ទារករបស់មាតាបិតាទាំងនោះ បើបានឮពាក្យនិយាយរបស់មាតាមុនក៏នឹងនិយាយភាសាទមិឡ បើបានឮពាក្យនិយាយរបស់បិតាមុន ក៏នឹងនិយាយភាសាអន្ធកៈ ។ តែបើមិនបានឮពាក្យនិយាយរបស់ជនទាំង ២ គឺមាតា និងបិតានោះ ក៏នឹងនិយាយភាសាមគធៈ ។

សូម្បីទារកណាកើតក្នុងព្រៃធំ មិនមានផ្ទះ អ្នកដទៃដែលឈ្មោះថា នឹងនិយាយជាមួយក៏មិនមានក្នុងទីនោះ ទារកនោះ កាលបើនឹងផ្ដើមនិយាយតាមធម្មតារបស់ខ្លួន ក៏នឹងនិយាយភាសាមគធៈនោះឯង ។ ភាសាមគធៈមានច្រើនក្នុងទីទាំងពួង គឺក្នុងនរក ក្នុងកំណើតតិរច្ឆាន ក្នុងបិត្តិវិស័យ ក្នុងមនុស្សលោក ក្នុងទេវលោក ។ បណ្ដាភាសារបស់សត្វក្នុងភូមិនោះៗ ភាសាដ៏សេស ដូចជាឱដ្ឋភាសា កិរាតភាសា អន្ធកភាសា យោនកភាសា និងទមិឡភាសាជាដើម រមែងប្រែប្រួលបាន មគធភាសាតែមួយប៉ុណ្ណោះ រាប់ថា ជាព្រហ្មវោហារ និងអរិយវោហារតាមសេចក្ដីពិត រមែងមិនប្រែប្រួល ។

សូម្បីព្រះសម្មាសម្ពុទ្ធ កាលទ្រង់លើកព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកឡើងជាបែបផែន ក៏ទ្រង់លើកឡើងក្នុងមគធភាសាប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ក៏ព្រោះដើម្បីនឹងនាំអត្ថមកឲ្យដឹងបានដោយងាយ ។ ពិតហើយ ព្រះពុទ្ធវចនៈដែលលើកឡើងជាបែបផែនដោយមគធភាសា មកដល់គន្លងនៃសោតបសាទរបស់ព្រះអរិយបុគ្គល ដែលសម្រេចបដិសម្ភិទានោះជាការយឺតយូរ ។ តែកាលពុទ្ធវចនៈប៉ះខ្ទប់សោតបសាទហើយប៉ុណ្ណោះ អត្ថក៏ប្រាកដរាប់រយរាប់ពាន់

ន័យ ។ ក៏ព្រះពុទ្ធវចនៈដែលលើកឡើងសម្តែង ទៅតាមបែបផែនភាសាដទៃ ក៏រមែងត្រូវរៀនយកបែបផែនលម្អិតសេចក្តីហើយលម្អិតសេចក្តីទៀត ។ តាមធម្មតាការរៀនព្រះពុទ្ធវចនៈសូម្បីច្រើន ហើយសម្រេចបដិសម្ភិទា រមែងមិនមានដល់បុថុជ្ជន តែព្រះអរិយសាវកដែលឈ្មោះថា មិនសម្រេចបដិសម្ភិទានោះ រមែងមិនមានឡើយ ។

បទថា **ញាណេសុ ញាណំ** សេចក្តីថា បញ្ញាបែកធ្លាយក្នុងញាណនោះរបស់ព្រះអរិយបុគ្គលអ្នកធ្វើញាណ ដែលមានក្នុងទីទាំងពួង ឲ្យជាអារម្មណ៍ហើយពិចារណា ឬថា បញ្ញាបែកធ្លាយដែលដល់នូវការធំទូលាយក្នុងញាណទាំង ៣ នោះ តាមដែលពោលហើយ ដោយអំណាចនៃអារម្មណ៍ និងកិច្ចជាដើម ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

ក៏បណ្ឌិតគប្បីជ្រាបបដិសម្ភិទាទាំង ៤ នេះថា រមែងដល់នូវការបែកធ្លាយក្នុងឋានៈ ២ រមែងផ្សផង់ដោយហេតុ ៥ ។ រមែងដល់នូវការបែកធ្លាយក្នុងឋានៈ ២ ពួកណា គឺក្នុងសេក្ខភូមិ ១ អសេក្ខភូមិ ១ ។

ក្នុង ២ ភូមិនោះ បដិសម្ភិទារបស់មហាថេរៈ ៨០ អង្គ មានព្រះថេរៈអ្នកមានឈ្មោះយ៉ាងនេះ គឺព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរជាដើម ដល់នូវការបែកធ្លាយក្នុងអសេក្ខភូមិ បដិសម្ភិទារបស់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះអរិយបុគ្គលដែលមាននាមយ៉ាងនេះ គឺព្រះអានន្ទត្ថេរ ចិត្តគហបតី ធម្មិក-ឧបាសក ឧបាលិគហបតី ខុជ្ជុត្តរាឧបាសិកាជាដើម ដល់នូវការបែកធ្លាយក្នុង

សេក្ខភូមិ បដិសម្ភិទា រមែងដល់នូវការបែកធ្លាយក្នុងភូមិ ២ នេះ ដោយប្រការដូច្នេះ ។

បដិសម្ភិទា រមែងផូរផង់ដោយហេតុ ៥ ប្រការដូចម្តេច រមែងផូរផង់ដោយហេតុ ៥ ប្រការ គឺដោយអធិគម ដោយបរិយត្តិ ដោយសវនៈ ដោយបរិបុច្ឆា ដោយបុព្វយោគ ។

ក្នុងហេតុទាំង ៥ ប្រការនោះ ការសម្រេចព្រះអរហត្តឈ្មោះថា **អធិគម** ។ បដិសម្ភិទារបស់អ្នកសម្រេចព្រះអរហត្ត រមែងផូរផង់ ។

ព្រះពុទ្ធវចនៈ ឈ្មោះថា **បរិយត្តិ** ។ បដិសម្ភិទារបស់អ្នករៀនព្រះពុទ្ធវចនៈនោះ រមែងផូរផង់ ។

ការស្តាប់ព្រះសទ្ធម្ម ឈ្មោះថា **សវនៈ** ។ បដិសម្ភិទារបស់អ្នកយកចិត្តទុកដាក់ស្តាប់ធម៌ដោយគោរព រមែងផូរផង់ ។

កថាជាគ្រឿងវិនិច្ឆ័យ គណ្ឋិបទ និងអត្ថបទក្នុងព្រះបាលី និងអដ្ឋកថាជាដើម ឈ្មោះថា **បរិបុច្ឆា** ។ បដិសម្ភិទារបស់អ្នកសាកសួរអត្ថក្នុងព្រះពុទ្ធវចនៈទាំងឡាយ មានព្រះបាលីដែលខ្លួនរៀនហើយជាដើម រមែងផូរផង់ ។

ការបំពេញនូវសេចក្តីព្យាយាមក្នុងសាសនានៃព្រះពុទ្ធអង្គមុនៗ និងការបំពេញវិបស្សនាកម្មដ្ឋានរឿយៗ រហូតដល់ក្បែរអនុលោមញ្ញាណ និងគោត្រភូញាណ ដោយភាពជាអ្នកបំពេញគតបច្ចាគតិកវត្ត ឈ្មោះថា **បុព្វយោគ** ។ បដិសម្ភិទារបស់អ្នកបំពេញព្យាយាមមកហើយ ក្នុងកាលមុន រមែងផូរផង់ ។ បដិសម្ភិទា រមែងផូរផង់ដោយហេតុ ៥ ប្រការនេះ ដោយប្រការដូច្នេះ ។

ក្នុងហេតុទាំង ៥ នេះ ហេតុ ៣ នេះ គឺបរិយត្តិ ១ សវន ១ បរិបុច្ឆា ១ ជាហេតុមានកម្លាំងដើម្បីការបែកធ្លាយ ។ បុព្វយោគជាបច្ច័យមានកម្លាំងដើម្បីសម្រេចអរហត្ត ។

សួរថា បុព្វយោគ ជាបច្ច័យមានកម្លាំងដើម្បីការបែកធ្លាយដែរឬទេ ឆ្លើយថា មាន តែមិនដូចហេតុទាំង ៣ នោះ ព្រោះបរិយត្តិ សវន និងបរិបុច្ឆា ទោះមានក្នុងកាលមុនក្តី មិនមានក្តី តែវៀរការពិចារណាសង្ខារធម៌ ដោយការបំពេញការព្យាយាមក្នុងកាលមុន និងក្នុងបច្ចុប្បន្នហើយ ឈ្មោះថា **បដិសម្ភិទា** ក៏មានមិនបានទាំង ២ នេះ ( ហេតុទាំង ៣ និងបុព្វយោគ ) រួមគ្នាជួយឧបត្ថម្ភបដិសម្ភិទាធ្វើឲ្យផូរផង់បាន ។ អាចារ្យពួកដទៃបានពោលថា

បុព្វយោគ ១ ពាហុសច្ច ១ ទេសភាសា ១ អាគម ១ បរិបុច្ឆា
១ អធិគម ១ គរុសន្និស្សយ ១ មិត្តសម្បត្តិ ១ ។ រួម ៨ ប្រការ
នេះ សុទ្ធតែជាបច្ច័យដល់បដិសម្ភិទា ដូច្នេះ ។

បណ្តាធម៌ទាំង ៨ ប្រការនោះ បុព្វយោគ មានន័យដូចបានពោលហើយនោះឯង ។

ការឈ្លាសក្នុងអត្ថនោះៗ និងក្នុងសិប្បៈទាំងឡាយឈ្មោះថា **ពាហុសច្ច** ។

ការឈ្លាសក្នុងភាសា ១០១ ភាសា ការឈ្លាសក្នុងភាសាមគធៈ ដោយវិសេស ឈ្មោះថា **ទេសភាសា** ។

ការរៀនព្រះពុទ្ធវចនៈដោយហោចសូម្បីត្រឹមតែឱបម្មវគ្គ ឈ្មោះថា **អាគម** ។

ការវិនិច្ឆ័យសាកសួរអត្ថ សូម្បីក្នុងគាថា ១ ឈ្មោះថា **បរិបុច្ឆា** ។

ភាពជាព្រះសោតាបន្នក្តី ភាពជាព្រះសកទាគាមីក្តី ភាពជាព្រះអនាគាមីក្តី ភាពជាព្រះអរហន្តក្តី ឈ្មោះថា **អធិគម** ។

ការនៅក្នុងសម្នាក់គ្រូ ដែលច្រើនដោយសុតៈ និងបដិភាណ ឈ្មោះថា **គរុសន្និស្សយ** ។

ការបានមិត្តមានសភាពបែបនោះឯង ឈ្មោះថា **មិត្តសម្បត្តិ** ។

បណ្តាធម៌ទាំង ៨ ប្រការនោះ ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធទាំងឡាយ អាស្រ័យបុព្វយោគ និងអធិគមហើយ សម្រេចបដិសម្ភិទា ចំណែកព្រះសាវកទាំងឡាយ អាស្រ័យហេតុទាំងអស់នេះ ទើបសម្រេចបដិសម្ភិទា ។

ក្នុងការសម្រេចបដិសម្ភិទា មិនមានការបំពេញនូវសេចក្តីព្យាយាម ក្នុងកម្មដ្ឋានភាវនាដោយចំពោះទៀត សម្រាប់ព្រះសេក្ខបុគ្គល ការសម្រេចបដិ-សម្ភិទា មានផល និងវិមោក្ខរបស់ព្រះសេក្ខៈជាទីបំផុត សម្រាប់ព្រះអសេក្ខ-បុគ្គល ការសម្រេចបដិសម្ភិទា មានផល និងវិមោក្ខរបស់ព្រះអសេក្ខៈជាទីបំផុត ។

អធិប្បាយថា បដិសម្ភិទាទាំងឡាយ រមែងសម្រេចដល់ព្រះអរិយបុគ្គលទាំងឡាយដោយអរិយផលទាំងឡាយនោះឯង ដូចជាទសពលញ្ញាណសម្រេចដល់ព្រះតថាគតទាំងឡាយដូច្នោះ ។ ផ្លូវនៃបដិសម្ភិទាទាំង ៤ នេះ ព្រោះហេតុនោះ ទើបឈ្មោះថា **បដិសម្ភិទាមគ្គ** បករណ៍ គឺបដិសម្ភិទាមគ្គ ឈ្មោះថា **បដិសម្ភិទាមគ្គបករណ៍** ឈ្មោះថា **បករណ៍** ព្រោះអត្ថថា ជាគម្ពីរមានអត្ថដ៏ជ្រាលជ្រៅចែកដោយប្រភេទផ្សេងៗ ដែលលោករចនា ពោលដោយប្រការផ្សេងៗ ។

បដិសម្ភិទាមគ្គប្បករណ៍នេះ សម្បូរដោយអត្ថ សម្បូរដោយព្យញ្ជនៈជ្រាលជ្រៅ មានអត្ថជ្រាលជ្រៅ ប្រកាសលោកុត្តរធម៌ ប្រកបដោយសុញ្ញតា ឲ្យសម្រេចផលវិសេសក្នុងកិច្ចបដិបត្តិ ហាមអកុសលដែលជាបដិបក្ខ ជាប្រភពកើតនៃរតនៈ គឺញាណដ៏ប្រសើរដល់ព្រះយោគាវចរ ជាហេតុដ៏វិសេសឲ្យធម្មកថារបស់ព្រះធម្មកថិកទាំងឡាយ ផូរផង់ ជាគ្រឿងនាំចេញចាកទុក្ខរបស់អ្នកខ្លាចភ័យក្នុងសង្សារវដ្ត ដែលព្រះសារីបុត្តត្ថេរជាធម្មសេនាបតីរបស់ព្រះធម្មរាជា ដែលប្រាថ្នាភាពរុងរឿង មិនដាច់ខ្សែរហូត ៥០០០ ព្រះវស្សា នៃមហាប្រទីប គឺព្រះសទ្ធម្មដែលព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់មានពន្លឺដែលជាប្រទីបធំ គឺសព្វញ្ញុតញ្ញាណដែលមិនមានអ្វីរាំងក្នុងទីទាំងពួង ទ្រង់មានព្រះហឫទ័យស្រឡាញ់ ដោយមហាករុណាដែលផ្សាយទៅក្នុងពពួកជន ទ្រង់ឲ្យរុងរឿងហើយ ដើម្បីកម្ចាត់ងងឹត គឺកិលេស ដែលនៅក្នុងហទយៈ របស់វេនេយ្យជន ព្រោះស្រោចហើយ ដោយសេចក្តីស្រឡាញ់ក្នុងការដែលនឹងពង្រីកព្រះពុទ្ធបំណងនោះ ហើយពោលតាមព្រះតម្រិះរបស់ព្រះសាស្តាដែលនឹងអនុគ្រោះសត្វលោក ដើម្បីញុំាងការស្រោកស្រាន្តឲ្យកើត ព្រោះឃើញឧបាយក្នុងការចេញចាកទុក្ខនោះ ដើម្បីទម្លាយអកុសលធម៌ ដែលជាបដិបក្ខចំពោះធម៌ជាគ្រឿងនាំចេញចាកទុក្ខនោះ និងដើម្បីឲ្យកើតសេចក្តីត្រេកអរក្នុងហទយៈរបស់កល្យាណជន ដោយការបើកផ្លូវអត្ថនៃបទព្រះសូត្រមិនមែនតិច ដែលមានអត្ថដ៏ជ្រាលជ្រៅ ព្រះអានន្ទត្ថេរ ស្តាប់បដិសម្ភិទាមគ្គប្បករណ៍នោះហើយលើកឡើងសង្គ្រោះ ក្នុងកាលបឋមមហាសង្គីតិ តាមដែលបានស្តាប់មកហើយ

នោះឯង ។

ក្នុងបិដកទាំង ៣ គឺព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក បដិសម្ភិទាមគ្គប្បករណ៍នេះ រាប់ចូលក្នុងព្រះសុត្តន្តបិដក ។

ក្នុងនិកាយធំទាំង ៥ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរ-និកាយ និងខុទ្ទកនិកាយ បដិសម្ភិទាមគ្គប្បករណ៍នេះ រាប់ចូលក្នុងខុទ្ទកនិកាយ ។

ក្នុងអង្គនៃសត្ថុសាសនៈទាំង ៩ គឺសុត្ត គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភុតធម្ម វេទល្ល បដិសម្ភិទាមគ្គបករណ៍នេះ រាប់សង្គ្រោះចូលក្នុងអង្គ ២ គឺគេយ្យៈ និងវេយ្យាករណៈ តាមដែលចូលបាន ។

បណ្តាព្រះធម្មក្ខន្ធ ៨៤០០០ ព្រះធម្មក្ខន្ធដែលព្រះអានន្ទត្ថេរជាធម្មភណ្ឌា-គារិក ដែលព្រះមានព្រះភាគទ្រង់លើកឡើងកាន់ឯតទគ្គក្នុង ៥ តំណែង ប្តេជ្ញា ( ក្នុងថេរគាថា ) យ៉ាងនេះថា

> សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ ( ក្នុងហឫទ័យ )
> របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះមាន ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ
> ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ម៉ឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២
> ពាន់ធម្មក្ខន្ធ ដូច្នេះ ។

បដិសម្ភិទាមគ្គប្បករណ៍នេះ រាប់បញ្ចូលក្នុងព្រះធម្មក្ខន្ធ ច្រើនជាងមួយរយ ក្នុងធម្មក្ខន្ធ ២០០០ ព្រះធម្មក្ខន្ធ ដែលរៀនពីភិក្ខុ ។ បដិសម្ភិទាមគ្គប្ប-ករណ៍ មាន ៣ វគ្គ គឺមហាវគ្គ មជ្ឈិមវគ្គ និងចូឡវគ្គ ។

ក្នុងវគ្គនីមួយៗ មាន ១០ កថា រួមជា ៣០ កថា មានញាណកថាជាខាង

ដើម មានមាតិកាកថាជាខាងចុង ។ ខ្ញុំនឹងពណ៌នាអត្ថនៃបទមិនច្បាស់ដែលៗ តាមលំដាប់នៃបដិសម្ភិទាមគ្គប្បករណ៍នេះ ដែលកំណត់ច្រើនចំណែកយ៉ាង នេះ ។ បករណ៍នេះ ទាំងអ្នកសូធ្យ ទាំងអ្នកសម្តែងដោយបាឋៈ ដោយអត្ថ ក៏គប្បីសូធ្យ គប្បីសម្តែងដោយគោរព សូម្បីរៀនក៏គប្បីរៀន គប្បីចាំទុកដោយ គោរព ។ សេចក្តីនោះ ព្រោះហេតុអ្វី គប្បីសូធ្យ គប្បីសម្តែងដោយគោរព ព្រោះបករណ៍នេះ ជាបករណ៍មានអត្ថដ៏ជ្រាលជ្រៅ គប្បីរៀន គប្បីចាំដោយ គោរព ដើម្បីប្រយោជន៍ដល់សត្វលោក ដើម្បីសេចក្តីតាំងមាំនៅក្នុងលោក ។

ប្រសិនបើមានពាក្យសួរថា ក្នុងកថា ៣០ ក្នុងបករណ៍នោះ ព្រោះហេតុ អ្វី ទើបលោកពោលញាណកថាទុកខាងដើម ឆ្លើយថា ព្រោះញាណជាខាង ដើមនៃកិច្ចបដិបត្តិ ព្រោះជាហេតុជម្រះមន្ទិលនៃកិច្ចបដិបត្តិ ។

សមពិតដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្ត-និកាយ មហាវារវគ្គ ) ថា

> ម្នាលភិក្ខុ បើដូច្នោះ ចូរអ្នកជម្រះក្នុងកុសលធម៌ទាំងឡាយ ជាខាងដើមបន្តិសសិនចុះ ។ ចុះអ្វីជាខាងដើមនៃកុសលធម៌ ទាំងឡាយ ។ គឺសីលដ៏បរិសុទ្ធ ១ ទិដ្ឋិត្រង់ ១ ដូច្នេះ ។

ក៏ញាណ ពោល គឺសម្មាទិដ្ឋិ ហៅថា ទិដ្ឋិត្រង់ ព្រោះហេតុនោះ ទើប លោកពោលញាណកថាជាខាងដើម ។

សូម្បីពាក្យដទៃ ព្រះមានព្រះភាគ ក៏បានត្រាស់ទៀត ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា

ម្នាលភិក្ខុទាំងឡាយ បណ្តាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតដល់មុន ( ជាប្រធាន ) ។ ម្នាលភិក្ខុទាំងឡាយ ឯសម្មាទិដ្ឋិ ជាធម្មជាតដល់មុន តើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវមិច្ឆាទិដ្ឋិថាជាមិច្ឆាទិដ្ឋិ ដឹងច្បាស់នូវសម្មាទិដ្ឋិថាជាសម្មាទិដ្ឋិ ។ សេចក្តីដឹងនោះ ជាសម្មាទិដ្ឋិរបស់បុគ្គលនោះ ។ បុគ្គលដឹងច្បាស់នូវមិច្ឆាសង្កប្បថាជាមិច្ឆាសង្កប្ប ដឹងច្បាស់នូវសម្មាសង្កប្បថាជាសម្មាសង្កប្ប ។ បុគ្គលដឹងច្បាស់នូវមិច្ឆាវាចា ថាជាមិច្ឆា-វាចា ដឹងច្បាស់នូវសម្មាវាចា ថាជាសម្មាវាចា ។ បុគ្គលដឹងច្បាស់នូវមិច្ឆាកម្មន្តៈថាជាមិច្ឆាកម្មន្តៈ ដឹងច្បាស់នូវសម្មាកម្មន្តៈថាជាសម្មាកម្មន្តៈ ។ បុគ្គលដឹងច្បាស់នូវមិច្ឆាអាជីវៈ ថាជាមិច្ឆាអាជីវៈ ដឹងច្បាស់នូវសម្មាអាជីវៈ ថាជាសម្មាអាជីវៈ ។ បុគ្គលដឹងច្បាស់នូវមិច្ឆាវាយាមៈថាជាមិច្ឆាវាយាមៈ ដឹងច្បាស់នូវសម្មាវាយាមៈ ថាជាសម្មាវាយាមៈ ។ បុគ្គលដឹងច្បាស់នូវមិច្ឆាសតិថាជាមិច្ឆាសតិ ដឹងច្បាស់នូវសម្មាសតិ ថាជាសម្មា-សតិ ។ បុគ្គលដឹងច្បាស់នូវមិច្ឆាសមាធិថាជាមិច្ឆាសមាធិ ដឹងច្បាស់នូវសម្មាសមាធិថាជាសម្មាសមាធិ ។ សេចក្តីដឹងច្បាស់នោះ ជាសម្មាទិដ្ឋិរបស់បុគ្គលនោះ[១] ។

---

១- ក្នុងទីនេះ ព្រះអដ្ឋកថា លោកលើកមកដោយសង្ខេប លោកអ្នកប្រាថ្នាសេចក្តីពិស្តារ សូមមើលក្នុងបិដកលេខ ២៦ ឃ្នាប ២៥៤ ឯណោះចុះ ។

លោកពោលញាណកថាខាងដើម ក៏ដើម្បីឲ្យញាណ ពោលគឺសម្មាទិដ្ឋិសម្រេចមុន ដោយគិតថា កាលសម្មាទិដ្ឋិជាប្រធានសម្រេចហើយ ព្រះយោគាវចរនឹងស្គាល់មិច្ឆាទិដ្ឋិទាំងឡាយ ថាជាមិច្ឆាទិដ្ឋិបាន ។

ម្យ៉ាងទៀត លោកពោលញាណកថាខាងដើម ព្រោះលោកពោលដល់ញាណប៉ុណ្ណោះ ដោយវៀរទិដ្ឋិដែលជាចំណែកអតីត និងទិដ្ឋិដែលជាចំណែកអនាគត តាមព្រះបាលី ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា

ប៉ុន្តែណ្ហើយចុះ ឧទាយិ ទីបំផុតខាងដើមលើកទុក ទីបំផុតខាងចុងក៏លើកទុកចុះ តថាគតនឹងសម្ដែងធម៌ដល់អ្នក កាលបើទីបំផុតខាងដើមនេះមាន ទីបំផុតខាងចុងនេះក៏មាន ទីបំផុតខាងចុងនេះកើតឡើងបាន ព្រោះទីបំផុតខាងដើមនេះកើតឡើង កាលបើទីបំផុតខាងដើមនេះមិនមាន ទីបំផុតខាងចុងនេះក៏មិនមាន ទីបំផុតខាងចុងនេះរលត់ទៅ ព្រោះទីបំផុតខាងដើមនេះរលត់ទៅ ដូច្នេះ ។

ម្យ៉ាងទៀត លោកពោលញាណកថាជាលំដាប់ដំបូង ព្រោះសម្ដែងដល់អរិយមគ្គមានអង្គ ៨ និងព្រោះញាណ ពោលគឺសម្មាទិដ្ឋិជាប្រធានក្នុងមគ្គមានអង្គ ៨ ដោយវៀរវាទះរបស់ពួកសមណព្រាហ្មណ៍បុថុជ្ជន ដែលជាចំណែកបរប្បវាទទាំងឡាយ តាមព្រះបាលី ( ក្នុងទីឃនិកាយ មហាវគ្គ ) ថា

ម្នាលសុភទ្ទ ណ្ហើយចុះ ពាក្យដែលអ្នកនិយាយថា ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹង ដូចជាពាក្យប្ដេជ្ញារបស់ខ្លួនមែន ឬ

សុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ ដូច្នេះនេះ ចូរលើកទុកសិនចុះ ម្នាលសុភទ្ទ តថាគតនឹងសម្តែងធម៌ដល់អ្នក ចូរអ្នកស្តាប់ធម៌នោះ ចូរតាំងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ដូច្នេះ ។

ម្យ៉ាងទៀត លោកពោលញាណកថាជាលំដាប់ដំបូង ធ្វើសុតមយញ្ញាណជាខាងដើមតាមលំដាប់ ដោយអនុលោមសុត្តន្តបទ មិនមែនតិច ( ទីឃនិកាយ បាដិកវគ្គ ) ថា

អង្គនៃសោតាបត្តិមគ្គ ៤ យ៉ាង គឺការសេពគប់នូវសប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ១ សេចក្តីប្រតិបត្តិធម៌សមគួរដល់លោកុត្តរធម៌ ១ ដូច្នេះ ។

និងព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា

កុលបុត្តក្នុងសាសនានេះ មានសទ្ធា ទើបចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត លុះចូលទៅអង្គុយជិតហើយ ទើបផ្ទៀងនូវសោតប្បសាទ លុះផ្ទៀងនូវសោតប្បសាទហើយ ទើបស្តាប់ធម៌ លុះស្តាប់ធម៌ហើយ ទើបចងចាំធម៌ ( នោះ ) កាលបើចងចាំធម៌ ( នោះ ) ហើយ ទើបពិចារណារកសេចក្តី លុះពិចារណារកសេចក្តីនៃធម៌នោះហើយ ធម៌ទាំងឡាយ តែងគួរដល់កិរិយាសែលកមើល កាលបើមាន

ការលៃលកមើលហើយ ឆន្ទៈក៏កើតឡើង បុគ្គលនោះ លុះមានឆន្ទៈកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ ( កាន់ព្រះនិព្វាន ) ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈ ដោយនាមកាយ ទាំងបានចាក់ធ្លុះ ឃើញច្បាស់នូវបរមសច្ចៈនោះ ដោយប្រាជ្ញា ដូច្នេះ ។

និងព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

ម្នាលព្រាហ្មណ៍ ឧបមេយ្យដូចជាព្រះតថាគត កើតឡើងក្នុងលោកនេះ ។បេ។ ព្រះតថាគតនោះ សម្តែងធម៌ មានលម្អបទដើម ដូច្នេះ ។

ញាណកថានេះ បែងចែកជា ២ គឺឧទ្ទេស ១ និទ្ទេស ១ ។ ក្នុងឧទ្ទេសលោកសម្តែងញាណ ៧៣ ដោយអំណាចនៃមាតិកា ដោយន័យថា **សោតាវធានេ បញ្ញា សុតមយេ ញាណំ** ដែលប្រែថា បញ្ញា ( ការដឹងច្បាស់ ) ក្នុងការប្រុងត្រចៀក ឈ្មោះថា **សុតមយញ្ញាណ** ដូច្នេះជាដើម ។

ក្នុងនិទ្ទេស លោកសម្តែងញាណទាំង ៧៣ នោះឯងយ៉ាងពិស្តារ ដោយន័យថា **កថំ សោតាវធានេ បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា អភិញ្ញេយ្យាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ** ដែលប្រែថា បញ្ញាក្នុងការប្រុងត្រចៀក ឈ្មោះថា **សុតមយញ្ញាណ** តើដូចម្តេច ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរដឹងច្បាស់ បញ្ញាជាគ្រឿង

ដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា **សុតមយញ្ញាណ** ដូច្នេះជាដើម ។

## គន្ថារម្ភកថា ចប់

# មហាវគ្គ

## ញាណកថា មាតិកុទ្ទេស

### ១. អដ្ឋកថា

### សុតមយញាណុទ្ទេស

ក្នុងឧទ្ទេស និងនិទ្ទេសនោះ នឹងពោលក្នុងឧទ្ទេសមុន **សោត** សព្ទ ក្នុងពាក្យនេះថា **សោតាវធានេ បញ្ញា សុតមយេ ញាណំ** មានប្រភេទនៃអត្ថច្រើនយ៉ាង ។ ពិតហើយ **សោត** សព្ទនោះ ប្រាកដក្នុងអត្ថថា មំសសោត សោតវិញ្ញាណ ញាណសោត តណ្ហាសោតជាដើម ផ្លូវនៃទឹក អរិយមគ្គ និងចិត្តសន្តតិ ។

ក៏ **សោត** សព្ទនេះ ប្រាកដក្នុងអត្ថថា **មំសសោត** ដូចក្នុងប្រយោគជាដើមថា **សោតាយតនំ សោតធាតុ សោតិន្ទ្រិយំ** សោតាយតនៈ សោតធាតុ សោតិន្ទ្រិយ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សោតវិញ្ញាណ** ដូចក្នុងប្រយោគជាដើមថា **សោតេន សទ្ទំ សុត្វា** ឮសំឡេងដោយត្រចៀក ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **ញាណសោត** ដូចក្នុងប្រយោគជាដើមថា **ទិព្វាយ សោតធាតុយា** ដោយសោតធាតុដូចជាទិព្វ ដូច្នេះ ។

ប្រាកដក្នុងធម៌ទាំង ៥ មានតណ្ហាជាដើម ដូចក្នុងប្រយោគជាដើមថា **យានិ សោតានិ លោកស្មិន្តិ យានិ ឯតានិ សោតានិ មយា កិត្តិតានិ បកិត្តិតានិ អាចិក្ខិតានិ ទេសិតានិ បញ្ញបិតានិ បដ្ឋបិតានិ វិវរិតានិ វិភជិតានិ**

**ឧត្តានីកតានិ បកាសិតានិ ។ សេយ្យថិទំ តណ្ហាសោតោ ទិដ្ឋិសោតោ កិលេសសោតោ ទុច្ចរិតសោតោ អវិជ្ជាសោតោ** ពាក្យថា ខ្សែទាំងឡាយណាក្នុងលោក សេចក្តីថា ខ្សែទាំងឡាយណា ដែលតថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក បែក ធ្វើឲ្យងាយ ប្រកាសហើយថា ខ្សែគឺតណ្ហា ខ្សែ គឺទិដ្ឋិ ខ្សែ គឺកិលេស ខ្សែ គឺទុច្ចរិត ខ្សែ គឺអវិជ្ជា ដូច្នេះ ។

ប្រាកដក្នុងអត្ថថា ផ្លូវនៃទឹក ដូចក្នុងប្រយោគជាដើមថា **អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា សោតេន វុយ្ហមានំ** ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹកក្នុងស្ទឹងទន្លេគង្គា ដូច្នេះ ។

ប្រាកដក្នុងអត្ថថា អរិយមគ្គ ដូចក្នុងប្រយោគជាដើមថា **អរិយស្សេតំ អាវុសោ អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ យទិទំ សោតោ** អាវុសោ ពាក្យថា **សោត** ជាឈ្មោះរបស់អរិយមគ្គមានអង្គ ៨ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **ចិត្តសន្តតិ** គឺការបន្តនៃចិត្ត ដូចក្នុងប្រយោគជាដើមថា **បុរិសស្ស ច វិញ្ញាណសោតំ បជានាតិ ឧភយតោ អព្វោច្ឆិន្នំ ឥធ លោកេ បតិដ្ឋិតញ្ច បរលោកេ បតិដ្ឋិតញ្ច** ទាំងដឹងច្បាស់នូវវិញ្ញាណសោតៈរបស់បុរសដែលមិនដាច់ចេញជាពីរចំណែក គឺមិនតាំងនៅក្នុងលោកនេះ ១ ផ្នែក មិនតាំងនៅក្នុងលោកខាងមុខ ១ ផ្នែក ដូច្នេះ ។

**សោត** សព្ទ ក្នុងទីនេះ សំដៅយក **មំសសោត** ។

ឈ្មោះថា **សោតាវធានេ** ព្រោះអត្ថថា ចាំទុក កំណត់ទុក តាំងទុក ដោយ

សោតៈនោះ ដែលជាហេតុ ឬជាគ្រឿងធ្វើ ។ ឈ្មោះថា **សោតាវធានេ** នោះ គឺអ្វី គឺ **សុត** ។ ធម្មជាតដែលដឹងច្បាស់ កំណត់បានតាមគន្លងនៃសោតទ្វារ ឈ្មោះថា **សុត** ដូចក្នុងព្រះបាលីជាដើមថា **ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ** ជាអ្នកចេះចាំច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ដូច្នេះ សុតៈនោះក្នុងទីនេះ លោកពោលថា **សោតាវធានេ** ។ បញ្ញាដែលប្រព្រឹត្តទៅក្នុងសុតៈ ពោលគឺ **សោតាវធានេ** នោះ ឈ្មោះថា **សោតាវធានេ បញ្ញា** ។ បទថា **បញ្ញា** បានដល់ បញ្ញា ដោយអត្ថថា ជាគ្រឿងធ្វើឲ្យដឹងច្បាស់ ពោលគឺជាគ្រឿងធ្វើអត្ថនោះៗ ឲ្យប្រាកដ ។ ម្យ៉ាងទៀត ធម្មជាតណា ដឹងធម៌ទាំងឡាយ ដោយប្រការនោះៗ គឺដោយអនិច្ចលក្ខណៈជាដើម ហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **បញ្ញា** ។

**សុត** សព្ទ ក្នុងបទថា **សុតមយេ ញាណំ** ទាំងដែលមានឧបសគ្គ និងមិនមានឧបសគ្គ រមែងប្រាកដក្នុងអត្ថថា ទៅ ប្រាកដ តម្រេក ប្រកបរឿយៗ សន្សំ សទ្ទារម្មណ៍ ដឹងបានតាមគន្លងនៃសោតទ្វារ ។

ពិតហើយ **សុត** សព្ទ មានអត្ថថា ទៅ ដូចក្នុងប្រយោគជាដើមថា **សេនាយ បសុតោ** ទៅហើយដោយសេនា សេចក្តីថា ទ័ពដើរទៅ ដូច្នេះ ។

**សុត** សព្ទ មានអត្ថថា មានធម៌ដែលប្រាកដហើយ ដូចក្នុងប្រយោគជាដើមថា **សុតធម្មស្ស បស្សតោ** បុគ្គលមានធម៌ស្តាប់ហើយ បានឃើញច្បាស់ សេចក្តីថា ជាអ្នកមានធម៌ប្រាកដហើយ ដូច្នេះ ។

**សុត** សព្ទ មានអត្ថថា ត្រេកអរ និងមិនត្រេកអរ ដូចក□ប្រយោគ

*ជាដើមថា* **អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស** *សុន្ទរីនន្ទាជាម្ចាស់មានតម្រេក មិនគួរនឹងត្រេកអរឲ្យបុរសបុគ្គល ... ដូច្នេះ ។*

**សុត** *សព្ទ មានអត្ថថា* **ប្រកបរឿយៗ** *ដូចក្នុងប្រយោគជាដើមថា* **យេ ឈានប្បសុតា ធីរា** *អ្នកប្រាជ្ញពួកណា ជាអ្នកប្រកបរឿយៗ ក្នុងឈាន សេចក្តីថា ខ្វល់ខ្វាយរឿយៗ ក្នុងឈាន ដូច្នេះ ។*

**សុត** *សព្ទ មានអត្ថថា* **សន្សំ** *ដូចក្នុងប្រយោគជាដើមថា* **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** *បុណ្យ ឈ្មោះថា បានសន្សំទុកមិនមែនតិចឡើយ សេចក្តីថា ចូលទៅសន្សំហើយ ដូច្នេះ ។*

**សុត** *សព្ទ មានអត្ថថា* **សទ្ទារម្មណ៍** *ដូចក្នុងប្រយោគជាដើមថា* **ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ** *អារម្មណ៍ណាដែលបានឃើញ បានឮ បានពាល់ត្រូវ បានដឹងច្បាស់ ដូច្នេះ ។*

**សុត** *សព្ទ មានអត្ថថា ទ្រទ្រង់នូវសទ្ទារម្មណ៍ ដែលខ្លួនដឹងហើយ ដោយគន្លងនៃសោតទ្វារ ដូចក្នុងប្រយោគជាដើមថា* **ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ** *ជាអ្នកចេះចាំច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ដូច្នេះ ។ ម្យ៉ាងទៀត* **សុត** *សព្ទ នោះ មានអត្ថថា សទ្ទារម្មណ៍ ដែលខ្លួនដឹងច្បាស់ហើយ ចូលទៅទ្រទ្រង់ទុកហើយ ដោយគន្លងនៃសោតទ្វារ ។*

*បទថា* **សុតមយេ ញាណំ** *សេចក្តីថា បញ្ញានេះប្រាកដព្រះសទ្ធម្មដែលបានឮហើយ ដែលដឹងហើយ ដែលទ្រទ្រង់ទុកបានហើយ ធ្វើឲ្យជាអារម្មណ៍*

ប្រព្រឹត្តទៅហើយក្នុងគ្រាដំបូង និងគ្រា-តៗ មក បញ្ញានោះ លោកពោលថាជា សុតមយញ្ញាណ អធិប្បាយថា ញាណដែលសម្រេចហើយអំពីការស្តាប់ ។ បទថា **សុតមយេ** នេះ ជាបឋមាវិភត្តិ ។ ក្នុងបទជាដើមថា **ន ហេវំ វត្តព្វេ** ( មិនគប្បីពោលយ៉ាងនោះ ) **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** គុម្ពឈើក្នុងព្រៃមានត្រួយលូតលាស់ **នត្ថិ អត្តការេ នត្ថិ បរការេ នត្ថិ បុរិសការេ** អំពើរបស់ខ្លួនក៏មិនមាន អំពើរបស់អ្នកដទៃក៏មិនមាន អំពើរបស់បុរសក៏មិនមានយ៉ាងណា សូម្បីក្នុងទីនេះ បទថា **សុតមយេ** ក៏គប្បីយល់យ៉ាងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលពាក្យថា **សុតមយំ ញាណំ** អធិប្បាយថា ញាណដែលសម្រេចហើយអំពីការស្តាប់ ។

ម្យ៉ាងទៀត ពួកធម៌ មានផស្សៈជាដើម ដែលសម្រេចហើយដោយការស្តាប់ឈ្មោះថា **សុតមយ** ញាណដែលប្រព្រឹត្តទៅក្នុងពួកនៃធម៌ ដែលឈ្មោះថា សុតមយៈនោះ គឺដែលសម្បយុត្តដោយពួកធម៌នោះ ឈ្មោះថា **សុតមយ-ញាណ** ។ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹងធម៌ទាំងឡាយដោយអំណាចសាមញ្ញលក្ខណៈតាមសេចក្តីពិត ។ ញាណនោះឯង គប្បីជ្រាបថា លោកពោលថា បញ្ញា ដោយមិនកំណត់ ក៏ដើម្បីអធិប្បាយពាក្យពោលដោយអមក្នុងកាលខាងក្រោយបំណងយកហើយ ទើបពោលកំណត់ថា **ញាណំ** ។

ឈ្មោះថា **ញាណ** មានការចាក់ធ្លុះសភាវៈជាលក្ខណៈ ឬមានការចាក់ធ្លុះដោយមិនខុសភ្លាត់ជាលក្ខណៈ ដូចការបាញ់ព្រួញរបស់នាយខ្មាន់ធ្នូដែលជំនាញបាញ់ទៅហើយ ដូច្នោះ ។

*មានការបំភ្លឺនូវអារម្មណ៍ជារស ដូចប្រទីបចាំងបំភ្លឺ ដូច្នោះ ។*

*មានការមិនវង្វេងជាបច្ចុប្បដ្ឋាន ដូចអ្នកជំនាញក្នុងផ្លូវក្នុងព្រៃ ដូច្នោះ ។*

*មានសមាធិជាបទដ្ឋាន តាមព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តតម្កល់នៅនឹងនួន តែងដឹងច្បាស់តាមពិត ដូច្នេះ ។*

*ក្នុងលក្ខណៈជាដើម គប្បីជ្រាបថា សភាវៈក្តី សាមញ្ញក្តី ឈ្មោះថា លក្ខណៈ កិច្ចក្តី សម្បត្តិក្តី ឈ្មោះថា រស អាការដែលប្រាកដក្តី ផលក្តី ឈ្មោះថា បច្ចុប្បដ្ឋាន ហេតុជិត ឈ្មោះថា បទដ្ឋាន ដូច្នេះ ។៙*

**អដ្ឋកថាសុតមយញ្ញាណុទ្ទេស ចប់**

# ២. អដ្ឋកថា

## សីលមយញ្ញាណនិទ្ទេស

ពាក្យថា **សុត្វាន សំវរេ បញ្ញា** សេចក្តីថា ធម៌ ៥ ទាំងប្រការនេះ គឺ បាតិមោក្ខ ១ សតិ ១ ញាណ ១ ខន្តិ ១ វីរិយៈ ១ លោកសម្តែងថា សំវរៈ ។ សំវរៈមកហើយដោយន័យ ( ក្នុងអភិធម្មវិភង្គ ) ថា

ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយការសង្រួមក្នុងបាតិមោក្ខនេះជាដើម ឈ្មោះថា បាតិមោក្ខសំវរៈ ។

សំវរៈដែលមកហើយដោយន័យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា

ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយចក្ខុហើយ តែមិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយជាដើម ឈ្មោះថា សតិសំវរៈ ។

សំវរៈដែលមកហើយដោយន័យ ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា

ម្នាលអជិតៈ ខ្សែទាំងឡាយណា ក្នុងលោក សតិជាគ្រឿងបិទ
ខ្សែទាំងនោះ តថាគតពោលនូវការបិទខ្សែទាំងឡាយ ខ្សែទាំង
នោះ បុគ្គលបិទបានដោយបញ្ញាជាដើម ឈ្មោះថា ញាណសំវរៈ ។

សំវរៈដែលមកហើយដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរជាដើម ឈ្មោះថា បច្ចយបដិសេវនាសំវរៈ បច្ចយបដិសេវនាសំវរៈនោះ លោកសង្គ្រោះចូលក្នុងញាណសំវរៈនុ៎ះឯង ។

សំវរៈដែលមកហើយដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

អត់ធន់ចំពោះត្រជាក់ ក្តៅ ឃ្លាន ស្រេក ជាអ្នកអត់ទ្រាំនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ និងគន្លងពាក្យដែលគេនិយាយមិនពីរោះ ទ្រគោះ ខ្វីខ្វា និងទុក្ខវេទនាដែលកើតឡើង ប្រព្រឹត្តទៅក្នុងសរីរកាយដ៏ក្លា អាក្រក់ខ្លោចផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត និងនាំឲ្យខូចជីវិតជាដើម ឈ្មោះថា ខន្តិសំវរៈ ។

សំវរៈដែលមកហើយដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញ នូវកាមវិតក្កដែលកើតឡើងហើយជាដើម ឈ្មោះថា វីរិយសំវរៈ ។

សំវរៈដែលមកហើយដោយន័យ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា

ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស សម្រេចការចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតត្រូវជាដើម ឈ្មោះថា

អាជីវបារិសុទ្ធិសំវរៈ អាជីវបារិសុទ្ធិសំវរៈនោះ លោកសង្គ្រោះចូលក្នុងវីរិយ-សំវរៈនុ៎ះឯង ។

ក្នុងសំវរៈទាំង ៧ នោះ សំវរៈ ៤ គឺបាតិមោក្ខសំវរៈ ឥន្ទ្រិយសំវរៈ អាជីវបារិសុទ្ធិសំវរៈ និងបច្ចយបដិសេវនាសំវរៈ លោកបំណងយកក្នុងទីនេះ និងក្នុងសំវរៈទាំង ៤ នោះ បាតិមោក្ខសំវរៈ លោកសំដៅយកជាពិសេស ។ ក៏សំវរៈនេះសូម្បីទាំងអស់ លោកហៅថា សំវរៈ ព្រោះរាំងទុច្ចរិតទាំងឡាយមានកាយទុច្ចរិតជាដើម ដែលចាំបាច់ត្រូវសង្រួមតាមធម្មតារបស់ខ្លួន ។

កាលកុលបុត្តស្តាប់ធម៌តាមដែលពោលក្នុងសុតមយញ្ញាណ ហើយសង្រួម ធ្វើការសង្រួម បញ្ញាដែលប្រព្រឹត្តទៅក្នុងសំវរៈនោះ គឺសម្បយុត្តជាមួយសំវរៈនោះហៅថា **សុត្វាន សំវរេ បញ្ញា** គឺបញ្ញាក្នុងការស្តាប់ធម៌ ហើយសង្រួម ។ អធិប្បាយថា បញ្ញាក្នុងការសង្រួម ព្រោះមានការស្តាប់ជាហេតុ ដូច្នេះក៏មាន ព្រោះមានពាក្យថា **ហេតុអត្ថេ សុត្វា** ស្តាប់ហេតុ និងផល ។

បទថា **សីលំ** ក្នុងពាក្យនេះថា **សីលមយេ ញាណំ** សេចក្តីថា ឈ្មោះថា សីល ព្រោះអត្ថថា សង្រួម សីលនេះ ឈ្មោះថា សង្រួមដូចម្តេច គឺជាហេតុតាំងមាំ អធិប្បាយថា ភាពដែលកាយកម្មជាដើមមិនរាត់រាយដោយអំណាចនៃភាពជាអ្នកសង្រួមដោយល្អ ឬភាពជាហេតុចូលទៅរម្ងាប់ អធិប្បាយថា ភាវៈជាគ្រឿងទ្រកុសលធម៌ទាំងឡាយ ដោយអំណាចជាទីតាំង ។

ក្នុងសីលនេះ អ្នកប្រាជ្ញដែលចេះលក្ខណសព្ទ ទទួលអត្ថទាំងពីរយ៉ាងនេះប៉ុណ្ណោះ តែអាចារ្យពួកដទៃពណ៌នាថា ឈ្មោះថា សីល ដោយអត្ថថាជា

បដិបទាក្រៃលែង ដោយអត្ថថា ជាទីទ្រ ដោយអត្ថថា មាំទាំ ដោយអត្ថថា ជាប្រក្រតី ដោយអត្ថថា ជាក្បាល ដោយអត្ថថា ត្រជាក់ ដោយអត្ថថា ក្សេម ។

សីលនោះ សូម្បីមានប្រភេទផ្សេងៗ ច្រើនយ៉ាង ក៏មានការសង្រួម
ជាលក្ខណៈ ដូចរូប ( រូបារម្មណ៍ ) មានប្រភេទផ្សេងៗ ជា
ច្រើន ក៏មានការឃើញបានដោយភ្នែកជាលក្ខណៈ ដូច្នោះ ។

ដូចភាពដែលរូបាយតនៈ សូម្បីមានប្រភេទផ្សេងៗ ដ៏ច្រើន ដោយប្រភេទមានពណ៌ខៀវ និងពណ៌លឿងជាដើម ក៏មានការឃើញបានដោយភ្នែក ជាលក្ខណៈ ព្រោះរូបាយតនៈ សូម្បីមានប្រភេទផ្សេងៗ ដោយប្រភេទនៃពណ៌ខៀវជាដើម ក៏មិនឈានកន្លងភាវៈដែលឃើញបានដោយភ្នែកយ៉ាងណា ការសង្រួមដែលពោលហើយ ថាជាទីតាំងមាំនៃកាយកម្មជាដើម និងជាគ្រឿងទ្រកុសលធម៌ទាំងឡាយនោះឯង ជាលក្ខណៈនៃសីល មានប្រភេទផ្សេងៗ ច្រើនយ៉ាង ដោយប្រភេទនៃវិរតិ មានចេតនាវិរតិជាដើម ព្រោះសីល សូម្បីមានប្រភេទផ្សេងៗ ច្រើនយ៉ាង ដោយប្រភេទនៃវិរតិ មានចេតនាវិរតិជាដើម ក៏មិនឈានកន្លងភាពជាទីតាំងនិងជាគ្រឿងទ្រទៅបានយ៉ាងនោះ ។

ការកម្ចាត់ភាពជាអ្នកទ្រុស្តសីល និងគុណ គឺការមិនមានទោស
លោកហៅថា ជារស ដោយអត្ថថា ជាកិច្ច និងសម្បត្តិនៃសីល
នោះ ដែលមានលក្ខណៈដូចដែលពោលមកហើយយ៉ាងនេះ ។

ព្រោះហេតុនោះ ធម្មតាថាសីលនេះ បណ្ឌិតគប្បីជ្រាបថា មានការកម្ចាត់ភាពជាអ្នកទ្រុស្តសីល ជារស ព្រោះរសមានអត្ថថា ជាកិច្ច មានការមិនមាន

ទោសជារស ដោយរសមានអត្ថថា ជាសម្បត្តិ ។

សីលនេះ វិញ្ញូជនទាំងឡាយពណ៌នាថា មានការស្អាតជាបច្ចុប្បដ្ឋាន មានហិរិ និងឱត្តប្បៈ ជាបទដ្ឋាននៃសីលនោះ ។

សីលនេះ មានសោចេយ្យៈ គឺការស្អាតជាបច្ចុប្បដ្ឋានតាមដែលព្រះមានព្រះភាគត្រាស់ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) យ៉ាងនេះថា សេចក្តីស្អាតដោយកាយ ១ សេចក្តីស្អាតដោយវាចា ១ សេចក្តីស្អាតដោយចិត្ត ១ ដូច្នេះ ។ រមែងប្រាកដដោយភាពជារបស់ស្អាត គឺដល់នូវភាវៈចាប់ពាល់បាន ។ ចំណែកហិរិ និងឱត្តប្បៈ វិញ្ញូជនទាំងឡាយពណ៌នាថា ជាបទដ្ឋានរបស់សីលនោះ អធិប្បាយថា ជាហេតុជិត ។ ព្រោះកាលបើហិរិ និងឱត្តប្បៈមាន សីលក៏រមែងកើតឡើង និងតាំងនៅ កាលបើហិរិ និងឱត្តប្បៈមិនមាន សីលក៏រមែងមិនកើតឡើង និងមិនតាំងនៅ ព្រោះហេតុនោះ ញាណដែលសហគតៈដោយសីល តាមដែលពោលហើយយ៉ាងនេះ គឺដែលសម្បយុត្តដោយសីលនោះ ឈ្មោះថា **សីលមយេញាណំ** ។ ម្យ៉ាងទៀត សីលនោះឯងជាប្រក្រតី ឈ្មោះថា **សីលមយញាណ** ក្នុងសីលមយៈនោះ គឺសម្បយុត្តដោយសីលមយៈនោះ ។

ការពិចារណាទោស ក្នុងការមិនសង្រួម ការពិចារណាអានិសង្សក្នុងការសង្រួម ការពិចារណាសេចក្តីបរិសុទ្ធក្នុងការសង្រួម ការពិចារណាសេចក្តីស្អាតចាកសង្កិលេស ព្រោះការសង្រួម លោកសង្គ្រោះចូលក្នុងសីលមយញាណនុ៎ះឯង ។៚

## អដ្ឋកថាសីលមយញាណុទ្ទេស ចប់

## ៣. អដ្ឋកថា

## សមាធិភាវនាមយញ្ញាណុទ្ទេស

ពាក្យថា **សំវរិត្វា សមាទហនេ បញ្ញា** សេចក្តីថា កាលកុលបុត្តសង្រួមដោយសីលសំវរៈ តាមដែលពោលក្នុងសីលមយញ្ញាណ ហើយធ្វើការសង្រួមតាំងនៅក្នុងសីល មានចិត្តតាំងទុកដោយល្អ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ បញ្ញាដែលប្រព្រឹត្តទៅក្នុងសមាធិចិត្តនោះ គឺសម្បយុត្តជាមួយសមាធិចិត្តនោះ ។ ការតាំងទុក ការតម្កល់ទុកដោយល្អប្រពៃ ព្រោះហេតុនោះ ទើបឈ្មោះថា **សមាទហនំ** ការតាំងទុកដោយល្អ ពាក្យនេះ ជាពាក្យហៅសមាធិដោយអម ។

ឯកគ្គតានៃកុសលចិត្ត ឈ្មោះថា សមាធិក្នុងពាក្យនេះថា **សមាធិភាវនាមយេញាណំ** ឈ្មោះថា សមាធិ ដោយអត្ថដូចម្តេច ឈ្មោះថា សមាធិដោយអត្ថថា តម្កល់ទុកល្អ ឈ្មោះថា តម្កល់ទុកល្អនេះដូចម្តេច មានពាក្យអធិប្បាយថា ការដាក់ ការតម្កល់នូវចិត្ត និងចេតសិក ក្នុងអារម្មណ៍តែមួយដោយល្អ ដោយប្រពៃ ព្រោះហេតុនោះ ចិត្ត និងចេតសិក មិនផ្សាយទៅ មិនរាយមាយ តាំងនៅដោយល្អ ដោយប្រពៃក្នុងអារម្មណ៍មួយ ដោយអានុភាពនៃធម៌ណា ធម៌នេះ គប្បីជ្រាបថា **សមាហានំ** ។

សមាធិនោះ មានការមិនរាយមាយជាលក្ខណៈ មានការកម្ចាត់នូវការរាយមាយជារស មានការមិនញាប់ញ័រជាបច្ចុប្បដ្ឋាន មានសុខជាបទដ្ឋាន ។

ធម្មជាតណាដែលព្រះយោគីបុគ្គលអប់រំចម្រើន ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ភាវនា** ។ ភាវនា គឺសមាធិ ឈ្មោះថា **សមាធិភាវនា** ។

ម្យ៉ាងទៀត ការអប់រំចម្រើននូវសមាធិ ឈ្មោះថា សមាធិភាវនា លោកហាមភាវនាដទៃ ដោយពាក្យថា សមាធិភាវនា ។

បញ្ញាជាសមាធិភាវនាមយញ្ញាណ ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ ដូច ( ពណ៌នា ) ក្នុងកាលមុន ។

## អដ្ឋកថាសមាធិភាវនាមយញ្ញាណុទ្ទេស ចប់

# ៤.អដ្ឋកថា

# ធម្មដ្ឋិតិញ្ញាណានុទ្ទេស

បទថា **បច្ចយ** ក្នុងបទថា **បច្ចយបរិគ្គហេ បញ្ញា** មានវិគ្គហៈថា ផល រមែងអាស្រ័យធម៌នោះកើត ព្រោះហេតុនោះ ធម៌នោះឈ្មោះថា **បច្ច័យ** ។

ពាក្យថា **អាស្រ័យ** បានដល់ មិនវៀរចាកធម៌ដែលជាបច្ច័យនោះ អធិប្បាយថា មិនលះបង់ ។ ពាក្យថា **កើត** បានដល់ រមែងកើតឡើងផង រមែងប្រព្រឹត្តទៅផង ។ ម្យ៉ាងទៀត មានអត្ថថា ឧបការៈ មានអត្ថថា ជាដែនកើតបញ្ញាក្នុងការកំណត់ជុំវិញ និងកំណត់នូវបច្ច័យទាំងឡាយ ព្រោះបច្ច័យនោះមានច្រើនយ៉ាង ឈ្មោះថា **បច្ចយបរិគ្គហេ បញ្ញា** ។

**ធម្ម** សព្ទ ក្នុងបទថា **ធម្មដ្ឋិតិញ្ញាណំ** នេះ រមែងប្រាកដក្នុងអត្ថថា សភាវៈ បញ្ញា បុញ្ញ បញ្ញត្តិ អាបត្តិ បរិយត្តិ និស្សត្តតា វិការៈ គុណ បច្ច័យ បច្ចយុប្បន្នជាដើម ។

**ធម្ម** សព្ទនេះ ប្រាកដក្នុងអត្ថថា **សភាវៈ** ដូចក្នុងប្រយោគជាដើមថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា** ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យាក្រឹត ដូច្នេះ ។

**ធម្ម** សព្ទ ប្រាកដក្នុងអត្ថថា **បញ្ញា** ដូចក្នុងប្រយោគជាដើមថា **យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ សច្ចំ ធម្មោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ** ធម៌ទាំង ៤ នេះ គឺសច្ចៈ ១ ធម្មៈ ( បញ្ញា ) ១ ធិតិ ( ព្យាយាម ) ១ ចាគៈ ( ការបរិច្ចាគ ) ១ របស់បុគ្គលណា មានសទ្ធានៅគ្រប់គ្រង

ផុះ បុគ្គលនោះឯង រមែងមិនសោយសោកក្នុងលោកខាងមុខ ដូច្នេះ ។

ធម្ម សព្ទ ប្រាកដក្នុងអត្ថថា **បុញ្ញ** ដូចក្នុងប្រយោគជាដើមថា **ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ** សភាវៈទាំង ២ គឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែនមានផលស្មើគ្នាទេ អកុសលធម៌នាំសត្វទៅកាន់នរក កុសលធម៌ ញុំាំងសត្វឲ្យដល់នូវសុគតិ ដូច្នេះ ។

ធម្ម សព្ទ ប្រាកដក្នុងអត្ថថា **បញ្ញត្តិ** ដូចក្នុងប្រយោគជាដើមថា **បញ្ញត្តិធម្មា និរុត្តិធម្មា អធិវចនធម្មា** ពួកធម៌ជាបញ្ញត្តិ ពួកធម៌ជានិរុត្តិ ពួកធម៌ជាឈ្មោះ ដូច្នេះ ។

ធម្ម សព្ទ ប្រាកដក្នុងអត្ថថា **អាបត្តិ** ដូចក្នុងប្រយោគជាដើមថា **បារាជិកា ធម្មា សង្ឃាទិសេសា ធម្មា** អាបត្តិឈ្មោះបារាជិក អាបត្តិឈ្មោះសង្ឃាទិសេស ដូច្នេះ ។

ធម្ម សព្ទ ប្រាកដក្នុងអត្ថថា **បរិយត្តិ** ដូចក្នុងប្រយោគជាដើមថា **ឥធ ភិក្ខុ ធម្មំ ជាណាតិ សុត្តំ គេយ្យំ វេយ្យាករណំ** ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ ដូច្នេះ ។

ធម្ម សព្ទ ប្រាកដក្នុងអត្ថថា **និស្សត្តតា** ដូចក្នុងប្រយោគជាដើមថា **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ ធម្មេសុ ធម្មានុបស្សី វិហរតិ** ពួកធម៌កើតមានក្នុងសម័យនោះ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ដូច្នេះ ។

**ធម្ម** សព្ទ ប្រាកដក្នុងអត្ថថា **វិការ** ដូចក្នុងប្រយោគជាដើមថា **ជាតិធម្មា ជរាធម្មា មរណធម្មា** ពួកសត្វមានជាតិជាធម្មតា ពួកសត្វមានជរាជាធម្មតា ពួកសត្វមានមរណៈជាធម្មតា ដូច្នេះ ។

**ធម្ម** សព្ទ ប្រាកដក្នុងអត្ថថា **គុណ** ដូចក្នុងប្រយោគជាដើមថា **ឆន្នំ ពុទ្ធធម្មានំ** ធម៌របស់ព្រះពុទ្ធ ៦ យ៉ាង ដូច្នេះ ។

**ធម្ម** សព្ទ ប្រាកដក្នុងអត្ថថា **បច្ចយ** ដូចក្នុងប្រយោគជាដើមថា **ហេតុម្ហិ ញាណំ ធម្មប្បដិសម្ភិទា** សេចក្ដីដឹងហេតុឈ្មោះថា **ធម្មប្បដិសម្ភិទា** ដូច្នេះ ។

**ធម្ម** សព្ទ ប្រាកដក្នុងអត្ថថា បច្ចយុប្បន្ន ( ធម៌ដែលកើតអំពីបច្ច័យ ) ដូចក្នុងប្រយោគជាដើមថា **ឋិតាវ សា ធាតុ ធម្មដ្ឋិតតា ធម្មនិយាមតា** ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា ដូច្នេះ ។

**ធម្ម** សព្ទនោះ ក្នុងទីនេះ គប្បីឃើញថា ចុះក្នុងអត្ថថា បច្ចយុប្បន្ន ។ ដោយអត្ថ លោកហៅតាមសមគួរថា **ធម្ម** ព្រោះទ្រទ្រង់នូវសភាវៈរបស់ខ្លួន ឬដែលបច្ច័យទ្រទ្រង់ ឬរមែងទ្រទ្រង់នូវផលរបស់ខ្លួន ឬទ្រទ្រង់នូវអ្នកបំពេញខ្លួនឲ្យបរិបូរ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ឬទ្រទ្រង់ក្នុងលក្ខណៈរបស់ខ្លួន ឬដែលចិត្តទ្រទ្រង់ តែក្នុងទីនេះឈ្មោះថា **ធម៌** ព្រោះអត្ថថា ដែលបច្ច័យទាំងឡាយរបស់ខ្លួនទ្រទ្រង់ ធម៌ទាំងឡាយអាស្រ័យបច្ច័យកើតឡើង រមែងតាំងឡើង គឺរមែងកើតឡើងផង រមែងប្រព្រឹត្តទៅផង ដោយធម្មជាតណា ហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **ធម្មដ្ឋិតិ** ពាក្យនេះជាឈ្មោះរបស់បច្ចយធម៌ទាំងឡាយ ញាណក្នុងធម្មដ្ឋិតិនោះ ឈ្មោះថា **ធម្មដ្ឋិ-**

**តិញ្ញាណំ** ធម្មដ្ឋិតិញ្ញាណនេះ ដែលជាហេតុនៃការកំណត់បច្ច័យនៃនាមរូបទាំងឡាយទាំងនោះ រមែងកើតឡើងដល់ព្រះយោគី បុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីយថាភូតញ្ញាណទស្សនៈ ដោយចិត្តដែលតាំងមាំដោយសមាធិតាមដែលពោលទុក ក្នុងសមាធិភាវនាមយញ្ញាណ ហើយកំណត់នាមរូប ។ ប្រសិនបើមានពាក្យសួរថា ញាណនេះ ហេតុអ្វីលោកមិនពោលថា នាមរូបវវត្ថានញ្ញាណ តែបែរជាពោលថា ធម្មដ្ឋិតិញ្ញាណវិញ ឆ្លើយថា ព្រោះការកំណត់ធម៌ដែលអាស្រ័យបច្ច័យកើតឡើង សុទ្ធតែសម្រេចដោយការកំណត់បច្ច័យទាំងអស់ ។ ពិតហើយ ធម៌ដែលអាស្រ័យបច្ច័យកើតឡើង ដែលព្រះយោគីបុគ្គលមិនបានកំណត់ហើយ ក៏មិនអាចនឹងធ្វើការកំណត់បច្ច័យបាន ព្រោះហេតុនោះ គប្បីជ្រាបថា នាមរូបវវត្ថានញ្ញាណដែលជាហេតុនៃបច្ចយបរិគ្គហញ្ញាណនោះ សម្រេចហើយក្នុងកាលមុន ក៏រមែងជាញាណដែលលោកពោលហើយដោយសព្ទថា **ធម្មដ្ឋិតិញ្ញាណំ** នុ៎ះឯង ។

ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបលោកមិនពោលថា បញ្ញាក្នុងការដែលចិត្តតាំងមាំហើយកំណត់បច្ច័យ ដូចញាណទី ២ និងញាណទី ៣ ឆ្លើយថា ព្រោះសមថៈ និងវិបស្សនា ជាធម៌គូគ្នា ។

សមដូចគាថាព័ន្ធដែលបុរាណាចារ្យពោលថា

ប្រសិនបើព្រះយោគីបុគ្គលមានចិត្តតាំងមាំ រមែងឃើញច្បាស់
បានដោយប្រការណាសោត និងប្រសិនបើព្រះយោគីបុគ្គល
កាលឃើញច្បាស់ រមែងមានចិត្តតាំងមាំបានដោយប្រការនោះ

*ក្នុងកាលនោះ វិបស្សនា និងសមថៈ ជាធម៌មានចំណែក ស្មើគ្នា ជាធម៌គូគ្នាប្រព្រឹត្តទៅ ។*

*ព្រោះហេតុនោះ គប្បីជ្រាបថា លោកពោលថា* **បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិ ញ្ញាណំ** *ប្រែថា បញ្ញាក្នុងការកំណត់បច្ច័យជាធម្មដ្ឋិតិញ្ញាណ ដូច្នេះ ក៏ដើម្បីឲ្យដឹងថា ព្រះយោគីបុគ្គលកុំលះសមាធិ ធ្វើសមាធិ និងបញ្ញាឲ្យជាធម៌គូគ្នាហើយ គប្បីខ្វល់ខ្វាយរហូតដល់អរិយមគ្គ ។៚*

**អដ្ឋកថាធម្មដ្ឋិតិញ្ញាណុទ្ទេស ចប់**

## ៥. អដ្ឋកថា

## សម្មសនញ្ញាណនិទ្ទេស

ក្នុងបទថា **អតីតានាគតបច្ចុប្បន្នានំ ធម្មានំ សង្ខិបិត្វា វវត្ថានេ បញ្ញា** មានវិគ្គហៈថា ធម៌ទាំងឡាយ ឈ្មោះថា **អតីត** ព្រោះអត្ថថា ដល់ហើយ ទៅហើយ ប្រព្រឹត្តទៅហើយ ឈានកន្លងហើយនូវសភាវៈរបស់ខ្លួន ឬនូវខណៈ មានឧប្បាទក្ខណៈជាដើម ឈ្មោះថា អនាគត ព្រោះអត្ថថា មិនដល់ហើយ មិនដល់ព្រមហើយនូវសភាវៈទាំងពីរនោះ ឈ្មោះថា **បច្ចុប្បន្ន** ព្រោះអត្ថថា សម្រេចហើយ ដល់ហើយ ប្រព្រឹត្តទៅហើយ ក្នុងខាងលើនៃឧប្បាទក្ខណៈជាដើម ព្រោះអាស្រ័យហេតុនោះៗ ។ ក្នុងអទ្ធាបច្ចុប្បន្ន សន្តតិ-បច្ចុប្បន្ន និងខណបច្ចុប្បន្ន ក្នុងទីនេះ បំណងយកសន្តតិបច្ចុប្បន្ន ។ បញ្ញាក្នុងការសង្ខេបធម៌ គឺខន្ធ ៥ ទាំងដែលជាអតីត អនាគត បច្ចុប្បន្នទាំងនោះចូលទុកក្នុងលក្ខណៈនៃខន្ធនីមួយៗ ហើយធ្វើឲ្យជាគំនរ ដោយជាកលាបៈ ហើយកំណត់វិនិច្ឆ័យកាត់សម្រេច ។

**ញាណ** គឺបញ្ញាក្នុងការពាល់ត្រូវ ជ្រើសរើស សម្លឹងពិនិត្យដោយល្អ អធិប្បាយថា កលាបសម្មសនញ្ញាណ គឺញាណក្នុងការពិចារណាក្នុងបញ្ចក្ខន្ធដោយភាពជាកលាបៈ ឈ្មោះថា **សម្មសនេ ញាណំ**។ ពិតហើយ **កលាប-សម្មសនញ្ញាណ** នេះ រមែងកើតដល់ព្រះយោគីបុគ្គលអ្នកបានធម្មដ្ឋិតិញ្ញាណជាគ្រឿងកំណត់បច្ច័យរបស់នាមរូបក្នុងលំដាប់នៃនាមរូបវវត្ថានញ្ញាណ ដែលលើកយកខន្ធនីមួយៗ ដែលកំណត់ហើយ ក្នុងកាលមុនឡើងកាន់ត្រៃលក្ខណ៍ ហើយឃើញច្បាស់ដោយភាពជា **អនិច្ចំ ទុក្ខំ អនត្តា** ដោយអំណាចនៃការ

ពិចារណាតាមដែលពោលហើយ ដោយន័យជាដើមថា រូបណាមួយជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណាក្នុងទីឆ្ងាយ ឬទីជិតក្តី បុគ្គលកំណត់នូវរូបទាំងអស់នោះថា មិនទៀង ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ថា ជាទុក្ខ ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ថា មិនមែនខ្លួន ឈ្មោះថា សម្មសនញ្ញាណ ១[១] ៗ៚

## អដ្ឋកថាសម្មសនញ្ញាណុទ្ទេស ចប់

១- បិដកលេខ ៦៩ ឃ្នាប ៩៩ ។

## ៦. អដ្ឋកថា

## ឧទយព្វយានុបស្សនាញាណុទ្ទេស

*ពាក្យថា* **បច្ចុប្បន្នានំ ធម្មានំ វិបរិណាមានុបស្សនេ បញ្ញា** *សេចក្ដីថា បញ្ញាក្នុងការឃើញការប្រែប្រួលទៅ គឺការរលត់ទៅនៃធម៌ គឺបញ្ចក្ខន្ធក្នុងខាងក្នុងដែលជាបច្ចុប្បន្ន ដោយអំណាចសន្តតិ ។ ព្រោះចិត្តសូម្បីកំណត់ការកើតឡើងថា ធម៌ទាំងឡាយនេះ កាលកើតឡើងហើយ ក៏រមែងបែកធ្លាយទៅ រមែងតាំងនៅក្នុងការបែកធ្លាយទៅដូចគ្នា ហេតុនោះ គប្បីជ្រាបថា ការកើតឡើងសូម្បីមិនបានពោលហើយ ក៏ឈ្មោះថា ពោលដូចគ្នា ។* *ម្យ៉ាង**ទៀត ការកើតឡើង រមែងឈ្មោះថា ពោលហើយនោះឯង ព្រោះមានការឃើញការកើតឡើង ដោយការឃើញបច្ចុប្បន្នធម៌ទាំងឡាយ ។*

*ពិតហើយ វៀរការកើតឡើង ការកើតឡើងនៃធម៌ទាំងឡាយក៏មានមិនបាន ព្រោះហេតុនោះ សូម្បីកាលមិនពោលថា បញ្ញាក្នុងការពិចារណាឃើញការកើតឡើង និងការប្រែប្រួលទៅនៃបច្ចុប្បន្នធម៌ទាំងឡាយ ក៏គប្បីជ្រាបថា ឈ្មោះថា ពោលហើយនោះឯង ។ ឧទយព្វយានុបស្សនាញាណ រមែងកើតដល់ព្រះយោគីបុគ្គលអ្នកសម្រេចសម្មសនញ្ញាណ តាមដែលបានពោលហើយ ក្នុងលំដាប់ថា ការឃើញ ការកើតឡើងរមែងសម្រេចបាន ព្រោះកំណត់ពាក្យថា ឧទយព្វយានុបស្សនាញាណ ( បញ្ញាក្នុងការឃើញការកើត និងការរលត់ ) ហើយកំណត់ការកើតឡើង និងការរលត់ទៅដែលប្រាកដក្នុងខណៈពិចារណាបញ្ចក្ខន្ធនោះឯង ហើយប្រារព្ធឧទយព្វយានុបស្សនា ដើម្បីធ្វើការកំណត់*

សង្ខារធម៌ទាំងឡាយ ។ ញាណនោះ លោកហៅថា ឧទយព្វយានុបស្សនា ព្រោះតាមពិចារណាឃើញការកើត និងការរលត់ ។៚

## អដ្ឋកថាឧទយព្វយានុបស្សនាញាណុទ្ទេស ចប់

## ៧. អដ្ឋកថា

## វិបស្សនាញាណុទ្ទេស

*បទថា* **អារម្មណំ បដិសង្ខា** *បានដល់ ពិចារណា គឺដឹង ឃើញអារម្មណ៍ មានរូបក្ខន្ធជាដើម ដោយការបែកធ្លាយទៅ ។*

*បទថា* **ភង្គានុបស្សនេ បញ្ញា វិបស្សនេ ញាណំ** *បានដល់ បញ្ញាណា ដឹងក្នុងការតាមឃើញការរលត់នៃញាណដែលកើតឡើងហើយ ដោយពិចារណា អារម្មណ៍ដោយការបែកធ្លាយទៅ បញ្ញានោះ លោកហៅថា វិបស្សនាញាណ ។*

*បទថា* **វិបស្សនេ** *បានដល់ ឃើញ ឃើញច្បាស់ដោយប្រការផ្សេងៗ ។ បាឋៈថា* **អារម្មណាបដិសង្ខា** *ដូច្នេះក៏មាន ។*

*អត្ថនៃអារម្មណាបដិសង្ខានោះ មានដូច្នេះ គឺការពិចារណាអារម្មណ៍ និង ពិចារណាអារម្មណ៍ដោយន័យតាមដែលពោលហើយថា ការដឹង ការឃើញ មានពាក្យអធិប្បាយថា បញ្ញាក្នុងការពិចារណាឃើញនូវការបែកធ្លាយទៅ ជា វិបស្សនាញាណ ព្រោះវិបស្សនារមែងដល់ទីបំផុតដោយការពិចារណាឃើញ ការបែកធ្លាយទៅនោះឯង ហេតុនោះ ទើបលោកពោលពាក្យនេះឲ្យពិសេសថា វិបស្សនាញាណ ។ ព្រោះមគ្គាមគ្គញ្ញាណទស្សនៈ រមែងកើតដល់ព្រះយោគី-បុគ្គលដែលបានឧទយព្វយានុបស្សនា ហេតុនោះ កាលឧទយព្វយានុបស្សនា នោះសម្រេចហើយ មគ្គាមគ្គញ្ញាណទស្សនៈនោះ ក៏រមែងសម្រេចផងដែរនោះ ឯង ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិនបានពោលដល់មគ្គាមគ្គញ្ញាណ-ទស្សនៈនោះឡើយ ពោលញាណដែលជាកំពូលនៃវិបស្សនា ក្នុងការ*

ពិចារណាឃើញការបែកធ្លាយទៅប៉ុណ្ណោះ ។ កាលសង្ខារទាំងឡាយ ដែលព្រះយោគីបុគ្គលអ្នកឃើញការកើតឡើង និងការរលត់ទៅ ជាក់ច្បាស់ហើយ ដោយឧទយព្វយានុបស្សនា កំណត់ល្អហើយ តាំងនៅស្រាលៗ ប៉ុណ្ណោះ កាលញាណចាស់ក្លា សតិក៏លះការកើត ហើយតាំងនៅក្នុងការរលត់តែម្យ៉ាង កាលព្រះយោគីបុគ្គលនោះឃើញថា ធម្មតាសង្ខារធម៌ទាំងឡាយ កើតឡើងហើយយ៉ាងនេះ រមែងបែកធ្លាយទៅយ៉ាងនេះ ភង្គានុបស្សនាញាណ ក៏រមែងកើតឡើងបានក្នុងឋានៈនេះ ។ល។

## អដ្ឋកថាវិបស្សនាញាណុទ្ទេស ចប់

# ៨. អដ្ឋកថា
# អាទីនវញ្ញាណុទ្ទេស

បទថា **ភយតូបដ្ឋានេ បញ្ញា** សេចក្តីថា បញ្ញាក្នុងការប្រាកដឡើងនៃ ឧប្បាទ គឺការកើត បវត្តិ គឺការប្រព្រឹត្តទៅ និមិត្ត គឺគ្រឿងសម្គាល់ អាយូហនា គឺការប្រមូលមក និងបដិសន្ធិ គឺការកើតក្នុងភពថ្មី ដោយភាពជាភ័យ គឺការចូលទៅកាន់យកថា មានភ័យប្រាកដនៅចំពោះមុខដោយការប្រកប ដោយការបៀតបៀនរឿយៗ ។ អារម្មណ៍ ឈ្មោះថា ភយតូបដ្ឋាន ព្រោះអត្ថថា រមែងប្រាកដ ដោយភាពជាភ័យ ។ បញ្ញាក្នុងភយតូបដ្ឋាននោះ ។ ម្យ៉ាង ទៀត មានពាក្យអធិប្បាយថា ឈ្មោះថា **ភយតូបដ្ឋាន** ព្រោះអត្ថថា ចូលទៅ សម្លឹងពិនិត្យដោយភាពជាភ័យ ភយតូបដ្ឋាននោះ គឺបញ្ញានោះឯង ។

បទថា **អាទីនវេ ញាណំ** ជាសត្តមីវិភត្តិ ។ សូម្បីពោលហាក់បីដូចមាន តែមួយ ព្រោះព្រះធម្មសេនាបតីសារីបុត្តបានពោលថា បញ្ញាក្នុងការប្រាកដ ឡើងថាជាភ័យឯណាក្តី ការដឹងក្នុងទោសឯណាក្តី ការនឿយណាយឯណាក្តី ធម៌ទាំងនេះមានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា[១] ដូច្នេះ តែក៏មាន ៣ យ៉ាងនោះឯង ដោយប្រភេទនៃការកំណត់ ដូចមុញ្ចិតុកម្យតាញាណជាដើម ។ ព្រោះហេតុនោះ សូម្បីមិនពោលថា កាលភយតូបដ្ឋាន និងអាទីនវានុបស្សនា សម្រេចហើយ និព្វិទានុបស្សនា ក៏រមែងសម្រេច គប្បីជ្រាបថា ឈ្មោះថា ពោលហើយនោះឯង ។

---

១- បិដកលេខ ៧០ ឃ្នាប ២១៥ ។

សង្ខារទាំងឡាយ ដែលចែកក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ រមែងប្រាកដជាមហាភ័យដល់ព្រះយោគីបុគ្គលអ្នកសេពចម្រើន ធ្វើឲ្យច្រើននូវភង្គានុបស្សនា ដែលមានការរលត់ទៅនៃសង្ខារទាំងពួងជាអារម្មណ៍ ដូចជាសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន យក្ស អារក្សទឹក គោកាច ឆ្កែកាច ដំរីចុះប្រេង ពស់កាច រន្ទះ ព្រៃស្មសាន សមរភូមិ រណ្ដៅរងើកភ្លើងដែលឆេះសន្ធោសន្ធៅជាដើម រមែងប្រាកដជាភ័យធំដល់បុរសអ្នកខ្លាចភ័យ ចង់រស់នៅជាសុខ ភយតូបដ្ឋានញ្ញាណ រមែងកើតឡើងបានក្នុងឋានៈនេះដល់ព្រះយោគីបុគ្គលអ្នកឃើញថា សង្ខារទាំងឡាយក្នុងអតីត ក៏រលត់ទៅហើយ ក្នុងបច្ចុប្បន្នក៏កំពុងរលត់ សូម្បីអនាគតក៏នឹងរលត់ទៅយ៉ាងនេះដូចគ្នា ។

ក្នុងភព កំណើត គតិ ឋិតិ និងសត្តាវាស ទូទៅទាំងអស់ ទីជ្រកកោន ទីពួន ទីទៅ ទីពឹង រមែងមិនប្រាកដដល់ព្រះយោគីបុគ្គលអ្នកសេព ចម្រើនធ្វើឲ្យច្រើននូវភយតូបដ្ឋានញ្ញាណនោះឡើយ ការប្រាថ្នាក្ដី ការប្រកាន់មាំក្ដីក្នុងសង្ខារទាំងឡាយ ដែលមានក្នុងភព កំណើត គតិ ឋិតិ និវាសទាំងអស់ សូម្បីតែសង្ខារមួយរមែងមិនមាន ភពទាំង ៣ ប្រាកដដូចជារណ្ដៅរងើកភ្លើងដែលពេញដោយរងើកភ្លើងមិនមានអណ្ដាត មហាភូតរូប ៤ ប្រាកដដូចអសិរ-ពិសដែលមានពិសដ៏ពន្លឹក ខន្ធ ៥ ប្រាកដដូចពេជ្ឈឃាត ដែលកំពុងនាដាវ អាយតនៈខាងក្នុង ៦ ប្រាកដដូចផ្ទះស្ងាត់ អាយតនៈខាងក្រៅ ៦ ប្រាកដដូចចោរប្លន់អ្នកស្រុក វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ ប្រាកដដូចភ្លើង ១១ កងឆេះសន្ធោសន្ធៅ សង្ខារទាំងឡាយប្រាកដដូចជាបូស ជារោគ ជាសរ ជាជំងឺ

*ជាអាពាធ ប្រាសចាកការស្រស់បស់ មិនមានរសជាតិ ជាគំនរនៃទោសធំ ដងព្រៃសូម្បីតាំងនៅដោយអាការដែលគួរត្រេកអរ រមែងប្រាកដដូចដងព្រៃដែលមានសត្វសាហាវដល់បុរសអ្នកភ័យខ្លាច ប្រាថ្នាជីវិតរស់នៅជាសុខ គុហាហាក់បីដូចមានខ្លាធំ ស្រះទឹកហាក់បីដូចមានអារក្សទឹកអាស្រ័យនៅ សត្រូវហាក់ដូចកំពុងងាដាវ ភោជនហាក់ដូចលាយដោយថ្នាំពិស ផ្លូវហាក់ដូចពេញដោយចោរ ផ្ទះហាក់ដូចភ្លើងកំពុងឆេះ លានចម្បាំងហាក់ដូចកងទ័ពកំពុងច្បាំងគ្នា ។*

*ឧបមាដូចបុរសនោះអាស្រ័យដងព្រៃ ដែលពេញទៅដោយសត្វសាហាវជាដើម ភ័យខ្លាច ហើយរន្ធត់ ហើយព្រឺរោម ព្រឺស្បែក រមែងឃើញតែទោសដោយជុំវិញ យ៉ាងណា ព្រះយោគាវចរនោះ ក៏យ៉ាងនោះដូចគ្នា កាលសង្ខារទាំងឡាយប្រាកដហើយ ដោយភាពជាភ័យ ដោយអំណាចភយតូបដ្ឋានញាណ ... រមែងឃើញតែទោសប្រាសចាករសជាតិ អស់នូវការស្រស់បស់ដោយជុំវិញ អាទីនវានុបស្សនាញាណ រមែងកើតឡើងដល់ព្រះយោគីបុគ្គលនោះ ដែលឃើញយ៉ាងនេះ ។*

*ព្រះយោគីបុគ្គលនោះ កាលឃើញសង្ខារទាំងពួងដោយភាពជាទោសយ៉ាងនេះ រមែងនឿយណាយ ធុញទ្រាន់ មិនត្រេកអរក្នុងសង្ខារដែលមានការបែកធ្លាយទៅ ដែលប្រព្រឹត្តទៅក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួង ។ ដូចស្តេចហង្សមាស ដែលត្រេកអរក្រៃលែង ត្រង់ជើងភ្នំចិត្តកូដ រមែងមិនត្រេកអរនឹងអណ្តូងទឹកជិតទ្វារស្រុកមនុស្សចណ្ឌាល ដែលមិនស្អាត*

រមែងត្រេកអរក្នុងស្រះធំទាំង ៧ ប៉ុណ្ណោះយ៉ាងណា ស្តេចហង្ស គឺព្រះយោគី-បុគ្គលនេះ រមែងមិនត្រេកអរក្នុងសង្ខារ ដែលមានការបែកធ្លាយទៅ ដែលប្រកបដោយទោសដែលខ្លួនឃើញជាក់ច្បាស់ហើយ តែរមែងត្រេកអរក្រៃលែងក្នុងអនុបស្សនា ៧ ប៉ុណ្ណោះ ព្រោះប្រកបដោយសេចក្តីត្រេកអរក្នុងភាវនា គឺការពេញចិត្តក្នុងភាវនាក៏ដូច្នោះដូចគ្នា ដូចសីហមិគរាជត្រូវចាប់ឃាំងទុកសូម្បីក្នុងទ្រុងមាសក៏មិនត្រេកអរ តែរមែងត្រេកអរក្នុងហិមវន្តប្បទេសដ៏ធំធេង ទំហំ ៣០០០ យោជន៍ប៉ុណ្ណោះ យ៉ាងណា សីហៈ គឺព្រះយោគីបុគ្គលនេះ រមែងមិនត្រេកអរក្នុងសុគតិភពទាំង ៣ តែរមែងត្រេកអរក្នុងអនុបស្សនា ៣ ប៉ុណ្ណោះ ។

ដូចស្តេចដំរីឆទ្ទន្ត មានពណ៌សសុទ្ធមានទី ៧ ស្ថាន តាំងនៅដោយល្អ[1] ជាសត្វមានឫទ្ធិ ហោះទៅក្នុងអាកាសបាន រមែងមិនត្រេកអរនៅក្នុងកណ្តាលនគរ តែរមែងត្រេកអរក្នុងស្រះធំឈ្មោះឆទ្ទន្តក្នុងព្រៃហិមពាន្តប៉ុណ្ណោះ យ៉ាងណា ព្រះយោគីបុគ្គល ដូចដំរីប្រសើរនេះ រមែងមិនត្រេកអរក្នុងសង្ខារធម៌ទាំងពួង តែរមែងត្រេកអរក្នុងសន្តិបទ គឺព្រះនិព្វានប៉ុណ្ណោះ ដែលលោកសម្តែងហើយដោយន័យជាដើមថា ការមិនកើតឡើងជាទីក្សេម[2] មានចិត្តបង្អោនទៅទោរទន់ទៅក្នុងសន្តិបទ គឺព្រះនិព្វាននោះ ។ និព្វិទានុបស្សនាញាណ រមែងកើតឡើងហើយដល់ព្រះយោគីបុគ្គលនោះ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

## អដ្ឋកថាអាទីនវញ្ញាណុទ្ទេស ចប់

---

១- មានជើង ៤ កន្ទុយ ១ ចុងភេទអង្គជាត ១ ប្រមោយ ១ ដល់ផែនដី ។

២- បិដកលេខ ៦៩ ឃ្នាប ២២ ។

## ៩. អដ្ឋកថា

## សង្ខារុបេក្ខាញាណនិទ្ទេស

*បទថា* **មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ** *សេចក្តីថា ព្រះយោគីបុគ្គលណា មានបំណងប្រាថ្នាដើម្បីនឹងរួចផុត ដើម្បីនឹងលះបង់ ព្រោះហេតុនោះ ទើបព្រះយោគីបុគ្គលនោះ ឈ្មោះថា* **មុញ្ចិតុកម្យោ** *ប្រែថា អ្នកប្រាថ្នានឹងរួចផុត ភាពជាអ្នកប្រាថ្នានឹងរួចផុត ឈ្មោះថា* **មុញ្ចិតុ កម្យតា ។**

*បញ្ញាណារមែងពិចារណា រមែងត្រិះរិះ ព្រោះហេតុនោះ បញ្ញានោះទើបឈ្មោះថា* **បដិសង្ខា** *ម្យ៉ាងទៀត ការពិចារណា ឈ្មោះថា* **បដិសង្ខា ។**

*បញ្ញាណារមែងយល់ព្រម រមែងព្រងើយកន្តើយ ព្រោះហេតុនោះបញ្ញានោះឈ្មោះថា* **សន្តិដ្ឋនា** *ប្រែថា ព្រងើយ ។ ម្យ៉ាងទៀត ការព្រងើយ ឈ្មោះថា* **សន្តិដ្ឋនា ។**

*បញ្ញា ឈ្មោះថា មុញ្ចិតុកម្យតានោះផង បដិសង្ខាផង សន្តិដ្ឋនាផង ព្រោះហេតុនោះ ទើបឈ្មោះថា* **មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា** *ប្រែថា ការប្រាថ្នានឹងរួចផុត ការពិចារណា និងការព្រងើយកន្តើយ ។ ដោយប្រការដូច្នេះ ភាពជាអ្នកប្រាថ្នានឹងលោសចោលនូវការកើត ( ឧប្បាទ ) ជាដើម របស់ព្រះយោគីបុគ្គលអ្នកនឿយណាយ ដោយនិព្វិទាញាណក្នុងខាងដើម ឈ្មោះថា* **មុញ្ចិតុកម្យតា ។** *ការពិចារណាដើម្បីធ្វើឧបាយនៃការរួចផុត ត្រង់កណ្តាល ឈ្មោះថា* **បដិសង្ខា** *ការរួចផុតហើយព្រងើយក្នុងទីបំផុត ឈ្មោះថា* **សន្តិដ្ឋនា ។**

បញ្ញា ៣ ប្រការដោយប្រភេទនៃការកំណត់យ៉ាងនេះ ឈ្មោះថា បញ្ញាក្នុងការព្រងើយនូវសង្ខារទាំងឡាយ គប្បីជ្រាបថា បុគ្គលប្រាថ្នាការចូលទៅព្រងើយក្នុងសង្ខារដោយបញ្ញាទាំង ៣ មានប្រភេទនៃការកំណត់ ពោលគឺភាពជាអ្នកប្រាថ្នានឹងរួចផុត ( មុញ្ចិតុកម្យតា ) ការពិចារណាសង្ខារទាំងឡាយ ( បដិសង្ខា ) ការព្រងើយក្នុងសង្ខារទាំងឡាយ ( សន្តិដ្ឋនា ) ធ្វើជាពហុវចនៈថា **បញ្ញា** និង **សង្ខារុបេក្ខាសុ** តែធ្វើជាឯកវចនៈថា **ញាណំ** ព្រោះសូម្បីផ្សេងគ្នាដោយប្រភេទនៃការកំណត់ ក៏តែមួយដូចគ្នានោះឯង ។

ព្រះធម្មសេនាបតីសារីបុត្ត ពោលថា មុញ្ចិតុកម្យតាញាណណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី ធម៌ទាំងនោះមានសេចក្តីជាមួយគ្នា តែមានព្យញ្ជនៈផ្សេងគ្នា[១] ។ តែអាចារ្យពួកខ្លះ ពោលថា **សង្ខារុបេក្ខាសុ** នេះ ជាពហុវចនៈ ព្រោះសង្ខារុបេក្ខាជារបស់ច្រើនដោយអំណាចនៃសមថៈ និងវិបស្សនាដូច្នេះក៏មាន ។ ពាក្យថា **សង្ខារុបេក្ខាសុ** គប្បីជ្រាបថា សម្ពីងការធ្វើ ។

តែចិត្តរបស់ព្រះយោគីបុគ្គលអ្នកនឿយណាយ ធុញទ្រាន់ នៅដោយនិព្វិទាញាណនោះ ដោយប្រភេទនៃការកំណត់ រមែងមិនជាប់ រមែងមិនទើសទាក់ រមែងមិនជាប់ជំពាក់នៅក្នុងសង្ខារទាំងឡាយ ដែលមានការបែកធ្លាយទៅ ដែលនៅក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួង ចិត្តនោះ រមែងប្រាថ្នារួចផុត ប្រាថ្នានឹងរលាស់ចោលសង្ខារទាំងពួង ។

---

១- បិដកលេខ ៧០ ឃ្នាប ២១៦ ។

ម្យ៉ាងទៀត ដូចត្រីដែលជាប់នៅក្នុងសំណាញ់ កង្កែបដែលនៅក្នុងមាត់ពស់ មាន់ព្រៃដែលត្រូវក្រុងនៅក្នុងទ្រុង ម្រឹគដែលជាប់អន្ទាក់ ពស់ដែលនៅក្នុងកណ្តាប់ដៃអាលម្ពាយ ដំរីដែលដើរទៅធ្លាក់ក្នុងរណ្តៅធំ នាគរាជនៅក្នុងមាត់របស់គ្រុឌ ព្រះចន្ទដែលចូលទៅនៅក្នុងមាត់របស់រាហុ បុរសដែលត្រូវសត្រូវបោមព័ទ្ធទាំងនេះជាដើម សុទ្ធតែជាអ្នកប្រាថ្នាដើម្បីរួចផុត ដើម្បីនឹងរួចរដោះទៅចាកគ្រឿងចងនោះៗ ដូចគ្នាទាំងអស់ យ៉ាងណា ចិត្តរបស់ព្រះយោគីបុគ្គលនោះ រមែងប្រាថ្នានឹងរួចផុត ប្រាថ្នានឹងរួចរដោះចាកសង្ខារទាំងពួង ក៏យ៉ាងនោះ ។ កាលពោលបាឋៈយ៉ាងនេះថា **មុញ្ចិតុកាមស្ស មុញ្ចិតុកម្យតា** ប្រែថា ការប្រាថ្នារួចផុត របស់ព្រះយោគីបុគ្គលអ្នកប្រាថ្នានឹងរួចផុត ក៏រមែងត្រឹមត្រូវ ។ កាលបើដូច្នេះ ក៏គប្បីពោលបានថា **ឧប្បាទា មុញ្ចិតុកម្យតា** ជាដើម ក្នុងបទថា **ឧប្បាទំ មុញ្ចិតុកម្យតា** ជាដើម ព្រោះហេតុនោះ អត្ថមុននោះឯងប្រពៃជាង ។

ម្យ៉ាងទៀត មុញ្ចិតុកម្យតាញាណ រមែងកើតដល់ព្រះយោគីបុគ្គលនោះដែលដកនូវអាល័យក្នុងសង្ខារទាំងពួងហើយ ដែលប្រាថ្នានឹងលែងចោលនូវសង្ខារទាំងពួង ។ ព្រះយោគីបុគ្គលដែលប្រាថ្នាលែងចោលនូវសង្ខារទាំងឡាយ ដែលមានការបែកធ្លាយទៅ ដែលមានក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួងយ៉ាងនេះ រមែងលើកសង្ខារទាំងនោះឡើងកាន់ត្រៃលក្ខណ៍ ពិចារណាឃើញច្បាស់ដោយបដិសង្ខានុបស្សនាញាណទៀត ដើម្បីនឹងធ្វើឧបាយនៃការរួចផុតឲ្យសម្រេច ។ កាលព្រះយោគីបុគ្គលនោះ ឃើញច្បាស់យ៉ាងនេះឯង

បដិសង្ខាញាណ ដែលមាននិមិត្តដោយអនិច្ចលក្ខណៈរមែងកើតឡើង បដិ-សង្ខាញាណ ដែលប្រព្រឹត្តទៅដោយអំណាចជាទុក្ខលក្ខណៈរមែងកើតឡើង និងបដិសង្ខាញាណដែលមាននិមិត្ត និងប្រព្រឹត្តទៅដោយអំណាចជាអនត្តលក្ខណៈក៏រមែងកើតឡើង ។ ព្រះយោគីបុគ្គលនោះឃើញថា **សព្វេ សង្ខារា សុញ្ញា** គឺសង្ខារទាំងឡាយជារបស់ទទេដោយបដិសង្ខានុបស្សនាញាណហើយ ទើបលើកឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ។ លះនូវការខ្លាច និងការត្រេកអរចេញបាន រមែងព្រងើយ មានខ្លួនជាកណ្តាលក្នុងសង្ខារទាំងឡាយ ដូចបុរសឃើញទោសរបស់ភរិយាហើយ លះបង់ភរិយាទៅ ហើយព្រងើយមានខ្លួនជាកណ្តាលក្នុងភរិយានោះ ព្រះយោគីបុគ្គលនោះ រមែងមិនប្រកាន់ថា អញ ឬថា របស់អញ ។ ចិត្តរបស់ព្រះយោគីបុគ្គលនោះកាលដឹង ឃើញយ៉ាងនេះក៏រមែងគេចចេញ ថយត្រឡប់ វិលត្រឡប់ មិនត្រេកអរក្នុងភពទាំង ៣ ។ ដូចស្លឹកឈូកឱនទៅបន្តិច តំណក់ទឹកទាំងឡាយ រមែងហូរទៅ ថយត្រឡប់ វិលត្រឡប់មិនជន់លិច ឬដូចរោមមាន់ ឬសរសៃ និងស្បែកដែលគេដាក់ក្នុងភ្លើង រមែងខ្វាតចេញ រួញ មូរត្រឡប់ មិនរលាចេញ យ៉ាងណា ចិត្តរបស់ព្រះយោគីបុគ្គលនោះ រមែងគេចចេញ ថយត្រឡប់ វិលត្រឡប់ មិនត្រេកអរក្នុងភពទាំង ៣ ក៏យ៉ាងនោះ ឧបេក្ខារមែងតាំងមាំ ។ សង្ខារុបេក្ខាញាណ រមែងកើតឡើងហើយ ដល់ព្រះយោគីបុគ្គលនោះ ដោយប្រការដូច្នេះ ។

អនុលោមញ្ញាណ និងសង្ខារុបេក្ខាញាណនេះ ជាហេតុឲ្យសម្រេចគោត្រ-ភូញាណក្នុងខាងលើ សូម្បីមិនបានពោលទុក ដោយញាណដើម និងញាណ

ក្រោយ ក៏គប្បីជ្រាបថា រមែងឈ្មោះថាពោលហើយនោះឯង ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណាឃើញនូវសង្ខារនីមួយ ថាទៀង នឹងប្រកបដោយអនុលោមិកខន្តី ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះ មិនប្រកបដោយអនុលោមិកខន្តី នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះកាលមិនចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ[១] ដូច្នេះជាដើម ។

ព្រះធម្មសេនាបតីសារីបុត្តបានពោលពាក្យជាដើមថា

ភិក្ខុបាននូវអនុលោមិកខន្តីដោយអាការប៉ុន្មាន ចុះកាន់សម្មត្តនិយាមធម៌ដោយអាការប៉ុន្មាន ។ ភិក្ខុបាននូវអនុលោមិកខន្តី ដោយអាការ ៤០ ចុះកាន់សម្មត្តនិយាមធម៌ ក៏ដោយអាការ ៤០ ដែរ[១] ដូច្នេះ ។

ក្នុងបដ្ឋានប្បករណ៍ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា

អនុលោម ( ជាបច្ច័យ ) នៃគោត្រភូដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃវោទានៈដោយអនន្តរប្បច្ច័យ ។ ពិតហើយ កាលព្រះយោគីបុគ្គលនោះសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយនូវសង្ខារុបេក្ខាញាណនោះ អធិមោក្ខសទ្ធា ក៏រមែងមានកម្លាំងក្រៃលែង វីរិយៈក៏ផ្គងបានដោយល្អ

១- បិដកលេខ ៧១ ឃ្នាប ២០២ ។

១- បិដកលេខ ៧១ ឃ្នាប ២០៦ ។

សតិក៏មាំមួន ចិត្តក៏ជាសមាធិ សង្ខារុបេក្ខាញាណ ក៏រមែងប្រព្រឹត្តទៅក្លៀវក្លាជាង ។

សង្ខារុបេក្ខាញាណ របស់ព្រះយោគីបុគ្គលនោះ ពិចារណាសង្ខារទាំងឡាយ ថាមិនទៀង ជាទុក្ខ និងជាអនត្តា ហើយក៏ចុះកាន់ភវង្គដោយមនសិការថា មគ្គនឹងកើតឡើងក្នុងឥឡូវនេះ ។ បន្ទាប់អំពីភវង្គ មនោទ្វារាវជ្ជនៈក៏កើតឡើង ធ្វើសង្ខារទាំងឡាយ ដោយន័យដែលសង្ខារុបេក្ខាញាណធ្វើហើយនោះឯងឲ្យជាអារម្មណ៍ ថាមិនទៀង ជាទុក្ខ និងជាអនត្តា ។ បន្ទាប់ពីមនោទ្វារាវជ្ជនៈនោះ ជវនចិត្តក៏កើតឡើង ២ ខណៈ ៣ ខណៈ ឬ ៤ ខណៈ ទទួលយកសង្ខារទាំងឡាយ ធ្វើឲ្យជាអារម្មណ៍យ៉ាងនោះឯង ។ ញាណដែលសម្បយុត្តដោយជវនចិត្តនោះ ឈ្មោះថា អនុលោមញ្ញាណ ។

ពិតហើយ អនុលោមញ្ញាណនោះ រមែងអនុលោមតាមវិបស្សនាញាណ ៨ ខាងដើម ព្រោះមានកិច្ចយ៉ាងនោះ និងរមែងអនុលោមតាមពោធិបក្ខិយធម៌ ៣៧ ដែលជាធម៌គប្បីសម្រេចខាងមុខ ។

ដូចព្រះរាជាអ្នកទ្រទ្រង់ធម៌ គង់ប្រថាប់លើបល្ល័ង្កជាទីវិនិច្ឆ័យ ទ្រង់ស្តាប់ការវិនិច្ឆ័យរបស់មហាមាត្យដែលច្លាតឈ្លាសក្នុងវោហារ ៨ នាក់ ហើយទ្រង់លះអគតិ ដាក់ព្រះហឫទ័យជាកណ្តាល អនុមោទនាថា យ៉ាងនុ៎ះចុះ រមែងអនុលោមតាមការវិនិច្ឆ័យរបស់មហាមាត្យទាំង ៨ នាក់នោះ និងអនុលោមតាមបុរាណរាជធម៌ ។ ក្នុងឧបមានោះ អនុលោមញ្ញាណ ប្រៀបដូចព្រះរាជា វិបស្សនាញាណ ៨ ប្រៀបដូចមហាមាត្យដែលឈ្លាសក្នុងវោហារ ៨ នាក់

ពោធិបក្ខិយធម៌ ៣៧ ប្រៀបដូចបុរាណរាជធម៌ ព្រះរាជាអនុមោទនាថា ពិតយ៉ាងនោះចុះ ឈ្មោះថា រមែងអនុលោមតាមការវិនិច្ឆ័យរបស់ពួកមហាមាត្យដែលឈ្លាសក្នុងវោហារផង តាមរាជធម៌ផង យ៉ាងណា អនុលោមញ្ញាណក៏យ៉ាងនោះ រមែងអនុលោមតាមវិបស្សនាញាណ ៨ ដែលកើតឡើងប្រារព្ធសង្ខារទាំងឡាយ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ព្រោះមានកិច្ចយ៉ាងនោះ និងរមែងអនុលោម តាមពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលជាធម៌គប្បីសម្រេចខាងមុខ ។ ព្រោះហេតុនោះ ទើបញ្ញាណនេះ លោកហៅថា អនុលោមញ្ញាណ ៕

## អដ្ឋកថាសង្ខារុបេក្ខាញាណុទ្ទេស ចប់

## ១០. អដ្ឋកថា

## គោត្រភូញាណនិទ្ទេស

ក្នុងបទថា **ពហិទ្ធា វុដ្ឋានវិវដ្តនេ បញ្ញា គោត្រភូញាណំ** នេះ មាន វិនិច្ឆ័យដូចតទៅ

បទថា **ពហិទ្ធា** បានដល់ សង្ខារនិមិត្ត ។ សង្ខារនិមិត្តនោះ លោកពោលថា ពហិទ្ធា ព្រោះអាស្រ័យអកុសលក្ខន្ធក្នុងចិត្តសន្តានក្នុងខាងក្នុង ។ គោត្រភូញាណនោះ រមែងចេញអំពីសង្ខារនិមិត្តខាងក្រៅ គឺទៅប្រាសហើយ តាំងនៅខាងលើ ព្រោះហេតុនោះ ទើបគោត្រភូញាណនោះ ឈ្មោះថា **វុដ្ឋាន** ( ការចេញ ) ។ គោត្រភូញាណនោះ រមែងចៀសចេញ រមែងវិលត្រឡប់ គឺបែរក្រោយ ព្រោះហេតុនោះ ទើបគោត្រភូញាណនោះ ឈ្មោះថា **វិវដ្ដន** ( ការចៀសទៅ ) ។ វុដ្ឋានទោះផង វិវដ្ដនៈនោះផង ឈ្មោះថា **វុដ្ឋានវិវដ្តន** គឺការចេញ និងការចៀសចេញទៅ ។ ព្រោះហេតុនោះ ទើបព្រះពុទ្ធឃោសាចារ្យពោលថា គោត្រភូញាណមិនទាន់ចេញអំពីកិលេស និងខន្ធដែលនៅប្រព្រឹត្តទៅ ព្រោះកាត់សមុទយៈមិនដាច់ តែចេញអំពីនិមិត្តបាន ព្រោះមានព្រះនិព្វានជាអារម្មណ៍ ហេតុនោះទើបឈ្មោះថា **ឯកតោវុដ្ឋាន** គឺចេញពីសង្ខារនិមិត្តដោយចំណែកមួយ ។

ឈ្មោះថា **គោត្រភូ** ព្រោះគ្របសង្កត់នូវបុថុជ្ជនគោត្ត និងព្រោះឈានឡើងកាន់អរិយគោត្ត ។ គោត្រភូញាណនេះ ធ្វើព្រះនិព្វានដែលមិនមាននិមិត្តឲ្យជាអារម្មណ៍បន្ទាប់អំពីការសេពអនុលោមញ្ញាណ របស់ចិត្តដែលនឿយណាយចាកសង្ខារទាំងពួង ព្រោះអនុលោមញ្ញាណទាំងឡាយ ដូចទឹកធ្លាក់អំពីស្លឹក

ឈ្មោះ ឈានកន្លងនូវបុថុជ្ជនគោត្ត ដែលរាប់បានថា បុថុជ្ជន ភូមិនៃបុថុជ្ជន ឈានចុះកាន់គោត្តនៃអរិយៈដែលរាប់ថាអរិយៈ ភូមិនៃអរិយៈឲ្យសម្រេចភាពជាបច្ច័យដល់មគ្គដោយអាការ ៦ គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អាសេវនប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ដែលជាការប្រព្រឹត្តទៅក្នុងគ្រាដំបូង ដែលជាការសេពក្នុងគ្រាដំបូង ដែលជាការប្រជុំព្រមគ្នាក្នុងគ្រាដំបូងក្នុងអារម្មណ៍ គឺនិព្វាន ដល់នូវកំពូលជាទីបំផុតនៃវិបស្សនា រមែងកើតឡើង ធ្វើឲ្យជាសភាពដែលឲ្យវិលត្រឡប់មកវិញទៀតមិនបាន ។ល។

## អដ្ឋកថាគោត្រភូញាណុទ្ទេស ចប់

# ១១. អដ្ឋកថា

## មគ្គញ្ញាណុទ្ទេស

ក្នុងបទថា **ឧភតោ វុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ** នេះ មានវិនិច្ឆ័យដូចតទៅ

បទថា **ឧភតោ** បានដល់ ទាំង ២ យ៉ាងទៀត មានពាក្យអធិប្បាយថា ទាំងគូ ៗ មគ្គញ្ញាណរមែងចេញ រមែងវិលត្រឡប់ចាកកិលេសទាំងឡាយ និងចាកខន្ធដែលប្រព្រឹត្តទៅតាមកិលេសទាំងនោះ ព្រោះកាត់កិលេសទាំងឡាយបាន និង ( វិលត្រឡប់ ) ចាកសង្ខារនិមិត្តទាំងពួងខាងក្រៅ ព្រោះធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ហេតុនោះ ទើបឈ្មោះថា **ឧភតោ វុដ្ឋានវិវដ្ដនេ បញ្ញា** ។ ព្រោះហេតុនោះ ទើបព្រះពុទ្ធឃោសាចារ្យពោលថា មគ្គញ្ញាណសូម្បីទាំង ៤ ចេញចាកពីនិមិត្ត ព្រោះមានព្រះនិព្វានដែលមិនមាននិមិត្តជាអារម្មណ៍ និងរមែងចេញចាកកិលេស និងខន្ធដែលប្រព្រឹត្តទៅ ព្រោះកាត់សមុទយៈបាន ហេតុនោះ ទើបឈ្មោះថា **ឧភតោវុដ្ឋាន** គឺចេញដោយចំណែកទាំង ២ ដូច្នេះ ។

ធម្មជាតណារមែងខ្វល់ខ្វាយ រមែងសម្លឹងមើលព្រះនិព្វាន ឬធម្មជាតណាដែលព្រះយោគីបុគ្គលអ្នកត្រូវការព្រះនិព្វានរមែងខ្វល់ខ្វាយ គឺរមែងស្វែងរក ឬធម្មជាតណាញ៉ាំងកិលេសទាំងឡាយឲ្យស្លាប់ទៅ ប្រព្រឹត្តទៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា មគ្គ ញាណក្នុងមគ្គនោះ ឈ្មោះថា **មគ្គេ ញាណំ** មគ្គញ្ញាណលោកធ្វើជាឯកវចនៈ ៗ មគ្គញ្ញាណលោកធ្វើជាឯកវចនៈដោយជាតិសព្ទ ៗ ក៏មគ្គញ្ញាណនោះ កើតឡើងធ្វើព្រះនិព្វានឲ្យជាអារម្មណ៍

*តអំពីគោត្រភូញាណ លះបង់កិលេសដែលទីងគប្បីសម្លាប់បាន ដោយមិនមានចំណែកសេសសល់ ដុតបំផ្លាញនូវសមុទ្ទ គឺទុក្ខក្នុងសង្សារវដ្តដែលមានខាងដើម និងទីបំផុត ដែលបុគ្គលដឹងមិនបាន ឲ្យរីងស្ងួតទៅ បិទទ្វារអបាយទាំងពួង ធ្វើអរិយទ្រព្យ ៧ ឲ្យប្រាកដនៅចំពោះមុខ លះមិច្ឆាមគ្គប្រកបដោយអង្គ ៨ ធ្វើពៀរ និងភ័យទាំងពួងឲ្យស្ងប់ នាំខ្លួនចូលកាន់ភាពជាបុត្តនៃព្រះសម្មាសម្ពុទ្ធ និងបាននូវអានិសង្សដទៃៗ ទៀត ច្រើនរយ ដូចពាក្យដែលលោកពោលថា*

*បុរសប្រាថ្នានឹងលោតឆ្លងស្ទឹងតូច ឡើងទៅឈរនៅលើមាត់ច្រាំងខាងនាយ ទើបចាប់ខ្សែ ឬកំណាត់ឈើដែលជាប់នៅនឹងដើមឈើលើត្រើយអាយ ហើយលោតឆ្លងទៅដោយរហ័សរហូតខ្លួនទៅធ្លាក់នៅលើត្រើយនាយ កាលខ្លួនធ្លាក់ត្រង់ត្រើយនាយហើយ ក៏លះនូវការញាប់ញ័រនោះ ឡើងលើត្រើយបានយ៉ាងណា ព្រះយោគីបុគ្គលដែលឃើញភ័យ ក្នុងត្រើយអាយដែលប្រកបដោយសក្កាយទិដ្ឋិ ប្រាថ្នាឆ្លងផុតកិលេសទាំងឡាយហើយឈរត្រង់ត្រើយ គឺព្រះនិព្វានដែលមិនមានភ័យ ទើបចាប់ខ្សែ គឺរូបក្ខន្ធជាទីតោង លោតទៅដោយរហ័សដោយឧទយព្វយានុបស្សនាជាខាងដើម ឬចាប់ឈើ គឺនាមខន្ធនោះទុកដោយល្អ លោតទៅដោយអាវជ្ជនចិត្តដោយន័យតាមដែលពោលហើយក្នុងកាលមុន លោតឡើងដោយអនុលោមញាណ*

ហើយបង្អោនទៅក្នុងព្រះនិព្វាន ចូលទៅកាន់ទីជិតនៃព្រះនិព្វាន នោះ លះនូវការញាប់ញ័រនោះបានដោយគោត្រភូញាណ ដែលមិនធ្លាប់សេពហើយ ធ្លាក់ចុះត្រង់ត្រើយដទៃនៃសង្ខតធម៌ បន្ទាប់អំពីនោះ ក៏តាំងនៅដោយមគ្គញ្ញាណយ៉ាងនោះ ។ នរជនប្រាថ្នាមើលព្រះចន្ទ ក្នុងវេលាដែលព្រះចន្ទត្រូវពពកបិទបាំង កាលពពកត្រូវព្យុះបក់ទៅតាមលំដាប់ អំពីស្រទាប់ដែលក្រាស់ស្តើងបន្តិចម្តងៗ ក៏ឃើញព្រះចន្ទបានយ៉ាងណា គោត្រភូញាណដែលកំពុងសម្លឹងអមតនិព្វាន កាលមោហៈដែលបិទបាំងសច្ចៈត្រូវទម្លាយឲ្យវិនាសទៅ ដោយអនុលោមញ្ញាណតាមលំដាប់ក៏យ៉ាងនោះដូចគ្នា អនុលោមញ្ញាណ ក៏មិនបានឃើញអមត-និព្វានដូចខ្យល់ទាំងនោះ មិនបានឃើញព្រះចន្ទ គោត្រភូញាណក៏កម្ចាត់ភាពងងឹតមិនបាន ដូចបុរសបន្ទោបង់ពពកអ័ព្ទមិនបាន តែមគ្គញ្ញាណនេះ ប្រព្រឹត្តទៅក្នុងព្រះនិព្វាន មិនបានលះសញ្ញាដែលគោត្រភូញាណឲ្យឡើយ ទើបទម្លាយគំនរកិលេស មានគំនរលោភៈជាដើមបាន ដូចចក្កយន្តដែលវិលដោយកម្លាំងបង្វិល ហើយនាយខ្មាន់ធ្នូឈរតម្រង់បាញ់ហើយ លុះអ្នកដទៃឲ្យសញ្ញាហើយ ក៏បាញ់ព្រួញទៅទម្លុះនូវក្តារប៉ាយរាប់រយ ដូច្នោះមគ្គញ្ញាណនោះឯងធ្វើសមុទ្ទធំ គឺសង្សារទុក្ខឲ្យរីងស្ងួតទៅ បិទទ្វារទុគ្គតិបាន ធ្វើមនុស្សដែលមានបំណុល គឺកិលេសឲ្យជា

សេដ្ឋបុគ្គល អ្នកសម្បូរណ៍ដោយអរិយទ្រព្យ លះមិច្ឆាមគ្គ បាន ។ ធ្វើពៀរ និងភ័យទាំងឡាយឲ្យស្ងប់ ធ្វើខ្លួនឲ្យជាកូន អ្នកកើតពីទ្រូងនៃព្រះពុទ្ធ ជាទីពឹងរបស់លោក ញាណនេះ រមែងបាននូវអានិសង្សដទៃទៀតច្រើនរយ ៕៚

## អដ្ឋកថាមគ្គញ្ញាណុទ្ទេស ចប់

## ១២. អដ្ឋកថា

## ផលញ្ញាណុទ្ទេស

ក្នុងបទថា **បយោគប្បដិប្បស្សទ្ធិប្បញ្ញា ផលេ ញាណំ** នេះ មានវិនិច្ឆ័យដូចតទៅ

បទថា **បយោគ** បានដល់ ការប្រកបយ៉ាងខ្ជាំងក្លា គឺសេចក្ដីព្យាយាមដែលចេញអំពីកិលេសក្ខន្ធ និងសង្ខារទាំង ២ បានដោយមគ្គភាវនា ដោយធ្វើឲ្យច្បាស់នូវផល សេចក្ដីស្ងប់រម្ងាប់ គឺដល់ទីបំផុតនៃយោគៈនោះ ឈ្មោះថា **យោគប្បដិប្បស្សទ្ធិ** ។ យោគប្បដិប្បស្សទ្ធិនោះដូចម្ដេច គឺការអស់នូវកិច្ចក្នុងមគ្គទាំង ៤ ។

បញ្ញាក្នុងផលដែលប្រព្រឹត្តទៅហើយ ព្រោះបយោគប្បដិប្បស្សទ្ធិនោះជាហេតុឈ្មោះថា **បយោគប្បដិប្បស្សទ្ធិបញ្ញា** ។ បញ្ញានេះជាផល ព្រោះអត្ថថារមែងឲ្យនូវផល គឺរមែងឲ្យកើតវិបាកញ្ញាណក្នុងផលនោះ គឺដែលសម្បយុត្តដោយផលចិត្តនោះ ឈ្មោះថា **ផលេ ញាណំ** ។ បន្ទាប់អំពីមគ្គញាណមួយៗ ផលចិត្តដែលជាវិបាកនៃមគ្គចិត្តនោះៗ ឯង មានព្រះនិព្វានជាអារម្មណ៍កើតឡើង ៣ ខណៈក៏មាន ២ ខណៈក៏មាន ១ ខណៈក៏មាន ។ ព្រោះផលចិត្តនោះ ជាវិបាកកើតឡើងក្នុងលំដាប់នៃលោកុត្តរកុសលទាំងឡាយ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ខុទ្ទកបាឋៈ ) ថា បណ្ឌិតទាំងឡាយ ពោលហើយនូវសមាធិណា ថាជាធម៌ឲ្យផលដោយលំដាប់ ដូច្នេះ និងព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា បុគ្គលនោះ រមែងសម្រេចអនន្តរិយគុណ

( មគ្គសមាធិដែលឲ្យផលជាលំដាប់ ) ដើម្បីអស់អាសវៈទាំងឡាយ បាន យឺតយូរ ដូច្នេះជាដើម ។ ព្រះយោគីបុគ្គលដែលមានអនុលោមចិត្ត ២ ខណៈ ខណៈទី ៣ ជាគោត្រភូ ខណៈទី ៤ ជាមគ្គចិត្ត ផលចិត្ត ៣ ខណៈទៀត ( រួមជា ៧ ខណៈតាមជវននិយាម ) ។ ព្រះយោគីបុគ្គលដែលមាន អនុលោមចិត្ត ៣ ខណៈ ខណៈទី ៤ ជាគោត្រភូ ខណៈទី ៥ ជាមគ្គចិត្ត ផលចិត្ត ២ ខណៈទៀត ( រួម ជា ៧ ខណៈ ) ។ ព្រះយោគីបុគ្គលដែល មានអនុលោមចិត្ត ៤ ខណៈ ខណៈទី ៥ ជាគោត្រភូ ខណៈទី ៦ ជា មគ្គចិត្ត មានផលចិត្ត ១ ខណៈទៀត ។ នេះជាផលក្នុងមគ្គវីថិ ។ ចំណែក ផលក្នុងរវាងកាលដែលកើតឡើង ដោយអំណាចសមាបត្តិ និងកើតឡើង ដល់អ្នកចេញពីនិរោធសមាបត្តិ ក៏សង្គ្រោះដោយផលញាណនេះដូចគ្នា ។៕

## អដ្ឋកថាផលញាណុទ្ទេស ចប់

## ១៣. អដ្ឋកថា

## វិមុត្តិញ្ញាណុទ្ទេស

បទថា **ឆិន្នវដុមានុបស្សនេ បញ្ញា** បានដល់ បញ្ញាក្នុងការឃើញខាងក្រោយនូវឧបក្កិលេសនោះៗ ដែលអរិយមគ្គនោះៗ កាត់ផ្ដាច់ហើយ ។

បទថា **វិមុត្តិញ្ញាណំ** បានដល់ ញាណក្នុងវិមុត្តិ ។

បទថា **វិមុត្តិ** បានដល់ ចិត្តដែលរួចផុតចាកឧបក្កិលេសទាំងឡាយ គឺបរិសុទ្ធហើយ ឬភាពដែលចិត្តនោះរួចផុតហើយ ញាណ គឺការដឹងក្នុងវិមុត្តិនោះ ឈ្មោះថា វិមុត្តិញ្ញាណ ។ លោកពោលអធិប្បាយការពិចារណាកិលេសដែលលះហើយដោយញាណនេះថា ព្រះអរិយបុគ្គល កាលពិចារណាការបន្តនៃចិត្តដែលរួចផុតចាកកិលេសហើយក្តី ឲ្យនូវការរួចផុតចាកកិលេសក្តី វៀរកិលេសចេញ ក៏ពិចារណាមិនបាន ។ និងដូចព្រះតម្រាស់ ( ក្នុងវិនយបិដក ) ថា កាលដែលចិត្តផុតស្រឡះ ( ចាកអាសវៈ ) ហើយ ញាណ ( របស់អរិយសាវ័កនោះ ) ក៏កើតឡើងប្រាកដថា ចិត្ត ( របស់អញ ) ផុតស្រឡះ ( ចាកអាសវៈ ) ហើយ ដូច្នេះ ។ ពាក្យនេះ ទ្រង់ត្រាស់សំដៅយកវិមុត្តិញ្ញាណនេះឯង ។ ចំណែកការពិចារណាកិលេសដែលនៅសេសសល់ សូម្បីមិនបានពោលហើយ ក៏គប្បីកាន់យកថា ជាការពោលហើយ ដោយវិមុត្តិញ្ញាណនេះឯងសមដូចលោកពោលថា

ក្នុងធម៌ឯណានីមួយ ដែលពោលហើយ ធម៌ពួកណា មាន
លក្ខណៈដូចគ្នានឹងធម៌នោះ ធម៌ទាំងអស់នោះ ឈ្មោះថា

ពោលហើយ ធម៌ឯណានីមួយ ដែលមានលក្ខណៈតាមដែល
ពោលហើយ ជាបែបឲ្យកាន់យកបាន ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ឈ្មោះថា ពោលដល់ការពិចារណាកិលេស ដែលលះហើយដល់ព្រះអរិយបុគ្គល ៤ នឹងគប្បីបាន ព្រោះព្រះអរហន្តមិនមានការពិចារណាកិលេសដែលនៅសេសសល់ឡើយ ៕

## អដ្ឋកថាវិមុត្តិញ្ញាណុទ្ទេស ចប់

## ១៤.អដ្ឋកថា

## បច្ចវេក្ខណាញ្ញាណុទ្ទេស

បទថា **តទា សមុទាគតេ ធម្មេ បស្សនេ បញ្ញា** សេចក្ដីថា បញ្ញាជាគ្រឿងឃើញ សម្ដីង ដឹងក្នុងធម៌ គឺមគ្គ និងផល ទាំងក្នុងធម៌ គឺសច្ចៈ ៤ ដែលកើតឡើងក្នុងមគ្គក្ខណៈ និងផលក្ខណៈ គឺមកព្រមហើយ ដល់ព្រមហើយ ប្រជុំគ្នាក្នុងកាលនោះ ដោយអំណាចការបានចំពោះ និងដោយអំណាចនៃការចាក់ធ្លុះ ។ បទថា **បច្ចវេក្ខណេ ញាណំ** បានដល់ ញាណជាគ្រឿងពិចារណាត្រឡប់មកឃើញដឹងច្បាស់ ។ បច្ចវេក្ខណញ្ញាណ លោកពោលដោយញាណទាំង ២ នេះ ។

ក្នុងទីបំផុតនៃសោតាបត្តិផលក្នុងមគ្គវិថី ចិត្តរបស់ព្រះសោតាបន្នក៏ចុះកាន់ភវង្គ បន្ទាប់ពីនោះ មនោទ្វារាវជ្ជនៈក៏កើតឡើងកាត់ផ្ដាច់នូវភវង្គ ដើម្បីពិចារណាមគ្គ កាលមនោទ្វារាវជ្ជនៈនោះ រលត់ហើយ ជវនចិត្តពិចារណាមគ្គក៏កើតឡើង ៧ ខណៈ ដោយលំដាប់ដូច្នេះឯង ។ បន្ទាប់មក ក៏ចុះកាន់ភវង្គទៀត អាវជ្ជនចិត្តជាដើមក៏កើតឡើង ដើម្បីពិចារណាធម៌ទាំងឡាយ មានផលជាដើម ដោយន័យនោះឯង ។ ព្រោះការកើតឡើងនៃអាវជ្ជនៈពួកណា ព្រះសោតាបន្ននោះ រមែងពិចារណាមគ្គ ផល កិលេសដែលលះហើយ កិលេសដែលនៅសល់ និងព្រះនិព្វាន ។

ព្រះសោតាបន្ននោះពិចារណាមគ្គថា អាត្មាអញសម្រេចហើយដោយមគ្គនេះហ្ន៎ បន្ទាប់អំពីនោះ ក៏ពិចារណាផលថា អានិសង្សនេះអញបានហើយ បន្ទាប់អំពីនោះ ក៏ពិចារណាកិលេសដែលលះហើយថា ដែលឈ្មោះថា កិលេសទាំងនេះអញលះបានហើយ បន្ទាប់អំពីនោះ ក៏ពិចារណាកិលេសដែលមគ្គខាងលើ

គប្បីលះថា កិលេសទាំងនេះរបស់អញនៅសេសសល់ ក្នុងទីបំផុតក៏ពិចា-រណាអមតនិព្វានថា ធម៌នេះអញបានហើយ ដោយភាពជាអារម្មណ៍ ។ ព្រះអរិយសាវកជាសោតាបន្ន មានបច្ចវេក្ខណៈ ៥ យ៉ាង ដោយប្រការដូច្នេះ ។ បច្ចវេក្ខណៈរបស់ព្រះសកទាគាមី និងព្រះអនាគាមីក៏មានដូចព្រះសោតាបន្ន ។ តែចំពោះព្រះអរហន្ត មិនមានការពិចារណាកិលេសដែលនៅសេសសល់ ព្រោះហេតុនោះ ទើបមានបច្ចវេក្ខណៈ ៤ ប៉ុណ្ណោះ ។ រួមបច្ចវេក្ខណញ្ញាណទាំងអស់ មាន ១៩ ដោយប្រការដូច្នេះ ។ នេះជាការកំណត់យ៉ាងឧក្រិដ្ឋ ។ ការពិចារណាកិលេសដែលលះបានហើយ និងដែលនៅសេសសល់ នឹងមានដល់ព្រះសេក្ខៈទាំងឡាយក៏បាន មិនមានក៏បាន ។ ព្រោះការពិចារណានោះមិនមាន ទើបព្រះបាទមហានាមសក្យរាជ ទូលសួរព្រះមានព្រះភាគ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ចុះធម៌អ្វីហ្ន៎ នៅខាងក្នុងសន្ដានដែលអាត្មាអញមិនទាន់លះអស់បាន ជាជួនកាល ធម៌ គឺលោភៈ គ្របសង្កត់ចិត្តរបស់អាត្មាអញខ្លះ ដូច្នេះជាដើម ។

ក្នុងទីនេះ ដើម្បីឲ្យញាណ ១១ មានធម្មដ្ឋិតិញ្ញាណជាដើមជាក់ច្បាស់ គប្បីជ្រាបឧបមាដូចតទៅ

ប្រៀបដូចបុរសគិតថា អញនឹងចាប់ត្រី ទើបកាន់យកអង្រុតទៅរុតក្នុងទឹក ដែលគិតថា គួរមានត្រី ហើយទើបលូកដៃតាមមាត់អង្រុត ហើយក៏ស្រវាចាប់កពស់វែកដែលនៅក្នុងទឹក ដោយសម្គាល់ថាជាត្រី ត្រេកអរ គិតថា អញបានត្រីធំ ហើយក៏លើកឡើង លុះឃើញ ក៏ដឹងថាពស់ ព្រោះឃើញប្រឡៅ-ក

៣ ជាន់ កើតនូវការខ្លាច ឃើញទោស ជិនណាយក្នុងការចាប់ ប្រាថ្នានឹងលែងចោល ទើបធ្វើឧបាយដើម្បីនឹងលែងចោល ក៏ចាប់ពស់ឲ្យរលាចេញអំពីដៃ តាំងអំពីចុងកន្ទុយឡើងមក ហើយលើកដៃឡើងគ្រវីលើក្បាល ២-៣ ជុំ ធ្វើពស់ឲ្យអស់កម្លាំងហើយ បោះទៅ មួយអន្ទើដោយពោលថា វ៉ឺយទៅចុះ ពស់កាច ហើយលោតឡើងទៅឈរលើគោកដោយរហ័សនោះឯងកើតនូវសោមនស្សថា ឱ អញផុតហើយចាកមាត់ពស់ធំ ហើយសម្លឹងមើលផ្លូវដែលខ្លួនមក ។

ក្នុងសេចក្ដីនោះ មានឧបមេយ្យដូចតទៅនេះថា ការប្រកាន់មាំនូវខន្ធ ៥ ដែលគួរខ្លាចដោយអំណាចនៃលក្ខណៈ មានការមិនទៀងជាដើម ដោយសម្គាល់ថា ទៀង ដោយតណ្ហាដែលសម្បយុត្តដោយទិដ្ឋិថា អញ របស់អញ ហើយត្រេកអររបស់ព្រះយោគីបុគ្គលនេះ ដែលជាពាលបុថុជ្ជនក្នុងខាងដើម ដូចការចាប់ពស់វែកយ៉ាងមាំ ដោយសម្គាល់ថា ជាត្រី ហើយត្រេកអររបស់បុរសនោះ ។

ការទម្លាយឃនសញ្ញា ដោយការកំណត់នាមរូប ព្រមទាំងបច្ច័យ ហើយឃើញត្រៃលក្ខណ៍ មានការមិនទៀងជាដើមនៃខន្ធ ៥ ដោយញាណ មានការពិចារណាដោយភាពជាកលាបៈជាដើមហើយ កំណត់ខន្ធ ៥ នោះថា មិនទៀង ជាទុក្ខ ជាអនត្តា ដូចការនាំពស់ចេញពីមាត់អង្រុត ហើយឃើញប្រឡៅ-ក ៣ ជាន់ ក៏ដឹងថាពស់ របស់បុរសនោះ ។

ភយតូបដ្ឋានញាណរបស់ព្រះយោគីបុគ្គលនេះ ដូចការខ្លាចរបស់បុរស

នោះ ។ អាទីនវានុបស្សនាញាណ ដូចការឃើញទោសក្នុងពស់ ។ និព្វិទានុ-បស្សនាញាណ ដូចការក្រែងរអាក្នុងការចាប់ពស់ ។ មុញ្ចិតុកម្យតាញាណ ដូចការប្រាថ្នានឹងរលាស់ពស់ទៅឲ្យផុត ។ បដិសង្ខានុបស្សនាញាណ ដូចការធ្វើឧបាយដើម្បីនឹងរលាស់ពស់ឲ្យផុត ។ ការពិចារណាដោយជុំវិញនូវសង្ខារទាំងឡាយ ដោយសង្ខារុបេក្ខាញាណ និងអនុលោមញាណ ដោយការលើកឡើងកាន់ត្រៃលក្ខណ៍ ហើយធ្វើឲ្យទុព្វល រហូតមិនអាចនឹងប្រាកដដោយអាការថា ទៀង ជាសុខ និងជាអត្តាបានទៀត ដូចការលើកពស់ឡើងគ្រវីទៅជុំវិញ ធ្វើឲ្យទុព្វល រហូតមិនអាចវិលត្រឡប់មកចឹកបានទៀត ។

គោត្រភូញាណ ដូចការគ្រវាត់ពស់ចោលទៅ ។ មគ្គញាណ ផលញាណ ឈានឡើង តាំងនៅលើគោក គឺព្រះនិព្វាន ដូចការគ្រវាត់ពស់ចោលទៅ ហើយឡើងទៅឈរលើគោក ។ ញាណ គឺការពិចារណាមគ្គជាដើម ដូចការសម្លឹងមើលផ្លូវដែលមកហើយ របស់បុរសដែលត្រេកអរ ។

បណ្ដាបច្ចវេក្ខណញ្ញាណទាំងឡាយនោះ គប្បីជ្រាបថា ការពិចារណាកិលេសជាលំដាប់ដំបូងតពីនោះ ទើបជាការពិចារណាមគ្គ ផល និងនិព្វាន ព្រោះលំដាប់នៃទេសនា ដែលព្រះយោគីបុគ្គលធ្វើហើយ តាមលំដាប់នៃការកើតឡើងនៃញាណទាំង ១៤ នេះ មានសុតមយញ្ញាណជាដើម និងតាមលំដាប់នៃកិច្ចបដិបត្តិ ។

ភាពដែលការពិចារណាកិលេស តាមសមគួរដល់កិច្ចបដិបត្តិនោះឯង ជាលំដាប់ដំបូង រមែងត្រឹមត្រូវ ព្រោះលោកពោលកិច្ចបដិបត្តិមគ្គ ដោយធ្វើការ

លះកិលេសនោះឯង ឲ្យជាគោលសំខាន់ថា បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ជាឈានដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីធ្វើកាមរាគ និងព្យាបាទឲ្យស្រាលស្តើង ដើម្បីលះបង់នូវកាមរាគ និងព្យាបាទឲ្យអស់រលីង ដើម្បីលះបង់នូវកាមរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជាឲ្យអស់រលីង[១] ក៏លោកសម្តែងលំដាប់ តាមដែលពោលក្នុងអដ្ឋកថាហើយនោះឯង ។

លំដាប់នោះ មាន ៥ យ៉ាង គឺលំដាប់នៃការកើតឡើង លំដាប់នៃការលះ លំដាប់នៃកិច្ចបដិបត្តិ លំដាប់នៃភូមិ លំដាប់នៃទេសនា ។

លំដាប់យ៉ាងនេះ ( សំយុត្តនិកាយ សគាថវគ្គ ) ថា

កលលរូបកើតជាដំបូង តពីកលលរូបមក កើតជាអម្ពុទរូប តពីអម្ពុទរូបមក កើតជាបេសិរូប តពីបេសិរូបមក កើតជាឃនរូប ដូច្នេះជាដើម ឈ្មោះថា លំដាប់នៃការកើត ។

លំដាប់យ៉ាងនេះ ( ធម្មសង្គណិ ) ថា ពួកធម៌ដែលត្រូវលះដោយទស្សនៈ ពួកធម៌ដែលត្រូវលះដោយភាវនាដូច្នេះជាដើម ឈ្មោះថា លំដាប់នៃការលះ ។

លំដាប់យ៉ាងនេះ ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា សីលវិសុទ្ធិ ចិត្តវិសុទ្ធិ ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិដូច្នេះជាដើម ឈ្មោះថា លំដាប់នៃកិច្ចបដិបត្តិ ។

---

១- បិដកលេខ ៧៨ ឃ្នាប ១៩៦-២៧៣ ។

លំដាប់យ៉ាងនោះ ( ធម្មសង្គណិ ) ថា ពួកធម៌ជាកាមាវចរ ពួកធម៌ជារូបាវចរ ពួកធម៌ជាអរូបាវចរ ដូច្នេះជាដើម ឈ្មោះថា លំដាប់នៃភូមិ ។

លំដាប់យ៉ាងនេះ ( ខុទ្ទកនិកាយ មហានិទ្ទេស ) ថា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូច្នេះជាដើម ឬលំដាប់យ៉ាងនេះ ( វិនយបិដក មហាវគ្គ ) ថា ទើបព្រះដ៏មានព្រះភាគទ្រង់សម្តែងអនុបុព្វីកថា ព្រះអង្គសម្តែងអនុបុព្វីកថាដូចម្តេច គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា និងទោសនៃកាមទាំងឡាយដ៏លាមក ដ៏សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ( បួស ) ដូច្នេះជាដើម ឈ្មោះថា លំដាប់នៃទេសនា ។

តែក្នុងទីនេះ គប្បីជ្រាបថា សំដៅយកលំដាប់ ៣ ប្រការ គឺលំដាប់នៃការកើតឡើងនៃញាណ ១៤ លំដាប់នៃកិច្ចបដិបត្តិ និងលំដាប់នៃទេសនា ព្រោះសម្តែងតាមលំដាប់ ដោយអំណាចលំដាប់ទាំង ២ នោះ ៕

## អដ្ឋកថាបច្ចវេក្ខណាញាណុទ្ទេស ចប់

## ១៥. អដ្ឋកថា

## វត្ថុនានត្តញ្ញាណនិទ្ទេស

ព្រោះនាមរូបវវត្ថានញ្ញាណ លោកមិនទាន់បានពោលសរុប ហេតុនោះ ដើម្បីនឹងសម្ដែងប្រភេទនៃនាមរូប ៥ យ៉ាងក្នុងឥឡូវនេះ ទើបលោកលើកយក ញាណ ៥ សម្ដែងថា **អជ្ឈត្តវវត្ថានេ បញ្ញា វត្ថុនានត្តេ ញាណំ** ដូច្នេះ ជាដើម ។ ពិតហើយ ក្នុងនាមរូបទាំងអស់ដែលលោកពោលហើយ នាមរូប ណាអាចកំណត់បាន និងនាមរូបណាគួរកំណត់ បញ្ញាក៏កំណត់នាមរូបនោះ ។ ចំណែកនាមដែលជាលោកុត្តរ មិនអាចនឹងកំណត់បាន ព្រោះនៅមិនទាន់ សម្រេច និងមិនគួរកំណត់ ព្រោះនាមដែលជាលោកុត្តរ មិនមែនជាអារម្មណ៍ របស់វិបស្សនា ។

បណ្ដាបទទាំងនោះ បទថា **អជ្ឈត្តវវត្ថានេ** សេចក្ដីថា ឈ្មោះថា **អជ្ឈត្ត** ព្រោះអត្ថថា ធ្វើខ្លួនឲ្យជាធំប្រព្រឹត្តទៅ ដូចជាបំណងយ៉ាងនេះថា អញ កាលប្រព្រឹត្តទៅយ៉ាងនេះ ក៏នឹងដល់នូវការប្រកាន់មាំ ថាជាអត្តា ។

ឯ **អជ្ឈត្ត** សព្ទនេះ ប្រាកដក្នុងអត្ថ ៤ យ៉ាង គឺគោចរជ្ឈត្ត ១ និយកជ្ឈត្ត ១ អជ្ឈត្តជ្ឈត្ត ១ វិសយជ្ឈត្ត ១ ។

**គោចរជ្ឈត្ត** សព្ទនេះ ប្រាកដក្នុង **គោចរជ្ឈត្ត** ដូចក្នុងប្រយោគជាដើម ថា **តេនានន្ទ ភិក្ខុនា តស្មឹយេវ បុរិមស្មឹ សមាធិនិមិត្តេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតព្វំ អជ្ឈត្តរតោ សមាហិតោ** ម្នាលអានន្ទ ភិក្ខុនោះ ត្រូវតាំង ចិត្តខាងក្នុង ក្នុងសមាធិនិមិត្តពីមុននោះវិញ ជាអ្នកមានចិត្តតម្កល់មាំ តែង មានចិត្តត្រេកអរក្នុងធម៌ ដូច្នេះជាដើម ។

*ប្រាកដក្នុងនិយកជ្ឈត្ត ដូចក្នុងប្រយោគជាដើមថា* **អជ្ឈត្តំ សម្បសាទនំ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ** *ជាធម្មជាតច្បាស់ ប្រាកដក្នុងខ្លួន មានសេចក្ដីជ្រះថ្លា គឺសទ្ធា ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី ដូច្នេះជាដើម ។*

*ប្រាកដក្នុងអជ្ឈត្តជ្ឈត្ត ដូចក្នុងប្រយោគជាដើមថា* **ឆ អជ្ឈត្តិកានិ អាយតនានិ អជ្ឈត្តិកា ធម្មា** *អាយតនៈខាងក្នុង ៦ ពួកធម៌ជាខាងក្នុង ដូច្នេះជាដើម ។*

*ប្រាកដក្នុងវិសយជ្ឈត្ត គឺឥស្សរិយដ្ឋាន ដូចក្នុងប្រយោគជាដើមថា* **អយំ ខោ បនានន្ទ វិហារោ តថាគតេន អភិសម្ពុទ្ធោ យទិទំ សព្វនិមិត្តានំ អមនសិការា អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហរតិ** *ម្នាលអានន្ទ វិហារធម៌ ( ការនៅ ) ក្នុងទីស្ងាត់ តថាគតបានត្រាស់ដឹងហើយ គឺបានសម្រេចនូវសុញ្ញត ផលសមាបត្តិក្នុងសន្តាន ព្រោះមិនធ្វើទុកក្នុងចិត្តនូវសង្ខតនិមិត្តទាំងអស់ ( មានរូបជាដើម ) ដូច្នេះជាដើម ។ ពិតហើយ ផលសមាបត្តិ ឈ្មោះថាឥស្សរិយដ្ឋានរបស់ព្រះពុទ្ធទាំងឡាយ ។ តែក្នុងទីនេះ* **អជ្ឈត្ត** *សព្វ គប្បីឃើញថា សំដៅយកអត្ថថា* **អជ្ឈត្តជ្ឈត្ត** *។ ក្នុងការកំណត់អជ្ឈត្តទាំងនោះ ឈ្មោះថា* **អជ្ឈត្តវវត្ថានេ** *។*

*បទថា* **វត្ថុនានត្តេ** *បានដល់ ក្នុងភាពផ្សេងៗ នៃវត្ថុទាំងឡាយ អធិប្បាយថា ក្នុងវត្ថុផ្សេងៗ ។ ក្នុងពាក្យនេះ សូមប្បីភវង្គចិត្តដែលជាបច្ច័យដល់*

មនោវិញ្ញាណ គឺជវន ក៏ហៅថា វត្ថុ ព្រោះជាឋានៈដែលកើតឡើង ដូចពួកបសាទទាំង ៥ មានចក្ខុបសាទជាដើម ។ សូម្បីអាវជ្ជនចិត្ត ក៏គប្បីធ្វើឲ្យអាស្រ័យកវត្ថុចិត្តនោះឯង ។៚

## អដ្ឋកថាវត្ថុនានត្តញ្ញាណុទ្ទេស ចប់

## ១៦. អដ្ឋកថា

## គោចរនានត្តញ្ញាណុទ្ទេស

បទថា **ពហិទ្ធា** បានដល់ ក្នុងអារម្មណ៍នៃញាណទាំងនោះ ដែលមានខាងក្រៅ អំពីធម៌ដែលជាអជ្ឈត្តជ្ឈត្ត ៦ ។

ពាក្យថា **គោចរនានត្តេ** បានដល់ ក្នុងការផ្សេងគ្នានៃវិស័យ ( អារម្មណ៍ ) ។l

**អដ្ឋកថាគោចរនានត្តញ្ញាណុទ្ទេស ចប់**

## ១៧. អដ្ឋកថា

## ចរិយានានត្តញ្ញាណុទ្ទេស

បទថា **ចរិយាវវត្ថានេ** បានដល់ ក្នុងការកំណត់ចរិយាទាំងឡាយ គឺ វិញ្ញាណចរិយា អញ្ញាណចរិយា និងញាណចរិយា ។ អាចារ្យពួកខ្លះ ធ្វើរស្សៈខ្លះ ហើយសូធ្យថា **ចរិយវវត្ថានេ** ។៚

អដ្ឋកថាចរិយានានត្តញ្ញាណុទ្ទេស ចប់

## ១៨. អដ្ឋកថា

## ភូមិនានត្តញ្ញាណុទ្ទេស

បទថា **ចតុធម្មវវត្ថានេ** បានដល់ ក្នុងការកំណត់ធម៌ទាំងឡាយនីមួយៗ ៤ មានកាមាវចរភូមិជាដើម ដោយអំណាចចតុក្កៈ ១៤ ។

បទថា **ភូមិ** រមែងប្រព្រឹត្តទៅក្នុងអត្ថថា ផែនដី ដូចក្នុងប្រយោគជាដើមថា **ភូមិគតញ្ច វេហាសដ្ឋញ្ច** ( មានប្រាក់ និងមាសជាច្រើន ) ដែលស្ថិតនៅលើផែនដីក្តី ដែលស្ថិតនៅលើអាកាសក្តី ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងអត្ថថា វិសយ ( ស្ថានទី ) ដូចក្នុងប្រយោគជាដើមថា **អភូមឹ តាត មា[1]សេវ** ម្នាលកូន អ្នកកុំសេពគប់នូវទីមិនមែនផែនដី ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងអត្ថថា ជាទីកើត ដូចក្នុងប្រយោគជាដើមថា **សុខភូមិយំ កាមាវចរេ** វៀរតែសុខវេទនាក្នុងសុខភូមិជាកាមាវចរ ដូច្នេះ ។ តែក្នុងទីនេះ រមែងប្រព្រឹត្តទៅក្នុងកោដ្ឋាស គឺចំណែក ។ អាចារ្យពួកខ្លះពោលថា រមែងប្រព្រឹត្តទៅក្នុងអត្ថថា បរិច្ឆេទ គឺការកំណត់ ដូច្នេះក៏មាន ៕

### អដ្ឋកថាភូមិនានត្តញ្ញាណុទ្ទេស ចប់

១- បិដកខ្មែរ មិនមានពាក្យថា មា ដែលប្រែថា កុំ នេះឡើយ ។

## ១៩. អដ្ឋកថា

## ធម្មនានត្តញាណុទ្ទេស

បទថា **នវធម្មវវត្ថានេ** បានដល់ ក្នុងការកំណត់ធម៌ទាំងឡាយទីមួយៗ ៩ ដោយអំណាចនៃកាមាវចរកុសលធម៌ ដោយអំណាចនៃធម៌ មានបាមោជ្ជជាមូល និងដោយអំណាចនៃធម៌ មានយោនិសោមនសិការជាមូល ។

បណ្ដាញាណទាំង ៥ នេះ អជ្ឈត្តធម៌ ជាធម៌ដែលព្រះយោគីបុគ្គល គប្បីកំណត់ ។ ព្រោះហេតុនោះ ទើបលោកពោលថា **វត្ថុនានត្តញ្ញាណ** ( ញាណក្នុងភាពផ្សេងៗ នៃវត្ថុ ) ទុកជាទី ១ តពីនោះ ក៏គប្បីកំណត់អារម្មណ៍នៃនានត្តធម៌ទាំងនោះ ក្នុងលំដាប់តអំពីវត្ថុនានត្តញ្ញាណនោះ លោកពោលគោចរនានត្តញ្ញាណ គឺញាណក្នុងការផ្សេងគ្នានៃអារម្មណ៍ ញាណ ៣ ដទៃទៀតពីនោះ លោកពោលដោយអនុលោមការរាប់ដោយអំណាចនៃធម៌ ៣ ធម៌ ៤ និងធម៌ ៩ ៕

**អដ្ឋកថាធម្មនានត្តញ្ញាណុទ្ទេស ចប់**

# ២០. អដ្ឋកថា

## ញាតដ្ឋញ្ញាណនិទ្ទេស

ព្រោះបរិញ្ញា ៣ គឺញាណក្នុងការកំណត់ដឹងនាមរូបដោយប្រភេទនោះឯង ជាញាតបរិញ្ញា តពីនោះក៏ជាតីរណបរិញ្ញា ក្នុងលំដាប់តទៅក៏ជាបហានបរិញ្ញា ទាំងភាវនា ( ការចម្រើន ) សច្ឆិកិរិយា ( ការធ្វើឲ្យជាក់ច្បាស់ ) ដែលសម្ពន្ធគ្នាដោយបរិញ្ញា ៣ នោះ មានហេតុនោះ ឥឡូវនេះ ទើបលោកលើកយកញាណទាំង ៥ មានញាតដ្ឋញ្ញាណជាដើមឡើងសម្តែងតពីធម្មនានត្តញាណ ។ បរិញ្ញា មាន ៣ គឺញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា ។ ក្នុងបរិញ្ញាទាំង ៣ នោះ មានវិនិច្ឆ័យដូច្នេះថា បញ្ញាដែលប្រព្រឹត្តទៅក្នុងការកំណត់លក្ខណៈ ដោយចំពោះៗ នៃសភាវធម៌ទាំងនោះៗ យ៉ាងនេះថា រូបមានការបែកធ្លាយទៅជាលក្ខណៈ វេទនាមានការសោយអារម្មណ៍ជាលក្ខណៈ ឈ្មោះថា ញាតបរិញ្ញា ។ វិបស្សនាបញ្ញាដែលមានលក្ខណៈជាអារម្មណ៍ ដែលលើកសាមញ្ញលក្ខណៈនៃសភាវធម៌ទាំងនោះៗ ឡើង ប្រព្រឹត្តទៅដោយន័យជាដើមថា រូបមិនទៀង ជាទុក្ខ ជាអនត្តា វេទនាមិនទៀង ជាទុក្ខ ជាអនត្តា ឈ្មោះថា តីរណបរិញ្ញា ។ វិបស្សនាដែលមានលក្ខណៈជាអារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយនោះ ដោយអំណាចនៃការលះសញ្ញាថាទៀងជាដើម ឈ្មោះថា បហានបរិញ្ញា ។

បណ្តាបរិញ្ញាទាំង ៣ នោះ ញាណតាំងអំពីសង្ខារបរិច្ឆេទញាណ ( ញាណក្នុងការកំណត់សង្ខារធម៌ ) រហូតដល់បច្ចយបរិគ្គហញ្ញាណ ( ញាណក្នុងការកំណត់បច្ច័យ ) ជាភូមិនៃញាតបរិញ្ញា ។ ភាពជាធំនៃការចាក់ធ្លុះលក្ខណៈចំពោះនៃសភាវធម៌ទាំងឡាយនោះឯង រមែងមានក្នុងរវាងនេះ ។ ញាណតាំង

អំពីកលាបសម្មសនញ្ញាណ ( ញាណក្នុងការពិចារណាសង្ខារធម៌ ដោយកលាបៈ ) រហូតដល់ឧទយព្វយានុបស្សនាញាណ ( ញាណក្នុងការឃើញរឿយៗ នូវការកើតឡើង និងការរលត់ទៅនៃសង្ខារធម៌ ) ជាភូមិនៃតីរណ-ប្បរិញ្ញា ក្នុងរវាងនេះ ភាពជាធំនៃការចាក់ធ្លុះសាមញ្ញលក្ខណៈនោះឯង រមែងមានក្នុងរវាងនេះ ។ ញាណតាំងពីភង្គានុបស្សនាញាណ ( ញាណក្នុងការឃើញរឿយៗ នូវការរលត់ទៅនៃសង្ខារធម៌ ) ឡើងទៅ ជាភូមិនៃបហាន-ប្បរិញ្ញា ។ ញាណតាំងអំពីភង្គានុបស្សនាញាណ ( ញាណក្នុងការឃើញរឿយៗ នូវការរលត់ទៅនៃសង្ខារធម៌ ) ឡើងទៅ ជាភូមិនៃបហានប្បរិញ្ញា ។ ចាប់អំពីនោះទៅ ភាពជាធំ រមែងមានដល់អនុបស្សនា ៧ ដែលឲ្យសម្រេចការលះសញ្ញាវិបល្លាសថាទៀងជាដើម បានយ៉ាងនេះ គឺបុគ្គលកាលពិចា-រណាឃើញថាមិនទៀង ក៏លះបង់នូវសញ្ញាថាទៀង កាលពិចារណាឃើញថាជាទុក្ខ ក៏លះបង់នូវសញ្ញាថាជាសុខ កាលពិចារណាឃើញថាមិនមែនខ្លួន ក៏លះបង់នូវសញ្ញាថាខ្លួន កាលនឿយណាយ ក៏លះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ ក៏លះបង់នូវតម្រេក កាលរម្ងត់ ក៏លះបង់នូវការកើតឡើង កាលរលាស់ចោល ក៏លះបង់នូវសេចក្ដីប្រកាន់[១] ។

បណ្ដាបទទាំងនោះ បទថា **អភិញ្ញាបញ្ញា** បានដល់ បញ្ញាជាគ្រឿងដឹងតាមភាវៈមានរុប្បនលក្ខណៈ គឺរូបមានការបែកធ្លាយទៅជាលក្ខណៈជាដើមនៃសភាវធម៌ទាំងឡាយ ។ ពិតហើយ បញ្ញានោះ លោកហៅថា **អភិញ្ញា** ព្រោះ

---

១- បិដកលេខ ៦៩ ឃ្នាប ១១២ ។

អធិប្បាយដោយ **អភិ** សព្ទ មានអត្ថថា ស្អាត ថាការដឹងស្អាត ដោយអំណាចនៃការដឹងសភាវៈរបស់ធម៌នោះៗ ។ បទថា **ញាតដ្ឋេ ញាណំ** បានដល់ ញាណដែលមានការដឹងជាសភាវៈ ។ល។

## អដ្ឋកថាញាតដ្ឋញ្ញាណុទ្ទេស ចប់

# ២១. អដ្ឋកថា

# តីរណដ្ឋញ្ញាណុទ្ទេស

*បទថា* **បរិញ្ញាបញ្ញា** *បានដល់ បញ្ញាជាគ្រឿងដឹង ។ ពិតហើយ បញ្ញានោះ លោកហៅថា* **បរិញ្ញា** *ព្រោះអធិប្បាយដោយ* **បរិ** *សព្ទ ដែលមានអត្ថថា ផ្សាយទៅជុំវិញ ថាការដឹងដែលផ្សាយទៅដោយអំណាចនៃសាមញ្ញលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ឬដោយអំណាចនៃការសម្រេចកិច្ចរបស់ខ្លួន ។ បទថា* **តីរណដ្ឋេ ញាណំ** *បានដល់ ញាណមានការចូលទៅពិចារណាជាសភាវៈ ឬមានការពិចារណាជាសភាវៈ ។ល។*

**អដ្ឋកថាតីរណដ្ឋញ្ញាណុទ្ទេស ចប់**

## ២២. អដ្ឋកថា

## បរិច្ចាគដ្ឋញ្ញាណុទ្ទេស

*បទថា* **បហានេ បញ្ញា** *បានដល់ បញ្ញា ជាគ្រឿងលះនិច្ចសញ្ញាជាដើម ឈ្មោះថា* **បហាន** *ព្រោះអត្ថថា លះ ឬព្រោះអត្ថថា ជាហេតុលះ ។ បទថា* **បរិច្ចាគដ្ឋេ ញាណំ** *បានដល់ ញាណ មានការលះនិច្ចសញ្ញាជាដើម ជាសភាវៈ ៗ។*

**អដ្ឋកថាបរិច្ចាគដ្ឋញ្ញាណុទ្ទេស ចប់**

# ២៣. អដ្ឋកថា

# ឯការសដ្ឋញ្ញាណុទ្ទេស

*បទថា* **ភាវនាបញ្ញា** *បានដល់ បញ្ញាជាហេតុឲ្យចម្រើន ។ បទថា* **ឯការសដ្ឋេ ញាណំ** *បានដល់ ញាណ មានកិច្ចតែមួយជាសភាវៈ ឬញាណ មានរសតែមួយជាសភាវៈ គឺវិមុត្តិ ។ល។*

**អដ្ឋកថាឯការសដ្ឋញ្ញាណុទ្ទេស ចប់**

## ២៤.អដ្ឋកថា

## ផស្សនដ្ឋញ្ញាណុទ្ទេស

*បទថា* **សច្ចិកិរិយាបញ្ញា** *បានដល់ បញ្ញាជាគ្រឿងធ្វើព្រះនិព្វានឲ្យប្រចក្ស ដោយអំណាចនៃការចាក់ធ្លុះ ឬដោយអំណាចនៃការបានចំពោះ ។ បទថា* **ផស្សនដ្ឋេ ញាណំ** *បានដល់ ញាណមានការបាននូវព្រះនិព្វានជាសភាវៈ ដោយអំណាចនៃការចាក់ធ្លុះ និងការបានចំពោះទាំង ២ នោះឯង ៕*

**អដ្ឋកថាផស្សនដ្ឋញ្ញាណុទ្ទេស ចប់**

# ២៥-២៨. អដ្ឋកថា
# អត្ថប្បដិសម្ភិទា
# ធម្មប្បដិសម្ភិទា
# និរុត្តិប្បសម្ភិទា
# បដិភាណប្បដិសម្ភិទាញាណុទ្ទេស

ព្រោះញាណក្នុងការលះ ក្នុងការចម្រើន និងក្នុងការធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ រមែងប្រកបដោយអរិយមគ្គ អរិយផលដូច្នោះ ឥឡូវនេះ ទើបលោកលើកយកបដិសម្ភិទាញាណ ៤ ដែលព្រះអរិយបុគ្គលនោះឯងនឹងបានសម្តែងបន្ទាប់អំពីផស្សនញ្ញាណនោះ ។ សូម្បីក្នុងបដិសម្ភិទា ៤ នោះ អត្ថដែលកើតអំពីបច្ច័យ រមែងប្រាកដច្បាស់ និងដឹងបានដោយងាយ ដូចទុក្ខសច្ច ព្រោះហេតុនោះ ទើបលោកលើកយកអត្ថប្បដិសម្ភិទាញាណសម្តែងមុន បន្ទាប់អំពីនោះ ក៏លើកយកធម្មប្បដិសម្ភិទាញាណសម្តែង ព្រោះអត្ថនោះ ជាវិស័យនៃធម៌ដែលជាហេតុ បន្ទាប់អំពីនោះ ទើបលើកយកនិរុត្តិប្បដិសម្ភិទាញាណសម្តែង ព្រោះអត្ថ និងធម៌ទាំង ២ នោះ ជាវិស័យនៃនិរុត្តិ បន្ទាប់អំពីនិរុត្តិប្បដិសម្ភិទាញាណនោះ លោកក៏លើកយកបដិភាណប្បដិសម្ភិទាញាណសម្តែង ព្រោះប្រព្រឹត្តទៅក្នុងញាណទាំង ៣ នោះ ។ តែអាចារ្យពួកខ្លះធ្វើទីឃៈ ប អក្ខរៈ ហើយសូធ្យក៏មាន ។៚

**អដ្ឋកថា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា**

**និរុត្តិប្បសម្ភិទា បដិភាណប្បដិសម្ភិទាញាណុទ្ទេស ចប់**

# ២៩-៣១. អដ្ឋកថា
# វិហារដ្ឋញ្ញាណ
# សមាបត្តដ្ឋញ្ញាណ
# វិហារសមាបត្តដ្ឋញ្ញាណុទ្ទេស

ញាណទាំងឡាយដទៃអំពីនេះ ៣ មានវិហារដ្ឋញ្ញាណជាដើម លោកលើកឡើងសម្ដែង បន្ទាប់អំពីបដិសម្ភិទាញាណ ព្រោះកើតដល់ព្រះអរិយបុគ្គលប៉ុណ្ណោះ និងព្រោះជាប្រភេទនៃបដិសម្ភិទា ។ ពិតហើយ វិហារដ្ឋញ្ញាណជាធម្មប្បដិសម្ភិទា សមាបត្តដ្ឋញ្ញាណជាអត្ថប្បដិសម្ភិទា ។ ពិតហើយ ញាណក្នុងសភាវធម៌ លោកពោលក្នុងបដិសម្ភិទាកថាថា ធម្មប្បដិសម្ភិទា ។ ចំណែកញាណក្នុងនិព្វាន ជាអត្ថប្បដិសម្ភិទានោះឯង ។

បណ្ដាបទទាំងនោះ បទថា **វិហារនានត្តេ** បានដល់ ក្នុងធម៌ជាគ្រឿងនៅ គឺវិបស្សនាផ្សេងៗ ដោយអំណាចអនិច្ចានុបស្សនាជាដើម ។

បទថា **វិហារដ្ឋេ** បានដល់ ក្នុងសភាវៈនៃធម៌ជាគ្រឿងនៅ គឺវិបស្សនា ។

បទថា **វិហារោ** បានដល់ វិបស្សនា មួយអន្លើដោយសម្បយុត្តធម៌នោះឯង ។

បទថា **សមាបត្តិនានត្តេ** បានដល់ ក្នុងផលសមាបត្តិផ្សេងៗ ដោយអំណាចនៃអនិមិត្តនិព្វានជាដើម ។

បទថា **សមាបត្តិ** បានដល់ ចិត្ត និងចេតសិកធម៌ទាំងឡាយ ដែលជាលោកុត្តរផល ។ បទថា **វិហារសមាបត្តិនានត្តេ** លោកពោលហើយដោយ

*អំណាចនៃញាណទាំង ២ ។ល។*

**អដ្ឋកថាវិហារដ្ឋសមាបត្តដ្ឋវិហារសមាបត្តដ្ឋញ្ញាណនិទ្ទេស ចប់**

## ៣២. អដ្ឋកថា
## អានន្តរិកសមាធិញ្ញាណនិទ្ទេស

*បន្ទាប់អំពីនោះ មគ្គញ្ញាណណា សូម្បីព្រះសារីបុត្តថាប់ពោលហើយថា បញ្ញាក្នុងការចេញ និងការចៀសទៅអំពីកិលេស ខន្ធ និងសង្ខារនិមិត្តទាំង ២ ដែលឲ្យសម្រេចញាណ ក្នុងវិហារសមាបត្តិញាណ លោកបំណងនឹងពោលភាពដែលមគ្គញ្ញាណនោះ អាចកាត់អាសវៈ និងឲ្យផលក្នុងលំដាប់បន្ទាប់ទៅ ។ ដោយអាការដទៃទៀតឲ្យពិសេសឡើងដោយហេតុ ទើបលើកមគ្គញ្ញាណនោះឯងឡើងសម្តែងថា* **អានន្តរិកសមាធិម្ហិ ញាណំ** *ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **អវិក្ខេបបរិសុទ្ធត្តា** *មានវិគ្គហៈថា ចិត្តរមែងរាយមាយទៅដោយធម្មជាតនោះ ហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា* **វិក្ខេប** *គឺសេចក្តីរាយមាយ ពាក្យនេះ ជាឈ្មោះរបស់ឧទ្ធច្ចៈ ។ ធម្មជាតដែលមិនមែនវិក្ខេប ឈ្មោះថា* **អវិក្ខេប** *ពាក្យនេះ ជាឈ្មោះរបស់សមាធិជាបដិបក្ខចំពោះឧទ្ធច្ចៈ ។ សេចក្តីបរិសុទ្ធ ឈ្មោះថា* **បរិសុទ្ធត្ត** *សេចក្តីបរិសុទ្ធនៃសមាធិ ឈ្មោះថា* **អវិក្ខេបបរិសុទ្ធត្ត** *ព្រោះហេតុនោះ ទើបលោកពោលថា*

**អវិក្ខេបបរិសុទ្ធត្តា** អធិប្បាយថា ព្រោះជាសភាពនៃសេចក្តីបរិសុទ្ធរបស់សមាធិ ។ ពិតហើយ ពាក្យនេះ ជាពាក្យពោលដោយហេតុនៃការកាត់អាសវៈបាន និងនៃការឲ្យផលក្នុងលំដាប់បន្ទាប់ទៅ ។ ក្នុងបទថា **អាសវសមុច្ឆេទេ** មានវិនិច្ឆ័យដូចតទៅ ធម្មជាតណា រមែងហូរទៅ ព្រោះហេតុនោះធម្មជាតនោះ ឈ្មោះថា អាសវៈ មានពាក្យអធិប្បាយថា អាសវៈទាំងឡាយរមែងហូរទៅ គឺរមែងប្រព្រឹត្តទៅ តាមផ្លូវភ្នែកខ្លះ ។បេ។ ផ្លូវចិត្តខ្លះ ។ ម្យ៉ាងទៀត ឈ្មោះថា អាសវៈ ព្រោះអត្ថថា បើពោលដោយធម៌ រមែងហូរទៅដល់គោត្រភូ បើពោលដោយឱកាស រមែងហូរទៅដល់ភវគ្គកព អធិប្បាយថាអាសវៈទាំងឡាយ រមែងគ្របសង្កត់ទាំងធម៌នោះផង ទាំងឱកាសនោះផងប្រព្រឹត្តទៅ ។ ពិតហើយ **អា** អក្ខរៈនេះ មានអត្ថថា គ្របសង្កត់ ។ មេរ័យដែលឈ្មោះថា **មទិរ** ជាដើមឈ្មោះថា អាសវៈ ព្រោះដូចជារបស់ត្រាំ ព្រោះអត្ថថា ត្រាំមកយូរ ។ ពិតហើយ មេរ័យដែលឈ្មោះថា មទិរៈជាដើម ដែលត្រាំមកយូរ ក្នុងផ្លូវលោក គេហៅថា អាសវៈ ។ បើឈ្មោះថា អាសវៈព្រោះអត្ថថា ត្រាំមកយូរសោត អាសវៈទាំងនោះ ក៏រមែងនឹងមានបាន ។

សមដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុនអំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយដូច្នេះជាដើម ។ ម្យ៉ាងទៀត ធម្មជាតណារមែងទៅ គឺរមែងហូរទៅកាន់សង្សារទុក្ខតទៅ ព្រោះហេតុនោះ ទើបធម្មជាតនោះឈ្មោះថា អាសវៈ ព្រះយោគីបុគ្គល រមែងកាត់ផ្តាច់

នូវធម៌នោះ ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា សមុច្ឆេទ គឺធម៌ជាគ្រឿងកាត់ផ្ដាច់នូវអាសវៈ ។

បទថា **បញ្ញា** បានដល់ បញ្ញាក្នុងការកាត់ផ្ដាច់អាសវៈ ៤ មានកាមាសវៈជាដើម ។

បទថា **អានន្តរិកសមាធិម្ហិ ញាណំ** សេចក្ដីថា មគ្គសមាធិ ឈ្មោះថា **អនន្តរិក** ព្រោះឲ្យផលដោយពិតប្រាកដនោះឯង ក្នុងលំដាប់នៃការប្រព្រឹត្តទៅរបស់ខ្លួន ព្រោះកាលមគ្គសមាធិកើតឡើងហើយ អន្តរាយណាមួយដែលនឹងរារាំងចំពោះការកើតឡើងនៃផលរបស់មគ្គសមាធិនោះ រមែងមិនមាន ។ ដូចព្រះមានព្រះភាគទ្រង់ត្រាស់ ( ក្នុងបុគ្គលបញ្ញត្តិ ) ថា បុគ្គលនេះ ជាអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ទុកជាវេលាភ្លើងឆេះកប្បនឹងមាន បើបុគ្គលនេះ មិនទាន់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរ នេះហៅថា បុគ្គលជាឋិតកប្បី ដូច្នេះ ។ នេះជាញាណដែលសម្បយុត្តដោយអានន្តរិកសមាធិនោះ ៚

**អដ្ឋកថាអានន្តរិកសមាធិញ្ញាណុទ្ទេស ចប់**

## ៣៣. អដ្ឋកថា
## អរណាវិហារញ្ញាណុទ្ទេស

ញាណទាំង ៤ មានអរណាវិហារញ្ញាណជាដើម លោកលើកឡើងសម្តែងក្នុងលំដាប់នៃញាណនេះ ព្រោះកើតដល់ព្រះអរិយៈទាំងឡាយ ដែលសម្រេចអរិយផលដោយមគ្គញាណនេះប៉ុណ្ណោះ ។ ក្នុងញាណទាំង ៤ នោះ លោកលើកអរណាវិហារញ្ញាណឡើងសម្តែងមុន ព្រោះកើតជាប់តគ្នាដល់ព្រះអរហន្តនោះឯង បន្ទាប់អំពីនោះ លោកក៏លើកនិរោធសមាបត្តិញ្ញាណឡើងសម្តែង ព្រោះនិរោធសមាបត្តិ ទោះបីកើតដល់ព្រះអនាគាមី និងព្រះអរហន្ត ក៏ជាធម៌មានសម្ភារច្រើន និងព្រោះនិរោធសមាបត្តិ ជាធម៌ដែលលោកសន្មតដោយពិសេសថា ជានិព្វាន បន្ទាប់អំពីនោះ លោកក៏លើកបរិនិព្វានញ្ញាណសម្តែងថា **ទីឃកាលិក** គឺកាលិកមានកាលយូរ ព្រោះតាំងនៅអស់កាលជាទីបរិនិព្វាន ក្នុងរវាងកាលបរិនិព្វាន ក្នុងលំដាប់បន្តអំពីនោះ លោកក៏លើកសមសីសដ្ឋញ្ញាណសម្តែងថា **រស្សកាលិក** គឺកាលិកមានកាលខ្លី ព្រោះតាំងនៅអស់កាលជាទីបរិនិព្វានក្នុងលំដាប់នៃការអស់កិលេសទាំងពួង របស់ព្រះអរហន្តដែលជាសមសីសៈ ។

បណ្តាបទទាំងនោះ ច អក្ខរៈ ក្នុងបទថា **សន្តោ** ច គប្បីភ្ជាប់ចូលជាមួយបទទាំង ៣ យ៉ាងនេះ គឺ **ឧស្សន្នាធិបតេយ្យំ ច សន្តោវិហារាភិគមោ ច បណីតាធិមុត្តតា ច** ។

បទថា **ឧស្សន្នំ** បានដល់ វិបស្សនាញាណ ភាពជាធំនោះឯង ឈ្មោះថា **អាធិបតេយ្យ** ម្យ៉ាងទៀត ព្រោះសម្រេចដល់ដោយភាពជាធំ ទើបឈ្មោះថា

**អាធិបតេយ្យំ** ទស្សនៈនោះផង ជាអធិបតេយ្យនោះផង ព្រោះហេតុនោះ ទើបឈ្មោះថា **ទស្សនាធិបតេយ្យំ** ។

ធម៌ណារមែងនៅ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វិហារ** ឬថា ព្រះយោគីបុគ្គលរមែងនៅដោយធម៌នោះ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វិហារ** ធម៌ណាដែលព្រះយោគីបុគ្គលរមែងដល់ គឺរមែងសម្រេច ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **អធិគម** គុណជាតជាគ្រឿងសម្រេច គឺវិហារធម៌ ព្រោះហេតុនោះ ទើបឈ្មោះថា **វិហារាធិគមោ** ។

វិហារាធិគមនោះ រលត់ឥតសេសសល់ហើយ ព្រោះវៀរចាកការក្ដៅក្រហាយព្រោះកិលេស ព្រោះហេតុនោះ ទើបឈ្មោះថា **សន្តោ** វិហារាធិគមនោះ ជាអរហត្តផលសមាបត្តិប្បញ្ញា ។ ឈ្មោះថា **បណីតោ** ព្រោះអត្ថថា ឧត្តម និងព្រោះអត្ថថា មិនធ្វើឲ្យក្ដៅក្រហាយ ម្យ៉ាងទៀត ឈ្មោះថា **បណីតោ** ព្រោះនាំទៅកាន់ភាពជាប្រធាន បុគ្គលមានចិត្តបង្អោនទៅ គឺរសោត់ទៅហើយ ក្នុងធម៌ដែលប្រណីត មានធម៌ដែលប្រណីតនោះយ៉ាងក្រៃលែង ឈ្មោះថា **បណីតាធិមុត្ត** ការបង្អោនចិត្តទៅក្នុងបណីតាធិមុត្តនោះ ឈ្មោះថា **បណីតាធិមុត្តតា** បណីតាធិមុត្តតានោះ ជាបុព្វភាគប្បញ្ញាដែលបង្អោនចិត្តទៅក្នុងផលសមាបត្តិ ។

បទថា **អរណវិហារេ** បានដល់ វិហារធម៌ មានកិលេសទៅប្រាសហើយ ។ ពិតហើយ កិលេសទាំងឡាយ មានរាគៈជាដើម រមែងរុករាន ញាំញី បៀតបៀនសត្វទាំងឡាយ ព្រោះហេតុនោះ ទើបរាគាទិក្កិលេសនោះ ឈ្មោះថា **រណា** គឺអ្នកបៀតបៀន ម្យ៉ាងទៀត សត្វទាំងឡាយ រមែងយំរៀបរាប់ដោយរាគាទិក្កិលេស

*ទាំងនោះ ព្រោះហេតុនោះ ទើបរាគាទិក្កិលេសទាំងនោះ ឈ្មោះថា **រណា** គឺកិលេសជាហេតុឲ្យសត្វយំរៀបរាប់ វិហារធម៌សូម្បីទាំង ៣ យ៉ាង លោកបានពោលហើយ **រណ** មិនមានដល់ធម៌នេះ ព្រោះហេតុនោះ ទើបធម៌នេះ ឈ្មោះថា **អរណា** ព្រះអរិយបុគ្គលរមែងនាំធម៌ដែលជាសត្រូវចេញបាន ដោយធម៌នោះ ព្រោះហេតុនោះ ទើបធម៌នោះឈ្មោះថា **វិហារ** គឺនាំធម៌ជាសត្រូវចេញ ។ ក្នុងអរណាវិហារធម៌នោះ ។ ក្នុងនិទ្ទេសវារៈ បឋមជ្ឈានដែលលោកពោលហើយជាដើម លោកសម្ដែងសង្គ្រោះក្នុងបណីតាធិមុត្តតាដូចគ្នា ។ ក៏ព្រោះបំណងនឹងចូលផលសមាបត្តិ ទើបចូលឈាន មានបឋមជ្ឈានជាដើម ចេញហើយ ឃើញច្បាស់ធម៌ដែលសម្បយុត្តជាមួយឈាន អរណាបដិបទាណាដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ក្នុងអរណាវិភង្គសូត្រ អរណាប្ប-ដិបទានោះ ក៏គប្បីជ្រាបថា លោកសង្គ្រោះដោយបទនេះដូចគ្នា ។*

*ពិតហើយ ក្នុងអរណាវិភង្គសូត្រនោះ ព្រះមានព្រះភាគត្រាស់ថា*

> *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវអរណាវិភង្គចំពោះអ្នកទាំងឡាយ ។បេ។ បុគ្គលមិនគប្បីប្រកបរឿយៗ នូវសេចក្ដីសុខក្នុងកាមដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ មួយទៀត មិនគប្បីប្រកបរឿយៗ នូវសេចក្ដីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍*

ឡើយ ឯមជ្ឈិមប្បដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល មិនប៉ះពាល់នូវធម៌អមខាងទាំង ២ នោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង តែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ។ បុគ្គលគប្បីដឹងនូវការលើកតម្កើងផង គប្បីដឹងនូវការបន្ទុះបន្អាប់ផង លុះដឹងនូវការលើកតម្កើង ទាំងដឹងនូវការបន្ទុះបន្អាប់ហើយ មិនគប្បីលើកតម្កើង មិនគប្បីបន្ទុះបន្អាប់ ត្រូវសម្តែងធម៌ដោយត្រង់ គប្បីដឹងនូវសេចក្តីសុខដែលថោកថយ លុះដឹងនូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងសន្តាន មិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ ( ពាក្យញុះញង់ ) មិនគប្បីពោលពាក្យសៅហ្មងក្នុងទីចំពោះមុខ គប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេក មិនគប្បីប្រកាន់ភាសាក្នុងជនបទ មិនគប្បីប្រព្រឹត្តកន្លងនូវឈ្មោះ នេះជាឧទ្ទេសនៃអរណវិភង្គ ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកបរឿយៗ នូវសេចក្តីព្យាយាម ដោយសោមនស្សរបស់បុគ្គល ដែលមានសេចក្តីសុខដោយកាមប្បដិសន្ធិ ជាធម៌ថោកទាប ។បេ។ មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះមិនមានទុក្ខ មិនមានសេចក្តី

លំបាក មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិត្រូវ ។ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកបរឿយៗ នូវសេចក្ដីព្យាយាម ធ្វើខ្លួនឯងឲ្យលំបាក ជាសេចក្ដីព្យាយាម នាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះមិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ សេចក្ដីប្រតិបត្តិយ៉ាងកណ្ដាលណា ដែលព្រះតថាគតត្រាស់ដឹងហើយ ។បេ។ ធម៌នុ៎ះ ឈ្មោះថា មិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ការដែលមិនលើកតម្កើង និងការមិនបន្ទះបន្ថោក ទាំងការសម្ដែងធម៌ដោយត្រង់ណា ធម៌នេះ មិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ សេចក្ដីសុខណាដែលជាសេចក្ដីសុខ ក្នុងការចេញចាកកាម ជាសេចក្ដីសុខក្នុងការស្ងាត់ ជាសេចក្ដីសុខក្នុងការរម្ងាប់កិលេស ជាសេចក្ដីសុខក្នុងការត្រាស់ដឹងមគ្គផល ធម៌នុ៎ះ មិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ

ធម៌ទុំះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ពាក្យស្វាត់កំបាំងណា ជាពាក្យពិត ទៀង ប្រកបដោយប្រយោជន៍ ធម៌ទុំះ មិននាំមកនូវសេចក្ដីទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌ទុំះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខណា ជាពាក្យពិត ទៀង ទាំងប្រកបដោយប្រយោជន៍ ធម៌ទុំះ មិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌ទុំះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺពាក្យរបស់បុគ្គលអ្នកពោលមិនរហ័សពេក ធម៌ទុំះ មិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌ទុំះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។បេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកាន់នូវភាសា ក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ ធម៌ទុំះ មិននាំមកនូវទុក្ខ ។បេ។ ព្រោះហេតុនោះ ធម៌ទុំះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាក្នុងសាសនានេះថា យើងទាំងឡាយ នឹងដឹងនូវធម៌ ដែលប្រកបដោយសេចក្ដីសៅហ្មងផង នឹងដឹងនូវធម៌ដែលមិនមានសេចក្ដីសៅហ្មងផង លុះដឹងនូវធម៌ដែលប្រកបដោយសេចក្ដីសៅហ្មង និងដឹងនូវធម៌ដែលមិនមាន

សេចក្តីសៅហ្មងហើយ ក៏នឹងដើរទៅកាន់ផ្លូវប្រតិបត្តិដែលមិន
មានសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ
ត្រូវសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចំណែក
សុភូតិកុលបុត្ត បានដើរទៅកាន់ផ្លូវប្រតិបត្តិ ដែលមិនមាន
សេចក្តីសៅហ្មង[១] ដូច្នេះ ។

មជ្ឈិមប្បដិបទាក្នុងអរណវិភង្គសូត្រនោះ លោកសង្គ្រោះដោយទស្សនា-ធិបតេយ្យ និងវិហារាធិគមដ៏ស្ងប់ ។ ការមិនប្រកបកាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគ ជាមជ្ឈិមប្បដិបទាពិតនោះឯង ។ ពិតហើយ សំរាប់ព្រះអរហន្ត បុព្វភាគនៃវិបស្សនាជាមជ្ឈិមប្បដិបទា ឯអរហត្តផលសមាបត្តិ ក៏ជាមជ្ឈិមប្បដិបទាដោយអំណាចនៃមគ្គមានអង្គ ៨ ។ ចំណែកបដិបទាដ៏សេស គប្បីជ្រាបថា សង្គ្រោះដោយបណីតាធិមុត្តតានោះឯង ។ ព្រះអរហន្តទាំងឡាយ ជាអ្នកនៅដោយអរណធម៌ក៏ពិត តែព្រះអរហន្តពួកដទៃ កាលនឹងសម្តែងធម៌ ក៏រមែងសម្តែងធម៌លើកសរសើរនិងសង្កត់សង្កិន ដោយអំណាចនៃបុគ្គលថា កុលបុត្តទាំងនោះ បដិបត្តិប្រពៃក្នុងសម្មាបដិបត្តិ និងថា កុលបុត្តទាំងនេះ បដិបត្តិខុសក្នុងមិច្ឆាបដិបត្តិ តែព្រះសុភូតិត្ថេរ សម្តែងធម៌ដោយអំណាចនៃធម៌ប៉ុណ្ណោះថា នេះជាមិច្ឆាបដិបត្តិ នេះជាសម្មាបដិបត្តិ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់សរសើរថា ព្រះសុភូតិ ជាអ្នកបដិបត្តិអរណបដិបទានោះឯង

---

១- ក្នុងទីនេះ លោកលើកមកដោយសង្ខេប សេចក្តីពិស្តារ មានក្នុងអរណវិភង្គសូត្រ បិដកខ្មែរលេខ ២៨ ឯណោះ ។

*ទ្រង់តាំងក្នុងតំណែងដ៏កំពូល លើសភិក្ខុទាំងឡាយ អ្នកមានអរណវិហារីថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុ អ្នកនៅដោយឥតកិលេស ស្រេចនឹងសុភូតិ ដែលជាសាវករបស់តថាគតប្រសើរជាងគេ ដូច្នេះ ។*

## អដ្ឋកថាអរណវិហារញ្ញាណុទ្ទេស ចប់

## ៣៤. អដ្ឋកថា
## និរោធសមាបត្តិញ្ញាណនិទ្ទេស

បទថា **ទ្វីហិ ពលេហិ** បានដល់ ដោយសមថពល និងវិបស្សនាពល ។

បទថា **សមន្នាគតត្តា** បានដល់ ព្រោះប្រកបហើយ ឬព្រោះបរិបូរណ៍ហើយ ។

បទថា **តយោ ច** ជាវិភត្តិវិបល្លាស លោកពោលកែថា **តិណ្ណញ្ច** ។

បទថា **សង្ខារានំ** បានដល់ វចីសង្ខារ កាយសង្ខារ និងចិត្តសង្ខារ ។

បទថា **បដិប្បស្សទ្ធិយា** បានដល់ ដើម្បីសេចក្តីស្ងប់ គឺដើម្បីរម្ងាប់ អធិប្បាយថា ដើម្បីមិនឲ្យប្រព្រឹត្តទៅ ។

បទថា **សោឡសហិ** បានដល់ ១៦ គឺអនុបស្សនា ៨ មានអនិច្ចានុបស្សនាជាដើម លោកុត្តរ ៨ គឺមគ្គ ៤ ផល ៤ ។

បទថា **ញាណចរិយាហិ** បានដល់ ដោយការប្រព្រឹត្តទៅនៃញាណ ។

បទថា **នវហិ** បានដល់ ជា ៩ គឺរូបាវចរសមាធិ ៤ អរូបាវចរសមាធិ ៤ និងឧបចាររបស់រូបាវចរសមាធិ អរូបាវចរសមាធិ ១ ទៀត ។

បទថា **វសិភាវតា បញ្ញា** សេចក្តីថា **ឥស្សរិយ** ប្រព្រឹត្តទៅតាមសប្បាយដោយស្រួសរាន់ ឈ្មោះថា **វស** វសៈនោះ មានដល់បុគ្គលនោះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **វសី** គឺអ្នកមានអំណាច ភាពជាបុគ្គលអ្នកមានវសី ឈ្មោះថា **វសីភាវ** វសីភាវៈនោះឯង ឈ្មោះថា **វសិភាវតា** ដូច **ទាដិកុល្យមេវ** ( ភាពជារបស់បដិកូលនោះឯង ) ឈ្មោះថា **ទាដិកុល្យតា** ។ ម្យ៉ាងទៀត

អធិប្បាយថា បញ្ញាមានបែបយ៉ាងនេះ ឈ្មោះថា **វសិភាវតា បញ្ញា ។** តែអាចារ្យពួកខ្លះ ធ្វើទីឃៈ **សិ** អក្ខរៈ ហើយសូធ្យ ។ **ច** អក្ខរៈ គប្បីភ្ជាប់បទថា **សមន្នាគតត្តា ច បដិប្បស្សទ្ធិយា ច ញាណចរិយាហិ ច សមាធិចរិយាហិ ច ។**

បទថា **និរោធសមាបត្តិយា ញាណំ** បានដល់ ញាណដែលជានិមិត្តនៃនិរោធសមាបត្តិរបស់ព្រះអនាគាមី និងព្រះអរហន្ត ឧបមាដូចខ្លាដំបងត្រូវសម្លាប់ ក៏ព្រោះស្បែក ។

បទថា **និរោធសមាបត្តិ** សេចក្តីថា ត្រឹមតែនេវសញ្ញានាសញ្ញាយតនៈក៏មិនមាន និងថា ជាធម៌ណានីមួយ ក៏មិនមែន ត្រឹមតែជាបញ្ញត្តិ ។ ឈ្មោះថា **និរោធ** ព្រោះហេតុត្រឹមតែមិនមាន មួយទៀត ធម្មជាតណា ដែលព្រះអរិយបុគ្គលចូល ឈ្មោះថា រមែងចូល ព្រោះហេតុនោះ ធម្មជាតនោះ ហៅថា សមាបត្តិ ៕ ០៚

**អដ្ឋកថានិរោធសមាបត្តិញ្ញាណុទ្ទេស ចប់**

## ៣៥. អដ្ឋកថា

## បរិនិព្វានញ្ញាណុទ្ទេស

បទថា **សម្បជានស្ស** មានវិគ្គហៈថា ព្រះយោគីបុគ្គលណា រមែងដឹង ដោយប្រការទាំងឡាយដោយប្រពៃ ព្រោះហេតុនោះ ព្រះយោគីបុគ្គលនោះ ឈ្មោះថា **សម្បជានោ។** នៃព្រះយោគីបុគ្គលដែលមានសម្បជញ្ញៈនោះ ។

បទថា **បវត្តបរិយាទានេ** បានដល់ ការប្រព្រឹត្តទៅនៃកិលេស និងខន្ធ ឈ្មោះថា **បវត្ត** អធិប្បាយថា ការកើតឡើង ។ គឺការប្រព្រឹត្តទៅនៃកិលេស និងការប្រព្រឹត្តទៅនៃខន្ធ ការអស់ទៅ ការសូន្យទៅ ការមិនប្រព្រឹត្តទៅនៃការ ប្រព្រឹត្តទៅរបស់កិលេស និងខន្ធនោះ ឈ្មោះថា **បវត្តបរិយាទានេ ។** ក្នុង ការអស់ទៅនៃការប្រព្រឹត្តទៅរបស់កិលេស និងខន្ធនោះ ។

បទថា **បរិនិព្វានេ ញាណំ** សេចក្តីថា ញាណដែលប្រព្រឹត្តទៅហើយ ក្នុងកិលេសបរិនិព្វាន និងខន្ធបរិនិព្វាននោះរបស់ព្រះអរហន្ត អ្នកពិចារណានូវ ការរលត់ទៅ គឺការមិនប្រព្រឹត្តទៅនៃកិលេសទាំងឡាយ មានកាមច្ឆន្ទៈជាដើម និងនូវអនុបាទិសេសបរិនិព្វាន ៕៙

**អដ្ឋកថាបរិនិព្វានញ្ញាណុទ្ទេស ចប់**

## ៣៦. អដ្ឋកថា
## សមសីសដ្ឋញ្ញាណុទ្ទេស

បទថា **សព្វធម្មានំ** បានដល់ នៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងពួង ។

បទថា **សម្មាសមុច្ឆេទេ** បានដល់ ក្នុងការរម្ងត់ដោយល្អ ដោយការកាត់ផ្ដាច់សន្តតិ ។

បទថា **និរោធេ ច អនុបដ្ឋានតា** បានដល់ កាលរលត់ទៅហើយ និងក្នុងការមិនប្រាកដទៀត អធិប្បាយថា ក្នុងការមិនកើតឡើងទៀត ។ **ច** អក្ខរៈគប្បីភ្ជាប់នឹងបទថា **សម្មាសមុច្ឆេទេ ច និរោធេ ច អនុបដ្ឋានតា ច** ។

បទថា **សមសីសដ្ឋេ ញាណំ** សេចក្ដីថា ធម៌ ៣៧ ប្រការ មានទេក្ខម្មៈជាដើម ឈ្មោះថា **សម** ធម៌ ១៣ ប្រការ មានតណ្ហាជាដើម ឈ្មោះថា **សីស** ។ ឈ្មោះថា **សម** ព្រោះធម៌ដែលជាសត្រូវទាំងឡាយស្ងប់ ឈ្មោះថា **សីស** ព្រោះជាប្រធានតាមសមគួរដល់ការប្រកប និងព្រោះជាកំពូល ។

ធម៌ដែលស្ងប់ មានទេក្ខម្មជាដើម និងធម៌ដែលជាប្រធាន មានសទ្ធាជាដើម ក្នុងឥរិយាបថមួយក្ដី ក្នុងរោគមួយក្ដី ក្នុងជីវិតិន្ទ្រិយមួយ ដោយការបន្តគ្នាដោយស្មើកាតក្ដី មានដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះថា **សមសីសី** អត្ថនៃសមសីសី ឈ្មោះថា **សមសីសដ្ឋ** ។ ក្នុងអត្ថនៃសមសីសដ្ឋនោះ អធិប្បាយថា ក្នុងភាពជាសមសីសី ។

ភាពនៃសមសីសី រមែងមានដល់ព្រះអរហន្តប៉ុណ្ណោះ ដែលប្រារព្ធវិបស្សនាក្នុងឥរិយាបថមួយ ឬក្នុងរោគមួយ ឬក្នុងជីវិតដោយការបន្តគ្នា ដោយស្មើកាតហើយសម្រេចមគ្គ ៤ ផល ៤ ក្នុងឥរិយាបថនោះៗ ឯង ក្នុងរោគ ឬក្នុងជីវិត

*ដោយការបន្តគ្នាដោយស្មើភាគ ហើយបរិនិព្វានក្នុងខណៈនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា ញាណក្នុងភាពជាសមសីសីនោះ ។ សមដូចព្រះតម្រាស់ក្នុងបុគ្គលបញ្ញត្តិប្បករណ៍ និងពោលក្នុងអដ្ឋកថានៃបករណ៍នេះថា*

*បុគ្គលជាសមសីសី តើដូចម្តេច ។ បុគ្គលណា មានការអស់ទៅនៃអាសវៈ និងការអស់ទៅនៃជីវិត មិនមុន មិនក្រោយ នេះ ហៅថា បុគ្គលជាសមសីសី ដូច្នេះ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងសមសីសីនិទ្ទេសដូចតទៅនេះ ពាក្យថា* ***មិនមុន មិនក្រោយ*** *សេចក្តីថា មិនមែនក្នុងខាងមុខ មិនមែនក្នុងខាងក្រោយ គឺក្នុងគ្រាជាមួយគ្នា ដោយអំណាចនៃបច្ចុប្បន្នសន្តតិ អធិប្បាយថា ក្នុងពេលតែមួយនោះឯង ។*

*ពាក្យថា* ***ការអស់ទៅ*** *បានដល់ ការអស់ទៅជុំវិញ ។*

*ពាក្យថា* ***នេះ*** *សេចក្តីថា បុគ្គលនេះ ហៅថា សមសីសី ។ សមសីសីបុគ្គលនេះ មាន ៣ ជំពូក គឺឥរិយាបថសមសីសី ១ រោគសមសីសី ១ ជីវិតសមសីសី ១ ។*

*បណ្តាសមសីសីបុគ្គលទាំង ៣ ពួកនោះ បុគ្គលណាកំពុងចង្ក្រម ផ្តើមចម្រើនវិបស្សនា ហើយសម្រេចអរហត្តនៅចង្ក្រមនោះឯង ក៏បរិនិព្វាន បុគ្គលណា កំពុងឈរផ្តើមចម្រើនវិបស្សនា សម្រេចអរហត្តនៅឈរនោះឯង ក៏បរិនិព្វាន បុគ្គលណា កំពុងអង្គុយផ្តើមចម្រើនវិបស្សនា ហើយសម្រេចអរហត្តនៅអង្គុយនោះឯង ក៏បរិនិព្វាន បុគ្គលណា កំពុងដេកផ្តើមចម្រើនវិបស្សនា ហើយក៏*

*សម្រេចអរហត្តនៅដេកនោះឯង ក៏បរិនិព្វាន បុគ្គលនេះ ឈ្មោះថា* **ឥរិយាបថសមសីសី** *។*

*ចំណែកបុគ្គលណា កើតរោគណាមួយហើយ ផ្តើមចម្រើនវិបស្សនា ខាងក្នុងរោគនោះឯង ហើយសម្រេចអរហត្ត ហើយក៏បរិនិព្វានទៅដោយរោគនោះឯង បុគ្គលនោះ ឈ្មោះថា* **រោគសមសីសី** *។*

*បុគ្គល ឈ្មោះថា* **ជីវិតសមសីសី** *ដូចម្តេច សីសៈមាន ១៣ ។ បណ្តាសីសៈទាំងនោះ អរហត្តមគ្គ រមែងគ្របសង្កត់អវិជ្ជា ដែលជាកិលេសសីសៈ ចុតិចិត្ត រមែងគ្របសង្កត់ជីវិតិន្ទ្រិយដែលជាបវត្តសីសៈ ចិត្តដែលគ្របសង្កត់អវិជ្ជាមិនអាចគ្របសង្កត់ជីវិតិន្ទ្រិយបាន ចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រិយក៏មិនអាចគ្របសង្កត់អវិជ្ជាបាន ។ ចិត្តដែលគ្របសង្កត់អវិជ្ជាម្យ៉ាង ចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រិយម្យ៉ាងទៀត ។ សីសៈទាំង ២ នេះ របស់បុគ្គលណា រមែងដល់នូវការអស់ទៅព្រមគ្នា បុគ្គលនោះ ឈ្មោះថា* **ជីវិតសមសីសី** *។*

*សីសៈទាំង ២ នេះ នឹងមានព្រមគ្នាបានដូចម្តេច មានបាន ព្រោះព្រមគ្នាដោយវារៈ អធិប្បាយថា ការចេញដោយមគ្គមានក្នុងវារៈណា ព្រះអរិយបុគ្គលតាំងនៅក្នុងបច្ចវេក្ខណញ្ញាណ ១៩ គឺ*

*ក្នុងសោតាបត្តិមគ្គ មានបច្ចវេក្ខណញ្ញាណ ៥ ក្នុងសកទាគាមិមគ្គ មានបច្ចវេក្ខណញ្ញាណ ៥ ក្នុងអនាគាមិមគ្គ មានបច្ចវេក្ខណញ្ញាណ ៥ ក្នុងអរហត្តមគ្គ មានបច្ចវេក្ខណញ្ញាណ ៤ ហើយធ្លាក់ចុះកាន់ភវង្គ ទើបបរិនិព្វាន ។*

*ការអស់ទៅនៃសីសៈទាំង ២ ឈ្មោះថា រមែងមានព្រមគ្នាបាន ព្រោះព្រមគ្នាដោយវារៈនោះឯង ព្រោះហេតុនោះ ទើបបុគ្គលនេះ លោកហៅថា*

**ជីវិតសមសីសី** ។ ជីវិតសមសីសីបុគ្គលនេះឯង ព្រះមានព្រះភាគ ទ្រង់បំណង
យកហើយ ក្នុងទីនេះ ។

## អដ្ឋកថាសមសីសដ្ឋញ្ញាណុទ្ទេស ចប់

# ៣៧. អដ្ឋកថា

## សល្លេខដ្ឋញ្ញាណុទ្ទេស

ព្រោះសុតមយញ្ញាណ សីលមយញ្ញាណ និងភាវនាមយញ្ញាណ ដែលជាបាទនៃវដ្តសង្សារ រមែងមិនឈ្មោះថា **សល្លេខ** ( ធម៌ជាគ្រឿងជុសខាត់ ) ញាណទាំងនេះក្តី ញាណដទៃក្តី ចំពោះដែលជាបាទនៃលោកុត្តរ ហៅថា **សល្លេខ** ហេតុនោះ ដើម្បីនឹងសម្តែងញាណទាំងឡាយដែលប្រព្រឹត្តទៅ ដោយអាការជុសខាត់ធម៌ដែលជាសត្រូវ ទើបព្រះធម្មសេនាបតីសារីបុត្ត លើកយកសល្លេខដ្ឋញ្ញាណឡើង សម្តែងបន្ទាប់អំពីសមសីសដ្ឋញ្ញាណ ។

ក្នុងសល្លេខដ្ឋញ្ញាណនោះ បទថា **បុថុនានត្តតេជបរិយាទានេ បញ្ញា** សេចក្តីថា បញ្ញាក្នុងការអស់ទៅសូន្យទៅនៃកិលេសដែលក្រាស់ ដោយអត្ថថាមិនលាយឡំដោយលោកុត្តរទាំងឡាយ មានរាគៈជាដើម និងនៃនានត្តកិលេសដែលជាសភាវៈផ្សេងៗ មានកាមច្ឆន្ទៈជាដើម និងទាំងកិលេស មានកាពជាអ្នកទ្រុស្តសីលជាដើម ដែលបានឈ្មោះថា **តេជ** ព្រោះអត្ថថា ធ្វើឲ្យក្តៅ មាន

អធិប្បាយថា បញ្ញាក្នុងធម៌ ៣៧ ប្រភេទមាននេក្ខម្មជាដើម ។

ម្យ៉ាងទៀត អធិប្បាយថា កិលេសដែលក្រាស់ និងមានសភាពផ្សេងៗ ក៏គឺ **តេជ** នោះឯង បញ្ញាក្នុងការអស់ទៅនៃតេជះ ៥ មានភាពជាអ្នកទ្រុស្តសីល ជាដើម ដែលក្រាស់ ដែលមានសភាពផ្សេងៗ ទាំងនោះ ។ ខ្ញុំនឹងសម្ដែងការ សង្គ្រោះបុថុធម៌ និងនានត្តធម៌ដោយតេជះទាំងឡាយ ក្នុងនិទ្ទេសវារៈ ។

បទថា **សល្លេខដ្ឋេ ញាណំ** មានវិគ្គហៈថា ធម៌ណាវមែងជុសខាត់ រមែង កាត់ផ្ដាច់ធម៌ដែលជាសត្រូវទាំងឡាយ ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា សល្លេខញាណក្នុងធម៌ជាសល្លេខៈ ៣៧ ប្រភេទ មាននេក្ខម្មៈជាដើមនោះ ។ សូម្បីសល្លេខធម៌ ៤៤ ប្រភេទ ដែលព្រះមានព្រះភាគ ត្រាស់ក្នុងសល្លេខ-សូត្រ ដោយន័យជាដើមថា ពួកអ្នកត្រូវធ្វើនូវសេចក្ដីជូរផង់យ៉ាងនេះថា ជន ទាំងឡាយដទៃ នឹងជាអ្នកបៀតបៀន ក្នុងវត្ថុណា ពួកយើង នឹងជាអ្នកមិន បៀតបៀនក្នុងវត្ថុនោះ ដូច្នេះ ។ ក៏គប្បីជ្រាបថា លោកសង្គ្រោះដោយ សល្លេខញាណ នេះដូចគ្នា ។៙

**អដ្ឋកថាសល្លេខដ្ឋញ្ញាណុទ្ទេស ចប់**

## ៣៨. អដ្ឋកថា

## វិរិយារម្ភញ្ញាណុទ្ទេស

ឥឡូវនេះ ដើម្បីនឹងសម្តែងវិរិយៈ គឺសម្មប្បធានដែលព្រះយោគីបុគ្គល អ្នកតាំងនៅក្នុងសល្លេខជ្ញាណ ហើយគប្បីធ្វើ ទើបព្រះធម្មសេនាបតីសារីបុត្ត លើកយកវិរិយារម្ភញ្ញាណឡើង សម្តែងបន្ទាប់អំពីសល្លេខជ្ញាណនោះ ។

ក្នុងវិរិយារម្ភញ្ញាណនោះ បទថា **អសល្លីនត្តបហិតត្តបគ្គហដ្ឋេ** មាន វិគ្គហៈថា ឈ្មោះថា **អសល្លីនត្តោ** ព្រោះអត្ថថា បុគ្គលនោះ មានចិត្តមិន រួញរា មិនធូរថយដោយអំណាចនៃការខ្ជិលច្រអូស ។

បទថា **អត្តា** បានដល់ ចិត្ត ដូចព្រះមានព្រះភាគត្រាស់ថា ធម្មតាអ្នក បង្ហូរទឹកតែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញតែងពត់ព្រួញ ( ឲ្យត្រង់ ) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន ( ដូច្នោះដែរ ) ដូច្នេះជាដើម ។

ឈ្មោះថា **បហិតត្តោ** ព្រោះអត្ថថា មានខ្លួនតម្កល់ទុកពិតប្រាកដ បញ្ជូនទៅ បន្សាត់ទៅ ដោយមិនគិតដល់រាងកាយ និងជីវិត ដោយសេចក្តីព្យាយាមនោះ ។

បទថា **អត្តា** បានដល់ អត្តភាព ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុង ភិក្ខុនីវិភង្គ ) ថា ភិក្ខុនីណាមួយ វាយតប់ទះខ្លួនឯង ហើយយំ ( ត្រូវអាបត្តិ បាចិត្តិយៈ ) ដូច្នេះជាដើម ។ មានចិត្តដែលមិនរួញរាផង មានខ្លួនបញ្ជូនទៅផង ឈ្មោះថា **អសល្លីនត្តបហិតត្តោ** ។ ធម៌ណាមួយ រមែងផ្គង គឺរមែងឧបត្ថម្ភ សហជាតធម៌ទាំងឡាយ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **បគ្គហោ** អត្ថ គឺការផ្គង ឈ្មោះថា **បគ្គហដ្ឋ** អធិប្បាយថា មានការផ្គងជាសភាវៈ ។ ការ

ផ្គងនូវចិត្តមិនរួញរា និងខ្វនដែលបញ្ជូនទៅហើយ ឈ្មោះថា **អសល្លីនត្ត-បហិតត្តបគ្គហដ្ឋ** ។ ក្នុងការផ្គងទុកនូវចិត្ត ដែលមិនរួញរា និងខ្វនដែលបញ្ជូនទៅហើយនោះ ។ ការមិនរួញរា ការមិនវិលត្រឡប់ក្នុងសេចក្តីព្យាយាម ដែលព្រះធម្មសេនាបតីសារីបុត្តពោលហើយ ដោយពាក្យថា **អសល្លីនត្ត-បហិតត្តបគ្គហដ្ឋ** ព្រោះជាពាក្យដែលព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ទុកនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ គប្បីផ្គងទុកនូវសេចក្តីមិនរួញរាថា ស្បែក សរសៃ ឆ្អឹង សូមឲ្យសល់នៅចុះ សាច់និងឈាមក្នុងសរីរៈ ចូរហួតហែងទៅចុះ គុណវិសេសណាដែលបុគ្គលគួរបានដល់ដោយកម្លាំងរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស ( បើ ) មិនទាន់ដល់គុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវព្យាយាមទៅវិញឡើយ ដូច្នេះ ។

ក៏វីរិយៈដែលប្រព្រឹត្តទៅដោយល្អ ផុតហើយពីកោសជ្ជៈ និងឧទ្ធច្ចៈ ព្រះធម្មសេនាបតីសារីបុត្តពោលហើយ ដោយពាក្យថា **បគ្គហដ្ឋ** ។

បទថា **វីរិយារម្ភេ ញាណំ** បានដល់ ភាពនៃសេចក្តីក្លាហាន ឈ្មោះថា វីរិយៈ ឬកម្មរបស់អ្នកក្លាហានទាំងឡាយ ឈ្មោះថា វីរិយៈ ឬឈ្មោះថា វីរិយៈ ព្រោះជាកិច្ចដែលបុគ្គលគប្បីឲ្យដំណើរទៅ គប្បីឲ្យប្រព្រឹត្តទៅបាន ដោយវិធី ដោយន័យ ដោយឧបាយ ។

*វិរិយៈនេះ មានសេចក្ដីឧស្សាហ៍ជាលក្ខណៈ មានការឧបត្ថម្ភសហជាតធម៌ជាកិច្ច មានការមិនរួញរាជាអាការប្រាកដ មានការសង្វេគជាហេតុជិត ដោយព្រះបាលី ( អង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ជាអ្នកតក់ស្លុត ទើបតម្កល់សេចក្ដីព្យាយាមដោយឧបាយនៃប្រាជ្ញា ដូច្នេះជាដើម ឬមានហេតុជាគ្រឿងផ្ដើមសេចក្ដីព្យាយាមជាហេតុជិត ។*

*ការប្រារព្ធសេចក្ដីព្យាយាមដោយល្អ គប្បីជ្រាបថា ជាមូលនៃសម្បត្តិទាំងពួង ។ ការផ្ដួចផ្ដើម ពោលគឺសេចក្ដីព្យាយាម ឈ្មោះថា* **វីរិយារម្ភ** ។ *លោកបដិសេធការផ្ដួចផ្ដើមដ៏សេស ដោយវីរិយារម្ភសព្ទនេះ ។ ពិតហើយ* **អារម្ភ** *សព្ទនេះ មកហើយ ក្នុងអត្ថជាអនេក មានកម្ម អាបត្តិ កិរិយា សេចក្ដីព្យាយាម ការបៀតបៀន និងការព្រាត់ប្រាស ។*

*ពិតហើយ* **អារម្ភ** *មកក្នុងអត្ថថា កម្ម ដូចក្នុងប្រយោគជាដើមថា* **យំកិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភបច្ចយា អារម្ភានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ** *ទុក្ខនីមួយ ទាំងអស់តែងកើតឡើងព្រោះព្យាយាម ( កម្ម ) ជាបច្ច័យ ការមិនកើតឡើងនៃទុក្ខ ព្រោះរលត់នូវព្យាយាម ដូច្នេះ ។*

**អារម្ភ** *មកក្នុងអត្ថថា អាបត្តិ ដូចក្នុងប្រយោគជាដើមថា* **អារម្ភតិ ច វិប្បដិសារី ច ហោតិ** *រមែងប្រារព្ធ ( ត្រូវអាបត្តិ ) ផង មានសេចក្ដីក្ដៅក្រហាយផង ដូច្នេះ ។*

**អារម្ភ** *មកក្នុងអត្ថថា កិរិយា ជាគ្រឿងលើកសសរសម្រាប់ចងសត្វបូជាយញ្ញជាដើម ដូចក្នុងប្រយោគជាដើមថា* **មហាយញ្ញា មហារម្ភា ន តេ**

**ហោន្តិ មហប្ផលា** ការបូជាធំ មានកិច្ចដែលត្រូវធ្វើច្រើន ការបូជាធំទាំងនោះ មិនមានផលឡើយ ដូច្នេះ ។

**អារម្ភ** មកក្នុងអត្ថថា ព្យាយាម ដូចក្នុងប្រយោគជាដើមថា **អារម្ភថ និក្កមថ យុញ្ជថ ពុទ្ធសាសនេ** អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាមក្នុងពុទ្ធសាសនា ដូច្នេះ ។

**អារម្ភ** មកក្នុងអត្ថថា បៀតបៀន ដូចក្នុងប្រយោគជាដើមថា **សមណំ គោតមំ ឧទ្ទិស្ស បាណំ អារម្ភន្តិ** ពួកជនតែងសម្លាប់សត្វ ( បៀតបៀន ) ចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយសាច់ដែលគេធ្វើចំពោះ ដូច្នេះ ។

**អារម្ភ** មកក្នុងអត្ថថា ការព្រាត់ប្រាស ដូចក្នុងប្រយោគជាដើមថា **ពីជភូតគាមសមារម្ភា បដិវិរតោ ហោតិ** ភិក្ខុវៀរស្រឡះចាកការធ្វើពីជគាម និងភូតគាមឲ្យវិនាស ដូច្នេះ ។

តែក្នុងទីនេះ លោកបំណងយកសេចក្ដីព្យាយាមប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ការផ្ដួចផ្ដើម ពោល គឺសេចក្ដីព្យាយាម ឈ្មោះថា **វីរិយារម្ភ** ។ វីរិយៈ លោកហៅថា **អារម្ភ** ដោយអំណាចនៃការផ្ដើមប្រារព្ធ ។ ញាណក្នុងវីរិយារម្ភនោះ ។ អាចារ្យពួកខ្លះពោលថា **អសល្លីនត្តា បហិតត្តា** ដូច្នេះក៏មាន អធិប្បាយថា ព្រោះមិនរួញរា ព្រោះមានខ្លួនបញ្ជូនទៅហើយ ។ ពាក្យមុននោះឯងប្រពៃ ។ តែអាចារ្យពួកខ្លះ ពណ៌នាថា ភាពដែលសម្ពោជ្ឈង្គ គឺសតិ ធម្មវិចយៈ វីរិយៈ បីតិមានស្មើ ឈ្មោះថា **អសល្លី-**

**ឆត្តតា** *កាលដែលសម្ពោជ្ឈង្គ គឺសតិ សមាធិ បស្សទ្ធិ ឧបេក្ខាមានស្មើគ្នា ឈ្មោះថា* **បហិតត្តា** *កាលដែលសម្ពោជ្ឈង្គទាំង ៧ មានស្មើគ្នា ឈ្មោះថា* **បគ្គហាដ្ឋ** *ដូច្នេះ ។ល។*

## អដ្ឋកថាវីរិយារម្ភញ្ញាណុទ្ទេស ចប់

## ៣៩. អដ្ឋកថា

## អត្ថសន្ទស្សនញ្ញាណុទ្ទេស

ឥឡូវនេះ ដើម្បីសម្ដែងថា លោកអ្នកសម្រេចមគ្គផល ដែលសម្រេចដោយសម្មាវាយាមៈ គប្បីសម្ដែងធម្មទេសនា ដើម្បីប្រយោជន៍ដល់មនុស្ស-លោក ទើបព្រះធម្មសេនាបតីសារីបុត្ត លើកអត្ថសន្ទស្សនញ្ញាណឡើងសម្ដែង បន្ទាប់អំពីវិរិយារម្មញ្ញាណនោះ ។

ក្នុងអត្ថសន្ទស្សនញ្ញាណនោះ បទថា **នានាធម្មប្បកាសនតា** បានដល់ការសម្ដែងការទេសនាដោយការប្រកាសធម៌ផ្សេងៗគឺសង្ខតធម៌ និងអសង្ខ-តធម៌ទាំងពួង ។ ក៏ការប្រកាសនោះឯង ឈ្មោះថា **បកាសនតា** ។

បទថា **អត្ថសន្ទស្សនេ** បានដល់ ក្នុងការសម្ដែងអត្ថទាំងឡាយផ្សេងៗដល់ជនទាំងឡាយដទៃ ។ ធម៌ទាំងឡាយផង អត្ថទាំងឡាយផង ឈ្មោះថាអត្ថទាំងឡាយទាំងនោះនោះឯង ។ល។

**អដ្ឋកថាអត្ថសន្ទស្សនញ្ញាណុទ្ទេស ចប់**

# ៤០. អដ្ឋកថា
# ទស្សនវិសុទ្ធិញ្ញាណុទ្ទេស

ឥឡូវនេះ ដើម្បីសម្តែងទស្សនវិសុទ្ធិ ដែលជាហេតុនៃការសម្តែងធម្មទេសនា តាមសេចក្តីពិតរបស់ព្រះអរិយបុគ្គលនោះ ដែលកំពុងសម្តែងឲ្យឃើញច្បាស់ ដល់ជនទាំងឡាយពួកដទៃដោយធម្មីកថា ទើបព្រះធម្មសេនាបតីសារីបុត្តលើក យកទស្សនវិសុទ្ធិញ្ញាណឡើងសម្តែង បន្ទាប់អំពីអត្ថសន្ទស្សនញ្ញាណនោះ ។

ក្នុងទស្សនវិសុទ្ធិញ្ញាណនោះ បទថា **សព្វធម្មានំ ឯកសង្គហាតា នានត្តេកត្តប្បដិវេធេ** សេចក្តីថា ការចាក់ធ្លុះ គឺការត្រាស់ដឹងនូវសភាវៈ ដែលសង្ខតធម៌ និងអសង្ខតធម៌ទាំងពួង សង្គ្រោះដោយភាពជាពួកតែមួយ នូវការផ្សេងគ្នានៃធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម និងនូវភាពតែមួយនៃធម៌ទាំងឡាយ មាននេក្ខម្មៈជាដើម ។ ការចាក់ធ្លុះនោះ ជាមគ្គបញ្ញា និងផលបញ្ញា ។ មគ្គបញ្ញា ឈ្មោះថា ការចាក់ធ្លុះ ព្រោះអត្ថថា ចាក់ធ្លុះដោយការត្រាស់ដឹងសច្ចៈ ក្នុងខណៈត្រាស់ដឹងសច្ចៈ ផលបញ្ញា ឈ្មោះថា ការចាក់ធ្លុះ ព្រោះចាក់ធ្លុះហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯកសង្គហាតា** ដូចតទៅនេះ

**សង្គហា** គឺការសង្គ្រោះ មាន ៤ យ៉ាង គឺ **ជាតិសង្គហា** សង្គ្រោះដោយជាតិ ១ **សញ្ជាតិសង្គហា** សង្គ្រោះដោយសញ្ជាតិ ១ **កិរិយាសង្គហា** សង្គ្រោះដោយការធ្វើ ១ **គណនសង្គហា** សង្គ្រោះដោយការរាប់ ១ ។

បណ្តាសង្គហៈ ៤ យ៉ាងនោះ សង្គហៈដូចក្នុងប្រយោគនេះថា ក្សត្រទាំង

ពួន ចូរមក ព្រាហ្មណ៍ទាំងពួង ចូរមក អ្នកជំនួញទាំងពួង ចូរមក សូទ្រៈទាំងពួង ចូរមក និងដូចក្នុងប្រយោគ ( មជ្ឈិមនិកាយ មូលបណ្ណាសក ) នេះថា ម្នាលអាវុសោវិសាខៈ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ ដូច្នេះ ឈ្មោះថា **ជាតិ-សង្គហា** ។ ក្នុងទីនេះ ក្សត្រជាដើម ដូចដែលបានពោលហើយទាំងអស់ លោកសង្គ្រោះកំណត់ជាមួយគ្នាដោយជាតិ ដូចក្នុងឋានៈនៃពាក្យដែលពោលថា មនុស្សជាតិដូចគ្នាចូរ មក ដូច្នេះ ។

សង្គហៈនេះថា អ្នកកោសលទាំងពួង ចូរមក អ្នកមគធៈទាំងពួង ចូរមក អ្នកការុកច្ឆកៈ ចូរមក និងដូចក្នុងប្រយោគនេះថា ម្នាលអាវុសោវិសាខៈ សម្មាវា-យាមៈ ១ សម្មាសតិ ១ សម្មាសមាធិ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ ដូច្នេះ ឈ្មោះថា **សញ្ជាតិសង្គហា** ។ ក្នុងទីនេះ អ្នកកោសលជាដើមទាំងអស់ លោកសង្គ្រោះតែមួយដោយទីកើត ដោយទីនៅអាស្រ័យ ដូចក្នុងឋានៈនៃពាក្យដែលពោលថា អ្នកដែលសម្ពន្ធគ្នាដោយជាតិក្នុងទីជាមួយគ្នា ចូរមក ។

សង្គហៈនេះថា ក្បួនដំរីទាំងពួង ចូរមក ក្បួនសេះទាំងពួង ចូរមក ក្បួនរថទាំងពួង ចូរមក និងប្រយោគថា ម្នាលអាវុសោវិសាខៈ សម្មាទិដ្ឋិ ១ សម្មា-សង្កប្បៈ ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ដូច្នេះ ឈ្មោះថា **កិរិយាសង្គហា** ។ ក្បួនដំរីជាដើមទាំងអស់នោះ សង្គ្រោះតែមួយដោយការធ្វើ គឺកិរិយារបស់ខ្លួន ។

សង្គហៈនេះថា អាយតនៈ គឺក្អែក ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈ គឺក្អែក ដល់នូវការរាប់ដោយរូបក្ខន្ធយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈ គឺក្អែក សង្គ្រោះដោយរូបក្ខន្ធដូច្នេះ ឈ្មោះថា **គណនសង្គហ** ( សង្គ្រោះដោយការរាប់ ) ។ ក្នុងទីនេះ លោកបំណងយកគណនសង្គហៈនេះ ។

ការសង្គ្រោះ គឺការកំណត់រាប់ធម៌ទាំងនោះជាផ្នែកៗ ដោយភាពតែមួយក្នុងអាការ ១២ មាន **តថដ្ឋ** ( ដោយភាពដែលពិត ) ជាដើម ទើបឈ្មោះថា **ឯកសង្គហ** ភាពនៃការសង្គ្រោះជាពួកតែមួយ ឈ្មោះថា **ឯកសង្គហតា** ។

បទថា **ទស្សនវិសុទ្ធិញ្ញាណំ** មានវិនិច្ឆ័យថា មគ្គញ្ញាណ និងផលញ្ញាណ ឈ្មោះថា ទស្សនៈ ទស្សនៈនោះឯងបរិសុទ្ធ ឈ្មោះថា ទស្សនវិសុទ្ធិ ញាណគឺទស្សនវិសុទ្ធិ ឈ្មោះថា ទស្សនវិសុទ្ធិញ្ញាណ ។

មគ្គញ្ញាណ រមែងបរិសុទ្ធិ ព្រោះហេតុនោះ ទើបឈ្មោះថា ទស្សនវិសុទ្ធិ ផលញ្ញាណ ក៏ឈ្មោះថា ទស្សនវិសុទ្ធិ ព្រោះបរិសុទ្ធហើយ ។

## អដ្ឋកថាទស្សនវិសុទ្ធិញ្ញាណុទ្ទេស ចប់

## ៤១. អដ្ឋកថា

## ខន្តិញាណុទ្ទេស

ឥឡូវនេះ ដើម្បីសម្តែងវិបស្សនាញាណ ២ ប្រការ ដែលឲ្យសម្រេចទស្សនវិសុទ្ធិ ទើបព្រះធម្មសេនាបតីសារីបុត្តលើកខន្តិញាណ និងបរិយោគាហណញាណឡើងសម្តែង បន្ទាប់អំពីទស្សនវិសុទ្ធិញាណនោះ ។

ក្នុងខន្តិញាណនោះ បទថា **វិទិតត្តា បញ្ញា** បានដល់ បញ្ញាដែលប្រព្រឹត្តទៅហើយ ព្រោះដឹងច្បាស់នូវធម៌ មានរូបក្ខន្ធជាដើម ដោយភាពជារបស់មិនទៀងជាដើម ។

បទថា **ខន្តិ ញាណំ** សេចក្តីថា ធម្មជាតណា រមែងទទួលបាននូវវត្ថុដែលដឹងច្បាស់ដោយភាពជារបស់មិនទៀងនោះឯង ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា ខន្តិ ញាណ គឺខន្តិ ឈ្មោះថា ខន្តិញាណ ។ ដោយខន្តិញាណនេះ លោកបដិសេធអធិវាសនខន្តិ ។ ខន្តិញាណនេះ ជាតរុណវិបស្សនាញាណ ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការពិចារណាសង្ខារធម៌ដោយភាពជាកលាបៈជាដើម ។l៙

### អដ្ឋកថាខន្តិញាណុទ្ទេស ចប់

# ៤២. អដ្ឋកថា

## បរិយោគាហណញ្ញាណុទ្ទេស

បទថា **ផុដ្ឋត្តា បញ្ញា** បានដល់ បញ្ញាដែលប្រព្រឹត្តទៅហើយ ព្រោះភាពនៃធម៌ទាំងឡាយ មានរូបក្ខន្ធជាដើម ជាធម៌ដែលញាណផស្សៈពាល់ត្រូវហើយ ដោយអំណាចនៃការពិចារណា ដោយភាពជារបស់មិនទៀងជាដើម ។ បទថា **បរិយោគាហណេ ញាណំ** មានវិគ្គហៈថា ញាណណា រមែងឈមចុះ រមែងចូលទៅកាន់ធម៌ ដែលញាណផស្សៈពាល់ត្រូវហើយនោះឯង ព្រោះហេតុនោះ ទើបញាណនោះ ឈ្មោះថា បរិយោគាហណញ្ញាណ ។ ពួកអាចារ្យខ្លះធ្វើ **គា** អក្ខរៈ ឲ្យជារស្សៈហើយសូធ្យ ។ បរិយោគាហណញ្ញាណនេះ ជាតិក្ខវិបស្សនា ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃភង្គានុបស្សនាជាដើម ។ តែអាចារ្យពួកខ្លះពោលថា វិបស្សនាញាណនោះឯង ជាខន្តិញ្ញាណសម្រាប់អ្នកមានសទ្ធា ជាគ្រឿងនាំទៅ ជាបរិយោគាហណញ្ញាណ សម្រាប់អ្នកមានបញ្ញាជាគ្រឿងនាំទៅ ។ កាលបើដូច្នោះ ញាណទាំង ២ នេះ រមែងមិនកើតព្រមដល់បុគ្គលម្នាក់ ទើបញាណ ៦៧ ដែលជាសាធារណៈដល់សាវកមិនកើតឡើងព្រមគ្នា ដល់សាវកមួយរូប ព្រោះការមិនកើតឡើងព្រមគ្នានៃញាណទាំង ២ នោះ ព្រោះហេតុនោះ ទើបពាក្យរបស់អាចារ្យពួកខ្លះនោះ មិនត្រឹមត្រូវ ៕

**អដ្ឋកថាបរិយោគាហណញ្ញាណុទ្ទេស ចប់**

# ៤៣. អដ្ឋកថា

## បទេសវិហារញ្ញាណុទ្ទេស

ព្រោះបុថុជ្ជន និងព្រះសេក្ខបុគ្គលទាំងឡាយ រមែងពិចារណាធម៌ទាំងមូល មានខន្ធជាដើម ដែលសម្រេចដល់វិបស្សនា រមែងមិនពិចារណាញែកនូវចំណែកនៃធម៌ទាំងនោះ ព្រោះហេតុនោះ បទេសវិហារញ្ញាណ រមែងមិនបានដល់បុថុជ្ជន និងព្រះសេក្ខបុគ្គលទាំងនោះ តែរមែងបានដល់ព្រះអរហន្តប៉ុណ្ណោះតាមគាប់ចិត្ត ព្រោះហេតុនោះ ឥឡូវនេះ ព្រះធម្មសេនាបតីសារីបុត្ត កាលពោលញាណ ដែលឲ្យសម្រេចអំពីទស្សនវិសុទ្ធិញ្ញាណហើយ ទើបលើកបទេសវិហារញ្ញាណ ដែលសម្រេចអំពីទស្សនវិសុទ្ធិញ្ញាណ របស់ព្រះអរហន្តឡើង សម្តែងបន្ទាប់អំពីបរិយោគាហណញ្ញាណនោះ ។

ក្នុងបទទាំងនោះ បទថា **សមោធហនេ បញ្ញា** បានដល់ បញ្ញាក្នុងការប្រមូលមក គឺបញ្ញាក្នុងការរួបរួមមក បានដល់ បញ្ញាក្នុងការធ្វើឲ្យជាគំនរនូវធម៌ គឺវេទនាដែលជាធម៌ពួកជាមួយគ្នានៃធម៌ មានខន្ធជាដើម ។ បាឋៈថា **សមោធានេ បញ្ញា** ( បញ្ញាក្នុងការប្រជុំ ) យ៉ាងនេះ ក៏មានអត្ថន័យយ៉ាងនោះឯង ។

បទថា **បទេសវិហារេ ញាណំ** បានដល់ ធម៌ជាគ្រឿងនៅដោយបទេស គឺដោយចំណែកមួយ ដោយការប្រកបនៃធម៌ មានខន្ធជាដើម ឈ្មោះថាបទេសវិហារ ។ ញាណក្នុងបទេសវិហារធម៌នោះ ។

ក្នុងបទថា បទេសវិហារនោះ ឈ្មោះថា **បទេស** មានច្រើនយ៉ាង គឺ

ខន្ធប្បទេស អាយតនប្បទេស ធាតុប្បទេស សច្ចប្បទេស ឥន្ទ្រិយប្បទេស បច្ចយាការប្បទេស សតិប្បដ្ឋានប្បទេស ឈានប្បទេស នាមរូបប្បទេស ធម្ម-ប្បទេស ។ បទេសមានច្រើនយ៉ាង យ៉ាងនេះ ក៏គឺវេទនានោះឯង ។ សេចក្តីនេះដូចម្តេច

គឺវេទនានោះឯងជាបទេសនៃធម៌ មានខន្ធជាដើមយ៉ាងនេះ គឺចំណែកមួយនៃខន្ធក្នុងខន្ធ ៥ គឺវេទនាខន្ធ ចំណែកមួយនៃធម្មាយតនៈក្នុងអាយតនៈ ១២ គឺវេទនា ចំណែកមួយនៃធម្មធាតុក្នុងធាតុ ១៨ គឺវេទនា ចំណែកមួយនៃទុក្ខសច្ចក្នុងសច្ចៈ ៤ គឺវេទនា ចំណែកមួយនៃឥន្ទ្រិយក្នុងឥន្ទ្រិយ ២២ គឺឥន្ទ្រិយដែលជាវេទនា ៥ ចំណែកមួយនៃបច្ចយាការក្នុងអង្គនៃបដិច្ចសមុប្បាទ ១២ គឺវេទនាដែលមានព្រោះផស្សៈជាបច្ច័យ ចំណែកមួយនៃសតិប្បដ្ឋានក្នុងសតិប្បដ្ឋាន ៤ គឺវេទនានុបស្សនា ចំណែកមួយនៃឈានក្នុងឈាន ៤ គឺសុខវេទនានិងឧបេក្ខាវេទនា ចំណែកមួយនៃនាមរូបក្នុងនាមរូប គឺវេទនា ចំណែកមួយនៃធម៌ក្នុងធម៌ទាំងពួង មានកុសលធម៌ជាដើម គឺវេទនា ឈ្មោះថា បទេសវិហារ ដោយអំណាចនៃការពិចារណាវេទនានោះៗ ឯង ។០៚

## អដ្ឋកថាបទេសវិហារញ្ញាណុទ្ទេស ចប់

# ៤៤.អដ្ឋកថា

## សញ្ញាវិវដ្តញាណុទ្ទេស

ព្រោះហេតុដែលបុថុជ្ជន និងព្រះសេក្ខបុគ្គលទាំងឡាយ កាលចម្រើនញាណ ដែលសម្រេចហើយដោយសមាធិភាវនាជាដើម ធ្វើភាវនាធម៌ដែលគួរចម្រើន នោះៗ ឲ្យជាអធិបតី ឲ្យជាធំ ហើយពិចារណាធម៌ទាំងឡាយ ដែលមានសភាវៈ ផ្សេងៗ ដែលគប្បីលះដោយធម៌នោះៗ ដែលជាសត្រូវចំពោះធម៌នោះ ដែល មានទោសជាអនេក ដោយភាពជាធម៌មានទោសហើយតាំងចិត្តទុក ដោយ អំណាចនៃភាវនា ធម៌នោះៗ ក៏រមែងលះធម៌ដែលជាសត្រូវនោះៗ ចេញបាន ម្យ៉ាងទៀត កាលលះក្នុងខណៈចម្រើនវិបស្សនា ក៏ឃើញសង្ខារធម៌ទាំងពួង ដោយភាពជារបស់ទទេ រមែងលះបានដោយសមុច្ឆេទប្បហាន ក្នុងកាលជា ខាងក្រោយ ម្យ៉ាងទៀត កាលលះបង់យ៉ាងនោះ ចាក់ធ្លុះសច្ចៈទាំងឡាយ រមែងលះបានដោយការត្រាស់ដឹងក្នុងខណៈមួយ ព្រះអរិយៈទាំងឡាយ រមែង បដិបត្តិតាមគួរ ដោយអាការទាំងឡាយ តាមដែលពោលហើយនោះឯង ហេតុនោះ ទើបឥឡូវនេះ ព្រះធម្មសេនាបតីសារីបុត្តលើកញាណទាំង ៦ មាន សញ្ញាវិវដ្តញាណជាដើមឡើង សម្ដែងបន្ទាប់អំពីបទេសវិហារញ្ញាណតាមលំដាប់ ។

ក្នុងសញ្ញាវិវដ្តញាណនោះ បទថា **អធិបតត្តា បញ្ញា** បានដល់ បញ្ញា ដែលធ្វើកុសលធម៌ មាននេក្ខម្មជាដើម ឲ្យជាធម៌ដែលក្រៃលែង ដោយភាព ជាអធិបតីនៃកុសលធម៌ទាំងឡាយ មាននេក្ខម្មៈជាដើម ហើយប្រព្រឹត្តទៅ ដោយភាពជាធម៌ដ៏ក្រៃលែងក្នុងកុសលធម៌ មាននេក្ខម្មជាដើមនោះ ។

បទថា **សញ្ញាវិវដ្តេ ញាណំ** មានវិនិច្ឆ័យថា ការចៀសចេញ ការវិលចេញ ភាពជាអ្នកបែរខ្នងឲ្យ ( នីវរណៈ មានកាមច្ឆន្ទៈជាដើម ) បានដោយសញ្ញា ព្រោះហេតុនោះ ទើបឈ្មោះថា សញ្ញាវិវដ្ត មានអធិប្បាយថា ព្រះយោគីបុគ្គល រមែងបំពេញភាវនាធម៌នោះៗ ឲ្យជាអធិបតី ដោយសញ្ញាណាញាណក្នុងការចៀសចេញចាកនីវរណៈ មានកាមច្ឆន្ទៈជាដើមនោះៗ ដោយសញ្ញាដែលជាហេតុ ជាការណៈនោះ សូម្បីមិនបានពោលថា ចៀសចេញចាកធម៌នេះ ក៏រមែងកាន់យកបានថា ចៀសចេញចាកធម៌ណា ក៏ចៀសចេញចាកធម៌នោះឯង ដូចវិវដ្តនានុបស្សនា ( ដែរ ) ។

សញ្ញានោះ មានការចាំអារម្មណ៍ជាលក្ខណៈ មានការធ្វើគ្រឿងសម្គាល់ដែលជាបច្ច័យឲ្យដឹងថា នេះគឺរបស់នោះជាកិច្ច ដូចជាងឈើធ្វើគ្រឿងសម្គាល់ត្រង់ឈើជាដើម មានការធ្វើការប្រកាន់មាំ ដោយអំណាចគ្រឿងសម្គាល់តាមដែលកាន់យកហើយជាអាការប្រាកដ ដូចមនុស្សភ្នែកខ្វាក់ស្ទាបដំរី ម្យ៉ាងទៀត មានការតាំងនៅមិនយូរ ព្រោះប្រព្រឹត្តទៅ ដោយមិនឈមចុះក្នុងអារម្មណ៍ជាអាការប្រាកដដូច ផ្លេកបន្ទោរ មានអារម្មណ៍តាមដែលប្រាកដជាហេតុជិត ដូចសញ្ញាក្នុងទីងមោងដែលធ្វើដោយស្មៅ កើតដល់កូនម្រឹគថាជាបុរស ៕០៚

**អដ្ឋកថាសញ្ញាវិវដ្តញ្ញាណុទ្ទេស ចប់**

## ៤៥. អដ្ឋកថា

## ចេតោវិវដ្តញ្ញាណុទ្ទេស

បទថា **នានត្តេ បញ្ញា** បានដល់ បញ្ញាដែលប្រព្រឹត្តទៅហើយ ក្នុងសភាវធម៌ផ្សេងៗ ដោយភាពជាភាវេតព្វធម៌ ធម៌ដែលគួរចម្រើន និងក្នុងសភាវធម៌ដទៃ មានកាមច្ឆន្ទៈជាដើម ដោយឃើញថា ជាធម៌មានទោស ។

ម្យ៉ាងទៀត បទថា **នានត្តេ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃនិមិត្តសត្តមី ម្យ៉ាងទៀត ការលះនូវភាពជាធម៌ផ្សេងៗ ឈ្មោះថា **នានត្ត** អធិប្បាយថា បញ្ញាក្នុងនេក្ខម្មៈជាដើម ជានិមិត្តនៃការលះនូវភាពជាធម៌ផ្សេងៗ ជាហេតុនៃការលះនូវភាពជាធម៌ផ្សេងៗ ។

បទថា **ចេតោវិវដ្តេ ញាណំ** បានដល់ ញាណក្នុងនេក្ខម្មជាដើម ដែលជាគ្រឿងចេញចាកកាមច្ឆន្ទៈជាដើមបានដោយចិត្ត ។

ក្នុងបទថា **ចេតោ** នេះ លោកបំណងយកចេតនា ។ ចេតនានោះមានការតាំងចិត្តជាលក្ខណៈ ឬមានការតាក់តែងជាលក្ខណៈ មានការប្រមូលមកជាកិច្ច មានការចាត់ចែងជាអាការប្រាកដ ដូចសិស្សច្បង និងមេជាងធ្វើកិច្ចរបស់ខ្លួន និងកិច្ចរបស់អ្នកដទៃឲ្យសម្រេច ដូច្នោះ ។ ក៏ចេតនានេះ រមែងប្រាកដដោយការលើកសម្បយុត្តធម៌ទាំងឡាយក្នុងកិច្ច មានការតាមរឭកដល់ការងារដែលប្រញាប់ប្រញាល់ជាដើម ៕

**អដ្ឋកថាចេតោវិវដ្តញ្ញាណុទ្ទេស ចប់**

# ៤៦. អដ្ឋកថា

# ចិត្តវិវដ្ដញ្ញាណុទ្ទេស

បទថា **អធិដ្ឋានេ បញ្ញា** បានដល់ បញ្ញាក្នុងការធ្វើចិត្តឲ្យតាំងមាំដោយអំណាចនៃគុណ មាននេក្ខម្មៈជាដើម ។

បទថា **ចិត្តវិវដ្ដេ ញាណំ** បានដល់ ញាណក្នុងការគេចចេញនៃចិត្តដោយអំណាចនៃការលះកាមច្ឆន្ទៈជាដើម ។ ក៏ក្នុងទីនេះ ចិត្ត មានការដឹងជាលក្ខណៈ មានការកើតមុនជាកិច្ច មានការកើតឡើងជាប់តគ្នាមិនដាច់ជាអាការប្រាកដ មាននាមរូបជាហេតុជិត ៕ ៚

**អដ្ឋកថាចិត្តវិវដ្ដញ្ញាណុទ្ទេស ចប់**

## ៤៧. អដ្ឋកថា

## ញាណវិវដ្ដញ្ញាណុទ្ទេស

បទថា **សុញ្ញតេ បញ្ញា** បានដល់ បញ្ញាជាគ្រឿងតាមឃើញដោយភាពជាអនត្តា ដែលប្រព្រឹត្តទៅហើយក្នុងអនត្តធម៌ និងធម៌ដែលទាក់ទងដោយអនត្ត ដោយភាពជាសភាវៈទទេចាកអត្តា និងធម៌ដែលទាក់ទងដោយអត្តា ។

បទថា **ញាណវិវដ្ដេ ញាណំ** មានវិគ្គហៈថា ញាណនោះឯង រមែងចៀសចេញចាកការប្រកាន់មាំ ព្រោះហេតុនោះ ទើបឈ្មោះថា **វិវដ្ដ** ។ ញាណដែលជាហេតុនៃការចៀសចេញដោយញាណនោះ ។ល។

អដ្ឋកថាញាណវិវដ្ដញ្ញាណុទ្ទេស ចប់

# ៤៨. អដ្ឋកថា

## វិមោក្ខវិវដ្ដញ្ញាណុទ្ទេស

ក្នុងបទនេះថា **វោស្សគ្គេ បញ្ញា** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ធម៌ណា រមែងលះបង់ចេញ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វោស្សគ្គោ** ។ ការលះបង់ចេញនូវកាមច្ឆន្ទៈជាដើម ជាបញ្ញាក្នុងគុណ មាននេក្ខម្មៈជាដើម ។

បទថា **វិមោក្ខវិវដ្ដេ ញាណំ** មានវិនិច្ឆ័យថា ធម៌ណា រមែងផុតពីកាមច្ឆន្ទៈជាដើម ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វិមោក្ខ** ។ ការបៀសចេញ គឺវិមោក្ខ ឈ្មោះថា **វិមោក្ខវិវដ្ដ** វិមោក្ខវិវដ្ដនោះឯងជាញាណ ។៤៨

**អដ្ឋកថាវិមោក្ខវិវដ្ដញ្ញាណុទ្ទេស ចប់**

## ៤៩.អដ្ឋកថា

## សច្ចវិវដ្ដញ្ញាណុទ្ទេស

បទថា **តជ្ជេ បញ្ញា** បានដល់ បញ្ញាដែលប្រព្រឹត្តទៅដោយមិនវង្វេង ដោយអំណាចនៃកិច្ច ក្នុងសភាវៈដែលមិនវិបរិត ក្នុងសច្ចៈនីមួយៗ សច្ចៈនីមួយៗ មាន ៤ ។

បទថា **សច្ចវិវដ្ដេ ញាណំ** មានវិនិច្ឆ័យថា ធម្មជាតណា រមែងចៀសចេញ ដោយអំណាចនៃការចេញចាកចំណែកទាំង ២ ក្នុងសច្ចៈទាំង ៤ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **សច្ចវិវដ្ដ សច្ចវិវដ្ដ** នោះឯងជាញាណ ។ ញាណមួយប៉ុណ្ណោះលោកពោលដល់ ៤ ប្រការយ៉ាងនេះ គឺ **សញ្ញាវិវដ្ដ** ដោយអំណាចនៃធម៌ដែលធ្វើឲ្យជាអធិបតី ១ **ចេតោវិវដ្ដ** ដោយអំណាចនៃធម៌ដែលគួរលះបង់ ១ **ចិត្តវិវដ្ដ** ដោយអំណាចនៃការធ្វើចិត្តឲ្យតាំងមាំ ១ **វិមោក្ខវិវដ្ដ** ដោយអំណាចនៃការលះធម៌ដែលជាសត្រូវ ១ ។

អនត្តានុបស្សនានោះឯង លោកពោលថា ញាណវិវដ្ដញ្ញាណ ដោយអំណាចនៃអាការដែលទទេចាកអត្តា ។ មគ្គញ្ញាណនោះឯង ក៏ធ្លាប់ពោល ២ យ៉ាង គឺមគ្គញ្ញាណ និងអានន្តរិកសមាធិញ្ញាណ ។ ក្នុងទីនេះ ពោលថា សច្ចវិវដ្ដញ្ញាណ ដោយអំណាចនៃការចៀសចេញ ៕

**អដ្ឋកថាសច្ចវិវដ្ដញ្ញាណុទ្ទេស ចប់**

## ៩០. អដ្ឋកថា

## ឥទ្ធិវិធញ្ញាណុទ្ទេស

ឥឡូវនេះ ព្រះធម្មសេនាបតីសារីបុត្ត លើកឡើងនូវអភិញ្ញាញាណ ៦ ដែលប្រព្រឹត្តទៅដោយអំណាចនៃញាណ ក្នុងការអស់ទៅនៃអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចសច្ចវិវដ្តញ្ញាណនោះ សម្តែងដោយលំដាប់ ។ ក្នុងអភិញ្ញាញាណ ៦ នោះ លោកលើកឡើងនូវឥទ្ធិវិធញ្ញាណសម្តែងជាលំដាប់ដំបូង ព្រោះថា ជាការចម្លែក ព្រោះជាអានុភាពដែលប្រាកដដល់លោក លើកឡើងនូវទិព្វសោតញ្ញាណសម្តែងជាលំដាប់ទី ២ ព្រោះថា ទិព្វសោតញ្ញាណ ជាវិស័យដែលនៅគ្រោតគ្រាត ដោយវិស័យរបស់ចេតោបរិយញ្ញាណ លើកឡើងនូវចេតោបរិយញ្ញាណ សម្តែងជាលំដាប់ទី ៣ ព្រោះជាវិស័យដែលល្អិត ។ បណ្តាវិជ្ជា ៣ លោកលើកបុព្វេនិវាសានុស្សតិញ្ញាណ សម្តែងជាលំដាប់ទី ១ ព្រោះបន្ទោបង់ភាពងងឹតក្នុងអតីត ដែលបិទបាំងការកើតក្នុងជាតិមុន លើកទិព្វចក្ខុញ្ញាណសម្តែងជាលំដាប់ទី ២ ព្រោះបន្ទោបង់ភាពងងឹត ទាំងក្នុងបច្ចុប្បន្ន និងអនាគត លើកអាសវក្ខយញ្ញាណឡើងសម្តែងជាលំដាប់ទី ៣ ព្រោះកាត់នូវងងឹតទាំងអស់បានជាសមុច្ឆេទ ។

បណ្តាបទទាំងនោះ បទថា **កាយម្បិ** បានដល់ នូវរូបកាយ ។ បទថា **ចិត្តម្បិ** បានដល់ នូវចិត្តដែលមានឈានជាបាទ ។

បទថា **ឯកវវត្ថានតា** មានពាក្យអធិប្បាយថា ដោយការតាំងទុកដោយភាពជាមួយគ្នា ដោយបរិកម្មចិត្ត និងដោយការធ្វើកាយ និងចិត្ត ឲ្យលាយឡំគ្នា

តាមដែលប្រកបបានក្នុងគ្រាដែលបំណាន់នឹងទៅដោយការប្រាកដនៃកាយ ( ឲ្យឃើញកាយ ) ឬដោយការមិនប្រាកដនៃកាយ ( បំបាំងកាយ ) ។

បទថា **កាយោ** ក្នុងទីនេះ បានដល់ សរីរៈ ។ ពិតហើយ សរីរៈលោកហៅថា កាយ ព្រោះជាប្រភពកើតនៃអវយវៈទាំងឡាយ មានសក់ជាដើមដែលគួរខ្ពើម ព្រោះសន្សំទុកនូវការមិនស្អាត និងជាប្រភពកើតនៃរោគច្រើនរយ មានចក្ខុរោគជាដើម ។

៥ សព្ទ លោកប្រកបក្នុងពាក្យនេះថា **សុខសញ្ញញ្ចលហុសញ្ញញ្ច** ប្រើក្នុងអត្ថឲ្យរួមចូលគ្នាដោយធ្វើសញ្ញាតែមួយប៉ុណ្ណោះ ដែលសម្បយុត្តជាមួយចតុត្ថជ្ឈានឲ្យជាពីរយ៉ាង ដោយការផ្សេងគ្នាដោយអាការ ។ ពិតហើយឧបេក្ខាក្នុងចតុត្ថជ្ឈាន លោកពោលថា ស្ងប់ ជាសុខ សញ្ញាដែលសម្បយុត្តជាមួយឧបេក្ខានោះ ឈ្មោះថា សុខសញ្ញា ។ សុខសញ្ញានោះឯង ឈ្មោះថា **លហុសញ្ញា** ព្រោះផុតចាកនីវរណធម៌ទាំងឡាយ និងធម៌ដែលជាសត្រូវមានវិតក្កជាដើម ។

បទថា **អធិដ្ឋានវសេន** បានដល់ ដោយអំណាចនៃការតាំងទុក ដោយធ្វើឲ្យក្រៃលែង អធិប្បាយថា ដោយអំណាចនៃការចូលទៅ ។ ៥ សព្ទ គប្បីនាំមកភ្ជាប់ថា **អធិដ្ឋានវសេន** ៥ ។ ហេតុតាមដែលប្រកបបានរបស់ឥទ្ធិវិធៈដែលមានប្រការទាំងពួង លោកពោលហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បទថា **ឥជ្ឈនដ្ឋេ បញ្ញា** បានដល់ បញ្ញាក្នុងសភាវៈ គឺការសម្រេច ។

បទថា **ឥទ្ធិវិធេ ញាណំ** មានពាក្យអធិប្បាយថា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច ឬព្រោះអត្ថថា បានចំពោះ ដោយអត្ថថា សម្រេច ។ ពិតហើយ របស់ណានឹងសម្រេចក្តី នឹងបានចំពោះក្តី របស់នោះ លោកហៅថា រមែងសម្រេច ។ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា កាលសត្វប្រាថ្នាកាមណា បើកាមនោះ សម្រេចដល់សត្វនោះដូច្នេះ ។ មួយទៀត ដូចលោកពោលថា ឈ្មោះថា ឥទ្ធិ ព្រោះនេក្ខម្មៈសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់កាមច្ឆន្ទៈ ឈ្មោះថា ឫទ្ធិ ព្រោះអរហត្តមគ្គសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវកិលេសទាំងពួង[១] ដូច្នេះ។ ន័យមួយទៀតថា ឈ្មោះថា ឥទ្ធិ ដោយអត្ថថា សម្រេច ពាក្យនេះ ជាឈ្មោះនៃឧបាយសម្បទា ពិតហើយ ឧបាយសម្បទា រមែងសម្រេចព្រោះប្រសព្វផលដែលខ្លួនប្រាថ្នា ។ សមដូចទេវតាគិត ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ចិត្តគហបតីនេះមានសីល មានធម៌ល្អ បើគាត់នឹងតាំងសេចក្តីប្រាថ្នាថា អាត្មាអញ គប្បីបានជាស្តេចចក្រពត្តិ ក្នុងកាលជាអនាគត ( ក៏បាន ) ។ ឯសេចក្តីប្រាថ្នាក្នុងចិត្តនេះ របស់ចិត្តគហបតីដែលមានសីលនោះ នឹងសម្រេចព្រោះសីលបរិសុទ្ធដូច្នេះ ន័យដទៃទៀតថា សត្វទាំងឡាយរមែងសម្រេចបានដោយធម្មជាតនោះ ហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **ឥទ្ធិ** ។

ពាក្យថា រមែងសម្រេច មានអធិប្បាយថា សម្រេច គឺចម្រើន គឺរមែងដល់នូវការប្រាកដច្បាស់ ។ **វិធ** គឺឥទ្ធិនោះឯង ឈ្មោះថា ឥទ្ធិវិធៈ អធិប្បាយ

---

១- បិដកលេខ ៧១ ឃ្នាប ១៩៣ ។

ថា ចំណែកនៃឫទ្ធិ ការកំណត់ដោយឫទ្ធិ ។ មានអធិប្បាយថា ញាណ គឺ ឥទ្ធិវិធៈនោះ ។ល។

## អដ្ឋកថាឥទ្ធិវិធញ្ញាណុទ្ទេស ចប់

## ៥១. អដ្ឋកថា
## សោតធាតុវិសុទ្ធិញ្ញាណុទ្ទេស

បទថា **វិតក្កវិប្ផារវសេន** បានដល់ ដោយអំណាចការផ្សាយទៅនៃវិតក្ក គឺដោយអំណាចនៃវិតក្ករបស់ខ្លួន ក្នុងសទ្ទនិមិត្តក្នុងពេលធ្វើបរិកម្ម ដើម្បីធ្វើទិព្វសោតធាតុឲ្យកើតឡើង ។

ក្នុងបទថា **វិតក្កោ** នេះ មានវិគ្គហៈថា ធម្មជាតណារមែងត្រិះរិះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វិតក្ក** ម្យ៉ាងទៀត ការត្រិះរិះ ឈ្មោះថា **វិតក្កោ** មានពាក្យអធិប្បាយថា ការទល់គ្នានឹងអារម្មណ៍ ។ វិតក្កនោះ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ មានការធ្វើឲ្យចិត្តប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច ។ ពិតហើយ លោកពោលថា ព្រះយោគីបុគ្គល រមែងធ្វើអារម្មណ៍ឲ្យជាធម្មជាតត្រូវវិតក្កប៉ះខ្ទប់ហើយ ប៉ះខ្ទប់ទៀតរឿយៗ ដោយចិត្តនោះ ។ មានការនាំចិត្តមកក្នុងអារម្មណ៍ជាអាការប្រាកដ ។ លោកពោលថា មានអារម្មណ៍ ដែលមកដល់គន្លង ដោយការកើតឡើង ដោយឥន្ទ្រិយដែល

មកប្រជុំព្រម ដើម្បីការកើតឡើងនៃវិតក្កនោះ និងដោយមិនមានការទើស ទាក់ក្នុងអារម្មណ៍ ដែលចោមរោមហើយជាហេតុជិត ។

បទថា **នានត្តេកត្តសទ្ទនិមិត្តានំ** បានដល់ នូវសំឡេងជានិមិត្ត ទាំងដែល មានសភាវៈផ្សេងៗ និងមានសភាវៈមួយ ។ ក្នុងពាក្យថា សំឡេងនោះឯងជា និមិត្ត ព្រោះជាហេតុនៃការកើតឡើងនៃវិតក្ក និងព្រោះជានិមិត្តនៃសង្ខារ ។ សំឡេងច្រើនយ៉ាងដែលមូលគ្នាតែមួយ ដូចសំឡេងស្គរជាដើម ឬសំឡេងក្នុង ទិសផ្សេងៗ ឬសំឡេងក្នុងសត្វផ្សេងៗ ឈ្មោះថា **នានត្តសទ្ទា** សំឡេងក្នុងទិស មួយ ឬសំឡេងសត្វមួយ ឬសំឡេងតែមួយ សំឡេងដូចជាសំឡេងស្គរ ជាដើម ឈ្មោះថា **ឯកត្តសទ្ទា** ។

បទថា **សទ្ទោ** នេះ មានវិគ្គហៈថា ធម្មជាតណា រមែងផ្សាយទៅ ព្រោះ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា សំឡេង អធិប្បាយថា សំឡេងដែលបន្លឺ ចេញមក ។

បទថា **បរិយោគាហណេ បញ្ញា** បានដល់ បញ្ញាជាគ្រឿងចូលដល់ អធិប្បាយថា បញ្ញាជាគ្រឿងដឹង ។

បទថា **សោតធាតុវិសុទ្ធិញ្ញាណំ** មានវិនិច្ឆ័យថា ឈ្មោះថា **សោតធាតុ** ព្រោះអត្ថថា បាន ឬព្រោះអត្ថថា មិនមែនជីវៈ និងឈ្មោះថា **សោតធាតុ** ព្រោះអត្ថថា ដូចសោតធាតុ ដោយអំណាចនៃការធ្វើកិច្ចរបស់សោតធាតុ ឈ្មោះថា **វិសុទ្ធិ** ព្រោះសោតធាតុនោះ បរិសុទ្ធហើយ ព្រោះមិនមាន ឧបក្កិលេស ការបរិសុទ្ធ គឺសោតធាតុ ឈ្មោះថា **សោតធាតុវិសុទ្ធិ** ញាណ

*គឺសោតធាតុ វិសុទ្ធិ ឈ្មោះថា* **សោតធាតុវិសុទ្ធិញ្ញាណ** *។*

**អដ្ឋកថាសោតធាតុវិសុទ្ធិញ្ញាណុទ្ទេស ចប់**

## ៥២. អដ្ឋកថា

## ចេតោបរិយញ្ញាណុទ្ទេស

*បទថា* **តិណ្ណំ ចិត្តានំ** *បានដល់ នៃចិត្ត ៣ គឺសោមនស្សសហគតចិត្ត ១ ទោមនស្សសហគតចិត្ត ១ ឧបេក្ខាសហគតចិត្ត ១ ។*

*បទថា* **វិប្ផារត្តា** *បានដល់ ព្រោះភាវៈដែលផ្សាយទៅ អធិប្បាយថា ព្រោះការស្ទុះទៅ ។ បទថា* **វិប្ផារត្តា** *នេះ ជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថនៃហេតុ សេចក្ដីថា ព្រោះហេតុនៃការផ្សាយទៅនៃចិត្ត ៣ ដទៃ ក្នុងកាលជាទីធ្វើបរិកម្ម ដើម្បីឲ្យចេតោបរិយញ្ញាណកើតឡើង ។*

*បទថា* **ឥន្ទ្រិយានំ បសាទវសេន** *បានដល់ ដោយអំណាចការផូរផង់នៃឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ក្នុងទីនេះ ឱកាសជាទីតាំងនៃឥន្ទ្រិយទាំងឡាយ លោកពោលដោយពាក្យថា* **ឥន្ទ្រិយានំ** *ដោយផលូបចារន័យ ( ពោលហេតុតែសំដៅដល់ផល ) ដូចពាក្យ ( វិនយបិដក មហាវគ្គ ) ថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នក ជ្រះថ្លាណាស់ ឆវិវណ្ណ ( សម្បុរស្បែក ឬសម្បុរថ្ងៃ ) របស់អ្នកក៏បរិសុទ្ធផូរផង់ ដូច្នេះ ។ ហទយវត្ថុនោះឯង លោក*

បំណងហើយក្នុងទីនេះ សូម្បីក្នុងឱកាសដែលជាទីតាំងនៃឥន្ទ្រិយទាំងឡាយ ។

បទថា **បសាទវសេន** បានដល់ ដោយអំណាចនៃការមិនល្អក់កករ ។ កាលគួរពោលថា **បសាទប្បសាទវសេន** ( ដោយអំណាចនៃការផូរផង់ និងការមិនផូរផង់ ) ពាក្យនេះ គប្បីជ្រាបថា លោកធ្វើការលុប **អប្បសាទ** សព្ទចេញ ។ ម្យ៉ាងទៀត គប្បីជ្រាបថា សូម្បីការមិនជ្រះថ្លា ក៏លោកពោលហើយនោះឯង ដោយពាក្យថា **បសាទវសេន** នោះឯងដោយដែនកើត ព្រោះសម្ទឹងដល់ការផូរផង់នៃសព្ទថា ឥន្ទ្រិយនេះមិនផូរផង់ហើយ ។

បទថា **នានត្តេកត្តវិញ្ញាណចរិយាបរិយោគាហណេ បញ្ញា** បានដល់ បញ្ញាក្នុងការដឹងការប្រព្រឹត្តទៅរបស់ចិត្ត ៨៩ ដែលមានសភាវៈផ្សេងៗ គ្នា និងមានសភាវៈដូចគ្នា តាមសមគួរដល់ការកើតឡើង ។ ក្នុងវិញ្ញាណចរិយាទាំង ២ នេះ វិញ្ញាណចរិយារបស់អ្នកមិនបានសមាធិ ជាវិញ្ញាណចរិយាច្រើនយ៉ាង វិញ្ញាណចរិយារបស់អ្នកបានសមាធិ ជាវិញ្ញាណចរិយាតែមួយ ម្យ៉ាងទៀត ចិត្តប្រកបដោយរាគៈជាដើម ជាវិញ្ញាណចរិយាច្រើនយ៉ាង ។ ចិត្តប្រាសចាករាគៈជាដើម ជាវិញ្ញាណចរិយាតែមួយ ។

ឈ្មោះថា **បរិយ** ក្នុងបទថា **ចេតោបរិយញ្ញាណំ** នេះ ព្រោះអត្ថថាកំណត់ អធិប្បាយថា កំណត់ជុំវិញ ។ ការកំណត់ដោយចិត្ត ឈ្មោះថា **ចេតោ-បរិយ** ចេតោបរិយៈនោះផង ជាញាណផង ព្រោះហេតុនោះ ឈ្មោះថា **ចេតោបរិយញ្ញាណ** ។ បាឋៈថា **វិត្ថារតា** ដូច្នេះក៏មាន អធិប្បាយថា ព្រោះការផ្សាយទៅ ៕៚

## អដ្ឋកថាចេតោបរិយញ្ញាណុទ្ទេស ចប់

## ៥៣. អដ្ឋកថា

## បុព្វេនិវាសានុស្សតិញ្ញាណុទ្ទេស

បទថា **បច្ចយប្បវត្តានំ ធម្មានំ** បានដល់ នូវបច្ចយុប្បន្នធម៌ដែលប្រព្រឹត្តទៅហើយដោយបច្ច័យ ដោយអំណាចនៃការអាស្រ័យគ្នាកើតឡើង ។

បទថា **នានត្តេកត្តកម្មវិជ្ជារវសេន** នេះ មានវិនិច្ឆ័យថា អកុសលកម្ម ឈ្មោះថា កម្មដែលមានសភាពផ្សេងៗ គ្នា កុសលកម្មឈ្មោះថា កម្មមានសភាពតែមួយ ម្យ៉ាងទៀត កាមាវចរកម្ម ឈ្មោះថា កម្មដែលមានសភាពផ្សេងៗ គ្នា រូបាវចរកម្ម និងអរូបាវចរ ឈ្មោះថា កម្មមានសភាពតែមួយ ។ គប្បីសម្ពន្ធថា បញ្ញាក្នុងការកំណត់ធម៌ ដែលប្រព្រឹត្តទៅដោយបច្ច័យ ដោយអំណាចនៃការផ្សាយទៅនៃកម្មដែលមានសភាពផ្សេងៗ គ្នា ឬកម្មមានសភាពតែមួយ ។

បទថា **បុព្វេនិវាសានុស្សតិញ្ញាណំ** បានដល់ ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន គឺក្នុងអតីតជាតិ ឈ្មោះថា **បុព្វេនិវាស** ។

បទថា **និវុត្ថា** បានដល់ ខន្ធដែលធ្លាប់នៅ គឺដែលមានហើយ កើតឡើងហើយ ក៏រលត់ទៅក្នុងសន្តានរបស់ខ្លួន ។ ឬធម៌ដែលធ្លាប់នៅហើយក្នុងកាលមុន គឺក្នុងអតីតជាតិ ឈ្មោះថា **បុព្វេនិវាស** ( ធម៌ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ) ។

បទថា **និវុត្ថា** បានដល់ ខន្ធដែលធ្លាប់នៅ គឺដែលមានហើយ បានដល់កើតឡើងហើយ ក៏រលត់ទៅក្នុងសន្តានរបស់ខ្លួន ឬធម៌ដែលធ្លាប់នៅហើយក្នុងកាលមុន គឺក្នុងអតីតជាតិ ឈ្មោះថា **បុព្វេនិវាស** ។

*បទថា* **និវុត្ថា** *បានដល់ នៅហើយដោយការនៅព្រោះអាស្រ័យធម៌ដូច ពោលហើយជាអារម្មណ៍ គឺដឹងច្បាស់ កំណត់បានដោយចិត្តរបស់ខ្លួន ឬដឹងច្បាស់ដោយចិត្តរបស់អ្នកដទៃ ។ ធម៌ទាំងនោះ រមែងមានដល់ព្រះសម្ពុទ្ធប៉ុណ្ណោះ បណ្ដាការរឭកដល់ការវិលវល់ ស្លាប់កើត រំលងលំដាប់ជាដើម ។*

*ពាក្យថា* **បុព្វេនិវាសានុស្សតិ** *បានដល់ តាមរឭកដល់ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងគ្រាមុន បានដោយសតិណា សតិនោះ ឈ្មោះថា* **បុព្វេនិ-វាសានុស្សតិ** *។*

*បទថា* **ញាណំ** *បានដល់ ញាណដែលសម្បយុត្តដោយសតិនោះ ៕*

អដ្ឋកថាបុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស ចប់

# ៥៤. អដ្ឋកថា
# ទិព្វចក្ខុញ្ញាណុទ្ទេស

*បទថា* **ឱភាសវសេន** *បានដល់ ដោយអំណាចនៃកសិណមានពន្លឺ ដែលជាអារម្មណ៍នៃចតុត្ថជ្ឈានឯណានីមួយ បណ្ដាតេជោកសិណ ឱទាតកសិណ អាលោកកសិណ ដែលផ្សាយទៅដើម្បីឃើញរូបដោយទិព្វចក្ខុ ។*

*បទថា* **នានត្តេកត្តរូបនិមិត្តានំ** *បានដល់ រូបរបស់សត្វផ្សេងៗ ឬរូបរបស់សត្វទាំងឡាយដែលកើតឡើងក្នុងជំពូកសត្វដែលមានកាយផ្សេងគ្នា ឬរូបទាំងឡាយក្នុងទិសផ្សេងៗ ឬរូបទាំងឡាយដែលមិនលាយឡំគ្នា ឈ្មោះថា* **នានត្តរូប** *រូបនៃសត្វមួយ ឬរូបនៃសត្វដែលកើតនៅក្នុងជំពូកដែលមានកាយដូចគ្នា ឬរូបទាំងឡាយក្នុងទិសតែមួយ ឬរូបទាំងឡាយដែលចូលគ្នាបាននៃទិសផ្សេងៗជាដើម ឈ្មោះថា* **ឯកត្តរូប** *។*

*ក្នុងបទថា* **រូបំ** *នេះ បានដល់ វណ្ណាយតនៈ គឺពណ៌ប៉ុណ្ណោះ ព្រោះវណ្ណាយតនៈនោះ រមែងបែកធ្លាយទៅ ព្រោះហេតុនោះ ទើបឈ្មោះថា រូប អធិប្បាយថា វណ្ណាយតនៈនោះ កាលដល់នូវវណ្ណវិការ រមែងប្រកាសការដល់នូវហទយៈ ។ រូបនោះឯងឈ្មោះថា* **រូបនិមិត្តំ** *។ រូបជានិមិត្តច្រើនយ៉ាង ឬតែមួយទាំងនោះ ។*

*បទថា* **ទស្សនដ្ឋេ បញ្ញា** *បានដល់ បញ្ញាក្នុងការឃើញជាសភាវៈ ។*

*បទថា* **ទិព្វចក្ខុញ្ញាណំ** *មានវិគ្គហៈថា ឈ្មោះថា* **ទិព្វ** *ព្រោះដូចជារបស់ទិព្វ ។ ពិតហើយ បសាទចក្ខុដែលជាទិព្វរបស់ពួកទេវតា ដែលកើតឡើងដោយសុចរិតកម្ម មិនប្រឡាក់ដោយមន្ទិលទាំងឡាយ មានទឹកប្រមាត់ ស្លេស្ម*

*និងឈាមជាដើម អាចទទួលអារម្មណ៍ សូម្បីនៅក្នុងទីឆ្ងាយបាន ព្រោះផុតចាកមន្ទិលជាគ្រឿងសៅហ្មង ។ សូម្បីញាណចក្ខុនេះ ដែលកើតព្រោះកម្លាំងនៃវិរិយភាវនាក៏ដូចគ្នានោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា* **ទិព្វ** *ព្រោះដូចគ្នានឹងរបស់ទិព្វ ឈ្មោះថា* **ទិព្វ** *ព្រោះជាធម៌ដែលខ្លួនអាស្រ័យទិព្វវិហារធម៌ ព្រោះបានចំពោះដោយអំណាចទិព្វវិហារធម៌ ឈ្មោះថា* **ទិព្វ** *ព្រោះជារបស់រុងរឿងច្រើនដោយការកំណត់ពន្លឺ ឈ្មោះថា* **ទិព្វ** *ព្រោះមានគតិច្រើន ដោយការឃើញរូបខាងក្រៅជញ្ជាំងផ្ទះជាដើមបាន ។*

*ពាក្យទាំងអស់នោះ គប្បីជ្រាបតាមគន្លងនៃគម្ពីរសព្ទសាស្ត្រ ។ ឈ្មោះថា* **ចក្ខុ** *ដោយអត្ថថា ឃើញ ឈ្មោះថា* **ចក្ខុ** *ព្រោះអត្ថថា ដូចចក្ខុដោយការធ្វើកិច្ចរបស់ចក្ខុ ចក្ខុនោះផង ជាទិព្វផង ព្រោះហេតុនោះ ទើបឈ្មោះថា* **ទិព្វចក្ខុ** *ទិព្វចក្ខុនោះផង ញាណផង ទើបឈ្មោះថា* **ទិព្វចក្ខុញ្ញាណ** *៕*

**អដ្ឋកថាទិព្វចក្ខុញ្ញាណុទ្ទេស ចប់**

## ៥៥. អដ្ឋកថា

## អាសវក្ខយញ្ញាណុទ្ទេស

បទថា **ចតុសដ្ឋិយា អាការេហិ** បានដល់ ដោយអាការ ៦៤ ដោយអំណាចនៃឥន្ទ្រិយនីមួយៗ ៨ ក្នុងមគ្គផលនីមួយៗ ៨ ។

បទថា **តិណ្ណន្នំ ឥន្ទ្រិយានំ** បានដល់ ក្នុងឥន្ទ្រិយទាំង ៣ គឺ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ។

បទថា **វសិភាវតា បញ្ញា** បានដល់ បញ្ញាដែលប្រព្រឹត្តទៅហើយដោយភាពជាអ្នកមានសេចក្តីជំនាញ គប្បីជ្រាបថា លោកពោលពាក្យនេះហើយ ព្រោះការសម្រេចប្រយោជន៍នៃបញ្ញានោះ ដោយអំណាចនៃការសម្រេចហេតុ ក្នុងការមិនមានក្នុងខណៈនៃអរហត្តមគ្គ ដោយភាពជាអ្នកមានការជំនាញក្នុងអញ្ញាតាវិន្ទ្រិយនោះឯង ដោយអាការ ៨ ដោយអំណាចនៃឥន្ទ្រិយ ៨ ក្នុងអរហត្តផល ។

បទថា **អាសវានំ ខយេ ញាណំ** បានដល់ អរហត្តមគ្គញ្ញាណ ដែលធ្វើនូវការអស់ទៅនៃអាសវៈទាំងឡាយ ដែលខ្ជួនទម្លាយហើយ ។៚

**អដ្ឋកថាអាសវក្ខយញ្ញាណុទ្ទេស ចប់**

# ៩៦-៩៩. អដ្ឋកថា

## ទុក្ខសមុទយនិរោធមគ្គញ្ញាណនិទ្ទេស

ឥឡូវនេះ ដើម្បីសម្ដែងភាពដែលមគ្គញ្ញាណនីមួយៗ បណ្ដាមគ្គញ្ញាណទាំង ៤ ជាការត្រាស់ដឹងតែមួយ ទាក់ទងជាមួយអរហត្តមគ្គញ្ញាណ ពោលគឺ អាសវក្ខយញ្ញាណ ទើបព្រះធម្មសេនាបតីសារីបុត្ត លើកឡើងនូវញាណទាំង ៤ មានបទថា **បរិញ្ញេយ្យ បញ្ញា** ជាដើមសម្ដែង ។ បណ្ដាសច្ចៈទាំង ៤ នោះ លោកពោលទុក្ខសច្ចមុន ដ្បិតថា ជាវត្ថុដែលដឹងបានងាយ ព្រោះទុក្ខសច្ច ជារបស់គ្រោតគ្រាត និងព្រោះមានទៅទូទៅដល់សត្វទាំងពួង ហើយសម្ដែង សមុទយសច្ច បន្ទាប់អំពីទុក្ខសច្ចនោះ ដើម្បីសម្ដែងហេតុនៃទុក្ខសច្ចនោះ បន្ទាប់អំពីនោះ ក៏សម្ដែងនិរោធសច្ច ដើម្បីឲ្យដឹងថាផលរលត់ ក៏ព្រោះហេតុ រលត់ហើយសម្ដែងមគ្គសច្ចក្នុងទីបំផុត ដើម្បីសម្ដែងឧបាយជាគ្រឿងសម្រេច ដល់និរោធសច្ចនោះ ។ ម្យ៉ាងទៀត លោកពោលទុក្ខមុន ដើម្បីឲ្យកើតសេចក្ដី សង្វេគដល់សត្វទាំងឡាយ ដែលជាប់ដោយសេចក្ដីត្រេកអរ និងសុខក្នុងភព បន្ទាប់មក ទើបពោលសមុទយសច្ច ដើម្បីឲ្យដឹងថា ទុក្ខនោះ មិនមែនមានមក ដោយឥតហេតុ មិនមែនមានព្រោះព្រះឥស្សរនិម្មិតជាដើម តែមានមកពីសមុ-ទយៈនេះ បន្ទាប់អំពីនោះ ទើបពោលនិរោធ ដើម្បីឲ្យកើតនូវការធូរស្បើយ ចិត្ត ព្រោះឃើញធម៌ជាគ្រឿងផុតទុក្ខដល់សត្វទាំងឡាយ ដែលមានចិត្តសង្វេគ ហើយ ព្រោះត្រូវទុក្ខដែលប្រព្រឹត្តទៅជាមួយហេតុគ្របសង្កត់ ស្វែងរកធម៌ជា គ្រឿងផុតទុក្ខ បន្ទាប់អំពីនោះ ទើបពោលមគ្គដែលជាគ្រឿងឲ្យដល់និរោធ

ដើម្បីឲ្យសម្រេចនិរោធ ។ ឥឡូវនេះ លោកលើកឡើងនូវញាណទាំងឡាយដែលមានសច្ចៈទាំង ៤ នោះជាអារម្មណ៍ សម្ដែងតាមលំដាប់នោះឯង ។

បណ្ដាញាណទាំងនោះ បទថា **បរិញ្ញដ្ឋេ** បានដល់ ក្នុងសភាវៈដែលទុក្ខជាវត្ថុដែលគួរកំណត់ដឹង ៤ យ៉ាង មានអត្ថថា បៀតបៀនជាដើម ។

បទថា **បហានដ្ឋេ** បានដល់ ក្នុងសភាវៈដែលសមុទយៈជាវត្ថុដែលគួរលះ ៤ យ៉ាង មានអត្ថថា ប្រមូលមកជាដើម ។

បទថា **សច្ឆិកិរិយដ្ឋេ** បានដល់ ក្នុងសភាវៈដែលនិរោធជាវត្ថុដែលគួរធ្វើឲ្យជាក់ច្បាស់ ៤ យ៉ាង មានអត្ថថា រលាស់ចេញចាកទុក្ខជាដើម ។

បទថា **ភាវនដ្ឋេ** បានដល់ ក្នុងសភាវៈដែលមគ្គជាវត្ថុគួរចម្រើន ៤ យ៉ាង មានអត្ថថា ជាគ្រឿងនាំចេញចាកទុក្ខជាដើម ។ល។

## អដ្ឋកថាទុក្ខសមុទយនិរោធមគ្គញ្ញាណុទ្ទេស ចប់

## ៦០-៦៣. អដ្ឋកថា

## ទុក្ខទុក្ខសមុទយទុក្ខនិរោធ
## ទុក្ខនិរោធគាមិនីបដិបទាញាណុទ្ទេស

ឥឡូវនេះ ដើម្បីសម្តែងសច្ចញ្ញាណជាផ្នែកៗ ដោយអំណាចនៃការពិចារណាដល់មគ្គដែលបានចម្រើនហើយក្តី ដោយអំណាចការបានឮ បានស្តាប់របស់អ្នកមិនបានអប់រំមគ្គក្តី ទើបព្រះធម្មសេនាបតីសារីបុត្ត លើកឡើងនូវញាណ ៤ មានទុក្ខញ្ញាណជាដើមសម្តែង ។

បណ្តាញាណទាំងនោះ បទថា **ទុក្ខេ** នេះ មានវិនិច្ឆ័យដូចតទៅនេះ **ទុ** សព្ទនេះ រមែងប្រាកដក្នុងអត្ថថា គួរខ្ពើម ។ ពិតហើយ ជនទាំងឡាយ រមែងហៅបុត្តគួរខ្ពើមថា **ទុបុត្ត**។ ឯ **ខំ** សព្ទនោះ រមែងប្រាកដក្នុងអត្ថថា សោះសូន្យ ។ ពិតហើយ លោកហៅអាកាសដែលទទេថា **ខំ**។ សច្ចៈទី ១ នេះ ឈ្មោះថា គួរខ្ពើម ព្រោះជាទីតាំងនៃឧបទ្រពជាអនេក ឈ្មោះថា សោះសូន្យ ព្រោះវៀរចាកការស្ថិតស្ថេរ ស្អាត សុខ និងតួខ្លួន ដែលពាលជនកំណត់ហើយ ។ ព្រោះហេតុនោះ ទើបពោលថា **ទុក្ខ** ព្រោះភាពជារបស់គួរខ្ពើម និងព្រោះជារបស់សោះសូន្យ ។

ក្នុងបទថា **ទុក្ខសមុទយេ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា **សំ** សព្ទនេះ សម្តែងដល់ សំយោគ ( ការប្រកបព្រមគ្នា ) ដូចក្នុងប្រយោគជាដើមថា **សមាគមោ** មកប្រជុំព្រមគ្នា **សមេតំ** មកដល់ព្រមគ្នា **ឧ** សព្ទនេះ សម្តែងដល់ការកើតឡើង ដូចក្នុងប្រយោគជាដើមថា **ឧប្បន្នំ** កើតឡើងហើយ **ឧទិតំ**

តាំងឡើងហើយ ។ **អយ** សព្ទ រមែងសម្តែងដល់ **ការណ** ( ហេតុ ) ។ សច្ចៈទី ២ នេះ កាលការប្រជុំព្រមនៃបច្ច័យដ៏សេសមាន ក៏ជាហេតុកើតឡើងនៃទុក្ខ ហេតុនោះ ទើបហៅថា **ទុក្ខសមុទយ** ព្រោះហេតុដែលសច្ចៈទី ២ ជាហេតុកើតនៃទុក្ខ ក្នុងកាលមានការប្រកបព្រម ។

ក្នុងបទថា **ទុក្ខនិរោធ** នេះ មានវិនិច្ឆ័យដូចតទៅនេះ **និ** សព្ទ សម្តែងដល់ការមិនមាន ឯ **រោធ** សព្ទ សម្តែងដល់ការត្រាច់ទៅក្នុងវដ្តសង្សារ ។ ព្រោះហេតុនោះ ក្នុងទីនេះ ការមិនមាននៃការត្រាច់ទៅក្នុងទុក្ខ ពោលគឺការត្រាច់ទៅក្នុងសង្សារទុក្ខ ព្រោះទទេចាកគតិទាំងពួង ។ ម្យ៉ាងទៀត កាលការត្រាច់ទៅក្នុងទុក្ខនោះ ដល់ទីបំផុតហើយ ការត្រាច់ទៅក្នុងទុក្ខ ដែលជាការត្រាច់ទៅក្នុងសង្សារទុក្ខ រមែងមិនមានព្រោះហាមការត្រាច់ទៅក្នុងទុក្ខនោះ ព្រោះហេតុនោះ ទើបហៅថា ទុក្ខនិរោធ ម្យ៉ាងទៀត ហៅថា ទុក្ខនិរោធ ព្រោះជាបច្ច័យដល់ ការមិនកើតឡើង និងការរលត់នៃទុក្ខ ។

ក្នុងបទថា **ទុក្ខនិរោធគាមិនិយា បដិបទាយ** នេះ មគ្គនេះ រមែងទៅកាន់ទុក្ខនិរោធនោះ ព្រោះបែរមុខចំពោះទុក្ខនិរោធនោះ ដោយការធ្វើឲ្យជាអារម្មណ៍ និងជាបដិបទាដើម្បីសម្រេចទុក្ខនិរោធ ព្រោះហេតុនោះ ទើបហៅថា ទុក្ខនិរោធគាមិនីបដិបទា ។

មគ្គញាណទាំង ៤ នោះឯង ក្នុងខាងដើម លោកពោលថា មគ្គញាណ ដោយអំណាចសម្តែងអាការ គឺការចេញ លោកពោលថា **អានន្តរិកសមាធិញ្ញាណ** ដោយអំណាចនៃការសម្តែងហេតុនៃការឲ្យផលក្នុងលំដាប់ លោក

ពោលថា **សច្ចវិវដ្ដញ្ញាណ** ដោយអំណាចនៃការគេចចេញអំពីវដ្ដដោយសច្ចៈ លោកពោលអរហត្តមគ្គញ្ញាណនោះឯងថា **អាសវក្ខយញ្ញាណ** ដើម្បីសម្ដែងការកើតឡើងនៃអរហត្តមគ្គញ្ញាណ តាមលំដាប់នៃមគ្គ និងដើម្បីសម្ដែងការដឹងដ៏ក្រៃលែងនៃញាណនោះ ។

លោកពោលញាណ ៤ ជាដើមថា បញ្ញាក្នុងវត្ថុដែលគួរកំណត់ដឹង ជាទុក្ខញ្ញាណ ដើម្បីសម្ដែងភាពដែលមគ្គញ្ញាណទាំង ៤ ជាញាណដែលត្រាស់ដឹង ដោយភាពតែមួយដដែលទៀត ។ លោកលើកឡើងនូវញាណទាំង ៤ មានទុក្ខញ្ញាណជាដើមសម្ដែងទៀត ដោយអំណាចនៃការសម្ដែងការកើតឡើងញែកគ្នាក្នុងសច្ចៈមួយៗ ព្រោះហេតុនោះ គប្បីជ្រាបការផ្សេងគ្នា ទាំងខាងដើម និងខាងចុង ដូចសម្ដែងមក ដោយប្រការដូច្នេះឯង ៕

## អដ្ឋកថា

## ទុក្ខទុក្ខសមុទយទុក្ខនិរោធ

## ទុក្ខនិរោធគាមិនីបដិបទាញាណុទ្ទេស ចប់

## ៦៤-៦៧. អដ្ឋកថា

## អត្ថប្បដិសម្ភិទាធម្មប្បដិសម្ភិទា
## និរុត្តិប្បដិសម្ភិទាបដិភាណប្បដិសម្ភិទាញាណនិទ្ទេស

ឥឡូវនេះ ដើម្បីសម្ដែងថា បដិសម្ភិទាញាណសម្រេចដល់ព្រះអរិយបុគ្គលទាំងពួងបាន ដោយអានុភាពនៃអរិយមគ្គប៉ុណ្ណោះ ទើបលោកលើកយកបដិសម្ភិទាញាណ ៤ មានអត្ថប្បដិសម្ភិទាញាណជាដើមឡើង សម្ដែងទៀត ។ បដិសម្ភិទាញាណទាំងនេះ ជាសុទ្ធិកបដិសម្ភិទាញាណ ដែលទូទៅដល់ព្រះអរិយបុគ្គលទាំងពួង សូម្បីមិនមានការបែកធ្លាយក្នុងបដិសម្ភិទា តែបដិសម្ភិទាញាណដែលលោកលើកឡើងសម្ដែងខាងដើម គប្បីជ្រាបថា ជាបដិសម្ភិទាញាណដែលដល់នូវការបែកធ្លាយ របស់លោកអ្នកមានបដិសម្ភិទាបែកធ្លាយ នេះជាការផ្សេងគ្នាក្នុងការពោលអត្ថទាំង ២ នៃបដិសម្ភិទាញាណទាំងនោះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រោះញាណដែលលោកលើកឡើងសម្ដែងក្នុងលំដាប់ មានទុក្ខជាអារម្មណ៍ និងមាននិរោធជាអារម្មណ៍ ជាអត្ថប្បដិសម្ភិទាដែលមានសមុទយៈជាអារម្មណ៍ និងមានមគ្គជាអារម្មណ៍ ជាធម្មប្បដិសម្ភិទាញាណក្នុងវោហារដែលសម្ដែងអត្ថ និងធម៌នោះ ជានិរុត្តិប្បដិសម្ភិទា ញាណក្នុងញាណទាំង ៣ នោះ ជាបដិភាណប្បដិសម្ភិទា ហេតុនោះ គប្បីជ្រាបថា លោកលើកសុទ្ធិកបដិសម្ភិទាញាណឡើងសម្ដែង ដើម្បីចង្អុលបង្ហាញនូវការប្លែកគ្នានៃខ្លឹមសារនោះ ព្រោះហេតុនោះឯង ទើបខាងដើម លោកពោលឲ្យផ្សេងគ្នាដោយនានត្តសព្ទ ក្នុងទីនេះ លោកមិនបានពោលឲ្យផ្សេងគ្នាយ៉ាងនោះ ដូច្នេះ ៕

## ៦៨. អដ្ឋកថា

## ឥន្ទ្រិយបរោបរិយត្តញាណនិទ្ទេស

ព្រះធម្មសេនាបតីសារីបុត្ត កាលលើកឡើងនូវញាណដែលទូទៅដល់សាវក ៦៧ ញាណសម្ដែងតាមលំដាប់យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងញាណដែលមានដោយចំពោះ ដល់ព្រះតថាគតទាំងឡាយប៉ុណ្ណោះ មិនទូទៅដល់សាវកទាំងឡាយ ទើបលើកឡើងនូវអសាធារណញ្ញាណ ៦ មានឥន្ទ្រិយបរោបរិយត្តញ្ញាណជាដើមសម្ដែង ។ សូម្បីអសាធារណញ្ញាណទាំង ៦ នោះ ព្រោះព្រះតថាគតទាំងឡាយ កាលទ្រង់ពិចារណាមើលថា សត្វទាំងឡាយ ជាអ្នកមានឥន្ទ្រិយទទួលព្រះធម្មទេសនាបានដែរឬ ក៏ពិចារណាមើលដោយពុទ្ធចក្ខុ ។ ឥន្ទ្រិយបរោបរិយត្តញ្ញាណ និងអាសយានុសយញ្ញាណទាំង ២ នេះប៉ុណ្ណោះ ឈ្មោះថា ពុទ្ធចក្ខុ ។ សមដូចលោកពោល ( ក្នុងវិនយបិដក មហាវគ្គ ) ថា ព្រះដ៏មានព្រះភាគ កាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែក ( ខ្លះ ) មានធូលីគឺរាគាទិក្កិលេសច្រើនក្នុងភ្នែក ( ខ្លះ ) មានឥន្ទ្រិយរឹង ( ខ្លះ ) មានឥន្ទ្រិយទន់ ( ខ្លះ ) ដូច្នេះជាដើម ។

កាលពិចារណាមើល ទ្រង់រមិលមើលការចាស់ក្លា និងមិនចាស់ក្លា នៃឥន្ទ្រិយក្នុងសន្តានរបស់សត្វមុន កាលទ្រង់ជ្រាបការចាស់ក្លានៃឥន្ទ្រិយហើយ បន្ទាប់អំពីនោះ ទ្រង់ពិចារណាមើលអាសយានុសយៈ និងចរិត ដើម្បីសម្ដែងធម៌តាមសមគួរដល់អាសយៈជាដើម ព្រោះហេតុនោះ ទើបលោកលើកឡើងនូវ

ឥន្ទ្រិយបរោបរិយត្តញ្ញាណសម្តែងមុន ក្នុងលំដាប់បន្ទាប់អំពីនោះ ក៏លើកឡើងនូវអាសយានុសយញ្ញាណសម្តែង ម្យ៉ាងទៀត កាលទ្រង់សម្តែងធម៌ រមែងធ្វើបាដិហារ្យដល់អ្នកគួរទូន្មានដោយបាដិហារ្យ ហេតុនោះ គប្បីជ្រាបថា ព្រះធម្មសេនាបតីសារីបុត្ត លើកឡើងនូវញាណក្នុងយមកប្បាដិហារញ្ញាណ សម្តែងក្នុងលំដាប់បន្ទាប់អំពីអាសយានុសយញ្ញាណ បន្ទាប់អំពីនោះ ទើបលើកមហាករុណាញាណសម្តែង ដើម្បីសម្តែងហេតុនៃញាណទាំង ៣ នេះ ហើយលើកសព្វញ្ញុតញ្ញាណសម្តែងជាលំដាប់តទៅ ដើម្បីសម្តែងសេចក្តីបរិសុទ្ធនៃមហាករុណាញាណ ព្រះធម្មសេនាបតីសារីបុត្ត បានលើកអនាវរណញ្ញាណសម្តែងក្នុងលំដាប់នៃសព្វញ្ញុតញ្ញាណនោះ ដើម្បីសម្តែងភាពដែលសព្វញ្ញុតញ្ញាណជាញាណដែលទាក់ទងដោយការរឭកដល់ធម៌ទាំងពួង និងដើម្បីសម្តែងភាពដែលសព្វញ្ញុតញ្ញាណជាអនាវរិយភាព គឺមិនមានអ្វីរាំង ។

ក្នុងបទថា **ឥន្ទ្រិយបរោបរិយត្តញ្ញាណំ** នេះ បទថា **សត្តានំ** ខាងមុខ គប្បីនាំមកប្រកបក្នុងទីនេះថា **សត្តានំ ឥន្ទ្រិយបរោបរិយត្តញ្ញាណំ** ។ កាលគួរពោលថា **បរ** ផង **អបរ** ផង ឈ្មោះថា **បរាបរ** លោកបែរជាពោលថា **បរោបរ** ព្រោះធ្វើឲ្យជា **រោ** អក្ខរៈ ដោយសន្ធិវិធី ។ ភាវៈនៃ **បរោបរ** ឈ្មោះថា **បរោបរិយ** បរោបរិយនោះឯង ឈ្មោះថា **បរោបរិយត្ត** ការទន់ និងការចាស់ក្លានៃឥន្ទ្រិយ ៥ មានសទ្ធាជាដើម របស់វេនេយ្យសត្វទាំងឡាយ ឈ្មោះថា **ឥន្ទ្រិយបរោបរិយត្ត** ញាណក្នុងឥន្ទ្រិយបរោបរិយត្ត ឈ្មោះថា **ឥន្ទ្រិយ-**

**បរោបរិយត្តញ្ញាណ** អធិប្បាយថា ញាណក្នុងភាពដែលឥន្ទ្រិយទាំងឡាយជាគុណខ្ពស់ និងទាប ។ បាឋៈថា **ឥន្ទ្រិយវរោវរិយត្តញ្ញាណំ** ដូច្នេះក៏មាន ។ គប្បីប្រកបថា **វរ** ផង **អវរិយ** ផង ជា **វរោវរិយ** ភាវៈនៃវរោវរិយៈ ឈ្មោះថា **វរោវរិយត្ត** ។

បទថា **អវរិយានិ** បានដល់ មិនប្រសើរ ។ ម្យ៉ាងទៀត គប្បីប្រកបថា **បរ** ផង **ឱបរ** ផង ឈ្មោះថា **បរោបរ** ភាវៈនៃបរោបរ ឈ្មោះថា **បរោបរិយត្ត** ។

បទថា **ឱបរានិ** មានពាក្យអធិប្បាយថា ថោកថយ សេចក្ដីថា លាមក ដូចក្នុងប្រយោគ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា ធម៌ទាំងឡាយទាំងខាងក្នុង និងខាងក្រៅ ( ធម៌លាមក ) មិនមាន ដែលព្រះតថាគតណាបានត្រាស់ដឹងកម្ចាត់បង់ហើយ ដូច្នេះជាដើម ។ លោកតាំងបាឋៈ ជាសត្តមីវិភត្តិថា **ឥន្ទ្រិយ បរោបរិយត្តេ ញាណំ** យ៉ាងនេះក៏មាន ។

## អដ្ឋកថាឥន្ទ្រិយបរោបរិយត្តញ្ញាណុទ្ទេស ចប់

## ៦៩. អដ្ឋកថា

## អាសយានុសយញ្ញាណុទ្ទេស

ក្នុងបទថា **សត្តានំ អាសយានុសយេ ញាណំ** មានវិនិច្ឆ័យថា សត្វទាំងឡាយជាប់ជំពាក់ គឺជាប់ជំពាក់ដោយឆន្ទរាគៈក្នុងខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **សត្តា** ។ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលរាធៈ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណាក្នុងរូប បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ជំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ក្នុងវិញ្ញាណ បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ជំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ដូច្នេះ ។

ចំណែកអាចារ្យពួកខ្លះ អ្នកសម្លឹងចំពោះតួអក្ខរៈ មិនពិចារណាដល់អត្ថ ក៏សម្រេចសេចក្តីយល់ឃើញថា ពាក្យនេះ ត្រឹមតែជាពាក្យនាមប៉ុណ្ណោះ ។ ចំណែកអាចារ្យ អ្នកពិចារណាដល់អត្ថ អាចារ្យទាំងនោះ ក៏រមែងបំណងថា ឈ្មោះថា សត្វ ព្រោះប្រកបក្នុងវត្ថុដែលជាប់ជំពាក់ ។ ( ញាណក្នុងអាសយានុសយៈ ) នៃសត្វទាំងនោះ ។ វត្ថុណាអាស្រ័យនៅ ជាទីអាស្រ័យនៅ ព្រោះហេតុនោះ វត្ថុនោះ ឈ្មោះថា អាសយៈ ។ ពាក្យនេះ ជាឈ្មោះរបស់សន្តានដែលមិច្ឆាទិដ្ឋិ ឬសម្មាទិដ្ឋិអប់រំហើយ ។ ឬដែលទោសទាំងឡាយមានកាមជាដើម ឬគុណទាំងឡាយ មាននេក្ខម្មៈជាដើមអប់រំហើយ ។

កិលេសពួកណា រមែងដេកត្រាំ រមែងទៅតាមក្នុងសន្ដានរបស់សត្វ ព្រោះហេតុនោះ ទើបកិលេសទាំងនោះ ឈ្មោះថា អនុសយៈ ។ ពាក្យនេះ ជាឈ្មោះរបស់កិលេសទាំងឡាយ មានកាមរាគៈជាដើម ដែលមានកម្លាំង ។

អាសយៈផង អនុសយៈផង ឈ្មោះថា អាសយានុសយ ។ គប្បីជ្រាបថាជាឯកវចនៈ ដោយជាតិសព្ទ និងដោយអំណាចនៃទ្វន្ទសមាស ។ ព្រោះចរិត និងអធិមុត្តិ សង្គ្រោះចូលក្នុងអាសយានុសយៈ ហេតុនោះ ក្នុងឧទ្ទេសទើបលោកសង្គ្រោះញាណក្នុងចរិត និងអធិមុត្តិ ចូលជាមួយអាសយានុសយញ្ញាណ ហើយពោលថា អាសយានុសយញ្ញាណ ។ លោកធ្វើឧទ្ទេសដោយបំណងណា និទ្ទេសលោកក៏ធ្វើទុកដោយបំណងនោះឯង ៗ។០៚

## អដ្ឋកថាអាសយានុសយញ្ញាណុទ្ទេស ចប់

# ៧០. អដ្ឋកថា

# យមកប្បាដិហីរញ្ញាណុទ្ទេស

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា* **យមកប្បាដិហីរេ ញាណំ** *នេះ ដូចតទៅ ឈ្មោះថា* **យមក** *ព្រោះធ្វើផ្ការភ្លើង និងផ្ការទឹកជាដើម ឲ្យប្រព្រឹត្តទៅក្នុងគ្រាជាមួយគ្នា មិនមុនមិនក្រោយនោះឯង ឈ្មោះថា* **បាដិហីរ** *ព្រោះកម្ចាត់បង់នូវធម៌ដែលជាបដិបក្ខទាំងឡាយ មានការមិនជឿជាដើម យមកៈផង បាដិហីរៈផង ព្រោះហេតុនោះ ទើបឈ្មោះថា* **យមកប្បាដិហីរ** ។

**អដ្ឋកថាយមកប្បាដិហីរញ្ញាណុទ្ទេស ចប់**

## ៧១. អដ្ឋកថា

## មហាករុណាសមាបត្តិញ្ញាណុទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **មហាករុណាសមាបត្តិយា ញាណំ** នេះដូចតទៅ

ធម្មជាតណា កាលបើទុក្ខរបស់អ្នកដទៃមាន រមែងធ្វើឲ្យញាប់ញ័រចិត្ត ដល់សាធុជនទាំងឡាយ ឬថា រមែងស្មោះត្រង់ គឺរមែងបៀតបៀន បំផ្លាញទុក្ខរបស់អ្នកដទៃ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ករុណា ម្យ៉ាងទៀត ធម្មជាតណា រមែងបានទទួលការញាប់ញ័រចិត្ត គឺរមែងលាចេញទៅដោយអំណាចការផ្សាយទៅក្នុងពួកសត្វដែលមានទុក្ខ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ករុណា ករុណាធំដោយអំណាចកម្ម គឺការផ្សាយទៅ និងដោយអំណាចគុណនៃកម្ម ឈ្មោះថា មហាករុណា បុគ្គលប្រកបដោយមហាករុណា រមែងចូលកាន់ធម្មជាតនោះបាន ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា សមាបត្តិ មហាករុណានោះផង ជាសមាបត្តិផង ព្រោះហេតុនោះ ទើបឈ្មោះថា **មហាករុណាសមាបត្តិ ៗ** ក្នុងមហាករុណាសមាបត្តិនោះ ៗ ញាណដែលសម្បយុត្តដោយមហាករុណាសមាបត្តិនោះ ៕

**អដ្ឋកថាមហាករុណាសមាបត្តិញ្ញាណុទ្ទេស ចប់**

# ៧២-៧៣. អដ្ឋកថា

## សព្វញ្ញុតញ្ញាណអនាវរណញ្ញាណុទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **សព្វញ្ញុតញ្ញាណំ អនាវរណញ្ញាណំ** នេះដូចតទៅ

ព្រះពុទ្ធអង្គណា ទ្រង់ត្រាស់ដឹងធម៌ទាំងពួង មានប្រភេទនៃគន្លងដែលនឹងគប្បីទូន្មាន ៥ ប្រការ ព្រោះហេតុនោះ ព្រះពុទ្ធអង្គនោះ ឈ្មោះថា **សព្វញ្ញូ** ភាពនៃសព្វញ្ញូ ឈ្មោះថា **សព្វញ្ញុតា** ញាណ គឺសព្វញ្ញុតានោះ គួរពោលថា **សព្វញ្ញុតាញាណ** លោកបែរជាពោលថា **សព្វញ្ញុតញ្ញាណ** ។ ពិតហើយ ធម៌ទាំងពួង មានសង្ខតធម៌ជាដើម ជាគន្លងធម៌ដែលគប្បីទូន្មាន មាន ៥ យ៉ាង នោះឯង គឺសង្ខារ ១ វិការ ១ លក្ខណៈ ១ និព្វាន ១ និងបញ្ញត្តិ ១ ។

បទថា **សព្វញ្ញូ** បានដល់ សព្វញ្ញូ មាន ៥ យ៉ាង គឺ **កមសព្វញ្ញូ** ដឹងធម៌ទាំងពួងតាមលំដាប់ ១ **សកឹសព្វញ្ញូ** ដឹងធម៌ទាំងពួងក្នុងគ្រាជាមួយគ្នា ១ **សតតសព្វញ្ញូ** ដឹងធម៌ទាំងពួងជាប់តគ្នា ១ **សត្តិសព្វញ្ញូ** ដឹងធម៌ទាំងពួងតាមសមត្ថភាព ១ **ញាតសព្វញ្ញូ** ដឹងធម៌ទាំងពួងដែលដឹងហើយ ១ ។ **កមសព្វញ្ញុតា** រមែងមានមិនបាន ព្រោះមិនកើតកាលជាទីដឹងធម៌ទាំងពួងតាមលំដាប់ **សកឹសព្វញ្ញុតា** ក៏មានមិនបាន ព្រោះមិនមានការទទួលអារម្មណ៍ទាំងពួងបាន ក្នុងគ្រាតែមួយ **សតតសព្វញ្ញុតា** ក៏មានមិនបានព្រោះចិត្តមានចក្ខុវិញ្ញាណចិត្តជាដើម កើតឡើងតាមសមគួរដល់អារម្មណ៍ ព្រោះជំទាស់ជាមួយភវង្គចិត្ត និងព្រោះមិនមានការពោលត្រូវ **សត្តិសព្វញ្ញុតា** គប្បីមានបាន

ព្រោះអាចដឹងធម៌ទាំងពួង ដោយមានចំណែកសេសសល់ ឬការដឹងធម៌ទាំងពួងដែលដឹងហើយ ក៏គប្បីមានបាន ព្រោះដឹងច្បាស់ធម៌ទាំងពួងហើយ ។ ភាពជាអ្នកដឹងធម៌ទាំងពួង រមែងមានក្នុងការដឹងធម៌ទាំងពួងតាមសមត្ថភាព ព្រោះហេតុនោះ ការដឹងធម៌ទាំងពួងតាមសមត្ថភាពនោះ រមែងមិនត្រឹមត្រូវ ។ ភាពជាអ្នកដឹងធម៌ទាំងពួង ដែលដឹងហើយប៉ុណ្ណោះ រមែងត្រឹមត្រូវ ព្រោះលោកពោល ( ក្នុងខុទ្ទកនិកាយ មហានិទ្ទេស ) ថា

> ហេតុនីមួយ ក្នុងលោកនេះ ដែលព្រះមានព្រះភាគនោះ ទ្រង់មិនឃើញ ឬថា មិនជ្រាប មិនយល់ មិនមានទេ ហេតុណាដែលត្រូវដឹង ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវហេតុ ( នោះ ) ទាំងអស់ ព្រោះហេតុនោះ ទើបព្រះតថាគត ឈ្មោះថា សមន្តចក្ខុ ដូច្នេះ ។

ហេតុនោះ សព្វញ្ញុតញ្ញាណនោះឯង រមែងមានដោយកិច្ច ដោយការមិនវង្វេង ដោយការសម្រេចនៃហេតុ ដោយទាក់ទងជាមួយអាវជ្ជនៈដោយប្រការដូច្នេះ ។ ញាណនោះ រមែងមិនមានគ្រឿងរារាំង ព្រោះជាញាណដែលទាក់ទងដោយអាវជ្ជនៈនោះឯង ព្រោះហេតុនោះ ទើបញាណនោះ ឈ្មោះថា អនាវរណៈ អនាវរណៈនោះឯង ហៅថា **អនាវរណញ្ញាណ** ដោយប្រការដូច្នេះ ។

បទថា **ឥមានិ តេសត្តតិ ញាណានិ** បានដល់ ញាណ ៧៣ នេះ លោកលើកឡើងសម្តែង ដោយអំណាចនៃញាណដែលទូទៅ និងមិនទូទៅដល់ព្រះសាវកទាំងឡាយ ។

*បទថា* **ឥមេសំ តេសត្តតិយា ញាណានំ** *បានដល់ បណ្ដាញាណទាំង ៧៣ នេះ ដែលលោកពោលហើយតាំងអំពីដើម ។ ពាក្យនេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថថា រួមគ្នា ។ បាឋៈថា* **តេសត្តតីនំ** *ដូច្នេះក៏មាន ។ កាលគួរពោលថា* **តេសត្តតិយា** *គប្បីជ្រាបថា ជាពហុវចនៈ ក្នុងរូបឯកវចនៈ ។*

*បទថា* **សត្តសដ្ឋិ ញាណានិ** *បានដល់ ញាណ ៦៧ រាប់តាំងពីដើមមក ។*

*បទថា* **សាវកសាធារណានិ** *បានដល់ ឈ្មោះថា* **សាវក** *ព្រោះកើតដោយជាតិនៃអរិយៈក្នុងទីបំផុតនៃការស្ដាប់ ឈ្មោះថា* **សាធារណា** *ព្រោះការទ្រទ្រង់ទុកស្មើគ្នាមានដល់ញាណទាំងនោះ ញាណ ៦៧ នោះ ជាញាណដែលទូទៅដល់សាវករបស់ព្រះតថាគតទាំងឡាយ ឈ្មោះថា* **សាវកសាធារណា** *។*

*បទថា* **ឆ ញាណានិ** *បានដល់ ញាណ ៦ ដែលលោកលើកឡើងសម្ដែងខាងចុង ។*

*បទថា* **អសាធារណានិ សាវកេហិ** *បានដល់ ញាណទាំងឡាយ ៦ មានចំពោះតែព្រះតថាគតទាំងឡាយ មិនទូទៅដល់សាវកទាំងឡាយ ដូច្នេះឯង ។៚*

**អដ្ឋកថាសព្វញ្ញុតញ្ញាណអនាវរណញ្ញាណុទ្ទេស ចប់**

**អដ្ឋកថាញាណកថាមាតិកុទ្ទេស ចប់**

# សុត្តន្តបិដក

## មហាវគ្គ ញាណកថា

[ ១ ] បញ្ញាក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ការប្រុងត្រចៀកថា ធម៌ទាំងនេះបុគ្គលគួរដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរកំណត់ដឹង បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរលះ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរចម្រើន បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះ ថាសុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរធ្វើឲ្យជាក់ច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ គប់រកនូវសេចក្តីសាបសូន្យ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ គប់រកនូវការតាំងនៅ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ គប់រកនូវគុណវិសេស ( ដោយអំណាចនៃការត្រាស់ដឹងនូវគុណវិសេសខាងលើ ) បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ គប់នូវការទម្លាយនូវកិលេស បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ

ការប្រុងត្រចៀកថា សង្ខារទាំងពួងមិនទៀង បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា សង្ខារទាំងពួងជាទុក្ខ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងពួងជាអនត្តា បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុង ត្រចៀកថានេះ ទុក្ខ-អរិយសច្ច បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា នេះទុក្ខសមុទយអរិយសច្ច បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា នេះទុក្ខ-និរោធអរិយសច្ច បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុត-មយញ្ញាណ ការប្រុងត្រចៀកថា នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

# ញាណកថា

## អដ្ឋកថា សុតមយញ្ញាណនិទ្ទេស

## វិសជ្ជនុទ្ទេស

[ ១ ] ឥឡូវនេះ លោកប្រារព្ធនិទ្ទេសវារៈ មានជាដើមថា **កថំ សោតាវធានេ បញ្ញា សុតមយេ ញាណំ** ក៏ដើម្បីសម្តែងធម៌ទាំងឡាយដែលរួបរួមដោយឧទ្ទេស តាមដែលបានលើកឡើងសម្តែងហើយដោយប្រភេទ ។

ក្នុងនិទ្ទេសវារៈនោះ ពាក្យណា ដែលលោកពោលថា **សោតាវធានេ បញ្ញា សុតមយេ ញាណំ** ពាក្យនោះដូចម្តេច ពាក្យនេះ ជាពាក្យសួរដើម្បីឆ្លើយឯង ។ ពិតហើយ ពាក្យសួរមាន ៥ យ៉ាង គឺ **អទិដ្ឋជោតនាបុច្ឆា** សួរដើម្បីបំភ្លឺសេចក្តី ដែលនៅមិនទាន់ឃើញ ១ **ទិដ្ឋសំសន្ទនាបុច្ឆា** សួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ១ **វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់សេចក្តីសង្ស័យ ១ **អនុមតិបុច្ឆា** សួរដើម្បីផ្ទៀងផ្ទាត់ការយល់ដឹង ១ **កថេតុកម្យតាបុច្ឆា** សួរដើម្បីនឹងឆ្លើយឯង ១ ។

ការផ្សេងគ្នានៃបុច្ឆា ៥ យ៉ាងនោះ មានដូចតទៅនេះ

អទិដ្ឋជោតនាបុច្ឆា តើដូចម្តេច គឺបុគ្គលរមែងសួរបញ្ហាដើម្បីដឹង ដើម្បីឃើញ ដើម្បីប្រៀបធៀប ដើម្បីពិចារណា ដើម្បីជាក់ច្បាស់ ដើម្បីបើកនូវលក្ខណៈតាមប្រក្រតីដែលជាន័យមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់ប្រៀបធៀប មិនធ្លាប់ពិចារណា មិនធ្លាប់ជាក់ច្បាស់ មិនធ្លាប់បើក បុច្ឆានេះ ឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។

*ទិដ្ឋសំសន្ទនាបុច្ឆា តើដូចម្តេច គឺបុគ្គលនោះ រមែងសួរបញ្ហាដល់លក្ខណៈ តាមប្រក្រតីដែលខ្លួនធ្លាប់ដឹងហើយ ធ្លាប់ឃើញហើយ ធ្លាប់ប្រៀបធៀបហើយ ធ្លាប់ពិចារណាហើយ ធ្លាប់ជាក់ច្បាស់ហើយ ធ្លាប់បើកហើយ ដើម្បីប្រៀបធៀបជាមួយបណ្ឌិតដទៃ បុច្ឆានេះ ឈ្មោះថា* **ទិដ្ឋសំសន្ទនាបុច្ឆា** ។

*វិមតិច្ឆេទនាបុច្ឆា ដូចម្តេច គឺបុគ្គលនោះ តាមធម្មតាជាអ្នកកើតសេចក្តីសង្ស័យ ជាអ្នកកើតនូវការងឿងឆ្ងល់ ជាអ្នកកើតនូវការឃើញដែលដូចជាផ្លូវបំបែកជា ២ រមែងសួរបញ្ហាដើម្បីកាត់សេចក្តីសង្ស័យថា យ៉ាងនោះឬហ្ន៎ ឬមិនមែនយ៉ាងនោះ អ្វីហ្ន៎ ដូចម្តេចហ្ន៎ បុច្ឆានេះ ឈ្មោះថា* **វិមតិច្ឆេទនាបុច្ឆា** ។

*អនុមតិបុច្ឆា តើដូចម្តេច គឺព្រះមានព្រះភាគត្រាស់សួរបញ្ហាតាមការចេះដឹងរបស់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច រូបទៀង ឬមិនទៀង កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន រូបមិនទៀងទេ ក៏ត្រាស់សួរតទៅទៀតថា របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ កាលភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ក៏ត្រាស់សួរបន្តទៅទៀតថា ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញរបស់នុ៎ះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ បុច្ឆានេះ ឈ្មោះថា* **អនុមតិបុច្ឆា** ។

*កថេតុកម្យតាបុច្ឆា តើដូចម្តេច គឺព្រះមានព្រះភាគត្រាស់សួរដល់ភិក្ខុទាំង*

ឡាយ ព្រោះមានបំណងនឹងឆ្លើយដោយព្រះអង្គឯងថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះ មាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច បុច្ឆានេះ ឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

បណ្តាបុច្ឆាទាំង ៥ នោះ បុច្ឆានេះ បណ្ឌិតគប្បីជ្រាបថា ជាកថេតុកម្យតា-បុច្ឆារបស់ព្រះសារីបុត្តត្ថេរ ។

ឥឡូវនេះ ព្រះសារីបុត្តបានពោលវិសជ្ជនុទ្ទេស គឺឧទ្ទេសតាំងឡើងដើម្បីនឹងឆ្លើយ ១៦ ប្រការ មានពាក្យថា **ឥមេ ធម្មា អភិញ្ញេយ្យាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ** ដូច្នេះជាដើម ដើម្បីធ្វើពាក្យសួរដែលប្រាថ្នានឹងឆ្លើយឯង ដែលប្រព្រឹត្តទៅជាមួយមាតិកាឧទ្ទេស ។

បណ្តាបទទាំងនោះ បាឋៈដ៏សេស គប្បីភ្ជាប់ថា **ឥមេ ធម្មា អភិញ្ញេយ្យាតិ ទេសយន្តស្ស** អធិប្បាយថា កាលព្រះសាស្តា ឬសព្រហ្មចារី ដែលគួរគោរពអង្គណាមួយ សម្តែងនូវធម៌ថា ធម៌ទាំងនេះ ដែលព្រះយោគីបុគ្គលគួរដឹងក្រៃលែង សុតៈដែលជាគ្រឿងទ្រទ្រង់ចាំធម៌ដែលបានស្តាប់ហើយ តាមន័យដែលលោកបានពោលហើយក្នុងកាលមុន ឈ្មោះថា សោតាវធាន បញ្ញាជាគ្រឿងដឹងសោតាវធាននោះ គឺបញ្ញាជាគ្រឿងដឹងសុតៈនោះ បានដល់ បញ្ញាជាគ្រឿងកំណត់ហេតុ ឈ្មោះថា សុតមយញ្ញាណ ។ ពាក្យថា ជាគ្រឿងដឹងនូវសុតៈនោះ ជាឆដ្ឋីតប្បុរិសសមាសថា **តំបជាននា** ។ ម្យ៉ាងទៀត បទថា **តំបជាននា** ជាទុតិយាវិភត្តិ ដោយអំណាចនៃវិភត្តិវិបល្លាស ។

បទថា **អភិញ្ញេយ្យា** បានដល់ គួរដឹងដោយអាការដ៏ល្អ ដោយអំណាច

នៃការដឹងនូវសភាវៈលក្ខណៈ ។

បទថា **បរិញ្ញេយ្យា** បានដល់ គួរដឹងដោយអំណាចនៃការដឹងនូវសាមញ្ញលក្ខណៈ និងដោយអំណាចនៃការញុំាងកិច្ចឲ្យសម្រេច ។

បទថា **ភាវេតព្វា** បានដល់ គួរឲ្យចម្រើន ។

បទថា **សច្ឆិកាតព្វា** បានដល់ គួរធ្វើឲ្យប្រចក្ស ។ ការធ្វើឲ្យជាក់ច្បាស់មាន ២ យ៉ាង គឺបដិលាភសច្ឆិកិរិយា ការធ្វើឲ្យជាក់ច្បាស់ ដោយការបានចំពោះ ១ អារម្មណសច្ឆិកិរិយា ការធ្វើឲ្យជាក់ច្បាស់ដោយការធ្វើឲ្យជាអារម្មណ៍ ១ ។

ធម៌ទាំងឡាយណា ចាត់ចូលជាផ្នែកវិនាស ពោលគឺប្រព្រឹត្តទៅក្នុងផ្នែកនៃភាពវិនាស ដោយអំណាចនៃការកម្រើកឡើងនូវធម៌ដែលជាសត្រូវ ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **ហានភាគិយា** ។ ធម៌ទាំងឡាយណា ចាត់ចូលក្នុងចំណែកតាំងនៅ ពោលគឺតាំងនៅដោយអំណាចនៃការតាំងមាំរបស់សតិ តាមសមគួរដល់ធម៌នោះ ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **ឋិតិភាគិយា** ។

ធម៌ទាំងឡាយណា ចាត់ចូលក្នុងចំណែកគុណវិសេស ដោយអំណាចនៃការសម្រេចគុណវិសេសខាងលើ ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **វិសេសភាគិយា** ។

ធម៌ណា រមែងជ្រៀតចូល រមែងកម្ចាត់កងលោភៈ ទោសៈ មោហៈដែលមិនធ្លាប់ជ្រៀតចូល មិនធ្លាប់កម្ចាត់ ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា

**និព្វេធ** គឺអរិយមគ្គ ធម៌ទាំងឡាយណា រមែងចាត់ចូលក្នុងចំណែកនិព្វេធនោះ ដោយអំណាចនៃការតាំងឡើងនៃសញ្ញាមនសិការ ដែលសហគតៈដោយនិព្វិទា ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **និព្វេធភាគិយា** ។

បទថា **សព្វេ សង្ខារា** បានដល់ ធម៌ដែលប្រព្រឹត្តទៅដោយបច្ច័យទាំងពួង ។ ធម៌ទាំងនោះ ឈ្មោះថា សង្ខតសង្ខារ ។ ធម៌ពួកណាដែលបច្ច័យទាំងឡាយប្រជុំតាក់តែងឡើង ព្រោះហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា **សង្ខារ** សង្ខារទាំងនោះឯង លោកពោលឲ្យប្លែកចេញទៅថា **សង្ខតា** ព្រោះត្រូវបច្ច័យទាំងឡាយប្រជុំធ្វើឡើង ។ រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលកើតអំពីកម្ម ក្នុងអដ្ឋកថា លោកពោលថា **អភិសង្ខតសង្ខារ** ។ សូម្បីអភិសង្ខតសង្ខារទាំងនោះ ក៏រមែងសង្គ្រោះចូលក្នុង **សង្ខតសង្ខារ** ដូចក្នុងប្រយោគជាដើមថា **អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយ មិនទៀងហ្ន៎ ដូច្នេះ ។

សង្ខារទាំងឡាយ មានអវិជ្ជាជាបច្ច័យ មកហើយក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ បើបុរសបុគ្គលលុះក្នុងអំណាចអវិជ្ជាហើយ រមែងតាក់តែងសង្ខារជាបុណ្យ គឺកុសលចេតនា អកុសលចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **អភិសង្ខរណកសង្ខារ** ។

សេចក្តីព្យាយាមដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្ត មកក្នុងប្រយោគជាដើមថា ចក្កៈនោះ ដែលអ្នកបង្វិលទៅ ក៏ទៅកាន់ទីអស់កំណត់ ត្រឹមតែមួយវិលប៉ុណ្ណោះ ហើយក៏តាំងនៅនឹងថ្កល់ ហាក់ដូចជាខ្ទាស់ត្រង់ក្តៅ

ឈ្មោះថា **បយោគាភិសង្ខារ** ។

វិតក្កវិចារ តាក់តែងវាចា មកហើយក្នុងប្រយោគជាដើមថា ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធនោះ វចីសង្ខាររលត់មុន តមកទើបកាយសង្ខារ ( រលត់ ) តពីនោះមកទៀត ទើបចិត្តសង្ខារ ( រលត់ ) ឈ្មោះថា **វចីសង្ខារ** ។

អស្សាសបស្សាសៈ ខ្យល់ដកដង្ហើមចូល-ចេញ ដែលកាយរមែងតាក់តែង ឈ្មោះថា **កាយសង្ខារ** ។

សញ្ញា និងវេទនាដែលចិត្តតាក់តែង ឈ្មោះថា **ចិត្តសង្ខារ** ។ តែក្នុងទីនេះ លោកបំណងយក **សង្ខតសង្ខារ** ។

ឈ្មោះថា **អនិច្ចា** ដោយអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ ឈ្មោះថា **ទុក្ខា** ដោយអត្ថថា បៀតបៀន ។

បទថា **សព្វេ ធម្មា** លោកពោលរួមយកព្រះនិព្វានចូលផង ។ ឈ្មោះថា **អនត្តា** ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។

ក្នុងបទជាដើមថា **ឥទំ ទុក្ខំ អរិយសច្ចំ** ក្នុងកាលគួរពោលថា **ទុក្ខសមុទយោ ទុក្ខនិរោធោ** ដូច្នេះ លោកធ្វើឲ្យជាលិង្គវិបល្លាសថា **ទុក្ខសមុទយំ ទុក្ខនិរោធំ** ដូច្នេះ ។ ព្រោះព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងចាក់ធ្លុះ ហេតុនោះ ទើបលោកពោលថា **អរិយសច្ចានិ** ។ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច មាន ៤ នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ជារបស់

ពិត ។ ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះអរិយសច្ចទាំងនេះ ។ ព្រោះហេតុនោះ បានជាតថាគតហៅថា អរិយសច្ច ដូច្នេះ ។

ឈ្មោះថា អរិយសច្ច ព្រោះជាសច្ចៈរបស់ព្រះអរិយៈ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ព្រះតថាគតជាអរិយបុគ្គលក្នុងលោក ព្រមទាំងទេវលោក ។បេ។ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រោះហេតុនោះ ( សច្ចៈ ៤ ដែលតថាគតសម្តែងហើយ ) ហៅថា អរិយសច្ច ដូច្នេះ ។

ឈ្មោះថា អរិយសច្ច ព្រោះសម្រេចភាពជាអរិយៈ ព្រោះត្រាស់ដឹងសច្ចៈទាំងនោះ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលមានឈ្មោះថា **អរហំសម្មាសម្ពុទ្ធ** ព្រោះព្រះតថាគតបានត្រាស់ដឹងនូវអរិយសច្ច ៤ នេះ តាមសេចក្តីពិត ដូច្នេះ ។

ឈ្មោះថា អរិយសច្ច ព្រោះអត្ថថា សច្ចៈដ៏ប្រសើរ ។ ពាក្យថា ដ៏ប្រសើរ បានដល់ មិនប្រែប្រួល អធិប្បាយថា មិនឃ្លៀងឃ្លាត ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ព្រោះហេតុនោះ បានជាតថាគតហៅថា អរិយសច្ច ដូច្នេះ ។

ពាក្យថា សច្ចៈ សេចក្តីថា បើសួរថា អ្វីជាអត្ថរបស់សច្ចៈ ក៏មានពាក្យឆ្លើយថា ធម៌ណា កាលអ្នកប្រាជ្ញទាំងឡាយពិនិត្យពិចារណា ដោយបញ្ញាចក្ខុ រមែងមិនវិបរិតដូចមាយា មិនធ្វើឲ្យយល់ខុស ដូចថ្ងៃបណ្តើរកូន និងមិនជាសភាវៈដែលរកមិនបាន ដូចអត្តាដែលពួកតិរ្ថិយកំណត់ហើយដែលពិត

រមែងជាអារម្មណ៍របស់អរិយញ្ញាណ ដោយភាវៈដែលពិត មិនវិបរិតដោយប្រការជាគ្រឿងបៀតបៀន ជាដែនកើតស្ងប់សុខ នាំចេញចាកទុក្ខ ធម៌នោះគប្បីជ្រាបថា ជាអត្ថនៃសច្ចៈ ដែលមានភាវៈដែលពិត មិនវិបរិត ដូចលក្ខណៈរបស់ភ្លើង និងដូចប្រក្រតីរបស់លោក ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ ទុំះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ដូច្នេះ ។ អត្ថដោយពិស្ដារគួរស្វែងរក ។

ម្យ៉ាងទៀត

ព្រោះទុក្ខដែលមិនបៀតបៀន មិនមាន វត្ថុដទៃដែលបៀតបៀនក្រៅអំពីទុក្ខមិនមាន ហេតុនោះ ទើបទុក្ខនេះ ហៅថា សច្ចៈ ដោយកំណត់សភាវៈដែលបៀតបៀន វៀរចាកវត្ថុនោះ ( តណ្ហា ) ចេញហើយ ទុក្ខ មិនមានមកអំពីវត្ថុដទៃ កាលវត្ថុនោះ មិនមានទុក្ខនោះ ក៏មិនមាន ព្រោះហេតុនោះ ទើបតណ្ហាជាគ្រឿងជាប់ជំពាក់ ហៅថា សច្ចៈ ព្រោះកំណត់ថា ជាហេតុនៃទុក្ខ ។ ព្រោះការស្ងប់ដទៃចាកព្រះនិព្វាន មិនមាន និព្វាននោះមាន មិនមែនមិនមាន ហេតុនោះ ទើបនិព្វាននេះ ហៅថា សច្ចៈ ព្រោះកំណត់ដល់ការស្ងប់ ។ ផ្លូវនាំចេញចាកទុក្ខ ដទៃក្រៅអំពីអរិយមគ្គ មិនមាន មគ្គនោះ មិនជាគ្រឿងនាំចេញចាកទុក្ខក៏មិនមែន មគ្គនោះហៅថា សច្ចៈ ព្រោះជាហេតុនាំចេញចាកទុក្ខ យ៉ាងពិតប្រាកដ ព្រោះហេតុនោះ ទើបបណ្ឌិតទាំងឡាយ បានពោលភាពដែល

សច្ចៈជារបស់ពិត មិនវិបល្លាសក្នុងធម៌ទាំង ៤ មានទុក្ខជាដើម ថាជាអត្ថនៃសច្ចៈ ដោយមិនប្លែកគ្នា ។

**សច្ច** សព្ទនេះ ប្រាកដក្នុងអត្ថច្រើនយ៉ាង រមែងប្រាកដក្នុងអត្ថថា វាចាសច្ច ដូចក្នុងប្រយោគជាដើមថា **សច្ចំ ភណេ ន កុជ្ឈេយ្យ** បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ ដូច្នេះ ។

រមែងប្រាកដក្នុងអត្ថថា វិរតិសច្ច ដូចក្នុងប្រយោគជាដើមថា **សច្ចេ ឋិតា សមណព្រាហ្មណា** ច សមណៈ និងព្រាហ្មណ៍ដែលតាំងនៅក្នុងសច្ចៈ ដូច្នេះ ។

រមែងប្រាកដក្នុងអត្ថថា ទិដ្ឋិសច្ច ដូចក្នុងប្រយោគជាដើមថា **កស្មា នុ សច្ចានិ វទន្តិ នានា បវាទិយាសេ កុសលាវទានា** ព្រោះហេតុអ្វីហ្ន៎ បានជាសមណព្រាហ្មណ៍ទាំងឡាយ ដែលពោលលើកខ្លួនថាជាអ្នកឈ្លាសវៃ ជាអ្នកពោលតាមបំណងរបស់ខ្លួន តែងពោលសច្ចៈផ្សេងៗ គ្នា ... ដូច្នេះ ។

រមែងប្រាកដក្នុងអត្ថថា បរមត្ថសច្ច គឺនិព្វាន និងមគ្គ ដូចក្នុងប្រយោគជាដើមថា **ឯកំ ហិ សច្ចំ ន ទុតីយមត្ថិ យស្មឹ បជា នោ វិវទេ បជានំ** ព្រោះថា បុគ្គលកាលដឹងច្បាស់ក្នុងសច្ចៈណា ទើបមិនទាស់ទែងគ្នា ឯសច្ចៈនោះ មានតែមួយ មិនមែនមានពីរឡើយ ដូច្នេះ ។

រមែងប្រាកដក្នុងអត្ថថា អរិយសច្ច ដូចក្នុងប្រយោគជាដើមថា **ចតុន្នំ សច្ចានំ កតិ កុសលា កតិ អកុសលា** បណ្ដាអរិយសច្ចទាំង ៤ អរិយសច្ច ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ដូច្នេះ ។ ក្នុងទីនេះ **សច្ច** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា អរិយសច្ច ដូច្នេះឯង ។៚

**អដ្ឋកថាវិសជ្ជនុទ្ទេសដែលសង្គ្រោះក្នុងនិទ្ទេសវារៈ ចប់**

# សុត្តន្តបិដក

[ ២ ] ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ធម៌ ១ ដែលបុគ្គលត្រូវដឹងច្បាស់ បានដល់ ពួកសត្វទាំងអស់ ដែលស្ថិតនៅបានដោយអាហារ ធម៌ ២ ត្រូវដឹងច្បាស់ បានដល់ ធាតុ ២ គឺសង្ខតធាតុ អសង្ខតធាតុ ធម៌ ៣ ត្រូវដឹងច្បាស់ បានដល់ ធាតុ ៣ គឺកាមធាតុ រូបធាតុ អរូបធាតុ ធម៌ ៤ ត្រូវដឹងច្បាស់ បានដល់ អរិយសច្ច ៤ ធម៌ ៥ ត្រូវដឹងច្បាស់ បានដល់ វិមុត្តាយតនៈ ៥ ធម៌ ៦ ត្រូវដឹងច្បាស់ បានដល់ អនុត្តរិយៈ ៦ ធម៌ ៧ ត្រូវដឹងច្បាស់ បានដល់ និទ្ទេសវត្ថុ ៧ ធម៌ ៨ ត្រូវដឹងច្បាស់ បានដល់ អភិភាយតនៈ ៨ ធម៌ ៩ ត្រូវដឹងច្បាស់ បានដល់ អនុបុព្វវិហារធម៌ ៩ ធម៌ ១០ ត្រូវដឹងច្បាស់ បានដល់ និជ្ជរវត្ថុ ១០ យ៉ាង ។

[ ៣ ] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុ បុគ្គលត្រូវដឹងច្បាស់ រូប ត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណ ត្រូវដឹងច្បាស់ ចក្ខុសម្ផស្ស ត្រូវដឹងច្បាស់ ការទទួលអារម្មណ៍ណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះត្រូវដឹងច្បាស់ សោតៈត្រូវដឹងច្បាស់ សទ្ទៈត្រូវដឹងច្បាស់ ។បេ។ ឃានៈត្រូវដឹងច្បាស់ គន្ធៈត្រូវដឹងច្បាស់ ជិវ្ហាត្រូវដឹងច្បាស់ រសៈត្រូវដឹងច្បាស់ កាយត្រូវដឹងច្បាស់ ផោដ្ឋព្វៈត្រូវដឹងច្បាស់ មនៈត្រូវដឹងច្បាស់ ធម៌ត្រូវដឹងច្បាស់ មនោវិញ្ញាណត្រូវដឹងច្បាស់ មនោសម្ផស្សត្រូវដឹងច្បាស់ ការទទួល

អារម្មណ៍ណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះ ត្រូវដឹងច្បាស់ ។

[ ៤ ] រូបត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ សញ្ញាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ ចក្ខុត្រូវដឹងច្បាស់ សោតៈត្រូវដឹងច្បាស់ ឃានៈត្រូវដឹងច្បាស់ ជិវ្ហាត្រូវដឹងច្បាស់ កាយត្រូវដឹងច្បាស់ មនៈត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ សទ្ទៈត្រូវដឹងច្បាស់ គន្ធៈត្រូវដឹងច្បាស់ រសៈត្រូវដឹងច្បាស់ ផោដ្ឋព្វៈត្រូវដឹងច្បាស់ ធម៌ត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណត្រូវដឹងច្បាស់ សោតវិញ្ញាណត្រូវដឹងច្បាស់ ឃានវិញ្ញាណត្រូវដឹងច្បាស់ ជិវ្ហាវិញ្ញាណត្រូវដឹងច្បាស់ កាយវិញ្ញាណត្រូវដឹងច្បាស់ មនោវិញ្ញាណត្រូវដឹងច្បាស់ ចក្ខុសម្ផស្សត្រូវដឹងច្បាស់ សោតសម្ផស្សត្រូវដឹងច្បាស់ ឃានសម្ផស្សត្រូវដឹងច្បាស់ ជិវ្ហាសម្ផស្សត្រូវដឹងច្បាស់ កាយសម្ផស្សត្រូវដឹងច្បាស់ មនោ-សម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីចក្ខុសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីសោតសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីឃានសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីជិវ្ហាសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីកាយសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីមនោសម្ផស្សត្រូវដឹងច្បាស់ រូបសញ្ញាត្រូវដឹងច្បាស់ សទ្ទសញ្ញាត្រូវដឹងច្បាស់ គន្ធសញ្ញាត្រូវដឹងច្បាស់ រសសញ្ញាត្រូវដឹងច្បាស់ ផោដ្ឋព្វសញ្ញាត្រូវដឹងច្បាស់ ធម្មសញ្ញាត្រូវដឹងច្បាស់ រូបសញ្ចេតនាត្រូវដឹងច្បាស់ សទ្ទសញ្ចេតនាត្រូវដឹងច្បាស់ គន្ធសញ្ចេតនាត្រូវដឹងច្បាស់ រសសញ្ចេតនាត្រូវដឹងច្បាស់ ផោដ្ឋព្វសញ្ចេតនា

ត្រូវដឹងច្បាស់ ធម្មសញ្ចេតនាត្រូវដឹងច្បាស់ រូបតណ្ហាត្រូវដឹងច្បាស់ សទ្ទតណ្ហាត្រូវដឹងច្បាស់ គន្ធតណ្ហាត្រូវដឹងច្បាស់ រសតណ្ហាត្រូវដឹងច្បាស់ ផោដ្ឋព្វតណ្ហាត្រូវដឹងច្បាស់ ធម្មតណ្ហាត្រូវដឹងច្បាស់ រូបវិតក្កត្រូវដឹងច្បាស់ សទ្ទវិតក្កត្រូវដឹងច្បាស់ គន្ធវិតក្កត្រូវដឹងច្បាស់ រសវិតក្កត្រូវដឹងច្បាស់ ផោដ្ឋព្វវិតក្កត្រូវដឹងច្បាស់ ធម្មវិតក្កត្រូវដឹងច្បាស់ រូបវិចារត្រូវដឹងច្បាស់ សទ្ទវិចារត្រូវដឹងច្បាស់ គន្ធវិចារត្រូវដឹងច្បាស់ រសវិចារត្រូវដឹងច្បាស់ ផោដ្ឋព្វវិចារត្រូវដឹងច្បាស់ ធម្មវិចារត្រូវដឹងច្បាស់ ។

[ ៥ ] បឋវីធាតុបុគ្គលត្រូវដឹងច្បាស់ អាបោធាតុត្រូវដឹងច្បាស់ តេជោធាតុត្រូវដឹងច្បាស់ វាយោធាតុត្រូវដឹងច្បាស់ អាកាសធាតុត្រូវដឹងច្បាស់ វិញ្ញាណ-ធាតុត្រូវដឹងច្បាស់ បឋវីកសិណត្រូវដឹងច្បាស់ អាបោកសិណត្រូវដឹងច្បាស់ តេជោកសិណត្រូវដឹងច្បាស់ វាយោកសិណត្រូវដឹងច្បាស់ នីលកសិណត្រូវដឹងច្បាស់ បីតកសិណត្រូវដឹងច្បាស់ លោហិតកសិណត្រូវដឹងច្បាស់ ឱទាត-កសិណត្រូវដឹងច្បាស់ អាកាសកសិណត្រូវដឹងច្បាស់ វិញ្ញាណកសិណត្រូវដឹងច្បាស់ ។

[ ៦ ] សក់បុគ្គលត្រូវដឹងច្បាស់ រោមត្រូវដឹងច្បាស់ ក្រចកត្រូវដឹងច្បាស់ ធ្មេញត្រូវដឹងច្បាស់ ស្បែកត្រូវដឹងច្បាស់ សាច់ត្រូវដឹងច្បាស់ សរសៃត្រូវដឹងច្បាស់ ឆ្អឹងត្រូវដឹងច្បាស់ ខួរក្នុងឆ្អឹងត្រូវដឹងច្បាស់ តម្រងបស្សាវៈត្រូវដឹងច្បាស់ បេះដូងត្រូវដឹងច្បាស់ ថ្លើមត្រូវដឹងច្បាស់ វាវត្រូវដឹងច្បាស់ ក្រពះត្រូវដឹងច្បាស់ សួតត្រូវដឹងច្បាស់ ពោះវៀនធំត្រូវដឹងច្បាស់ ពោះវៀនតូច

ត្រូវដឹងច្បាស់ អាហារថ្មីត្រូវដឹងច្បាស់ អាហារចាស់ត្រូវដឹងច្បាស់ ប្រមាត់ត្រូវដឹងច្បាស់ ស្លេស្មត្រូវដឹងច្បាស់ ខ្ទុះត្រូវដឹងច្បាស់ ឈាមត្រូវដឹងច្បាស់ ញើសត្រូវដឹងច្បាស់ ខ្លាញ់ខាប់ត្រូវដឹងច្បាស់ ទឹកភ្នែកត្រូវដឹងច្បាស់ ខ្លាញ់រាវត្រូវដឹងច្បាស់ ទឹកមាត់ត្រូវដឹងច្បាស់ ទឹកសម្បោរត្រូវដឹងច្បាស់ ទឹករំអិលត្រូវដឹងច្បាស់ ទឹកមូត្រត្រូវដឹងច្បាស់ ខួរក្នុងក្បាលត្រូវដឹងច្បាស់ ។

[ ៧ ] ចក្ខាយតនៈ បុគ្គលត្រូវដឹងច្បាស់ រូបាយតនៈត្រូវដឹងច្បាស់ សោតាយតនៈត្រូវដឹងច្បាស់ សទ្ទាយតនៈត្រូវដឹងច្បាស់ ឃានាយតនៈត្រូវដឹងច្បាស់ គន្ធាយតនៈត្រូវដឹងច្បាស់ ជិវ្ហាយតនៈត្រូវដឹងច្បាស់ រសាយតនៈត្រូវដឹងច្បាស់ កាយាយតនៈត្រូវដឹងច្បាស់ ផោដ្ឋព្វាយតនៈត្រូវដឹងច្បាស់ មនាយតនៈត្រូវដឹងច្បាស់ ធម្មាយតនៈត្រូវដឹងច្បាស់ ។ ចក្ខុធាតុត្រូវដឹងច្បាស់ រូបធាតុត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណធាតុត្រូវដឹងច្បាស់ សោតធាតុត្រូវដឹងច្បាស់ សទ្ទធាតុត្រូវដឹងច្បាស់ សោតវិញ្ញាណធាតុត្រូវដឹងច្បាស់ ឃានធាតុត្រូវដឹងច្បាស់ គន្ធធាតុត្រូវដឹងច្បាស់ ឃានវិញ្ញាណធាតុត្រូវដឹងច្បាស់ ជិវ្ហាធាតុត្រូវដឹងច្បាស់ រសធាតុត្រូវដឹងច្បាស់ ជិវ្ហាវិញ្ញាណធាតុត្រូវដឹងច្បាស់ កាយធាតុត្រូវដឹងច្បាស់ ផោដ្ឋព្វធាតុត្រូវដឹងច្បាស់ កាយវិញ្ញាណធាតុត្រូវដឹងច្បាស់ មនោធាតុត្រូវដឹងច្បាស់ ធម្មធាតុត្រូវដឹងច្បាស់ មនោវិញ្ញាណធាតុត្រូវដឹងច្បាស់ ។ ចក្ខុន្ទ្រិយត្រូវដឹងច្បាស់ សោតិន្ទ្រិយត្រូវដឹងច្បាស់ ឃានិន្ទ្រិយត្រូវដឹងច្បាស់ ជិវ្ហិន្ទ្រិយត្រូវដឹងច្បាស់ កាយិន្ទ្រិយត្រូវដឹងច្បាស់ មនិន្ទ្រិយត្រូវដឹងច្បាស់ ជីវិតិន្ទ្រិយត្រូវដឹងច្បាស់ ឥត្ថិន្ទ្រិយត្រូវដឹងច្បាស់ បុរិសិន្ទ្រិយត្រូវដឹង

ច្បាស់ សុខិន្ទ្រិយត្រូវដឹងច្បាស់ ទុក្ខិន្ទ្រិយត្រូវដឹងច្បាស់ សោមនស្សិន្ទ្រិយត្រូវដឹងច្បាស់ ទោមនស្សិន្ទ្រិយត្រូវដឹងច្បាស់ ឧបេក្ខិន្ទ្រិយត្រូវដឹងច្បាស់ សទ្ធិន្ទ្រិយត្រូវដឹងច្បាស់ វីរិយិន្ទ្រិយត្រូវដឹងច្បាស់ សតិន្ទ្រិយត្រូវដឹងច្បាស់ សមាធិន្ទ្រិយត្រូវដឹងច្បាស់ បញ្ញិន្ទ្រិយត្រូវដឹងច្បាស់ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយត្រូវដឹងច្បាស់ អញ្ញិន្ទ្រិយត្រូវដឹងច្បាស់ អញ្ញាតាវិន្ទ្រិយត្រូវដឹងច្បាស់ ។

[ ៨ ] កាមធាតុត្រូវដឹងច្បាស់ រូបធាតុត្រូវដឹងច្បាស់ អរូបធាតុត្រូវដឹងច្បាស់ កាមភពត្រូវដឹងច្បាស់ រូបភពត្រូវដឹងច្បាស់ អរូបភពត្រូវដឹងច្បាស់ សញ្ញាភពត្រូវដឹងច្បាស់ អសញ្ញាភពត្រូវដឹងច្បាស់ នេវសញ្ញានាសញ្ញាភពត្រូវដឹងច្បាស់ ឯកវោការភពត្រូវដឹងច្បាស់ ចតុវោការភពត្រូវដឹងច្បាស់ បញ្ចវោការភពត្រូវដឹងច្បាស់ ។ បឋមជ្ឈានត្រូវដឹងច្បាស់ ទុតិយជ្ឈានត្រូវដឹងច្បាស់ តតិយជ្ឈានត្រូវដឹងច្បាស់ ចតុត្ថជ្ឈានត្រូវដឹងច្បាស់ ។

[ ៩ ] មេត្តាចេតោវិមុត្តិត្រូវដឹងច្បាស់ ករុណាចេតោវិមុត្តិត្រូវដឹងច្បាស់ មុទិតាចេតោវិមុត្តិត្រូវដឹងច្បាស់ ឧបេក្ខាចេតោវិមុត្តិត្រូវដឹងច្បាស់ អាកាសានញ្ចាយតនសមាបត្តិត្រូវដឹងច្បាស់ វិញ្ញាណញ្ចាយតនសមាបត្តិត្រូវដឹងច្បាស់ អាកិញ្ចញ្ញាយតនសមាបត្តិត្រូវដឹងច្បាស់ នេវសញ្ញានាសញ្ញាយតនសមាបត្តិត្រូវដឹងច្បាស់ ។ អវិជ្ជាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ នាមរូបត្រូវដឹងច្បាស់ សឡាយតនៈត្រូវដឹងច្បាស់ ផស្សៈត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ តណ្ហាត្រូវដឹងច្បាស់ ឧបាទានត្រូវដឹងច្បាស់ ភពត្រូវដឹងច្បាស់ ជាតិត្រូវដឹងច្បាស់ ជរាមរណៈត្រូវដឹងច្បាស់ ។

[ ១០ ] ទុក្ខបុគ្គលត្រូវដឹងច្បាស់ ទុក្ខសមុទ័យត្រូវដឹងច្បាស់ ទុក្ខនិរោធត្រូវដឹងច្បាស់ ទុក្ខនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ រូបសមុទ័យត្រូវដឹងច្បាស់ រូបនិរោធត្រូវដឹងច្បាស់ រូបនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ ។បេ។ សញ្ញាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ ចក្ខុត្រូវដឹងច្បាស់ ។បេ។ ជរាមរណៈត្រូវដឹងច្បាស់ ជរាមរណសមុទ័យ ត្រូវដឹងច្បាស់ ជរាមរណនិរោធត្រូវដឹងច្បាស់ ជរាមរណនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ។

[ ១១ ] អត្ថនៃការកំណត់ដឹងនូវទុក្ខបុគ្គលត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវទុក្ខសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវទុក្ខនិរោធត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវទុក្ខនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ។ អត្ថនៃការកំណត់ដឹងនូវរូបត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវរូបសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវរូបនិរោធត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវទុក្ខនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ។ អត្ថនៃការកំណត់ដឹងនូវរូបត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវរូបសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវរូបនិរោធត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវរូបនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ នូវវេទនា ។បេ។ នូវសញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ អត្ថនៃការកំណត់ដឹងនូវជរាមរណៈត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវជរាមរណសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវជរាមរណនិរោធត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវជរាមរណនិរោធគាមិនីបដិបទាត្រូវ

ដឹងច្បាស់ ។

[ ១២ ] អត្ថនៃការចាក់ធ្លុះនូវការកំណត់ដឹងទុក្ខ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការលះបង់ទុក្ខសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការធ្វើឲ្យជាក់ច្បាស់ទុក្ខនិរោធ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវសេចក្តីចម្រើន ទុក្ខនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ។ អត្ថនៃការចាក់ធ្លុះនូវការកំណត់ដឹងរូបត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការលះបង់រូបសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការធ្វើឲ្យជាក់ច្បាស់នូវរូបនិរោធត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការចម្រើនរូបនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ នូវវេទនា ។បេ។ នូវសញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ អត្ថនៃការចាក់ធ្លុះនូវការកំណត់ដឹងជរាមរណៈ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការលះបង់ជរាមរណសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការធ្វើឲ្យជាក់ច្បាស់ជរាមរណនិរោធត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការចម្រើនជរាមរណ-និរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ។

[ ១៣ ] ទុក្ខបុគ្គលត្រូវដឹងច្បាស់ ទុក្ខសមុទ័យត្រូវដឹងច្បាស់ ទុក្ខនិរោធត្រូវដឹងច្បាស់ ទុក្ខសមុទយនិរោធត្រូវដឹងច្បាស់ ទុក្ខឆន្ទរាគនិរោធត្រូវដឹងច្បាស់ ទុក្ខស្សាទៈត្រូវដឹងច្បាស់ ទុក្ខាទីនវៈត្រូវដឹងច្បាស់ ទុក្ខនិស្សរណៈត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ រូបសមុទ័យត្រូវដឹងច្បាស់ រូបនិរោធត្រូវដឹងច្បាស់ រូបសមុទយនិរោធត្រូវដឹងច្បាស់ រូបឆន្ទរាគនិរោធត្រូវដឹងច្បាស់ រូបស្សាទៈត្រូវដឹងច្បាស់ រូបាទីនវៈត្រូវដឹងច្បាស់ រូបនិស្សរណៈត្រូវដឹងច្បាស់

វេទនាត្រូវដឹងច្បាស់ ។បេ។ សញ្ញាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ ចក្ខុ ។បេ។ ជរាមរណៈត្រូវដឹងច្បាស់ ជរាមរណសមុទ័យត្រូវដឹងច្បាស់ ជរាមរណៈនិរោធត្រូវដឹងច្បាស់ ជរាមរណសមុទយនិរោធត្រូវដឹងច្បាស់ ជរាមរណាធន្ទរាគនិរោធត្រូវដឹងច្បាស់ ជរាមរណស្សាទៈត្រូវដឹងច្បាស់ ជរាមរណាទីនវៈត្រូវដឹងច្បាស់ ជរាមរណនិស្សរណៈត្រូវដឹងច្បាស់ ។

[ ១៤ ] ទុក្ខបុគ្គលត្រូវដឹងច្បាស់ ទុក្ខសមុទ័យត្រូវដឹងច្បាស់ ទុក្ខនិរោធត្រូវដឹងច្បាស់ ទុក្ខនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ទុក្ខស្សាទៈត្រូវដឹងច្បាស់ ទុក្ខាទីនវៈត្រូវដឹងច្បាស់ ទុក្ខនិស្សរណៈត្រូវដឹងច្បាស់ ។ រូបត្រូវដឹងច្បាស់ រូបសមុទ័យត្រូវដឹងច្បាស់ រូបនិរោធត្រូវដឹងច្បាស់ រូបនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ រូបស្សាទៈត្រូវដឹងច្បាស់ រូបាទីនវៈត្រូវដឹងច្បាស់ រូបនិស្សរណៈត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ ។បេ។ សញ្ញាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ ចក្ខុ ។បេ។ ជរាមរណៈត្រូវដឹងច្បាស់ ជរាមរណសមុទ័យត្រូវដឹងច្បាស់ ជរាមរណនិរោធត្រូវដឹងច្បាស់ ជរាមរណនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ជរាមរណស្សាទៈត្រូវដឹងច្បាស់ ជរាមរណាទីនវៈត្រូវដឹងច្បាស់ ជរាមរណនិស្សរណៈត្រូវដឹងច្បាស់ ។

[ ១៥ ] អនិច្ចានុបស្សនា ( ការពិចារណាឃើញរឿយៗ ថាមិនទៀង ) បុគ្គលត្រូវដឹងច្បាស់ ទុក្ខានុបស្សនា ( ការពិចារណាឃើញរឿយៗ ថាជាទុក្ខ ) ត្រូវដឹងច្បាស់ អនត្តានុបស្សនា ( ការពិចារណាឃើញរឿយៗ ថាមិនមែនរបស់ខ្លួន ) ត្រូវដឹងច្បាស់ និព្វិទានុបស្សនា ( ការពិចារណាឃើញរឿយៗ នូវសេចក្តី

នឿយណាយ ) ត្រូវដឹងច្បាស់ វិរាគានុបស្សនា ( ការពិចារណាឃើញរឿយៗ នូវសេចក្តីប្រាសចាកតម្រេក ) ត្រូវដឹងច្បាស់ និរោធានុបស្សនា ( ការពិចារណាឃើញរឿយៗ នូវសេចក្តីរលត់ ) ត្រូវដឹងច្បាស់ បដិនិស្សគ្គានុបស្សនា ( ការពិចារណាឃើញរឿយៗ នូវសេចក្តីលះបង់ ) ត្រូវដឹងច្បាស់ ។ ការពិចារណាឃើញរឿយៗ ក្នុងរូបថា មិនទៀងត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងរូបថាជាទុក្ខ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងរូបថាមិនមែនខ្លួន ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ នូវសេចក្តីនឿយណាយក្នុងរូប ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ នូវសេចក្តីប្រាសចាកតម្រេកក្នុងរូប ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ នូវសេចក្តីរលត់ក្នុងរូប ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ នូវសេចក្តីលះបង់ក្នុងរូប ត្រូវដឹងច្បាស់ ក្នុងវេទនា ។បេ។ ក្នុងសញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈថាមិនទៀង ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈ ថាជាទុក្ខ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈ ថាមិនមែនខ្លួន ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈ ថាជាសេចក្តីនឿយណាយ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈ ថាជាសេចក្តីប្រាសចាកតម្រេក ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈ ថាជាសេចក្តីរលត់ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយៗ ក្នុងជរាមរណៈថាជាសេចក្តីលះបង់ ត្រូវដឹងច្បាស់ ។

[ ១៦ ] ការកើតឡើង ( ព្រោះកម្មអំពីមុនជាបច្ច័យ ) ត្រូវដឹងច្បាស់

ការប្រព្រឹត្តទៅ ( របស់ពួកសត្វ ) ត្រូវដឹងច្បាស់ ការកំណត់ ( នូវសង្ខារ ) ត្រូវដឹងច្បាស់ ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀត ត្រូវដឹងច្បាស់ បដិសន្ធិ ត្រូវដឹងច្បាស់ គតិ ត្រូវដឹងច្បាស់ ការកើត ( នៃខន្ធទាំងឡាយ ) ត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅនៃវិបាក ត្រូវដឹងច្បាស់ ជាតិ ត្រូវដឹងច្បាស់ ជរាត្រូវដឹងច្បាស់ ព្យាធិត្រូវដឹងច្បាស់ មរណៈត្រូវដឹងច្បាស់ សេចក្ដីសោកត្រូវដឹងច្បាស់ សេចក្ដីខ្សឹកខ្សួលត្រូវដឹងច្បាស់ សេចក្ដីតានតឹងត្រូវដឹងច្បាស់ ។ ការមិនកើតឡើងត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅត្រូវដឹងច្បាស់ ការមិនកំណត់ត្រូវដឹងច្បាស់ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតត្រូវដឹងច្បាស់ ការមិនមានបដិសន្ធិត្រូវដឹងច្បាស់ ការមិនមានគតិត្រូវដឹងច្បាស់ ការមិនកើតឡើងត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅ ( នៃវិបាក ) ត្រូវដឹងច្បាស់ ការមិនមានជាតិត្រូវដឹងច្បាស់ ការមិនមានជរាត្រូវដឹងច្បាស់ ការមិនមានព្យាធិត្រូវដឹងច្បាស់ ការមិនស្លាប់ត្រូវដឹងច្បាស់ ការមិនសោកត្រូវដឹងច្បាស់ ការមិនខ្សឹកខ្សួលត្រូវដឹងច្បាស់ ការមិនតានតឹងត្រូវដឹងច្បាស់ ។

[ ១៧ ] ការកើតឡើង បុគ្គលត្រូវដឹងច្បាស់ ការមិនកើតឡើងត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅត្រូវដឹងច្បាស់ ការកំណត់ត្រូវដឹងច្បាស់ ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតត្រូវដឹងច្បាស់ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតត្រូវដឹងច្បាស់ បដិសន្ធិត្រូវដឹងច្បាស់ ការមិនមានបដិសន្ធិត្រូវដឹងច្បាស់

គតិត្រូវដឹងច្បាស់ ការមិនមានគតិត្រូវដឹងច្បាស់ ការកើតឡើងត្រូវដឹងច្បាស់ ការមិនកើតឡើងត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅនៃវិបាកត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅ ( នៃវិបាក ) ត្រូវដឹងច្បាស់ ជាតិត្រូវដឹងច្បាស់ ការមិនមានជាតិត្រូវដឹងច្បាស់ ជរាត្រូវដឹងច្បាស់ ការមិនមានជរាត្រូវដឹងច្បាស់ ព្យាធិត្រូវដឹងច្បាស់ ការមិនមានព្យាធិត្រូវដឹងច្បាស់ មរណៈត្រូវដឹងច្បាស់ ការមិនមានមរណៈត្រូវដឹងច្បាស់ សេចក្ដីសោកត្រូវដឹងច្បាស់ ការមិនមានសេចក្ដីសោកត្រូវដឹងច្បាស់ សេចក្ដីខ្សឹកខ្សួលត្រូវដឹងច្បាស់ ការមិនមានសេចក្ដីខ្សឹកខ្សួលត្រូវដឹងច្បាស់ សេចក្ដីតានតឹងត្រូវដឹងច្បាស់ ការមិនមានសេចក្ដីតានតឹងត្រូវដឹងច្បាស់ ។

[ ១៨ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ត្រូវដឹងច្បាស់ថាការប្រព្រឹត្តទៅជាទុក្ខ ត្រូវដឹងច្បាស់ថាការកំណត់ ( នូវសង្ខារ ) ជាទុក្ខ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាទុក្ខ ត្រូវដឹងច្បាស់ថាបដិសន្ធិជាទុក្ខ ត្រូវដឹងច្បាស់ថាគតិជាទុក្ខ ត្រូវដឹងច្បាស់ថាការកើតឡើងជាទុក្ខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាទុក្ខ ត្រូវដឹងច្បាស់ថាជាតិជាទុក្ខ ត្រូវដឹងច្បាស់ថាជរាជាទុក្ខ ត្រូវដឹងច្បាស់ថាព្យាធិជាទុក្ខ ត្រូវដឹងច្បាស់ថាមរណៈជាទុក្ខ ត្រូវដឹងច្បាស់ថាសេចក្ដីសោកជាទុក្ខ ត្រូវដឹងច្បាស់ថាសេចក្ដីខ្សឹកខ្សួលជាទុក្ខ ត្រូវដឹងច្បាស់ថាសេចក្ដីតានតឹងជាទុក្ខ ។

[ ១៩ ] បុគ្គលត្រូវដឹងច្បាស់ថា ការមិនកើតឡើងជាសុខ ត្រូវដឹងច្បាស់ថាការមិនប្រព្រឹត្តទៅជាសុខ ត្រូវដឹងច្បាស់ថា ការមិនកំណត់ ( នូវសង្ខារ )

ជាសុខ ត្រូវដឹងច្បាស់ថាការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាសុខ ត្រូវដឹងច្បាស់ថាការមិនមានបដិសន្ធិជាសុខ ត្រូវដឹងច្បាស់ថាការមិនមានគតិជាសុខ ត្រូវដឹងច្បាស់ថាការមិនបានកើតឡើងជាសុខ ត្រូវដឹងច្បាស់ថាការមិនប្រព្រឹត្តទៅនៃវិបាកជាសុខ ត្រូវដឹងច្បាស់ថាការមិនមានជាតិជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានជរាជាសុខ ត្រូវដឹងច្បាស់ថាការមិនមានព្យាធិជាសុខ ត្រូវដឹងច្បាស់ថា ការមិនស្លាប់ជាសុខ ត្រូវដឹងច្បាស់ថាការមិនមានសេចក្តីសោកជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីខ្សឹកខ្សួលជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីតានតឹងជាសុខ ។

[ ២០ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ការមិនកើតឡើងជាសុខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាទុក្ខ ការមិនប្រព្រឹត្តទៅជាសុខ ត្រូវដឹងច្បាស់ថា ការកំណត់ ( នូវសង្ខារ ) ជាទុក្ខ ការមិនកំណត់ ( នូវសង្ខារ ) ជាសុខ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាទុក្ខ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាសុខ ត្រូវដឹងច្បាស់ថាបដិសន្ធិជាទុក្ខ ការមិនមានបដិសន្ធិជាសុខ ត្រូវដឹងច្បាស់ថាគតិជាទុក្ខ ការមិនមានគតិជាសុខ ត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ការមិនកើតឡើងជាសុខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាទុក្ខ ការមិនប្រព្រឹត្តទៅនៃវិបាកជាសុខ ត្រូវដឹងច្បាស់ថា ជាតិជាទុក្ខ ការមិនមានជាតិជាសុខ ត្រូវដឹងច្បាស់ថាជរាជាទុក្ខ ការមិនមានជរាជាសុខ ត្រូវដឹងច្បាស់ថា ព្យាធិជាទុក្ខ ការមិនមានព្យាធិជាសុខ ត្រូវដឹងច្បាស់ថាមរណៈជាទុក្ខ ការ

មិនមានមរណៈជាសុខ ត្រូវដឹងច្បាស់ថា សេចក្ដីសោកជាទុក្ខ ការមិនមានសេចក្ដីសោកជាសុខ ត្រូវដឹងច្បាស់ថាសេចក្ដីខ្សឹកខ្សួលជាទុក្ខ ការមិនមានសេចក្ដីខ្សឹកខ្សួលជាសុខ ត្រូវដឹងច្បាស់ថាសេចក្ដីតានតឹងជាទុក្ខ ការមិនមានសេចក្ដីតានតឹងជាសុខ ។

[ ២១ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាភ័យ ត្រូវដឹងច្បាស់ថា ការកំណត់ ( នូវសង្ខារ ) ជាភ័យ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាភ័យ ត្រូវដឹងច្បាស់ថាបដិសន្ធិជាភ័យ ត្រូវដឹងច្បាស់ថាគតិជាភ័យ ត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាភ័យ ត្រូវដឹងច្បាស់ថាជាតិជាភ័យ ត្រូវដឹងច្បាស់ថា ជរាជាភ័យ ត្រូវដឹងច្បាស់ថា ព្យាធិជាភ័យ ត្រូវដឹងច្បាស់ថាមរណៈជាភ័យ ត្រូវដឹងច្បាស់ថាសេចក្ដីសោកជាភ័យ ត្រូវដឹងច្បាស់ថា សេចក្ដីខ្សឹកខ្សួលជាភ័យ ត្រូវដឹងច្បាស់ថាសេចក្ដីតានតឹងជាភ័យ ។

[ ២២ ] បុគ្គលត្រូវដឹងច្បាស់ថា ការមិនកើតឡើង ជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនកំណត់ ( នូវសង្ខារ ) ជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានគតិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅនៃវិបាកជាទីក្សេម

ត្រូវដឹងច្បាស់ថា ការមិនមានជាតិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានជរាជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានមរណៈជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីសោកជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីខ្សឹកខ្សួលជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីតានតឹងជាទីក្សេម ។

[ ២៣ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាភ័យ ការមិនប្រព្រឹត្តទៅជាទីក្សេម ត្រូវដឹងច្បាស់ថា ការកំណត់ ( នូវសង្ខារ ) ជាភ័យ ការមិនកំណត់ ( នូវសង្ខារ ) ជាទីក្សេម ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាភ័យ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាទីក្សេម ត្រូវដឹងច្បាស់ថាបដិសន្ធិជាភ័យ ការមិនមានបដិសន្ធិជាទីក្សេម ត្រូវដឹងច្បាស់ថា គតិជាភ័យ ការមិនមានគតិជាទីក្សេម ត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាភ័យ ការមិនប្រព្រឹត្តទៅនៃវិបាក ជាទីក្សេម ត្រូវដឹងច្បាស់ថាជាតិជាភ័យ ការមិនមានជាតិជាទីក្សេម ត្រូវដឹងច្បាស់ថាជរាជាភ័យ ការមិនមានជរាជាទីក្សេម ត្រូវដឹងច្បាស់ថាព្យាធិជាភ័យ ការមិនមានព្យាធិជាទីក្សេម ត្រូវដឹងច្បាស់ថាមរណៈជាភ័យ ការមិនមានមរណៈជាទីក្សេម ត្រូវដឹងច្បាស់ថា សេចក្តីសោកជាភ័យ ការមិនមានសេចក្តីសោកជាទីក្សេម ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួលជាភ័យ ការមិនមានសេចក្តីខ្សឹកខ្សួលជាទី

ក្សេម ត្រូវដឹងច្បាស់ថាសេចក្តីតានតឹងជាភ័យ ការមិនមានសេចក្តីតានតឹងជាទីក្សេម ។

[ ២៤ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកំណត់ ( នូវសង្ខារ ) ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀត ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាបដិសន្ធិប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាគតិប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកើតឡើងប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាជាតិប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាជរាប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាព្យាធិប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាមរណៈ ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាសេចក្តីសោកប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាសេចក្តីខ្សឹកខ្សួលប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹងប្រកបដោយអាមិសៈ ។

[ ២៥ ] បុគ្គលត្រូវដឹងច្បាស់ថា ការមិនបានកើតឡើង មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានប្រព្រឹត្តទៅ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានកំណត់ ( នូវសង្ខារ ) មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានគតិ មិនប្រកបដោយអាមិសៈ

ត្រូវដឹងច្បាស់ថា ការមិនបានកើត មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានប្រព្រឹត្តទៅនៃវិបាកមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានជាតិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានជរាមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានមរណៈ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីសោក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីខ្សឹកខ្សួល មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីតានតឹង មិនប្រកបដោយអាមិសៈ ។

[ ២៦ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងប្រកបដោយអាមិសៈ ការមិនកើតឡើងមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅប្រកបដោយអាមិសៈ ការមិនប្រព្រឹត្តទៅមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកំណត់ ( នូវសង្ខារ ) ប្រកបដោយអាមិសៈ ការមិនកំណត់ ( នូវសង្ខារ ) មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀត ប្រកបដោយអាមិសៈ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថាបដិសន្ធិប្រកបដោយអាមិសៈ ការមិនមានបដិសន្ធិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា គតិប្រកបដោយអាមិសៈ ការមិនមានគតិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកើតប្រកបដោយអាមិសៈ ការមិនកើតមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាក

ប្រកបដោយអាមិសៈ ការមិនប្រព្រឹត្តទៅនៃវិបាក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ជាតិប្រកបដោយអាមិសៈ ការមិនមានជាតិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ជរាប្រកបដោយអាមិសៈ ការមិនមានជរាមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ព្យាធិប្រកបដោយអាមិសៈ ការមិនមានព្យាធិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា មរណៈប្រកបដោយអាមិសៈ ការមិនមានមរណៈ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីសោកប្រកបដោយអាមិសៈ ការមិនមានសេចក្តីសោក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួលប្រកបដោយអាមិសៈ ការមិនមានសេចក្តីខ្សឹកខ្សួល មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹងប្រកបដោយអាមិសៈ ការមិនមានសេចក្តីតានតឹង មិនប្រកបដោយអាមិសៈ ។

[ ២៧ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថាការកំណត់ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថាការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថាបដិសន្ធិឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថាគតិឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការកើតឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថាការប្រព្រឹត្តទៅនៃវិបាកឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថាជាតិឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ជរាឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ព្យាធិឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា មរណៈឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា

សេចក្តីសោកឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួលឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹងឈ្មោះថាសង្ខារ ។

[ ២៨ ] បុគ្គលត្រូវដឹងច្បាស់ថា ការមិនកើតឡើងឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនបានកំណត់ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានគតិឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនកើតឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅនៃវិបាក ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានជាតិឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានជរាឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានមរណៈឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីសោក ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីខ្សឹកខ្សួលឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីតានតឹង ឈ្មោះថា និព្វាន ។

[ ២៩ ] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងឈ្មោះថាសង្ខារ ការមិនកើតឡើងឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅឈ្មោះថាសង្ខារ ការមិនប្រព្រឹត្តទៅឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការកំណត់ឈ្មោះថាសង្ខារ ការមិនកំណត់ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតឈ្មោះថាសង្ខារ ការមិនប្រមូលមក គឺកម្មដែល

មិនមែនជាហេតុនៃបដិសន្ធិតទៅទៀតឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា បដិសន្ធិ ឈ្មោះថាសង្ខារ ការមិនមានបដិសន្ធិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា គតិ ឈ្មោះថាសង្ខារ ការមិនមានគតិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការកើត ឈ្មោះថាសង្ខារ ការមិនកើតឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកឈ្មោះថាសង្ខារ ការមិនប្រព្រឹត្តទៅនៃវិបាកឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថាជាតិឈ្មោះថាសង្ខារ ការមិនមានជាតិឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ជរាឈ្មោះថាសង្ខារ ការមិនមានជរាឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ព្យាធិ ឈ្មោះថាសង្ខារ ការមិនមានព្យាធិឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា មរណៈ ឈ្មោះថាសង្ខារ មិនមានមរណៈឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា សេចក្តីសោកឈ្មោះថាសង្ខារ ការមិនមានសេចក្តីសោក ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួល ឈ្មោះថាសង្ខារ ការមិនមានសេចក្តីខ្សឹកខ្សួល ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា សេចក្តីតានតឹងឈ្មោះថាសង្ខារ ការមិនមានសេចក្តីតានតឹង ឈ្មោះថា និព្វាន ។

**បឋមភាណវារៈ ចប់**

## បឋមភាណវារៈ

## អដ្ឋកថា អភិញ្ញេយ្យនិទ្ទេស

[ ២ ] ឥឡូវនេះ ព្រះធម្មសេនាបតីសារីបុត្តបានសម្ដែងនិទ្ទេសវារៈថា **កថំ ឥមេ ធម្មា អភិញ្ញេយ្យា** ជាដើម ដើម្បីសម្ដែងធម៌ដែលលោករួបរួម ក្នុងវិសជ្ជនុទ្ទេសជាប្រភេទតទៅ ។

ក្នុងពាក្យទាំងនោះ ព្រះធម្មសេនាបតីសារីបុត្ត បានលើកយកវិសជ្ជនាមួយប្រការ ដប់ៗ ដោយអំណាចនៃធម៌ពួកមួយជាដើម តាំងអំពីផ្ដើមក្នុងនិទ្ទេស ៥ មានអភិញ្ញេយ្យនិទ្ទេសជាដើម សម្ដែងប្រៀបធៀបដោយបរិយាយនៃទសុត្តរ-សូត្រ ។

បណ្ដានិទ្ទេសទាំង ៥ នោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអភិញ្ញេយ្យនិទ្ទេសមុន បទថា **សព្វេ សត្តា** បានដល់ សត្វទាំងពួង ក្នុងភពទាំងពួង គឺក្នុងកាមភពជាដើម ក្នុងសញ្ញាភពជាដើម និងក្នុងឯកវោការភពជាដើម ។

បទថា **អាហារដ្ឋិតិកា** មានវិគ្គហៈថា ការតាំងនៅរបស់សត្វទាំងឡាយនោះ មានព្រោះអាហារ ព្រោះហេតុនោះ ទើបឈ្មោះថា **អាហារដ្ឋិតិកា** ។

ក្នុងបទថា **ឋិតិ** នេះ លោកប្រាថ្នាយកការមាននៅក្នុងខណៈរបស់ខ្លួន ។

ឈ្មោះថា **អាហារ** ព្រោះជាហេតុនៃការតាំងនៅនៃសត្វទាំងឡាយជាធម៌មួយ គប្បីដឹងដោយបញ្ញាដ៏ក្រៃលែង ។ កាលបើដឹងបច្ច័យហើយ ក៏ជាការដឹងបច្ចយុប្បន្នធម៌ ( ធម៌ដែលកើតពីបច្ច័យ ) ព្រោះបច្ច័យ និងបច្ចយុប្បន្នធម៌ទាំង ២ នោះ សម្ព័ន្ធការអាស្រ័យគ្នានឹងគ្នា ។ **ញាតប្បរិញ្ញា** ឈ្មោះថា លោកពោលហើយ ដោយពាក្យនោះ ។

*សួរថា កាលបើយ៉ាងនោះ ពាក្យណាដែលលោកពោល ( ក្នុងអភិធម្ម-បិដក វិភង្គ ) ថា ពួកទេវតាជាអសញ្ញសត្វមិនមានហេតុ មិនមានអាហារ មិនមានផស្សៈ ដូច្នេះជាដើម ពាក្យនោះ មិនខុសទៅហើយឬ ឆ្លើយថា ពាក្យដែលលោកពោលនោះមិនខុស ព្រោះថា ឈានជាអាហាររបស់អសញ្ញសត្តព្រហ្មទាំងនោះ ។ សួរថា សូម្បីយ៉ាងនោះ ពាក្យនេះ ( សំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ អាហារនេះមាន ៤ តែងប្រព្រឹត្តទៅដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។ អាហារទាំង ៤ តើដូចម្តេច ។ កពឡិង្ការាហារ ដ៏គ្រោតគ្រាតក្តី ល្អិតក្តី ( ជាទី ១ ) ផស្សាហារជាទី ២ មនោសញ្ចេតនាហារជាទី ៣ វិញ្ញាណាហារជាទី ៤ ដូច្នេះក៏រមែងខុស ឆ្លើយថា ទោះបីពាក្យនោះក៏មិនខុស ព្រោះក្នុងសូត្រនោះ ត្រាស់ដោយត្រង់ថា ធម៌ទាំងឡាយ មានអាហារជាលក្ខណៈ ឈ្មោះថា អាហារ តែក្នុងទីនេះ ត្រាស់ដោយអមថា បច្ច័យ ឈ្មោះថា អាហារ ព្រោះសង្ខតធម៌ទាំងពួងបានបច្ច័យរមែងគួរ បច្ច័យនោះ រមែងញ៉ាំងផលណាមួយឲ្យកើតឡើង ឈ្មោះថា រមែងនាំមកនូវផលនោះៗ ព្រោះហេតុនោះ ទើបបច្ច័យនោះ លោកហៅថា អាហារ ។ ដោយហេតុនោះឯង ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អវិជ្ជាប្រាកដដោយអាហារ មិនបានពោលថា អវិជ្ជាឥតអាហារទេ ។ ចុះអ្វី ជាអាហាររបស់អវិជ្ជា ។ គប្បីឆ្លើយថា នីវរណៈ ៥ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា នីវរណៈ ៥ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ... គប្បីឆ្លើយថា អយោនិ-*

សោមនស្សិការ[1] ដូច្នេះជាដើម ។

អាហារដូចពោលហើយនេះ បំណងយកហើយក្នុងទីនេះ កាលបើកាន់យកអាហារ គឺបច្ច័យនេះហើយ អាហារ ទាំងដោយអម និងអាហារ ទាំងដោយត្រង់ ក៏ឈ្មោះថា កាន់យកទាំងអស់ ។

ក្នុងពាក្យនោះ **បច្ចយាហារ** រមែងបានក្នុងអសញ្ញីភព ។ ពិតហើយ កាលព្រះពុទ្ធមិនទាន់កើតឡើង ពួកអ្នកបួសជាតិ្ថិយ ធ្វើបរិកម្មក្នុងវាយោកសិណ ញុំាងចតុត្ថជ្ឈានឲ្យកើតឡើង ចេញពីឈាននោះហើយ ក៏ឃើញថា ចិត្តនេះជារបស់គួរតិះដៀលច្រើន ការមិនមានចិត្តជាការល្អ ដ្បិតថា ទុក្ខមានការសម្លាប់និងចងជាដើម ជាបច្ច័យរមែងកើតឡើងព្រោះអាស្រ័យចិត្ត កាលបើមិនមានចិត្ត ទុក្ខនោះក៏មិនមាន ដូច្នេះហើយ ទើបកើតសេចក្តីត្រេកអរ មានឈានមិនសាបសូន្យ ធ្វើកាលកិរិយាហើយ កើតក្នុងអសញ្ញីភព ។ បុគ្គលណាតាំងនៅក្នុងឥរិយាបថណាក្នុងមនុស្ស បុគ្គលនោះក៏កើតហើយ ដោយឥរិយាបថនោះ រហូត ៥០០ កប្ប ។ ដូចជាដេក អង្គុយ ឬឈរ រហូតអស់កាលយូរ មានប្រមាណត្រឹមនោះ ។ បច្ចយាហារ រមែងបានដល់សត្វទាំងឡាយដែលមានសភាពយ៉ាងនោះ ។ សត្វទាំងនោះ ចម្រើនឈានណា ហើយកើតឈាននោះឯង ក៏ជាបច្ច័យដល់សត្វទាំងឡាយនោះ ដូចព្រួញដែលបាញ់ទៅដោយកម្លាំងនៃខ្សែធ្នូ កម្លាំងខ្សែធ្នូមានកម្លាំងត្រឹមណា ក៏ទៅបានត្រឹមនោះយ៉ាងណា កម្លាំងឈានបច្ច័យមានប្រមាណត្រឹមណា ក៏តាំងនៅដរាបនោះយ៉ាងនោះ ។ កាល

---

១- សេចក្តីពិស្តារ សូមមើលក្នុងបិដកខ្មែរ លេខ ៥០ ឃ្នាប ៦១ ។

បើកម្លាំងឈានប្បច្ច័យអស់ហើយ សត្វទាំងនោះក៏ចុតិ ដូចព្រួញដែលមានកម្លាំងអស់ហើយ ដូច្នោះ ។

សួរថា ចំណែកសត្វពួកណា ជាអ្នកកើតក្នុងនរក សត្វទាំងនោះ លោកពោលថា មិនជាអ្នកមានជីវិតនៅដោយសេចក្ដីព្យាយាម មិនជាអ្នកមានជីវិតនៅដោយផលនៃបុណ្យឡើយ អ្វីជាអាហាររបស់សត្វទាំងនោះ ឆ្លើយថា កម្មនោះឯង ជាអាហាររបស់សត្វទាំងនោះ ដូច្នេះ ។

សួរថា អាហារមាន ៥ យ៉ាងឬ ឆ្លើយថា ពាក្យនេះ មិនគប្បីពោលថា មាន ៥ ឬមិនមែន ៥ យ៉ាងនេះ ។ វាទៈថា បច្ច័យជាអាហារ លោកពោលហើយ មិនមែនឬ ព្រោះហេតុនោះ សត្វទាំងនោះ កើតក្នុងនរកដោយកម្មណា កម្មនោះឯង ជាអាហាររបស់សត្វទាំងនោះ ព្រោះជាបច្ច័យនៃការរស់នៅ ដែលព្រះមានព្រះភាគ ត្រាស់សំដៅយកពាក្យនេះហើយ ( ក្នុងអង្គុត្តរ-និកាយ តិកនិបាត ) ថា អំពើអាក្រក់ មិនទាន់អស់ដរាបណា ក៏មិនទាន់ធ្វើមរណកាលដរាបនោះ ។

ព្រោះហេតុនោះ បទថា **អាហារដ្ឋិតិកា** ទើបមានសេចក្ដីថា តាំងនៅបានព្រោះបច្ច័យ ។ ក្នុងពាក្យនេះថា ព្រោះប្រារព្ធកពឡិង្ការាហារ មិនគប្បីធ្វើនូវការឈ្លោះប្រកែក ព្រោះថា សូម្បីទឹកមាត់ដែលកើតក្នុងមាត់ ក៏ឲ្យសម្រេចកិច្ចជាអាហារដល់សត្វទាំងនោះបាន ។ ពិតហើយ ទឹកមាត់ក៏ជាបច្ច័យដល់ពួកសត្វកើតក្នុងនរក ដែលសោយទុក្ខវេទនា និងដល់ពួកអ្នកកើតក្នុងស្ថានសួគ៌ ដែលសោយសុខវេទនា ។

*ក្នុងកាមភព មានអាហារ ៤ ដោយត្រង់ ក្នុងរូបភព និងអរូបភព វៀរអសញ្ញីភពចេញ ក្រៅពីនោះ មានអាហារ ៣ អសញ្ញីភព និងភពក្រៅពីនោះ មានបច្ចយាហារ ដោយប្រការដូច្នេះ ព្រោះហេតុនោះ សត្វទាំងឡាយទាំងពួង តាំងនៅបានព្រោះអាហារ ដោយអាហារដូចពោលមកហើយនេះ ។*

*បទថា* **សព្វេ សត្តា** *ជាបុគ្គលាធិដ្ឋាននៃធម៌ទេសនា អធិប្បាយថា សង្ខារទាំងឡាយទាំងពួង ។ ពិតហើយ ទេសនារបស់ព្រះមានព្រះភាគ មាន ៤ យ៉ាងដោយអំណាចនៃធម៌ និងបុគ្គល គឺធម្មាធិដ្ឋានធម្មទេសនា ១ ធម្មាធិដ្ឋានបុគ្គលទេសនា ១ បុគ្គលាធិដ្ឋានបុគ្គលទេសនា ១ បុគ្គលាធិដ្ឋានធម្មទេសនា ១ ។*

*ធម្មាធិដ្ឋានធម្មទេសនា ដូចសម្តែង ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចម្រើនហើយ ទើបជាធម្មជាតគួរដល់ការងារដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលចម្រើនហើយ ទើបជាធម្មជាតគួរដល់ការងារ ។*

*ធម្មាធិដ្ឋានបុគ្គលទេសនា ដូចសម្តែង ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គឺសោតាបន្ន គប្បីប្រកាន់នូវសង្ខារណាមួយថា ជាវត្ថុទៀង ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺថា ហេតុនុ៎ះ មិនដែលមានឡើយ ។*

*បុគ្គលាធិដ្ឋានបុគ្គលទេសនា ដូចសម្តែង ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត )*

ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

បុគ្គលាធិដ្ឋានធម្មទេសនា ដូចសម្ដែង ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក ជាការកើតប្រាកដនៃចក្ខុដ៏ប្រសើរ ។

ក្នុងទេសនាទាំង ៤ នោះ ក្នុងទីនេះ លោកបំណងយកបុគ្គលាធិដ្ឋានធម្មទេសនា ។ គួរជ្រាបថា លោកសម្ដែងធម្មសព្ទដោយសត្តសព្ទ ព្រោះសំដៅយកធម៌ប៉ុណ្ណោះ តាំងពីដើមរហូតដល់ពួក ១០ យ៉ាងទៀត គប្បីជ្រាបថា លោកសម្ដែងសត្តសព្ទដោយវិសេស ព្រោះគប្បីចូលទៅពិចារណាធម៌ដែលទាក់ទងក្នុងសន្ដានរបស់សត្វបានតាមសភាវៈ ដោយញាណដ៏ក្រៃលែង ឬគួរជ្រាបថា សង្ខារទាំងឡាយ លោកពោលថា សត្វ ដោយផលូបចារន័យ ព្រោះត្រឹមតែបញ្ញត្តថា សត្វ ក៏ព្រោះអាស្រ័យសង្ខារទាំងឡាយ ។ សត្វណាមួយឈ្មោះថា តាំងនៅដោយបច្ច័យនោះ មិនមានឡើយក្រៅអំពីសង្ខារទាំងឡាយ តែលោកហៅយ៉ាងនេះ ដោយអំណាចនៃវោហារ ។ ញាតបរិញ្ញា ឈ្មោះថា លោកពោលដោយពាក្យនេះ ដោយប្រការដូច្នេះ ។ បទថា **ទ្វេ ធាតុយោ** បានដល់ សង្ខតធាតុ ១ អសង្ខតធាតុ ១ ។ បណ្ដាធាតុទាំង ២ នោះ ខន្ធ ៥ ដែលបច្ច័យដ៏អនេកតាក់តែងហើយ ឈ្មោះថា សង្ខតធាតុ ព្រះនិព្វានដែល

បច្ច័យណាមួយតាក់តែង មិនបានឈ្មោះថា អសង្ខតធាតុ ។ បទថា **តិស្សោ ធាតុយោ** បានដល់ កាមធាតុ ១ រូបធាតុ ១ អរូបធាតុ ១ ។

បណ្តាធាតុ ៣ នោះ កាមធាតុ តើដូចម្តេច ខាងក្រោម តាំងអំពីអវិចីនរកជាទីបំផុត ខាងលើ តាំងអំពីបរនិម្មិតវសវត្តីទេវតាជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណណា មានក្នុងចន្លោះនេះ ត្រាច់ចុះក្នុងចន្លោះនេះ រាប់បញ្ចូលក្នុងចន្លោះនេះ នេះហៅថា កាមធាតុ[១] ។

បណ្តាធាតុទាំង ៣ នោះ រូបធាតុ តើដូចម្តេច ខាងក្រោម រាប់តាំងអំពីព្រហ្មលោកជាទីបំផុត ខាងលើ រាប់តាំងអំពីអកនិដ្ឋទេវតាជាទីបំផុត ពួកធម៌ប្រព្រឹត្តទៅក្នុងចិត្ត និងចេតសិកណា របស់បុគ្គលដែលចូលឈានក្តី ដែលទៅកើតហើយក្តី ដែលនៅជាសុខក្នុងបច្ចុប្បន្នក្តី ក្នុងចន្លោះនុ៎ះ ត្រាច់ចុះក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះហៅថា រូបធាតុ ។

បណ្តាធាតុទាំង ៣ នោះ អរូបធាតុ តើដូចម្តេច ខាងក្រោម រាប់តាំងអំពីអាកាសានញ្ចាយតនទេវតាជាទីបំផុត ខាងលើ រាប់តាំងអំពីនេវសញ្ញានាសញ្ញាយតនទេវតាជាទីបំផុត ពួកធម៌ប្រព្រឹត្តទៅក្នុងចិត្ត និងចេតសិកណា របស់បុគ្គលដែលចូលឈានក្តី ដែលទៅកើតហើយក្តី ដែលនៅជាសុខក្នុងបច្ចុប្បន្នក្តី ក្នុងចន្លោះនុ៎ះ ត្រាច់ចុះក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះលោកហៅថា អរូបធាតុ ។

តែក្នុងអដ្ឋកថាពោលថា កាមភព ឈ្មោះថា កាមធាតុ រមែងបានខន្ធ ៥

១- បិដកខ្មែរ លេខ ៨០ ឃ្នាប ១២២ ។

រូបភព ឈ្មោះថា រូបធាតុ រមែងបានខន្ធ ៥ អរូបភព ឈ្មោះថា អរូបធាតុ រមែងបានខន្ធ ៤ ។ នេះជាការប្រកបតាមបរិយាយនៃទសុត្តរសូត្រ ។

ចំណែកក្នុងបរិយាយនៃសង្គីតិសូត្រថា សូម្បីធាតុទាំងឡាយដែលលោកពោលថា ធាតុជាកុសល ៣ យ៉ាង គឺធាតុប្រកបដោយការចេញចាកកាម ១ ធាតុប្រកបដោយការមិនព្យាបាទ ១ ធាតុប្រកបដោយការមិនបៀតបៀន ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺធាតុប្រកបដោយរូប ១ ធាតុប្រកបដោយអរូប ១ ធាតុប្រកបដោយសេចក្តីរលត់ គឺព្រះនិព្វាន ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺធាតុយ៉ាងទាប ១ ធាតុយ៉ាងកណ្តាល ១ ធាតុយ៉ាងឧត្តម ១ ក៏រមែងចាត់ចូលក្នុងទីនេះបាន ។

សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ តម្រិះត្រូវដែលប្រកបដោយនេក្ខម្មៈ គឺសម្មាសង្កប្បៈ នេះហៅថា នេក្ខម្មធាតុ ។ មួយទៀត កុសលធម៌ទាំងអស់ក៏ឈ្មោះថា នេក្ខម្មធាតុដែរ ។

សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយអព្យាបាទ គឺសម្មាសង្កប្បៈ នេះហៅ ថាអព្យាបាទធាតុ ។ ការស្រឡាញ់ អាការប្រព្រឹត្តស្រឡាញ់ ភាពនៃអាការប្រព្រឹត្តស្រឡាញ់ គឺមេត្តាចេតោវិមុត្តិណាក្នុងពួកសត្វ នេះហៅថា អព្យាបាទធាតុ ។

សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយអវិហឹសា គឺសម្មាសង្កប្បៈ នេះហៅថា អវិហឹសាធាតុ ។ ការអាណិត អាការប្រព្រឹត្តអាណិត ភាពនៃអាការប្រព្រឹត្តអាណិត គឺករុណាចេតោវិមុត្តិណា ក្នុងសត្វ

ទាំងឡាយ នេះហៅថា អវិហឹសាធាតុ[១] ។

រូបធាតុ និងអរូបធាតុ បានពោលហើយ ។ និរោធធាតុ ជាព្រះនិព្វាន ។ ហីនធាតុ ជាអកុសលចិត្តុប្បាទ ១២ មជ្ឈិមធាតុ ជាធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ។ បណីតធាតុ ជាលោកុត្តរធម៌ ៩ ធម៌ទាំងអស់ ហៅថា ធាតុ ដោយអត្ថថា មិនមែនជីវៈ ។

បទថា **ចត្តារិ អរិយសច្ចានិ** បានដល់ ទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ អធិប្បាយនៃអរិយសច្ចទាំង ៤ នេះ នឹងមានជាក់ច្បាស់ ក្នុងវិសជ្ជនានៃសច្ចៈនោះឯង ។

បទថា **បញ្ច វិមុត្តាយតនានិ** សេចក្តីថា ហេតុនៃការផុត ៥ ប្រការទាំងនេះ គឺការស្តាប់ធម្មទេសនាដែលអ្នកដទៃសម្តែង ដើម្បីប្រយោជន៍ដល់ខ្លួន ១ ការសម្តែងធម៌តាមដែលខ្លួនបានស្តាប់មកហើយ ដើម្បីប្រយោជន៍ដល់អ្នកដទៃ ១ ការសូធ្យាយធម៌ដែលខ្លួនបានស្តាប់មកហើយ ១ ការត្រិះរិះដល់ធម៌ តាមដែលបានស្តាប់មកហើយដោយចិត្ត ១ អារម្មណ៍ ដែលសមគួរដល់សមថកម្មដ្ឋាន ៤០ មានកសិណ ១០ អសុភ ១០ ជាដើម ១ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ក្នុងសាសនានេះ ជាគរុដ្ឋានីយបុគ្គល ( បុគ្គលគួរគោរព )

---

១- បិដកខ្មែរ លេខ ៨០ ឃ្នាប ១២២ ។

សម្តែងធម៌ដល់ភិក្ខុ ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល សម្តែងធម៌ដល់ភិក្ខុនោះយ៉ាងណាៗ ភិក្ខុនោះ រមែងដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផងក្នុងធម៌នោះយ៉ាងនោះៗ កាលបើភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជ ( សេចក្តីរីករាយ ) រមែងកើតឡើង កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយ ក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្តីសុខ រមែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ១ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសម្តែងធម៌ដល់ភិក្ខុ តែថា សម្តែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការរេះដឹង តាមសមគួរដល់ការសិក្សាដោយពិស្តារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្តែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការរេះដឹង សមគួរដល់ការសិក្សាដោយពិស្តារ យ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផងក្នុងធម៌នោះ យ៉ាងនោះៗ កាលភិក្ខុនោះ ដឹងច្បាស់នូវអដ្ឋកថា

ដឹងច្បាស់នូវបាលី បាមោជ្ជក៏កើតឡើង ។បេ។ ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ រមែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ជាគរុដ្ឋានីយបុគ្គល មិនបានសម្តែងធម៌ដល់ភិក្ខុទេ ទាំងមិនបានសម្តែងធម៌ ដល់បុគ្គលដទៃ តាមសមគួរដល់ការរេះដឹង តាមសមគួរដល់ការសិក្សាដោយពិស្តារទេ គ្រាន់តែធ្វើការស្វាធ្យាយធម៌ តាមសមគួរដល់ការរេះដឹង សមគួរដល់ការសិក្សាដោយពិស្តារ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការរេះដឹង សមគួរដល់ការសិក្សាដោយពិស្តារយ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះ យ៉ាងនោះៗ កាលភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជក៏រមែងកើតឡើង ។បេ។ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្តីសុខតែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសម្តែងធម៌ដល់ភិក្ខុ ទាំងមិនបានសម្តែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការរេះដឹង សមគួរដល់ការសិក្សាដោយពិស្តារទេ ទាំងមិន

ធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះដឹង សមគួរ
ដល់ការសិក្សាដោយពិស្តារដែរ គ្រាន់តែត្រិះរិះពិចារណារំពឹង
ក្នុងចិត្ត ដោយចិត្តចំពោះធម៌តាមសមគួរដល់ការចេះដឹង សម
គួរដល់ការសិក្សា ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រិះរិះពិចារណា
រំពឹងក្នុងចិត្ត ដោយចិត្ត ចំពោះធម៌តាមសមគួរដល់ការចេះដឹង
សមគួរដល់ការសិក្សា យ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវ
អដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះ យ៉ាងនោះៗ
កាលភិក្ខុនោះ ដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជ
រមែងកើតឡើង ។បេ។ ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ ក៏
រមែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រះសាស្តា ឬភិក្ខុជា
សព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនបានសម្តែង
ធម៌ដល់ភិក្ខុទេ ទាំងមិនបានសម្តែងធម៌ដល់បុគ្គលដទៃ តាម
សមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្តារទេ
ទាំងមិនបានធ្វើនូវការស្វាធ្យាយធម៌ តាមសមគួរដល់ការចេះ
ដឹង សមគួរដល់ការសិក្សាដោយពិស្តារទេ ទាំងមិនបានត្រិះរិះ
ពិចារណារំពឹងក្នុងចិត្ត ដោយចិត្តចំពោះធម៌តាមសមគួរ ដល់
ការចេះដឹង សមគួរដល់ការសិក្សាទេ តែលោករៀនយកដោយ
ល្អនូវសមាធិនិមិត្តណាមួយ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំ

ដោយល្អ យល់ច្បាស់ដោយល្អដោយប្រាជ្ញា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀនយកដោយល្អ នូវសមាធិនិមិត្តណាមួយ ធ្វើទុកក្នុងចិត្តដោយល្អ ចងចាំដោយល្អ យល់ច្បាស់ដោយល្អ ដោយបញ្ញា យ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះ យ៉ាងនោះៗ កាលភិក្ខុនោះដឹងច្បាស់នូវអដ្ឋកថា ដឹងច្បាស់នូវបាលី បាមោជ្ជក៏កើតឡើង កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្ដីសុខ ចិត្តរបស់ភិក្ខុដែលប្រកបសេចក្ដីសុខ តែងតម្កល់មាំ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈទី ៥ ដូច្នេះ ។

ក្នុងបទថា ៨ **អនុត្តរិយានិ** មានវិគ្គហៈថា គុណដែលក្រៃលែងជាងធម្មជាតទាំងនោះមិនមាន ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា អនុត្តរ អនុត្តរនោះឯង ឈ្មោះថា អនុត្តរិយ អធិប្បាយថា ចម្រើនបំផុត ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ឆក្កនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ ( ធម្មជាតប្រសើរបំផុត ) នេះមាន ៦ ។ ៦ តើអ្វីខ្លះ ។ គឺទស្សនានុត្តរិយៈ ( ការឃើញដ៏ប្រសើរបំផុត ) ១ សវនានុត្តរិយៈ ( ការស្ដាប់ប្រសើរបំផុត ) ១ លាភានុត្តរិយៈ ( ការបានប្រសើរបំផុត ) ១ សិក្ខានុត្តរិយៈ

( ការសិក្សាប្រសើរបំផុត ) ១ បារិចរិយានុត្តរិយៈ ( ការបម្រើប្រសើរបំផុត ) ១ អនុស្សតានុត្តរិយៈ ( ការរឭកប្រសើរបំផុត ) ១ ។ ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ទៅមើលដំរីរ័ត្នក្ដី ទៅមើលសេះរ័ត្នក្ដី ទៅមើលមណីរ័ត្នក្ដី ឬក៏ទៅមើលរបស់ធំតូចណាមួយក្ដី ទៅមើលសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្ដី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការឃើញនុ៎ះ ឈ្មោះថា ឃើញហើយ ការឃើញនុ៎ះ មិនមែនជាមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ តែថា ការឃើញនុ៎ះ ជារបស់ថោកសម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា ទៅឃើញតថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការឃើញនុ៎ះទើបប្រសើរបំផុត ជាងការឃើញទាំងឡាយ ( ព្រោះប្រព្រឹត្តទៅ ) ដើម្បីសេចក្ដីបរិសុទ្ធដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្ដីសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និង

ទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលទៅឃើញតថាគត ឬសាវ័កនៃតថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការឃើញនេះ ទើបតថាគតឲ្យឈ្មោះថា ការឃើញប្រសើរបំផុត ។ ទស្សនានុត្តរិយៈដូច្នេះឯង ។ ចំណែកសវនានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ទៅស្តាប់សំឡេងស្គរក្តី ទៅស្តាប់សំឡេងពិណក្តី ទៅស្តាប់សំឡេងច្រៀងក្តី ឬក៏ទៅស្តាប់សំឡេងធំតូចណាមួយក្តី ទៅស្តាប់ធម៌របស់សមណៈឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិអ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយតថាគតពោលថា ការស្តាប់នុ៎ះ ក៏ឈ្មោះថា ស្តាប់ដែរ ការស្តាប់នុ៎ះ មិនមែនជាមិនស្តាប់ទេ ម្នាលភិក្ខុទាំងឡាយ តែថាការស្តាប់នុ៎ះ ជារបស់ថោក ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណាទៅស្តាប់ធម៌តថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការស្តាប់នុ៎ះ ទើបប្រសើរបំផុត ជាងការស្តាប់ទាំងឡាយ ព្រោះប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ ដល់សត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលទៅស្តាប់ធម៌តថាគត ឬ

សាវ័កនៃតថាគត ហើយជាអ្នកមានសទ្ធាខាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការស្ដាប់នេះ ទើបតថាគតឲ្យឈ្មោះថា ការស្ដាប់ប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ ដូច្នេះឯង ។ ឯលាភានុត្តរិយៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ បានលាភ គឺកូនក្ដី បានលាភ គឺប្រពន្ធក្ដី បានលាភ គឺទ្រព្យក្ដី ឬក៏បានលាភធំតូចណាមួយក្ដី បានសេចក្ដីជឿក្នុងសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិអ្នកប្រតិបត្តិខុសក្ដី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា លាភនុ៎ះ ក៏ជាលាភដែរហើយ មិនមែនឥតលាភទេ ម្នាលភិក្ខុទាំងឡាយ តែថា លាភនុ៎ះ ជារបស់ថោក ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បានសេចក្ដីជឿក្នុងតថាគត ឬក្នុងសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបាននុ៎ះប្រសើរបំផុតជាងលាភទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធដល់សត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលបានសេចក្ដីជឿ ក្នុងតថាគត ឬក្នុងសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបាននេះ ទើប

តថាគតឲ្យឈ្មោះថា ជាលាភប្រសើរបំផុត ។ ទស្សនា-នុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈដូច្នេះឯង ។ ចំណែកខាងសិក្ខានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ សិក្សាវិជ្ជាដំរីក្តី សិក្សាវិជ្ជាសេះក្តី សិក្សាវិជ្ជារថក្តី សិក្សាវិជ្ជាធ្នូក្តី សិក្សាវិជ្ជាដងដាវក្តី ឬក៏សិក្សាវិជ្ជាខ្ពស់ទាបក្តី សិក្សា ( វិជ្ជា ) របស់សមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិអ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសិក្សានុ៎ះ ក៏ជាការសិក្សាហើយ មិនមែនមិនសិក្សាទេ ម្នាលភិក្ខុទាំងឡាយ តែថា ការសិក្សានុ៎ះជារបស់ថោក ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា សិក្សានូវអធិសីល សិក្សានូវអធិចិត្ត សិក្សានូវអធិប្បញ្ញាក្នុងធម្មវិន័យដែលតថាគតសម្តែងហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការសិក្សានុ៎ះប្រសើរបំផុតជាងការសិក្សាទាំងឡាយ ព្រោះប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ ដល់សត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលសិក្សានូវអធិសីលក្តី សិក្សានូវអធិចិត្តក្តី សិក្សានូវអធិប្បញ្ញាក្តី ក្នុងធម្មវិន័យដែលតថាគតសម្តែងហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការ

សិក្សានេះ ទើបតថាគតហៅថា ការសិក្សាប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ ដូច្នេះឯង ។ ឯបារិចរិយានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ បម្រើក្សត្រក្តី បម្រើព្រាហ្មណ៍ក្តី បម្រើគហបតីក្តី ឬបម្រើបុគ្គលធំតូចណាមួយក្តី បម្រើសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិអ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថាការបម្រើនុ៎ះ ក៏ជាការបម្រើហើយ មិនមែនមិនបម្រើទេ ម្នាលភិក្ខុទាំងឡាយ តែថា ការបម្រើនុ៎ះ ជារបស់ថោក ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បម្រើតថាគត ឬសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបម្រើនុ៎ះ ប្រសើរបំផុតជាងការបម្រើទាំងឡាយ ព្រោះប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធដល់សត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលបម្រើតថាគត ឬសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបម្រើនេះ ទើបតថាគតហៅថា ការបម្រើប្រសើរបំផុត ។ ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ បារិរិយាច-

នុត្តរិយៈ ដូច្នេះឯង ។ ចំណែកអនុស្សតានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រឭកនូវការបាទកូនក្តី រឭកនូវការបាទប្រពន្ធក្តី រឭកនូវការបាទទ្រព្យក្តី ឬក៏រឭកនូវការបាទរបស់តូចធំក្តី រឭកនូវសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិអ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការរឭកនោះ ក៏ឈ្មោះថារឭកដែរ មិនមែនមិនរឭកទេ ម្នាលភិក្ខុទាំងឡាយ តែថា ការរឭកនុ៎ះ ជារបស់ថោក ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា រឭកនូវតថាគត ឬសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ សេចក្តីរឭកនុ៎ះ ប្រសើរបំផុតជាងសេចក្តីរឭកទាំងឡាយ ព្រោះប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធដល់សត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន គឺនៅត្រង់បុគ្គលរឭកនូវតថាគត ឬសាវ័ករបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការរឭកនេះ ទើបតថាគតហៅថា ការរឭកប្រសើរបំផុត ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអនុត្តរិយៈទាំង ៦ យ៉ាង ។

ក្នុងបទថា **សត្ត និទ្ទសវត្ថូនិ** នេះ មានវិគ្គហៈថា ដប់មិនមានដល់បុគ្គល

នោះ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **និទ្ទស** វត្ថុ គឺហេតុនៃនិទ្ទស គឺភាពជានិទ្ទស ឈ្មោះថា **និទ្ទសវត្ថុ** ។ ពិតហើយ ព្រះខីណាស្រពបរិនិព្វាន ក្នុងកាលដែលមានវស្សា ១០ ក៏រមែងមិនមានវស្សា ១០ ទៀត ព្រោះមិនមាន បដិសន្ធិតទៅទៀត ព្រោះហេតុនោះ ទើបហៅថា **និទ្ទស** គឺមិនមានវស្សា ១០ ។ មិនមែនមិនមានវស្សា ១០ តែម្យ៉ាងប៉ុណ្ណោះទេ សូម្បីវស្សា ៩ ក៏មិនមាន ។បេ។ សូម្បីកាលត្រឹមតែមួយស្របក់ ក៏មិនមាន ។ ព្រះខីណាស្រពបរិនិព្វាន ក្នុង កាលដែលមានវស្សា ១០ ប៉ុណ្ណោះក៏មិនមែន សូម្បីបរិនិព្វានក្នុងកាល ដែលមានវស្សា ៧ ក៏ឈ្មោះថា មិនមានវស្សា ៧ មិនមានវស្សា ១០ មិនមានកាលសូម្បីត្រឹមតែមួយស្របក់ ។ ព្រះមានព្រះភាគ កាលទ្រង់លើក យកវោហារ ដែលកើតក្នុងលទ្ធិតិរ្ថិយ មកសម្រាប់ព្រះខីណាស្រព ក្នុងសាសនា ហើយ ទ្រង់សម្តែងការមិនមាននៃព្រះខីណាស្រពបែបនោះ ក្នុងលទ្ធិតិរ្ថិយ នោះ និងការមាននៅនៃព្រះខីណាស្រពបែបនោះ ក្នុងសាសនានេះ ត្រាស់ ហេតុនៃការមាននៅនៃព្រះខីណាស្រពបែបនោះថា **សត្ត និទ្ទសវត្ថូនិ** ។ ដូច ព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ សត្តកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ និទ្ទសវត្ថុទាំងឡាយនេះ មាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការសមាទាននូវសិក្ខា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការ សមាទាននូវសិក្ខា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុង

ការពិចារណានូវធម៌ តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លាក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការកម្ចាត់បង់ឥច្ឆា គឺតណ្ហា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការពួនសម្ងំ តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការប្រារព្ធព្យាយាម តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការចាក់ធ្លុះដោយទិដ្ឋិ តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងនិទ្ទសវត្ថុ ៧ យ៉ាង ។

ព្រះថេរៈ កាលលើកឡើងនូវទេសនាយ៉ាងនោះហើយ ក៏ពោលថា **សត្ត និទ្ទសវត្ថូនិ** ដូច្នេះ ។

ក្នុងពាក្យថា **អដ្ឋ អភិភាយតនានិ** នេះ មានវិគ្គហៈថា អាយតនៈទាំង

ឡាយនៃឈានទាំងនោះដែលត្រូវគ្របសង្កត់មាន ព្រោះហេតុនោះ ទើបឈ្មោះថា **អភិភាយតន** បានដល់ ឈាន ។ បទថា **អាយតនានិ** បានដល់ ជាអារម្មណកសិណ ពោល គឺអាយតនៈ ដោយអត្ថថា ជាទីតាំងដ៏ប្រសើរ អធិប្បាយថា បុគ្គលមានញាណដ៏ប្រសើរ អ្នកមានញាណក្លៀវក្លាគិតថា អាត្មាអញគប្បីចូលក្នុងអារម្មណ៍នេះ ព្រោះហេតុអ្វី ភារៈក្នុងការធ្វើចិត្តឲ្យជាឯកគ្គតាមិនមានដល់អញ ហើយគ្របសង្កត់អារម្មណ៍ទាំងនោះ ចូលសមាបត្តិ ញ៉ាំងអប្បនាឲ្យកើតឡើងក្នុងអារម្មណ៍នេះ ព្រមជាមួយការកើតឡើងនៃនិមិត្ត ។ ឈានដែលឲ្យកើតឡើងដោយប្រការយ៉ាងនេះ លោកហៅថា **អភិភាយតនៈ**។

អភិភាយតនៈ ( ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអារម្មណ៍ផង ) មាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលពួកមួយ មានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ មានប្រមាណតិច ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ រកប្រមាណមិនបាន ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គល

ពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ មានប្រមាណតិច ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ រកប្រមាណមិនបាន ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ដ៏ច្នុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ ប្រៀបដូចផ្កាត្រកៀតខៀវ មានសម្បុរខៀវ ដ៏ច្នុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ ពុំនោះសោត ប្រៀបដូចសំពត់ខៀវកើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌ខៀវ ដ៏ច្នុះចេញនូវពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅដែលជារូបខៀវ មានសម្បុរខៀវ ដ៏ច្នុះចេញនូវសម្បុរខៀវ មានពន្លឺខៀវគ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មា

អញដឹង អាត្មាអញឃើញដូច្នេះ យ៉ាងនេះឯង នេះជាអភិភា-
យតនៈទី ៥ ។ បុគ្គលពួកមួយ មានសេចក្ដីសម្គាល់នូវអរូប
ខាងក្នុង ឃើញនូវពួករូបខាងក្រៅដែលជារូបលឿង មានពណ៌
លឿង ដ៏ធ្លុះចេញនូវពណ៌លឿង មានពន្លឺលឿង ប្រៀបដូច
ផ្កាកណិការលឿង មានពណ៌លឿង ដ៏ធ្លុះចេញនូវពណ៌លឿង
មានពន្លឺលឿង ពុំនោះសោត ប្រៀបដូចសំពត់លឿង កើតក្នុង
ក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌លឿង ដ៏
ធ្លុះចេញនូវពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គល
ពួកមួយ មានសេចក្ដីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួក
រូបខាងក្រៅ ដែលជារូបលឿង មានសម្បុរលឿង ដ៏ធ្លុះចេញ
នូវសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ
ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មា
អញឃើញ ដូច្នេះ យ៉ាងនេះឯង នេះជាអភិភាយតនៈទី ៦ ។
បុគ្គលពួកមួយ មានសេចក្ដីសម្គាល់នូវអរូបខាងក្នុង ឃើញ
នូវពួករូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ដ៏
ធ្លុះចេញនូវសម្បុរក្រហម មានពន្លឺក្រហម ប្រៀបដូចផ្កាចប្បា
ក្រហម មានពណ៌ក្រហម ដ៏ធ្លុះចេញនូវពណ៌ក្រហម មានពន្លឺ
ក្រហម ពុំនោះសោត ប្រៀបដូចសំពត់ក្រហម កើតក្នុងក្រុង
ពារាណសីនោះ រលីងទាំងពីរខាង មានពណ៌ក្រហម ដ៏ធ្លុះ

ចេញនូវពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គល ពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួក រូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ដ៏ផ្ទុះចេញ នូវសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មា អញឃើញ ដូច្នេះ យ៉ាងនេះឯង នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញ នូវរូបខាងក្រៅ ដែលជារូប-ស មានសម្បុរ-ស ដ៏ផ្ទុះចេញនូវ សម្បុរ-ស មានពន្លឺសប្រៀបដូចផ្កាយព្រឹក-ស មានពណ៌ស ដ៏ផ្ទុះចេញនូវពណ៌ស មានពន្លឺស ពុំនោះសោត ប្រៀបដូច សំពត់ កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មាន ពណ៌ស ដ៏ផ្ទុះចេញនូវពណ៌ស មានពន្លឺស យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញ នូវពួករូបខាងក្រៅ ដែលជារូប-ស មានសម្បុរ-ស ដ៏ផ្ទុះចេញ នូវសម្បុរ-ស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញ ឃើញ ដូច្នេះ យ៉ាងនេះឯង នេះជាអភិភាយតនៈទី ៨[១] ។

បទថា **ឆវ អនុបុព្វវិហារា** មានវិនិច្ឆ័យថា ខាងក្រោយនៃធម៌ដែលមាន

---

១- បិដកខ្មែរ លេខ ១៩ ឃ្នាប ២២០ ។

ក្នុងកាលមុន ឈ្មោះថា **អនុបុព្វ** វិហារ គឺធម៌ជាគ្រឿងនៅ ឈ្មោះថា **អនុបុព្វវិហារ** ព្រោះជាធម៌ដែលយោគីបុគ្គលគប្បីនៅ គឺគប្បីចូលទៅតាមលំដាប់ អធិប្បាយថា ធម៌ជាគ្រឿងនៅដែលព្រះយោគីបុគ្គលគប្បីចូលនៅតាមលំដាប់ ។

ព្រះមានព្រះភាគ ត្រាស់អនុបុព្វវិហារធម៌ ៩ ថា

អនុបុព្វវិហារធម៌ ៩ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិ និងសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់នោះ ។

ភិក្ខុព្រោះស្ងប់ស្ងាត់ចាកវិតក្ក វិចារ ក៏បានដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួនប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធាមានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ។

ភិក្ខុព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ។

ភិក្ខុព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍

មិនមែនជាទុក្ខមិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។

ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់បដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏បានដល់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ។

ព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ។

ព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ។

ព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។

ព្រោះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់សញ្ញាវេទយិតនិរោធ ។

បទថា **ទស និជ្ជរវត្ថូនិ** មានវិគ្គហៈថា មិច្ឆាទិដ្ឋិជាដើម រមែងវិនាស រមែងបែកធ្លាយទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **និជ្ជរ** ។

បទថា **វត្ថូនិ** បានដល់ ហេតុ ។ វត្ថុ គឺហេតុនោះផង វិនាសផង ព្រោះហេតុនោះ ទើបឈ្មោះថា **និជ្ជរវត្ថុ** ។ និជ្ជរវត្ថុនេះ ជាឈ្មោះរបស់កុសលធម៌មានសម្មាទិដ្ឋិជាដើម ។

ព្រះមានព្រះភាគ ត្រាស់និជ្ជរវត្ថុ ១០ ហើយថា

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនាំឲ្យសាបរលាបទៅនេះមាន ១០ យ៉ាង ។ ១០ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយសម្មាទិដ្ឋិ រមែងមានមិច្ឆាទិដ្ឋិសាបរលាបទៅ អកុសលទាំងឡាយដ៏លាមកច្រើនប្រការណាមានមិច្ឆាទិដ្ឋិជាបច្ច័យកើតព្រម អកុសលធម៌ទាំងឡាយនោះរបស់បុគ្គលជាសម្មាទិដ្ឋិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាទិដ្ឋិជាបច្ច័យ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសង្កប្ប រមែងមានមិច្ឆាសង្កប្បសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសង្កប្បជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មា-សង្កប្បនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាសង្កប្បជាបច្ច័យ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាចា រមែងមានមិច្ឆាវាចាសាបរលាបទៅ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាវាចាជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាវាចានោះរមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវាចាជាបច្ច័យក៏ដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាកម្មន្តៈ រមែងមានមិច្ឆាកម្មន្តៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆា-កម្មន្តៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលដែលជាសម្មា-

កម្មន្តៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មា-កម្មន្តៈជាបច្ច័យ ក៏រមែងដល់នូវការបរិបូណ៌ដោយការនៃ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាអាជីវៈ រមែងមានមិច្ឆាអាជីវៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆា-អាជីវៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាអាជីវៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាអាជីវៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាវាយាមៈ រមែងមានមិច្ឆាវាយាមៈសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆា-វាយាមៈជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាអាជីវៈនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការដែលមានសម្មាវាយាមៈជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសតិ រមែងមានមិច្ឆាសតិសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាសតិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាសតិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាសតិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយការនៃ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាសមាធិ រមែងមានមិច្ឆាសមាធិសាបរលាបទៅ អកុសលធម៌ទាំងឡាយ ដ៏លាមកច្រើនប្រការណា ដែលមាន

មិច្ឆាសមាធិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មា-សមាធិនោះ រមែងសាបរលាបទៅ ទើបកុសលធម៌ច្រើនប្រការ ដែលមានសម្មាសមាធិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាញាណ រមែងមានមិច្ឆាញាណសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆាញាណជាបច្ច័យកើតព្រម អកុសលធម៌ទាំងអស់នោះ របស់បុគ្គលជាសម្មាញាណនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាញាណជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសម្មាវិមុត្តិ រមែងមានមិច្ឆាវិមុត្តិសាបរលាបទៅ អកុសលធម៌ទាំងឡាយដ៏លាមកច្រើនប្រការណា ដែលមានមិច្ឆា-វិមុត្តិជាបច្ច័យកើតព្រម អកុសលធម៌ទាំងនោះ របស់បុគ្គលជាសម្មាវិមុត្តិនោះ រមែងសាបរលាបទៅ កុសលធម៌ច្រើនប្រការ ដែលមានសម្មាវិមុត្តិជាបច្ច័យ រមែងដល់នូវការបរិបូណ៌ដោយភាវនា ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនាំឲ្យសាបរលាបទៅ មាន ១០ យ៉ាងនេះឯង ។

[ ៣ ] បទថា **សព្វំ ភិក្ខវេ អភិញ្ញេយ្យំ** ជាដើម ជាបទដែលព្រះមានព្រះភាគត្រាស់ គប្បីជ្រាបថា ព្រះធម្មសេនាបតីសារីបុត្តនាំមកសម្តែងហើយក្នុងទីនេះ ។ ឥ អក្ខរៈ ក្នុងបទថា **កិញ្ច** ជានិបាត ត្រឹមតែធ្វើបទឲ្យពេញ ។ វិសជ្ជនា ៣០ មានភ្នែកជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្តែងចែកម្យ៉ាង ៥ៗ ក្នុងទ្វារមួយៗ ក្នុងទ្វារទាំង ៦ តាមលំដាប់នៃការប្រព្រឹត្តទៅនៃទ្វារ និង

អារម្មណ៍ ។

ក្នុងបទថា **ចក្ខុំ** ចក្ខុមាន ២ យ៉ាង គឺមំសចក្ខុ ១ បញ្ញាចក្ខុ ១ ។ ក្នុងចក្ខុទាំង ២ នោះ បញ្ញាចក្ខុមាន ៥ យ៉ាង គឺពុទ្ធចក្ខុ សមន្តចក្ខុ ១ ញាណចក្ខុ ១ ទិព្វចក្ខុ ១ ធម្មចក្ខុ ១ ។

ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតកំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញ ឈ្មោះថា ពុទ្ធចក្ខុ ។

ពាក្យនេះថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ឈ្មោះថា សមន្តចក្ខុ ។

ពាក្យនេះថា ចក្ខុកើតឡើង ញាណកើតឡើង ឈ្មោះថា ញាណចក្ខុ ។

ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញ ( ពួកបញ្ចវគ្គិយ-ភិក្ខុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ) ដោយទិព្វចក្ខុដ៏បរិសុទ្ធ ឈ្មោះថា ទិព្វចក្ខុ ។

មគ្គញ្ញាណខាងក្រោម ៣ នេះ មកក្នុងពាក្យថា ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងហើយ ឈ្មោះថា ធម្មចក្ខុ ។

ឯមំសចក្ខុមាន ២ យ៉ាង គឺសសម្ភារចក្ខុ ១ បសាទចក្ខុ ១ ។

ដុំសាច់ណា ដែលតាំងនៅក្នុងប្រឡង់ភ្នែកព្រមដោយស្បែក ស្រោបគ្រាប់ភ្នែកផ្នែកខាងក្រៅទាំង ២ ខាង ខាងក្រោម កំណត់ដោយឆ្អឹងប្រឡង់ភ្នែក ខាងលើ កំណត់ដោយឆ្អឹងចញ្ចើម ចងដោយសរសៃដែលចេញអំពីកណ្តាលប្រឡង់ភ្នែក តោងជាប់ទៅដល់ខួរក្បាល វិចិត្រដោយមណ្ឌលប្រស្រីខ្មៅ ព័ទ្ធជុំវិញ

ដោយសាច់ពណ៌ស ដុំសាច់នេះ ឈ្មោះថា សសម្ភារចក្ខុ ។

ចំណែកភាពថ្លាណា អាស្រ័យក្នុងសសម្ភារចក្ខុនេះ ទាក់ទងក្នុងសសម្ភារ-ចក្ខុនេះ អាស្រ័យមហាភូតរូប ៤ មានភាពថ្លា នេះឈ្មោះថា បសាទចក្ខុ ។ ក្នុងទីនេះ លោកសំដៅយកបសាទចក្ខុនេះ ។ បសាទចក្ខុនេះ ដោយប្រមាណប៉ុនក្បាលចៃ អាស្រ័យធាតុទាំង ៤ ផ្សើមដោយភ្នាសទាំង ៧ ជាន់ ដូចប្រេងដែលចាក់លើស្រទាប់សំឡី ៧ ជាន់ ផ្សើមសំឡីគ្រប់ស្រទាប់ដូច្នោះ ឲ្យសម្រេចទៅជាវត្ថុ និងទ្វារតាមសមគួរដល់ចិត្តក្នុងវីថិ មានចក្ខុវិញ្ញាណចិត្តជាដើម តាំងនៅក្នុងតំណែងជាទីកើតឡើងនៃសរីរសណ្ឋាន ដែលនៅត្រង់មុខក្នុងកណ្ដាលប្រស្រីខ្មៅ ដែលព័ទ្ធជុំវិញដោយមណ្ឌលពណ៌សនៃសសម្ភារចក្ខុនោះ ។

ធម្មជាតណា រមែងឃើញ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ចក្ខុ អធិប្បាយថា រមែងត្រេកអរក្នុងរូប និងធ្វើឲ្យរូបប្រាកដជាក់ច្បាស់បាន ។

ធម្មជាតណា រមែងបែកធ្លាយទៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា រូប អធិប្បាយថា កាលដល់នូវការប្រែប្រួលទៅនៃវណ្ណៈ រមែងប្រកាសសេចក្ដីដល់ហទយៈ ។

វិញ្ញាណប្រព្រឹត្តទៅតាមភ្នែក ឬវិញ្ញាណរបស់ចក្ខុ ឈ្មោះថា ចក្ខុវិញ្ញាណ ។

ឈ្មោះថា ផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។ លោកពោលថា សម្ផស្ស ព្រោះបន្ថែមបទឧបសគ្គ ។ សម្ផស្សដែលប្រព្រឹត្តទៅតាមផ្លូវភ្នែក ឈ្មោះថា ចក្ខុសម្ផស្ស ។ បទថា **ចក្ខុសម្ផស្សប្បច្ចយា** បានដល់ ព្រោះផស្សចេតសិកដែលប្រកបជាមួយចក្ខុវិញ្ញាណជាបច្ច័យ ។

បទថា **វេទយិតំ** បានដល់ ការទទួលអារម្មណ៍ អធិប្បាយថា ការសោយអារម្មណ៍ ។

ការទទួលអារម្មណ៍នោះឯង រមែងធ្វើឲ្យជាសុខ ព្រោះហេតុនោះ ទើបឈ្មោះថា **សុខ** អធិប្បាយថា សុខកើតដល់បុគ្គលណា ក៏រមែងធ្វើបុគ្គលនោះឲ្យដល់នូវសេចក្តីសុខ ។ ម្យ៉ាងទៀត ធម្មជាតណា រមែងទំពាស៊ី និងគាស់រម្លើងដោយល្អនូវអាពាធផ្លូវកាយ និងផ្លូវចិត្ត ព្រោះហេតុនោះ ធម្មជាតនោះឈ្មោះថា **សុខ** ។

ធម្មជាតណា រមែងធ្វើឲ្យជាទុក្ខ ព្រោះហេតុនោះ ទើបធម្មជាតនោះឈ្មោះថា **ទុក្ខ** អធិប្បាយថា ទុក្ខកើតដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យដល់នូវសេចក្តីទុក្ខ ។

ធម្មជាតណា ទុក្ខក៏មិនមែន សុខក៏មិនមែន ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **អទុក្ខមសុខ** ។ ម អក្ខរៈ លោកពោលដោយអំណាចនៃការភ្ជាប់បទ ។

ចក្ខុសម្ផស្សនោះជាបច្ច័យ ៨ ដល់វេទនាដែលសម្បយុត្តនឹងខ្លួន គឺសហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ។ ជាបច្ច័យ ៥ ដល់វេទនាដែលសម្បយុត្តដោយសម្បដិច្ឆន្នចិត្ត គឺអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ។ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តដោយសន្តីរណចិត្តជាដើម ដោយអំណាចឧបនិស្ស-យប្បច្ច័យ ត្រឹមតែបច្ច័យមួយ ។

ធម្មជាតណា រមែងបានឮ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សោត** ។ សោតៈនោះ ញុំាងកាពជាវត្ថុ និងទ្វារ តាមសមគួរដល់ចិត្តក្នុងវីថិ មានសោត-វិញ្ញាណចិត្តជាដើម ឲ្យសម្រេចតាំងនៅក្នុងតំណែងដែលមានសណ្ឋានដូចវង់ចិញ្ចៀន មានរោមពណ៌ក្រហមខ្ចី ដុះនៅខាងក្នុងរន្ធនៃសសម្ភារសោតៈ ។

ធម្មជាតណា រមែងបន្លឺចេញ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សទ្ទ** អធិប្បាយថា រមែងបន្លឺសំឡេង ។

ធម្មជាតណា រមែងហិត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ឃាន** ឃានៈនោះ ញុំាងកាពជាវត្ថុ និងទ្វារ តាមសមគួរដល់ចិត្តក្នុងវីថិ មានឃាន-វិញ្ញាណជាដើមឲ្យសម្រេច តាំងនៅក្នុងតំណែងដែលមានសណ្ឋានដូចក្រចកជើងពពែ ក្នុងខាងក្នុងនៃរន្ធសសម្ភារឃានៈ ។

ធម្មជាតណា រមែងផ្សាយទៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **គន្ធ** អធិប្បាយថា រមែងប្រកាសនូវលំនៅរបស់ខ្លួន ។

ធម្មជាតណា រមែងនាំមកនូវជីវិត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ជិវ្ហា** ឬឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា លិទ្ធរស ។ ជិវ្ហានោះ ញុំាងកាពជាវត្ថុ និងទ្វារ តាមសមគួរដល់ចិត្តក្នុងវីថិ មានជិវ្ហាវិញ្ញាណចិត្តជាដើមឲ្យសម្រេច តាំងនៅក្នុងតំណែង មានសណ្ឋានដូចចុងត្របកផ្កាឈូករីក ក្នុងកណ្តាលផ្ទៃអណ្តាត ខាងលើ វៀរចុងបំផុត គល់ និងចំហៀងៗ នៃសសម្ភារជិវ្ហា ។ សត្វទាំងឡាយ រមែងត្រេកអរនូវធម្មជាតនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **រស** អធិប្បាយថា រមែងពេញចិត្ត ។

ធម្មជាតណា ជាប្រភពកើតនៃសាសវធម៌ទាំងឡាយ ដែលបណ្ឌិតខ្ពើម ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **កាយ** ពាក្យថា ប្រភពកើត បានដល់ ប្រទេសជាទីកើតឡើង ។ ការប្រព្រឹត្តទៅនៃឧបាទិន្នរូបក្នុងកាយនេះ មាននៅដរាបណា ដរាបនោះ កាយបសាទនោះ ញុំាងភាពជាវត្ថុ និងទ្វារ តាមសមគួរដល់ចិត្តក្នុងវីថិ មានកាយវិញ្ញាណចិត្តជាដើមឲ្យសម្រេច តាំងនៅត្រង់កាយនោះដោយច្រើន ។

ធម្មជាតណា រមែងពាល់ត្រូវ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ផោដ្ឋព្វ** ។

ធម្មជាតណា រមែងដឹង ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **មនោ** អធិប្បាយថា រមែងដឹងអារម្មណ៍ផ្សេងៗ ។

ធម្មជាតណា រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ធម្ម** ។

បទថា **មនោ** បានដល់ ភវង្គចិត្តដែលប្រព្រឹត្តទៅជាមួយការទទួលអារម្មណ៍ ។ បទថា **ធម្មា** បានដល់ ធម៌ គឺធម្មារម្មណ៍ មាន ១២ ប្រភេទ[១]។

បទថា **មនោវិញ្ញាណំ** បានដល់ មនោវិញ្ញាណដែលធ្វើជវនកិច្ច ។ បទថា **មនោសម្ផស្សោ** បានដល់ ផស្សចេតសិកដែលសម្បយុត្តជាមួយមនោ-

---

១- កាមអារម្មណ៍ ១ មហគ្គតអារម្មណ៍ ១ និព្វានអារម្មណ៍ ១ នាមអារម្មណ៍ ១ រូបអារម្មណ៍ ១ បច្ចុប្បន្នអារម្មណ៍ ១ អតីតអារម្មណ៍ ១ កាលវិមុត្តិអារម្មណ៍ ១ បញ្ញត្តិអារម្មណ៍ ១ បរមត្ថអារម្មណ៍ ១ អជ្ឈត្តអារម្មណ៍ ១ ពហិទ្ធអារម្មណ៍ ១ រួមជា ១២ ។

វិញ្ញាណនោះ ។ មនោសម្ផស្សនោះ ជាបច្ច័យដល់វេទនាដែលសម្បយុត្ត ដោយអំណាចបច្ច័យ ៧ ដ៏សេស វៀរវិបាកប្បច្ច័យជាបច្ច័យដល់វេទនាក្នុងលំដាប់បន្ទាប់ទៅ ( វេទនាក្នុងជវនៈជួនទី ២ ) ដោយអំណាចបច្ច័យទាំងនោះដូចគ្នា ជាបច្ច័យដល់វេទនាដ៏សេស ( វេទនាក្នុងជវនៈជួនទី ៣ ដល់ទី ៧ ) ដោយអំណាចឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

[ ៤ ] វិសជ្ជនា ៥ មានរូបជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្តែងដោយអំណាចនៃខន្ធ ។

ធម្មជាតណា រមែងបែកធ្លាយទៅ រមែងត្រូវបៀតបៀនដោយវិរោធិប្បច្ច័យមានត្រជាក់ជាដើម ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **រូប** ។

ធម្មជាតណា រមែងសោយអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វេទនា** ។

ធម្មជាតណា រមែងចាំអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សញ្ញា** ។

ធម្មជាតណា រមែងតាក់តែង ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សង្ខារ** ។

ធម្មជាតណា រមែងដឹងច្បាស់នូវអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វិញ្ញាណ** ។

វិសជ្ជនា ៦០ ដោយអំណាចនៃពួកប្រាំមួយ ១០ ពួក មានចក្ខុជាដើម មានធម្មវិចារជាទីបំផុត ព្រះធម្មសេនាបតីសារីបុត្តសម្តែងដោយភាពជាបិយ-

រូប សាតរូប ។ វេទនា មានវេទនាដែលកើតពីចក្ខុសម្ផស្សជាដើម ជាធម៌ដែលសម្បយុត្តដោយចក្ខុវិញ្ញាណជាដើមនោះឯង ។ ការសម្គាល់ក្នុងរូប ឈ្មោះថា **រូបសញ្ញា** ។ ធម្មជាតណា រមែងតាំងចិត្តក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សញ្ចេតនា** អធិប្បាយថា រមែងបង្អោនទៅកាន់អារម្មណ៍ ។ ធម្មជាតណា រមែងអន្ទះអន្ទែង ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **តណ្ហា** អធិប្បាយថា រមែងស្រេកឃ្លាន ។ ធម្មជាតណា រមែងត្រិះរិះនូវអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វិតក្ក** ម្យ៉ាងទៀត ការត្រិះរិះ ឈ្មោះថា វិតក្ក អធិប្បាយថា ការលើកចិត្តឡើងកាន់អារម្មណ៍ ។ ធម្មជាតណា រមែងផ្គងចិត្តទុកក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វិចារ** ម្យ៉ាងទៀត ការពិចារណា ឈ្មោះថា **វិចារ** អធិប្បាយថា ការពិចារ ណារឿយៗ ។

[ ៥ ] វិសជ្ជនា ៦ មានបឋវីធាតុជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្តែងដោយអំណាចការកំណត់នាមរូបដោយសង្ខេប ។ ឈ្មោះថា **បឋវី** ព្រោះជាធម្មជាតផ្សាយទៅ ។ ធម្មជាតណារមែងជ្រួតជ្រាប ឬរមែងហូរទៅ ឬប្រមូលផ្តុំ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អាបោ**។ ធម្មជាតណារមែងធ្វើឲ្យក្តៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **តេជោ**។ ធម្មជាតណា រមែងបក់ទៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វាយោ** ។ ធម្មជាតណាដែលបុគ្គលណាមួយ រមែងគូសមិនបាន សរសេរមិនបាន គឺដែលបុគ្គលណាមួយ មិនអាចនឹងកួរ កាត់ ឬបំផ្លាញបាន ព្រោះហេតុនោះ ធម្មជាតនោះ

ឈ្មោះថា **អាកាស** ។ ឈ្មោះថា **ធាតុ** ដោយអត្ថថា មិនមែនសត្វ ។

វិសជ្ជនា ១០ មានបឋវីកសិណជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្ដែងដោយអំណាចនៃកសិណភាវនា ។ វង់កសិណដោយអំណាចការផ្សាយទៅក្នុងអារម្មណ៍ទាំងមូលក្ដី និមិត្តដែលប្រាកដព្រោះកសិណនោះក្ដី ឈានមានកសិណនោះជាអារម្មណ៍ក្ដី លោកហៅថា កសិណ ។ តែក្នុងទីនេះ លោកបំណងយកឈាន គឺឈាន ៤ ខាងដើម មានមហាភូតកសិណជាអារម្មណ៍ បន្ទាប់អំពីនោះឈាន ៤ ខាងចុង មានវណ្ណកសិណជាអារម្មណ៍ ។ **អាកាសកសិណ** បានដល់ អាកាសដែលកំណត់ និងឈាន ដែលមានអាកាសកំណត់នោះជាអារម្មណ៍ អាកាសដែលបើកកសិណ និងអាកាសានញ្ចាយតនជ្ឈាន ដែលមានអាកាសដែលបើកកសិណជាអារម្មណ៍ **វិញ្ញាណកសិណ** បានដល់ ចិត្តដែលដឹងអាកាសានញ្ចាយតនជ្ឈាន និងវិញ្ញាណញ្ចាយតនជ្ឈាន ដែលមានអាកាសានញ្ចាយតនជ្ឈាននោះជាអារម្មណ៍ ។

[ ៦ ] វិសជ្ជនា ៣២ មានសក់ជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្ដែងដោយអំណាចកម្មដ្ឋាន មានអាការ ៣២ ជាអារម្មណ៍ ។ កាលអាការ ៣២ មានសក់ជាដើមទាំងនោះ ប្រាកដដោយភាពជារបស់បដិកូល ក៏ជាអសុភកម្មដ្ឋាន ដោយអំណាចកាយគតាសតិ កាលប្រាកដដោយភាពជាពណ៌ ក៏ជាវណ្ណកម្មដ្ឋាន កាលប្រាកដដោយភាពជាធាតុ ក៏ជាចតុធាតុវវត្ថានកម្មដ្ឋាន ម្យ៉ាងទៀត អាការ ៣២ មានសក់ជាដើម កាលប្រាកដដោយជារបស់បដិកូល ឬដោយពណ៌ ក៏ជាឈានដែលមានវត្ថុដែលប្រាកដនោះជាអារម្មណ៍ ។ កាល

ប្រាកដដោយភាពជាធាតុ ក៏គប្បីជ្រាបកោដ្ឋាសទាំងនោះ និងធាតុការទៅដែលមានកោដ្ឋាសនោះជាអារម្មណ៍ ។

**កេសា** សក់ទាំងឡាយ កើតត្រង់ស្បែកស្រោបលលាដ៍ក្បាល ជម្រៅឫសត្រឹមមួយចុងគ្រាប់ស្រូវ ក្នុងផ្នែកទាំង ២ នៃក្បាល កំណត់ដោយគុម្ពត្រចៀកទាំង ២ ខាង មុខកំណត់ដោយថ្ងាសជាទីបំផុត និងខាងក្រោយ កំណត់ដោយកញ្ចឹង-ក រាប់បានច្រើនសែនសរសៃ ។

**លោមា** រោមទាំងឡាយ តាំងនៅជម្រៅប្រមាណមួយលិក្ខា[១]ក្នុងស្បែកស្រោបសរីរៈដោយច្រើន លើកលែងកន្លែងជាទីតាំងនៃអវយវៈ មានសក់ជាដើម និងបាតដៃ បាតជើង ទាំង ២ ចេញ លោកកំណត់រន្ធរោមទុកដល់ ៩ ម៉ឺន ៩ ពាន់រណ្ដៅ ។

**នខា** ក្រចកទាំងឡាយ តាំងនៅលើខ្នងនៃចុងម្រាមទាំងឡាយ រាប់បាន ២០ ។

**ទន្តា** ធ្មេញទាំងឡាយ តាំងនៅត្រង់ឆ្អឹងចង្កាទាំង ២ រាប់បាន ៣២ ធ្មេញ ។

**តចោ** ស្បែកស្រោបសរីរៈពេញរាងកាយ តាំងនៅលើវាវស្រទាប់ក្រៅខាងក្រោមសម្បុរថ្ងៃ ។

**មំសំ** សាច់រាប់បាន ៩០០ ដុំ តាំងនៅព័ទ្ធជុំវិញឆ្អឹងជាង ៣០០ កំណាត់ ។

**ន្ហារូ** សរសៃទាំងឡាយរាប់បាន ៩០០ ចងព័ទ្ធឆ្អឹងទាំងឡាយ តាំងនៅទូទៅក្នុងសរីរៈ ។

---

១- គ្រាប់ស្រូវ បែងជា ៤៩ ចំណែក មួយចំណែក ហៅថា មួយលិក្ខា ។

**អដ្ឋី** ធ្អឹងទាំងឡាយរាប់បាន ៣០០ កំណាត់ តាំងនៅទាំងខាងក្រោម ទាំងខាងលើ ពេញសរីរៈ ។

**អដ្ឋិមិញ្ជំ** ខួរក្នុងធ្អឹង តាំងនៅក្នុងធ្អឹងទាំងឡាយនោះៗ ។

**វក្កំ** ទាច បានដល់ ដុំសាច់ ២ ដុំ នៅព័ទ្ធសាច់បេះដូងមានទងជាមួយគ្នា បែកចេញពីបំពង់កទៅបន្តិច ហើយចែកចេញជា ២ រឹតជាប់ដោយសរសៃគ្រោតគ្រាត ។

**ហទយំ** បេះដូង បានដល់ សាច់ហទយៈ តាំងនៅចំកណ្ដាលដោះទាំងពីរ ក្នុងខាងក្នុងសរីរៈ ពេញទៅដោយឈាមប្រមាណកន្លះទូកដៃ ជាទីអាស្រ័យនៃចិត្ត មានប្រហោងក្នុងប្រមាណប៉ុនគ្រាប់បុសនាគ ។

**យកនំ** ថ្លើម បានដល់ បន្ទះសាច់មួយគូអាស្រ័យតាំងនៅខាងស្ដាំ ខាងក្នុងរាងកាយរវាងដោះទាំង ២ ខាង ។

**កិលោមកំ** វាវ បានដល់ សាច់ស្រោប ២ យ៉ាង គឺសាច់ស្រោបដែលបិតស្រោបបេះដូង និងទាច តាំងនៅ ១ សាច់ស្រោបដែលមិនបិតស្រោបសាច់ខាងក្រោមស្បែក តាំងនៅពេញរាងកាយ ១ ។

**បិហកំ** ក្រពះ បានដល់ សាច់មានសណ្ឋានដូចអណ្ដាតនៅក្នុងឧទរ តាំងនៅខាងលើផ្ទៃឧទរខាងឆ្វេងបេះដូង ។

**បប្ផាសំ** សួត បានដល់ ដុំសាច់ដែលហៅថា សួត ដោយប្រភេទរាប់បាន ៣២ ដុំ សំយុងបិទសាច់ខាងលើបេះដូង និងថ្លើម តាំងនៅចន្លោះកន្ទ្រាមដោះទាំងពីរ ក្នុងខាងក្នុងសរីរៈ ។

**អន្តំ** *ពោះវៀនធំ បានដល់ ចង្វាយពោះវៀនជាផ្នត់បត់នៅក្នុងទីទាំងឡាយ គឺខាងលើក្រោមបំពង់កចុះមក ខាងក្រោមដល់ទ្វារធំ តាំងនៅខាងក្នុងសរីរៈ មានបំពង់កជាដើម និងមានទ្វារធំជាទីបំផុត ព័ន្ធព័ទ្ធគ្នានិងគ្នា របស់បុរសប្រវែង ៣២ ហត្ថ របស់ស្ត្រីប្រវែង ២៨ ហត្ថ បត់ចុះបត់ឡើងជា ២១ ផ្នត់ដូចគ្នា ។*

**អន្តគុណំ** *ពោះវៀនតូច បានដល់ ពោះវៀនតូចដែលរុំព័ទ្ធពោះវៀនធំឲ្យនៅរួមគ្នា តាំងនៅក្នុងចន្លោះផ្នត់ពោះវៀនធំទាំង ២១ ផ្នត់ ។*

**ឧទរិយំ** *អាហារថ្មី បានដល់ អាហារថ្មីផ្សេងៗ ដែលផឹក ទំពា បរិភោគ ភ្លក្ស លេបចូលទៅ ដែលត្រូវបុកលម្អិតដោយអង្រែ គឺធ្មេញ បង្វិលដោយដៃ គឺអណ្តាត ផ្សើមដោយទឹកមាត់ ក្នុងខណៈនោះ ក៏ប្រាសចាកសម្បត្តិនៃពណ៌ ក្លិន និងរសជាដើម ដូចគ្នានឹងបាយ**ម៉ាន**ជ្រលក់អំបោះ របស់ជាងតម្បាញ និងកំអួតឆ្កែធ្លាក់ទៅ វាយត្រឡប់ដោយខ្យល់ ប្រឡាក់ប្រឡូសដោយទឹកប្រមាត់ និងស្លេស្ម ចំហុយដោយកម្តាំងកម្តៅនៃភ្លើងក្នុងផ្ទៃ ពពាក់ពពូនដោយជន្លេនត្រកូលតូចធំ បែកពពុះខាងលើ រហូតដល់នូវភាពជាលាមកមានក្លិនស្អុយ គួរខ្ពើមពន់ពេក នៅត្រង់ផ្ទៃពោះវៀនធំ ខាងលើផ្ចិត ពោល គឺទីអាស្រ័យរបស់អាហារថ្មី ។*

**ករីសំ** *អាហារចាស់ បានដល់ ឧច្ចារៈ តាំងនៅក្នុងទីបំផុតនៃពោះវៀនធំ* *កម្ពស់**ប្រមាណ ៨ ធ្នាប់ ក្នុងរវាងផ្ចិត និងទីបំផុតនៃឆ្អឹងខ្នងក្នុងខាងក្រោម ពោល គឺទីនៅរបស់អាហារដែលរលាយហើយ ។*

**បិត្តំ** *ទឹកប្រមាត់ បានដល់ ប្រមាត់ ២* *យ៉ាង* *ពោល គឺប្រមាត់មានស្រោម*

*ដែលមានសណ្ឋានដូចស្រកីនទោងធំ អាស្រ័យនៅត្រង់វាងថ្លើម បេះដូង និង សួត ១ និងប្រមាត់មិនមានស្រោមជ្រួតជ្រាបពេញសរីរៈ វៀរលែងតែសក់ រោម ក្រចក ធ្មេញ ទីដែលមិនមានសាច់ ស្បែកក្រិន និងស្បែកស្ងួត ១ ។*

**សេម្ហំ** *ស្លេស្ម បានដល់ ស្លេស្ម ប្រមាណពេញមួយកម្ប្ង់ តាំងនៅ ត្រង់ផ្ទៃពោះ ។*

**បុព្វោ** *ខ្ទុះ បានដល់ ការប្រែប្រួលទៅនៃលោហិតក្នុងរាងកាយដែលត្រូវ ដង្គត់ឈើ បន្លា និងអណ្តាតភ្លើងជាដើម ពាល់ត្រូវហើយ ឬត្រង់អវយវៈ ដែលមានបូស និងពងបែកជាដើម កើតឡើងហើយ ដោយការកម្រើកនៃ ធាតុខាងក្នុង ។*

**លោហិតំ** *លោហិត បានដល់ ឈាម ២ យ៉ាង គឺឈាមដែលសន្សំ មានប្រមាណពេញមួយកម្ប្ង់ ពេញចំណែកខាងក្រោមរបស់ថ្លើម ហូរចេញ បន្តិចៗ ខាងលើបេះដូង ក្រពះ និងសួត ផ្សើមត្រង់ក្រពះ បេះដូង ថ្លើម និងសួត ១ និងឈាមដែលរត់ផ្សាយទៅពេញសរីរៈ ដែលមានចិត្តគ្រប់គ្រងទាំងពួង ដោយទំនងនៃអណ្តាតភ្លើងដែលផ្សាយទៅ វៀរតែសក់ រោម ក្រចក និង ធ្មេញ ទីមិនមានសាច់ និងស្បែកក្រិនស្បែកស្ងួត ១ ។*

**សេទោ** *ញើស បានដល់ អាបោធាតុ ដែលហូរចេញអំពីរន្ធសក់ និងរន្ធ រោមទាំងពួង ក្នុងសរីរៈដែលក្តៅព្រោះកម្តៅអំពីភ្លើង និងកម្តៅអំពីព្រះអាទិត្យ និងភាពប្រែប្រួលនៃរដូវជាដើម ។*

**មេទោ** *ខ្លាញ់ខាប់ បានដល់ ខ្លាញ់ស្អិតខាប់របស់បុគ្គលអ្នកធាត់ តាំង*

*នៅរវាងស្បែក និងសាច់របស់បុគ្គលអ្នកស្គម នៅត្រង់អវយវៈទាំងឡាយមានសាច់ស្ទងជាដើម ។*

**អស្សុ** *ទឹកភ្នែក បានដល់ អាបោធាតុ ដែលតាំងនៅពេញប្រឡង់ភ្នែក ដែលហូរចេញមកក្តីព្រោះកើតអំពីការសប្បាយចិត្ត ព្រួយចិត្ត អាហារដែលជាវិសភាគ ( ហឹរ ) និងឧតុ ។*

**វសា** *ខ្លាញ់រាវ បានដល់ ខ្លាញ់រាវថ្លា តាំងនៅត្រង់បាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ចុងច្រមុះ ថ្ងាស និងចុងស្មា ដោយច្រើនកើតអំពីកម្តៅភ្លើង កម្តៅព្រះអាទិត្យ និងរដូវពុំជូកាល ។*

**ខេឡោ** *ទឹកមាត់ បានដល់ អាបោធាតុដែលលាយឡំគ្នាជាពពុះដែលកើតឡើងដោយច្រើនដល់បុគ្គលដែលឃើញ ឬនឹកគិត ឬប្បិយកអាហារបែបនោះដាក់ក្នុងមាត់ កើតដល់បុគ្គលអ្នកហត់នឿយ ឬកើតដល់បុគ្គលដែលខ្ពើមក្នុងវត្ថុណាមួយ ទឹកមាត់ក៏ហូរចេញអំពីក្រពេញថ្ពាល់ទាំងសងខាងហើយតាំងនៅត្រង់អណ្តាត ។*

**សិង្ឃាណិកា** *ទឹកសម្បោរ បានដល់ របស់ស្អុយ មិនស្អាត រអិលដូចខ្លាញ់ដែលហូរចេញអំពីខួរក្នុងក្បាល របស់បុគ្គលអ្នកមានធាតុកម្រើក ដោយអាហារដែលជាវិសភាគ និងឧតុពុំជូកាល ឬរបស់បុគ្គលដែលទួញយំទឹកសម្បោរហូរមកតាមចន្លោះពិតាន ពេញក្នុងរន្ធច្រមុះ ខាប់ក៏មាន ហូរចេញមកក៏មាន ។*

**លសិកា** *ទឹករំអិល បានដល់ វត្ថុរអិល ដូចខ្លាញ់ដែលឲ្យសម្រេចកិច្ចក្នុងការបន្តក់ត្រង់សន្លាក់នៃឆ្អឹង តាំងនៅចន្លោះសន្លាក់នៃឆ្អឹង ១៨០ តំណ ។*

**មុត្តំ** ទឹកមូត្រ បានដល់ អាបោធាតុ តាំងនៅក្នុងតម្រងបស្សាវៈ ដោយអំណាចអាហារ និងឧតុ ។

**មត្ថលុង្គំ** ខួរក្នុងក្បាល បានដល់ ដុំនៃខួរដែលរួមគ្នាជា ៤ ដុំ តាំងនៅមានស្នាមថ្នេរ ៤ កន្លែង ខាងក្នុងលលាដ៏ក្បាល ។

[ ៧ ] វិបស្សនា ១២ មានចក្ខាយតនៈជាដើម ព្រះធម្មសេនាបតីសារីបុត្ត សម្ដែងដោយអំណាចនៃអាយតនៈ ១២ ។ ឈ្មោះថា អាយតនៈ ព្រោះជាទីបន្ត ព្រោះផ្សាយទៅនូវប្រភពកើត និងព្រោះនាំទៅនូវការបន្ត ។ មានពាក្យអធិប្បាយថា ពិតហើយ ធម៌ គឺចិត្ត និងចេតសិក រមែងបន្ត គឺរមែងប្រឹងប្រែង ខ្នះខ្នែង ព្យាយាមតាមកិច្ចរៀងៗ ខ្លួន មានការសោយអារម្មណ៍ជាដើមក្នុងទ្វារ និងអារម្មណ៍នោះៗ មានចក្ខុទ្វារ និងរូបារម្មណ៍ជាដើម ។ ( ម្យ៉ាងទៀត ) មានពាក្យអធិប្បាយថា ទ្វារ និងអារម្មណ៍ទាំងនោះរមែងផ្សាយ គឺពង្រីកធម៌ទាំងនោះ ដែលជាប្រភពកើត ។ ( ម្យ៉ាងទៀត ) មានពាក្យអធិប្បាយថា សង្សារទុក្ខ បន្តគ្នាទៅយ៉ាងច្រើនសន្ទឹកសន្ធាប់ ប្រព្រឹត្តទៅក្នុងសង្សារដ៏វែងឆ្ងាយ មិនមានទីបំផុតនេះនៅវិលដរាបណា ទ្វារ និងអារម្មណ៍ទាំងនោះ ក៏រមែងនាំទៅ គឺរមែងឲ្យប្រព្រឹត្តទៅដរាបនោះ ។

ម្យ៉ាងទៀត ឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាទីអាស្រ័យនៅ ព្រោះអត្ថថា ជាប្រភពកើត ព្រោះអត្ថថា ជាទីប្រជុំចុះ ព្រោះអត្ថថា ជាកន្លែងកើត និងព្រោះអត្ថថា ជាហេតុ ។

ពិតហើយ ក្នុងផ្លូវលោកទីលំនៅលោក ហៅថា អាយតនៈ ដូចក្នុងពាក្យ

ថា **ឥស្សរាយតនំ** លំនៅរបស់ព្រះឥស្សរ **វាសុទេវាយតនំ** លំនៅរបស់វាសុទេពជាដើម ។

ប្រភពកើត ហៅថា អាយតនៈ ដូចក្នុងពាក្យថា **សុវណ្ណាយតនំ** ប្រភពកើតនៃមាស **រជតាយតនំ** ប្រភពកើតនៃប្រាក់ជាដើម ។

តែក្នុងសាសនា ទីប្រជុំ ហៅថា អាយតនៈ ដូចក្នុងពាក្យថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា** ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ប្រជុំគ្នាក្នុងទីជាទីរីករាយចិត្តជាដើម ។

ប្រទេសកើត ហៅថា អាយតនៈ ដូចក្នុងពាក្យថា **ទក្ខិណាបថោ គុន្នំ អាយតនំ** ទក្ខិណាបថ ជាទីកើតនៃគោទាំងឡាយជាដើម ។

ហេតុ ហៅថា អាយតនៈ ដូចក្នុងពាក្យថា **តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ** កាលបើមានហេតុមានទំនង បុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ក្នុងធម៌នោះៗ ជាដើម ។ ធម៌ គឺចិត្ត និងចេតសិកទាំងនោះអាស្រ័យនៅត្រង់ចក្ខុវត្ថុជាដើម ព្រោះប្រព្រឹត្តទៅទាក់ទងដោយចក្ខុវត្ថុជាដើមនោះ ព្រោះហេតុនោះ ទើបចក្ខុវត្ថុជាដើមនោះ ឈ្មោះថា ជាទីអាស្រ័យនៅនៃធម៌ គឺចិត្ត និងចេតសិកទាំងនោះ ។ ធម៌ គឺចិត្ត និងចេតសិកទាំងឡាយទាំងនោះកើតត្រង់ចក្ខុវត្ថុជាដើម ព្រោះមានចក្ខុវត្ថុជាដើមនោះ ជាទីអាស្រ័យ និងព្រោះមានចក្ខុវត្ថុជាដើមនោះជាអារម្មណ៍ ព្រោះហេតុនោះ ទើបចក្ខុវត្ថុជាដើម ឈ្មោះថា ជាប្រភពកើតនៃធម៌ គឺចិត្ត និងចេតសិកទាំងនោះ ។ ចក្ខុវត្ថុជាដើម ជាទីប្រជុំនៃធម៌ គឺចិត្ត និងចេតសិកទាំងនោះ ព្រោះប្រជុំចុះដោយអំណាចនៃ

វត្ថុទ្វារ និងអារម្មណ៍ ក្នុងចក្ខុវត្ថុជាដើមនោះៗ ។ ចក្ខុវត្ថុជាដើម ជាប្រទេសកើតនៃធម៌ គឺចិត្ត និងចេតសិកទាំងនោះ ព្រោះកើតឡើងក្នុងចក្ខុវត្ថុជាដើមនោះ ដោយការអាស្រ័យចក្ខុវត្ថុជាដើមនោះ ជាអារម្មណ៍ ។ ចក្ខុវត្ថុជាដើមជាហេតុនៃធម៌ គឺចិត្ត និងចេតសិកទាំងនោះ ព្រោះកាលចក្ខុវត្ថុជាដើមមិនមាន ធម៌ គឺចិត្ត និងចេតសិកក៏មិនមាន ។ ចក្ខុនោះផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខាយតនៈ តាមន័យដែលបានពោលមកហើយនេះឯង ។ សូម្បីអាយតនៈដ៏សេស ក៏មានន័យយ៉ាងនេះដូចគ្នា ។

វិសជ្ជនា ១៨ មានចក្ខុធាតុជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្តែងដោយអំណាចនៃធាតុ ១៨ ។ ធម៌នីមួយៗ ក្នុងធម៌មានចក្ខុធាតុជាដើម ឈ្មោះថា ធាតុ ព្រោះអត្ថថា ទ្រទ្រង់ ដែលសត្វទ្រទ្រង់ សភាវៈទ្រទ្រង់ ជាហេតុទ្រទ្រង់ ឬជាទីទ្រទ្រង់តាមសមគួរដល់ការកើត អធិប្បាយថា លោកិយធាតុទាំងឡាយកំណត់ តាំងទុកដោយភាពជាហេតុ រមែងទ្រទ្រង់នូវសង្សារទុក្ខជាច្រើនប្រការ ដូចធាតុ មានធាតុមាស និងធាតុប្រាក់ជាដើម ទ្រទ្រង់នូវមាស និងប្រាក់ជាដើម ។ ធម្មជាតណា ដែលសត្វទ្រទ្រង់ សេចក្តីថា ទ្រទ្រង់ ដូចភារៈដែលបុគ្គលអ្នករែកអម្រែកទៅ ដូច្នោះ ។ ម្យ៉ាងទៀត ធាតុនេះ មានសភាពទ្រទ្រង់នូវទុក្ខប៉ុណ្ណោះ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ សង្សារទុក្ខ ដែលសត្វទាំងឡាយទ្រទ្រង់ ស្មើដោយធាតុទាំងឡាយ ដែលជាហេតុ អធិប្បាយថា សង្សារទុក្ខនោះ ដែលសត្វទ្រទ្រង់ហើយយ៉ាងនោះ រមែងតាំងនៅ ស្ថិតនៅក្នុងធាតុទាំងឡាយនោះឯង ។

មួយទៀត សម្រាប់អត្ថារបស់ត្ថិរិយទាំងឡាយ មិនមានដោយសភាវៈ យ៉ាងណា ធាតុទាំងឡាយនេះ នឹងមានសភាវៈយ៉ាងនោះ ក៏មិនមែន ។ តែធាតុទាំងនោះ ឈ្មោះថា ធាតុ ព្រោះអត្ថថា ទ្រទ្រង់នូវសភាវៈរបស់ខ្លួន ។ ដូចចំណែកផ្សេងៗ របស់ថ្ម មានហរតាល និងមនោសីលាជាដើម ដែលវិចិត្រក្នុងលោកក៏ហៅថា ធាតុ យ៉ាងណា ធាតុទាំងឡាយដែលវិចិត្រសូម្បីទាំងនេះ ក៏ឈ្មោះថា ធាតុ ព្រោះដូចជាធាតុក៏យ៉ាងនោះ ។ ធាតុដែលវិចិត្រទាំងនោះ ជាចំណែកដែលគប្បីដឹងបានដោយញាណ ។ ម្យ៉ាងទៀត ក្នុងចំណែកទាំងឡាយមានរស និងលោហិតជាដើម កំណត់តាមលក្ខណៈដែលជាវិសភាគដល់គ្នានិងគ្នាដែលជាចំណែកផ្សេងៗ របស់រាងកាយ ពោលគឺសរីរៈ គប្បីជ្រាបថា ឈ្មោះថា ធាតុ យ៉ាងណា ក្នុងចំណែកផ្សេងៗ នៃអត្តភាព ពោលគឺបញ្ចក្ខន្ធទាំងនេះ ក៏គប្បីជ្រាបថា ឈ្មោះថា ធាតុ យ៉ាងនោះដូចគ្នា ។ ព្រោះធាតុទាំងនោះ មានចក្ខុធាតុជាដើម ក៏កំណត់ដោយលក្ខណៈដែលជាវិសភាគដល់គ្នានិងគ្នា ។ ម្យ៉ាងទៀត ពាក្យថា ធាតុនេះ គ្រាន់តែជាឈ្មោះនៃនិជ្ជីវធម៌ ។ ពិតហើយ ក្នុងព្រះបាលី ( មជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ម្នាលភិក្ខុ បុរសនេះ មានធាតុ ៦ ជាដើម ព្រះមានព្រះភាគ បានធ្វើទេសនាក្នុងរឿងធាតុ ក៏ដើម្បីនឹងដកការប្រកាន់មាំ ថាជាជីវៈ គឺបុគ្គល ។

ចក្ខុនោះផង ជាធាតុផង ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខុធាតុ តាមន័យដែលបានពោលហើយ ។ សូម្បីធាតុដ៏សេសក៏យ៉ាងនោះដូចគ្នា ។

បទថា **មនោធាតុ** បានដល់ មនោធាតុ ៣ ។

បទថា **ធម្មធាតុ** បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ សុខុមរូប ១៦ និងនិព្វាន ។

បទថា **មនោវិញ្ញាណធាតុ** បានដល់ មនោវិញ្ញាណធាតុ ៧៦ ។

វិសជ្ជនា ២២ មានចក្ខុន្ទ្រិយជាដើម ព្រះធម្មសេនាបតីសារីបុត្ត សម្តែងដោយអំណាចនៃឥន្ទ្រិយ ២២ ។

ឈ្មោះថា **ចក្ខុន្ទ្រិយំ** ព្រោះចក្ខុនោះឯង ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការឃើញ ។

ឈ្មោះថា **សោតិន្ទ្រិយំ** ព្រោះសោតនោះឯង ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការបានឮ ។

ឈ្មោះថា **ឃានិន្ទ្រិយំ** ព្រោះឃានៈនោះឯង ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការហិតក្លិន ។

ឈ្មោះថា **ជិវ្ហិន្ទ្រិយំ** ព្រោះជិវ្ហានោះឯង ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការលិទ្ធរស ។

ឈ្មោះថា **កាយិន្ទ្រិយំ** ព្រោះកាយនោះឯង ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការពាល់ត្រូវ ។

ឈ្មោះថា **មនោ** ព្រោះដឹងអារម្មណ៍ អធិប្បាយថា រមែងដឹងអារម្មណ៍ផ្សេងៗ បាន ។ តែព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា **មនោ** ព្រោះគិត ព្រោះដឹងអារម្មណ៍ ដូចមនុស្សកំណត់រាប់ដោយនាឡិ និងដូចទ្រទ្រង់ដោយជញ្ជីងធំដូច្នោះ ឈ្មោះថា **មនិន្ទ្រិយំ** ព្រោះមនោនោះឯង ធ្វើខ្លួនឲ្យជាធំ

ក្នុងលក្ខណៈនៃការដឹងអារម្មណ៍ ។

សហជាតធម៌តាំងនៅបានដោយធម្មជាតនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ជីវិត** ឈ្មោះថា **ជីវិតិន្ទ្រិយំ** ព្រោះជីវិតនោះឯង ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការរក្សា ។ ជីវិតិន្ទ្រិយនោះមាន ២ យ៉ាង គឺរូបជីវិតិន្ទ្រិយ ១ អរូបជីវិតិន្ទ្រិយ ១ ។ ជីវិតិន្ទ្រិយ ( ជីវិតរូប ) ដែលកើតរួមជាមួយកម្មជរូបទាំងអស់ រក្សារូបដែលកើតរួមគ្នា ឈ្មោះថា រូបជីវិតិន្ទ្រិយ ជីវិតិន្ទ្រិយ ( ចេតសិក ) ដែលកើតរួមជាមួយចិត្តទាំងអស់ រក្សាអរូបដែលកើតរួមគ្នា ឈ្មោះថា អរូបជីវិតិន្ទ្រិយ ។

បុគ្គលណារមែងសម្លាប់ គឺរមែងដល់នូវការប្រហារ ជាអ្នកមានគភ៌បាន ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ឥត្ថី** ។ ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងភេទស្រីជាដើម ពោលដោយការកំណត់ ភាពជាធំនៃស្រីនោះឯង ឈ្មោះថា **ឥត្ថិន្ទ្រិយំ** ។

**និរយ** គឺនរក លោកហៅថា **បុំ** បុគ្គលណាត្រូវបៀតបៀនក្នុងនរក ពោលគឺ **បុំ** ព្រោះហេតុនោះ បុគ្គលនោះឈ្មោះថា **បុរិស** គឺប្រុស ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងភេទប្រុសជាដើម ពោលដោយការកំណត់ភាពជាធំនៃបុរសនោះ ឈ្មោះថា **បុរិសិន្ទ្រិយំ** ។ ក្នុងឥន្ទ្រិយសូម្បីទាំង ២ នោះ ឥន្ទ្រិយនីមួយៗ ដែលកើតរួមនឹងកម្មជរូបរបស់បុគ្គលនីមួយៗ តាមភាវៈរបស់ខ្លួន ។

សុខវេទនាដែលប្រកបជាមួយកាយវិញ្ញាណចិត្តដែលជាកុសលវិបាក ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការដឹងសប្បាយផ្លូវកាយ ឈ្មោះថា **ឥន្ទ្រិយំ** ឥន្ទ្រិយ

គឺសេចក្ដីសុខ ឈ្មោះថា **សុខិន្ទ្រិយំ** ។

ទុក្ខវេទនាដែលប្រកបជាមួយកាយវិញ្ញាណចិត្ត ដែលជាអកុសលវិបាក ធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការដឹងមិនសប្បាយផ្លូវកាយ ឈ្មោះថា **ឥន្ទ្រិយំ** ឥន្ទ្រិយ គឺសេចក្ដីទុក្ខ ឈ្មោះថា **ទុក្ខិន្ទ្រិយំ** ។

**មន** ដែលល្អ គឺស្អាត ព្រោះប្រកបដោយបីតិ និងសោមនស្សរបស់បុគ្គលនោះមាន ព្រោះហេតុនោះ ទើបឈ្មោះថា **សុមនោ** ភាពជាសុមនៈ ឈ្មោះថា **សោមនស្សំ** ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការត្រេកអរផ្លូវចិត្ត ឥន្ទ្រិយ គឺសោមនស្ស ឈ្មោះថា **សោមនស្សិន្ទ្រិយំ** ។

**មន** អាក្រក់ ព្រោះប្រកបដោយទោមនស្សរបស់បុគ្គលនោះមាន ឬ **មន** របស់បុគ្គលនោះគួរខ្ពើម ព្រោះសោយអារម្មណ៍អាក្រក់ ព្រោះហេតុនោះ ទើបឈ្មោះថា **ទុម្មនោ** ភាពជាទុម្មនៈ ឈ្មោះថា **ទោមនស្សំ** ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការមិនត្រេកអរផ្លូវចិត្ត ឥន្ទ្រិយ គឺទោមនស្ស ឈ្មោះថា **ទោមនស្សិន្ទ្រិយំ** ។

ធម្មជាតណា រមែងសម្លឹងការប្រព្រឹត្តទៅនៃអាការរបស់សុខវេទនា និងទុក្ខវេទនា គឺរមែងប្រព្រឹត្តទៅដោយអាការនោះ ព្រោះតាំងនៅដោយអាការនៃភាពជាកណ្ដាល ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ឧបេក្ខា** ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃភាពជាកណ្ដាល ឥន្ទ្រិយ គឺឧបេក្ខា ឈ្មោះថា **ឧបេក្ខិន្ទ្រិយំ** ។

បុគ្គលរមែងជឿដោយធម្មជាតនោះក្ដី ជឿឯងក្ដី ធម្មជាតនោះត្រឹមតែការ

ជឿនោះឯងក្តី ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សទ្ធា** ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះអត្ថថា ជាអធិបតី ព្រោះគ្របសង្កត់ការមិនមានសទ្ធា ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការបង្អោនចិត្ត ឥន្ទ្រិយ គឺសទ្ធា ឈ្មោះថា **សទ្ធិន្ទ្រិយំ** ។

ភាពជាអ្នកក្លៀវក្លាក្តី ការងារនៃបុគ្គលអ្នកក្លៀវក្លាទាំងឡាយក្តី ឈ្មោះថា **វីរិយ** ម្យ៉ាងទៀត គប្បីខ្វល់ខ្វាយ គឺគប្បីប្រព្រឹត្តទៅដោយវិធី ដោយន័យ ព្រោះហេតុនោះ ទើបឈ្មោះថា **វីរិយ** ឈ្មោះថា **ឥន្ទ្រិយំ** ដោយអត្ថថា ជាអធិបតី ព្រោះគ្របសង្កត់ការខ្ជិលច្រអូស ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃសេចក្តីព្យាយាម ឥន្ទ្រិយ គឺវីរិយៈ ឈ្មោះថា **វីរិយិន្ទ្រិយំ** ។

បុគ្គលរមែងរឭកបានដោយធម្មជាតនោះក្តី រឭកបានឯងក្តី ធម្មជាតនោះត្រឹមតែការរឭកបាននោះឯងក្តី ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **សតិ** ឈ្មោះថា **ឥន្ទ្រិយំ** ដោយអត្ថថា ជាអធិបតី ព្រោះគ្របសង្កត់ការភ្លាំងភ្លាត់សតិ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃការប្រាកដ ឥន្ទ្រិយ គឺសតិ ឈ្មោះថា **សតិន្ទ្រិយំ** ។ ធម្មជាតណា រមែងទ្រទ្រង់ រមែងតាំងទុកដោយល្អនូវចិត្តក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សមាធិ** ឈ្មោះថា **ឥន្ទ្រិយំ** ដោយអត្ថថា ជាអធិបតីព្រោះគ្របសង្កត់នូវការរាយមាយក្នុងអារម្មណ៍ផ្សេងៗ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំ ក្នុងលក្ខណៈនៃការមិនរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ ឥន្ទ្រិយ គឺសមាធិ ឈ្មោះថា **សមាធិន្ទ្រិយំ** ។

ធម្មជាតណា រមែងដឹងអរិយសច្ចដោយន័យជាដើមថា នេះទុក្ខ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **បញ្ញា** ។ តែក្នុងអដ្ឋកថា ពោលថា បញ្ញា ដោយអំណាចឲ្យដឹងថា មិនទៀង ជាទុក្ខ ជាអនត្តា ។ ឈ្មោះថា **ឥន្ទ្រិយំ** ដោយអត្ថថា ជាអធិបតីព្រោះគ្របសង្កត់អវិជ្ជា ។ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើខ្លួនឲ្យជាធំក្នុងលក្ខណៈនៃទស្សនញ្ញាណ ឥន្ទ្រិយ គឺបញ្ញា ឈ្មោះថា **បញ្ញិន្ទ្រិយំ** ។

ឈ្មោះថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** ព្រោះកើតដល់ព្រះយោគីបុគ្គលអ្នកបដិបត្តិដោយគិតថា អញនឹងដឹងព្រះនិព្វានដែលជាអមតបទ ដែលមិនធ្លាប់ដឹងក្នុងសង្សារវដ្តដ៏វែងឆ្ងាយក្តី នឹងដឹងសច្ចធម៌ ៤ នោះឯងក្តី និងព្រោះកើតដោយអត្ថថា ជាធំ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយនេះ ជាឈ្មោះរបស់សោតាបត្តិមគ្គញាណ ។

ឈ្មោះថា **អញ្ញិន្ទ្រិយំ** ព្រោះអត្ថថា ជាឥន្ទ្រិយដែលដឹងទូទៅ ព្រោះមិនឈានកន្លងព្រំដែនដែលបឋមមគ្គដឹងហើយ ដឹងសច្ចធម៌ ៤ ទាំងនោះឯង ដែលមគ្គនោះដឹងហើយ និងព្រោះកើត ដោយអត្ថថា ជាធំ អញ្ញិន្ទ្រិយនេះ ជាឈ្មោះនៃញាណ ក្នុងឋានៈ ៦ មានសោតាបត្តិផលជាដើម ។

ឈ្មោះថា **អញ្ញាតាវិន្ទ្រិយំ** ព្រោះកើតដល់ព្រះខីណាស្រពដែលដឹងទូទៅហើយ គឺជាអ្នកមានកិច្ចនៃញាណក្នុងសច្ចៈ ៤ ចប់ហើយ និងព្រោះកើតដោយអត្ថថា ជាធំ ម្យ៉ាងទៀត ឈ្មោះថា **អញ្ញាតាវិន្ទ្រិយំ** ព្រោះសម្រេចភាពជាធំក្នុងរវាងនៃធម៌ទាំងឡាយដែលព្រះខីណាស្រពដឹងទូទៅហើយ ដែលមានកិច្ចក្នុង

សច្ចៈ ៤ ចប់ហើយ ដែលចាក់ធ្លុះសច្ចៈ ៤ ហើយតាំងនៅ ។ អញ្ញាតាវិន្ទ្រិយ នេះជាឈ្មោះនៃអរហត្តផលញ្ញាណ ។

ឥន្ទ្រិយទាំងអស់នេះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ប្រកាសភាពជាកំពូល ដោយអត្ថថា បុគ្គលជាកំពូលសម្តែងហើយ ដោយអត្ថថា បុគ្គលជាកំពូលឃើញហើយ ដោយអត្ថថា បុគ្គលជាកំពូលចាត់ចែងហើយ និងដោយអត្ថថា បុគ្គលជាកំពូលសេពហើយ តាមដែលប្រកបបាន ពិតហើយ ព្រះមានព្រះភាគសម្មាសម្ពុទ្ធ ឈ្មោះថា បុគ្គលជាកំពូល ព្រោះទ្រង់ជាអគ្គបុគ្គល ឯកម្មទាំងដែលជាកុសល និងអកុសល ឈ្មោះថា ជាកំពូល ព្រោះមិនមានអ្វីជាធំជាងក្នុងកម្មទាំងឡាយ ។ ដោយហេតុនោះឯង ក្នុងឥន្ទ្រិយទាំងនេះ ឥន្ទ្រិយដែលកម្មឲ្យកើត រមែងប្រកាសឲ្យដឹងកុសលកម្ម និងអកុសលកម្ម ឥន្ទ្រិយទាំងនោះ ដែលកុសលកម្ម និងអកុលកម្មនោះចាត់ចែងហើយ ព្រោះហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ដោយអត្ថថា ប្រកាសភាពជាកំពូល និងដោយអត្ថថា បុគ្គលជាកំពូលចាត់ចែងហើយ មួយវិញទៀត ឥន្ទ្រិយទាំងអស់នោះឯង ដែលព្រះមានព្រះភាគ ព្រះអង្គជាកំពូលនៃមុនី ទ្រង់ប្រកាសហើយ និងត្រាស់ដឹងដ៏ក្រៃលែងហើយ តាមសេចក្តីពិត ព្រោះហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ដោយអត្ថថា បុគ្គលជាកំពូលសម្តែងហើយ និងដោយអត្ថថា បុគ្គលជាកំពូលឃើញហើយ ។ ព្រះមានព្រះភាគនោះឯង ជាកំពូលមុនី សេពឥន្ទ្រិយប្រភេទខ្លះ ដោយការសេពដោយភាពជាអារម្មណ៍ សេពឥន្ទ្រិយប្រភេទខ្លះដោយការសេព ដោយការនា ព្រោះហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា បុគ្គលជាកំពូលសេព

ហើយក៏មាន ។ មួយវិញទៀត ឥន្ទ្រិយទាំងនេះ ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ជាធំ ពោល គឺជាអធិបតីក៏មាន ។ ដ្បិតថា ភាពជាអធិបតីសម្រេចហើយ ដល់ចក្ខុជាដើម ក្នុងបវត្តិកាលនៃចក្ខុវិញ្ញាណជាដើម ព្រោះកាលបើឥន្ទ្រិយ ចាស់ក្លា ចក្ខុវិញ្ញាណជាដើម ក៏ចាស់ក្លា និងព្រោះកាលឥន្ទ្រិយនៅទន់ខ្សោយ ចក្ខុវិញ្ញាណជាដើមក៏ទន់ខ្សោយ ដូច្នេះឯង ។

[ ៨ ] វិសជ្ជនា ១២ មានកាមធាតុជាដើម ព្រះធម្មសេនាបតីសារីបុត្ត សម្ដែងហើយ ដោយប្រភេទនៃភព ។

ធាតុដែលប្រកបដោយកាម ពោល គឺកាមរាគៈ ឈ្មោះថា កាមធាតុ ឬធាតុ ពោល គឺកាម ឈ្មោះថា **កាមធាតុ** ។

ធាតុដែលប្រកបហើយ ដោយរូបជ្ឈាន ព្រោះលះកាមចេញបាន ឈ្មោះថា រូបធាតុ ធាតុ ពោល គឺរូបជ្ឈាន ឈ្មោះថា **រូបធាតុ** ។

ធាតុដែលប្រកបហើយដោយអរូបជ្ឈាន ព្រោះលះកាម និងរូបជ្ឈានបាន ឈ្មោះថា អរូបធាតុ ឬធាតុ ពោល គឺអរូបជ្ឈាន ឈ្មោះថា **អរូបធាតុ** ។

ធាតុទាំងនោះឯង លោកពោលដោយបរិយាយនៃភពទៀត ។ ពិតហើយ លោកហៅថា ភព ព្រោះរមែងកើត ។

ភពដែលប្រកបហើយដោយសញ្ញា ឈ្មោះថា សញ្ញាភព ឬភពដែល សហគតៈដោយសញ្ញា ឈ្មោះថា សញ្ញាភព ឬសញ្ញាមាននៅក្នុងភពនេះ ព្រោះហេតុនោះ ទើបភពនេះ ឈ្មោះថា **សញ្ញាភវោ** ។

សញ្ញាភពនោះ ជាកាមភពក៏បាន ជារូបភព វៀរអសញ្ញាភពក៏បាន ជា

អរូបភព វៀរនេវសញ្ញានាសញ្ញាភពក៏បាន ។ ភពដែលមិនមានសញ្ញា ឈ្មោះថា អសញ្ញាភព អសញ្ញាភពនោះ ជាចំណែកមួយនៃរូបភព ។

ព្រោះភាពមិនមានសញ្ញាគ្រោតគ្រាត ឈ្មោះថា នេវសញ្ញា គឺមានសញ្ញាក៏មិនមែន ព្រោះមានសញ្ញាល្អិត ឈ្មោះថា នាសញ្ញា គឺមិនមានសញ្ញាក៏មិនមែន ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញា ភពដែលប្រកបដោយនេវសញ្ញានាសញ្ញានោះ ឈ្មោះថា នេវសញ្ញានាសញ្ញាភព ម្យ៉ាងទៀត ឈ្មោះថា នេវសញ្ញានាសញ្ញា ព្រោះការមិនមានសញ្ញាគ្រោតគ្រាត និងព្រោះការមានសញ្ញាល្អិតមានក្នុងភពនេះ ព្រោះហេតុនោះ ទើបភពនេះ ឈ្មោះថា នេវសញ្ញានាសញ្ញាភព នេវសញ្ញានាសញ្ញាភពនោះ ជាចំណែកមួយនៃអរូបភព ។

ភពដែលប្របូកប្របល់ដោយរូបក្ខន្ធតែម្យ៉ាង គឺរូបក្ខន្ធសុទ្ធៗ នៃភពនោះមាន ព្រោះហេតុនោះ ទើបភពនោះ ឈ្មោះថា ឯកវោការភព ឯកវោការភពនោះ ជាអសញ្ញាភពនោះឯង ។

ភពដែលប្របូកប្របល់ដោយនាមក្ខន្ធ ៤ គឺនាមក្ខន្ធ ៤ សុទ្ធៗ នៃភពនោះមាន ព្រោះហេតុនោះ ទើបភពនោះ ឈ្មោះថា ចតុវោការភព ចតុវោការភពនោះ ជាអរូបភពនោះឯង ។

ភពដែលលាយឡំដោយខន្ធ ៥ គឺខន្ធ ៥ សុទ្ធៗ នៃភពនោះមាន ព្រោះហេតុនោះ ទើបភពនោះ ឈ្មោះថា បញ្ចវោការភព បញ្ចវោការភពនោះ ជាកាមភពផង ជាចំណែកមួយនៃរូបភពផង ។

វិសជ្ជនា ១២ មានបឋមជ្ឈានជាដើម ព្រះធម្មសេនាបតីសារីបុត្ត សម្តែង

ដោយអំណាចនៃឈានសមាបត្តិ ។

ពាក្យថា ឈាន ក្នុងទីនេះ បំណងយកត្រឹមតែព្រហ្មវិហារធម៌ ។

បឋមជ្ឈានប្រកបដោយវិតក្ក វិចារ បីតិ សុខ និងឯកគ្គតានៃចិត្ត ។

ទុតិយជ្ឈានប្រកបដោយបីតិ សុខ និងឯកគ្គតានៃចិត្ត ។

តតិយជ្ឈានប្រកបដោយសុខ និងឯកគ្គតានៃចិត្ត ។

ចតុត្ថជ្ឈានប្រកបដោយឧបេក្ខា និងឯកគ្គតានៃចិត្ត ។

[ ៩ ] ធម្មជាតណា រមែងស្និទ្ធស្នាល ស្រឡាញ់ អធិប្បាយថា រមែងស្នេហា ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា មេត្តា ។ ម្យ៉ាងទៀត ធម្មជាតដែលមានក្នុងមិត្ត ឬប្រព្រឹត្តទៅដល់មិត្ត ព្រោះហេតុនោះ ទើបឈ្មោះថា មេត្តា ឈ្មោះថា វិមុត្តិ ព្រោះផុតអំពីបច្ចនិកធម៌ទាំងឡាយ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ ការផុតនៃចិត្ត ឈ្មោះថា ចេតោវិមុត្តិ ចេតោវិមុត្តិគឺមេត្តា ឈ្មោះថា **មេត្តាចេតោវិមុត្តិ** ។

**ករុណា** ក៏មានអត្ថតាមដែលពោលហើយនោះឯង ។

បុគ្គលប្រកបដោយធម្មជាតនោះ ហើយរមែងត្រេកអរ ឬធម្មជាតណារមែងត្រេកអរឯង ឬថា វត្ថុនោះ ត្រឹមតែការត្រេកអរ ព្រោះហេតុនោះ ទើបឈ្មោះថា **មុទិតា** ។

ធម្មជាតណា រមែងសម្លឹងដោយការលះសេចក្តីព្យាយាម ដោយន័យជាដើមថា សត្វទាំងឡាយទាំងពួង សូមជាអ្នកមិនមានពៀរចុះ និងដោយការចូលដល់ភាពជាកណ្តាល ព្រោះហេតុនោះ ធម្មជាតនោះ ទើបឈ្មោះថា **ឧបេក្ខា** ។

ព្រហ្មវិហារ ៣ មានមេត្តាជាដើម ប្រកបដោយឈាន ៣ មានបឋមជ្ឈាន ជាដើម ចំណែកឧបេក្ខាព្រហ្មវិហារ ប្រកបដោយចតុត្ថជ្ឈាន ។

ទីបំផុតនៃអាកាសនោះ មិនមានដោយអំណាចនៃការផ្សាយទៅ ព្រោះហេតុនោះ អាកាសនោះ ឈ្មោះថា អនន្ត អាកាសមិនមានទីបំផុត ឈ្មោះថា អាកាសានន្ត បានដល់ កសិណុគ្ឃាដិមាកាស ។ អាកាសានន្តនោះឯង ឈ្មោះថា អាកាសានញ្ចៈ អាកាសានញ្ចនោះ ឈ្មោះថា ជាអាយតនៈ ព្រោះអត្ថថា ជាទីតាំងនៃឈាននោះ ព្រមដោយសម្បយុត្តធម៌ ដូចគ្នានឹងលំនៅរបស់ទេវតាទាំងឡាយ ឈ្មោះថា ទេវាយតនៈ ព្រោះហេតុនោះ ទើបឈ្មោះថា អាកាសានញ្ចាយតនៈ សមាបត្តិ គឺអាកាសានញ្ចាយតនៈ ឈ្មោះថា **អាកាសានញ្ចាយតនសមាបត្តិ** ។

ទីបំផុតនៃវិញ្ញាណនោះមិនមាន ដោយអំណាចនៃការផ្សាយទៅ ព្រោះហេតុនោះ ឈ្មោះថា អនន្ត អនន្តនោះ ក៏គឺវិញ្ញាណដែលមានអាកាសជាអារម្មណ៍ ។ អនន្តនោះឯង ឈ្មោះថា អានញ្ចៈវិញ្ញាណមិនមានទីបំផុត លោកមិនពោលថា **វិញ្ញាណានញ្ចៈ** តែពោលថា **វិញ្ញាណញ្ចៈ** ។ សព្ទនេះ ក្នុងទីនេះ ជារុឡ្ហីសព្ទ គឺជាសព្ទដែលនិយាយផ្សេង តែមានន័យផ្សេង ។

វិញ្ញាណញ្ចនោះ ជាអាយតនៈ ព្រោះអត្ថថា ជាទីតាំងនៃឈាននោះ ព្រមដោយសម្បយុត្តធម៌ ដូចគ្នានឹងលំនៅរបស់ទេវតាទាំងឡាយ ហៅថា ទេវាយតនៈ ព្រោះហេតុនោះ ទើបឈ្មោះថា **វិញ្ញាណញ្ចាយតនៈ** ។

ឈាន ឈ្មោះថា **អាកិញ្ចញ្ញៈ** ព្រោះមិនមានអ្វីសូម្បីបន្តិចបន្តួច មានអធិប្បាយថា ដោយហោចត្រឹមកវង្គក្ខណៈក៏មិនមានសេសសល់នៅ ។ ភាវៈ

នៃអាកិញ្ចនៈ ឈ្មោះថា **អាកិញ្ចញ្ញ** ។ ពាក្យនេះ ជាឈ្មោះរបស់ឈានដែល មិនមានអាកាសានញ្ចាយតនៈ និងវិញ្ញាណ ។ អាកិញ្ចញ្ញនោះ ជាអាយតនៈ ដោយអត្ថថា ជាទីតាំងនៃឈាននោះ មួយអន្លើដោយសម្បយុត្តធម៌ ។ ដូចគ្នា នឹងលំនៅរបស់ទេវតាទាំងឡាយ ហៅថា ទេវាយតនៈព្រោះហេតុនោះ ទើប ហៅថា **អាកិញ្ចញ្ញាយតនៈ** ។

សញ្ញានៃឈាននោះ មួយអន្លើដោយសម្បយុត្តធម៌មិនមាន ព្រោះមិនមាន សញ្ញាគ្រោតគ្រាត និងព្រោះមិនមានសញ្ញា ក៏មិនមែន ព្រោះសញ្ញាល្អិតមាន ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញៈ ។ នេវសញ្ញានាសញ្ញៈ នោះផង ជាអាយតនៈ ព្រោះជាប់ទាក់ទងក្នុងមនាយតនៈ និងធម្មាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា **នេវសញ្ញានាសញ្ញាយតនៈ** ។

មួយទៀត សញ្ញាក្នុងឈាននេះ ឈ្មោះថា មិនមានសញ្ញា ព្រោះមិនអាច ធ្វើកិច្ចនៃសញ្ញាឲ្យច្បាស់លាស់បាន និងឈ្មោះថា មិនមានសញ្ញាសោះ ក៏មិន មែន ព្រោះសង្ខារដែលនៅសេសសល់មានដោយសុខុមភាព ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញា នេវសញ្ញានាសញ្ញានោះផង ជាអាយតនៈ ផង ព្រោះអត្ថថា ជាទីតាំងនៃធម៌ដ៏សេស[១] ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ។ ពាក្យនេះ ជាឈ្មោះនៃសមាបត្តិ ដែលមាន អាកិញ្ចញ្ញាយតនៈជាអារម្មណ៍ ។

មួយទៀត ក្នុងឈាននេះ មិនមែនសញ្ញាតែម្យ៉ាង ដែលមានសភាពយ៉ាង

១- ធម៌ដ៏សេស បានដល់ ចេតសិក ២៩ ចិត្ត ១ មានសញ្ញាជាប្រធាន ។

នេះ សូម្បីវេទនា ក៏ឈ្មោះថា នៅវេទនានាវេទនា សូម្បីចិត្ត ក៏ឈ្មោះថា នៅចិត្តនាចិត្ត សូម្បីផស្សៈ ក៏ឈ្មោះថា នៅផស្សនាផស្សៈ ក្នុងសម្បយុត្តធម៌ ដ៏សេសក៏មានន័យយ៉ាងនេះ តែទេសនានេះ លោកធ្វើសញ្ញាឲ្យជាមាតិកា ។

វិសជ្ជនា ១២ មានអវិជ្ជាជាដើម ព្រះធម្មសេនាបតីសារីបុត្តសម្តែងដោយអង្គនៃបដិច្ចសមុប្បាទ ។

កាយទុច្ចរិតជាដើម ឈ្មោះថា **អវិន្ទិយ** សេចក្តីថា មិនគួរបាន ព្រោះអត្ថថា មិនគួរបំពេញ ។ ធម្មជាតណា រមែងបាននូវអវិន្ទិយនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អវិជ្ជា** ។

កាយសុចរិតជាដើម ឈ្មោះថា **វិន្ទិយ** ព្រោះផ្ទុយគ្នានឹងអវិន្ទិយៈនោះ ធម្មជាតណា រមែងមិនបាននូវវិន្ទិយៈនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អវិជ្ជា** ។

ធម្មជាតណា ធ្វើអត្ថ គឺគំនរនៃខន្ធទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺការតនៃអាយតនៈទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺភាពទទេនៃធាតុទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺភាពជាធំនៃឥន្ទ្រិយទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺសេចក្តីពិតនៃសច្ចៈទាំងឡាយមិនឲ្យប្រាកដ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អវិជ្ជា** ធម្មជាតណា ធ្វើអត្ថនីមួយៗ ៤ យ៉ាងនៃសច្ចៈទាំងឡាយមានទុក្ខសច្ចជាដើម ដែលពោលហើយ ដោយអំណាចនៃការបៀតបៀនជាដើមមិនឲ្យប្រាកដ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អវិជ្ជា** ។

ធម្មជាតណា រមែងញុំាងសត្វទាំងឡាយឲ្យស្ទុះទៅក្នុងកំណើត គតិ ភព

វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួង ក្នុងសង្សារវដ្តដែលមិនមានទីបំផុត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អវិជ្ជា** ។

ធម្មជាតណា រមែងស្ទុះទៅក្នុងបញ្ញត្តទាំងឡាយ មានស្រី និងប្រុសជាដើម ដែលមិនមានដោយបរមត្ថ មិនស្ទុះទៅក្នុងវិជ្ជមានបញ្ញត្តិ មានខន្ធជាដើម ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **អវិជ្ជា** ។

ម្យ៉ាងទៀត ឈ្មោះថា **អវិជ្ជា** ព្រោះបិទបាំងនូវវត្ថុ និងអារម្មណ៍នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម និងនូវធម៌ទាំងឡាយ ដែលជាបដិច្ច-សមុប្បាទ និងដែលជាបដិច្ចសមុប្បន្ន ។

ធម្មជាតណា រមែងតាក់តែងនូវសង្ខតធម៌ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **សង្ខារ** ។

ធម្មជាតណា រមែងដឹងច្បាស់នូវអារម្មណ៍បាន ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វិញ្ញាណ** ។

ធម្មជាតណា រមែងបង្អោនទៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា នាម ម្យ៉ាងទៀត ធម្មជាតណា រមែងឲ្យបង្អោនទៅកាន់អារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **នាម** ។

ធម្មជាតណា រមែងបែកធ្លាយទៅ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **រូប** ។

ធម្មជាតណា រមែងផ្សាយទៅក្នុងចិត្ត និងចេតសិក ដែលជាទីកើត និងនាំទៅកាន់សង្សារទុក្ខ ដែលអូសបន្លាយតទៅ ព្រោះហេតុនោះ ធម្មជាតនោះ

ឈ្មោះថា **អាយតនៈ** ។ ធម្មជាតណា រមែងពាល់ត្រូវ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ផស្សៈ** ។

ធម្មជាតណា រមែងសោយអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វេទនា** ។

ធម្មជាតណា រមែងចង់បានក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **តណ្ហា** ។

ធម្មជាតណា រមែងចូលទៅប្រកាន់ក្នុងអារម្មណ៍ គឺរមែងប្រកាន់យ៉ាងមាំ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ឧបាទាន** ។

ធម្មជាតណា រមែងមាន គឺរមែងកើត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ភព** ។

ការកើត ឈ្មោះថា **ជាតិ** ។ ការចាស់ ឈ្មោះថា **ជរា** ។ សត្វទាំងឡាយ រមែងស្លាប់ដោយធម្មជាតនោះ ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា **មរណៈ** ។

[ ១០ ] ព្រះសារីបុត្ត បានសម្តែងដល់ការវិសជ្ជនា ៨០៨ ប្រការ មានទុក្ខជាដើមដោយប្រកបចូលគ្នាជាមួយនឹងអរិយសច្ច ៤ ។ ព្រះសារីបុត្តពោលប្រមូលការវិសជ្ជនា ២៤ យ៉ាង ដោយចតុក្កៈ ៦ ក្នុងពាក្យជាដើមថា **ទុក្ខំ អភិញ្ញេយ្យំ** ក្នុងបេយ្យាលៈថា **ចក្ខុ ។បេ។ ជរាមរណំ** ព្រះសារីបុត្តពោលវិសជ្ជនាប្រកបដោយវិសជ្ជនា ១៩៥ មានពាក្យថា **ចក្ខុំ អភិញ្ញេយ្យំ សោតំ អភិញ្ញេយ្យំ** ជាដើម មានពាក្យថា **ជាតិ អភិញ្ញេយ្យា** ជាទីបំផុត

*ទើបបាន ១៩៥ ចតុក្កៈដោយអំណាចចតុក្កៈទាំងនោះ ទើបជាវិសជ្ជនា ៧៨០ ។ ក្នុងចតុក្កៈ មានពាក្យថា* **ជរាមរណំ អភិញ្ញេយ្យំ** *ជាដើម បានវិសជ្ជនា ៤ ប្រការទៀត ហេតុនោះ ទើបមានវិសជ្ជនា ៨០៨ ដោយប្រការដូច្នេះ ។*

*ម្យ៉ាងទៀត ក្នុងការវិសជ្ជនានេះគប្បីជ្រាបថា បច្ច័យដែលជាប្រធាននៃធម៌នោះៗ ជាសមុទយៈ និព្វានទទេទោកសង្ខារទាំងពួង ជានិរោធ ។ ក្នុងអធិការនេះ បទថា* **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយនិរោធោ** *ជាដើម សំដៅយកការមិនមានឥន្ទ្រិយដែលជាលោកុត្តរ ៣ ប្រការ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម រមែងត្រឹមត្រូវ ។ បទថា* **និរោធគាមិនីបដិបទា** *ក្នុងទីគ្រប់អន្លើ ជាអរិយមគ្គទាំងអស់ ។ ដោយប្រការដូច្នេះ កាលពោលដល់ផល បទថា* **និរោធគាមិនីបដិបទា** *រមែងប្រើបានសូម្បីដល់អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ព្រោះបានការហៅថា មគ្គ ។ ព្រះសារីបុត្តបានសម្ដែងដល់ការវិសជ្ជនា ៨០៨ ប្រការ ដោយសភាពដែលគួរកំណត់ដឹងជាដើមនៃទុក្ខជាដើម ដដែលទៀត ។ លោកបានសម្ដែងដល់ការវិសជ្ជនា ៨០៨ ប្រការ ដោយសភាពដែលគួរកំណត់ដឹង និងចាក់ធ្លុះជាដើមនៃទុក្ខជាដើមទៀត ។ ការកំណត់ដឹងផង ការចាក់ធ្លុះដោយអត្ថថា គួរចាក់ធ្លុះផង ឈ្មោះថា បរិញ្ញាបដិវេធ ។ អត្ថ គឺបរិញ្ញា-បដិវេធនោះឯង ឈ្មោះថា ដោយសភាពដែលគួរកំណត់ដឹង និងចាក់ធ្លុះ ។*

*[ ១១-១៤ ] ព្រះសារីបុត្តប្រកបបទ ២០២ មានទុក្ខជាដើម មានជរាមរណៈជាទីបំផុត ទាំងនោះឯង ដោយបទនីមួយៗ ៧ មានសមុទយៈជាដើម សម្ដែងដល់វិសជ្ជនា ១៦១៦ ដោយអំណាចអដ្ឋកៈ ( ពួក ៨ ) ២០២ ទៀត ។*

ក្នុងអធិការនោះ បច្ច័យដែលជាប្រធាន គឺសមុទ័យ ការរម្ងាត់សមុទ័យនោះ ឈ្មោះថា **សមុទយនិរោធោ** ។ តម្រេក គឺការពេញចិត្ត ឈ្មោះថា **ឆន្ទរាគ** តម្រេក គឺការពេញចិត្តក្នុងទុក្ខដោយសម្គាល់ក្នុងទុក្ខថាជាសុខ សេចក្ដីរលត់តម្រេក គឺការពេញចិត្តក្នុងទុក្ខនោះ ឈ្មោះថា **ឆន្ទរាគនិរោធោ** ។ សុខសោមនស្សកើតឡើង ព្រោះអាស្រ័យទុក្ខ ឈ្មោះថា **ទុក្ខស្ស អស្សាទោ** ។ ភាពមិនទៀងនៃទុក្ខ ភាពប្រែប្រួលទៅជាធម្មតានៃទុក្ខ ឈ្មោះថា **ទុក្ខស្ស អាទីនវោ** ។ ការនាំចេញនូវឆន្ទរាគៈ ការលះបង់ឆន្ទរាគៈក្នុងទុក្ខ ឈ្មោះថា **ទុក្ខស្ស និសរណំ** ។ និព្វាននោះឯង គឺឧបាយជាគ្រឿងរលាស់ចេញចាកទុក្ខ ព្រោះបាលីថា ធម្មជាតណាដែលកើតហើយ ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យបច្ច័យ ការរលត់ ការរលាស់ចោលនូវធម្មជាតនោះ[1] ។ គប្បីជ្រាបថា លោកពោលដល់និព្វានក្នុងឋានៈ ៤ យ៉ាង ដោយពាក្យដែលមានបរិយាយផ្សេងៗ ដោយផ្ទុយគ្នាជាមួយនឹងសង្ខតធម៌ផ្សេងៗ ថា ការរលត់ទុក្ខ ការរលត់សមុទ័យ ការរលត់ឆន្ទរាគៈជាឧបាយគ្រឿងរលាស់ចេញចាកទុក្ខ ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រោះអាហារជាដើមហេតុ ទើបទុក្ខកើត ព្រោះរលត់អាហារ ទើបទុក្ខរលត់ ការរលត់សមុទ័យមានដោយអំណាចនៃកិច្ចរបស់ខ្លួន ម្យ៉ាងទៀត ការរលត់សមុទ័យ មានដោយការឃើញការកើត និងការរលត់មគ្គ មួយអន្លើដោយវិបស្សនា ឈ្មោះថា ការរម្ងាត់ឆន្ទរាគៈ ។ កាលលោកពោលយ៉ាងនេះ គប្បីកាន់យកន័យដែលពោលខាងដើមថា ការរលត់

---

១- បិដកខ្មែរ លេខ ៦៩ ឃ្នាប ៦៥ ។

*សមុទ័យដោយអំណាចនៃកិច្ចរបស់ខ្លួន មិនទាន់ជាសព្វសាធារណៈ ព្រោះឥន្ទ្រិយដែលជាលោកុត្តរ មិនទាន់ចូលដល់វិបស្សនា ។ ន័យដែលលោកពោលថា ការរលត់ធន្ទរាគៈ ព្រោះមិនមានធន្ទរាគៈក្នុងឥន្ទ្រិយដែលជា លោកុត្តរនោះឯង ទើបត្រឹមត្រូវ ។ ធន្ទរាគៈក្នុងសក់ជាដើម ដែលជាចំណែកមួយនៃសរីរៈ ឈ្មោះថា ធ្វើហើយនោះឯងដោយធន្ទរាគៈក្នុងសរីរៈនោះឯង ធន្ទរាគៈក្នុងជរា និងមរណៈ ក៏ឈ្មោះថាធ្វើហើយនោះឯង ដោយធន្ទរាគៈក្នុងកោដ្ឋាសដែលមានជរា និងមរណៈដោយពិត ។ គប្បីប្រកបការត្រេកអរ និងទោសយ៉ាងនេះ ។ ព្រះសារីបុត្ត ប្រកបបទ ២០២ មានទុក្ខជាដើម មានជរាមរណៈជាទីបំផុត ដោយបទនីមួយៗ ៦ មានសមុទយៈជាដើមហើយសម្តែងវិសជ្ជនា ១៤១៤ ន័យ ដោយអំណាចសត្តកៈ ( ពួក ៧ ) ២០២ ។*

*[ ១៥ ] ឥឡូវនេះ ដើម្បីសម្តែងប្រកបបទ ២០១ មានរូបជាដើម មានជរាមរណៈជាទីបំផុត ដោយអនុបស្សនា ៧ ទើបព្រះសារីបុត្តសម្តែងអនុ-បស្សនា ៧ មានអនិច្ចានុបស្សនាជាដើមមុន ។ ទើបទាំងអស់នោះជាវិសជ្ជនា ១៤១៤ ន័យ ព្រមទាំងការវិសជ្ជនាអនុបស្សនាសុទ្ធ ៧ ប្រការ ។ ការពិចារណាឃើញថា មិនទៀង ឈ្មោះថា* **អនិច្ចានុបស្សនា** *។ អនិច្ចានុបស្សនានោះជាបដិបក្ខចំពោះនិច្ចសញ្ញា ។ ការពិចារណាឃើញថាជាទុក្ខ ឈ្មោះថា* **ទុក្ខានុ-បស្សនា** *។ ទុក្ខានុបស្សនានោះជាបដិបក្ខចំពោះសុខសញ្ញា ។ ការពិចារណាឃើញថាជាអនត្តា ឈ្មោះថា* **អនត្តានុបស្សនា** *។ អនត្តានុបស្សនានោះជាបដិបក្ខចំពោះអត្តសញ្ញា ។ ធម្មជាតណា រមែងនឿយណាយ ព្រោះអនុបស្សនា*

*៣ បរិបូរណ៍ ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា និព្វិទា និព្វិទានោះផង អនុបស្សនាផង ឈ្មោះថា* **និព្វិទានុបស្សនា ។** *និព្វិទានុបស្សនានោះជាបដិបក្ខចំពោះនន្ទិ ។ ធម្មជាតណា រមែងប្រាសចាកតម្រេក ព្រោះអនុបស្សនា ៤ បរិបូរណ៍ ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា វិរាគៈ វិរាគៈនោះផង អនុបស្សនានោះផង ឈ្មោះថា* **វិរាគានុបស្សនា ។** *វិរាគានុបស្សនានោះជាបដិបក្ខចំពោះរាគៈ ។ ធម្មជាតណា រមែងរម្ងាត់រាគៈបាន ព្រោះអនុបស្សនា ៥ បរិបូរណ៍ ព្រោះហេតុនោះ ទើបធម្មជាតនោះឈ្មោះថា និរោធ ។ និរោធនោះផង អនុបស្សនាផង ឈ្មោះថា* **និរោធានុបស្សនា ។** *និរោធានុបស្សនានោះជាបដិបក្ខចំពោះសមុទយៈ ។ ធម្មជាតណា រមែងលះបង់បានព្រោះអនុបស្សនា ៦ បរិបូរណ៍ ព្រោះហេតុនោះ ទើបធម្មជាតនោះ ឈ្មោះថា បដិនិស្សគ្គ បដិនិស្សគ្គនោះផង អនុបស្សនាផង ឈ្មោះថា* **បដិនិស្សគ្គានុបស្សនា ។** *បដិនិស្សគ្គានុបស្សនានោះ ជាបដិបក្ខចំពោះអាទានៈ ( ការប្រកាន់ ) ។ សូម្បីមិនទាន់មានលោកុត្តរ ឥន្ទ្រិយដែលចូលដល់វិបស្សនា ក៏គប្បីជ្រាបថា លោកប្រកបអនុបស្សនា ៧ ដោយធម៌ទាំងនោះ ដោយពិចារណាឃើញថា ឈ្មោះថា មាននិរោធ ព្រោះមិនមាននន្ទិ និងរាគៈក្នុងវត្ថុដែលសម្គាល់ថាទៀង ជាសុខ ជាតួខ្លួន ព្រោះវត្ថុទាំងនោះជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដូចបាលីថា* **សព្វេ សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តា** *និង ព្រោះមានការលះបង់ដោយការបរិច្ចាគ ការលះបង់ដោយការស្ទុះទៅ ។ កាលឃើញកោដ្ឋាសដែលមានជរាមរណៈ ដោយភាពជារបស់មិនទៀងជាដើមហើយ*

ឈ្មោះថា ឃើញជរាមរណៈថា ជារបស់មិនទៀងជាដើម កាលនឿយណាយប្រាសចាកតម្រេកក្នុងកោដ្ឋាសដែលមានជរាមរណៈ ឈ្មោះថា នឿយណាយនិងប្រាសចាកតម្រេកក្នុងជរាមរណៈ កាលឃើញកោដ្ឋាសដែលមានជរាមរណៈដោយនិរោធ ឈ្មោះថា ឃើញជរាមរណៈដោយនិរោធកាលលះបង់ក្នុងកោដ្ឋាសដែលមានជរាមរណៈ រមែងឈ្មោះថា លះបង់ជរាមរណៈដោយពិត គប្បីជ្រាបថា លោកប្រកបអនុបស្សនា ៧ ដោយជរាមរណៈ ដោយប្រការដូច្នេះ ។

[ ១៦-២៩ ] ឥឡូវនេះ ព្រះសារីបុត្តបានសម្តែងដល់វិសជ្ជនា ១៥ មាន **ឧប្បាទោ** ជាដើម ដែលជាវេវចនៈរបស់ធម៌ទាំងនោះ ដោយអំណាចអារម្មណ៍ ៥ មានការកើតឡើងជាដើម ដែលជាវត្ថុនៃអាទីនវញ្ញាណ សម្តែងវិសជ្ជនា ១៥ មាន **អនុប្បាទោ** ជាដើម ដោយអំណាចអារម្មណ៍ ដែលជាបដិបក្ខចំពោះធម៌នោះនៃសន្តិបទញ្ញាណ ប្រកបបទមានការកើតឡើង និងការមិនកើតឡើងជាដើមទាំងនោះដោយអំណាចជាគូគ្នាហើយសម្តែងវិសជ្ជនា ៣០ ទៀត ។ ដោយប្រការដូច្នេះ ទើបជាវិសជ្ជនា ៦០ ក្នុងន័យនេះឯង ។

ក្នុងបទទាំងនោះ បទថា **ឧប្បាទោ** បានដល់ ការកើតក្នុងភពនេះ ព្រោះកម្មមុនជាបច្ច័យ ។

បទថា **បវត្តំ** បានដល់ ការប្រព្រឹត្តទៅនៃការកើតយ៉ាងនោះ ។

បទថា **និមិត្តំ** បានដល់ គ្រឿងសម្គាល់សង្ខារទាំងអស់ ។ ព្រោះសង្ខារទាំងឡាយ រមែងប្រាកដដល់ព្រះយោគាវចរ ដូចមានទ្រង់ទ្រាយ ព្រោះហេតុនោះ ទើបពោលថា **និមិត្តំ** ។

បទថា **អាយូហនា** បានដល់ កម្មដែលជាហេតុនៃបដិសន្ធិតទៅ កម្មនោះ លោកហៅថា **អាយូហនា** ព្រោះអត្ថថា តាក់តែងបដិសន្ធិ ។

បទថា **បដិសន្ធិ** បានដល់ ការកើតឡើងតទៅ ។ ការកើតឡើងនោះ លោកហៅថា បដិសន្ធិ ព្រោះបន្តគ្នាក្នុងរវាងភព ។

បទថា **គតិ** បានដល់ គតិដែលឲ្យបដិសន្ធិ ហៅថា គតិ ព្រោះសត្វត្រូវទៅ ។

បទថា **និព្វត្តិ** បានដល់ ការកើតឡើងនៃខន្ធទាំងឡាយ ។

បទថា **ឧបបត្តិ** បានដល់ ការប្រព្រឹត្តទៅនៃវិបាកដែលពោលយ៉ាងនេះថា ធម៌ទាំងឡាយ គឺចិត្ត និងចេតសិកណា របស់អ្នកចូលកាន់សមាបត្តិក្តី របស់អ្នកកើតក្នុងព្រហ្មលោកក្តី ដូច្នេះ ។

បទថា **ជាតិ** បានដល់ ការកើត គឺការប្រាកដគ្រាដំបូងនៃខន្ធរបស់សត្វទាំងឡាយដែលកើតក្នុងភពនោះៗ ។

បទថា **ជរា** បានដល់ ការគ្រាំគ្រា ។ ជរានោះមាន ២ យ៉ាង គឺសង្ខតលក្ខណៈ បានដល់ លក្ខណៈដែលតាំងនៅ និងយ៉ាងដទៃ ១ ភាពចាស់នៃខន្ធដែលទាក់ទងក្នុងភពមួយ ក្នុងសន្តតិដែលសន្មតថា ធ្មេញបាក់ជាដើម ១ ។ ក្នុងទីនេះ លោកបំណងយកជរានោះ ។

បទថា **ព្យាធិ** បានដល់ អាពាធ ៨ យ៉ាង ដែលតាំងឡើង ព្រោះធាតុកម្រើកជាបច្ច័យ គឺប្រមាត់ ១ ស្លេស្ម ១ ខ្យល់ ១ ប្រមាត់ស្លេស្មខ្យល់ប្រជុំគ្នា ១ ការប្រែប្រួលរដូវ ១ ការប្រព្រឹត្តទៅនៃរាងកាយមិនស្មើ ១ ព្យាយាម

ខ្លាំងពេក ១ វិបាករបស់កម្ម ១ ។ ឈ្មោះថា ព្យាធិ ព្រោះទុក្ខច្រើនយ៉ាងដុតរោល ចោមរោម ឬឈ្មោះថា ព្យាធិ ព្រោះទុក្ខបៀតបៀន ឲ្យក្តៅក្រហាយឲ្យញាប់ញ័រ ។

បទថា **មរណំ** មានវិគ្គហៈថា សត្វទាំងឡាយ រមែងស្លាប់ដោយធម្មជាតនោះ ហេតុនោះ ទើបឈ្មោះថាមរណៈ ។ មរណៈមាន ២ យ៉ាង គឺសង្ខតលក្ខណៈដែលមានសេចក្តីវិនាសជាលក្ខណៈ ១ ការកាត់ផ្តាច់នូវការទាក់ទងគ្នានៃជីវិតិន្ទ្រិយដែលទាក់ទងក្នុងភពមួយ ១ ។ ក្នុងទីនេះ បំណងយកមរណៈនោះ ។

បទថា **សោកោ** បានដល់ ការរីងស្ងួតនៃចិត្ត គឺការក្តៅក្រហាយចិត្តរបស់បុគ្គលដែលត្រូវសេចក្តីវិនាសចាកញាតិ សម្បត្តិ រោគ សីល និងទិដ្ឋិប៉ះខ្ទប់ ។

បទថា **បរិទេវោ** បានដល់ យំរៀបរាប់ គឺការយំរៀបរាប់របស់បុគ្គលដែលត្រូវសេចក្តីវិនាសចាកញាតិជាដើមប៉ះខ្ទប់ ។

បទថា **ឧបាយាសោ** បានដល់ ការតានតឹងចិត្តខ្លាំង គឺទោសៈដែលកើតអំពីទុក្ខផ្លូវចិត្តដ៏ធ្ងន់របស់បុគ្គល ដែលត្រូវសេចក្តីវិនាសចាកញាតិជាដើមនោះឯងប៉ះខ្ទប់ ។

ក្នុងនិទ្ទេសនេះ លោកពោលអភិញ្ញេយ្យធម៌ ៥ មាន **ឧប្បាទោ** ជាដើមដោយអំណាចជាវត្ថុនៃអាទីនវញ្ញាណដ៏សេស លោកពោលដោយអំណាចជាវេវចនៈ របស់អភិញ្ញេយ្យធម៌ទាំងនោះ ។ បទថា **និព្វត្តិ** ជាវេវចនៈរបស់**ឧប្បាទោ** ។ បទថា **ជាតិ** ជាវេវចនៈរបស់ **បដិសន្ធិ** ។ ពីរបទថា **គតិ**

**ឧបបត្តិ** ជាវេវចនៈរបស់ **បវត្តំ ។ ជរា** ជាដើម ជាវេវចនៈរបស់ **និមិត្តំ ។** លោកពោលនិព្វានប៉ុណ្ណោះដោយពាក្យថា **អនុប្បាទោ** ជាដើម ។ ព្រះសារីបុត្ត ប្រកបបទ ៦០ មានឧប្បាទ និងអនុប្បាទជាដើមនោះឯង ដោយបទថា ទុក្ខ និងសុខ ហើយសម្តែងវិសជ្ជនា ៦០ ទៀត ប្រកបដោយបទថា ភ័យ និងក្សេម ហើយសម្តែងវិសជ្ជនា ៦០ ប្រកបដោយបទថា សាមិសៈ និងនិរាមិសៈ ហើយសម្តែងវិសជ្ជនា ៦០ ប្រកបដោយបទថា សង្ខារ និងនិព្វាន ហើយ សម្តែងវិសជ្ជនា ៦០ ។

ក្នុងបទទាំងនោះ បទថា **ទុក្ខំ** បានដល់ ឈ្មោះថា **ទុក្ខ** ព្រោះជារបស់ មិនទៀង ។ ឈ្មោះថា **សុខ** ព្រោះផ្ទុយគ្នាជាមួយនឹងទុក្ខ ។ វត្ថុណាជាទុក្ខ វត្ថុនោះជា **ភយំ ។** ឈ្មោះថា **ខេមំ** ព្រោះផ្ទុយគ្នាជាមួយនឹង **ភយំ ។** វត្ថុណាជាភ័យ វត្ថុនោះ ឈ្មោះថា **សាមិសំ** ព្រោះមិនផុតទៅអំពីវដ្តាមិសៈ និង លោកាមិសៈ ឈ្មោះថា **និរាមិសំ** ព្រោះផ្ទុយគ្នាជាមួយនឹង **សាមិសំ ។** វត្ថុណាជា **សាមិសំ** វត្ថុនោះត្រឹមតែជាសង្ខារប៉ុណ្ណោះ ។ ឈ្មោះថា **និព្វាន** ព្រោះ ស្ងប់ចាកវត្ថុផ្ទុយគ្នាជាមួយនឹងសង្ខារ ។ ដ្បិតថា សង្ខារជារបស់ក្តៅ និព្វានជា របស់ស្ងប់ ។ គប្បីជ្រាបថា លោកពោលយ៉ាងនោះ សំដៅដល់ការប្រព្រឹត្ត ទៅដោយអាការនោះៗ យ៉ាងនេះថា ដោយអាការដែលជាទុក្ខ ដោយអាការ ដែលជាភ័យ ដោយអាការដែលមានអាមិសៈ ដោយអាការដែលជាសង្ខារ ដោយប្រការដូច្នេះ ។

# សុត្តន្តបិដក

[ ៣០ ] អត្ថនៃធម៌ដែលគួរកំណត់កាន់យក បុគ្គលត្រូវដឹងច្បាស់ អត្ថនៃធម៌ជាបរិវារត្រូវដឹងច្បាស់ អត្ថនៃធម៌គួរបំពេញត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលតាំងនៅក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងត្រូវដឹងច្បាស់ អត្ថនៃការមិនរាត់រាយត្រូវដឹងច្បាស់ អត្ថនៃការមិនកករល្អក់ត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រត្រូវដឹងច្បាស់ អត្ថនៃការតាំងស៊ប់របស់ចិត្តដោយអំណាចនៃការតាំងនៅក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃអារម្មណ៍ត្រូវដឹងច្បាស់ អត្ថនៃការត្រាច់ទៅរបស់អារម្មណ៍ត្រូវដឹងច្បាស់ អត្ថនៃការលះបោលត្រូវដឹងច្បាស់ អត្ថនៃការបរិច្ចាគត្រូវដឹងច្បាស់ អត្ថនៃការចេញចាកកិលេសត្រូវដឹងច្បាស់ អត្ថនៃការប្រែត្រឡប់ត្រូវដឹងច្បាស់ អត្ថនៃការស្ងប់រម្ងាប់ត្រូវដឹងច្បាស់ អត្ថនៃធម៌ដ៏ឧត្តមត្រូវដឹងច្បាស់ អត្ថនៃការផុតស្រឡះចាកអារម្មណ៍ត្រូវដឹងច្បាស់ អត្ថនៃការមិនមានអាសវៈត្រូវដឹងច្បាស់ អត្ថនៃការឆ្លងត្រូវដឹងច្បាស់ អត្ថនៃការមិនមានសង្ខារនិមិត្តត្រូវដឹងច្បាស់ អត្ថនៃការមិនតម្កល់ទុកនូវតណ្ហាត្រូវដឹងច្បាស់ អត្ថនៃសភាពសោះសូន្យត្រូវដឹងច្បាស់ អត្ថនៃសភាពមានរសតែមួយត្រូវដឹងច្បាស់ អត្ថនៃការមិនប្រព្រឹត្តកន្លង ( ទៅវិញទៅមករបស់សមថៈ និងវិបស្សនា ) ត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលជាប់គ្នាជាគូត្រូវដឹងច្បាស់ អត្ថនៃការចេញ ( ចាកសង្ខារ ) ត្រូវដឹងច្បាស់ អត្ថនៃការញុំាងសត្វឲ្យដល់ ( នូវព្រះនិព្វាន ) ត្រូវដឹងច្បាស់ អត្ថនៃការឃើញជាក់ស្តែង ( នូវព្រះនិព្វាន ) ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាអធិបតីត្រូវដឹងច្បាស់ ។

[ ៣១ ] អត្ថនៃការមិនរាយមាយរបស់សមថៈត្រូវដឹងច្បាស់ អត្ថនៃការឃើញរឿយៗ របស់វិបស្សនាត្រូវដឹងច្បាស់ អត្ថនៃរសតែមួយរបស់សមថៈនិងវិបស្សនាត្រូវដឹងច្បាស់ អត្ថនៃការមិនប្រព្រឹត្តកន្លងរបស់ធម៌ដែលជាប់គ្នាជាគូត្រូវដឹងច្បាស់ អត្ថនៃការសមាទានក្នុងសិក្ខាត្រូវដឹងច្បាស់ អត្ថនៃគោចររបស់អារម្មណ៍ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់ចិត្តដែលរួញរាត្រូវដឹងច្បាស់ អត្ថនៃការស្ងប់ស្ងៀមរបស់ចិត្តដែលអណ្តែតអណ្តូងត្រូវដឹងច្បាស់ អត្ថនៃការព្រងើយកន្តើយរបស់ចិត្ត ដ៏បរិសុទ្ធចាកចំណែកទាំងពីរត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងនូវគុណវិសេសត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវធម៌ដ៏ក្រៃលែងត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងនូវសច្ចៈ ៤ ត្រូវដឹងច្បាស់ អត្ថនៃការញុំាងចិត្តឲ្យស្ថិតនៅក្នុងនិរោធត្រូវដឹងច្បាស់ ។

[ ៣២ ] អត្ថនៃការជឿស៊ប់របស់សទ្ធិន្ទ្រិយ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើង របស់វីរិយិន្ទ្រិយត្រូវដឹងច្បាស់ អត្ថនៃការប្រុងប្រយ័ត្នរបស់សតិន្ទ្រិយត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់សមាធិន្ទ្រិយត្រូវដឹងច្បាស់ អត្ថនៃការឃើញរបស់បញ្ញិន្ទ្រិយត្រូវដឹងច្បាស់ ។

[ ៣៣ ] អត្ថនៃការមិនញាប់ញ័រ ដោយការមិនជឿរបស់សទ្ធាពលបុគ្គលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រដោយសេចក្តីខ្ជិលច្រអូសរបស់វីរិយពលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រដោយសេចក្តីប្រមាទរបស់សតិពលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រ ដោយការអណ្តែតអណ្តូងរបស់សមាធិពលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រ ដោយសេចក្តីល្ងង់

របស់បញ្ញាពលត្រូវដឹងច្បាស់ ។

[ ៣៤ ] អត្ថនៃការប្រុងប្រយ័ត្នរបស់សតិសម្ពោជ្ឈង្គ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការពិចារណា របស់ធម្មវិចយសម្ពោជ្ឈង្គត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់វីរិយសម្ពោជ្ឈង្គត្រូវដឹងច្បាស់ សភាពផ្សព្វផ្សាយរបស់បីតិសម្ពោជ្ឈង្គត្រូវដឹងច្បាស់ អត្ថនៃការស្ងប់រម្ងាប់របស់បស្សទ្ធិសម្ពោជ្ឈង្គត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់សមាធិសម្ពោជ្ឈង្គត្រូវដឹងច្បាស់ អត្ថនៃការត្រួតត្រារបស់ឧបេក្ខាសម្ពោជ្ឈង្គត្រូវដឹងច្បាស់ ។

[ ៣៥ ] អត្ថនៃការឃើញរបស់សម្មាទិដ្ឋិ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការលើកចិត្តឡើង របស់សម្មាសង្កប្បត្រូវដឹងច្បាស់ អត្ថនៃការកំណត់នូវវចីសំវរៈ ៤ របស់សម្មាវាចាត្រូវដឹងច្បាស់ អត្ថនៃការតាំងឡើងរបស់សម្មាកម្មន្តៈត្រូវដឹងច្បាស់ អត្ថនៃការផូរផង់របស់សម្មាអាជីវៈត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់សម្មាវាយាមៈត្រូវដឹងច្បាស់ អត្ថនៃការប្រុងប្រយ័ត្នរបស់សម្មាសតិត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់សម្មាសមាធិត្រូវដឹងច្បាស់ ។

[ ៣៦ ] អត្ថនៃភាពជាធំរបស់ឥន្ទ្រិយទាំងឡាយ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រ របស់ពលទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការចេញចាកធម៌ជាសត្រូវរបស់ពោជ្ឈង្គទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការញុំាងសត្វឲ្យដល់ ( នូវព្រះនិព្វាន ) របស់មគ្គត្រូវដឹងច្បាស់ អត្ថនៃការប្រុងប្រយ័ត្នរបស់សតិប្បដ្ឋានទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការតម្កល់ទុករបស់សម្មប្បធានទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់ឥទ្ធិបាទទាំងឡាយ

ត្រូវដឹងច្បាស់ អត្ថនៃការទៀងរបស់សច្ចៈទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការស្ងប់រម្ងាប់របស់បយោគទាំងឡាយ គឺអរិយមគ្គត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់របស់ផលទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការលើកចិត្តឡើងរបស់វិតក្កត្រូវដឹងច្បាស់ អត្ថនៃការពិចារណារបស់វិចារត្រូវដឹងច្បាស់ អត្ថនៃការផ្សាយទៅរបស់បីតិត្រូវដឹងច្បាស់ អត្ថនៃការហូរមករបស់សុខត្រូវដឹងច្បាស់ អត្ថនៃការតម្កល់នឹងក្នុងអារម្មណ៍តែមួយរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការរំពឹងរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការដឹងផ្សេងៗ ( របស់វិញ្ញាណ ) ត្រូវដឹងច្បាស់ អត្ថនៃការដឹងសព្វ ( របស់បញ្ញា ) ត្រូវដឹងច្បាស់ អត្ថនៃការដឹងព្រម ( របស់បញ្ញា ) ត្រូវដឹងច្បាស់ អត្ថនៃការខ្ពស់ឯក គឺសមាធិត្រូវដឹងច្បាស់ ។

[ ៣៧ ] អត្ថនៃការដឹងរបស់អភិញ្ញា បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការត្រិះរិះរបស់បរិញ្ញាត្រូវដឹងច្បាស់ អត្ថនៃការលះរបស់បហានៈត្រូវដឹងច្បាស់ អត្ថនៃរសតែមួយរបស់ភាវនាត្រូវដឹងច្បាស់ អត្ថនៃការពាល់ត្រូវរបស់សច្ឆិកិរិយាត្រូវដឹងច្បាស់ អត្ថនៃការទ្រទ្រង់នូវអវយវៈ ( ដោយកិច្ចទាំងឡាយមាននាំមកនូវភារៈដ៏លំបាកជាដើម ) របស់ខន្ធទាំងឡាយត្រូវដឹងច្បាស់ អត្ថនៃការទ្រទ្រង់ ( ដោយកិច្ចមានសោះសូន្យជាដើម ) របស់ពួកធាតុត្រូវដឹងច្បាស់ អត្ថនៃអណ្តូងរបស់ពួកអាយតនៈត្រូវដឹងច្បាស់ អត្ថនៃបច្ច័យតាក់តែងរបស់ពួកសង្ខតធម៌ត្រូវដឹងច្បាស់ អត្ថនៃបច្ច័យមិនតាក់តែងរបស់អសង្ខតធម៌ត្រូវដឹងច្បាស់ ។

[ ៣៨ ] អត្ថនៃការគិតនូវអារម្មណ៍ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃចិត្តមិនមានចន្លោះត្រូវដឹងច្បាស់ អត្ថនៃការចេញរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការវិលត្រឡប់របស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃហេតុរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃបច្ច័យរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃវត្ថុរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃភូមិរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃអារម្មណ៍របស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃគោចររបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការត្រាច់ទៅរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃដំណើររបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការប្រមូលរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការចេញចាកវដ្តៈរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការរលាស់ចេញរបស់ចិត្តត្រូវដឹងច្បាស់ ។

[ ៣៩ ] អត្ថនៃការរំពឹងក្នុងអារម្មណ៍តែមួយ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការដឹងច្បាស់ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការដឹងសព្វក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការដឹងព្រម ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការខ្ពស់ឯកក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការចងក្រៀកទុកក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការស្ទុះទៅក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការជ្រះថ្លាក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការតាំងនៅព្រមក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការផុតស្រឡះក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់ ក្នុងអារម្មណ៍តែមួយថាទុំះជាទីស្ងប់រម្ងាប់ត្រូវដឹងច្បាស់ អត្ថនៃការធ្វើដូចជាយានក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការធ្វើដូចជាវត្ថុ ជាទីតាំង ក្នុងអារម្មណ៍តែមួយ

ត្រូវដឹងច្បាស់ អត្ថនៃការតាំងនៅស៊ប់ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការសន្សំក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការប្រារព្ធព្យាយាមល្អក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការកំណត់កាន់យកក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃធម៌ជាបរិវារក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលត្រូវបំពេញ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការប្រជុំចុះក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការតាំងចិត្តមាំក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការថ្មីកក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការចម្រើនក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃកាធ្វើឲ្យច្រើនក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការអណ្តែតឡើងក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការផុតស្រឡះក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងរឿយៗ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងចំពោះ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងព្រមក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការញុំាងជនឲ្យត្រាស់ដឹងក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការញុំាងជនឲ្យត្រាស់ដឹងរឿយៗ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការញុំាងជនឲ្យត្រាស់ដឹងចំពោះក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការញុំាងជនឲ្យត្រាស់ដឹងព្រម ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកការត្រាស់ដឹងក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកការត្រាស់ដឹងរឿយៗ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែក

ការត្រាស់ដឹងចំពោះក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹងព្រម ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការទ្រោលបំភ្លឺក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺរឿយៗ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺចំពោះ ក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺព្រមក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ ។

[ ៤០ ] អត្ថនៃការញ៉ាំងជនឲ្យភ្លឺច្បាស់ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការរុងរឿងត្រូវដឹងច្បាស់ អត្ថនៃការញ៉ាំងកិលេសឲ្យក្តៅសព្វត្រូវដឹងច្បាស់ អត្ថនៃធម៌មិនមានមន្ទិលត្រូវដឹងច្បាស់ អត្ថនៃធម៌ប្រាសចាកមន្ទិលត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលគ្មានមន្ទិលត្រូវដឹងច្បាស់ អត្ថនៃសភាពស្មើត្រូវដឹងច្បាស់ អត្ថនៃការលះកិលេសត្រូវដឹងច្បាស់ អត្ថនៃការស្ងប់ស្ងាត់ត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការស្ងប់ស្ងាត់ត្រូវដឹងច្បាស់ អត្ថនៃការប្រាសចាករាគៈត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការប្រាសចាករាគៈត្រូវដឹងច្បាស់ អត្ថនៃការរលត់ទុក្ខត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការរលត់ទុក្ខត្រូវដឹងច្បាស់ អត្ថនៃការលះកិលេសត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការលះកិលេសត្រូវដឹងច្បាស់ អត្ថនៃការរួចចាកកិលេសត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការរួចចាកកិលេសត្រូវដឹងច្បាស់ ។

[ ៤១ ] អត្ថនៃឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃមូលរបស់ឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្ររបស់ឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់របស់ឆន្ទៈត្រូវដឹង

*ច្បាស់ អត្ថនៃការសម្រេចរបស់ឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃការជឿស៊ប់របស់ឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់ឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃការតម្កល់របស់ឆន្ទៈត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់ឆន្ទៈត្រូវដឹងច្បាស់ ។*

*[ ៤២ ] អត្ថនៃវីរិយៈ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃមូលរបស់វីរិយិន្ទ្រិយត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្រទ្រង់របស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់របស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃការជឿស៊ប់របស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃការតាំងខ្ជាប់របស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់វីរិយៈត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់វីរិយៈត្រូវដឹងច្បាស់ ។*

*[ ៤៣ ] អត្ថនៃចិត្ត ( ការគិតនូវអារម្មណ៍ ) ត្រូវដឹងច្បាស់ អត្ថនៃមូលរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្រទ្រង់របស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់របស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការចុះចិត្តស៊ប់របស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការតាំងខ្ជាប់របស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់ចិត្តត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់ចិត្តត្រូវដឹងច្បាស់ ។*

*[ ៤៤ ] អត្ថនៃវីមំសាត្រូវដឹងច្បាស់ អត្ថនៃមូលរបស់វីមំសាត្រូវដឹងច្បាស់*

អត្ថនៃគ្រឿងទ្រទ្រង់របស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់របស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃគ្រឿងសម្រេចរបស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃការចុះចិត្តស៊ប់របស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃការតាំងខ្ជាប់របស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់វីមំសាត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់វីមំសាត្រូវដឹងច្បាស់ ។

[ ៤៥ ] អត្ថនៃទុក្ខត្រូវដឹងច្បាស់ អត្ថនៃការបៀតបៀនរបស់ទុក្ខត្រូវដឹងច្បាស់ អត្ថនៃការតាក់តែងរបស់ទុក្ខត្រូវដឹងច្បាស់ អត្ថនៃការក្តៅសព្វរបស់ទុក្ខត្រូវដឹងច្បាស់ អត្ថនៃការប្រែប្រួលរបស់ទុក្ខត្រូវដឹងច្បាស់ អត្ថនៃសមុទ័យត្រូវដឹងច្បាស់ អត្ថនៃការប្រមូលមករបស់សមុទ័យត្រូវដឹងច្បាស់ អត្ថនៃហេតុរបស់សមុទ័យត្រូវដឹងច្បាស់ អត្ថនៃការប្រកបព្រម របស់សមុទ័យត្រូវដឹងច្បាស់ អត្ថនៃកង្វល់របស់សមុទ័យត្រូវដឹងច្បាស់ អត្ថនៃនិរោធត្រូវដឹងច្បាស់ អត្ថនៃការរលាស់ចេញរបស់និរោធត្រូវដឹងច្បាស់ អត្ថនៃវិវេករបស់និរោធត្រូវដឹងច្បាស់ អត្ថនៃការមិនតាក់តែងរបស់និរោធត្រូវដឹងច្បាស់ អត្ថនៃការមិនស្លាប់របស់និរោធត្រូវដឹងច្បាស់ អត្ថនៃមគ្គត្រូវដឹងច្បាស់ អត្ថនៃការនាំចេញទៅរបស់មគ្គត្រូវដឹងច្បាស់ អត្ថនៃហេតុរបស់មគ្គត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់មគ្គត្រូវដឹងច្បាស់ អត្ថនៃភាពជាអធិបតីរបស់មគ្គត្រូវដឹងច្បាស់ ។

[ ៤៦ ] អត្ថនៃសភាពទៀងត្រូវដឹងច្បាស់ អត្ថនៃសភាពមិនមែនខ្ជូនត្រូវដឹងច្បាស់ អត្ថនៃសភាពពិតត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងត្រូវដឹង

ច្បាស់ អត្ថនៃការដឹងច្បាស់ត្រូវដឹងច្បាស់ អត្ថនៃការកំណត់ដឹងត្រូវដឹងច្បាស់ អត្ថនៃធម៌ត្រូវដឹងច្បាស់ អត្ថនៃធាតុត្រូវដឹងច្បាស់ អត្ថនៃការដឹងត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់ត្រូវដឹងច្បាស់ អត្ថនៃការប៉ះពាល់ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងត្រូវដឹងច្បាស់ ។

[ ៤៧ ] នេក្ខម្មៈត្រូវដឹងច្បាស់ អព្យាបាទត្រូវដឹងច្បាស់ អលោកសញ្ញាត្រូវដឹងច្បាស់ ការមិនរាយមាយត្រូវដឹងច្បាស់ ការកំណត់នូវធម៌ត្រូវដឹងច្បាស់ ញាណត្រូវដឹងច្បាស់ បាមុជ្ជត្រូវដឹងច្បាស់ បឋមជ្ឈានត្រូវដឹងច្បាស់ ទុតិយជ្ឈានត្រូវដឹងច្បាស់ តតិយជ្ឈានត្រូវដឹងច្បាស់ ចតុត្ថជ្ឈានត្រូវដឹងច្បាស់ អាកាសានញ្ចាយតនសមាបត្តិត្រូវដឹងច្បាស់ វិញ្ញាណញ្ចាយតនសមាបត្តិត្រូវដឹងច្បាស់ អាកិញ្ចញ្ញាយតនសមាបត្តិត្រូវដឹងច្បាស់ នេវសញ្ញានាសញ្ញាយតនសមាបត្តិត្រូវដឹងច្បាស់ ។

[ ៤៨ ] អនិច្ចានុបស្សនាត្រូវដឹងច្បាស់ ទុក្ខានុបស្សនាត្រូវដឹងច្បាស់ អនត្តានុបស្សនាត្រូវដឹងច្បាស់ និព្វិទានុបស្សនាត្រូវដឹងច្បាស់ វិរាគានុបស្សនាត្រូវដឹងច្បាស់ និរោធានុបស្សនាត្រូវដឹងច្បាស់ បដិនិស្សគ្គានុបស្សនាត្រូវដឹងច្បាស់ ខយានុបស្សនាត្រូវដឹងច្បាស់ វយានុបស្សនាត្រូវដឹងច្បាស់ វិបរិណាមានុបស្សនា ត្រូវដឹងច្បាស់ អនិមិត្តានុបស្សនា ត្រូវដឹងច្បាស់ អប្បណិហិតានុបស្សនា ត្រូវដឹងច្បាស់ សុញ្ញតានុបស្សនាត្រូវដឹងច្បាស់ អធិប្បញ្ញាធម្មវិបស្សនាត្រូវដឹងច្បាស់ យថាភូតញ្ញាណទស្សនៈត្រូវដឹងច្បាស់ អាទីនវានុបស្សនាត្រូវដឹងច្បាស់ បដិសង្ខានុបស្សនាត្រូវដឹងច្បាស់ វិវដ្ដ-

នានុបស្សនាត្រូវដឹងច្បាស់ ។

[ ៤៩ ] សោតាបត្តិមគ្គត្រូវដឹងច្បាស់ សោតាបត្តិផលសមាបត្តិត្រូវដឹងច្បាស់ សកទាគាមិមគ្គត្រូវដឹងច្បាស់ សកទាគាមិផលសមាបត្តិត្រូវដឹងច្បាស់ អនាគាមិមគ្គត្រូវដឹងច្បាស់ អនាគាមិផលសមាបត្តិត្រូវដឹងច្បាស់ អរហត្តមគ្គត្រូវដឹងច្បាស់ អរហត្តផលសមាបត្តិត្រូវដឹងច្បាស់ ។

[ ៥០ ] សទ្ធិន្ទ្រិយ ដោយអត្ថថា ជឿស៊ប់ត្រូវដឹងច្បាស់ វីរិយិន្ទ្រិយដោយអត្ថថា ផ្គងឡើងត្រូវដឹងច្បាស់ សតិន្ទ្រិយ ដោយអត្ថថា ប្រុងប្រយ័ត្នត្រូវដឹងច្បាស់ សមាធិន្ទ្រិយ ដោយអត្ថថា មិនរាយមាយត្រូវដឹងច្បាស់ បញ្ញិន្ទ្រិយដោយអត្ថថាឃើញត្រូវដឹងច្បាស់ សទ្ធាពល ដោយអត្ថថា មិនកម្រើក ព្រោះការមិនជឿត្រូវដឹងច្បាស់ វីរិយពល ដោយអត្ថថាមិនកម្រើក ព្រោះការខ្ជិលច្រអូសត្រូវដឹងច្បាស់ សតិពល ដោយអត្ថថា មិនកម្រើកព្រោះការប្រមាទត្រូវដឹងច្បាស់ សមាធិពល ដោយអត្ថថា មិនកម្រើកព្រោះការអណ្ដែតអណ្ដូងត្រូវដឹងច្បាស់ បញ្ញាពល ដោយអត្ថថា មិនកម្រើកព្រោះអវិជ្ជាត្រូវដឹងច្បាស់ ។

[ ៥១ ] សតិសម្ពោជ្ឈង្គ ដោយអត្ថថា ប្រុងប្រយ័ត្នត្រូវដឹងច្បាស់ ធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថាពិចារណាត្រូវដឹងច្បាស់ វីរិយសម្ពោជ្ឈង្គ ដោយអត្ថថា ផ្គងឡើងត្រូវដឹងច្បាស់ បីតិសម្ពោជ្ឈង្គ ដោយអត្ថថាផ្សាយទៅត្រូវដឹងច្បាស់ បស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថា ស្ងប់រម្ងាប់ត្រូវដឹងច្បាស់ សមាធិសម្ពោជ្ឈង្គ ដោយអត្ថថា មិនរាយមាយត្រូវដឹងច្បាស់ ឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថា ត្រួតត្រាត្រូវដឹងច្បាស់ ។

[ ៥២ ] សម្មាទិដ្ឋិ ដោយអត្ថថា ឃើញច្បាស់ត្រូវដឹងច្បាស់ សម្មាសង្កប្ប ដោយអត្ថថា លើកចិត្តឡើងត្រូវដឹងច្បាស់ សម្មាវាចា ដោយអត្ថថា កំណត់ ( នូវវចីសំវរៈ ៤ ) ត្រូវដឹងច្បាស់ សម្មាកម្មន្តៈ ដោយអត្ថថាតាំងឡើងត្រូវដឹងច្បាស់ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ត្រូវដឹងច្បាស់ សម្មាវាយាមៈ ដោយអត្ថថាផ្គងឡើងត្រូវដឹងច្បាស់ សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្នត្រូវដឹងច្បាស់ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយត្រូវដឹងច្បាស់ ។

[ ៥៣ ] ឥន្ទ្រិយទាំងឡាយ ដោយអត្ថថា ជាធំត្រូវដឹងច្បាស់ ពលទាំងឡាយ ដោយអត្ថថា មិនកម្រើក ត្រូវដឹងច្បាស់ ពោជ្ឈង្គទាំងឡាយ ដោយអត្ថថា ចេញចាកធម៌ជាសត្រូវត្រូវដឹងច្បាស់ មគ្គ ដោយអត្ថថា ញុំាងសត្វឲ្យដល់ ( នូវព្រះនិព្វាន ) ត្រូវដឹងច្បាស់ សតិប្បដ្ឋាន ដោយអត្ថថា ប្រុងប្រយ័ត្នត្រូវដឹងច្បាស់ សម្មប្បធានទាំងឡាយ ដោយអត្ថថា តម្កល់ទុកត្រូវដឹងច្បាស់ ឥទ្ធិបាទទាំងឡាយ ដោយអត្ថថា សម្រេចត្រូវដឹងច្បាស់ សច្ចៈទាំងឡាយ ដោយអត្ថថា ទៀងត្រូវដឹងច្បាស់ សមថៈ ដោយអត្ថថា មិនរាយមាយ ត្រូវដឹងច្បាស់ វិបស្សនា ដោយអត្ថថា ពិចារណារឿយៗ ត្រូវដឹងច្បាស់ សមថៈ និងវិបស្សនា ដោយអត្ថថា មានរសតែមួយត្រូវដឹងច្បាស់ ធម៌ដែលជាប់គ្នាជាគូ ដោយអត្ថថា មិនប្រព្រឹត្តកន្លងត្រូវដឹងច្បាស់ ។

[ ៥៤ ] សីលវិសុទ្ធិ ដោយអត្ថថាសង្រួមត្រូវដឹងច្បាស់ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយត្រូវដឹងច្បាស់ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញត្រូវដឹងច្បាស់ វិមោក្ខ ដោយអត្ថថារួចស្រឡះត្រូវដឹងច្បាស់ វិជ្ជា ដោយអត្ថថាត្រាស់ដឹងត្រូវ

ដឹងច្បាស់ វិមុត្តិ ដោយអត្ថថាលះបង់ត្រូវដឹងច្បាស់ ខយញ្ញាណ ដោយអត្ថថាផ្ដិលផ្ដាច់ត្រូវដឹងច្បាស់ អនុប្បាទញ្ញាណ ដោយអត្ថថាស្ងប់រម្ងាប់ត្រូវដឹងច្បាស់ ឆន្ទៈត្រូវដឹងច្បាស់ ដោយអត្ថថាជាមូល មនសិការត្រូវដឹងច្បាស់ ដោយអត្ថថាតាំងឡើងព្រម ផស្សៈត្រូវដឹងច្បាស់ ដោយអត្ថថាប្រមូលមក វេទនាត្រូវដឹងច្បាស់ ដោយអត្ថថាប្រជុំចុះ សមាធិត្រូវដឹងច្បាស់ ដោយអត្ថថាជាប្រធាន សតិត្រូវដឹងច្បាស់ ដោយអត្ថថាជាធំ បញ្ញាត្រូវដឹងច្បាស់ ដោយអត្ថថាដ៏ប្រសើរជាងពួកកុសលធម៌នោះ វិមុត្តិត្រូវដឹងច្បាស់ ដោយអត្ថថា ជាខ្លឹមសារ និព្វាន ជាគុណជាតមិនស្លាប់ជាទីពឹង ( របស់សត្វ ) ត្រូវដឹងច្បាស់ ដោយអត្ថថា ចប់ស្រេច ( នៃសាសនា ) ។

[ ៥៥ ] ពួកធម៌ណាៗ ដែលបុគ្គលចេះប្រាកដហើយ ពួកធម៌នោះៗ ឈ្មោះថាបុគ្គលដឹងហើយ ឈ្មោះថា ញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ជាគ្រឿងដឹងសព្វនូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ពួកធម៌នេះបុគ្គលត្រូវដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

**ទុតិយភាណវារៈ ចប់**

## ទុតិយភាណវារៈ

## អដ្ឋកថា អភិញ្ញេយ្យនិទ្ទេស(ត)

[ ៣០ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៣១ មាន **បរិគ្គហដ្ឋោ** អត្ថនៃធម៌ដែលគួរកំណត់កាន់យកជាដើម ដោយអំណាចខណៈនៃអរិយមគ្គ ។ ពិតហើយ ធម៌ទាំងឡាយដែលសម្បយុត្តដោយអរិយមគ្គ លោកកំណត់កាន់យកដើម្បីកើតឡើងតាំងអំពីដើម ព្រោះហេតុនោះ ទើបឈ្មោះថា **បរិគ្គហា** ។ សភាពនៃធម៌ដែលគួរកំណត់កាន់យកទាំងនោះ ឈ្មោះថា **បរិគ្គហដ្ឋោ** ។

ឈ្មោះថា **បរិវារដ្ឋោ** ព្រោះធម៌ទាំងនោះឯង ជាបរិវារនៃគ្នានិងគ្នា ។

ឈ្មោះថា **បរិបូរដ្ឋោ** ព្រោះបរិបូរណ៍ដោយភាវនា ។

ឈ្មោះថា **ឯកគ្គដ្ឋោ** ព្រោះសម្លឹងកំណត់កាន់យកអារម្មណ៍តែមួយដោយការតាំងមាំនៃធម៌នោះឯង ។

ឈ្មោះថា **អវិក្ខេបដ្ឋោ** ព្រោះសម្លឹងដល់ការមិនរាយមាយក្នុងអារម្មណ៍ផ្សេងៗ ។

ឈ្មោះថា **បគ្គហដ្ឋោ** ព្រោះផ្គងដោយអំណាចសេចក្តីព្យាយាម ។

ឈ្មោះថា **អវិសារដ្ឋោ** ព្រោះធម៌មិនខ្ចាត់ខ្ចាយទៅដោយអំណាចសមាធិដូចលម្អិតសម្រាប់ងូតទឹកមិនខ្ចាត់ខ្ចាយទៅដោយទឹក ដូច្នោះ ។

ឈ្មោះថា **អនាវិលដ្ឋោ** ព្រោះមិនល្អក់ដោយការប្រកបសមាធិ ។

ឈ្មោះថា **អនិញ្ជនដ្ឋោ** ព្រោះឲ្យញាប់ញ័រមិនបាន ។

បទថា **ឯកត្តុបដ្ឋានវសេន** បានដល់ ដោយការប្រកបសមាធិ និងដោយ

អំណាចនៃការតាំងនៅក្នុងអារម្មណ៍តែមួយយ៉ាងមាំទាំ ។

បទថា **ឋិតដ្ឋោ** បានដល់ សភាពដែលតាំងនៅដោយមិនញាប់ញ័រក្នុងអារម្មណ៍ ។

ឈ្មោះថា **អារម្មណដ្ឋោ** ព្រោះទាញយកនិព្វានជាអារម្មណ៍ ។

ឈ្មោះថា **គោចរដ្ឋោ** ព្រោះត្រាច់ប្រាថ្នានិព្វាននោះឯង ។

ឈ្មោះថា **បហានដ្ឋោ** ព្រោះនិព្វានជាគ្រឿងលោះបង់ចេញ និងជាគ្រឿងប្រហារ ។

ឈ្មោះថា **បរិច្ចាគដ្ឋោ** ព្រោះអរិយមគ្គជាឧបាយលះកិលេស ។

ឈ្មោះថា **វុដ្ឋានដ្ឋោ** ព្រោះអំណាចចេញចាកនិមិត្ត និងការប្រព្រឹត្តទៅទាំងពីរ ។

ឈ្មោះថា **និវត្តនដ្ឋោ** ព្រោះអំណាចចៀសទៅ អំពីនិមិត្ត និងការប្រព្រឹត្តទៅ ។

ឈ្មោះថា **សន្តដ្ឋោ** ព្រោះរម្ងត់ឥតសេសសល់ ។

ឈ្មោះថា **បណីតដ្ឋោ** ព្រោះភាពជាធម៌មិនក្តៅក្រហាយ និងព្រោះភាពជាធម៌ខ្ពង់ខ្ពស់ ។

ឈ្មោះថា **វិមុត្តដ្ឋោ** ព្រោះរួចផុតចាកកិលេសទាំងឡាយ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ ។

ឈ្មោះថា **អនាសវដ្ឋោ** ព្រោះជាធម៌ដែលបរិសុទ្ធដោយមិនមែនជាវិស័យនៃអាសវៈទាំងឡាយ ។

ឈ្មោះថា **តរណដ្ឋោ** ព្រោះឈានកន្លងចាកកិលេសកន្តារ និង សង្ខារកន្តារ ។

ឈ្មោះថា **អនិមិត្តដ្ឋោ** ព្រោះមិនមានសង្ខារនិមិត្ត ។

ឈ្មោះថា **អប្បណិហិតដ្ឋោ** ព្រោះមិនមានទីតាំង គឺតណ្ហា ។

ឈ្មោះថា **សុញ្ញតដ្ឋោ** ព្រោះមិនមានសារក្នុងខ្លួន ។

ឈ្មោះថា **ឯករសដ្ឋោ** ព្រោះមានរសតែមួយ គឺវិមុត្តិរស ឬព្រោះ សមថៈ និងវិបស្សនា មានរសតែមួយដូចគ្នា ។

ឈ្មោះថា **អនតិវត្តនដ្ឋោ** ព្រោះសមថៈ និងវិបស្សនាអាស្រ័យគ្នានិងគ្នា ។

ឈ្មោះថា **យុគនទ្ធដ្ឋោ** ព្រោះសមថៈ និងវិបស្សនានោះឯងជាគូគ្នា ។

ឈ្មោះថា **និយ្យានដ្ឋោ** ព្រោះអរិយមគ្គជាឧបាយចេញទៅអំពីសង្ខារ ។

ឈ្មោះថា **ហេតុដ្ឋោ** ព្រោះជាហេតុឲ្យដល់និព្វាន ។

ឈ្មោះថា **ទស្សនដ្ឋោ** ព្រោះធ្វើឲ្យប្រចក្សនូវនិព្វាន ។

ឈ្មោះថា **អាធិបតេយ្យដ្ឋោ** ព្រោះភាពជាធំដ៏ក្រៃលែង ។

[ ៣១ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៤ មានសមថៈជាដើម ដោយ អំណាចនៃសមថៈ និងវិបស្សនា ។ ឈ្មោះថា **អនុបស្សនដ្ឋោ** ព្រោះតាម ពិចារណាឃើញដោយអនិច្ចលក្ខណៈជាដើម ។ ឈ្មោះថា **អនតិវត្តនដ្ឋោ** ព្រោះសមថៈ និងវិបស្សនាទាំងពីរជាធម៌គូគ្នា ដោយមានរសតែមួយដូចគ្នា ។

ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៩ មានសិក្ខាជាដើមដោយអំណាចខាង ដើម កណ្តាល និងខាងចុងនៃអរិយមគ្គ ។ ឈ្មោះថា **សិក្ខា** ព្រោះត្រូវសិក្សា ។

*ឈ្មោះថា* **សមាទានដ្ឋោ** *ព្រោះសិក្ខានោះគួរសមាទាន ។ ឈ្មោះថា* **គោចរដ្ឋោ** *ព្រោះអារម្មណ៍ដែលតាំងនៅក្នុងសីល ហើយកាន់យកដោយអំណាចកម្មដ្ឋាន ជាទីតាំងប្រព្រឹត្តទៅនៃភាវនា និងជាទីតាំងនៃគោចរ ។ ឈ្មោះថា* **បគ្គហដ្ឋោ** *គឺសភាវៈដែលធ្វើចិត្តដែលរួញរា ដោយអំណាចការខ្ជិលច្រអូស ក្នុងវេលាបំពេញសមថៈ ឬវិបស្សនាឲ្យឧស្សាហៈ ដោយការចម្រើនធម្មវិចយ-សម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ ។*

*ឈ្មោះថា* **វិនិគ្គហដ្ឋោ** *គឺសភាពធ្វើចិត្តដែលរាយមាយ ដោយអំណាចឧទ្ធច្ចៈឲ្យស្ងប់ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ។ បទថា* **ឧភោ វិសុទ្ធានំ** *បានដល់ ចិត្តដែលបរិសុទ្ធចាកធម៌ទាំងពីរ អធិប្បាយថា ចិត្តដែលបរិសុទ្ធហើយ ព្រោះហាមចាកការរួញរា និងការរាយមាយ ។ គប្បីជ្រាបថា លោកធ្វើជាពហុវចនៈដោយអំណាចនៃចិត្តដែលតាំងនៅក្នុងភាពជាកណ្តាល ហើយប្រព្រឹត្តទៅដោយអំណាច របស់សន្តតិ ។ ឈ្មោះថា* **អជ្ឈុបេក្ខនដ្ឋោ** *គឺការមិនមានសេចក្តីខ្វល់ខ្វាយក្នុងការព្យាយាម និងក្នុងការធ្វើឲ្យស្ងប់ ។ ឈ្មោះថា* **វិសេសាធិគមដ្ឋោ** *គឺការអប់រំដោយអំណាចនៃចិត្ត ដែលប្រព្រឹត្តទៅស្មើ ។ ឈ្មោះថា* **ឧត្តរិប្បដិវេធដ្ឋោ** *ព្រោះអំណាចធ្វើអរិយមគ្គឲ្យប្រាកដ ។ ឈ្មោះថា* **សច្ចាភិសមយដ្ឋោ** *ព្រោះចាក់ធ្លុះអរិយសច្ច ៤ ដែលសម្រេចដោយអរិយមគ្គ ។ ឈ្មោះថា* **និរោធេ បតិដ្ឋាបកដ្ឋោ** *ព្រោះអំណាចផលសមាបត្តិ ។ ពិតហើយ ផលសមាបត្តិនោះធ្វើបុគ្គលដែលមានការដល់ព្រមដោយផលសមាបត្តិនោះ ឲ្យតាំងនៅក្នុងនិព្វាន*

ដែលបានដល់និរោធ ។

[ ៣២ ] ព្រះសារីបុត្តពោលដល់ការវិសជ្ជនា ៥ ប្រការ មានសទ្ធិន្ទ្រិយជាដើមដោយអំណាចនៃសភាវធម៌ គឺឥន្ទ្រិយ ។ បទថា **អធិមោក្ខដ្ឋោ** បានដល់ សភាពដែលបង្អោនទៅ ។ បទថា **ឧបដ្ឋានដ្ឋោ** បានដល់ សភាពដែលចូលដល់អារម្មណ៍ហើយប្រាកដ ។ បទថា **ឧស្សូនដ្ឋោ** បានដល់ សភាពដែលសម្ងឹងដល់សេចក្តីពិត ។

[ ៣៣ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៥ ប្រការ មាន **សទ្ធាពល** ជាដើម ដោយអំណាចនៃសភាវធម៌ គឺពល ។ ឈ្មោះថា **សទ្ធាពលំ** ព្រោះកម្លាំង គឺសទ្ធា ដោយអត្ថថា មិនញាប់ញ័រ ។ បទថា **អស្សទ្ធិយេ** បានដល់ ព្រោះមិនមានសទ្ធា ។ ម្យ៉ាងទៀត ចិត្តុប្បាទដែលជាបដិបក្ខចំពោះសទ្ធា ឈ្មោះថា អស្សទ្ធិយ ។ បទថា **អកម្បិយដ្ឋោ** បានដល់ សភាពដែលឲ្យញាប់ញ័រមិនបាន អធិប្បាយថា បុគ្គលណាមួយមិនអាចឲ្យញាប់ញ័របាន ។ បទថា **កោសជ្ជេ** បានដល់ ព្រោះថីនមិទ្ធៈ ពោល គឺការខ្ជិលច្រអូស ។ បទថា **បមាទេ** បានដល់ ព្រោះចិត្តុប្បាទដែលជាបដិបក្ខចំពោះសតិ ។ បទថា **ឧទ្ធច្ចេ** បានដល់ ព្រោះការរាយមាយ ពោលគឺការមិនស្ងប់ ។ បទថា **អវិជ្ជាយ** បានដល់ ព្រោះមោហៈ ។

[ ៣៤ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៧ មានសតិសម្ពោជ្ឈង្គជាដើមដោយអំណាចនៃសភាវធម៌ គឺពោជ្ឈង្គ ។ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងឈ្មោះថា **ពោជ្ឈង្គ** ។ ពោជ្ឈង្គជាធម៌ដ៏ប្រសើរ និងជាធម៌ល្អ ឈ្មោះថា សម្ពោជ្ឈង្គ ។

សម្ពោជ្ឈង្គ គឺសតិ ឈ្មោះថា **សតិសម្ពោជ្ឈង្គ** ។ ឈ្មោះថា **ធម្មវិចយ** ព្រោះពិចារណាធម៌ទាំងឡាយ ។ ពាក្យនេះ ជាឈ្មោះរបស់បញ្ញា ។ បទថា **បវិចយដ្ឋោ** បានដល់ សភាវៈដែលពិចារណា ។ ឈ្មោះថា **បីតិ** ព្រោះអត្ថថា ឆ្អែតចិត្ត ។ បទថា **ផរណដ្ឋោ** បានដល់ សភាពដែលផ្សាយទៅ ។ ការស្ងប់ ឈ្មោះថា **បស្សទ្ធិ**។ បទថា **ឧបសមដ្ឋោ** បានដល់ សភាពដែលមិនមានសេចក្តីក្រវល់ក្រវាយ ។ ឈ្មោះថា **ឧបេក្ខា** ព្រោះសម្លឹងដោយឧប្បត្តិ អធិប្បាយថា សម្លឹងស្មើ គឺសម្លឹងមិនធ្លាក់ទៅក្នុងចំណែកណាមួយឡើយ ។ ឧបេក្ខានោះ ក្នុងទីនេះ បានដល់ **តត្រមជ្ឈត្តុបេក្ខា** គឺការព្រងើយដោយភាពជាកណ្តាលក្នុងអារម្មណ៍នោះៗ ។ ហៅថា **ពោជ្ឈង្គុបេក្ខា** ក៏បាន ។ ឈ្មោះថា **បដិសង្ខានដ្ឋោ** ព្រោះមានលក្ខណៈនាំទៅស្មើ ។

[ ៣៥ ] ព្រះសារីបុត្តត្ថេរ បានសម្តែងវិសជ្ជនា ៨ មានសម្មាទិដ្ឋិជាដើម ដោយអំណាចនៃមគ្គ ។ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា ឃើញត្រូវ ឬជាហេតុឲ្យឃើញត្រូវ ឬជាការឃើញ ដែលគួរសរសើរដ៏ប្រពៃ ។ នៃសម្មាទិដ្ឋិនោះ ។

ឈ្មោះថា **សម្មាសង្កប្បោ** ព្រោះអត្ថថា ត្រិះរិះត្រូវ ឬជាហេតុត្រិះរិះត្រូវ ឬការត្រិះរិះដែលគួរសរសើរដ៏ប្រពៃ ។

បទថា **អភិរោបនដ្ឋោ** បានដល់ សភាពដែលលើកចិត្តឡើងកាន់អារម្មណ៍ ។ បាឋៈថា **អារម្មណាភិនិរោបនដ្ឋោ** ដូច្នេះក៏មាន ។

ឈ្មោះថា **សម្មាវាចា** ព្រោះនិយាយត្រូវ ឬជាហេតុឲ្យនិយាយត្រូវ ឬជា

វាចាដែលគួរសរសើរដ៏ប្រពៃ ។ បទនេះជាឈ្មោះនៃការវៀរចាកមិច្ឆាវាចា ។

បទថា **បរិគ្គហដ្ឋោ** បានដល់ សភាពដែលកំណត់ការសង្រួមវាចា ៤ យ៉ាង ។

ឈ្មោះថា **សម្មាកម្មំ** ព្រោះអត្ថថា ធ្វើត្រូវ ឬជាហេតុឲ្យធ្វើត្រូវ ឬជាការងារដែលគួរសរសើរដ៏ប្រពៃ **សម្មាកម្មំ** នោះឯងឈ្មោះថា **សម្មាកម្មន្តោ** ។ បទនេះ ជាឈ្មោះនៃការវៀរចាកមិច្ឆាកម្មន្តៈ ។

បទថា **សមុដ្ឋានដ្ឋោ** បានដល់ សភាពដែលតាំងឡើងដោយការសង្រួមកាយ ៣ យ៉ាង ។

ឈ្មោះថា **សម្មាអាជីវោ** ព្រោះអត្ថថា រស់នៅត្រូវ ឬជាហេតុឲ្យរស់នៅត្រូវ ឬការរស់នៅដែលគួរសរសើរដ៏ប្រពៃ ។ បទនេះ ជាឈ្មោះនៃការវៀរចាកមិច្ឆាអាជីវៈ ។

បទថា **វោទានដ្ឋោ** បានដល់ សភាពដែលបរិសុទ្ធ ។

ឈ្មោះថា **សម្មាវាយាមោ** ព្រោះអត្ថថា ព្យាយាមត្រូវ ឬជាហេតុឲ្យព្យាយាមត្រូវ ឬជាការព្យាយាមដែលគួរសរសើរដ៏ប្រពៃ ។

ឈ្មោះថា **សម្មាសតិ** ព្រោះអត្ថថា រឭកត្រូវ ឬជាហេតុឲ្យរឭកត្រូវ ឬជាការរឭកដែលគួរសរសើរដ៏ប្រពៃ ។

ឈ្មោះថា **សម្មាសមាធិ** ព្រោះអត្ថថា តាំងមាំដោយប្រពៃ ឬជាហេតុឲ្យតាំងមាំដោយប្រពៃ ឬជាការតាំងមាំដែលគួរសរសើរដ៏ប្រពៃ ។

[ ៣៦ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ១០ មានឥន្ទ្រិយជាដើម ធ្វើ

*ឲ្យជាពួកតាមលំដាប់ ។*

*បទថា* **អាធិបតេយ្យដ្ឋោ** *បានដល់ សភាពដែលជាអធិបតីដោយអំណាចធ្វើភាពជាធំក្នុងកិច្ចរបស់ខ្លួន ។*

*បទថា* **អកម្បិយដ្ឋោ** *បានដល់ សភាពដែលធម៌ជាបដិបក្ខមិនអាចធ្វើឲ្យញាប់ញ័របាន ។*

*បទថា* **និយ្យានដ្ឋោ** *បានដល់ សភាពដែលពោធិបក្ខិយ ទាំងលោកិយនិងលោកុត្តរ ជាហេតុនាំចេញចាកធម៌ដែលជាសត្រូវ ។*

*បទថា* **ហេតុដ្ឋោ** *មានវិគ្គហៈថា ឈ្មោះថា* **ហេតុដ្ឋោ** *ព្រោះអត្ថថា សម្មាទិដ្ឋិជាដើម ជាហេតុដើម្បីលះមិច្ឆាទិដ្ឋិជាដើម ឬព្រោះអត្ថថា សម្មាទិដ្ឋិទាំងអស់ជាហេតុឲ្យចូលដល់និព្វាន ។*

*ឈ្មោះថា* **ឧបដ្ឋាន** *ព្រោះស្ទុះទៅក្នុងអារម្មណ៍ដែលជាទីតាំងនៃសតិ ហើយតាំងមាំ ការតាំងមាំ គឺសតិ ឈ្មោះថា* **សតិប្បដ្ឋានំ** ។

*សតិនោះមាន ៤ យ៉ាង ប្រព្រឹត្តទៅដោយអំណាចកាន់យកអាការថា មិនស្អាត ជាទុក្ខ មិនទៀង និងមិនមែនខ្លួន និងដោយអំណាចសម្រេចកិច្ចនៃការលះនូវការសម្គាល់ថា ជារបស់ស្អាត ជាសុខ ជារបស់ទៀង ជាតួខ្លួន ក្នុងកាយ វេទនា ចិត្ត ធម៌ ។ សតិទាំង ៤ ប្រភេទនោះ រមែងរកបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គសតិតែមួយប៉ុណ្ណោះ បានឈ្មោះគ្រប់ទាំង ៤ យ៉ាង ។*

*សម្មប្បធាន មានវិគ្គហៈថា ឈ្មោះថា បធាន ព្រោះអត្ថថា ជាហេតុផ្ដើម*

ប្រារព្ធ បធានដែលល្អ ឈ្មោះថា សម្មប្បធាន ឬឈ្មោះថា សម្មប្បធាន ព្រោះអត្ថថា ជាហេតុផ្តើមប្រារព្ធដោយប្រពៃ ម្យ៉ាងទៀត បធាននោះ ឈ្មោះថា ល្អ ព្រោះវៀរចាកកិលេស និងការមានសភាពខុសប្រក្រតី និងឈ្មោះថា បធាន ព្រោះនាំមកនូវភាពជាវត្ថុដ៏ប្រសើរបំផុត ដោយឲ្យសម្រេចប្រយោជន៍ និងសេចក្តីសុខ ឬព្រោះធ្វើភាពជាប្រធាន ទើបឈ្មោះថា សម្មប្បធាន ។ ពាក្យនេះ ជាឈ្មោះរបស់វីរិយៈ ។ វីរិយៈនោះមាន ៤ ប្រភេទ ប្រព្រឹត្តទៅដោយអំណាចឲ្យសម្រេចកិច្ច គឺលះនូវអកុសលធម៌ដែលកើតឡើងហើយ ធ្វើអកុសលធម៌ដែលមិនទាន់កើតមិនឲ្យកើតឡើង ធ្វើកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង និងធ្វើកុសលធម៌ដែលកើតឡើងហើយឲ្យតាំងនៅ ។ បធានទាំងនេះ រមែងរកបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គវីរិយៈតែម្យ៉ាងប៉ុណ្ណោះ បានឈ្មោះគ្រប់ទាំង ៤ យ៉ាង ។

បទថា **បធានដ្ឋោ** បានដល់ សភាពដែលឧស្សាហ៍ ។ បាឋៈថា **បធា-នដ្ឋោ** ដូច្នេះក៏មាន ឯសេចក្តីតែមួយដូចគ្នា ។ ក្នុងបទថា **ឥទ្ធិបាទានំ** នេះ មានវិគ្គហៈដូចតទៅនេះ ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា បណ្តាឆន្ទៈ វីរិយៈ ចិត្ត វីមំសា នីមួយៗ រមែងសម្រេច អធិប្បាយថា រមែងសម្រេចព្រម គឺរមែងសម្រេចបាន ។ ម្យ៉ាងទៀត ឈ្មោះថា **ឥទ្ធិ** ព្រោះជាហេតុឲ្យសត្វទាំងឡាយសម្រេចផល គឺថា សត្វទាំងឡាយ ជាអ្នកសម្រេចផលចម្រើនដល់នូវសេចក្តីល្អក្រៃលែង ។ ដោយអត្ថទី ១ បាទ គឺឥទ្ធិ ឈ្មោះថា ឥទ្ធិបាទ សេចក្តីថា ចំណែក គឺការសម្រេច ដោយអត្ថទី ២ បាទនៃឥទ្ធិ ឈ្មោះថា ឥទ្ធិបាទ ។

បទថា **ឋានោ** បានដល់ ជាទីតាំង អធិប្បាយថា ជាឧបាយឲ្យសម្រេច ។ ព្រោះថា សត្វទាំងឡាយរមែងដល់ គឺរមែងសម្រេចសេចក្តីសម្រេច ពោល គឺគុណវិសេសក្រៃលែងឡើងដោយឥទ្ធិបាទនោះ ព្រោះហេតុនោះ ទើបហៅថា **ឋាន** ។ ឥទ្ធិបាទ មានឆន្ទៈជាដើមទាំងនោះ រមែងរកបានក្នុងចិត្តផ្សេងៗ ដោយភាពជាធំក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គ រមែងរកបានព្រមគ្នា ដោយពិត ។

បទថា **ឥជ្ឈនដ្ឋោ** បានដល់ សភាពដែលសម្រេចផល ឬសភាពជាទីតាំង ។

បទថា **សច្ចានំ** បានដល់ អរិយសច្ច ៤ ។

បទថា **តថដ្ឋោ** បានដល់ សភាពតាមដែលពិត ។ វិសជ្ជនាទាំង ៨ នេះ ជាលោកិយផង ជាលោកុត្តរផង ។

បទថា **បយោគានំ** បានដល់ បយោគរបស់អរិយមគ្គ ៤ ។

បទថា **បដិប្បស្សទ្ធដ្ឋោ** បានដល់ សភាពដែលរម្ងាប់ដោយអរិយផល ៤ ។ ពិតហើយ មគ្គប្បយោគ ជាការរម្ងាប់បានក្នុងខណៈនៃផល ព្រោះអស់កិច្ចហើយ ។ ឬភាវៈនៃមគ្គប្បយោគរម្ងាប់ហើយ ដោយផលកើតឡើង ។

បទថា **ផលានំ សច្ឆិកិរិយដ្ឋោ** បានដល់ សភាពដែលធ្វើឲ្យប្រចក្ស ដោយអំណាចការពិចារណាអរិយផល ។ ជាការដែលលោកពោលដល់ការធ្វើឲ្យជាក់ច្បាស់នូវអារម្មណ៍ ។ ឬការធ្វើឲ្យជាក់ច្បាស់នូវការបានក្នុងខណៈនៃផល ។

ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៥ មានវិតក្កជាដើមដោយអង្គឈាន ។ ការត្រិះរិះ អធិប្បាយថា ការលើកឡើង ឈ្មោះថា វិតក្ក ការពិចារណា អធិប្បាយថា ការតាមពិនិត្យពិច័យឈ្មោះថាវិចារ ។ បទថា **ឧបវិចារដ្ឋោ** បានដល់ សភាពដែលតាមពិនិត្យពិចារណា ។ បទថា **អភិសន្ទនដ្ឋោ** បានដល់ សភាពដែលផ្សាយឡើង គឺសភាពដែលចិត្តមានអារម្មណ៍តែមួយ ដោយអំណាចសមាធិ ។

ព្រះសារីបុត្ត បានសម្តែងវិសជ្ជនា ១៥ មានអាវជ្ជនជាដើម ដោយជាចំណែកបន្ទិចបន្តួច ។ បទថា **អាវជ្ជនដ្ឋោ** បានដល់ សភាពដែលនឹករករបស់ចិត្ត ២ ក្នុងបញ្ចទ្វារ និងមនោទ្វារ ដែលបង្អោនទៅកាន់ចិត្តសន្តាន ក្នុងអារម្មណ៍ដទៃអំពីអារម្មណ៍នៃភវង្គ ។ បទថា **វិជាននដ្ឋោ** បានដល់ សភាពដែលដឹងច្បាស់នៃវិញ្ញាណ ។ បទថា **បជាននដ្ឋោ** បានដល់ សភាពដែលដឹងច្បាស់នៃបញ្ញា ។ បទថា **សញ្ជាននដ្ឋោ** បានដល់ សភាពដែលចាំបាននៃសញ្ញា ។ បទថា **ឯកោទដ្ឋោ** បានដល់ សភាពដែលសមាធិជាធម៌ឯកផុសឡើង ព្រោះថា សមាធិក្នុងទុតិយជ្ឈានជាឯក ផុសឡើង ទើបពោលថា **ឯកោទិ** អធិប្បាយថា ជាសមាធិដ៏ប្រសើរឯក កើតឡើង ព្រោះវិតក្កវិចារស្ងប់ ។ វត្ថុដែលប្រសើរ ហៅថា ឯកក្នុងលោក ។ម្យ៉ាងទៀត ទោះពោលថា ជាធម៌ឯកមិនមានគូ វៀរវិតក្កវិចារ ផុសឡើង ដូច្នេះ ក៏ត្រឹមត្រូវ ។ ម្យ៉ាងទៀត ទោះពោលថា កុសលសមាធិទាំងអស់ ជាធម៌ស្ងប់ចាកវិតក្កវិចារទាំងនោះ ព្រោះជាបដិបក្ខចំពោះនីវរណៈជាដើម ឬចំពោះឧទ្ធច្ចៈនោះឯង ព្រោះហេតុ

នោះ ទើបជាធម៌ដ៏ប្រសើរផុតឡើង ឬទឹងពោលថា វៀរចាកវិតក្កវិចារទាំង នោះ ព្រោះហេតុនោះ ទើបជាធម៌មិនមានសម្លាញ់ផុតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកោទិ** ក៏រមែងត្រឹមត្រូវ ។

[ ៣៧ ] បទថា **អភិញ្ញាយ ញាតដ្ឋោ** បានដល់ សភាពដែលដឹងដល់ សភាវធម៌ដោយញាតបរិញ្ញា ។

បទថា **បរិញ្ញាយ តីរណដ្ឋោ** បានដល់ សភាពដែលសម្លឹងពិចារណា ដោយជារបស់មិនទៀងជាដើម ដោយតីរណបរិញ្ញា ។

បទថា **បហានស្ស បរិច្ចាគដ្ឋោ** បានដល់ សភាពដែលលះធម៌ដែល ជាបដិបក្ខដោយបហានបរិញ្ញា ។ សភាពដែលភាវនាប្រព្រឹត្តទៅស្មើ ឈ្មោះ ថា **ភាវនាយ ឯករសដ្ឋោ** ។

បទថា **ផស្សនដ្ឋោ** បានដល់ សភាពដែលពាល់ត្រូវប៉ះពាល់ គឺសភាព ដែលជួបប្រទះ ។ ឈ្មោះថា **ខន្ធដ្ឋោ** ព្រោះមានសភាពទទួលភារៈដែលធ្ងន់ ក្រៃលែងជាដើមទៅ ។ ឈ្មោះថា **ធាតុដ្ឋោ** ព្រោះមានសភាពទទេជាដើម ។ ឈ្មោះថា **អាយតនដ្ឋោ** ព្រោះមានសភាពតព្រំដែនដែលជាចំណែករៀងៗ ខ្លួន ។ ឈ្មោះថា **សង្ខតដ្ឋោ** ព្រោះបច្ច័យទាំងឡាយប្រជុំគ្នាធ្វើ ។ ឈ្មោះថា **អសង្ខតដ្ឋោ** ព្រោះផ្ទុយគ្នានឹង **សង្ខតដ្ឋោ** នោះ ។

[ ៣៨ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ១៥ មាន **ចិត្តដ្ឋោ** ជាដើម ដោយភ្ជាប់ **ចិត្ត** សព្ទគ្រប់អន្ទើ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **ចិត្តដ្ឋោ** ដូចតទៅនេះ ឈ្មោះថា **ចិត្តំ** ព្រោះគិតដល់អារម្មណ៍ សេចក្តីថា រមែងដឹង

ច្បាស់នូវអារម្មណ៍ ។ ក្នុងទីនេះ ចិត្តដែលជាជវនៈ រមែងសន្សំសន្តានរបស់ខ្លួន ដោយជវនវិថីចិត្ត សូម្បីដូច្នេះ ក៏ឈ្មោះថា **ចិត្តំ** ។ ចិត្តដែលជាវិបាក ដែលកម្មក្កិលេសសន្សំ ដូច្នេះ ក៏ឈ្មោះថា **ចិត្តំ** ។ ទាំងអស់ ឈ្មោះថា ចិត្ត ព្រោះសន្សំតាមសមគួរ ឈ្មោះថា **ចិត្តំ** ព្រោះធ្វើឲ្យវិចិត្រ ចិត្តដែលជាបច្ច័យដល់វដ្ត រមែងសន្សំសង្សារទុក្ខ សូម្បីដូច្នេះ ក៏ឈ្មោះថា **ចិត្តំ** ។ សភាពដែលគិត ដោយមានការសន្សំអារម្មណ៍ជាដើម ដោយប្រការដូច្នេះ ។

ឈ្មោះថា **អនន្តរំ** ព្រោះចិត្តនោះ មិនមានចន្លោះក្នុងការកើតរបស់ចិត្ត ឬក្នុងការកើតរបស់ផល ។ ភាពជា **អនន្តរំ** ឈ្មោះថា **អនន្តរិយំ** ភាពដែលចិត្តមិនមានចន្លោះ ឈ្មោះថា **ចិត្តានន្តរិយំ** ។ ចិត្តានន្តរិយំនោះ គឺសភាពដែលមិនមានចន្លោះនៃចិត្ត អធិប្បាយថា សភាពដែលចិត្តឯណានីមួយរលត់តគ្នាទៅ វៀរចុតិចិត្តរបស់ព្រះអរហន្ត អាចធ្វើចិត្តឲ្យកើតតគ្នាទៅ សភាពដែលមគ្គចិត្ត អាចធ្វើឲ្យកើតផលចិត្តជាប់តគ្នាទៅ ។

បទថា **ចិត្តស្ស វុដ្ឋានដ្ឋោ** បានដល់ សភាពដែលគោត្រភូចិត្តចេញចាកនិមិត្ត និងសភាពដែលមគ្គចិត្តចេញចាកនិមិត្ត និងបវត្ត ។

បទថា **ចិត្តស្ស វិវដ្ដនដ្ឋោ** បានដល់ សភាពដែលចៀសចេញទៅក្នុងនិព្វានរបស់ចិត្តពីរដួងនោះ ដែលចេញចាកនិមិត្ត និងបវត្ត តាមដែលពោលហើយ ។

បទថា **ចិត្តស្ស ហេតុដ្ឋោ** បានដល់ សភាពដែលជាហេតុនៃហេតុ ៩ យ៉ាង ដែលជាហេតុប្បច្ច័យដល់ចិត្ត ។

បទថា **ចិត្តស្ស បច្ចយដ្ឋោ** បានដល់ សភាពដែលជាបច្ច័យនៃបច្ច័យដ៏ច្រើនសន្ទឹកសន្ធាប់របស់ចិត្ត មានវត្ថុ និងអារម្មណ៍ជាដើមនៃចិត្ត ។

បទថា **ចិត្តស្ស វត្ថុដ្ឋោ** បានដល់ សភាពជាទីតាំងនៃភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ( ហទយៈ ) ដែលជាទីតាំងនៃចិត្ត ។

បទថា **ចិត្តស្ស ភូមដ្ឋោ** បានដល់ សភាពដែលជាភូមិ មានកាមាវចរ-ភូមិជាដើម ដោយជាទីកន្លែងកើតរបស់ចិត្ត ។

បទថា **ចិត្តស្ស អារម្មណដ្ឋោ** បានដល់ ភាពនៃអារម្មណ៍ មានរូបជាដើម ។

ឈ្មោះថា **គោចរដ្ឋោ** ដោយអត្ថថា ជាទីសញ្ចរនៃអារម្មណ៍ដែលសន្សំ ។

ឈ្មោះថា **ចរិយដ្ឋោ** ព្រោះអំណាចត្រាច់ទៅនៃវិញ្ញាណ ដែលពោលក្នុងខាងដើម ។ ម្យ៉ាងទៀត សភាពដែលប្រាកដនៃបយោគ ឈ្មោះថា **ចរិយដ្ឋោ** ។

ឈ្មោះថា **គតដ្ឋោ** ព្រោះអំណាចចិត្តដែលកាន់យកអារម្មណ៍ឆ្ងាយ និងជិត សូម្បីមិនមានការទៅ ។

បទថា **អភិនីហារដ្ឋោ** បានដល់ សភាពដែលនាំទៅដ៏ក្រៃលែងនៃចិត្ត ដើម្បីមនសិការដល់អារម្មណ៍ដទៃចាកអារម្មណ៍ដែលប្រកាន់ ។

បទថា **ចិត្តស្ស និយ្យានដ្ឋោ** បានដល់ សភាពដែលមគ្គចិត្តនាំចេញចាកវដ្តៈ ។

ឈ្មោះថា **ចិត្តស្ស និស្សរណដ្ឋោ** ព្រោះន័យ មានជាដើមថា ចិត្តរបស់បុគ្គលអ្នកបាននេក្ខម្មៈ ជាការរលាស់ចេញចាកកាមច្ឆន្ទៈ ។

[ ៣៩ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៤២ មាន **ឯកត្តេ** ជាដើម ដោយភ្ជាប់ **ឯកត្ត** សព្វគ្រប់អន្ទើ ។

បទថា **ឯកត្តេ** បានដល់ ក្នុងភាពដែលចិត្តមានអារម្មណ៍តែមួយ អធិប្បាយថា បានដល់ ក្នុងអារម្មណ៍តែមួយ ។

ឈ្មោះថា **បក្ខន្ទនដ្ឋោ** ព្រោះអំណាចបឋមជ្ឈាន ។

ឈ្មោះថា **បសីទនដ្ឋោ** ព្រោះអំណាចទុតិយជ្ឈាន ។

ឈ្មោះថា **សន្តិដ្ឋនដ្ឋោ** ព្រោះអំណាចតតិយជ្ឈាន ។

ឈ្មោះថា **មុច្ចនដ្ឋោ** ព្រោះអំណាចចតុត្ថជ្ឈាន ។

ឈ្មោះថា **ឯតំ សន្តន្តិ បស្សនដ្ឋោ** ដោយអំណាចការពិចារណា ។

ការវិសជ្ជនា ៥ មាន **យានីកតដ្ឋោ** ជាដើម ជាការជំនាញដ៏វិសេសរបស់សមាធិ ។

បទថា **យានីកតដ្ឋោ** បានដល់ សភាពដែលធ្វើឲ្យដូចជាយានដែលទឹមហើយ ។

បទថា **វត្ថុកតដ្ឋោ** បានដល់ សភាពដែលធ្វើឲ្យដូចជាទីតាំង ដោយអត្ថថា ជាទីតាំងអាស្រ័យ ។

បទថា **អនុដ្ឋិតដ្ឋោ** បានដល់ សភាពដែលចូលទៅតាំងទុកចំពោះ ។

បទថា **បរិចិតដ្ឋោ** បានដល់ សភាពដែលសន្សំដោយជុំវិញ ។

បទថា **សុសមារទ្ធធ្ជោ** បានដល់ សភាពដែលផ្ដើមដោយល្អ អធិប្បាយថា សភាពដែលធ្វើទុកល្អ ។ មួយវិញទៀត គួរប្រកបបទ ៥ តាមលំដាប់ដោយភាពជាអ្នកជំនាញក្នុងអាវជ្ជនៈ សមាបជ្ជនៈ អធិដ្ឋាន វុដ្ឋាន បច្ចវេក្ខណៈ ។

អត្ថនៃការកំណត់កាន់យកក្នុងអារម្មណ៍តែមួយ អត្ថនៃធម៌ជាបរិវារ អត្ថនៃធម៌ដែលត្រូវបំពេញក្នុងអារម្មណ៍តែមួយ នៃចិត្ត និងចេតសិក ក្នុងវេលាដែលការភាវនា មានកសិណជាដើម ជាអារម្មណ៍ដល់កំពូល ។

ឈ្មោះថា **សមោធានដ្ឋោ** ព្រោះចិត្ត និងចេតសិកទាំងនោះ តាំងទុកដោយល្អហើយ ដោយការប្រជុំក្នុងអារម្មណ៍តែមួយ ។

ឈ្មោះថា **អធិដ្ឋានដ្ឋោ** ព្រោះអំណាចដែលចិត្ត និងចេតសិកទាំងនោះឯង គ្របសង្កត់អារម្មណ៍ ហើយតាំងមាំដោយការបន្ថែមកម្លាំង ។

ឈ្មោះថា **អាសេវនដ្ឋោ** ព្រោះអំណាចសេពសមថៈ ឬវិបស្សនាតាំងអំពីដើម ឬដោយអើពើ ។

ឈ្មោះថា **ភាវនដ្ឋោ** ព្រោះអាចឲ្យចម្រើន ។

ឈ្មោះថា **ពហុលីកម្មដ្ឋោ** ព្រោះអំណាចការធ្វើរឿយៗ ។

ឈ្មោះថា **សុសមុគ្គតដ្ឋោ** ព្រោះអំណាចការរួបរួមវត្ថុដែលធ្វើទុកច្រើនហើយដោយល្អ ។

ឈ្មោះថា **សុវិមុត្តដ្ឋោ** ព្រោះអំណាចការរួចផុតដោយល្អ ចាកធម៌ជាសត្រូវនៃសភាពដែលរួបរួមទុកល្អហើយ និងព្រោះអំណាចក្នុងការបង្អោនទៅដោយល្អក្នុងអារម្មណ៍ ។

ព្រះសារីបុត្តពោលដល់បទ ៤ មានបទថា **ពុជ្ឈនដ្ឋោ** ជាដើម ដោយអំណាចពោជ្ឈង្គ ។

ឈ្មោះថា **ពុជ្ឈនដ្ឋោ** នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងសោតាបត្តិមគ្គ ។

ឈ្មោះថា **អនុពុជ្ឈនដ្ឋោ** នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងសកទាគាមិមគ្គ ។

ឈ្មោះថា **បដិពុជ្ឈនដ្ឋោ** នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងអនាគាមិមគ្គ ។

ឈ្មោះថា **សម្ពុជ្ឈនដ្ឋោ** នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងអរហត្តមគ្គ ។ ម្យ៉ាងទៀត ឈ្មោះថា **ពុជ្ឈនដ្ឋោ** បានដល់ នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដោយវិបស្សនា ។ ឈ្មោះថា **អនុពុជ្ឈនដ្ឋោ** បានដល់ នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដោយទស្សនមគ្គ ។ ឈ្មោះថា **បដិពុជ្ឈនដ្ឋោ** បានដល់ នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដោយភាវនាមគ្គ ។ ឈ្មោះថា **សម្ពុជ្ឈនដ្ឋោ** បានដល់ នូវអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដោយផល ។ គប្បីជ្រាបអត្ថ ៤ យ៉ាង មាន **ពោធនដ្ឋោ** ជាដើម នៃពោជ្ឈង្គទាំងឡាយ ដោយន័យតាមដែលពោលហើយនោះឯង ដោយការធ្វើបុគ្គលនោះៗ ឲ្យត្រាស់ជាដើម ។ ធម៌ទាំងឡាយ ឈ្មោះថាប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ព្រោះមានក្នុងចំណែករបស់បុគ្គលដែលបាន ឈ្មោះថា **ពោធ** ដោយអត្ថថា ត្រាស់ដឹងនូវពោជ្ឈង្គទាំងឡាយតាមដែលពោលហើយនោះឯង ។ គប្បីជ្រាបអត្ថ ៤ យ៉ាង មាន **ពោធិបក្ខិយដ្ឋោ** ជាដើម នៃពោជ្ឈង្គតាមដែលពោលហើយនោះឯង ។

ឈ្មោះថា **ជោតនដ្ឋោ** ព្រោះអំណាចវិបស្សនាបញ្ញា ។

ឈ្មោះថា **ឧជ្ជោតនដ្ឋានុជោតនបដិជោតនសញ្ជោតនដ្ឋោ** ព្រោះអំណាច

*មគ្គប្បញ្ញា ៤ តាមលំដាប់ ។ម្យ៉ាងទៀត គប្បីជ្រាបពាក្យថា* **ជោតនដ្ឋោ** *ជាដើម ព្រោះអំណាចមគ្គប្បញ្ញា ៤ និងពាក្យថា* **សញ្ជោតនដ្ឋោ** *ជាដើម ព្រោះអំណាចផលប្បញ្ញាតាមលំដាប់ ។*

*[ ៤០ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ១៨ មាន* **បតាបនដ្ឋោ** *ជាដើម ដោយអរិយមគ្គ ។ ពិតហើយ អរិយមគ្គ ដែលកើតឡើងដល់ចិត្តណា រមែងញ៉ាំងចិត្តនោះឲ្យភ្លឺស្វាង ឲ្យភ្លឺថ្លា គឺឲ្យរុងរឿង ព្រោះហេតុនោះ ទើបឈ្មោះថា* **បតាបន** *សភាពដែលអរិយមគ្គនោះធ្វើឲ្យភ្លឺស្វាង ឈ្មោះថា* **បតាបនដ្ឋោ** *។ ឈ្មោះថា* **វិរោចនដ្ឋោ** *ព្រោះអរិយមគ្គនោះឯង ភ្លឺថ្លាក្រៃលែង ។ ឈ្មោះថា* **សន្តាបនដ្ឋោ** *ព្រោះឲ្យកិលេសទាំងឡាយរីងស្ងួតទៅ ។*

*ឈ្មោះថា* **អមលដ្ឋោ** *ព្រោះអរិយមគ្គ មានព្រះនិព្វានដែលមិនមានមន្ទិលជាអារម្មណ៍ ។*

*ឈ្មោះថា* **វិមលដ្ឋោ** *ព្រោះមិនមានមន្ទិលលាយឡំ ។*

*ឈ្មោះថា* **និម្មលដ្ឋោ** *ព្រោះមិនមានមន្ទិល ធ្វើអារម្មណ៍ ។ ម្យ៉ាងទៀត បទថា* **អមលដ្ឋោ** *បានដល់ នៃសោតាបត្តិមគ្គ ។ បទថា* **វិមលដ្ឋោ** *បានដល់ នៃសកទាគាមិមគ្គនិងអនាគាមិមគ្គ ។ បទថា* **និម្មលដ្ឋោ** *បានដល់ នៃអរហត្តមគ្គ ។*

*ម្យ៉ាងទៀត បទថា* **អមលដ្ឋោ** *បានដល់ នៃមគ្គរបស់ព្រះសាវ័ក ។ បទថា* **វិមលដ្ឋោ** *បានដល់ នៃមគ្គរបស់ព្រះបច្ចេកពុទ្ធ ។ បទថា* **និម្មលដ្ឋោ** *បានដល់ នៃមគ្គរបស់ព្រះសម្មាសម្ពុទ្ធ ។*

ឈ្មោះថា **សមដ្ឋោ** ព្រោះមិនមានការមិនស្ងប់ គឺកិលេស ។

ឈ្មោះថា **សមយដ្ឋោ** ព្រោះជាសភាពដែលអរិយមគ្គប្រហារកិលេស ដូចព្រះបាលីថា **សម្មា មានាភិសមយា** ដោយហេតុដែលបានលះបង់នូវមានះចោលដោយប្រពៃ ដូច្នេះជាដើម ។

ឈ្មោះថា **វិវេកដ្ឋោ** ព្រោះជាសមុច្ឆេទវិវេកក្នុងវិវេក ៥ គឺវិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិបស្សទ្ធិវិវេក ១ និស្សរណវិវេក ១ គឺសភាពដែលអរិយមគ្គធ្វើឲ្យវិនាស ។

ឈ្មោះថា **វិវេកចរិយដ្ឋោ** ព្រោះប្រព្រឹត្តក្នុងនិព្វានដែលជានិស្សរណវិវេក ។

ឈ្មោះថា **វិរាគដ្ឋោ** ព្រោះជាសមុច្ឆេទវិរាគក្នុងវិរាគ ៥ គឺសភាពប្រាសចាកតម្រេក ។

ឈ្មោះថា **វិរាគចរិយដ្ឋោ** ព្រោះប្រព្រឹត្តក្នុងនិព្វានដែលជានិស្សរណវិរាគ ។

ឈ្មោះថា **និរោធដ្ឋោ** ព្រោះជាសមុច្ឆេទនិរោធក្នុងនិរោធ ៥ ។

ឈ្មោះថា **និរោធចរិយដ្ឋោ** ព្រោះប្រព្រឹត្តក្នុងនិព្វានដែលជាការរម្ងត់ទុក្ខ ។

ឈ្មោះថា **វោស្សគ្គដ្ឋោ** ព្រោះលោះលះដោយការលះបង់ និងការស្ទុះទៅពិតហើយ អរិយមគ្គ ឈ្មោះថា លោះលះដោយការលះបង់ ព្រោះលះកិលេសដោយអំណាចសមុច្ឆេទប្បហាន និងឈ្មោះថា លោះលះដោយការស្ទុះទៅ ព្រោះស្ទុះទៅកាន់និព្វាន ដោយធ្វើនិព្វានឲ្យជាអារម្មណ៍ ។ តែវិបស្សនា ឈ្មោះថា លោះលះដោយការលះបង់ ព្រោះលះកិលេសដោយតទង្គប្បហាន ។ ឈ្មោះថា លោះលះដោយការស្ទុះទៅ ព្រោះស្ទុះទៅកាន់និព្វានដោយការបង្អោនទៅកាន់

និព្វាននោះ ។ ក្នុងទីនេះមិនបានសំដៅយកការលោះដែលជាវិបស្សនានោះ ។

ឈ្មោះថា **វោស្សគ្គចរិយដ្ឋោ** ព្រោះប្រព្រឹត្តក្នុងការលោះ ។

ឈ្មោះថា **វិមុត្តដ្ឋោ** ព្រោះជាសមុច្ចេទវិមុត្តិក្នុងវិមុត្តិ ៥ ។

ឈ្មោះថា **វិមុត្តិចរិយដ្ឋោ** ព្រោះប្រព្រឹត្តក្នុងនិស្សរណវិមុត្តិ ។

[ ៤១-៤៤ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៤០ មាន **ឆន្ទដ្ឋោ** ជាដើម ដោយអំណាចឥទ្ធិបាទ ៤ នីមួយៗ ១០ ដោយឥទ្ធិបាទនីមួយៗ ក្នុងឥទ្ធិបាទ ៤ គឺឆន្ទៈ វីរិយៈ ចិត្ត វីមំសា ។

សភាពដែលបុគ្គលប្រាថ្នានឹងធ្វើ ឈ្មោះថា **ឆន្ទដ្ឋោ** ។

ក្នុងវេលាផ្តើមការនាតាំងឆន្ទៈជាគោល ឈ្មោះថា **មូលដ្ឋោ** ។

ឈ្មោះថា **ឋានដ្ឋោ** ព្រោះជាទីតាំងនៃសហជាតធម៌ ។ បាឋៈថា **បទដ្ឋោ** ក៏មាន ។

ឈ្មោះថា **បធានដ្ឋោ** ព្រោះភាពជាធំដែលជាហេតុឲ្យដល់នូវការសម្រេច ។

ឈ្មោះថា **ឥជ្ឈនដ្ឋោ** ក្នុងវេលាប្រកបសេចក្តីព្យាយាម ។

ឈ្មោះថា **អធិមោក្ខដ្ឋោ** ព្រោះប្រកបដោយសទ្ធា ។

ឈ្មោះថា **បគ្គហដ្ឋោ** ព្រោះប្រកបដោយសេចក្តីព្យាយាម ។

ឈ្មោះថា **ឧបដ្ឋានដ្ឋោ** ព្រោះប្រកបដោយសតិ ។

ឈ្មោះថា **អវិក្ខេបដ្ឋោ** ព្រោះប្រកបដោយសមាធិ ។

ឈ្មោះថា **ទស្សនដ្ឋោ** ព្រោះប្រកបដោយបញ្ញា ។

សភាពដែលផ្គង ឈ្មោះថា **វីរិយដ្ឋោ** ។ ក្នុងវេលាផ្តើមការនាតាំង

វីរិយៈជាគោល ឈ្មោះថា **មូលដ្ឋោ** ។ ឈ្មោះថា **បគ្គហដ្ឋោ** ព្រោះមានសេចក្តីព្យាយាមដោយខ្លួនឯង ។

សភាពដែលគិតជាដើម ឈ្មោះថា **ចិត្តដ្ឋោ** ។ ក្នុងវេលាផ្តើមការនាំតាំងចិត្តទុកជាគោល ឈ្មោះថា **មូលដ្ឋោ** ។

សភាពដែលចូលទៅពិចារណា ឈ្មោះថា **វីមំសដ្ឋោ** ។

ក្នុងវេលាផ្តើមការនាំតាំងវីមំសាទុកជាគោល ឈ្មោះថា **មូលដ្ឋោ** ។

ឈ្មោះថា **ឧស្សនដ្ឋោ** ព្រោះពិចារណាឃើញដោយខ្លួនឯង ។

[ ៤៥ ] ព្រះសារីបុត្ត បានសម្តែងវិសជ្ជនា ១៦ មានបទថា **ទុក្ខស្ស បីឡនដ្ឋោ** ជាដើម ដោយលក្ខណៈដ៏ពិតនៃសច្ចៈ ។

ឈ្មោះថា **បីឡនដ្ឋោ** ព្រោះការឃើញទុក្ខនោះឯង ។

ឈ្មោះថា **សង្ខតដ្ឋោ** ព្រោះការឃើញសមុទយៈដែលប្រមូលមកនូវទុក្ខ ។

ឈ្មោះថា **សន្តាបដ្ឋោ** ព្រោះការឃើញមគ្គដែលជាសភាពត្រជាក់សប្បាយព្រោះនាំការក្តៅក្រហាយព្រោះកិលេសទាំងពួងចេញទៅ ។

ឈ្មោះថា **វិបរិណាមដ្ឋោ** ព្រោះការឃើញនិរោធ ដែលជាវត្ថុមិនប្រែប្រួល ។

ឈ្មោះថា **អាយូហានដ្ឋោ** ព្រោះឃើញសមុទយៈនោះឯង ។

ឈ្មោះថា **និទានដ្ឋោ** ព្រោះការឃើញទុក្ខដែលប្រមូលមក ដោយសមុទយៈ ។

ឈ្មោះថា **សញ្ញោគដ្ឋោ** ព្រោះការឃើញនិរោធ ដែលជាធម៌ប្រាសចាក

គ្រឿងចង ។

ឈ្មោះថា **បលិពោធដ្ឋោ** ព្រោះការឃើញមគ្គ ដែលជាឧបាយនាំចេញចាកទុក្ខ ។

ឈ្មោះថា **និស្សរណដ្ឋោ** ព្រោះឃើញនិរោធនោះឯង ។

ឈ្មោះថា **វិវេកដ្ឋោ** ព្រោះការឃើញសមុទយៈដែលមិនមែនជាវិវេក ។

ឈ្មោះថា **អសង្ខតដ្ឋោ** ព្រោះការឃើញមគ្គដែលជាសង្ខតធម៌ ។

ឈ្មោះថា **អមតដ្ឋោ** ព្រោះការឃើញទុក្ខដែលជាពិស ។

ឈ្មោះថា **និយ្យានដ្ឋោ** ព្រោះការឃើញមគ្គនោះឯង ។

ឈ្មោះថា **ហេតុដ្ឋោ** ព្រោះការឃើញសមុទយៈ ដែលមិនមែនហេតុនៃការសម្រេចនិព្វាន ។

ឈ្មោះថា **ទស្សនដ្ឋោ** ព្រោះការឃើញនិរោធ ដែលឃើញបានដ៏សែនលំបាក ។

ឈ្មោះថា **អាធិបតេយ្យដ្ឋោ** ដូចគ្នានឹងត្រកូលដែលធំ ព្រោះការឃើញទុក្ខដូចគ្នានឹងបុគ្គលក្រីក្រ អធិប្បាយថា រមែងប្រាកដ ។ ព្រះសារីបុត្តពោលដល់សភាពនៃសច្ចៈនីមួយៗ មានលក្ខណៈនីមួយៗ ៤ ដោយការឃើញសច្ចៈនោះៗ និងដោយការឃើញសច្ចៈដទៃក្រៅពីសច្ចៈនោះ ដោយប្រការដូច្នេះ ។

[ ៤៦ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ១២ មាន **តថដ្ឋោ** ជាដើមដោយ ១២ បទ ដែលសង្គ្រោះចូលបានក្នុងធម៌ទាំងអស់ ។

បទថា **តថដ្ឋោ** បានដល់ សភាវៈតាមសេចក្តីពិត ។ បទថា **អនត្តដ្ឋោ**

បានដល់ សភាពដែលវៀរចាកអត្តា ។

បទថា **សច្ចដ្ឋោ** បានដល់ ការដែលមិនឃៀងឃាត ។

បទថា **បដិវេធដ្ឋោ** បានដល់ សភាពដែលគប្បីចាក់ធ្លុះ ។

បទថា **អភិជាននដ្ឋោ** បានដល់ សភាពដែលគប្បីដឹងក្រៃលែង ។

បទថា **បរិជាននដ្ឋោ** បានដល់ សភាពដែលគប្បីកំណត់ដឹង ដោយការកំណត់ដឹងដោយបញ្ញា ។

បទថា **ធម្មដ្ឋោ** បានដល់ សភាពដែលទ្រទ្រង់សភាវៈជាដើម ។

បទថា **ធាតុដ្ឋោ** បានដល់ សភាពជារបស់ទទេជាដើម ។

បទថា **ញាតដ្ឋោ** បានដល់ សភាពដែលអាចដើម្បីដឹងបាន ។

បទថា **សច្ឆិកិរិយដ្ឋោ** បានដល់ សភាពដែលគប្បីធ្វើឲ្យជាក់ច្បាស់ ។

បទថា **ផស្សនដ្ឋោ** បានដល់ សភាពដែលគប្បីពាល់ត្រូវដោយញាណ ។ បទថា **អភិសមយដ្ឋោ** បានដល់ សភាពដែលគួរដល់ដោយល្អយ៉ាងក្រៃលែងដោយបច្ចវេក្ខណញ្ញាណ ឬសភាពដែលគប្បីបានចំពោះដោយញាណ ។ សូម្បីការបានចំពោះ លោកក៏ពោលថា ការត្រាស់ដឹង ដូចប្រយោគជាដើមថា **អត្ថាភិសមយា ធីរោ** ធីរជនឈ្មោះថាបណ្ឌិត ព្រោះការបាននូវប្រយោជន៍ទាំងពីរនោះ ។

[ ៤៧ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៧ មាននេក្ខម្មៈជាដើម ដោយឧបចារដ្ឋាន ។

បទថា **នេក្ខម្មំ** បានដល់ ការមិនលោភដែលជាបដិបក្ខចំពោះកាមច្ឆន្ទៈ ។

បទថា **អាលោកសញ្ញា** បានដល់ សញ្ញាក្នុងអាលោកនិមិត្តដែលជាបដិបក្ខចំពោះថីនមិទ្ធៈ ។

បទថា **អវិក្ខេបោ** បានដល់ សមាធិជាបដិបក្ខចំពោះឧទ្ធច្ចៈ ។

បទថា **ធម្មវវត្ថានំ** បានដល់ ញាណដែលជាបដិបក្ខចំពោះវិចិកិច្ឆា ។

បទថា **ញាណំ** បានដល់ ញាណដែលជាបដិបក្ខចំពោះអវិជ្ជា ។

បទថា **បាមុជ្ជំ** បានដល់ បីតិដែលជាបដិបក្ខចំពោះអរតិ ។

ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៨ មានបឋមជ្ឈានជាដើម ដោយរូបសមាបត្តិ និងអរូបសមាបត្តិ ។ ម្យ៉ាងទៀត ខាងដើម ( ត្រង់ឃ្នាប ៩ ) ព្រះសារីបុត្តបានសម្តែងព្រហ្មវិហារ ៤ ក្នុងលំដាប់រូបសមាបត្តិដោយភ្ជាប់ជាមួយរូបជ្ឈាន ។

[ ៤៨ ] ព្រះសារីបុត្តបានសម្តែង **អនិច្ចានុបស្សនា** ជាដើម ដោយមហាវិបស្សនា ១៨ ក្នុងចំណែកខាងដើមរបស់លោកុត្តរមគ្គ ។ ក្នុងខាងដើម ( ឃ្នាប ១៥ ) ព្រះសារីបុត្តបានពោលដល់អនុបស្សនា ៧ ដែលប្រកបចូលជាមួយរូបជាដើម តែក្នុងទីនេះ លោកពោលទាំងអស់ ។ បើសួរថា ព្រោះហេតុអ្វី ទើបមិនពោលដល់កលាបសម្មសនានុបស្សនា ( ការពិចារណាជាកលាបៈ ) និងឧទយព្វយានុបស្សនា ។ ឆ្លើយថា កាលលោកពោលដល់អនុបស្សនាទាំងនេះ ឈ្មោះថា ពោលដល់អនុបស្សនាទាំង ២ នោះផងដែរ ព្រោះអនិច្ចានុបស្សនាជាដើម សម្រេចដោយអំណាចវិបស្សនាទាំង ២ នោះ ឬកាលពោលដល់វិបស្សនាទាំងនេះ ក៏ឈ្មោះថា ពោលដល់វិបស្សនាទាំង

២ នោះផង ព្រោះវិបស្សនាទាំង ២ នោះ វៀរអនិច្ចានុបស្សនាជាដើមចេញហើយ ក៏ប្រព្រឹត្តទៅមិនបាន ។

បទថា **ខយានុបស្សនា** បានដល់ ការឃើញ និងការដឹងនូវការរលត់នៃរូបក្ខន្ធជាដើមដែលជាបច្ចុប្បន្ន និងការឃើញ និងការដឹងសភាពរលត់នៃចិត្តនិងចេតសិកដែលមានរូបក្ខន្ធជាដើមនោះជាអារម្មណ៍ ក្នុងលំដាប់នៃការឃើញនូវការរលត់នៃខន្ធនោះៗ ។

បទថា **វយានុបស្សនា** បានដល់ ការឃើញ និងការដឹងនូវការរលត់នៃខន្ធក្នុងអតីត និងអនាគត អនុលោមតាមខយានុបស្សនានោះឯង ក្នុងលំដាប់នៃការឃើញនូវការរលត់នៃខន្ធក្នុងបច្ចុប្បន្ន ។

បទថា **វិបរិណាមានុបស្សនា** បានដល់ ព្រោះបង្អោនទៅក្នុងនិរោធដែលបានដល់ការរលត់នោះ ពេលនោះ ទើបមានការឃើញ និងការដឹងនូវការប្រែប្រួលនៃខន្ធទាំងពួងថា ខន្ធដែលជាអតីត អនាគត បច្ចុប្បន្នទាំងអស់ សុទ្ធតែមានការប្រែប្រួល ។

បទថា **អនិមិត្តានុបស្សនា** បានដល់ ការពិចារណាឃើញនូវការមិនទៀងរបស់ព្រះយោគាវចរ ដែលឃើញការប្រែប្រួលរបស់សង្ខារទាំងពួងយ៉ាងនេះហើយពិចារណាឃើញ ដោយភាពជារបស់មិនទៀងនោះឯង ឈ្មោះថាអនិមិត្តានុបស្សនា ព្រោះមិនមានគ្រឿងសម្គាល់ដែលជាសភាពទៀង ដោយការលះបង់គ្រឿងសម្គាល់ដែលជាសភាពទៀងចេញបាន ។

បទថា **អប្បណិហិតានុបស្សនា** បានដល់ ការពិចារណាឃើញទុក្ខ

ដែលប្រព្រឹត្តទៅក្នុងលំដាប់នៃអនិច្ចានុបស្សនានោះឯង ឈ្មោះថា អប្បណិ-
ហិតានុបស្សនា ព្រោះមិនមានទីតាំង ដោយអំណាចការលះសេចក្តីប្រាថ្នា
សុខ ។

បទថា **សុញ្ញតានុបស្សនា** បានដល់ ការពិចារណាឃើញអនត្តាដែល
ប្រព្រឹត្តទៅ ក្នុងលំដាប់ទុក្ខានុបស្សនានោះឯង ឈ្មោះថា សុញ្ញតានុបស្សនា
ព្រោះឃើញសភាពជារបស់សូន្យទទេចាកខ្លួន ដោយអំណាចការលះនូវការ
ប្រកាន់មាំនូវត្តខ្លួន ។

បទថា **អធិប្បញ្ញាធម្មវិបស្សនា** បានដល់ កាលព្រះយោគាវចរពិចារណា
ម្តងហើយម្តងទៀត នូវការរលត់នៃសង្ខារទាំងឡាយយ៉ាងនេះ ហើយពិចារណា
ឃើញដោយភាពជារបស់មិនទៀងជាដើម វិបស្សនាដែលកាន់យកភាពទទេ
ប្រព្រឹត្តទៅដោយអំណាចការរលត់ថា សង្ខារទាំងឡាយរមែងរលត់ មានតែ
ការស្លាប់របស់សង្ខាររមែងមិនមានអ្វីដទៃ វិបស្សនានោះ ហៅថា អធិប្បញ្ញា
ធម្មវិបស្សនា ព្រោះវិគ្គហៈថា អធិប្បញ្ញាផង ការឃើញច្បាស់ក្នុងធម៌ទាំង
ឡាយផង ។

បទថា **យថាភូតញ្ញាណទស្សនំ** បានដល់ ភយតូបដ្ឋានញ្ញាណ ( បញ្ញា
ពិចារណាឃើញសង្ខារប្រាកដជារបស់គួរខ្លាច ) ដែលប្រព្រឹត្តទៅហើយថា
សង្ខារទាំងឡាយគួរខ្លាច ព្រោះឃើញការរលត់ហើយរលត់ទៀត ។

បទថា **អាទីនវានុបស្សនា** បានដល់ ញាណក្នុងការឃើញទោសក្នុងភព
ទាំងពួងជាដើម ដែលកើតឡើងហើយដោយអំណាចភយតូបដ្ឋានញ្ញាណ ។

កាលលោកពោលដល់ភយតូបដ្ឋានានុបស្សនា និងអាទីនវានុបស្សនា ក៏ឈ្មោះថា លោកពោលដល់និព្វិទានុបស្សនាទុកក្នុងទីនេះផងដែរ ព្រោះបាលី ( ក្នុងបដិសម្ភិទាមគ្គ ) ថា បញ្ញាក្នុងការប្រាកដឡើងថាជាភ័យឯណាក្តី ការដឹងក្នុងទោសឯណាក្តី ការនឿយណាយឯណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ក្នុងទីនេះ លោកមិនពោល ព្រោះលោកពោលជាបទទី ៤ ខាងដើមហើយ ។

បទថា **បដិសង្ខានុបស្សនា** បានដល់ អនិច្ចានុបស្សនាញាណ ទុក្ខានុបស្សនាញាណ អនត្តានុបស្សនាញាណ ដែលកើតឡើងដោយមុញ្ចិតុកម្យតាញាណ ដែលធ្វើឧបាយដើម្បីរួចផុត ដែលគេស្គាល់ថា បដិសង្ខានុបស្សនា ។ កាលលោកពោលដល់បដិសង្ខានុបស្សនា ឈ្មោះថា លោកពោលដល់មុញ្ចិតុកម្យតាញាណ និងសង្ខារុបេក្ខាញាណ ព្រោះព្រះបាលី ( ក្នុងបដិសម្ភិទាមគ្គ ) ថា មុញ្ចិតុកម្យតាញាណណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី ធម៌ទាំងនោះ មានសេចក្តីជាមួយគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ។

បទថា **វិវដ្ដនានុបស្សនា** បានដល់ គោត្រភូញាណដែលកើតឡើងដោយអំណាចអនុលោមញាណ ។ កាលលោកពោលដល់គោត្រភូញាណ ក៏ឈ្មោះថាជាការពោលដល់អនុលោមញាណផង ព្រោះគោត្រភូញាណសម្រេចដោយអនុលោមញាណ ។ លំដាប់នៃមហាវិបស្សនា ១៨ ដែលព្រះសារីបុត្តពោលយ៉ាងនេះ រមែងសមនឹងបាលី ។ ដូចលោកពោលទុកក្នុងឥន្ទ្រិយកថា ( ក្នុង

បដិសម្ភិទាមគ្គ ) ថា ឥន្ទ្រិយទាំង ៥ ដោយអំណាចបឋមជ្ឈាន រលាស់ចាក ឥន្ទ្រិយទាំង ៥ ក្នុងបុព្វភាគ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចទុតិយជ្ឈាន រលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងបឋមជ្ឈាន ១ ។

លោកពោលដល់ឥន្ទ្រិយតាមលំដាប់ក្រៃលែងឡើងទៅ ដោយន័យដើម រហូតដល់អរហត្តផល ។ ព្រោះហេតុនោះ មហាវិបស្សនា ១៨ រមែងត្រឹមត្រូវជាមួយបាលីតាមលំដាប់ដូចដែលពោលហើយ ។

លោកពោលក្នុងវិសុទ្ធិមគ្គថា ពាក្យថា ខយានុបស្សនា បានដល់ញាណរបស់ព្រះយោគាវចរដែលបែកឃនសញ្ញាចេញ ហើយឃើញការអស់ទៅយ៉ាងនេះថា ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ។ ពាក្យថា វិបរិណាមានុបស្សនា បានដល់ ការឈានកន្លងលំដាប់នោះៗ ដោយរូបសត្តក: និងអរូបសត្តក:ជាដើម ហើយឃើញការប្រព្រឹត្តទៅដោយប្រការដទៃ ។ម្យ៉ាងទៀត ការឃើញការប្រែប្រួលដោយអាការ ២ គឺជរា និងមរណៈរបស់សត្វដែលកើតមកហើយ ។ ពាក្យថា យថាភូតញ្ញាណទស្សនៈ បានដល់ ការកំណត់នាមរូប មួយអន្លើដោយបច្ច័យ ។ ពាក្យក្នុងវិសុទ្ធិមគ្គនោះ ប្រាកដដូចជំទាស់ជាមួយបាលី ។ ពាក្យថា វិវដ្ដនានុបស្សនា លោកពោលថា បានដល់សង្ខារុបេក្ខាញាណ និងអនុលោមញ្ញាណ ។ ពាក្យនោះ ដូចជំទាស់នឹងបាលី ។ ព្រោះថា ក្នុងកថាពោលអំពីញាណចរិយា លោកពោលអាវជ្ជនៈញែកគ្នានៃញាណដែលមានអាវជ្ជនៈញែកគ្នាថា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់អនិច្ចានុបស្សនា ( ការពិចារណាឃើញថា មិនទៀង ) ឈ្មោះថា

វិញ្ញាណចរិយា គួរអនិច្ចានុបស្សនា ឈ្មោះថា ញាណចរិយា ។បេ។ អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់បដិសង្ខានុបស្សនា ( ការពិចារណាឃើញដោយឧបាយបញ្ញា ) ឈ្មោះថា វិញ្ញាណចរិយា គួបដិសង្ខានុបស្សនា ឈ្មោះថា ញាណចរិយា[១] ។

លោកពោលដល់អាវជ្ជនៈដើម្បីវិវដ្ដនានុបស្សនា តែពោលថា វិវដ្ដនានុបស្សនាជាញាណចរិយា ។ បើសង្ខារុបេក្ខាញាណ និងអនុលោមញ្ញាណនឹងគប្បីឈ្មោះថា វិវដ្ដនានុបស្សនា ក៏គួរពោលដល់អាវជ្ជនៈ ព្រោះអាវជ្ជនៈរបស់វិវដ្ដនានុបស្សនានោះមានព្រម និងដើម្បីប្រយោជន៍ដល់វិវដ្ដនានុបស្សនានោះ តែលោកមិនពោលដល់អាវជ្ជនៈ ដើម្បីប្រយោជន៍ដល់វិវដ្ដនានុបស្សនានោះ ។ ឯគោត្រភូញាណមិនមានអាវជ្ជនៈបែកគ្នា ព្រោះកើតឡើងក្នុងអាវជ្ជនវីថិនៃអនុលោមញ្ញាណប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទោះពោលថា គោត្រភូញាណនោះឯង ជាវិវដ្ដនានុបស្សនា រមែងត្រឹមត្រូវ ព្រោះលោកមិនពោលដល់អាវជ្ជនៈ ដើម្បីប្រយោជន៍ដល់វិវដ្ដនានុបស្សនា ។

[ ៤៩ ] ព្រះសារីបុត្តបានសម្ដែងវិសជ្ជនា ៨ មានសោតាបត្តិមគ្គជាដើម ដោយអំណាចនៃមគ្គ និងផលដែលជាលោកុត្តរ ។

ការដល់ក្រសែនៃមគ្គ ឈ្មោះថា សោតាបត្តិមគ្គ មគ្គ គឺសោតាបត្តិ ឈ្មោះថា សោតាបត្តិមគ្គ ។

ផលនៃការដល់នូវក្រសែ ឈ្មោះថា សោតាបត្តិផល ឈ្មោះថា សមាបត្តិ

---

១- បិដកលេខ ៦៩ ឃ្នាប ១៦៩ ។

ព្រោះអត្ថថា ចូលដល់ ។ សមាបត្តិ គឺសោតាបត្តិផល ឈ្មោះថា សោតាបត្តិផលសមាបត្តិ ។

ឈ្មោះថា សកទាគាមី ព្រោះអត្ថថា មកកាន់លោកនេះតែម្តងប៉ុណ្ណោះ ដោយអំណាចបដិសន្ធិ មគ្គនៃសកទាគាមីនោះ ឈ្មោះថា សកទាគាមិមគ្គ ។ ផលនៃសកទាគាមី ឈ្មោះថា សកទាគាមិផល ។

ឈ្មោះថា អនាគាមី ព្រោះអត្ថថា មិនមកកាន់កាមភព ដោយអំណាចបដិសន្ធិនោះឯង មគ្គនៃអនាគាមីនោះ ឈ្មោះថា អនាគាមិមគ្គ ។ ផលនៃអនាគាមី ឈ្មោះថា អនាគាមិផល ។

ឈ្មោះថា **អរហំ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ព្រោះកម្ចាត់សឹកសត្រូវ គឺកិលេស ព្រោះកាច់បំបាក់កាំរបស់សង្សារចក្កបាន ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ព្រោះគួរដល់បច្ច័យជាដើម ។ ភាពជាអរហន្ត ឈ្មោះថា អរហត្ត នោះ គឺអ្វី គឺអរហត្តផល ។ មគ្គនៃអរហត្ត ឈ្មោះថា អរហត្តមគ្គ ។ ផលនៃអរហត្តនោះឯង ឈ្មោះថា អរហត្តផល ។

[ ៥០-៥៣ ] ព្រះសារីបុត្តបានសម្តែងវិសជ្ជនា ៣៣ មានបទថា **អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ** ជាខាងដើម មាន **តថដ្ឋេន សច្ចា** ជាទីបំផុត ។ វិសជ្ជនាមានស្មើគ្នានឹងវិសជ្ជនា ៣៣ ខាងដើម ( ត្រង់ឃ្នាប ៣២ ដល់ឃ្នាប ៣៦ ) មានបទថា **ឥន្ទ្រិយស្ស អធិមោក្ខដ្ឋោ** ជាដើម ។ លោកបានសម្តែងអត្ថដោយធម៌ទាំងឡាយក្នុងទីនោះសព្វគ្រប់ហើយ ក្នុងទីនេះ បានសម្តែងធម៌ទាំងឡាយ ដោយអត្ថនេះជាការផ្សេងគ្នា ។ ការផ្សេងគ្នានៃវិសជ្ជនា ៤ មាន

**អវិក្ខេបដ្ឋេន សមថោ** ជាដើម និងនៃវិសជ្ជនា ៤ មាន **សមថស្ស អវិក្ខេ-បដ្ឋោ** ( ឃ្នាប ៣១ ) ជាដើម គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនោះឯង ។

[ ៥៤ ] ព្រះសារីបុត្តបានសម្ដែងវិសជ្ជនា ៨ មានបទថា **សំវរដ្ឋេន** ជាដើម ដោយអំណាចធម៌មានសីលជាខាងដើម មានពលជាទីបំផុត ។

សីល ៤ មានបាតិមោក្ខសំវរសីលដែលបរិសុទ្ធដោយល្អជាដើម ឈ្មោះថា **សីលវិសុទ្ធិ** ព្រោះជម្រះមន្ទិល គឺភាពជាអ្នកទ្រុស្តសីល ។

សមាបត្តិ ៨ មួយអន្លើដោយឧបចារៈ ឈ្មោះថា **ចិត្តវិសុទ្ធិ** ។ ក្នុងទីនេះលោកពោលសមាធិដោយមាតិកាថាចិត្ត ។ សមាធិនោះ ឈ្មោះថា **ចិត្តវិសុទ្ធិ** ព្រោះជម្រះមន្ទិលរបស់ចិត្ត ។

ការឃើញនាមរូបតាមសេចក្ដីពិត ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ឈ្មោះថា **ទិដ្ឋិ-វិសុទ្ធិ** ព្រោះជម្រះមន្ទិលនៃទិដ្ឋិ ៧ ។

បទថា **មុត្តដ្ឋេន** បានដល់ ដោយអត្ថថា រួចផុតចាកឧបក្កិលេស ដោយអំណាចតទង្គវិមុត្តិ និងដោយអត្ថថា បង្អោនទៅក្នុងអារម្មណ៍ ។

បទថា **វិមោក្ខោ** បានដល់ ការរួចផុតដោយតទង្គវិមុត្តិ ។

បទថា **បដិវេធដ្ឋេន វិជ្ជា** បានដល់ បុព្វេនិវាសានុស្សតិញ្ញាណ ឈ្មោះថា វិជ្ជា ដោយអត្ថថា ចាក់ធ្លុះក្នុងកពមុន ទិព្វចក្ខុញ្ញាណ ឈ្មោះថា វិជ្ជា ដោយអត្ថថា ចាក់ធ្លុះការកើត និងការរលត់នៃសត្វទាំងឡាយ អាសវក្ខ-យញ្ញាណ ឈ្មោះថា វិជ្ជា ដោយអត្ថថា ចាក់ធ្លុះលើសច្ចៈ ។

*បទថា* **បដិវេធដ្ឋេន** *បានដល់ ដោយអត្ថថា ដឹងច្បាស់ ។*

*បទថា* **បរិច្ចាគដ្ឋេន វិមុត្តិ** *បានដល់ ឈ្មោះថា ផលវិមុត្តិ ព្រោះផុតចាកវត្ថុដែលលះបង់បានហើយ ។*

*បទថា* **សមុច្ឆេទដ្ឋេន ខយេ ញាណំ** *បានដល់ ញាណក្នុងអរិយមគ្គដែលធ្វើនូវការអស់កិលេស ដោយកាត់កិលេសបានជាសមុច្ឆេទ ។*

*បទថា* **បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ** *បានដល់ ញាណក្នុងអរិយផល ដែលកើតឡើងក្នុងទីបំផុតនៃការមិនកើតឡើងនៃកិលេស ដែលសម្លាប់ដោយមគ្គនោះៗ ដែលជាការមិនកើតដោយអំណាចបដិសន្ធិ ព្រោះរម្ងាប់ដោយបយោគ គឺមគ្គកិច្ចបាន ។*

*ព្រះសារីបុត្ត បានសម្តែងវិសជ្ជនា ៩ មានបទថា* **ឆន្ទោ មូលដ្ឋេន** *ជាដើម ដោយអំណាចអរិយមគ្គដែលជាខាងដើម កណ្តាល និងចុងបំផុត ។*

*បទថា* **ឆន្ទោ មូលដ្ឋេន** *បានដល់ ឆន្ទៈ គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើកុសលធម៌ទាំងឡាយគួរដឹងក្រៃលែង ដោយអត្ថថាជាមូល ព្រោះជាឫសគល់នៃកិច្ចបដិបត្តិ និងជាឫសគល់នៃការសម្រេច ។*

*បទថា* **មនសិការោ សមុដ្ឋានដ្ឋេន** *បានដល់ យោនិសោមនសិការគួរដឹងក្រៃលែង ដោយអត្ថថា ជាសមុដ្ឋាន ព្រោះញុំាងកុសលធម៌ទាំងអស់ឲ្យតាំងឡើង ។*

*បទថា* **ផស្សោ សមោធានដ្ឋេន** *មានអធិប្បាយថា ព្រោះហេតុដែលវេទនាជាបធានហេតុនៃតណ្ហាដោយចំពោះ ម្យ៉ាងទៀត ការលះតណ្ហារមែងលះ*

*បានដោយកំណត់ដឹងវេទនាដោយចំពោះ ឯផស្សៈជាបច្ច័យនៃវេទនានោះ កាលបើកំណត់ដឹងផស្សៈហើយ ឈ្មោះថា កំណត់ដឹងវេទនាផង ហេតុនោះ ទើបលោកពោលផស្សៈក្នុងវត្ថុដែលគួរដឹងក្រៃលែង ៧ ទុកមុន ។ ផស្សៈនោះ ឈ្មោះថា គួរដឹងក្រៃលែង ដោយអត្ថថា ប្រមូលមក ព្រោះប្រកាសដោយអំណាចនៃហេតុរបស់ខ្លួន ពោល គឺការប្រមូលមកនៃធម៌ទាំង ៣ និងព្រោះលោកពោលថា មានការប្រមូលមករួមគ្នារវាងវត្ថុ អារម្មណ៍ និងវិញ្ញាណ ៣ យ៉ាងជាអាការប្រាកដ តែអាចារ្យពួកខ្លះពោលថា ផស្សៈ គឺញាណផស្សៈ ។*

*ព្រោះវេទនាធ្វើចិត្ត និងចេតសិកឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងប្រជុំ គឺរមែងចូលទៅក្នុងចិត្ត និងចេតសិកនោះ ឬចូលទៅកាន់ចិត្តសន្តាននោះឯង ហេតុនោះ ទើបលោកពោលថា* **សមោសរណដ្ឋេនអភិញ្ញេយ្យា** *ដូច្នេះ ។*

*ចំណែកអាចារ្យពួកមួយពោលថា វត្ថុដែលគួរកំណត់ដឹងទាំងអស់ រមែងប្រជុំចុះក្នុងវេទនាទាំងឡាយ កាលបើកំណត់ដឹងវេទនាហើយ ឈ្មោះថា កំណត់ដឹងទីតាំងរបស់តណ្ហាទាំងអស់បាន ។ នោះព្រោះហេតុអ្វី ព្រោះតណ្ហាទាំងអស់មានវេទនាជាបច្ច័យ ព្រោះហេតុនោះ វេទនាគួរដឹងក្រៃលែង ដោយអត្ថថា ប្រជុំ ព្រោះសមាធិ ឈ្មោះថា ជាប្រមុខ ជាធំនៃកុសលធម៌ទាំងឡាយ ព្រោះប្រមូលនូវចិត្ត និងចេតសិកទាំងឡាយ ដូចជហ្វារបស់ផ្ទះកំពូល ជាប្រធានព្រោះទ្រទ្រង់នូវបន្ទង់ទាំងឡាយ ដូច្នោះ ទើបលោកពោលថា* **សមាធិ បមុខដ្ឋេន** *ដូច្នេះ ។ បាឋៈថា* **ធាមុខដ្ឋេន** *ដូច្នេះក៏មាន ។*

*ព្រោះសតិជាធំក្នុងការប្រាកដឡើងនៃអារម្មណ៍ របស់អ្នកចម្រើនសមថ-*

វិបស្សនា កាលអារម្មណ៍ប្រាកដឡើងដោយសតិ កុសលធម៌ទាំងអស់ រមែងធ្វើកិច្ចរៀងៗ ខ្លួនឲ្យសម្រេច ហេតុនោះ ទើបលោកពោលថា **សតិអាធិបតេយ្យដ្ឋេន** ដូច្នេះ ។

បទថា **បញ្ញា តទុត្តរដ្ឋេន** បានដល់ អរិយមគ្គប្បញ្ញា ឈ្មោះថា គួរដឹងក្រៃលែង ដោយអត្ថថា ក្រៃលែង គឺដោយអត្ថថា ប្រសើរជាងកុសលធម៌នោះៗ ។ មួយវិញទៀត ឈ្មោះថា **តទុត្តរា** ព្រោះអត្ថថា ខ្ពង់ផុត គឺឈានកន្លងចាកកិលេសទាំងឡាយ ឬចាកសង្សារវដ្តជាងកុសលធម៌នោះ អត្ថនៃភាវៈដែលប្រសើរជាងកុសលធម៌នោះ ឈ្មោះថា **តទុត្តរដ្ឋោ** ដោយអត្ថថា ប្រសើរជាងកុសលធម៌នោះៗ ។ បាឋៈថា **តតុត្តរដ្ឋេន** ដូច្នេះក៏មាន សេចក្ដីថា ដោយអត្ថថា ក្រៃលែងជាងធម៌នោះ ។

បទថា **វិមុត្តិ សារដ្ឋេន** បានដល់ ផលវិមុត្តិ ឈ្មោះថា ជាខ្លឹមសារ ព្រោះមានការតាំងមាំ ដោយអំណាចមិនវិនាស ព្រោះឈានកន្លងដល់វិមុត្តិនោះហើយ មិនមានវត្ថុដទៃដែលគប្បីស្វែងរក ក៏ឈ្មោះថា ជាខ្លឹមសារ ។ វិមុត្តិនោះគួរដឹងក្រៃលែង ដោយអត្ថថា ជាខ្លឹមសារនោះ ។

បទថា **អមតោគធំ និព្វានំ** មានវិគ្គហៈថា ឈ្មោះថា **អមតំ** ព្រោះនិព្វាននោះមិនមាន **មតំ** ពោល គឺសេចក្ដីស្លាប់ ។ ឈ្មោះថា **អមតំ** ព្រោះជាថ្នាំកែពិស គឺកិលេសដូច្នេះក៏មាន ។ ឈ្មោះថា **ឱគធំ** ព្រោះជាទីតាំងរបស់សត្វទាំងឡាយដោយការធ្វើឲ្យជាក់ច្បាស់ ។ ឈ្មោះថា **និព្វានំ** ព្រោះអត្ថថារលត់ដោយឥតសេសសល់ ព្រោះស្ងប់ចាកទុក្ខក្នុងសង្សារ ។ ឈ្មោះថា **និព្វានំ**

ព្រោះអត្ថថា ក្នុងនិព្វាននេះមិនមានគ្រឿងរួបរឹត គឺតណ្ហា ។ និព្វាននោះគួរដឹងក្រៃលែងព្រោះពាក្យប្រៀនប្រដៅដល់ទីបំផុតហើយ ។ ក្នុងអភិញ្ញេយ្យនិទ្ទេសនេះរួមវិសជ្ជនាបាន ៧៧៤០ បទ ដោយប្រការដូច្នេះ ។

[ ៥៥ ] ឥឡូវនេះ នឹងសរុបធម៌ទាំងនោះ ដែលព្រះសារីបុត្តបានសម្តែងហើយយ៉ាងនេះថា ពួកធម៌ណាៗ ដែលបុគ្គលចេះប្រាកដហើយ ពួកធម៌នោះៗ ឈ្មោះជាបុគ្គលដឹងហើយ អធិប្បាយថា ជាគុណដែលដឹងហើយព្រោះធ្វើពាក្យនោះឲ្យជាប្រធាន ។

បទថា **តំញាតដ្ឋេន ញាណំ** បានដល់ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងធម៌មានប្រការដូចពោលហើយនោះ ។

បទថា **បជាននដ្ឋេន បញ្ញា** បានដល់ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងដោយអាការទូទៅ ។

ពាក្យសួរ ដែលលោកសួរតាំងពីដើមថា **តេន វុច្ចតិ** លោកសម្តែងសរុប ។ មានអធិប្បាយថា ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ពួកធម៌នេះ បុគ្គលត្រូវដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ដោយប្រការដូច្នេះ ។ល។

## អដ្ឋកថាអភិញ្ញេយ្យនិទ្ទេស ចប់

## ទុតិយភាណវារៈ ចប់

# សុត្តន្តបិដក

[ ៥៦ ] ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវកំណត់ដឹង បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ធម៌ ១ បុគ្គលត្រូវកំណត់ដឹង គឺផស្សៈប្រកបដោយអាសវៈ ដែលជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ ២ ត្រូវកំណត់ដឹង គឺនាម ១ រូប ១ ពួកធម៌ ៣ ត្រូវកំណត់ដឹង គឺវេទនា ៣ ពួកធម៌ ៤ ត្រូវកំណត់ដឹង គឺអាហារ ៤ ពួកធម៌ ៥ ត្រូវកំណត់ដឹង គឺឧបាទានក្ខន្ធ ៥ ពួកធម៌ ៦ ត្រូវកំណត់ដឹង គឺអាយតនៈខាងក្នុង ៦ ពួកធម៌ ៧ ត្រូវកំណត់ដឹង គឺវិញ្ញាណដ្ឋិតិ ៧ ពួកធម៌ ៨ ត្រូវកំណត់ដឹង គឺលោកធម៌ ៨ ពួកធម៌ ៩ ត្រូវកំណត់ដឹង គឺសត្តាវាស ៩ ពួកធម៌ ១០ ត្រូវកំណត់ដឹង គឺអាយតនៈ ១០ ។

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង បុគ្គលត្រូវកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួង ដែលត្រូវកំណត់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុត្រូវកំណត់ដឹង រូបត្រូវកំណត់ដឹង ចក្ខុវិញ្ញាណត្រូវកំណត់ដឹង ចក្ខុសម្ផស្សត្រូវកំណត់ដឹង ការទទួលអារម្មណ៍ណាទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវកំណត់ដឹង សោតៈត្រូវកំណត់ដឹង សទ្ទៈត្រូវកំណត់ដឹង ។បេ។ ឃានៈត្រូវកំណត់ដឹង គន្ធៈត្រូវកំណត់ដឹង ជិវ្ហាត្រូវកំណត់ដឹង រសៈត្រូវកំណត់ដឹង កាយត្រូវកំណត់ដឹង ផោដ្ឋព្វៈត្រូវកំណត់ដឹង មនៈត្រូវកំណត់ដឹង ធម្មារម្មណ៍ត្រូវកំណត់ដឹង មនោវិញ្ញាណត្រូវកំណត់ដឹង មនោសម្ផស្សត្រូវកំណត់ដឹង ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី

មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវកំណត់ដឹង ។

[ ៥៨ ] រូប បុគ្គលត្រូវកំណត់ដឹង វេទនាត្រូវកំណត់ដឹង សញ្ញាត្រូវកំណត់ដឹង សង្ខារទាំងឡាយត្រូវកំណត់ដឹង វិញ្ញាណត្រូវកំណត់ដឹង ចក្ខុ ។បេ។ ជរាមរណៈ ។បេ។ ព្រះនិព្វានឈ្មោះអមតៈជាទីពំនាក់ ( របស់ពួកសត្វ ) ត្រូវកំណត់ដឹង ដោយអត្ថថា ចប់ស្រេច ( នៃសាសនា ) កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ ដល់ការបានចំពោះនូវធម៌ទាំងឡាយណាៗ ធម៌ទាំងឡាយនោះៗ ក៏បុគ្គលបានចំពោះហើយ ធម៌ទាំងឡាយនោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង ។

[ ៥៩ ] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវនេក្ខម្មៈ នេក្ខម្មៈក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអព្យាបាទ អព្យាបាទក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអាលោកសញ្ញា អាលោកសញ្ញាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអវិក្ខេបៈ ( ការមិនរាយមាយ ) អវិក្ខេបៈក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវធម្មវវត្ថាន: ( ការកំណត់នូវធម៌ ) ធម្មវវត្ថាន: ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ ដល់ការបានចំពោះនូវញាណ ញាណក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវបាមុជ្ជ ( សេចក្ដីរីករាយ ) បាមុជ្ជ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង ។

[ ៦០ ] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវបឋមជ្ឈាន បឋមជ្ឈានបុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯងនូវទុតិយជ្ឈាន ។បេ។ នូវតតិយជ្ឈាន កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវចតុត្ថជ្ឈាន ចតុត្ថជ្ឈានក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអាកាសានញ្ចាយតនសមាបត្តិ អាកាសានញ្ចាយតនសមាបត្តិក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ ដល់ការបានចំពោះនូវវិញ្ញាណញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង

យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវ អាកិញ្ចញ្ញាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ ដល់ការបានចំពោះនូវនេវ-សញ្ញានាសញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង ។

[ ៦១ ] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវ អនិច្ចានុបស្សនា អនិច្ចានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវទុក្ខានុបស្សនា ទុក្ខានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវ អនត្តានុបស្សនា អនត្តានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវនិព្វិទានុបស្សនា និព្វិទានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ ដល់ការបានចំពោះនូវវិរាគានុបស្សនា វិរាគានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ

ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង បុគ្គលកាល ព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវនិរោធានុបស្សនា និរោធានុ-បស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវបដិនិស្សគ្គានុបស្សនា បដិនិស្សគ្គានុបស្សនា ក៏បុគ្គលបាន ចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវ ខយានុបស្សនា ខយានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវវយានុបស្សនា វយានុបស្សនាក៏បុគ្គល បានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយ ផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវ វិបរិណាមានុបស្សនា វិបរិណាមានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គល ព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអនិមិត្តានុបស្សនា អនិមិត្តា-នុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ ការបានចំពោះ នូវអប្បណិហិតានុបស្សនា អប្បណិហិតានុបស្សនាក៏បុគ្គលបាន ចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង

យ៉ាងនេះឯង បុគ្គលកាលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវសុញ្ញតានុបស្សនា សុញ្ញតានុបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង ។

[ ៦២ ] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអធិប្បញ្ញាធម្មវិបស្សនា អធិប្បញ្ញាធម្មវិបស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ ដល់ការបានចំពោះនូវយថាភូតញ្ញាណទស្សនៈ យថាភូតញ្ញាណទស្សនៈ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអាទីនវានុបស្សនា អាទីនវានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវបដិសង្ខានុបស្សនា បដិសង្ខានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវវិវដ្ដនានុបស្សនា វិវដ្ដនានុ-បស្សនាក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផងពិចារណាហើយផងយ៉ាងនេះឯង ។

[ ៦៣ ] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវសោតាបត្តិមគ្គ សោតាបត្តិមគ្គ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា

បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវសកទាគាមិមគ្គ សកទាគាមិមគ្គក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអនាគាមិមគ្គ អនាគាមិមគ្គក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអរហត្តមគ្គ អរហត្តមគ្គ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវធម៌ទាំងឡាយណាៗ ធម៌ទាំងឡាយនោះៗ ក៏បុគ្គលបានចំពោះហើយ ធម៌ទាំងឡាយនោះឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផងយ៉ាងនេះឯង ឈ្មោះថាញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញាដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ លោកពោលថា ការប្រុងប្រយ័ត្នចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវកំណត់ដឹង បញ្ញាជាគ្រឿងដឹង នូវការប្រុងប្រយ័ត្នចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

# តតិយភាណវារៈ

## អដ្ឋកថា បរិញ្ញេយ្យនិទ្ទេស

[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិញ្ញេយ្យនិទ្ទេសដូចតទៅនេះថា លោកសង្គ្រោះបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ដោយ **បរិញ្ញា** សព្ទក៏ពិត តែក្នុងនិទ្ទេសនេះ លោកបំណងយកតីរណបរិញ្ញាប៉ុណ្ណោះ ព្រោះលោកពោលដល់ញាតបរិញ្ញា ដោយពាក្យថា **អភិញ្ញេយ្យា** ហើយក្នុងខាងដើម ព្រោះលោកពោលដល់បហានបរិញ្ញា ដោយពាក្យថា **បហាតព្វា** ក្នុងវគ្គតទៅ ។

បទថា **ផស្សោ សាសវោ ឧបាទានិយោ** បានដល់ ផស្សៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាបច្ច័យនៃអាសវៈ និងឧបាទាន ។ ពិតហើយ ផស្សៈនោះឈ្មោះថា **សាសវោ** ព្រោះធ្វើខ្លួនឲ្យជាអារម្មណ៍ ព្រមជាមួយអាសវៈដែលប្រព្រឹត្តទៅ ឈ្មោះថា **ឧបាទានិយោ** ព្រោះចូលដល់ភាពជាអារម្មណ៍ ហើយអនុគ្រោះដល់ឧបាទានដោយការចងទុកជាមួយឧបាទាន ។ ព្រោះកាលកំណត់ដឹងផស្សៈដោយតីរណបរិញ្ញាហើយ អរូបធម៌ដ៏សេស រមែងកំណត់ដឹងបានដោយមានផស្សៈជាប្រធាន និងរូបធម៌ រមែងកំណត់ដឹងបានដោយអនុលោមតាមផស្សៈនោះ ហេតុនោះ ទើបលោកពោលផស្សៈតែម្យ៉ាងប៉ុណ្ណោះ ។ ក្នុងធម៌ដ៏សេស ក៏គប្បីប្រកបតាមដែលប្រកបបាន ដោយប្រការដូច្នេះ ។

បទថា **នាមំ** បានដល់ អរូបក្ខន្ធ ៤ និងនិព្វាន ។ បទថា **រូបំ** បានដល់ មហាភូតរូប ៤ និងឧបាទាយរូប ២៤ ដែលអាស្រ័យមហាភូតរូប ៤ ។ ខន្ធ

៤ ឈ្មោះថា នាម ព្រោះអត្ថថា បង្អោនទៅ ។ ពិតហើយ ខន្ធទាំងនោះរមែង បង្អោនទៅចំពោះមុខកាន់អារម្មណ៍ ។ នាមទាំងអស់ក៏ឈ្មោះថា នាម ដោយអត្ថថា ឲ្យបង្អោនទៅ ។ ពិតហើយ ខន្ធ ៤ ញុំាងគ្នានិងគ្នាឲ្យបង្អោនទៅក្នុងអារម្មណ៍ និញ្វន ញុំាងធម៌ដែលមិនមានទោសឲ្យបង្អោនទៅក្នុងខ្លួន ព្រោះជាអារម្មណប្បច្ច័យ និងអធិបតិប្បច្ច័យ ។ ឈ្មោះថា **រូបំ** ព្រោះអត្ថថា ប្រែប្រួលទៅ ដោយបច្ច័យដែលជាសត្រូវ មានត្រជាក់ជាដើមដោយអំណាចសន្តតិ ។ ពាក្យថា ព្រោះអត្ថថាប្រែប្រួលទៅ បានដល់ដោយអត្ថថា កម្រើក ។ ធម្មជាតដែលត្រូវភាពត្រជាក់ជាដើមប៉ះខ្ទប់ដោយការប្រែប្រួលរបស់សន្តតិ លោកហៅថា **រូបំ** ។ តែក្នុងទីនេះ បទថា **នាមំ** លោកបំណងយកនាមដែលជាលោកិយប៉ុណ្ណោះ ចំណែករូបជាលោកិយដោយចំណែកមួយ ។

បទថា **តិស្សោ វេទនា** បានដល់ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ។ វេទនាទាំងនោះ ជាលោកិយប៉ុណ្ណោះ ។

បទថា **អាហារា** បានដល់ បច្ច័យ ។ បច្ច័យ ឈ្មោះថា **អាហារា** ព្រោះនាំមកនូវផលរបស់ខ្លួន ។ អាហារ ៤ យ៉ាង គឺកពឡឹការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។ ឈ្មោះថា កពឡឹការ ព្រោះគួរធ្វើឲ្យជាពំនូតដោយវត្ថុ ។ ឈ្មោះថា អាហារ ព្រោះគួរស៊ីលេប ។ បទនេះ ជាឈ្មោះរបស់ឱជៈ ដែលជាវត្ថុមានបាយ និងនំកុម្មាសជាដើម ។ ឱជៈនោះ ឈ្មោះថា អាហារ ព្រោះអត្ថថា នាំមកនូវរូបមានឱជៈជាគម្រប់ ៨ ។ ផស្សៈ ៦ យ៉ាង មានចក្ខុសម្ផស្សជាដើម ឈ្មោះថា អាហារ

ព្រោះអត្ថថា នាំមកនូវវេទនា ៣ ។ ឈ្មោះថា មនោសញ្ចេតនា ព្រោះអត្ថថា ជាការតាំងចិត្តរបស់ចិត្តមិនមែនរបស់សត្វ ដូចការមានអារម្មណ៍តែមួយនៃចិត្ត ។ ម្យ៉ាងទៀត សញ្ចេតនាសម្បយុត្តជាមួយចិត្ត ឈ្មោះថា មនោសញ្ចេតនា ដូចរថទឹមដោយសេះអាជានេយ្យ បានដល់ កុសលចេតនា និងអកុសលចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មនោសញ្ចេតនានោះឈ្មោះថា អាហារ ព្រោះអត្ថថា នាំមកនូវភព ៣ ។

បទថា **វិញ្ញាណំ** បានដល់ បដិសន្ធិវិញ្ញាណ ១៩ ។ បដិសន្ធិវិញ្ញាណនោះ ឈ្មោះថា អាហារ ព្រោះអត្ថថា នាំមកនូវនាមរូបក្នុងបដិសន្ធិ ។

បទថា **ឧបាទានក្ខន្ធា** បានដល់ ខន្ធដែលជាអារម្មណ៍របស់ឧបាទាន គប្បីឃើញថា លុបបទកណ្តាល ។ ម្យ៉ាងទៀត ខន្ធដែលកើតអំពីឧបាទានឈ្មោះថា ឧបាទានក្ខន្ធ ដូចភ្លើងកើតអំពីស្មៅ ភ្លើងកើតអំពីអង្កាម ។ ម្យ៉ាងទៀត ខន្ធដែលស្តាប់បង្គាប់ឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ ដូចរាជបុរស ។ ម្យ៉ាងទៀត ខន្ធជាដែនកើតនៃឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ ដូចដើមឈើជាដែនកើតនៃផ្កា ដើមឈើជាដែនកើតនៃផ្លែ ។ ឧបាទានមាន ៤ យ៉ាង គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ តែដោយអត្ថ ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ប្រកាន់មាំ ។ ឧបាទានក្ខន្ធ មាន ៥ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

បទថា **ឆ អជ្ឈត្តិកានិ អាយតនានិ** បានដល់ អាយតនៈខាងក្នុង ៦

គឺចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ ។

បទថា **សត្ត វិញ្ញាណដ្ឋិតិយោ** បានដល់ វិញ្ញាណដ្ឋិតិ ៧ តើដូចម្តេច ព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ សត្តកនិបាត ) ដូច្នេះថា

ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សខ្លះ ទេវតាពួកខ្លះ និងវិនិបាតពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិទី ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាក្នុងពួកព្រហ្មដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាវិញ្ញាណដ្ឋិតិទី ២ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតា ក្នុងជាន់អាភស្សរៈ នេះជាវិញ្ញាណដ្ឋិតិទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាវិញ្ញាណដ្ឋិតិទី ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង នេះជាវិញ្ញាណដ្ឋិតិទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចា-

យតនជ្ឈាន ដោយគិតថា វិញ្ញាណមិនមានទីបំផុត នេះជា វិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងបង់នូវ វិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូល កាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយគិតថា វត្ថុតិចតួចមិនមាន នេះជាវិញ្ញាណដ្ឋិតិទី ៧ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដ្ឋិតិ មាន ៧ យ៉ាងនេះឯង ។

ពាក្យថា **វិញ្ញាណដ្ឋិតិ** បានដល់ ទីតាំងនៃបដិសន្ធិវិញ្ញាណ គឺខន្ធដែល មានវិញ្ញាណនោះឯង ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ដូច** ជានិបាត ចុះក្នុងអត្ថថា សម្ដែងគំរូ ។

ពាក្យថា **ពួកមនុស្ស** អធិប្បាយថា ក្នុងមនុស្សមិនមានប្រមាណ ក្នុង ចក្កវាឡដែលប្រមាណមិនបាន មនុស្សពីរនាក់ដូចគ្នាដោយសម្បុរ និងសណ្ឋាន ជាដើម មិនមាន ។

សូម្បីមនុស្សដូចគ្នាដោយសម្បុរ ឬសណ្ឋានក៏មិនដូចគ្នាដោយការសម្លឹង មើលទៅមុខ និងការក្រឡេកមើលឆ្វេងស្ដាំជាដើម ព្រោះហេតុនោះ ទើប ទ្រង់ត្រាស់ថា មានកាយផ្សេងគ្នា ។

បដិសន្ធិសញ្ញារបស់មនុស្សទាំងនោះ ជាតិហេតុកៈខ្លះ ទ្វិហេតុកៈខ្លះ អហេតុកៈខ្លះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា មានសញ្ញាផ្សេងគ្នា ។

ពាក្យថា **ទេវតាពួកខ្លះ** បានដល់ កាមាវចរទេវតា ៦ ជាន់ ។ ពិត ហើយ បណ្ដាទេវតាទាំងនោះ ទេវតាពួកខ្លះ មានកាយពណ៌ខៀវ ពួកខ្លះ

មានពណ៌សម្បុរលឿងជាដើម តែសញ្ញារបស់ទេវតាទាំងនោះ ជាតិហេតុកៈខ្លះ ទ្វិហេតុកៈខ្លះ មិនជាអហេតុកៈទេ ។

ពាក្យថា **វិនិបាតិកពួកខ្លះ** បានដល់ វេមានិកប្រេតទាំងឡាយដទៃ មានយក្ខិនីឈ្មោះបុនព្វសុមាតា បិយង្ករមាតា ផុស្សមិត្តា ធម្មគុត្តា អ្នកផុតចាកអបាយ ៤ ជាដើម ។ ប្រេតទាំងនោះមានកាយផ្សេងគ្នា ដោយពណ៌សម្បុរ ស ខ្មៅ លឿង និងពណ៌និលជាដើម និងដោយមានលក្ខណៈ ស្គម ធាត់ ទាប ខ្ពស់ សូម្បីសញ្ញាក៏ផ្សេងគ្នាដោយអំណាចតិហេតុកៈ ទ្វិហេតុកៈ និងអហេតុកៈ ដូចសញ្ញារបស់មនុស្សទាំងឡាយ ។ តែវេមានិកប្រេតទាំងនោះ មិនមានសក្តិធំដូចទេវតាទាំងឡាយ មានសក្តិតូច អាហារ និងសំពត់ រកបានដោយលំបាក ត្រូវទុក្ខបៀតបៀនដូចមនុស្សកំព្រា ។ វិនិបាតិកពួកខ្លះ ក្នុងថ្ងៃខាងរនោចបានទទួលសេចក្តីទុក្ខ ក្នុងថ្ងៃខាងខ្នើតបានទទួលសេចក្តីសុខ ព្រោះហេតុនោះ ទើបលោកពោលថា **វិនិបាតិកពួកខ្លះ** ព្រោះធ្លាក់ទៅចាកគំនរនៃសេចក្តីសុខ ។

ម្យ៉ាងទៀត ក្នុងបទនេះ សូម្បីការដឹងធម៌របស់វិនិបាតិកសត្វ ដែលជាតិហេតុកៈក៏មាន ដូចការដឹងធម៌របស់យក្ខិនី ឈ្មោះបិយង្ករមាតាជាដើម ។

ពាក្យថា **ក្នុងពួកព្រហ្ម** បានដល់ ព្រហ្មបារិសជ្ជ ព្រហ្មបរោហិត និងមហាព្រហ្ម ។ ពាក្យថា ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ បានដល់ ពួកទេវតាទាំងអស់នោះកើតហើយ ដោយបឋមជ្ឈាន ។ ចំណែកពួកព្រហ្មបារិសជ្ជកើតដោយឈានមានកម្លាំងតិច ព្រហ្មបុរោហិត កើតដោយឈានថ្នាក់កណ្តាល ម្យ៉ាងទៀត កាយរបស់ពួកទេវតាទាំងនោះ មានពន្លឺផ្សាយចេញក្រៃលែង

មហាព្រហ្ម កើតដោយឈានដ៏ប្រណីត កាយរបស់មហាព្រហ្មទាំងនោះ មានពន្លឺផ្សាយចេញក្រៃលែងជាង ។ ព្រហ្មកាយិកាទាំងនោះ ព្រះមានព្រះភាគត្រាស់ថា មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ព្រោះកាយផ្សេងគ្នា ព្រោះសញ្ញាដូចគ្នា ដោយអំណាចបឋមជ្ឈាន ដោយប្រការដូច្នេះ ។

សត្វដែលកើតក្នុងអបាយ ៤ ក៏ដូចពួកព្រហ្មទាំងនោះ ។ ក្នុងនរកពួកខ្លះមានរាងកាយ ១ គាវុត ពួកខ្លះកន្លះយោជន៍ ពួកខ្លះ ៣ គាវុត ចំណែកទេវទត្តមានរាងកាយ ១០០ យោជន៍ ។ សូម្បីក្នុងតិរច្ឆានពួកខ្លះក៏តូច ពួកខ្លះក៏ធំ ។ សូម្បីក្នុងបិត្តិវិស័យ ពួកខ្លះក៏ ៦០ ហត្ថ ពួកខ្លះក៏ ៨០ ហត្ថ ពួកខ្លះសម្បុរស្អាត ពួកខ្លះសម្បុរអាក្រក់ ។ កាលកញ្ចិកាសុរក៏ដូចគ្នា ។ ម្យ៉ាងទៀត បណ្ដាប្រេតទាំងនេះ ពួកទីឃបិដ្ឋិកាប្រេត មានកាយកម្ពស់ ៦០ យោជន៍ តែសញ្ញារបស់ប្រេតទាំងអស់នោះ ជាអហេតុកអកុសលវិបាកប៉ុណ្ណោះ ។ សូម្បីសត្វក្នុងអបាយទាំងឡាយ ក៏ពោលបានថា ជាអ្នកមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដោយប្រការដូច្នេះ ។

ពាក្យថា **អាភស្សរ** មានវិគ្គហៈថា រស្មីផ្សាយចេញពីរាងកាយរបស់អាភស្សរទេវតាទាំងនោះ រុងរឿងភ្លឺស្វាងដូចដាច់ធ្លាក់ចុះមក ដូចអណ្ដាតភ្លើងនៃគប់ភ្លើងមានជ័រ ទើបឈ្មោះថា អាភស្សរា ។ បណ្ដាទេវតាទាំងនោះ ទេវតាដែលចម្រើនទុតិយជ្ឈាន និងតតិយជ្ឈានទាំងពីរ ក្នុងបញ្ចកន័យតិចតួចហើយកើតឡើង ឈ្មោះថា **បរិត្តាភា** ។ ទេវតាដែលចម្រើនឈានទាំងពីរថ្នាក់កណ្ដាលហើយកើតឡើង ឈ្មោះថា អប្បមាណាភា ទេវតាដែលចម្រើនឈានទាំងពីរ

ប្រណីតហើយកើតឡើង ឈ្មោះថា អាភស្សរា ។ តែក្នុងទីនេះ លោកកំណត់យកទេវតាទាំងអស់នោះ ដោយកំណត់យកថ្នាក់ឧក្រិដ្ឋ ។ កាយរបស់ទេវតាទាំងអស់នោះ មានរស្មីផ្សាយចេញដូចគ្នា តែសញ្ញាផ្សេងគ្នា គឺមិនមានវិតក្កមានតែវិចារ និងមិនមានវិតក្កផង មិនមានវិចារផង ។

ពាក្យថា **សុភកិណ្ហា** បានដល់ ពួកទេវតាអ្នកពោរពេញដោយភាពស្អាតផ្សាយទៅ អធិប្បាយថា មានរស្មីជាដុំតែមួយ ដោយពណ៌នៃរស្មីចេញចាករាងកាយដ៏ស្អាត ។ ឯរស្មីរបស់ពួកសុភកិណ្ហទេវតាទាំងនោះ មិនដាច់ជាដុំៗ ដូចរស្មីរបស់ពួកអាភស្សរទេវតាទេ ។ ពួកទេវតាបរិត្តសុភា អប្បមាណសុភា សុភកិណ្ហា កើតឡើងដោយអំណាចតតិយជ្ឈានក្នុងចតុក្កន័យ ចតុត្ថជ្ឈានក្នុងបញ្ចកន័យដែលជាឈានបន្ថិចបន្តួច កណ្តាល និងប្រណីត ។ ពួកទេវតាទាំងអស់នោះ គប្បីជ្រាបថា មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដោយសញ្ញាក្នុងចតុត្ថជ្ឈានដោយប្រការដូច្នេះ ។ ទេវតាវេហប្ផលា ក៏ចាត់ជាវិញ្ញាណដ្ឋិតិទី ៤ នេះឯង ។ អសញ្ញសត្វមិនសង្គ្រោះចូលក្នុងវិញ្ញាណដ្ឋិតិនេះ ព្រោះមិនមានវិញ្ញាណ តែសង្គ្រោះចូលក្នុងសត្តាវាស ។

ទេវតាជាន់សុទ្ធាវាសតាំងនៅក្នុងចំណែកនៃវិវដ្ត គឺនិព្វានមិនមែនតាំងនៅរហូតគ្រប់កាលទេ ទេវតាសុទ្ធាវាស រមែងមិនកើតក្នុងលោកដែលទទេចាកព្រះពុទ្ធ រហូតមួយសែនកប្បខ្លះ រហូតមួយអសង្ខេយ្យកប្បខ្លះ ។ កាលបើព្រះពុទ្ធឧប្បត្តិក្នុងរវាង ១៦០០០ កប្ប ទើបទេវតាសុទ្ធាវាសកើតឡើង ។ ពួកទេវតាទាំងនោះ ប្រៀបដូចជាកងទ័ពម្តងម្កាល របស់ព្រះមានព្រះភាគ អ្នក

ប្រកាសព្រះធម្មចក្ក ព្រោះហេតុនោះ ទើបមិនចាត់ជាវិញ្ញាណដ្ឋិតិ និងមិនចាត់ជាសត្តាវាស ។ តែព្រះមហាសិវត្ថេរពោលថា សុទ្ធាវាសក៏ចាត់ជាវិញ្ញាណដ្ឋិតិទី ៤ និងសត្តាវាសទី ៤ ដោយព្រះសូត្រនេះ ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលសារីបុត្ត អាវាសណាដែលតថាគតមិនធ្លាប់នៅហើយ ដោយកាលវែងនេះ វៀរលែងតែសុទ្ធាវាសទេវលោកទាំងឡាយចេញ អាវាសនុ៎ះឯង បុគ្គលមិនងាយរកបានទេ ដូច្នេះ ពាក្យរបស់លោកនោះរមែងទទួលបាន ព្រោះព្រះសូត្រមិនបានហាម ។

ឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ មានវិញ្ញាណក៏មិនមែន មិនមានវិញ្ញាណក៏មិនមែន ព្រោះវិញ្ញាណល្អិតដូចសញ្ញាដែលល្អិត ព្រោះហេតុនោះ ទើបទ្រង់មិនត្រាស់ក្នុងវិញ្ញាណដ្ឋិតិ ។

បទថា **អដ្ឋ លោកធម្មា** បានដល់ ធម៌ទាំង ៨ នេះ គឺលាភ ១ មិនមានលាភ ១ យស ១ មិនមានយស ១ និន្ទា ១ សរសើរ ១ សុខ ១ ទុក្ខ ១ ជាធម៌របស់លោក ព្រោះជាធម៌ដែលមិនបាត់បង់ដរាបណាដែលលោកនៅប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបឈ្មោះថា លោកធម៌ ។ ឈ្មោះថា សត្វនឹងផុតចាកលោកធម៌ទាំងនេះរមែងមិនមាន ។ លោកធម៌ទាំងនោះ រមែងមានសូម្បីដល់ព្រះពុទ្ធ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ ៨ យ៉ាងនេះ តែង
> ជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោក-

ធម៌ទាំង ៨ ដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺ**លាភ** ១ អលាភ ១ **យស** ១ អយស ១ **និន្ទា** ១ **បសំសា** ១ **សុខ** ១ **ទុក្ខ** ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំងសត្វលោកក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងនេះដែរ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **តែងជាប់តាម** បានដល់ ជាប់តាមទៅ គឺមិនលះ អធិប្បាយថា មិនត្រឡប់ទៅអំពីលោក ។

ពាក្យថា **លាភ** បានដល់ លាភរបស់បព្វជិត មានចីវរជាដើម របស់គ្រហស្ថ មានទ្រព្យ និងស្រូវជាដើម ។ កាលមិនបានលាភនោះ ឈ្មោះថា អលាភ ។ បើពោលថា **ឆ លាភោ អលាភោ** មិនគួរយល់ដោយភាពជារបស់មិនមានប្រយោជន៍ ។

ពាក្យថា **យស** បានដល់ បរិវារ ។ កាលមិនបានយសនោះ ឈ្មោះថា អយស ។

ពាក្យថា **និន្ទា** បានដល់ និយាយពោលទោស ។ ពាក្យថា **បសំសា** បានដល់ និយាយពោលដល់គុណ ។

ពាក្យថា **សុខ** បានដល់ សុខផ្លូវកាយ និងសុខផ្លូវចិត្តរបស់កាមាវចរសត្វ ។ ពាក្យថា **ទុក្ខ** បានដល់ ទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្តរបស់បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ។ ព្រះអនាគាមី និងព្រះអរហន្ត មានតែទុក្ខផ្លូវកាយប៉ុណ្ណោះ ។

បទថា **នវ សត្តាវាសា** បានដល់ លំនៅរបស់សត្វទាំងឡាយ អធិប្បាយថា កន្លែងជាទីរស់នៅ ។ កន្លែងរស់នៅទាំងនោះ បានដល់ ខន្ធដែលជាទីប្រាកដ ដែលគេស្គាល់ ( ទូទៅ ) ហើយនោះឯង ។ សត្តាវាស ៩ គឺអ្វីខ្លះ ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ នវកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ សត្តាវាស ( ប្រទេសជាទីនៅរបស់សត្វ ) នេះ មាន ៩ យ៉ាង ។ សត្តាវាស ៩ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកមនុស្ស និងទេវតាពួកខ្លះ និងអសុរកាយពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកព្រហ្មកាយិកទេវតា ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកទេវតាជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកទេវតាជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វឥតសញ្ញាឥតមានទទួលការដឹងក៏មាន ដូចពួកទេវតាជាន់អសញ្ញីសត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ លុះបានកន្លងរូបសញ្ញា បានរម្ងាប់បដិឃសញ្ញា មិនបានធ្វើទុកក្នុង

ចិត្តចំពោះនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់ អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះក៏មាន នេះជាសត្តាវាសទី ៦ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ បានដល់ វិញ្ញាណញ្ចាយតនជ្ឈានដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ដូច្នេះក៏មាន នេះជាសត្តាវាសទី ៧ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ បានដល់ អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមានដូច្នេះ នេះជាសត្តាវាសទី ៨ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួងហើយ បានដល់ នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាសត្តាវាសទី ៩ ។ ម្នាលភិក្ខុទាំងឡាយ សត្តាវាស មាន ៩ យ៉ាងនេះឯង ដូច្នេះ ។

បទថា **ទសាយតនានិ** បានដល់ អាយតនៈ ១០ យ៉ាងនេះ គឺចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ ។ ចំណែកមនាយតនៈ ធម្មាយតនៈ លោកមិនចាត់ចូល ព្រោះលាយឡំដោយលោកុត្តរ ។

[ ៥៧ ] ក្នុងវិសជ្ជនាទាំង ១០ នេះ លោកពោលដល់តីរណបរិញ្ញា

ដោយអំណាចវិបស្សនា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **សព្វំ ភិក្ខវេ បរិញ្ញេយ្យំ** ដូចតទៅនេះ លោកពោលដល់តីរណបរិញ្ញា ដោយអំណាចការបានចំពោះនូវធម៌ទាំងនេះ គឺធម៌ ៣ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម និរោធប្បដិបទា សភាពដែលគួរធ្វើឲ្យជាក់ច្បាស់ និងសភាពដែលគួរចម្រើន សភាពដែលចាក់ធ្លុះនូវធម៌ទាំងនោះ ឧបាយជាគ្រឿងរលាស់ចេញនូវទុក្ខជាដើម ធម៌ ១៥ មានការមិនកើតឡើងជាដើម ធម៌ ៣១ មានសភាពនៃធម៌ដែលគួរកំណត់កាន់យកជាដើម ធម៌ ៣ មានសភាពដែលចាក់ធ្លុះអរិយមគ្គដ៏ប្រសើរជាដើម ធម៌ ៨ ដែលជាអង្គនៃមគ្គ ធម៌ ២ មានសភាពដែលរម្ងាប់នៃបយោគជាដើម សភាពដែលបច្ច័យមិនបានតាក់តែង ធម៌ ២ មានសភាពដែលចេញជាដើម សភាពដែលនាំចេញ ធម៌ ៣ មានសភាពដែលត្រាស់ដឹងតាមជាដើម ធម៌ ៣ មានសភាពដែលភ្ញាក់តាមជាដើម ធម៌ ៣ មានសភាពដែលប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹងតាមជាដើម ធម៌ ៤ មានសភាពដែលភ្លឺស្វាងជាដើម ធម៌ ១៨ មានសភាពដែលអរិយមគ្គឲ្យភ្លឺស្វាងជាដើម ធម៌ ៩ មានការពិចារណាឃើញឧបាយ ដែលចៀសចេញទៅជាដើម ញាណក្នុងការអស់ទៅ និងញាណក្នុងការមិនកើតឡើង បញ្ញា វិមុត្តិ និងនិព្វាន[១] គប្បីជ្រាបថា លោកពោលតីរណបរិញ្ញា ដោយអំណាចវិបស្សនា និងដោយអំណាចការបានចំពោះ តាមសមគួរដល់ធម៌ដ៏សេស ។

[ ៥៨ ] លោកពោលដល់តីរណបរិញ្ញា ដោយអត្ថថា សម្រេចកិច្ច

---

១- ធម៌ដែលរៀបរាប់ខាងលើ មានចាប់ពីលេខឃ្នាបទី ៧ រហូតដល់លេខឃ្នាបទី ៥៤ ។

ដោយបទថា **យេសំ យេសំ ធម្មានំ បដិលាភត្ថាយ វាយមន្តស្ស តេ តេ ធម្មា បដិលទ្ធា ហោន្តិ ឯវំ តេ ធម្មា បរិញ្ញាតា ចេវ ហោន្តិ តីរិតា ច។** ព្រោះថា កាលកិច្ចសម្រេចហើយ ឈ្មោះថា បានធម៌នោះៗ ហើយ តែអាចារ្យពួកខ្លះពោលថា ញាតបរិញ្ញារបស់បុគ្គល ដែលមិនទាន់ចូលដល់វិបស្សនា ពាក្យនោះ មិនល្អ ព្រោះញាតបរិញ្ញា លោកពោលដោយធម៌ដែលគួរដឹងក្រៃលែង ។

បទថា **បរិញ្ញាតា ចេវ ហោន្តិ តីរិតា ច** សេចក្តីថា ធម៌ដែលបុគ្គលបានហើយ ឈ្មោះថា ជាធម៌ដែលកំណត់ដឹងហើយ និងឈ្មោះថា ពិចារណាហើយ ។ ជាការដែលលោកពោលប្រយោជន៍ ដែលកំណត់ដឹងដោយអំណាចប្រយោជន៍ គឺការសម្រេចកិច្ច ដោយប្រការដូច្នេះ ។

[ ៥៩-៦៣ ] ឥឡូវនេះ ដើម្បីប្រកបអត្ថនោះ ដោយការបានធម៌ឯណានីមួយ ហើយសម្តែងសរុបក្នុងទីបំផុត ទើបព្រះសារីបុត្តពោលថា **នេក្ខម្មំ** ជាដើម ។ គប្បីជ្រាបពាក្យទាំងអស់នោះ ដោយអនុលោមតាមពាក្យដែលលោកពោលហើយខាងដើមនោះឯង ។៚

**អដ្ឋកថាបរិញ្ញេយ្យនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ៦៤ ] ការប្រុងប្រយ័ត្នថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវលះ បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងប្រយ័ត្ននោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ធម៌ ១ ដែលត្រូវលះ គឺអស្មិមានះ ធម៌ ២ ដែលត្រូវលះ គឺអវិជ្ជា ១ ភវតណ្ហា ១ ធម៌ ៣ ដែលត្រូវលះ គឺតណ្ហា ៣ ធម៌ ៤ ដែលត្រូវលះ គឺឱឃៈ ៤ ធម៌ ៥ ដែលត្រូវលះ គឺនីវរណៈ ៥ ធម៌ ៦ ដែលត្រូវលះ គឺពួកតណ្ហា ៦ ធម៌ ៧ ដែលត្រូវលះ គឺអនុស័យ ៧ ធម៌ ៨ ដែលត្រូវលះ គឺមិច្ឆត្តៈ ៨ ធម៌ ៩ ដែលត្រូវលះ គឺឫសគល់តណ្ហា ៩ ធម៌ ១០ ដែលត្រូវលះ គឺមិច្ឆត្តៈ ១០ ។

[ ៦៥ ] បហាន ( ការលះ ) ២ យ៉ាង គឺសមុច្ឆេទប្បហាន ១ បដិប្បស្សទ្ធិប្បហាន ១ ឯសមុច្ឆេទប្បហាន សម្រាប់បុគ្គលកាលចម្រើននូវខយគាមិមគ្គជាលោកុត្តរ បដិប្បស្សទ្ធិប្បហាន កើតក្នុងខណៈនៃផល ។ បហាន ៣ យ៉ាង គឺនេក្ខម្មៈដែលជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ១ អារុប្បជ្ឈានដែលជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ១ ធម្មជាតណា ដែលកើតហើយ ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យបច្ច័យ ការរលត់ ការរលាស់ចោលនូវធម្មជាតនោះ ១ កាមទាំងឡាយរបស់បុគ្គល ដែលបានចំពោះនូវនេក្ខម្មៈ ឈ្មោះថា ជាកិលេសដែលលោកបន្សាត់ចោលផង លះចេញផង រូបទាំងឡាយរបស់បុគ្គល ដែលបានចំពោះនូវអារុប្បជ្ឈាន ឈ្មោះថា ជាគុណដែលលោកបន្សាត់ចោលផង លះចេញផង សង្ខារទាំងឡាយរបស់បុគ្គលដែលបានចំពោះនូវនិរោធ ឈ្មោះថា ជាធម៌ដែលលោកបន្សាត់ចោលផង លះចេញផង ។ បហាន ៤ យ៉ាង គឺបុគ្គលកាលត្រាស់ដឹងនូវទុក្ខសច្ច ដែលជាបរិញ្ញាបដិវេធហើយ

លះបង់ ១ បុគ្គលកាលត្រាស់ដឹងនូវសមុទយសច្ច ដែលជាបហានប្បដិវេធ ហើយ លះបង់ ១ បុគ្គលកាលត្រាស់ដឹងនូវនិរោធសច្ច ដែលជាសច្ឆិកិរិយា-បដិវេធ ហើយលះបង់ ១ បុគ្គលកាលត្រាស់ដឹងនូវមគ្គសច្ច ដែលជាភាវនាបដិវេធ ហើយលះបង់ ១ ។ បហាន ៥ យ៉ាង គឺវិក្ខម្ភនប្បហាន ១ តទង្គប្បហាន ១ សមុច្ឆេទប្បហាន ១ បដិប្បស្សទ្ធិប្បហាន ១ និស្សរ-ណប្បហាន ១ ឯវិក្ខម្ភនប្បហាន សម្រាប់បុគ្គលចម្រើននូវធម៌ជាគ្រឿងដុតបំផ្លាញនូវនីវរណៈទាំងឡាយជាបឋម តទង្គប្បហានសម្រាប់បុគ្គលចម្រើននូវសមាធិជាចំណែកនៃការទម្លុះទម្លាយនូវទិដ្ឋិទាំងឡាយ សមុច្ឆេទប្បហានសម្រាប់បុគ្គលចម្រើននូវខយគាមិមគ្គជាលោកុត្តរ បដិប្បស្សទ្ធិប្បហាន កើតឡើងក្នុងខណៈនៃផល និស្សរណប្បហាន គឺព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ។

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួងបុគ្គលត្រូវលះ ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួងដែលបុគ្គលត្រូវលះ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុត្រូវលះ រូបត្រូវលះ ចក្ខុវិញ្ញាណត្រូវលះ ចក្ខុសម្ផស្សត្រូវលះ ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯងក៏ត្រូវលះ សោតៈត្រូវលះ សទ្ទៈត្រូវលះ ។បេ។ ឃានៈត្រូវលះ គន្ធៈត្រូវលះ ជិវ្ហាត្រូវលះ រសត្រូវលះ កាយត្រូវលះ ផោដ្ឋព្វៈត្រូវលះ មនៈត្រូវលះ ធម្មារម្មណ៍ត្រូវលះ មនោវិញ្ញាណត្រូវលះ មនោសម្ផស្សត្រូវលះ ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះ

មនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវលះចេញ ។

បុគ្គលកាលឃើញនូវរូប រមែងលះបង់ កាលឃើញនូវវេទនា រមែងលះបង់ កាលឃើញនូវសញ្ញា រមែងលះបង់ កាលឃើញនូវសង្ខារទាំងឡាយ រមែងលះបង់ កាលឃើញនូវវិញ្ញាណ រមែងលះបង់ នូវចក្ខុ ។បេ។ នូវជរានិងមរណៈ កាលឃើញនូវនិព្វាន ឈ្មោះអមតៈ ជាទីពំនាក់ ( របស់ពួកសត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃសាសនា ) រមែងលះបង់ធម៌ទាំងឡាយណាៗ ដែលបុគ្គលបានបន្សាត់ហើយ ធម៌ទាំងនោះ ឈ្មោះថា បុគ្គលលះចេញហើយ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ជាគ្រឿងដឹងច្បាស់នូវធម៌នោះ ហេតុនោះ ទើបលោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវលះ បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

**តតិយភាណវារៈ ចប់**

## តតិយភាណវារៈ

## អដ្ឋកថា បហាតព្វនិទ្ទេស

[ ៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបហាតព្វនិទ្ទេសដូចតទៅ

បទថា **អស្មិមានោ** បានដល់ មានះក្នុងឧបាទានក្ខន្ធ ៥ មានរូបជាដើម ថាជាអញ ។ ពិតហើយ កាលលះបង់មានះនោះបាន ឈ្មោះថា បានសម្រេចអរហត្ត ។ កាលរូបរាគៈជាដើមនៅមាន ការដែលមិនពោលដល់សញ្ញោជនៈដ៏សេស ពោលដល់អស្មិមានះប៉ុណ្ណោះ គប្បីជ្រាបថា ព្រោះអស្មិមានះនោះគ្រោតគ្រាតប្រៀបបាននឹងទិដ្ឋិ ។

បទថា **អវិជ្ជា** ដោយសុត្តន្តបរិយាយ គឺការមិនដឹងក្នុងឋានៈ ៤ មានទុក្ខជាដើម ដោយអភិធម្មបរិយាយរួមជាមួយការមិនដឹងក្នុងចំណែកអតីតជាដើមជា ៨ ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ថា បណ្ដាធម៌ទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹងក្នុងទុក្ខ មិនដឹងក្នុងហេតុនៃទុក្ខ មិនដឹងក្នុងការរលត់ទុក្ខ មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ មិនដឹងក្នុងខន្ធជាចំណែកខាងដើម មិនដឹងក្នុងខន្ធជាចំណែកខាងចុង មិនដឹងក្នុងខន្ធជាចំណែកខាងដើម និងខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើងព្រោះអាស្រ័យបច្ច័យនោះៗ ដូច្នេះ ។

បទថា **ភវតណ្ហា** បានដល់ ការប្រាថ្នាក្នុងភព មានកាមភពជាដើម ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងអភិធម្ម វិភង្គ ) ថា បណ្ដាធម៌ទាំងនោះ ភវតណ្ហា តើដូចម្ដេច ។ សេចក្ដីប្រាថ្នាភពក្នុងភពទាំងឡាយ តម្រេកក្នុងភព សេចក្ដីស្រើបស្រាលក្នុងភព សេចក្ដីប្រាថ្នាក្នុងភព សេចក្ដីស្នេហាក្នុងភព

សេចក្ដីអន្ទះអន្ទែងក្នុងភព សេចក្ដីជ្រប់ក្នុងភព ការចុះចិត្តស៊ប់ក្នុងភពដូច្នេះ ។

បទថា **តិស្សោ តណ្ហា** បានដល់ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ក្នុងអភិធម្ម លោកសម្ដែងតណ្ហាទាំងនោះ ( ក្នុងអភិធម្ម វិភង្គ ) យ៉ាងនេះថា បណ្ដាតណ្ហាទាំង ៣ នោះ ភវតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រព្រឹត្តទៅមួយអន្លើដោយភវទិដ្ឋិ នេះហៅថា ភវតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ វិភវតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រព្រឹត្តទៅមួយអន្លើដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ។ តណ្ហាដ៏សេស ឈ្មោះថា កាមតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ កាមតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយកាមធាតុ នេះហៅថា កាមតណ្ហា ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រកបដោយរូបធាតុ និងអរូបធាតុ នេះហៅថា ភវតណ្ហា ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តប្រព្រឹត្តទៅ មួយអន្លើដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ដូច្នេះ ។

តែក្នុងអដ្ឋកថាពោលថា តម្រេកប្រព្រឹត្តទៅក្នុងកាមគុណ ៥ ឈ្មោះថា **កាមតណ្ហា** តម្រេកក្នុងរូបភព និងអរូបភព តម្រេកដែលសហគតៈដោយការប្រាថ្នាក្នុងឈាន និងសស្សតទិដ្ឋិ ការប្រាថ្នាដោយអំណាចភព ឈ្មោះថា **ភវតណ្ហា** តម្រេកដែលសហគតៈដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា **វិភវតណ្ហា** ។ នេះជាអធិប្បាយដោយបរិយាយនៃទសុត្តរសូត្រ ។ សូម្បីតណ្ហាលោកពោលដោយបរិយាយនៃសង្គីតិ និងដោយបរិយាយនៃអភិធម្មថា តណ្ហា ៣ ដទៃ

ទៀត គឺកាមតណ្ហា ១ រូបតណ្ហា ១ អរូបតណ្ហា ១ ។ តណ្ហា ៣ ដទៃទៀត គឺរូបតណ្ហា ១ អរូបតណ្ហា ១ និរោធតណ្ហា ១ ។ រមែងត្រឹមត្រូវក្នុងនិទ្ទេសនេះ ។ ក្នុងតណ្ហាទាំងនោះ តណ្ហា ៥ ប្រកបដោយកាមធាតុ រូបធាតុ និងអរូបធាតុ តណ្ហាចុងក្រោយ សហគតៈដោយឧច្ឆេទទិដ្ឋិ ។

បទថា **ចត្តារោ ឱឃា** បានដល់ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ឈ្មោះថា ឱឃៈ ព្រោះអត្ថថា រមែងញុំាងសត្វដែលមានឱឃៈនោះឲ្យលិច គឺឲ្យលិចចុះក្នុងវដ្ដៈ ។ ឱឃៈទាំងនេះជាកិលេសមានកម្លាំង ។ ឱឃៈក្នុងកាម ពោល គឺកាមគុណ ឈ្មោះថា កាមោឃៈ ពាក្យនេះ ជាឈ្មោះរបស់កាមតណ្ហា ។ ឱឃៈក្នុងភពទាំង ២ គឺដោយកម្ម និងដោយឧបបត្តិ ពោល គឺរូបភព និងអរូបភព ឈ្មោះថា ភវោឃៈ ពាក្យនេះ ជាឈ្មោះរបស់ភវតណ្ហា ។ ឱឃៈ គឺទិដ្ឋិ ឈ្មោះថា ទិដ្ឋោឃៈ ពាក្យនេះ ជាឈ្មោះរបស់ទិដ្ឋិ មានជាអាទិថា លោកទៀង ។ ឱឃៈ គឺអវិជ្ជា ឈ្មោះថា អវិជ្ជោឃៈ ពាក្យនេះ ជាឈ្មោះរបស់ការមិនដឹងក្នុងទុក្ខជាដើម ។

បទថា **បញ្ច និវរណានិ** បានដល់ កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ឈ្មោះថា **និវរណានិ** ព្រោះអត្ថថា ហាម គឺរឹតរុំចិត្ត ។ ឈ្មោះថា **កាម** ព្រោះអត្ថថា ដែលសត្វប្រាថ្នា បានដល់ កាមគុណ ៥ ។ ការពេញចិត្តក្នុងកាម ឈ្មោះថា កាមច្ឆន្ទៈ ។ ម្យ៉ាងទៀត ឈ្មោះថា **កាម** ព្រោះអត្ថថា រមែងប្រាថ្នា ។ ការពេញចិត្ត គឺកាម មិនមែនការពេញចិត្តប្រាថ្នានឹងធ្វើ មិនមែនការពេញចិត្តក្នុង

ធម៌ ព្រោះហេតុនោះ ទើបឈ្មោះថា កាមច្ឆន្ទៈ ពាក្យនេះ ជាឈ្មោះនៃកាមតណ្ហា ។

ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ជាហេតុឲ្យចិត្តប្រទូស្ត គឺដល់នូវការវិនាស ឬញុំាងវិន័យ អាចារៈ រូបសម្បត្តិ ប្រយោជន៍ សេចក្តីសុខឲ្យដល់នូវសេចក្តីវិនាស ពាក្យនេះ ជាឈ្មោះរបស់ទោសៈ ។ ការរួញរា ឈ្មោះថា **ថីន** ការងោកងក់ ឈ្មោះថា **មិទ្ធ** អធិប្បាយថា ភាពដែលចិត្តមិនមានឧស្សាហៈ និងការទម្លាយចេតសិក មិនឲ្យមានសមត្ថភាព ។ ចិត្តមិនខ្នះខ្នែង ឈ្មោះថា **ថីន** ភាពដែលចេតសិកមិនគួរដល់ការងារ ឈ្មោះថា **មិទ្ធ** ថីនៈផង មិទ្ធៈផង ឈ្មោះថា **ថីនមិទ្ធ**។ ភាពដែលចិត្តរាយមាយ ឈ្មោះថា **ឧទ្ធច្ច** អធិប្បាយថា ការមិនស្ងប់ ពាក្យនេះ ជាឈ្មោះនៃការរាយមាយ ។ វត្ថុដែលធ្វើចិត្តឲ្យគួរខ្ពើម ឈ្មោះថា **កុក្កត** ការៈដែលធ្វើចិត្តឲ្យគួរខ្ពើម ឈ្មោះថា **កុក្កច្ច** អធិប្បាយថា ការៈដែលធ្វើឲ្យគួរតិះដៀល ។ ពាក្យនេះ ជាឈ្មោះនៃការក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។

ឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ប្រាសចាកការគិត អធិប្បាយថា ប្រាសចាកបញ្ញា ។ មួយវិញទៀត ឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ជាហេតុឲ្យត្រិះរិះសេចក្តីពិតបានដោយលំបាក បានដោយក្រ ។ ពាក្យនេះ ជាឈ្មោះរបស់ការសង្ស័យក្នុងព្រះពុទ្ធជាដើម ។ នីវរណៈ គឺកាមច្ឆន្ទៈ ឈ្មោះថា កាមច្ឆន្ទនីវរណៈ ។ សូមជ្រាបក្នុងបទដ៏សេសក៏យ៉ាងនេះ ។

បទថា **ជ ជម្មា** បាឋៈថា **ជន្តុម្មា** ក៏មាន ។ បទថា **ជ តណ្ហាកាយា** គឺរូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១

ធម្មតណ្ហា ១ ។ តណ្ហាក្នុងរូប ឈ្មោះថា រូបតណ្ហា ។ រូបតណ្ហានោះឯង លោកពោលថាជាកាយ ដោយអត្ថថា ជាគំនរ ព្រោះមានច្រើនប្រភេទ ដោយប្រភេទ មានកាមតណ្ហាជាដើម ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **សត្តានុសយា** បានដល់ កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ។ ឈ្មោះថា អនុស័យ ព្រោះអត្ថថា ដេកត្រាំ ដោយអត្ថថា លះមិនទាន់បាន សេចក្តីត្រេកអរក្នុងកាម ឈ្មោះថា កាមរាគ ម្យ៉ាងទៀត រាគៈ គឺកាម ឈ្មោះ កាមរាគ ។ ឈ្មោះថា បដិឃៈ ព្រោះអត្ថថា ប៉ះខ្ទប់ក្នុងអារម្មណ៍ ។ ឈ្មោះថា ទិដ្ឋិ ព្រោះអត្ថថា ឃើញមិនពិត ។ ឈ្មោះថា មានះ ព្រោះអត្ថថា សម្គាល់ថាប្រសើរជាងគេជាដើម ។ តម្រេកក្នុងភព ឈ្មោះថា ភវរាគ ។ កាមរាគៈមានកម្លាំង ឈ្មោះថា កាមរាគានុស័យ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **អដ្ឋ មិច្ឆត្តា** បានដល់ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្ប ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១ មិច្ឆាអាជីវៈ ១ មិច្ឆាវាយាមៈ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។ ឈ្មោះថា **មិច្ឆត្ត** ព្រោះអត្ថថា ជាសភាពខុសដោយសង្ឃឹមយ៉ាងនេះថា វត្ថុនេះនឹងនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់អញ តែក៏មិនជាយ៉ាងនោះ និងដោយប្រព្រឹត្តវិបរិតក្នុងវត្ថុមិនស្អាតនោះឯងថា ស្អាតជាដើម ។ ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ឃើញខុស ឬជាហេតុឲ្យឃើញខុស ម្យ៉ាងទៀត ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ការឃើញវិបរិត ឬព្រោះអត្ថថា ការឃើញ

មិនពិត ឬព្រោះអត្ថថា ការឃើញដែលមិនពិត ដោយប្រកាន់ខុស ឬព្រោះអត្ថថា ការឃើញដែលបណ្ឌិតខ្ពើម ព្រោះនាំសេចក្តីវិនាសមកឲ្យ ។ សូម្បីក្នុងបទថា **មិច្ឆាសង្កប្ប** ជាដើម ក៏មានន័យដូចគ្នា ។

បទថា **មិច្ឆាទិដ្ឋិ** បានដល់ ប្រកាន់មាំនូវសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។

បទថា **មិច្ឆាសង្កប្បោ** បានដល់ វិតក្ក ៣ យ៉ាង មានកាមវិតក្កជាដើម ។

បទថា **មិច្ឆាវាចា** បានដល់ ចេតនា ៤ យ៉ាង មានមុសាវាទជាដើម ។

បទថា **មិច្ឆាកម្មន្តោ** បានដល់ ចេតនា ៣ យ៉ាង មានបាណាតិបាតជាដើម ។

បទថា **មិច្ឆាអាជីវោ** បានដល់ ចេតនាតាំងឡើងដោយការប្រកបមិច្ឆាអាជីវៈ ។

បទថា **មិច្ឆាវាយាមោ** បានដល់ ការព្យាយាមប្រកបដោយអកុសលចិត្ត ។

បទថា **មិច្ឆាសតិ** បានដល់ អកុសលចិត្តុប្បាទ ដែលជាបដិបក្ខចំពោះសតិ ។

បទថា **មិច្ឆាសមាធិ** បានដល់ អកុសលសមាធិ ។

បទថា **នវ តណ្ហាមូលកា** បានដល់ ការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហា លាភកើតមានព្រោះអាស្រ័យការស្វែងរក វិនិច្ឆ័យ គឺសេចក្តីត្រិះរិះកើតមានព្រោះអាស្រ័យលាភ ឆន្ទរាគៈ គឺសេចក្តីប្រាថ្នា និងតម្រេកកើតមានព្រោះអាស្រ័យវិនិច្ឆ័យ សេចក្តីចូលចិត្តមាំកើតមានព្រោះអាស្រ័យឆន្ទរាគៈ សេចក្តីហួងហែងកើតមាន ព្រោះអាស្រ័យសេចក្តីប្រកាន់មាំ សេចក្តីកំណាញ់

កើតមានព្រោះអាស្រ័យសេចក្ដីហួងហែង ការរក្សាមាំកើតមានព្រោះអាស្រ័យសេចក្ដីកំណាញ់ អកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះទាស់ទែង វិវាទ ពាក្យថា ឯង មឹង ពាក្យញុះញង់ ពាក្យកុហកកើតមានព្រោះអាស្រ័យការរក្សាមាំ គឺថា មានការរក្សាមាំជាហេតុ ដូច្នេះ ។ ធម៌ មានតណ្ហាជាមូល ៩ នេះ ។ ឈ្មោះថា **តណ្ហាមូលកា** ព្រោះអត្ថថា ធម៌មានតណ្ហាជាមូល ។ ការស្វែងរកជាដើម ជាអកុសលទាំងអស់ ។

ពាក្យថា ព្រោះអាស្រ័យតណ្ហា បានដល់ ព្រោះអាស្រ័យតណ្ហា ។ ពាក្យថា ការស្វែងរក បានដល់ ការស្វែងរកអារម្មណ៍ មានរូបជាដើម ព្រោះកាលតណ្ហាមាន ការស្វែងរកនោះក៏មាន ។

ពាក្យថា លាភ បានដល់ ការបានអារម្មណ៍ មានរូបជាដើម ព្រោះកាលការស្វែងរកមាន លាភនោះក៏មាន ។ វិនិច្ឆ័យមាន ៤ យ៉ាង គឺញាណ ១ តណ្ហា ១ ទិដ្ឋិ ១ វិតក្ក ១ ។

ក្នុងវិនិច្ឆ័យទាំងនោះ វិនិច្ឆ័យនេះ ( មជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា គប្បីដឹងនូវសេចក្ដីសុខដែលថោកថយ លុះដឹងនូវសេចក្ដីសុខដែលថោកថយហើយ គប្បីប្រកបរឿយៗ នូវសេចក្ដីសុខក្នុងសន្តាន ដូច្នេះ ឈ្មោះថា ញាណវិនិច្ឆ័យ ។

តណ្ហាវិចរិត ១០៨ ដែលមកហើយយ៉ាងនេះ ( ខុទ្ទកនិកាយ មហានិទ្ទេស ) ថា ត្រង់ពាក្យថា វិនិច្ឆ័យ បានដល់វិនិច្ឆ័យ ២ គឺតណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ

១ ដូច្នេះ ឈ្មោះថា តណ្ហាវិនិច្ឆយោ ។

ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិវិនិច្ឆ័យ ។ ក្នុងទីនេះលោកពោលវិតក្កថា វិនិច្ឆ័យ មកហើយក្នុងសូត្រនេះ ( ទីឃនិកាយ មហាវគ្គ ) ថា បពិត្រទេវានមិន្ទ ឆន្ទៈ មានវិតក្ក ( សេចក្តីត្រិះរិះ ) ជាដើមហេតុ ដូច្នេះ ។ បុគ្គលកាលបានលាភ ហើយ រមែងវិនិច្ឆ័យដល់វត្ថុដែលពេញចិត្ត មិនពេញចិត្ត ល្អ មិនល្អដោយ វិតក្កនោះឯងថា វត្ថុមានប្រមាណប៉ុណ្ណោះ នឹងមានដល់អញ ដើម្បីប្រយោជន៍ ដល់រូបារម្មណ៍ វត្ថុមានប្រមាណប៉ុណ្ណោះ នឹងមានដល់អញ ដើម្បីប្រយោជន៍ ដល់សទ្ទារម្មណ៍ជាដើម វត្ថុមានប្រមាណប៉ុណ្ណោះ នឹងជារបស់អញ វត្ថុមាន ប្រមាណប៉ុណ្ណោះ នឹងជារបស់អ្នកដទៃ វត្ថុមានប្រមាណប៉ុណ្ណោះ អញនឹងប្រើ ប្រាស់ វត្ថុមានប្រមាណប៉ុណ្ណោះ អញនឹងរក្សាទុក ។ ដោយហេតុនោះ ទើប ព្រះមានព្រះភាគ ត្រាស់ថា វិនិច្ឆ័យ គឺសេចក្តីត្រិះរិះកើតមាន ព្រោះ អាស្រ័យលាភ ។

ពាក្យថា **ឆន្ទរាគៈ** សេចក្តីថា កាលត្រិះរិះដល់វត្ថុ ដោយអកុសលវិតក្ក យ៉ាងនេះហើយ រមែងកើតរាគៈយ៉ាងទន់ និងយ៉ាងខ្លាំង ។ ពាក្យថា **ឆន្ទៈ** ក្នុងពាក្យថា **ឆន្ទរាគៈ** នេះ ជាឈ្មោះរបស់រាគៈយ៉ាងទន់ ។ ពាក្យថា រាគៈ ជាឈ្មោះរបស់រាគៈយ៉ាងខ្លាំងក្លា ។ ពាក្យថា សេចក្តីចូលចិត្តមាំ បានដល់ ការប្រកាន់យ៉ាងមាំថា អញ របស់អញ ។

ពាក្យថា សេចក្តីហួងហែង បានដល់ ធ្វើនូវការហួងហែងដោយអំណាច តណ្ហា និងទិដ្ឋិ ។

ពាក្យថា សេចក្តីកំណាញ់ បានដល់ ការមិនព្រមឲ្យវត្ថុជាសាធារណៈដល់អ្នកដទៃ ដោយហេតុនោះ ទើបបុរាណាចារ្យពោលអត្ថរបស់សេចក្តីកំណាញ់ទុកយ៉ាងនេះថា ហៅថា សេចក្តីកំណាញ់ ព្រោះប្រព្រឹត្តទៅថា របស់អស្ចារ្យនេះ ចូរមានដល់អញប៉ុណ្ណោះ ចូរកុំមានដល់អ្នកដទៃឡើយ ។

ពាក្យថា ការរក្សាមាំ បានដល់ ការរក្សាដោយល្អដោយបិទទ្វារ និងប្រមូលទុកក្នុងហិបជាដើម ។

ឈ្មោះថា ការឈ្លោះ ព្រោះធ្វើឲ្យក្រៃលែង ។ ពាក្យនេះ ជាឈ្មោះរបស់ហេតុ ។

ពាក្យថា ព្រោះអាស្រ័យការរក្សាមាំ គឺថា មានការរក្សាមាំជាហេតុ ជាការទប់សកលិង្គ អធិប្បាយថា ហេតុនៃការរក្សា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យ មានការកាន់ដំបងជាដើម ដូចតទៅនេះ ការកាន់ដំបង ដើម្បីហាមអ្នកដទៃ ឈ្មោះថា ការកាន់ដំបង ។ ការកាន់សស្ត្រាមានមុខម្ខាងជាដើម ឈ្មោះថា កាន់គ្រឿងសស្ត្រាវុធ ។ ជម្លោះផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ ឈ្មោះថា ការឈ្លោះ ។ ការខុសក្នុងគ្រាមុនៗ ឈ្មោះថា ទាស់ទែង ។ ការខុសគ្រាក្រោយៗ ឈ្មោះថា វិវាទ ។ ពាក្យថា **ឯង មឹង** បានដល់ និយាយឯងមឹង ដោយការមិនគោរព ។

បទថា **ទស មិច្ឆត្តា** បានដល់ មិច្ឆាទិដ្ឋិ ។បេ។ មិច្ឆាសមាធិ មិច្ឆាញាណ មិច្ឆាវិមុត្តិ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មិច្ឆាញាណ បានដល់ មោហៈកើតឡើង

ដោយគិតរកឧបាយ ក្នុងការធ្វើអាក្រក់ និងដោយអាការដែលធ្វើបាប ហើយពិចារណាថា អញធ្វើល្អហើយ ។

ពាក្យថា មិច្ឆាវិមុត្តិ បានដល់ កាលនៅមិនទាន់រួចផុត ក៏សម្គាល់ថា រួចផុត ។

[ ៦៥ ] ឥឡូវនេះ ដើម្បីសម្តែងធម៌ដែលគួរលះដោយបហានៈដែលមានប្រភេទច្រើនយ៉ាង ទើបព្រះសារីបុត្តផ្តើមបទថា **ទ្វេ បហានានិ** ជាដើម ។ កាលដឹងច្បាស់បហានៈហើយ ធម៌ដែលគួរលះដោយបហានៈនោះៗ ក៏គប្បីយល់បានងាយ ។ ក្នុងបហានៈ ៥ លោកពោលដល់លោកុត្តរប្បហានដែលមិនមានបយោគ ២ យ៉ាងមុន វៀរលោកិយប្បហាន ២ និងនិស្សរណប្បហានដែលមិនមានបយោគ ។

ឈ្មោះថា **សមុច្ឆេទ** ព្រោះអត្ថថា ជាហេតុកាត់កិលេសដាច់ទៅ ដោយប្រពៃ ឈ្មោះថា **បហាន** ព្រោះអត្ថថា ជាហេតុលះកិលេស ។ បហានពោលគឺសមុច្ឆេទមិនមែនបហាន ដែលមានចំណែកសេសសល់ ព្រោះហេតុនោះ ទើបឈ្មោះថា **សមុច្ឆេទប្បហាន** ។

ឈ្មោះថា **បដិប្បស្សទ្ធិ** ព្រោះកិលេសស្ងប់ ឈ្មោះថា **បហាន** ព្រោះលះកិលេស បហាន ពោលគឺបដិប្បស្សទ្ធិឈ្មោះថា **បដិប្បស្សទ្ធិប្បហាន** ។ ឈ្មោះថា **លោកុត្តរ** ព្រោះឆ្លងលោក ។ ឈ្មោះថា **ខយគាមី** ព្រោះដល់នូវការអស់ទៅ ពោលគឺនិព្វាន ។ ខយគាមីនោះផង មគ្គផង ឈ្មោះថា **ខយគា-មិមគ្គ** អធិប្បាយថា មគ្គនោះរបស់អ្នកចម្រើនខយគាមិមគ្គនោះ ឈ្មោះថា

**សមុច្ឆេទប្បហាន** ។ លោកុត្តរផលក្នុងខណៈនៃផល ឈ្មោះថា **បដិប្បស្សទ្ធិប្បហាន** ។

គប្បីជ្រាបវិគ្គហៈក្នុងបទជាដើមថា **កាមានមេតំ និស្សរណំ** ដូចតទៅ ឈ្មោះថា **និស្សរណា** ព្រោះអត្ថថា ជាហេតុរលាស់ចេញចាកកាម ចាករូប ចាកសង្ខតៈ ។ ម្យ៉ាងទៀត ឈ្មោះថា **និស្សរណា** ព្រោះចេញទៅចាកកាម ជាដើមទាំងនោះ បានដល់អសុភឈាន ។ ឈ្មោះថា **នេក្ខម្ម** ព្រោះចេញចាក កាមទាំងឡាយ ឬបានដល់អនាគាមិមគ្គ ។ ពិតហើយ អសុភឈាន ឈ្មោះថា ឧបាយជាគ្រឿងរលាស់ចេញនៃកាមទាំងឡាយ ព្រោះសង្កត់បាន ចំណែក អនាគាមិមគ្គដែលលោកធ្វើឈាននោះឲ្យជាបាទ ហើយឲ្យកើតឡើង ឈ្មោះ ថា ឧបាយជាគ្រឿងរលាស់ចេញសព្វយ៉ាងនៃកាមទាំងឡាយ ដោយប្រការ ទាំងពួង ព្រោះកាត់ផ្តាច់ ។ ឈ្មោះថា **រូប** ព្រោះអត្ថថា បែកធ្លាយទៅ មិន មែនរូបឈ្មោះថាអរូប អធិប្បាយថា ជាបដិបក្ខចំពោះរូប ដូចអមិត្តជាបដិបក្ខ ចំពោះមិត្ត និងដូចអលោភៈជាដើម ជាបដិបក្ខចំពោះលោភៈជាដើម ។ ម្យ៉ាង ទៀត ពោលដោយអំណាចនៃផល ឈ្មោះថា **អរូប** ព្រោះអត្ថថា ក្នុងឈាននេះ មិនមានរូប អរូបនោះឯង ឈ្មោះថា **អារុប្បំ** បានដល់ អរូបជ្ឈានទាំងឡាយ ។ អរូបជ្ឈានទាំងនោះ ឈ្មោះថា ជាឧបាយគ្រឿងរលាស់ចេញនៃរូប ។ អរហត្តមគ្គ ឈ្មោះថា ឧបាយជាគ្រឿងរលាស់ចេញនៃរូបដោយប្រការទាំងពួង ព្រោះ ហាមការកើតថ្មីដោយមិនមានរូប ។ បទថា **ភូតំ** បានដល់ ដែលកើតហើយ ។ បទថា **សង្ខតំ** បានដល់ ដែលបច្ច័យប្រជុំតាក់តែង ។

បទថា **បដិច្ចសមុប្បន្នំ** បានដល់ ដែលអាស្រ័យបច្ច័យនោះៗ កើតឡើងដោយប្រពៃ និងព្រមគ្នា ។ ដោយពាក្យដំបូងលោកសម្តែងការមិនទៀង ដោយការសម្តែងដល់ភាវៈដែលកើត ។ ដោយពាក្យទី ២ កាលមានការមិនទៀង លោកក៏សម្តែងដល់ការជាប់ទាក់ទងគ្នាជាមួយវត្ថុដទៃ ដោយការសម្តែងដល់អានុភាពនៃបច្ច័យ ។ ដោយពាក្យទី ៣ កាលមានការជាប់ទាក់ទងគ្នាជាមួយវត្ថុដទៃ លោកក៏សម្តែងដល់ភាពជាធម្មតាយ៉ាងនេះ ដោយការសម្តែងដល់ការមិនខ្វល់ខ្វាយនៃបច្ច័យ ។ បទថា **និរោធោ** បានដល់ និព្វាន ។ និព្វាន លោកហៅថា និរោធោ ព្រោះអត្ថថា ដល់ហើយរលត់ទុក្ខបាន ។ និរោធនោះឈ្មោះថា ជាឧបាយរលាស់ចេញចាកសង្ខតៈនោះ ព្រោះរលាស់ចេញពីសង្ខតៈទាំងអស់ ។ ឯក្នុងអដ្ឋកថា លោកពោលថា ក្នុងបទនេះថា និរោធជាឧបាយរលាស់ចេញចាកសង្ខតៈនោះ លោកបំណងយកអរហត្តផល ថាជានិរោធ ។ ពិតហើយ កាលបើឃើញនិព្វានដោយអរហត្តផល សង្ខារទាំងពួងក៏មិនមានតទៅទៀត ព្រោះហេតុនោះ ទើបលោកពោលអរហត្តផលថា ជានិរោធ ព្រោះជាបច្ច័យនៃនិរោធ ពោល គឺអរហត្ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **នេក្ខម្មំ បដិលទ្ធស្ស** ជាដើមដូចតទៅ

បុគ្គលបាននេក្ខម្មៈជាការលះបង់ និងបោះបង់កាមបានហើយ ដោយវិក្ខម្ភនប្បហាន ព្រោះអសុភជ្ឈាន ជាឧបាយរលាស់ចេញដោយសមុច្ឆេទប្បហាន ព្រោះអនាគាមិមគ្គជាឧបាយរលាស់ចេញ ។ រូបក៏គប្បីប្រកបយ៉ាងនេះ ព្រោះ

អរូបជ្ឈានជាឧបាយរលាស់ចេញ និងព្រោះអរហត្តមគ្គជាឧបាយរលាស់ចេញ ។ ការកាត់ផ្តាច់រូបទាំងឡាយ រមែងមានដោយការលះធន្ទរាគៈក្នុងរូបទាំងឡាយ ។ ម្យ៉ាងទៀត ក្នុងបទថា **រូបា** នេះ លោកធ្វើជាលិង្គវិបល្លាស ។ បុគ្គលដែលបាននិរោធ ឈ្មោះថា លះ និងលះបង់សង្ខារបានហើយ ដោយនិស្សរណប្បហាន ព្រោះព្រះនិព្វានជាឧបាយរលាស់ចេញដោយបដិប្បស្សទ្ធិប្បហាន ព្រោះអរហត្តផល ជាឧបាយរលាស់ចេញ ។ ម្យ៉ាងទៀត គប្បីជ្រាបការបាននិរោធដោយអំណាចធ្វើឲ្យជាអារម្មណ៍ ព្រោះព្រះនិព្វានជាឧបាយរលាស់ចេញ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **ទុក្ខសច្ចំ** ជាដើមដូចតទៅ

បទថា **បរិញ្ញាបដិវេធំ** ជាដើម ជាការវែនបុំសកលិង្គ ។ ការចាក់ធ្លុះដោយការកំណត់ដឹង ឈ្មោះថា **បរិញ្ញាបដិវេធំ** ។ ជាការចាក់ធ្លុះដោយការកំណត់ដឹងនោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **បជហាតិ** គប្បីកាន់យកសេចក្តីថា បុគ្គលកាលចាក់ធ្លុះបានយ៉ាងនោះៗ រមែងលះកិលេសដែលគួរលះបាន ។ សូម្បីក្នុងធម៌ដែលជាលោកិយនិងលោកុត្តរ គប្បីកាន់យកសេចក្តីថា ម្យ៉ាងទៀត រមែងលះកិលេសទាំងនោះបានដោយការលះធន្ទរាគៈ ។ បាឋៈថា **បជហាតិ** ដូច្នេះក៏មាន ។ មគ្គញាណរមែងត្រាស់ដឹងអរិយសច្ច ៤ ក្នុងខណៈជាមួយគ្នាមិនមុនមិនក្រោយ គឺរមែងត្រាស់ដឹងទុក្ខដោយបរិញ្ញាភិសម័យ រមែងត្រាស់ដឹងសមុទយៈដោយបហានាភិសម័យ រមែងត្រាស់ដឹងមគ្គដោយភាវនាភិសម័យ រមែងត្រាស់ដឹងនិរោធដោយសច្ឆិកិរិយាភិសម័យ ដូចទូករមែងធ្វើកិច្ច ៤ យ៉ាងក្នុងខណៈតែមួយ មិន

មុនមិនក្រោយ គឺរមែងលះត្រើយអាយ កាត់ខ្សែទឹក នាំទំនិញទៅដល់ត្រើយនាយ ដូច្នោះ ។ គប្បីជ្រាបថា លោកពោលដល់បហានសូម្បីក្នុងខណៈតែមួយក៏ដូចញែកគ្នា ព្រោះលោកពោល ( ក្នុងវិសុទ្ធិមគ្គ ) ថា មានពាក្យអធិប្បាយដូចម្ដេច អធិប្បាយថា ព្រះយោគាវចរធ្វើនិរោធឲ្យជាអារម្មណ៍ រមែងសម្រេច រមែងឃើញ រមែងចាក់ធ្លុះអរិយសច្ច ៤ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបហាន ៥ ដូចតទៅនេះ ការគ្របសង្កត់ ការធ្វើឲ្យឆ្ងាយពីបច្ចនិកធម៌ មាននីវរណធម៌ជាដើម ដោយលោកិយសមាធិនោះៗ ដូចយកឆ្នាំងបោះទៅក្នុងទឹកដែលមានចក ធ្វើឲ្យចកឃ្លាតទៅឆ្ងាយ ដូច្នោះ នេះឈ្មោះថា វិក្ខម្ភនប្បហាន ។

បទថា **វិក្ខម្ភនប្បហានញ្ច និវរណានំ បឋមជ្ឈានំ ភាវយតោ** គប្បីជ្រាបថា លោកពោលដល់ការលះនីវរណៈនោះឯង ព្រោះនីវរណៈជាសភាវៈប្រាកដច្បាស់ ។ ការពិតនីវរណៈមិនគ្របសង្កត់ចិត្តលឿនរហ័សទាំងក្នុងចំណែកខាងដើម ទាំងក្នុងចំណែកខាងក្រោយនៃឈាន ។ កាលចិត្តត្រូវនីវរណៈទាំងនោះគ្របសង្កត់ ឈានរមែងវិនាស តែវិតក្កជាដើម នៅប្រព្រឹត្តទៅបាន មិនជាសត្រូវទាំងមុន និងក្រោយទុតិយជ្ឈានជាដើម ព្រោះហេតុនោះ ការគ្របសង្កត់នីវរណៈ ទើបប្រាកដច្បាស់ ។

ការលះធម៌ដែលគួរលះនោះៗ ដោយជាសត្រូវដល់គ្នានិងគ្នា ដោយអង្គឈានដែលជាចំណែករបស់វិបស្សនានោះៗ ដូចដុតប្រទីបក្នុងពេលយប់កម្ចាត់កាពងងឹតចេញបាន នេះឈ្មោះថា តទង្គប្បហាន ។ បទថា **តទង្គប្ប-**

ហានញ្ចុ **ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ** គប្បីជ្រាបថា លោកពោលដល់ការលះបង់ទិដ្ឋិ ជារបស់គ្រោតគ្រាត ដ្បិតថា ទិដ្ឋិជារបស់គ្រោតគ្រាត និច្ចសញ្ញាជាដើមជារបស់ល្អិត ។ ក្នុងបទទាំងនោះ បទថា **ទិដ្ឋិគតានំ** បានដល់ ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិគត** ដូចពាក្យ ( ក្នុងអង្គុត្តរនិកាយ នវកនិបាត ) ថា **គូថគតំ មុត្តគតំ** ជាក់លាមក ជាក់មូត្រ ដូច្នេះ ។ វត្ថុនេះ ត្រឹមតែត្រាច់ទៅក្នុងទិដ្ឋិនោះឯង ព្រោះជាសភាវៈដែលគួរទៅខ្វះ ទើបឈ្មោះថា **ទិដ្ឋិគត** ។ ធម៌នោះទៅក្នុងទិដ្ឋិព្រោះធ្លាក់ចុះក្នុងទិដ្ឋិ ៦២ ខ្វះ ទើបឈ្មោះថា **ទិដ្ឋិគត** ។ ទិដ្ឋិគតៈទាំងនោះ លោកពោលជាពហុវចនៈ ។

បទថា **និព្វេធភាគិយំ សមាធឹ** បានដល់ សមាធិដែលសម្បយុត្តដោយវិបស្សនា ។

ការលះដោយអាការ ដែលប្រព្រឹត្តទៅមិនបានតទៅទៀតនៃធម៌ដែលជាសំយោជនៈ ដោយអរិយមគ្គញ្ញាណ ដូចដើមឈើដែលត្រូវរន្ទះបាញ់ នេះឈ្មោះថា **សមុច្ឆេទប្បហាន** ។

បទថា **និរោធោ និព្វានំ** បានដល់ និព្វាន ពោល គឺនិរោធ ។

[ ៦៦ ] កាលសម្តែងធម៌ដែលគួរលះដោយបហានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងធម៌ដែលគួរលះទៀតដោយសរុប ទើបព្រះមានព្រះភាគត្រាស់ថា **សព្វំ ភិក្ខវេ បហាតព្វំ** ដូច្នេះជាដើម ។

ក្នុងធម៌ទាំងនោះ គួរលះធម៌ មានចក្ខុជាដើម ដោយការលះឆន្ទរាគៈ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទជាដើមថា **រូបំ បស្សន្តោ បជហាតិ** បានដល់

កាលពិចារណាឃើញរូប ដោយសភាពជារបស់មិនទៀងជាដើម រមែងលះកិលេសដែលគួរលះបាន ។

ក្នុងបេយ្យាល ២ ថា **ចក្ខុំ ។បេ។ ជរា មរណំ ។បេ។ អមតោគធំ និព្វានំ** អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ គួរប្រកបដោយសមគួរដល់ធម៌នោះៗ ថា កាលពិចារណាឃើញ ពិនិត្យពិច័យ សម្លឹង ប្រាថ្នា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយក្នុងលោកុត្តរធម៌ទាំងនោះ ដោយន័យជាដើមថា **បស្សន្តោ បជហាតិ** រមែងលះកិលេសដែលគួរលះ ក្នុងខណៈនៃវិបស្សនា ។ល។

## អដ្ឋកថាបហាតព្វនិទ្ទេស ចប់

## តតិយភាណវារៈ ចប់

# សុត្តន្តបិដក

[ ៦៧ ] ការប្រុងប្រយ័ត្នបៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវចម្រើន បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងប្រយ័ត្នបៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្ដេច ធម៌ ១ ដែលត្រូវចម្រើន គឺកាយគតាសតិដែលប្រកបដោយសេចក្ដីសុខស្រួល ធម៌ ២ ដែលត្រូវចម្រើន គឺសមថៈ ១ វិបស្សនា ១ ធម៌ ៣ ដែលត្រូវចម្រើន គឺសមាធិ ៣ ធម៌ ៤ ដែលត្រូវចម្រើន គឺសតិប្បដ្ឋាន ៤ ធម៌ ៥ ដែលត្រូវចម្រើន គឺសម្មាសមាធិមានអង្គ ៥ ធម៌ ៦ ដែលត្រូវចម្រើន គឺអនុស្សតិដ្ឋាន ៦ ធម៌ ៧ ដែលត្រូវចម្រើន គឺពោជ្ឈង្គ ៧ ធម៌ ៨ ដែលត្រូវចម្រើន គឺអរិយមគ្គប្រកបដោយអង្គ ៨ ធម៌ ៩ ដែលត្រូវចម្រើន គឺបារិសុទ្ធិប្បធានិយង្គៈ ៩ ធម៌ ១០ ដែលត្រូវចម្រើន គឺកសិណាយតនៈ ១០ ។

[ ៦៨ ] ភាវនា ( ការចម្រើន ) ២ យ៉ាង គឺលោកិយភាវនា ១ លោកុត្តរភាវនា ១ ។ ភាវនា ៣ យ៉ាង គឺការចម្រើនពួកធម៌ជារូបាវចរកុសល ១ ការចម្រើនពួកធម៌ជាអរូបាវចរកុសល ១ ការចម្រើនពួកធម៌ជាកុសលដែលមិនបានរាប់បញ្ចូល ( ក្នុងវដ្ដៈ ) គឺលោកុត្តរ ១ ។ ការចម្រើនពួកធម៌ជារូបាវចរកុសល ដ៏ថោកទាបក៏មាន ជាកណ្ដាលក៏មាន ដ៏ខ្ពង់ខ្ពស់ក៏មាន ការចម្រើនពួកធម៌ជាអរូបាវចរកុសលដ៏ថោកទាបក៏មាន ជាកណ្ដាលក៏មាន ដ៏ខ្ពង់ខ្ពស់ក៏មាន ការចម្រើនធម៌ជាកុសល ដែលមិនបានរាប់បញ្ចូល ( ក្នុងវដ្ដៈ ) គឺលោកុត្តរដ៏ខ្ពង់ខ្ពស់ ។ ភាវនា ៤ យ៉ាង គឺបុគ្គលកាលត្រាស់ដឹងដែលជាបរិញ្ញាបដិវេធហើយចម្រើន ១ កាលត្រាស់ដឹងនូវសមុទយសច្ចដែលជាបហានប្បដិវេធហើយចម្រើន ១ កាលត្រាស់ដឹងនូវនិរោធសច្ចដែលជាសច្ឆិកិរិយា-

បដិវេធហើយចម្រើន ១ កាលត្រាស់ដឹងនូវមគ្គសច្ច ដែលជាភាវនាបដិវេធហើយចម្រើន ១ ភាវនាមាន ៤ យ៉ាងនេះឯង ។

[ ៦៩ ] ភាវនា ៤ យ៉ាង ដោយឡែកទៀត គឺឯសនាភាវនា ១ បដិលាភភាវនា ១ ឯករសាភាវនា ១ អាសេវនាភាវនា ១ ។

ឯសនាភាវនា តើដូចម្តេច កាលពួកជនទាំងពួង កំពុងចូលកាន់សមាធិ ធម៌ទាំងឡាយដែលកើតក្នុងចំណែកខាងដើមនោះ ជាធម៌មានកិច្ចស្មើគ្នា នេះឈ្មោះថា ឯសនាភាវនា ដោយប្រការដូច្នេះ ។

បដិលាភភាវនា តើដូចម្តេច កាលពួកជនទាំងពួង ដែលបានចូលកាន់សមាធិហើយ ធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ រមែងមិនកន្លងនូវគ្នានិងគ្នាឡើយ នេះឈ្មោះថា បដិលាភភាវនា ដោយប្រការដូច្នេះ ។

[ ៧០ ] ឯករសាភាវនា តើដូចម្តេច កាលបុគ្គលចម្រើនសទ្ធិន្ទ្រិយដោយអត្ថថា ជឿស៊ប់ ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយដោយអំណាចនៃសទ្ធិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនវីរិយិន្ទ្រិយ ដោយអត្ថថា ផ្គងឡើង ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃវីរិយិន្ទ្រិយ ហេតុនោះទើបឈ្មោះថា ភាវនា ដោយអត្ថថា ពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនសតិន្ទ្រិយ ដោយអត្ថថា ប្រុងប្រយ័ត្ន ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយដោយអំណាចនៃសតិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពួកឥន្ទ្រិយមានរសតែមួយ បុគ្គលកាលចម្រើនសមាធិន្ទ្រិយ

ដោយអត្ថថា មិនរាយមាយ ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយដោយអំណាចនៃសមាធិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនបញ្ញិន្ទ្រិយ ដោយអត្ថថា ឃើញច្បាស់ ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយដោយអំណាចនៃបញ្ញិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនសទ្ធាពល ដោយអត្ថថា មិនញាប់ញ័រព្រោះសេចក្ដីមិនជឿ ពលទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃសទ្ធាពល ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពលទាំងឡាយមានរសតែមួយ បុគ្គលកាលចម្រើនវីរិយពល ដោយអត្ថថា មិនញាប់ញ័រ ព្រោះសេចក្ដីខ្ជិលប្រអូស ពលទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃវីរិយពល ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពលទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសតិពល ដោយអត្ថថា មិនញាប់ញ័រព្រោះសេចក្ដីប្រមាទ ពលទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃសតិពល ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពលទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសមាធិពល ដោយអត្ថថា មិនញាប់ញ័រព្រោះការអណ្ដែតអណ្ដូង ពលទាំង ៤ ជាធម្មជាតមានរសតែមួយដោយអំណាចនៃសមាធិពល ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពលទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនបញ្ញាពល ដោយអត្ថថា មិនញាប់ញ័រព្រោះអវិជ្ជា ពលទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃបញ្ញា-

ពល ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពលទាំងឡាយមានរសតែមួយ ។ កាលបុគ្គលចម្រើនសតិសម្ពោជ្ឈង្គ ដោយអត្ថថា ប្រុងប្រយ័ត្ន ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយដោយអំណាចនៃសតិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថា ជ្រើសរើស ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃធម្មវិចយសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា សម្ពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនវីរិយសម្ពោជ្ឈង្គ ដោយអត្ថថា ផ្គងឡើង ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយដោយអំណាចនៃវីរិយសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនបីតិសម្ពោជ្ឈង្គ ដោយអត្ថថា ផ្សាយទៅ ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយដោយអំណាចនៃបីតិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនបស្សទ្ធិ-សម្ពោជ្ឈង្គ ដោយអត្ថថា ស្ងប់រម្ងាប់ ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃបស្សទ្ធិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពោជ្ឈង្គទាំងឡាយ មានរសតែមួយ កាលបុគ្គលចម្រើនសមាធិ-សម្ពោជ្ឈង្គ ដោយអត្ថថា មិនរាយមាយ ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃសមាធិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា សម្ពោជ្ឈង្គទាំងឡាយមានរសតែមួយ បុគ្គលកាលចម្រើន

ឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថា ត្រួតត្រា ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃឧបេក្ខាសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ពោជ្ឈង្គទាំងឡាយ មានរសតែមួយ ។ កាលបុគ្គលចម្រើនសម្មាទិដ្ឋិ ដោយអត្ថថា ឃើញជាក់លាក់ អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយដោយអំណាចនៃសម្មាទិដ្ឋិ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាសង្កប្ប ដោយអត្ថថា ជាទីលើកឡើងនូវចិត្ត អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាសង្កប្ប ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាវាចា ដោយអត្ថថា រក្សាទុក អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយដោយអំណាចនៃសម្មាវាចា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយ មានរសតែមួយ កាលបុគ្គលចម្រើន សម្មាកម្មន្តៈ ដោយអត្ថថា តាំងឡើង អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាកម្មន្តៈ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាអាជីវៈ ដោយអត្ថថា ផូរផង់ អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាអាជីវៈ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយដោយអំណាចនៃសម្មាវាយាមៈ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំង

ឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាសតិ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយមានរសតែមួយ បុគ្គលកាលចម្រើនសម្មាសមាធិ ដោយអត្ថថា មិនរាយមាយ អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាសមាធិ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា អង្គមគ្គទាំងឡាយ មានរសតែមួយ នេះឈ្មោះថា ឯករសាភាវនា ។

[ ៧១ ] អាសេវនាភាវនា តើដូចម្តេច ភិក្ខុក្នុងសាសនានេះ ឧស្សាហ៍គប់រក ( នូវសមាធិ ) ក្នុងវេលាព្រឹកខ្លះ ឧស្សាហ៍គប់រកក្នុងវេលាថ្ងៃត្រង់ខ្លះ ឧស្សាហ៍គប់រក ក្នុងវេលាថ្ងៃរសៀលខ្លះ ឧស្សាហ៍គប់រកក្នុងកាលមុនកត្តខ្លះ ឧស្សាហ៍គប់រកក្នុងកាលខាងក្រោយកត្តខ្លះ ឧស្សាហ៍គប់រកក្នុងយាមខាងដើមខ្លះ ឧស្សាហ៍គប់រកក្នុងយាមកណ្តាលខ្លះ ឧស្សាហ៍គប់រក ក្នុងយាមខាងចុងខ្លះ ឧស្សាហ៍គប់រកក្នុងវេលាយប់ខ្លះ ឧស្សាហ៍គប់រកក្នុងវេលាថ្ងៃខ្លះ ឧស្សាហ៍គប់រកក្នុងវេលាយប់ និងវេលាថ្ងៃខ្លះ ឧស្សាហ៍គប់រកក្នុងចំណែកខាងរនោចខ្លះ ឧស្សាហ៍គប់រក ក្នុងចំណែកខាងខ្នើតខ្លះ ឧស្សាហ៍គប់រកក្នុងរដូវភ្លៀងខ្លះ ឧស្សាហ៍គប់រកក្នុងរដូវត្រជាក់ខ្លះ ឧស្សាហ៍គប់រកក្នុងរដូវក្តៅខ្លះ ឧស្សាហ៍គប់រកក្នុងចំណែកនៃវ័យខាងដើមខ្លះ ឧស្សាហ៍គប់រកក្នុងចំណែកនៃវ័យកណ្តាលខ្លះ ឧស្សាហ៍គប់រកក្នុងចំណែកនៃវ័យខាងចុងខ្លះ នេះឈ្មោះថា អាសេវនា-ភាវនា ភាវនាមាន ៤ យ៉ាងនេះឯង ។

[ ៧២ ] ភាវនា ៤ យ៉ាង ដោយឡែកទៀត គឺភាវនាដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ ១ ភាវនាដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ភាវនាដោយអត្ថថា ជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ភាវនាដោយអត្ថថា ឧស្សាហ៍គប់រក ១ ។

[ ៧៣ ] ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ តើដូចម្ដេច កាលបុគ្គលលះកាមច្ឆន្ទៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃនេក្ខម្មៈ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះព្យាបាទ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃការមិនព្យាបាទ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះថីន-មិទ្ធៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃអាលោកសញ្ញា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះឧទ្ធច្ចៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃការមិនអណ្ដែតអណ្ដូង រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនាដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេស

នោះ កាលបុគ្គលលះវិចិកិច្ឆា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃការកំណត់នូវធម៌ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអវិជ្ជា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃញាណ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអរតិ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃបាមុជ្ជ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះនីវរណធម៌ទាំងឡាយ ដែលកើតហើយ ដោយអំណាចនៃបឋមជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹតកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះវិតក្ក និងវិចារ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃទុតិយជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតហើយ ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះបីតិ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃតតិយជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសុខ និងទុក្ខ ធម៌ទាំង

ឡាយដែលកើតហើយដោយអំណាចនៃចតុត្ថជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃអាកាសានញ្ចាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអាកាសានញ្ចាយតនសញ្ញា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃវិញ្ញាណញ្ចាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះវិញ្ញាណញ្ចាយតនសញ្ញា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃអាកិញ្ចញ្ញាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតហើយ ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអាកិញ្ចញ្ញាយតនសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃនេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះនិច្ចសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃអនិច្චា-នុបស្សនារមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា

ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេស នោះ កាលបុគ្គលលះសុខសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយ អំណាចនៃទុក្ខានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើប ឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើត ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអត្តសញ្ញា ធម៌ទាំងឡាយដែលកើត ហើយ ដោយអំណាចនៃអនត្តានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំង ឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះនន្ទិ ធម៌ទាំងឡាយ ដែលកើតហើយដោយអំណាចនៃនិព្វិទានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នា និងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះរាគៈ ធម៌ទាំង ឡាយដែលកើតហើយដោយអំណាចនៃវិរាគានុបស្សនា រមែងមិនប្រព្រឹត្តកន្លង នូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសមុទយៈ ធម៌ទាំងឡាយ ដែលកើតហើយដោយអំណាចនៃនិរោធានុបស្សនា រមែងមិន ប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិន ប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គល លះការប្រកាន់មាំ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃបដិនិស្សគ្គា-នុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា

ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេស នោះ កាលបុគ្គលលះសេចក្ដីសម្គាល់ថាជាប់នៅរឹងប៉ឹង ធម៌ទាំងឡាយដែល កើតហើយ ដោយអំណាចខយានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំង ឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការប្រមូលមក ធម៌ ទាំងឡាយដែលកើតហើយ ដោយអំណាចវយានុបស្សនា រមែងមិនប្រព្រឹត្ត កន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្ត កន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការ សម្គាល់ថាមាំមួន ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចវិបរិណាមានុបស្សនារមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេស នោះ កាលបុគ្គលលះការកំណត់ថាទៀង ធម៌ទាំងឡាយដែលកើតហើយដោយ អំណាចអនិមិត្តានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើប ឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើត ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រាថ្នា ធម៌ទាំងឡាយដែលកើត ហើយដោយអំណាចអប្បណិហិតានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិង គ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រកាន់ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចសុញ្ញតានុបស្សនា រមែងមិន

ប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រកាន់មាំ និងការប្រកាន់ស្អិតថាមានខ្លឹម ធម៌ទាំងឡាយដែលកើតហើយដោយអំណាចអធិប្បញ្ញា និងធម្មវិបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រកាន់ដោយការវង្វេងខ្វាំង ធម៌ទាំងឡាយដែលកើតហើយដោយអំណាចយថាភូតញ្ញាណទស្សនៈ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រកាន់ដោយអាល័យ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចអាទីនវានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការមិនពិចារណា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចបដិសង្ខានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រកាន់ដោយការប្រកបទុក ធម៌ទាំងឡាយដែលកើតហើយដោយអំណាចវិវដ្ដនានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើត

ក្នុងភាវនាវិសេសនោះ កិលេសទាំងឡាយ ដែលស្ថិតនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចសោតាបត្តិមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះកិលេសទាំងឡាយ ដ៏គ្រោតគ្រាត ធម៌ទាំងឡាយដែលកើតហើយដោយអំណាចសកទាគាមិមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះកិលេសទាំងឡាយដ៏ល្អិត ធម៌ទាំងឡាយដែលកើតហើយដោយអំណាចអនាគាមិមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះកិលេសទាំងអស់ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចអរហត្តមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ ភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ យ៉ាងនេះឯង ។

[ ៧៤ ] ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ តើដូចម្ដេច កាលបុគ្គលលះកាមច្ឆន្ទៈ ឥន្ទ្រិយទាំង ៥ មានរសតែមួយដោយអំណាចនេក្ខម្មៈ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំង

ឡាយមានរសតែមួយ កាលបុគ្គលលះព្យាបាទ ឥន្ទ្រិយទាំង ៥ មានរសតែមួយដោយអំណាចការមិនព្យាបាទ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ។បេ។ កាលបុគ្គលលះកិលេសទាំងអស់ ឥន្ទ្រិយទាំង ៥ មានរសតែមួយដោយអំណាចអរហត្តមគ្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយយ៉ាងនេះឯង ។

[ ៧៥ ] ភាវនា ដោយអត្ថថា ជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ តើដូចម្ដេច បុគ្គលកាលលះកាមច្ឆន្ទៈ ហើយនាំទៅនូវវីរិយៈដោយអំណាចនេក្ខម្មៈ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ បុគ្គលកាលលះព្យាបាទ ហើយនាំទៅនូវវីរិយៈដោយអំណាចការមិនព្យាបាទ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ជាទីនាំទៅនូវវីរិយៈ ដ៏សមគួរដល់ឥន្ទ្រិយនោះ ។បេ។ បុគ្គលកាលលះកិលេសទាំងអស់ ហើយនាំទៅនូវវីរិយៈដោយអំណាចអរហត្តមគ្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ភាវនា ដោយអត្ថថា ជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ យ៉ាងនេះឯង ។

[ ៧៦ ] ភាវនា ដោយអត្ថថា ឧស្សាហ៍គប់រក តើដូចម្ដេច បុគ្គលកាលលះកាមច្ឆន្ទៈ ឧស្សាហ៍គប់រកនេក្ខម្មៈ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ឧស្សាហ៍គប់រក បុគ្គលកាលលះព្យាបាទឧស្សាហ៍ គប់រកការមិនព្យាបាទ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ឧស្សាហ៍គប់រក ។បេ។ បុគ្គល

កាលលះកិលេសទាំងអស់ ឧស្សាហ៍គប់រកអរហត្តមគ្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថា ឧស្សាហ៍គប់រក ភាវនា ដោយអត្ថថា ឧស្សាហ៍គប់រកយ៉ាងនេះឯង នេះភាវនា ៤ បុគ្គលកាលឃើញរូបក៏ចម្រើន ( នូវធម៌ដែលគួរចម្រើន ) កាលឃើញវេទនាក៏ចម្រើន កាលឃើញសញ្ញាក៏ចម្រើន កាលឃើញសង្ខារទាំងឡាយក៏ចម្រើន កាលឃើញវិញ្ញាណក៏ចម្រើន ចក្ខុ ។បេ។ ជរា និងមរណៈ កាលឃើញព្រះនិព្វាន ឈ្មោះថា អមតៈជាទីពឹង ( របស់សត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃសាសនា ) ក៏ចម្រើន ធម៌ទាំងឡាយណាៗ ដែលបុគ្គលចម្រើនហើយ ធម៌ទាំងឡាយនោះៗ មានរសតែមួយ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងនេះបុគ្គលត្រូវចម្រើន បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

## ភាណវារៈទី ៤ ចប់

# ចតុត្ថភាណវារៈ

# អដ្ឋកថា ការវេតព្ទនិទ្ទេស

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងការវេតព្ទនិទ្ទេសដូចតទៅ

បទថា **កាយគតាសតិ** បានដល់ សតិសម្បយុត្តដោយមនសិការដល់អានាបានស្សតិ ឥរិយាបថ ៤ ឥរិយាបថតូច អាការ ៣២ ធាតុ ៤ ព្រៃខ្មោច ៩ និងការកំណត់វត្ថុជាបដិកូលដែលពោលហើយក្នុងសូត្រ ដែលពោលដោយកាយគតាសតិ និងសម្បយុត្តដោយរូបជ្ឈានតាមសមគួរ ។ សតិនោះលោកពោលថា **កាយគតា** ព្រោះអត្ថថា ទៅ គឺប្រព្រឹត្តទៅក្នុងកាយទាំងនោះ ។

បទថា **សាតសហគតា** បានដល់ ភាវៈ មានការកើតឡើងព្រមគ្នាជាដើម មួយអន្លើដោយសេចក្តីសុខស្រួល ពោលគឺការសោយសុខដ៏ត្រជាក់ ។

**សហគត** សព្ទ ប្រាកដក្នុងជិនវចនៈ ចុះក្នុងអត្ថ ៥ ប្រការ គឺ **តព្ភាវ** ភាពរបស់នោះ ១ **វោកិណ្ណ** ពេញទៅដោយ ១ **អារម្មណ** អារម្មណ៍ ១ **និស្សយ** អាស្រ័យ ១ **សំសដ្ឋ** ប្រឡូកប្រឡំ ១ ។

ប្រាកដក្នុងអត្ថថា **តព្ភាវ** ដូចក្នុងប្រយោគជាដើមថា **យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា** អរិយសច្ច គឺតណ្ហានេះឯង ជាធម្មជាតនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយ និងសេចក្តីត្រេកត្រអាលដូច្នេះ អធិប្បាយថា កើតនូវនន្ទិរាគៈ ។

ប្រាកដក្នុងអត្ថថា **វោកិណ្ណ** ដូចក្នុងប្រយោគជាដើមថា **យា ភិក្ខវេ**

**វីមំសា កោសជ្ជសហគតា កោសជ្ជសម្បយុត្តា** ម្នាលភិក្ខុទាំងឡាយ វីមំសាឯណាប្រកបដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ ដូច្នេះ អធិប្បាយថា វីមំសាលាយឡំដោយការខ្ជិលច្រអូស ដែលកើតឡើងក្នុងចន្លោះៗ ។

ប្រាកដក្នុងបទថា **អារម្មណា** ដូចក្នុងប្រយោគជាដើមថា **លាភី ហោតិ រូបសហគតានំ វា សមាបត្តីនំ អរូបសហគតានំ វា សមាបត្តីនំ** ជាអ្នកបានសមាបត្តិដែលសហគតៈដោយរូប ឬសមាបត្តិដែលសហគតៈដោយអរូប ដូច្នេះ អធិប្បាយថា សមាបត្តិមានរូបជាអារម្មណ៍ និងមានអរូបជាអារម្មណ៍ ។

ប្រាកដក្នុងអត្ថថា **និស្សយ** ដូចក្នុងប្រយោគជាដើមថា **អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ** ( ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ) ចម្រើនសតិសម្ពោជ្ឈង្គប្រកបដោយអដ្ឋិកសញ្ញា ដូច្នេះ អធិប្បាយថា ព្រោះចម្រើនអដ្ឋិកសញ្ញា ដែលអាស្រ័យអដ្ឋិកសញ្ញាដែលបានចំពោះហើយ ។

ប្រាកដក្នុងអត្ថថា **សំសដ្ឋ** ដូចក្នុងប្រយោគជាដើមថា **ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ** សេចក្តីសុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយឲ្យ ច្រឡំប្រកបដោយបីតិនេះ អធិប្បាយថា លាយឡំគ្នា ។ សូម្បីក្នុងទីនេះលោកក៏បំណងយកការច្រឡំគ្នា ។ ព្រោះសតិច្រឡំដោយការសុខស្រួល លោកពោលថា **សាតសហគតា** សហគតៈដោយការសុខស្រួល ។

ពិតហើយ សតិដែលសហគតៈដោយការសុខស្រួលនោះ វៀរចតុត្ថជ្ឈាន ក្នុងឈានដ៏សេស រមែងជា **សាតសហគតា** កាលសតិសហគតៈដោយ

ឧបេក្ខាមានដោយច្រើន លោកក៏ពោលថា **សាតសហគតា** ម្យ៉ាងទៀត កាល សតិសហគតៈដោយសេចក្តីសុខស្រួល សូម្បីសតិដែលសហគតៈដោយឧបេក្ខា ក៏ឈ្មោះថា លោកពោលហើយផងដែរ ព្រោះចតុត្ថជ្ឈាន មានឈានដែលកើតមុន ( ជាន់ទាបជាង ) ដែលសហគតៈដោយការសុខស្រួលជាមូល ព្រោះឧបេក្ខា ពោលក្នុងសេចក្តីសុខដែលល្អិត សូម្បីសតិដែលសម្បយុត្ត ដោយចតុត្ថជ្ឈាន ក៏ឈ្មោះថា ព្រះមានព្រះភាគត្រាស់ថា **សាតសហគត។**

បទថា **សមថោ ច វិបស្សនា ច** ឈ្មោះថា សមថៈ ព្រោះញុាំងធម៌ដែលជាសត្រូវ មានកាមច្ឆន្ទៈជាដើមឲ្យស្ងប់ គឺឲ្យវិនាសទៅ ។ ពាក្យនេះ ជាឈ្មោះរបស់សមាធិ ។ ឈ្មោះថា **វិបស្សនា** ព្រោះឃើញធម៌ដោយអាការច្រើនយ៉ាងដោយជារបស់មិនទៀងជាដើម ពាក្យនេះ ជាឈ្មោះរបស់បញ្ញា ។ ពីរបទនេះ ក្នុងបរិយាយនៃទសុត្តរសូត្រ លោកពោលថា ជាបុព្វភាគ និងក្នុងបរិយាយនៃសង្គីតិសូត្រលោកពោលថា ជាលោកិយផង លោកុត្តរផងលាយឡំគ្នា ។

បទថា **តយោ សមាធិ** បានដល់ សមាធិមានវិតក្ក មានវិចារ ១ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ ១ សមាធិមិនមានវិតក្កផង មិនមានវិចារផង ១ ។ សមាធិដែលប្រព្រឹត្តទៅជាមួយវិតក្ក ដែលប្រព្រឹត្តទៅដោយអំណាចសម្បយុត្ត ឈ្មោះថា មានវិតក្ក សមាធិដែលប្រព្រឹត្តទៅដោយវិចារ ឈ្មោះថា មានវិចារ ។ សមាធិនោះ ជាខណិកសមាធិ ( សមាធិជាខណៈ ) ជាវិបស្សនាសមាធិ ( សមាធិដ៏ងច្បាស់ ) ជាឧបចារសមាធិ ( សមាធិជា

កណ្តាលៗ ) ជាបឋមជ្ឈានសមាធិ ( សមាធិក្នុងបឋមជ្ឈាន ) ។ ឈ្មោះថា មិនមានវិតក្ក ព្រោះសមាធិនោះមិនមានវិតក្ក ឈ្មោះថា មានត្រឹមតែវិចារ ព្រោះអត្ថថា ក្នុងវិតក្កវិចារ វិចារជាប្រមាណ គឺជាសំខាន់ក្រៅលែងនៃសមាធិនោះ អធិប្បាយថា សមាធិមិនដល់ការប្រកបរួមគ្នាជាមួយវិតក្ក ក្រៅលែងជាងវិចារ ។ ក្នុងបញ្ចកន័យ សមាធិនោះ ជាសមាធិក្នុងទុតិយជ្ឈាន សមាធិវៀរទាំងពីរយ៉ាងនោះ ឈ្មោះថា មិនមានវិតក្កផង មិនមានវិចារផង ។ សមាធិនោះ ក្នុងចតុក្កន័យ ជារូបាវចរសមាធិមានទុតិយជ្ឈានជាដើម ។ ក្នុងបញ្ចកន័យ ជារូបាវចរសមាធិ មានតតិយជ្ឈានជាដើម ។ សមាធិសូម្បីទាំង ៣ នោះ ក៏ជាលោកិយនោះឯង ។ ក្នុងបរិយាយនៃសង្គីតិសូត្រ លោកពោលដល់សមាធិ ៣ យ៉ាងដទៃទៀត គឺសុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ក្នុងទីនេះ លោកមិនបំណងយកសមាធិទាំងនោះ ។

បទថា **ចត្តារោ សតិប្បដ្ឋានា** បានដល់ កាយានុបស្សនាសតិប្បដ្ឋាន ១ វេទនានុបស្សនាសតិប្បដ្ឋាន ១ ចិត្តានុបស្សនាសតិប្បដ្ឋាន ១ ធម្មានុបស្សនាសតិប្បដ្ឋាន ១ ។

ព្រះយោគី អ្នកកំណត់កាយដោយវិធី ១៤ យ៉ាង ក្នុងចំណែកខាងដើម គប្បីជ្រាបថា ជាកាយានុបស្សនាសតិប្បដ្ឋាន ។

ព្រះយោគី អ្នកកំណត់វេទនាដោយវិធី ៩ យ៉ាង គប្បីជ្រាបថា ជាវេទនានុបស្សនាសតិប្បដ្ឋាន ។

ព្រះយោគី អ្នកកំណត់ចិត្តដោយវិធី ១៦ យ៉ាង គប្បីជ្រាបថា ជា

ចិត្តានុបស្សនាសតិប្បដ្ឋាន ។

ព្រះយោគី អ្នកកំណត់ដឹងធម៌ ដោយវិធី ៥ យ៉ាង គប្បីជ្រាបថាជាធម្មានុបស្សនាសតិប្បដ្ឋាន ។ ក្នុងទីនេះ លោកមិនបំណងយកលោកុត្តរធម៌ទេ ។

បទថា **បញ្ចង្គិកោ សមាធិ** មានវិគ្គហៈថា សមាធិ ឈ្មោះថា មានអង្គ ៥ ព្រោះអត្ថថា សមាធិនោះមានអង្គ ៥ បានដល់ សមាធិក្នុងចតុត្ថជ្ឈាន ។ អង្គ ៥ គឺ **បីតិផរណតា** បីតិជ្រួតជ្រាប ១ **សុខផរណតា** សេចក្ដីសុខជ្រួតជ្រាប ១ **ចេតោផរណតា** ចិត្តជ្រួតជ្រាប ១ **អាលោកផរណតា** ពន្លឺភ្លឺស្វាងផ្សាយជ្រួតជ្រាប ១ **បច្ចវេក្ខណានិមិត្ត** ការពិចារណានិមិត្ត ១ ។

បញ្ញាក្នុងឈាន ២ ឈ្មោះថា **បីតិផរណតា** ព្រោះការផ្សាយបីតិកើតឡើង ។

បញ្ញាក្នុងឈាន ៣ ឈ្មោះថា **សុខផរណតា** ព្រោះការផ្សាយសេចក្ដីសុខកើតឡើង ។

ចេតោបរិយប្បញ្ញា ( បញ្ញាកំណត់ដឹងចិត្ត ) ឈ្មោះថា ចេតោផរណតា ព្រោះផ្សាយចិត្តដល់អ្នកដទៃកើតឡើង ។

ទិព្វចក្ខុប្បញ្ញា ( បញ្ញាកើតពីភ្នែកទិព្វ ) ឈ្មោះថា អាលោកផរណតា ព្រោះការផ្សាយពន្លឺកើតឡើង ។

បច្ចវេក្ខណញ្ញាណ ឈ្មោះថា បច្ចវេក្ខណនិមិត្ត ។ ក្នុងសេចក្ដីនេះ ព្រះមានព្រះភាគ ត្រាស់ ( ក្នុងអភិធម្ម វិភង្គ ) ថា បញ្ញាក្នុងឈាន ២ ឈ្មោះថា បីតិផរណតា បញ្ញាក្នុងឈាន ៣ ឈ្មោះថា សុខផរណតា បញ្ញាផ្សាយ

ទៅក្នុងចិត្តនៃបុគ្គលដទៃ ឈ្មោះថា ចេតោផរណតា ទិព្វចក្ខុ ឈ្មោះថា អាលោកផរណតា បច្ចវេក្ខណញាណរបស់បុគ្គល ដែលចេញចាកសមាធិនោះៗ ឈ្មោះថា បច្ចវេក្ខណនិមិត្ត ដូច្នេះ ។

បច្ចវេក្ខណញាណនោះ លោកពោលថា ជានិមិត្ត ព្រោះកាន់យកអាការដែលប្រព្រឹត្តទៅរបស់អ្នកដែលចេញពីសមាធិហើយ ។

ម្យ៉ាងទៀត ក្នុងអង្គ ៥ នោះ បីតិផរណតា សុខផរណតាដូចជើងទាំងពីរ ចេតោផរណតា អាលោកផរណតាដូចដៃទាំងពីរ ចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ដូចមជ្ឈិមកាយ ( កាយត្រង់កណ្តាល ) បច្ចវេក្ខណនិមិត្តដូចក្បាល ។

ព្រះធម្មសេនាបតីសារីបុត្តត្ថេរ សម្តែងសម្មាសមាធិមានអង្គ ៥ ប្រៀបដូចបុរសដែលសម្បូរដោយអវយវៈតូចធំ ។

បទថា **ឆ អនុស្សតិដ្ឋានានិ** សតិនោះឯង ឈ្មោះថា អនុស្សតិ ព្រោះកើតឡើងរឿយៗ សតិសមគួរដល់កុលបុត្តអ្នកបួសដោយសទ្ធា ព្រោះប្រព្រឹត្តទៅក្នុងឋានៈដែលគួរប្រព្រឹត្តទៅ ឈ្មោះថា អនុស្សតិក៏មាន អនុស្សតិនោះឯង ឈ្មោះថា អនុស្សតិដ្ឋាន ព្រោះជាឋានៈនៃបីតិជាដើម ។

ធម៌ ៦ តើដូចម្តេច ។ សេចក្តីរឭកនូវព្រះពុទ្ធ ១ រឭកនូវព្រះធម៌ ១ រឭកនូវព្រះសង្ឃ ១ រឭកនូវគុណនៃសីល ១ រឭកនូវទានដែលបានបរិច្ចាគហើយ ១ រឭកដល់ធម៌ទេវតា ១ ។

បទថា **ពោជ្ឈង្គា** បានដល់ អង្គដើម្បីការត្រាស់ដឹង ឬអង្គនៃអ្នកត្រាស់ដឹង ។ លោកអធិប្បាយថា ហៅថា **ពោធិ** ព្រោះព្រះអរិយសាវក រមែង

ត្រាស់ដឹងដោយធម្មសាមគ្គី ពោល គឺសតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខាដែលជាបដិបក្ខដល់អន្តរាយមិនមែនតិច មានការរួញរា ការរាយមាយ ការជាប់ស្អិត ការសន្សំ កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ ឧច្ឆេទទិដ្ឋិ សស្សតទិដ្ឋិ និងការប្រកាន់មាំជាដើម ដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គ ។ ពាក្យថា រមែងត្រាស់ដឹង បានដល់ ក្រោកឡើងចាកការដេកលក់ដែលជាកិលេសសន្តាន ឬចាក់ធ្លុះអរិយសច្ច ៤ ឬធ្វើនិព្វានឲ្យជាក់ច្បាស់ ។ អង្គនៃការត្រាស់ដឹង ពោល គឺធម្មសាមគ្គីនោះ ឈ្មោះថា ពោជ្ឈង្គៈ ដូចអង្គឈាន និងអង្គមគ្គជាដើម ។ ព្រះអរិយសាវកហៅថា ពោធិ ព្រោះត្រាស់ដឹងដោយធម្មសាមគ្គី មានប្រការដូចពោលហើយនោះ អង្គនៃអ្នកត្រាស់ដឹងនោះ ឈ្មោះថា **ពោជ្ឈង្គ** ដូចអង្គនៃសេនា និងអង្គនៃរថជាដើម ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា អង្គនៃបុគ្គលអ្នកត្រាស់ដឹង ឈ្មោះថា **ពោជ្ឈង្គ**។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពោជ្ឈង្គ ដោយន័យ ( ក្នុងបដិសម្ភិទាមគ្គ ) ជាដើមថា សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គដោយអត្ថដូចម្ដេច ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ដឹង ដូច្នេះ ។

បទថា **អរិយោ អដ្ឋង្គិកោ មគ្គោ** ឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសដែលត្រូវសម្លាប់ដោយមគ្គនោះៗ ព្រោះធ្វើភាពជាអរិយៈ និងព្រោះធ្វើឲ្យបានអរិយផល ។ ឈ្មោះថា **អដ្ឋង្គិក** ព្រោះអត្ថថា មគ្គនោះមានអង្គ ៨ ។ មគ្គមានអង្គ ៨ នោះ ត្រឹមតែជាអង្គប៉ុណ្ណោះ ដូចសេនាមានអង្គ ៤ និងដូច

តន្ត្រីមានអង្គ ៥ ។ ផុតពីអង្គហើយរមែងមិនមាន ។ ពោជ្ឈង្គ និងអង្គមគ្គជាលោកុត្តរ សូម្បីចំណែកខាងដើម ក៏រមែងបានដោយបរិយាយនៃទសុត្តរសូត្រ ។

បទថា **នវ បារិសុទ្ធិប្បធានិយង្គានិ** បានដល់ សីលវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ ១ ចិត្តវិសុទ្ធិជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ ១ ទិដ្ឋិវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ កង្ខាវិតរណវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ ១ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ ១ បដិបទាញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ ញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ ១ បញ្ញាវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ ១ **វិមុត្តិវិសុទ្ធិ** ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ[១] ដូច្នេះ ។

ពាក្យថា **សីលវិសុទ្ធិ** បានដល់ ចតុប្បារិសុទ្ធិសីល ដែលអាចឲ្យដល់សេចក្តីបរិសុទ្ធ ។ សីលវិសុទ្ធិនោះជម្រះមន្ទិល គឺភាពជាអ្នកទ្រុស្តសីល ឲ្យបរិសុទ្ធ ។

ពាក្យថា ជាអង្គនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ បានដល់ អង្គដែលជាប្រធាន គឺឧត្តមនៃសេចក្តីបរិសុទ្ធ ។

ពាក្យថា ចិត្តវិសុទ្ធិ បានដល់ សមាបត្តិ ៨ ដែលស្ទាត់ជំនាញ ជាបទដ្ឋាននៃវិបស្សនា ។ សមាបត្តិទាំងនោះ រមែងជម្រះមន្ទិលនៃចិត្ត មាន

---

១- ទីឃនិកាយ បាដិកវគ្គ ។

កាមច្ឆន្ទៈជាដើមឲ្យបរិសុទ្ធ ។

ពាក្យថា ទិដ្ឋិវិសុទ្ធិ បានដល់ ការឃើញនាមរូប មួយអន្លើដោយបច្ច័យ ។ ទិដ្ឋិវិសុទ្ធិនោះ ជម្រះមន្ទិលនៃទិដ្ឋិ ៧ ឲ្យបរិសុទ្ធ ។

ពាក្យថា កង្ខាវិតរណវិសុទ្ធិ បានដល់ ការដឹងបច្ចយាការ ។ ព្រះយោគាវចរ កាលណាឃើញថា ធម៌ទាំងឡាយរមែងប្រព្រឹត្តទៅដោយអំណាចបច្ច័យ ក្នុងអទ្ធា ( កាល ) ៣ ធ្វើមន្ទិល គឺការសង្ស័យ ៧ ក្នុងអទ្ធា ៣ បាន ដោយញាណនោះ ។

ពាក្យថា មគ្គាមគ្គញាណទស្សនវិសុទ្ធិ បានដល់ វិបស្សនូបក្កិលេស ១០ គឺឱភាស ១ ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១ អធិមោក្ខ ១ បគ្គហ ១ ឧបដ្ឋាន ១ ឧបេក្ខា ១ និកន្តិ ១ កើតឡើងក្នុងខណៈឧទយព្វយានុបស្សនា មិនមែនជាផ្លូវឧទយព្វយញ្ញាណដែលប្រព្រឹត្តទៅតាមវិថីជាផ្លូវ ព្រោះហេតុនោះ ទើបឈ្មោះថា មគ្គាមគ្គញាណ ដោយប្រការដូច្នេះ ។ ព្រោះព្រះយោគាវចរ រមែងជម្រះមន្ទិលដែលមិនមែនផ្លូវឲ្យបរិសុទ្ធិ ដោយញាណនោះ ។

ពាក្យថា បដិបទាញាណទស្សនវិសុទ្ធិ បានដល់ វិបស្សនាញាណទាំង ៩ នេះ គឺឧទយព្វយានុបស្សនាញាណដែលប្រព្រឹត្តទៅតាមវិថិ ១ ភង្គានុបស្សនាញាណ ១ ភយតូបដ្ឋានានុបស្សនាញាណ ១ អាទីនវានុបស្សនាញាណ ១ និព្វិទានុបស្សនាញាណ ១ មុញ្ចិតុកម្យតាញាណ ១ បដិសង្ខានុបស្សនាញាណ ១ សង្ខារុបេក្ខាញាណ ១ សច្ចានុលោមិកញ្ញាណ ១ ។ វិបស្សនាញាណទាំងនោះ រមែងជម្រះមន្ទិល មានការសម្គាល់ថាទៀងជាដើមឲ្យបរិសុទ្ធ ។

ពាក្យថា ញាណទស្សនវិសុទ្ធិ បានដល់ បញ្ញាក្នុងអរិយមគ្គ ៤ ។ អរិយមគ្គប្បញ្ញានោះ រមែងជម្រះមន្ទិល គឺកិលេសដែលត្រូវសម្លាប់ដោយមគ្គ រៀងៗ ខ្លួន ឲ្យបរិសុទ្ធដោយដាច់ខាត ។

ពាក្យថា បញ្ញាវិសុទ្ធិ បានដល់ បញ្ញាក្នុងអរហត្តផល ។

ពាក្យថា វិមុត្តិវិសុទ្ធិ បានដល់ វិមុត្តិក្នុងអរហត្តផល ។

បទថា **ទស កសិណាយតនានិ** លោកពោលដល់ កសិណ ១០ ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) យ៉ាងនេះ គឺបុគ្គលមួយពួកដឹងបឋវីកសិណទាំងខាងលើ ខាងក្រោម ទទឹង មិនមានគូ មិនមានប្រមាណ ១ បុគ្គលមួយពួកដឹងអាបោកសិណ ... ១ បុគ្គលមួយពួកដឹងតេជោកសិណ ... ១ បុគ្គលមួយពួកដឹងវាយោកសិណ ... ១ បុគ្គលមួយពួកដឹងនីលកសិណ ... ១ បុគ្គលមួយពួកដឹងបីតកសិណ ... ១ បុគ្គលមួយពួកដឹងលោហិតកសិណ ... ១ បុគ្គលមួយពួកដឹងឱទាតកសិណ ... ១ បុគ្គលមួយពួកដឹងអាកាសកសិណ ... ១ បុគ្គលមួយពួកដឹងវិញ្ញាណកសិណទាំងខាងលើ ខាងក្រោម ទទឹង មិនមានគូ មិនមានប្រមាណ ១ ។ កសិណទាំងនោះ ឈ្មោះថា កសិណ ដោយអត្ថថា ផ្សាយទូទៅ ឈ្មោះថា អាយតនៈ ដោយអត្ថថា ជាខេត្ត ឬដោយអត្ថថា ជាទីតាំងនៃធម៌ ដែលមានកសិណនោះជាអារម្មណ៍ ។

ពាក្យថា ខាងលើ បានដល់ សំដៅចំពោះអាកាសខាងលើ ។ ពាក្យថា ខាងក្រោម បានដល់ សំដៅចំពោះផែនដីខាងក្រោម ។

ពាក្យថា ទទឹង បានដល់ កំណត់ដោយជុំវិញ ដូចបរិវេណរបស់ផ្ទៃ

ដី ។ ព្រោះបុគ្គលពួកខ្លះ ពង្រីកកសិណទៅខាងលើ បុគ្គលពួកខ្លះ ខាងក្រោម បុគ្គលពួកខ្លះ ដោយជុំវិញ ។ ឬថា សូម្បីបុគ្គលមួយបំណងនឹងឃើញរូប ដូចបំណងនឹងឃើញពន្លឺ រមែងពង្រីកទៅយ៉ាងនេះ ដោយហេតុនោះៗ ។ ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលមួយពួកដឹងបឋវីកសិណ ទាំងខាងលើ ខាងក្រោម ទទឹង ដូច្នេះ ។

ពាក្យថា មិនមានគូ នេះ លោកពោលដើម្បីមិនឲ្យកសិណឯណានីមួយដល់នូវសភាពជាយ៉ាងដទៃ ។ បឋវីកសិណ រមែងជាបឋវីកសិណប៉ុណ្ណោះ បឋវីកសិណនោះមិនមានកសិណដទៃលាយឡំ ដូចបុគ្គលកាលចុះទៅក្នុងទឹក ទឹកប៉ុណ្ណោះ រមែងមានក្នុងទិសទាំងពួង មិនមែនវត្ថុដទៃ ។ ក្នុងបទទាំងពួងក៏មានន័យយ៉ាងនេះ ។

ពាក្យថា មិនមានប្រមាណ នេះ លោកពោលដោយអំណាច មិនមានប្រមាណនៃការផ្សាយទៅរបស់កសិណនោះៗ ។ ពិតហើយ កសិណនោះកាលផ្សាយទៅផ្លូវចិត្ត រមែងផ្សាយទូទៅ មិនបានកំណត់ថា នេះជាខាងដើម នេះជាកណ្តាលរបស់កសិណនោះ ។

ពាក្យថា អាកាសកសិណ បានដល់ កសិណុគ្ឃាដិមាកាស ( អាកាសដែលបានពីការបើកកសិណ ) និងបរិច្ឆេទាកាស ( អាកាសកសិណដែលកំណត់ ) ។

ពាក្យថា វិញ្ញាណកសិណ បានដល់ វិញ្ញាណដែលប្រព្រឹត្តទៅក្នុងកសិណុគ្ឃាដិមាកាស ។ ក្នុងវិញ្ញាណកសិណនោះ គប្បីជ្រាបសេចក្តីជាខាងលើ

*ខាងក្រោម ខាងទទឹង ក្នុងកសិណុគ្ឃាដិមាកាសដោយអំណាចកសិណ និង ក្នុងវិញ្ញាណដែលប្រព្រឹត្តទៅហើយ ក្នុងកសិណុគ្ឃាដិមាកាសនោះ ដោយ អំណាចកសិណុគ្ឃាដិមាកាស គប្បីជ្រាបខាងលើ ខាងក្រោម ទទឹង ដោយ អំណាចបរិច្ឆេទាកាសកសិណនោះ ព្រោះសូម្បីបរិច្ឆេទាកាសកសិណ ក៏ ពង្រីកបានដូច្នេះដែរ ។*

*[ ៦៨ ] ឥឡូវនេះ ព្រះសារីបុត្ត កាលសម្តែងប្រភេទរបស់ភាវនា ទើប ពោលថា* **ទ្វេ ភាវនា** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ គប្បីវិនិច្ឆ័យក្នុងបទ ថា* **លោកិយា** *ដូចតទៅនេះ វដ្ដៈ លោកពោលថា លោក ព្រោះអត្ថថា បែកធ្លាយទៅ ។ ឈ្មោះថា* **លោកិយ** *ព្រោះអត្ថថា ប្រកបហើយក្នុងលោក ដោយការទាក់ទងគ្នាក្នុងវដ្ដៈនោះ ការចម្រើនធម៌ដែលជាលោកិយ ឈ្មោះថា* **លោកិយ ។** *សូម្បីលោកពោលដោយវោហារថា ការចម្រើនធម៌ក៏ពិត តែក៏ មិនមានការចម្រើន ញែកចេញចាកធម៌ទាំងនោះ ព្រោះធម៌ទាំងនោះឯងដែល ចម្រើន ហៅថា ភាវនា ។ ឈ្មោះថា* **ឧត្តរ** *ព្រោះអត្ថថា ធ្វងផុត ។ ឈ្មោះ ថា* **លោកុត្តរ** *ព្រោះអត្ថថា ធ្វងចាកលោកដោយការមិនទាក់ទងក្នុងលោក ។*

*ឈ្មោះថា* **រូបាវចរ** *ព្រោះអត្ថថា ត្រាច់ទៅក្នុងរូប ពោល គឺរូបភព ។*

**កុសល** *សព្ទ ក្នុងបទថា* **រូបាវចរកុសលានំ** *នេះ រមែងប្រាកដក្នុងការ មិនមានរោគ មិនមានទោស ឈ្លាស និងសុខវិបាក ។ ប្រាកដក្នុងការមិនមាន រោគ ដូចក្នុងប្រយោគជាដើមថា* **កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ** *ព្រះអង្គមានសេចក្ដីសុខស្រួលទេឬ ព្រះអង្គមិនមានជំងឺតម្កាត់ទេ*

ឬ ដូច្នេះ ។

ប្រាកដក្នុងការមិនមានទោស ដូចក្នុងប្រយោគជាដើមថា **កតមោ បន ភន្តេ កាយសមាចារោ កុសលោ យោ ខោ មហារាជ កាយសមាចារោ អនវជ្ជោ** បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារជាកុសល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមិនមានទោស ដូច្នេះ ។ ឬ **បុន ចបរំ ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ កុសលេសុ ធម្មេសុ** បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងកុសលធម៌ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ដូច្នេះ ។

ប្រាកដក្នុងការឈ្លាស ដូចក្នុងប្រយោគជាដើមថា **តំ កឹ មញ្ញសិ រាជកុមារ កុសលោ ត្វំ រថស្ស អង្គបច្ចង្គានំ** ម្នាលរាជកុមារ តើទ្រង់សម្គាល់ហេតុនោះដូចម្តេច ទ្រង់ជាបុគ្គលឈ្លាសក្នុងអវយវៈតូចធំទាំងឡាយនៃរថដែរឬទេ ដូច្នេះ ។ ឬ **កុសលា នច្ចគីតស្ស សិក្ខិតា ចាតុរិត្ថិយោ** ស្ត្រីបួនជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង បានសិក្សា ( ក្នុងកិច្ចស្ត្រី ) ដូច្នេះ ។

ប្រាកដក្នុងសុខវិបាក ដូចក្នុងប្រយោគជាដើមថា **កុសលានំ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ** បុណ្យនេះ រមែងចម្រើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ យ៉ាងនេះ ដូច្នេះ ។ ឬ **កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា** ព្រោះហេតុបានធ្វើ បានសន្សំ ដូច្នេះ ។ **កុសល** សព្ទ ក្នុងទីនេះ រមែងសមគួរក្នុងការមិនមានរោគ ក្នុងការមិនមានទោស និងក្នុង

សុខវិបាក ។ ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយដូចតទៅនេះ ឈ្មោះថា កុសល ព្រោះអត្ថថា រមែងអគ្រូន រមែងធ្វើឲ្យញាប់ញ័រ រមែងធ្វើឲ្យរញ្ជួយ រមែងកម្ចាត់ធម៌ ដ៏លាមកគួរខ្ពើម ។ ម្យ៉ាងទៀត បាបធម៌ ឈ្មោះថា **កុស** ព្រោះអត្ថថា រមែងដេក គឺរមែងប្រព្រឹត្តទៅដោយអាការដែលគួរខ្ពើម ។ ឈ្មោះថា **កុសល** ព្រោះអត្ថថា បំផ្លាញនូវកុសៈ ពោល គឺអកុសលទាំងនោះ ម្យ៉ាងទៀត ញាណ ឈ្មោះថា **កុស** ព្រោះកាត់នូវវត្ថុគួរខ្ពើម ធ្វើឲ្យតិចចុះ ។ ឈ្មោះថា **កុសល** ព្រោះអត្ថថា គប្បីកាត់ គប្បីចាប់ គឺគប្បីឲ្យប្រព្រឹត្តទៅដោយកុសៈ ( ញាណ ) នោះ ។ ម្យ៉ាងទៀត កុសលទាំងនេះ រមែងកាត់នូវធម៌ដែលជាចំណែកសៅហ្មង ដែលដល់នូវចំណែកទាំងពីរ ដោយភាវៈដែលកើត និងមិនទាន់កើត ដូចស្បូវក្លាំងលះ ( មុត ) នូវដៃទាំងពីរខាង ព្រោះហេតុនោះ ទើបឈ្មោះថា កុសល ព្រោះអត្ថថា កាត់ ដូចស្បូវក្លាំងលះដៃ ។ ការចម្រើនធម៌ដែលជារូបាវចរកុសលទាំងនោះ ។ ឈ្មោះថា **អរូបាវចរ** ព្រោះអត្ថថា ត្រាច់ទៅក្នុងអរូប ពោល គឺអរូបភព ។ ឈ្មោះថា **បរិយាបន្ន** ព្រោះអត្ថថា ទាក់ទង គឺឈមចុះខាងក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ឈ្មោះថា **អបរិយាបន្ន** ព្រោះអត្ថថា មិនទាក់ទងក្នុងវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ បានដល់ ជាលោកុត្តរ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី ទើបលោកមិនពោលដល់ការចម្រើនធម៌ដែលជាកាមាវចរកុសល ឆ្លើយថា ព្រោះភាវនាដែលដល់លំដាប់អប្បនាប៉ុណ្ណោះ លោកបំណងថាជាភាវនាក្នុងអភិធម្ម ដូចលោកពោលក្នុងអភិធម្ម

( វិភង្គ ) នោះថា

បុគ្គលមិនបានស្តាប់ ( នូវពាក្យពន្យល់ ) អំពីសម្នាក់បុគ្គលដទៃទេ តែបាននូវសេចក្តីគាប់ចិត្ត នូវសេចក្តីយល់ឃើញ នូវសេចក្តីពេញចិត្ត នូវការឈ្វេងយល់ នូវសេចក្តីពិនិត្យឃើញ នូវការចូលចិត្តក្នុងការសម្លឹងមើលនូវធម៌ ដ៏សមគួរណាយ៉ាងនេះ ក្នុងការងារប្រកបដោយឧបាយបញ្ញាក្តី ក្នុងសិល្បសាស្ត្រប្រកបដោយឧបាយបញ្ញាក្តី ក្នុងវិជ្ជាស្ថានប្រកបដោយឧបាយបញ្ញាក្តី ថាសត្វមានកម្មជារបស់ខ្លួនក្តី ថាសត្វប្រព្រឹត្តទៅតាមមគ្គសច្ចក្តី ថារូបមិនទៀងក្តី ថាវេទនាមិនទៀងក្តី ថាសញ្ញាមិនទៀងក្តី ថាសង្ខារទាំងឡាយមិនទៀងក្តី ថាវិញ្ញាណមិនទៀងក្តី នេះហៅថា ចិន្តាមយប្បញ្ញា ។ បុគ្គលបានស្តាប់ ( នូវពាក្យពន្យល់ ) អំពីសម្នាក់នៃបុគ្គលដទៃ ហើយបាននូវសេចក្តីគាប់ចិត្ត នូវសេចក្តីយល់ឃើញ នូវសេចក្តីពេញចិត្ត នូវការឈ្វេងយល់ នូវសេចក្តីពិនិត្យឃើញ នូវការចូលចិត្តក្នុងការសម្លឹងមើលនូវធម៌ដ៏សមគួរយ៉ាងនេះ ក្នុងការងារប្រកបដោយឧបាយប្រាជ្ញាក្តី ក្នុងសិល្បសាស្ត្រ ប្រកបដោយឧបាយប្រាជ្ញាក្តី ក្នុងវិជ្ជាស្ថានប្រកបដោយឧបាយប្រាជ្ញាក្តី ថាសត្វមានកម្មជារបស់ខ្លួនក្តី ថាសត្វប្រព្រឹត្តទៅតាមមគ្គសច្ចក្តី ថារូបមិនទៀងក្តី ថាវេទនាមិនទៀងក្តី ថាសញ្ញាមិនទៀងក្តី ថាសង្ខារ

ទាំងឡាយមិនទៀងក្តី ថាវិញ្ញាណមិនទៀងក្តី នេះហៅថា សុត-
មយប្បញ្ញា ។ បញ្ញាទាំងអស់របស់បុគ្គល ចូលកាន់សមាបត្តិ
ឈ្មោះថា ភាវនាមយប្បញ្ញា(១) ដូច្នេះ ។

ចំណែកកាមាវចរភាវនានោះ គប្បីជ្រាបថា លោកមិនហៅថា ភាវនា ព្រោះភាវនា វៀរចាកអាវជ្ជនៈ និងការធ្លាក់ចុះកាន់កវង្គ ។

ភាពដែលឧបចារសមាធិនិងវិបស្សនាសមាធិជាបុណ្យសម្រេចដោយភា-វនាជាការសម្រេចហើយ ព្រោះបុណ្យទាំងអស់ឈមចុះក្នុងបុញ្ញកិរិយាវត្ថុ ៣ តែក្នុងទីនេះលោកសង្គ្រោះភាវនា ចូលក្នុងលោកិយភាវនានោះឯង ។

គប្បីជ្រាបវិនិច្ឆ័យនូវរូបាវចរ និងអរូបាវចរមាន ៣ យ៉ាង ដូចតទៅនេះ បទថា **ហីនា** គឺជាចំណែកលាមក ។ ភាវនា មានក្នុងចំណែកកណ្តាលនៃធម៌ថោកទាប និងធម៌ខ្ពង់ខ្ពស់ ឈ្មោះថា **មជ្ឈា** បាឋៈថា **មជ្ឈិមា** ក៏មាន ។ ឈ្មោះថា **បណីតា** អធិប្បាយថា ឧត្តម ព្រោះអត្ថថា នាំទៅកាន់ភាពជាប្រធាន ។

គប្បីជ្រាបភាពដែលភាវនា ជាចំណែកថោកទាប កណ្តាល និងប្រណីត ដោយអំណាចការប្រមូលមក ព្រោះថា ក្នុងខណៈប្រមូលមកនៃភាវនាណា ឆន្ទៈ វិរិយៈ ចិត្តៈ វីមំសា ជាធម៌ថោកថយ ភាវនានោះ ឈ្មោះថា ជាចំណែកថោកថយ ក្នុងខណៈប្រមូលមកនៃភាវនាណា ធម៌ទាំងនោះ ជាធម៌កណ្តាល

---

១- ពុទ្ធដីកានេះ ក្នុងអដ្ឋកថា លោកលើកយកមកដោយសង្ខេប តែក្នុងទីនេះ យើងលើកយកមកទាំងស្រុង ដ្បិតមិនអាចកាត់បាន ព្រោះនាំឲ្យខូចសេចក្តី ។

ភាវនានោះ ឈ្មោះថា ជាចំណែកកណ្តាល ។ ក្នុងខណៈប្រមូលមកនៃភាវនាណា ធម៌ទាំងនោះជាធម៌ប្រណីត ភាវនានោះ ឈ្មោះថា ជាចំណែកប្រណីត ។ ម្យ៉ាងទៀត ភាវនាដែលសម្បយុត្តដោយឥន្ទ្រិយទន់ខ្សោយ ឈ្មោះថា ជាចំណែកថោកថយ ។ ភាវនាដែលសម្បយុត្តដោយឥន្ទ្រិយជាកណ្តាល ឈ្មោះថា ជាចំណែកកណ្តាល ។ ភាវនាដែលសម្បយុត្តដោយឥន្ទ្រិយ មានប្រមាណក្រៃលែង ឈ្មោះថា ជាចំណែកប្រណីត ។ លោកពោលភាពដែលភាវនាមិនទាក់ទងក្នុងវដ្តៈ ជាចំណែកប្រណីតប៉ុណ្ណោះ ព្រោះភាវនាមិនជាប់ទាក់ទងក្នុងវដ្តៈ មិនមានចំណែកថោកថយ និងចំណែកជាកណ្តាល ។ ភាវនានោះ ឈ្មោះថា ជាចំណែកប្រណីត ដោយអត្ថថា ឧត្តម និងដោយអត្ថថា មិនក្តៅក្រហាយ ។

ក្នុងបឋមភាវនាចតុក្កៈ មានវិនិច្ឆ័យដូចតទៅនេះ

បទថា **ភាវេតិ** បានដល់ ព្រះយោគាវចរកាលចាក់ធ្លុះយ៉ាងនោះៗ ក្នុងខណៈមួយប៉ុណ្ណោះ ឈ្មោះថា រមែងចម្រើនអរិយមគ្គ ។

[ ៦៩ ] ក្នុងទុតិយភាវនាចតុក្កៈ មានវិនិច្ឆ័យដូចតទៅ

បទថា **ឯសនាភាវនា** បានដល់ ភាវនាក្នុងចំណែកខាងដើមរបស់អប្បនា ។ ភាវនានោះ លោកពោលថា **ឯសនា** ព្រោះជាហេតុស្វែងរកអប្បនា ។

បទថា **បដិលាភភាវនា** បានដល់ អប្បនាភាវនា ។ ភាវនានោះ លោកពោលថា **បដិលាភ** ព្រោះបានដោយការស្វែងរកនោះ ។

បទថា **ឯករសាភាវនា** បានដល់ ភាវនាក្នុងវេលាប្រកបសេចក្តីព្យាយាមរបស់អ្នកប្រាថ្នានឹងសម្រេចភាពជាអ្នកជំនាញ ក្នុងការបានចំពោះ ។ ភាវនា

នោះ លោកពោលថា **ឯករសា** ព្រោះអត្ថថា មានរសតែមួយ គឺវិមុត្តិរស ព្រោះផុតចាកកិលេសនោះៗ ដោយបហាននោះៗ ។

បទថា **អាសេវនាភាវនា** បានដល់ ភាវនាក្នុងវេលាបរិភោគតាមគាប់ចិត្ត របស់បុគ្គលដែលសម្រេចនូវការជំនាញក្នុងការបានចំពោះ ។ ភាវនានោះ លោកពោលថា អាសេវនា ព្រោះអត្ថថា សេពច្រើន ។ តែអាចារ្យពួកខ្លះពណ៌នាថា អាសេវនាភាវនាជាវសីកម្ម ។ ឯករសាភាវនា មានប្រយោជន៍ក្នុងទីទាំងពួង ។

គប្បីជ្រាបសេចក្ដីក្នុងចតុក្កវិភាគដូចតទៅនេះ បទថា **សមាធឹ សមាបជ្ជន្តានំ** ជាពាក្យបច្ចុប្បន្នជិតបច្ចុប្បន្ន ។

បទថា **តត្ថ ជាតា** បានដល់ ដែលកើតក្នុងធម៌ដែលជាចំណែកខាងដើមនោះ ។ បទថា **ឯករសា ហោន្តិ** បានដល់ ជាធម៌មានកិច្ចស្មើគ្នា ក្នុងការកើតឡើងនៃអប្បនា ។ បទថា **សមាធឹ សមាបន្នានំ** បានដល់ មានអប្បនាចុះស៊ប់ហើយ ។

បទថា **តត្ថ ជាតា** បានដល់ ដែលកើតក្នុងអប្បនានោះ ។

បទថា **អញ្ញមញ្ញំ នាតិវត្តន្តិ** បានដល់ មិនឈានកន្លងគ្នានិងគ្នាដោយប្រព្រឹត្តទៅស្មើគ្នា ។

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ ភាវយតោ** ជាដើម ដូចតទៅនេះថា ឥន្ទ្រិយដ៏សេស មានកិច្ចរៀងៗ ខ្លួនជាហេតុដោយអាស្រ័យឥន្ទ្រិយនោះៗ ក្នុងការធ្វើកិច្ចរៀងៗ ខ្លួននៃឥន្ទ្រិយនីមួយៗ សូម្បី

ក្នុងខណៈជាមួយគ្នា ទើបមានរសដូចគ្នាដោយវិមុត្តិរស ព្រោះហេតុនោះ ទើបឈ្មោះថា ភាវនា ព្រោះអត្ថថា មានរសតែមួយដោយវិមុត្តិរសនោះឯង ។ សូម្បីក្នុងពល ពោជ្ឈង្គ និងអង្គមគ្គ ក៏មានន័យនេះដូចគ្នា ។ មួយទៀត បទថា **ឯករសា** ជាលិង្គវិបល្លាស ។

[ ៧១ ] បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ឃើញភ័យក្នុងសង្សារ ។ ក្នុងបទថា **បុព្វណ្ហសមយំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃអច្ចន្តសំយោគ តែដោយអត្ថ ជាសត្តមីវិភត្តិ អធិប្បាយថា ក្នុងកាលមុននៃថ្ងៃ គឺពេលព្រឹក ។ បទថា **អាសេវតិ** បានដល់ សេពច្រើននូវសមាធិដែលដល់នូវភាពជំនាញ ។

បទថា **មជ្ឈន្តិកសមយំ** បានដល់ ក្នុងវេលាកណ្តាលនៃថ្ងៃ ។

បទថា **សាយណ្ហសមយំ** បានដល់ ក្នុងវេលាល្ងាចនៃថ្ងៃ ។

បទថា **បុរេភត្តំ** បានដល់ ក្នុងវេលាមុននៃភត្ត ។

បទថា **បច្ឆាភត្តំ** បានដល់ ក្នុងវេលាក្រោយនៃភត្ត ។

បទថា **បុរិមេបិ យាមេ** បានដល់ ក្នុងចំណែកខាងដើមរាត្រី ។

បទថា **កាឡេ** បានដល់ ក្នុងកាឡបក្ខ ។

បទថា **ជុណ្ហេ** បានដល់ ក្នុងសុក្កបក្ខ ។

បទថា **បុរិមេបិ វយោខន្ធេ** បានដល់ ក្នុងចំណែកវ័យដំបូង គឺបឋមវ័យ ។ មួយទៀត ក្នុង ៣ វ័យ មនុស្សមានអាយុ ១០០ ឆ្នាំ ក្នុងវ័យនីមួយៗ មានអាយុ ៣៣ ឆ្នាំ ៤ ខែ ។

[ ៧២-៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយភាវនាចតុក្កៈដូចតទៅ

បទថា **តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន** បានដល់ ដោយការមិនឈានកន្លងនូវគ្នានិងគ្នានៃយុគលធម៌ ពោល គឺសមាធិ និងបញ្ញាដែលកើតឡើងក្នុងភាវនាវិសេស មានទេក្ខម្មៈជាដើមនោះ ។

បទថា **ឥន្ទ្រិយានំ ឯករសដ្ឋេន** បានដល់ ដោយភាពដែលឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើម ក្នុងភាវនាវិសេសនោះ មានរសតែមួយ ដោយវិមុត្តិរស ព្រោះផុតចាកកិលេសផ្សេងៗ ។

បទថា **តទុបគវីរិយវាហនដ្ឋេន** បានដល់ ដោយការនាំទៅនូវសេចក្តីព្យាយាមដ៏សមគួរដល់ភាពដែលធម៌នោះ មានរសតែមួយមិនឈានកន្លងគ្នា ។

បទថា **អាសេវនដ្ឋេន** បានដល់ ដោយការសេពដ៏ច្រើននៃការសេពដែលប្រព្រឹត្តទៅក្នុងសម័យនោះ របស់ព្រះយោគាវចរនោះ ។

បទថា **រូបសញ្ញំ** បានដល់ រូបសញ្ញា ពោល គឺរូបាវចរជ្ឈាន ១៥ ដោយអំណាចកុសលវិបាកកិរិយា ។ សូម្បីរូបាវចរជ្ឈាន លោកក៏ហៅថា រូប ដូចបាលីថា **រូបី រូបានិ បស្សតិ** បុគ្គលមានរូបជ្ឈានតែងឃើញរូប ដូច្នេះជាដើម ។ សូម្បីអារម្មណ៍នៃឈាននោះ លោកក៏ហៅថា រូប ដូចក្នុងប្រយោគជាដើមថា **ពហិទ្ធា រូបានិ បស្សតិ សុវណ្ណទុព្វណ្ណានិ** ឃើញនូវពួករូបខាងក្រៅ ( គ្របសង្កត់នូវរូបទាំងនោះ ) ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ ដូច្នេះ ។ រូបាវចរជ្ឈានហៅថា រូបសញ្ញា ព្រោះអត្ថថា សញ្ញាក្នុងរូប ដោយមាតិកាថា សញ្ញា ។

បទថា **បដិឃសញ្ញំ** បានដល់ បដិឃសញ្ញា ១០ យ៉ាង គឺកុសលវិបាក

៥ អកុសលវិបាក ៥ ។ សញ្ញាសម្បយុត្តដោយទ្វិបញ្ចវិញ្ញាណ លោកហៅថា បដិឃសញ្ញា ព្រោះវត្ថុ មានចក្ខុជាដើម និងអារម្មណ៍ មានរូបជាដើម កើតឡើងដោយការប៉ះខ្ទប់គ្នា ។ សូម្បីពាក្យថា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ក៏ជាឈ្មោះបដិឃសញ្ញាទាំងអស់ ។

បទថា **នានត្តសញ្ញំ** បានដល់ នានត្តសញ្ញា ៤៤ យ៉ាង យ៉ាងនេះ គឺ កាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១ ។ សញ្ញានោះ ជាសញ្ញាប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូប និងសំឡេងជាដើមដែលមានការផ្សេងគ្នា គឺមានសភាពផ្សេងគ្នា ព្រោះហេតុនោះ ទើបហៅថា នានត្តសញ្ញា ។ ម្យ៉ាងទៀត សញ្ញាដែលមានការផ្សេងគ្នា មានសភាពផ្សេងគ្នា គឺមិនដូចគ្នានិងគ្នា ដោយប្រភេទ ៤៤ យ៉ាង ព្រោះហេតុនោះ ទើបហៅថា ជានានត្តសញ្ញា ។ សូម្បីសញ្ញាមានច្រើន លោកក៏ធ្វើឲ្យជាឯកវចនៈ ដោយកាន់យក **ជាតិ** ។

បទថា **និច្ចសញ្ញំ** បានដល់ សញ្ញាថា ជារបស់ទៀង ឈ្មោះថា និច្ចសញ្ញា ។ សុខសញ្ញា និងអត្តសញ្ញា ក៏យ៉ាងនោះ ។ បទថា **នន្ទឹ** បានដល់ តណ្ហា ដែលមានបីតិ ។ បទថា **រាគំ** បានដល់ តណ្ហា ដែលមិនមានបីតិ ។ បទថា **សមុទយំ** បានដល់ ហេតុកើតរាគៈ ។ ម្យ៉ាងទៀត ការកើតនៃសង្ខារទាំងឡាយ ព្រោះឃើញការរលត់ដោយកង្ខានុបស្សនាញាណនោះឯង ។

បទថា **អាទានំ** បានដល់ ប្រកាន់មាំដោយកិលេស ដោយអំណាចការកើត ឬប្រកាន់មាំក្នុងអារម្មណ៍ដែលជាសង្ខតៈ ព្រោះមិនឃើញទោស ។

បទថា **ឃនសញ្ញំ** បានដល់ សញ្ញាសម្គាល់ថាជាដុំដោយអំណាចសន្តតិ ។

បទថា **អាយូហានំ** បានដល់ ការធ្វើសេចក្តីព្យាយាមដើម្បីប្រយោជន៍ដល់សង្ខារ ។

បទថា **ធុវសញ្ញំ** បានដល់ សញ្ញាថា មាំមួន ។

បទថា **និមិត្តំ** បានដល់ គ្រឿងសម្គាល់ថា ទៀង ។

បទថា **បណិធឹ** បានដល់ ប្រាថ្នាសេចក្តីសុខ ។

បទថា **អភិនិវេសំ** បានដល់ ការប្រកាន់មាំថា ខ្លួនមាន ។

បទថា **សារាទានាភិនិវេសំ** បានដល់ ការប្រកាន់មាំ ដោយការប្រកាន់ថា ជានិច្ចសារៈ អត្តសារៈ ។

បទថា **សម្មោហាភិនិវេសំ** បានដល់ ការប្រកាន់មាំ ដោយការវង្វេងមានពាក្យ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា អាត្មាអញ បានកើតហើយក្នុងអតីតកាល ដូច្នេះជាដើម និងដោយពាក្យថា សត្វលោក កើតអំពីព្រះឥស្សរជាដើម ។

បទថា **អាលយាភិនិវេសំ** បានដល់ ការប្រកាន់មាំ ព្រោះមិនទាន់ឃើញទោសថា នេះគួរប្រកាន់ឲ្យខ្ជាប់ ។

បទថា **អប្បដិសង្ខំ** បានដល់ ការប្រកាន់មាំដោយមិនមែនឧបាយ ។ បទថា **សញ្ញោគាភិនិវេសំ** បានដល់ ការប្រព្រឹត្តទៅនៃកិលេស មានកាមយោគៈជាដើម ។

បទថា **ឱជ្ជកាជ្ជ** មានវិគ្គហៈថា ឈ្មោះថា **ឱជ្ជកាជ្ជ** ព្រោះអត្ថថា តាំង

នៅក្នុងទីតែមួយជាមួយទិដ្ឋិ ។ នូវកិលេសដែលតាំងនៅរួមគ្នា ជាមួយទិដ្ឋិទាំងនោះ ។

ឈ្មោះថា កិលេស ព្រោះអត្ថថា ធ្វើឲ្យសៅហ្មង ធ្វើឲ្យក្តៅក្រហាយ ឬធ្វើឲ្យលំបាក ។ នូវកិលេសទាំងនោះ ។ កិលេសដែលតាំងនៅក្នុងទីជាមួយគ្នា មាន ២ យ៉ាង គឺតាំងនៅក្នុងទីជាមួយគ្នាដោយការលះ ១ តាំងនៅក្នុងទីជាមួយគ្នាដោយការកើតរួមគ្នា ១ ។ ឈ្មោះថា តាំងនៅក្នុងទីជាមួយគ្នាដោយការលះ មានអធិប្បាយថា កិលេសទាំងឡាយ មួយអន្លើដោយទិដ្ឋិ ៦៣ ដែលមានសក្កាយទិដ្ឋិជាប្រធាន តាំងនៅក្នុងបុគ្គលម្នាក់ ទម្រាំលះបានដោយសោតាបត្តិមគ្គ ។ បទនេះ លោកបំណងយកក្នុងទីនេះ ។ កិលេស ១០ យ៉ាង ក្នុងទីនេះ សំដៅដល់កិលេស គឺទិដ្ឋិប៉ុណ្ណោះ ។ ក៏ក្នុងកិលេសដ៏សេស កិលេស ៩ យ៉ាង គឺលោភៈ ១ ទោសៈ ១ មោហៈ ១ មានះ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១ អនោត្តប្បៈ ១ ជាកិលេសធ្វើសត្វឲ្យទៅកាន់អបាយ តាំងនៅក្នុងទីជាមួយគ្នានឹងទិដ្ឋិ រមែងលះបានដោយសោតបត្តិមគ្គ ម្យ៉ាងទៀត បណ្តាកិលេស ១៥០០ មានរាគៈ ទោសៈ មោហៈ ជាប្រធាន កាលបើលះទិដ្ឋិបានដោយសោតាបត្តិមគ្គ កិលេសទាំងអស់ដែលធ្វើសត្វឲ្យទៅកាន់អបាយព្រមជាមួយនឹងទិដ្ឋិ រមែងលះបានដោយការតាំងនៅក្នុងទីជាមួយគ្នា ដោយការលះក្នុងកិលេសដែលតាំងនៅក្នុងទីជាមួយគ្នា ដោយកើតរួមគ្នា មានអធិប្បាយថា កិលេសទាំងឡាយ មួយអន្លើដោយទិដ្ឋិតាំងនៅក្នុងចិត្តដួងតែមួយ ។ កាលលះចិត្តដែលសម្បយុត្តដោយទិដ្ឋិ ជាអសង្ខារិកៈ ២ ដោយសោតាបត្តិមគ្គបាន

កិលេសទាំងនេះ គឺលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលកើតរួមជាមួយចិត្តទាំងនោះ រមែងលះបានដោយអំណាចកិលេសដែលតាំងនៅក្នុងទីជាមួយគ្នា ដោយកើតរួមគ្នា កាលលះចិត្តដែលសម្បយុត្តដោយទិដ្ឋិ ជាសសង្ខារិកៈ ២ យ៉ាងបាន កិលេសទាំងនេះ គឺលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលកើតរួមគ្នាជាមួយចិត្តទាំងនោះ រមែងលះបានដោយអំណាចកិលេសដែលតាំងនៅក្នុងទីជាមួយគ្នា ដោយកើតរួមគ្នា ។

បទថា **ឱឡារិកេ កិលេសេ** បានដល់ កាមរាគៈ និងព្យាបាទ ដែលជាកិលេសគ្រោតគ្រាត ។

បទថា **អនុសហគតេ កិលេសេ** បានដល់ កាមរាគៈ និងព្យាបាទដែលជាកិលេសយ៉ាងល្អិត ។

បទថា **សព្វក្កិលេស** បានដល់ កិលេសដ៏សេស ដែលទីងលះបានដោយមគ្គ ៣ ។

បទថា **វីរិយំ វាហេតិ** សេចក្តីថា ព្រះយោគាវចរធ្វើសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅ ។ លោកពោលដល់ឯសនាភាវនា បដិលាភាភាវនា ឯករសាភាវនា អាសេវនាភាវនាក្នុងខាងដើម ដើម្បីសម្តែងដល់ការផ្សេងគ្នានៃភាវនាទាំងឡាយថា ភាវនាជាយ៉ាងនេះ ។ លោកពោលពាក្យទាំងឡាយថា ឈ្មោះថា ភាវនា ដោយអត្ថថា ធម៌ទាំងឡាយដែលកើតក្នុងភាវនានោះ មិនកន្លងគ្នានិងគ្នា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ដោយអត្ថថា នាំទៅនូវសេចក្តីព្យាយាមដែលសមគួរដល់ធម៌នោះ ដោយអត្ថថា សេពយ៉ាងច្រើន

ដើម្បីសម្តែងហេតុនៃភាវនាថា ឈ្មោះថា ភាវនា ដោយហេតុនេះ និង ដោយហេតុនេះ លោកពោលដោយអំណាចខណៈផ្សេងៗ គ្នាខាងដើមថា អាសេវនាភាវនា ក្នុងទីនេះ លោកពោលដោយអំណាចខណៈជាមួយគ្នាថា ឈ្មោះថា ភាវនា ដោយអត្ថថា សេពយ៉ាងច្រើន ព្រោះហេតុនោះ ទើបមាន សេចក្តីផ្សេងគ្នា ។

បទថា **រូបំ បស្សន្តោ ភាវេតិ** មានអធិប្បាយថា ព្រះយោគាវចរ កាលពិចារណាឃើញរូបជាដើម ដោយអាការដែលគួរឃើញឲ្យ ឈ្មោះថា រមែងចម្រើនភាវនាដែលគួរចម្រើន ។

បទថា **ឯករសា ហោន្តិ** បានដល់ មានរូបតែមួយ ដោយវិមុត្តិរស ឬ ដោយរសដែលជាកិច្ច ។ ពាក្យថា វិមុត្តិរស បានដល់ សម្បត្តិរស ។ លោក ពោលថា ហៅថា រស ដោយអត្ថថា ដល់ព្រមដោយកិច្ច ដូច្នេះ ៕

**អដ្ឋកថាភាវនាញាណនិទ្ទេស ចប់**

**ចតុត្ថភាណវារៈ ចប់**

# សុត្តន្តបិដក

[ ៧៧ ] ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ធម៌ ១ ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ គឺចេតោវិមុត្តិដ៏មិនកម្រើក ធម៌ ២ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺវិជ្ជា ១ វិមុត្តិ ១ ធម៌ ៣ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺវិជ្ជា ៣ ធម៌ ៤ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺសាមញ្ញផល ៤ ធម៌ ៥ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺធម្មក្ខន្ធ ៥ ធម៌ ៦ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺអភិញ្ញា ៦ ធម៌ ៧ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺខីណាសវពល ៧ ធម៌ ៨ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺវិមោក្ខ ៨ ធម៌ ៩ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺអនុបុព្វនិរោធ ៩ ធម៌ ១០ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺអសេក្ខធម៌ ១០ ។

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួង ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ រូបត្រូវធ្វើឲ្យជាក់ច្បាស់ ចក្ខុវិញ្ញាណត្រូវធ្វើឲ្យជាក់ច្បាស់ ចក្ខុសម្ផស្សត្រូវធ្វើឲ្យជាក់ច្បាស់ ការទទួលអារម្មណ៍ណាទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី រមែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯងបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ សោតៈត្រូវធ្វើឲ្យជាក់ច្បាស់ សទ្ទៈត្រូវធ្វើឲ្យជាក់ច្បាស់ ។បេ។ ឃានៈត្រូវធ្វើឲ្យជាក់ច្បាស់ គន្ធៈត្រូវធ្វើឲ្យជាក់ច្បាស់ ជិវ្ហាត្រូវធ្វើឲ្យជាក់ច្បាស់ រសៈត្រូវធ្វើឲ្យជាក់ច្បាស់ កាយត្រូវធ្វើឲ្យជាក់ច្បាស់

ផោដ្ឋព្វៈត្រូវធ្វើឲ្យជាក់ច្បាស់ មនៈត្រូវធ្វើឲ្យជាក់ច្បាស់ ធម្មារម្មណ៍ត្រូវធ្វើឲ្យជាក់ច្បាស់ មនោវិញ្ញាណត្រូវធ្វើឲ្យជាក់ច្បាស់ មនោសម្ផស្សត្រូវធ្វើឲ្យជាក់ច្បាស់ ការទទួលអារម្មណ៍ណាទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី រមែងកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯងត្រូវធ្វើឲ្យជាក់ច្បាស់ ។

បុគ្គលកាលឃើញរូប រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញវេទនារមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញសញ្ញា រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញសង្ខារទាំងឡាយ រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញវិញ្ញាណ រមែងធ្វើឲ្យជាក់ច្បាស់ ចក្ខុ ។បេ។ ជរា និងមរណៈ កាលឃើញព្រះនិព្វានដែលឈ្មោះអមតៈ ជាទីពឹងរបស់សត្វ ដោយអត្ថថា ចប់ស្រេច ( នៃសាសនា ) រមែងធ្វើឲ្យជាក់ច្បាស់ ធម៌ទាំងឡាយណាៗ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយ ធម៌ទាំងឡាយនោះៗ ឈ្មោះថា បុគ្គលពាល់ត្រូវហើយ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ បញ្ញាជាគ្រឿងដឹងច្បាស់ នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ គប់រកនូវសេចក្តីសាបសូន្យ ធម៌ទាំងឡាយនេះ គប់រកនូវការស្ថិតនៅ ធម៌ទាំងឡាយនេះ គប់រកនូវគុណវិសេស ធម៌ទាំងឡាយនេះ គប់រកនូវការទម្លុះទម្លាយកិលេស បញ្ញាជាគ្រឿងដឹងច្បាស់

នូវការប្រែងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្ដេច សញ្ញា និង មនសិការ ដែលប្រកបដោយកាម របស់បុគ្គលអ្នកបាននូវបឋមជ្ឈាន រមែង ប្រព្រឹត្តទៅ នេះឈ្មោះថា ធម៌គប់រកនូវសេចក្ដីសាបសូន្យ សតិដ៏សមគួរ ដល់ឈាននោះតាំងនៅដដែល នេះឈ្មោះថា ធម៌គប់រកនូវការតាំងនៅដដែល សញ្ញា និងមនសិការដែលប្រកបដោយឈាន មិនមានវិតក្ក រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និងមនសិការ ដែលប្រកប ដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស សញ្ញា និងមនសិការដែលប្រកប ដោយវិតក្ក របស់បុគ្គលអ្នកបានទុតិយជ្ឈាន រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌ គប់រកនូវសេចក្ដីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថា ធម៌គប់រកនូវការតាំងនៅដដែល សញ្ញា និងមនសិការដែលប្រកប ដោយឧបេក្ខា និងសុខ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និងមនសិការ ដែលប្រកបដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស សញ្ញា និងមនសិការដែលប្រកបដោយបីតិ និងសុខ របស់បុគ្គលអ្នកបានតតិ-យជ្ឈាន រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវសេចក្ដីសោះសូន្យ សតិដ៏ សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថា ធម៌គប់រកនូវការតាំង នៅដដែល សញ្ញា និងមនសិការដែលប្រកបដោយអទុក្ខមសុខ គឺឧបេក្ខា-វេទនា រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និង

មនសិការដែលប្រឡំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយ-មគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស សញ្ញា និងមនសិការដែលប្រឡំដោយឧបេក្ខា និងសុខ របស់បុគ្គលអ្នកបាននូវចតុត្ថ-ជ្ឈាន រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថា ធម៌គប់រកនូវការតាំងនៅដដែល សញ្ញា និងមនសិការដែលប្រឡំដោយអាកាសានញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និងមនសិការដែលប្រឡំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស សញ្ញា និងមនសិការ ដែលប្រឡំដោយរូប របស់បុគ្គលអ្នកបាននូវអាកាសានញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថា ធម៌គប់រកនូវការតាំងនៅដដែល សញ្ញា និងមនសិការដែលប្រឡំដោយវិញ្ញាណញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និងមនសិការដែលប្រឡំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស សញ្ញា និងមនសិការដែលប្រឡំដោយអាកាសានញ្ចាយតនៈ របស់បុគ្គលអ្នកបានវិញ្ញាណញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថា ធម៌គប់រកនូវការតាំងនៅដដែល សញ្ញា និងមនសិការដែលប្រឡំដោយអាកិញ្ច-

ញ្ញាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និង មនសិការដែលប្រឡំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស សញ្ញា និង មនសិការដែលប្រឡំដោយវិញ្ញាណញ្ចាយតនៈ របស់បុគ្គលអ្នកបានអាកិញ្ច-ញ្ញាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថា ធម៌គប់រកនូវការតាំងនៅ សញ្ញា និងមនសិការដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវគុណវិសេស សញ្ញា និងមនសិការដែលប្រឡំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថា ធម៌គប់រកនូវការទម្លាយកិលេស ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ គប់រកនូវសេចក្តីសាបសូន្យ ធម៌ទាំងឡាយនេះ គប់រកនូវការតាំងនៅដដែល ធម៌ទាំងឡាយនេះ គប់រកនូវគុណវិសេស ធម៌ទាំងឡាយនេះ គប់រកនូវការទម្លាយកិលេស បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

# អដ្ឋកថា

## សច្ចិកាតព្វនិទ្ទេស

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ចិកាតព្វនិទ្ទេសដូចតទៅ

ព្រះសារីបុត្តត្ថេរ ពោលវិសជ្ជនាឯកុត្តរធម៌ ១០ ប្រការ ដោយការធ្វើឲ្យជាក់ច្បាស់ដល់ការបានចំពោះ ។

ក្នុងបទទាំងនោះ បទថា **អកុប្បា ចេតោវិមុត្តិ** បានដល់ អរហត្តផលវិមុត្តិ ។ ចេតោវិមុត្តិនោះ ឈ្មោះថា **អកុប្បា** ព្រោះអត្ថថា មិនកម្រើក មិនញាប់ញ័រ មិនឲ្យវិនាស លោកពោលថា **ចេតោវិមុត្តិ** ព្រោះចិត្តផុតវិសេសចាកកិលេសទាំងពួង ។

បទថា **វិជ្ជា** បានដល់ វិជ្ជា ៣ ។ បទថា **វិមុត្តិ** លោកពោលដល់អរហត្តផលដោយបរិយាយក្នុងទសុត្តរសូត្រ តែលោកពោលដោយបរិយាយក្នុងសង្គីតិសូត្រថា បទថា **វិមុត្តិ** បានដល់ វិមុត្តិ ២ គឺការបង្អោនចិត្តទៅ និងនិព្វាន ។ម្យ៉ាងទៀត ក្នុងវិមុត្តិទាំង ២ នេះ សមាបត្តិ ៨ ឈ្មោះថា **វិមុត្តិ** ព្រោះចិត្តផុតដោយល្អចាកនីវរណៈទាំងឡាយជាដើម និព្វាន ឈ្មោះថា **វិមុត្តិ** ព្រោះផុតចាកសង្ខតធម៌ទាំងពួង ។

បទថា **តិស្សោ វិជ្ជា** បានដល់ វិជ្ជា គឺបុព្វេនិវាសានុស្សតិញ្ញាណ ១ វិជ្ជា គឺចុតូបបាតញ្ញាណ ១ វិជ្ជា គឺអាសវក្ខយញ្ញាណ ១ ។ ឈ្មោះថា **វិជ្ជា** ដោយអត្ថថា ទម្លាយងងឹតបាន ឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើនូវការដឹងឲ្យជាក់ច្បាស់ ពិតហើយ បុព្វេនិវាសានុស្សតិញ្ញាណ ឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា

កាលកើតឡើង រមែងទម្លាយនូវងងឹតដែលបិទបាំងជាតិដែលធ្លាប់នៅក្នុងកាលមុនបាន និងរមែងធ្វើឲ្យដឹងច្បាស់ដល់ជាតិ ដែលធ្លាប់នៅក្នុងកាលមុនបាន ។ ចុតូបបាតញ្ញាណ ឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា ទម្លាយនូវងងឹតដែលបិទបាំងចុតិ និងបដិសន្ធិចេញបាន និងធ្វើឲ្យដឹងច្បាស់ ដល់ចុតិ និងបដិសន្ធិបាន ។ អាសវក្ខយញ្ញាណ ឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា ទម្លាយនូវងងឹត ដែលបិទបាំងអរិយសច្ច ៤ និងធ្វើឲ្យដឹងច្បាស់នូវសច្ចធម៌ ៤ ។

បទថា **ចត្តារិ សាមញ្ញផលានិ** បានដល់ សោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។ ឈ្មោះថា សមណៈ ព្រោះអត្ថថា ធ្វើធម៌លាមកឲ្យស្ងប់ គឺឲ្យវិនាស ភាពជាសមណៈ ឈ្មោះថា សាមញ្ញ ។ សាមញ្ញនេះ ជាឈ្មោះរបស់អរិយមគ្គ ៤ ។ ផលនៃសាមញ្ញ ឈ្មោះថា សាមញ្ញផល ។

បទថា **បញ្ច ធម្មក្ខន្ធា** បានដល់ សីលក្ខន្ធ ១ សមាធិក្ខន្ធ ១ បញ្ញាខន្ធ ១ វិមុត្តិក្ខន្ធ ១ វិមុត្តិញាណទស្សនក្ខន្ធ ១ ។

បទថា **ធម្មក្ខន្ធា** បានដល់ ការចែកធម៌ ចំណែករបស់ធម៌ ។ សូម្បីក្នុងសីលក្ខន្ធជាដើម ក៏មានន័យនេះដូចគ្នា ។ សីល សមាធិ បញ្ញា ទាំងដែលជាលោកិយ និងលោកុត្តរនោះឯង ឈ្មោះថា សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ ។ សមុច្ឆេទវិមុត្តិ បដិប្បស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិនោះឯង ឈ្មោះថា វិមុត្តិក្ខន្ធ ។ ការពិចារណាវិមុត្តិ ៣ យ៉ាងនោះឯង ឈ្មោះថា វិមុត្តិញាណទស្សនក្ខន្ធ ។ វិមុត្តិញាណទស្សនក្ខន្ធ ជាលោកិយប៉ុណ្ណោះ ។ ឈ្មោះថា

ញាណ ដោយអត្ថថា ដឹង ឈ្មោះថា ទស្សនៈ ដោយអត្ថថា ឃើញទស្សនៈ គឺញាណ ព្រោះហេតុនោះ ទើបឈ្មោះថា ញាណទស្សនៈ ញាណទស្សនៈនៃវិមុត្តិទាំងឡាយ ហៅថា វិមុត្តិញាណទស្សនៈ ។ ចំណែកវិក្ខម្ភនវិមុត្តិ និងតទង្គវិមុត្តិ លោកសង្គ្រោះចូលដោយសមាធិក្ខន្ធ និងបញ្ញាខន្ធនោះឯង ។ ធម្មក្ខន្ធទាំង ៥ នេះ សម្រាប់សេក្ខបុគ្គល ហៅថា សេក្ខធម៌ សម្រាប់អសេក្ខបុគ្គល ហៅថា អសេក្ខធម៌ ។ ក្នុងធម្មក្ខន្ធទាំងនេះ ធម្មក្ខន្ធដែលជាលោកិយ និងជានិស្សរណវិមុត្តិ ជានេវសេក្ខានាសេក្ខធម៌ ។ ធម្មក្ខន្ធទាំងនេះ ជាធម៌ដែលនៅសិក្សា ជារបស់សេក្ខបុគ្គលទាំងឡាយ ព្រោះហេតុនោះ ទើបហៅថា សេក្ខធម៌ ធម្មក្ខន្ធទាំងនេះ ជារបស់អសេក្ខបុគ្គលទាំងឡាយ ព្រោះហេតុនោះ ទើបហៅថា អសេក្ខធម៌ ។ ក្នុងសេចក្តីនេះថា ព្រះយោគាវចរ អ្នកប្រកបដោយវិមុត្តិក្ខន្ធដែលជាសេក្ខធម៌ គប្បីជ្រាបថា ព្រះយោគាវចរ ជាអ្នកប្រកបដោយការធ្វើនិស្សរណវិមុត្តិឲ្យជាអារម្មណ៍ ។

បទថា ៨ **អភិញ្ញា** បានដល់ ញាណដ៏ក្រៃលែង ៦ ។ ញាណដ៏ក្រៃលែង ៦ តើដូចម្តេច ញាណទាំង ៦ នេះ គឺឥទ្ធិវិធញាណ ១ ទិព្វសោតធាតុញាណ ១ បុព្វេនិវាសានុស្សតិញាណ ១ ចេតោបរិយញាណ ១ ទិព្វចក្ខុញាណ ១ អាសវក្ខយញាណ ១ ។

បទថា **សត្ត ខីណាសវពលានិ** មានវិគ្គហៈថា ឈ្មោះថា ខីណាស្រវៈ ព្រោះអត្ថថា មានអាសវៈអស់ហើយ កម្លាំងរបស់ព្រះខីណាស្រព ឈ្មោះថា ខីណាសវពល ។ ខីណាសវពល ៧ តើដូចម្តេច ព្រះមានព្រះភាគត្រាស់

( ទីឃនិកាយ បាដិកវគ្គ ) ថា

ម្នាលភិក្ខុទាំងឡាយ[១] សង្ខារទាំងពួងដែលភិក្ខុជាព្រះខីណាស្រព ក្នុងសាសនានេះ បានឃើញថា មិនទៀង តាមសេចក្ដីពិត ដោយបញ្ញាដ៏ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ ក៏សង្ខារទាំងពួង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញថា មិនទៀងតាមសេចក្ដីពិត ដោយបញ្ញាដ៏ប្រពៃ នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្ដេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាមទាំងឡាយ មានឧបមាដូចរណ្ដៅដ៏ពេញដោយរងើកភ្លើង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញតាមសេចក្ដីពិត ដោយបញ្ញាដ៏ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ ក៏កាមទាំងឡាយ មានឧបមាដូចរណ្ដៅដ៏ពេញដោយរងើកភ្លើង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញតាមសេចក្ដីពិត ដោយបញ្ញាដ៏ប្រពៃ នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្ដេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយ

---

១- បិដកខ្មែរជា ម្នាលអាវុសោទាំងឡាយ ។

ទៀត ចិត្តរបស់ភិក្ខុជាព្រះខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ។បេ។ នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សតិប្បដ្ឋាន ៤ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ឥន្ទ្រិយ ៥ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពោជ្ឈង្គទាំង ៧ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលភិក្ខុទាំងឡាយ ក៏មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អនេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញាច្បាស់ នូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញ អស់ហើយ ១ ដូច្នេះ ។

ក្នុងកម្លាំងទាំងនោះ លោកប្រកាសការចាក់ធ្លុះទុក្ខសច្ច ដោយកម្លាំងទី ១

ការចាក់ធ្លុះសមុទយសច្ច ដោយកម្លាំងទី ២ ការចាក់ធ្លុះនិរោធសច្ច ដោយកម្លាំងទី ៣ ការចាក់ធ្លុះមគ្គសច្ចដោយកម្លាំង ៤ យ៉ាងដ៏សេស ។

បទថា **អដ្ឋ វិមោក្ខា** មានវិគ្គហៈថា ឈ្មោះថា វិមោក្ខ ដោយអត្ថថា បង្អោនទៅក្នុងអារម្មណ៍ និងដោយអត្ថថា រួចផុតដោយល្អ ចាកធម៌ជាសត្រូវទាំងឡាយ ។

វិមោក្ខទាំង ៨ នោះ តើដូចម្ដេច ។ គឺបុគ្គលមានរូបជ្ឈានតែងឃើញរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជាវិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្ដីសម្គាល់ ក្នុងរូបខាងក្នុង មានសក់ជាដើម របស់ខ្លួន តែងឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈាន ក្នុងវណ្ណកសិណដែលបរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ បុគ្គលដែលកន្លងនូវរូបសញ្ញា ដល់នូវសេចក្ដីវិនាសនៃបដិឃសញ្ញា ទាំងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកាសានញ្ចាយតនជ្ឈាន ( ដោយធ្វើទុកក្នុងចិត្ត ) ថា អាកាសមិនមានទីបំផុត ដូច្នេះ នេះជាវិមោក្ខទី ៤ ។ បុគ្គលដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន ( ដោយធ្វើទុកក្នុងចិត្ត ) ថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលដែលកន្លង

នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ( ដោយធ្វើទុកក្នុងចិត្ត ) ថា អ្វីតិចតួចក៏មិនមាន ដូច្នេះ នេះជាវិមោក្ខទី ៦ ។ បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គល ដែលកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់សញ្ញាវេទយិតនិរោធ ( សេចក្តីរលត់នៃសញ្ញា និងវេទនា ) នេះជាវិមោក្ខទី ៨[១] ដូច្នេះ ។

បទថា **នវ អនុបុព្វនិរោធា** បានដល់ ការរម្ងត់តាមលំដាប់ ៩ យ៉ាង ។ អនុបុព្វនិរោធទាំង ៩ យ៉ាង តើដូចម្តេច ។ គឺកាលបុគ្គលចូលបឋមជ្ឈានហើយ កាមសញ្ញា[២]រលត់ទៅ ១ កាលចូលទុតិយជ្ឈាន វិតក្កវិចាររលត់ទៅ ១ កាលចូលតតិយជ្ឈាន បីតិរលត់ទៅ ១ កាលចូលទៅចតុត្ថជ្ឈាន អស្សាសៈ និងបស្សាសៈ រលត់ទៅ ១ កាលចូលអាកាសានញ្ចាយតនជ្ឈាន រូបសញ្ញារលត់ទៅ ១ កាលចូលវិញ្ញាណញ្ចាយតនជ្ឈាន អាកាសានញ្ចាយតនសញ្ញា រលត់ទៅ ១ កាលចូលអាកិញ្ចញ្ញា-

---

១- ទីឃនិកាយ មហាវគ្គ ។

២- បិដកខ្មែរ ជាអាមិសសញ្ញា ។

យតនជ្ឈាន វិញ្ញាណញ្ចាយតនសញ្ញារលត់ទៅ ១ កាលចូលនៅសញ្ញានាសញ្ញាយតនជ្ឈាន អាកិញ្ចញ្ញាយតនសញ្ញារលត់ទៅ ១ កាលចូលសញ្ញាវេទយិតនិរោធ សញ្ញា និងវេទនារលត់ទៅ ១[១] ដូច្នេះ ។

បទថា **ទស អសេក្ខា ធម្មា** មានវិគ្គហៈថា ឈ្មោះថា **អសេក្ខ** ព្រោះអត្ថថា មិនសិក្សា ព្រោះមិនមានវត្ថុដែលគួរសិក្សាតទៅ ។ ម្យ៉ាងទៀត ឈ្មោះថា **សេក្ខ** ព្រោះអត្ថថា នៅត្រូវសិក្សាក្នុងត្រៃសិក្ខា ឈ្មោះថា **អសេក្ខ** ព្រោះសេក្ខធម៌ដល់នូវការចម្រើនហើយ បានដល់ ព្រះអរហន្ត ។ ឈ្មោះថា អសេក្ខធម៌ ព្រោះអត្ថថា ធម៌ទាំងនេះជារបស់អសេក្ខបុគ្គល ។

១០ យ៉ាង តើអ្វីខ្លះ ។ គឺសម្មាទិដ្ឋិជាអសេក្ខៈ ១ សម្មាសង្កប្បជាអសេក្ខៈ ១ សម្មាវាចាជាអសេក្ខៈ ១ សម្មាកម្មន្តៈជាអសេក្ខៈ ១ សម្មាអាជីវៈជាអសេក្ខៈ ១ សម្មាវាយាមៈជាអសេក្ខៈ ១ សម្មាសតិជាអសេក្ខៈ ១ សម្មាសមាធិជាអសេក្ខៈ ១ សម្មា-ញាណៈជាអសេក្ខៈ ១ សម្មាវិមុត្តិជាអសេក្ខៈ ១[២] ដូច្នេះ ។

ពាក្យថា សម្មាញាណៈជាអសេក្ខៈ បានដល់ លោកិយប្បញ្ញាដ៏សេស វៀរអរហត្តផលប្បញ្ញា ។ ពាក្យថា សម្មាវិមុត្តិ បានដល់ អរហត្តផលវិមុត្តិ ។ លោកពោលក្នុងអដ្ឋកថាថា ធម៌ដែលសម្បយុត្តដោយផល សូម្បីទាំងអស់

---

១- អង្គុត្តរនិកាយ នវកនិបាត ។

២- អង្គុត្តរនិកាយ ទសកនិបាត ។

មានសម្មាទិដ្ឋិជាដើមនោះឯងជាអសេក្ខធម៌ ។ មួយវិញទៀត ក្នុងបទនេះ លោកពោលបញ្ញាក្នុងឋានៈ ២ យ៉ាង គឺសម្មាទិដ្ឋិ សម្មាញាណ ។ ដោយពាក្យនេះថា សម្មាវិមុត្តិ លោកសង្គ្រោះធម៌ដែលជាផលសមាបត្តិដោយមិនសេសសល់ តាមដែលពោលហើយ ។

[ ៧៨ ] ក្នុងបទថា **សព្វំ ភិក្ខវេ សច្ឆិកាតព្វំ** ជាដើម គប្បីជ្រាបការធ្វើឲ្យជាក់ច្បាស់ដោយភាពជាអារម្មណ៍ ។ ក្នុងបទថា **រូបំ បស្សន្តោ សច្ឆិករោតិ** ជាដើម សេចក្តីថា ព្រះយោគាវចរ កាលឃើញរូបជាដើម ដែលជាលោកិយ ដោយអាការដែលគួរឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវរូបជាដើមទាំងនោះ ដោយការធ្វើឲ្យជាក់ច្បាស់ដោយជាអារម្មណ៍ ឬកាលឃើញរូបជាដើម ដោយអាការដែលគួរឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវនិព្វានដែលគួរធ្វើឲ្យជាក់ច្បាស់ដោយហេតុ ( រូប ) នោះ ។ អ្នកគិតអក្ខរៈទាំងឡាយមានការយល់ឃើញថា បទថា **បស្សន្តោ** ប្រើក្នុងអត្ថនៃហេតុព្រះយោគាវចរ កាលឃើញលោកុត្តរធម៌ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម ដោយអំណាចការពិចារណា រមែងធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដោយការធ្វើឲ្យជាក់ច្បាស់ដោយជាអារម្មណ៍ ។ បទនេះថា **អមតោគធំ និព្វានំ បរិយោសានដ្ឋេន សច្ឆិករោតិ** ជាពាក្យត្រង់នោះឯង ព្រោះគប្បីធ្វើឲ្យជាក់ច្បាស់ក្នុងបរិញ្ញេយ្យ បហាតព្វ សច្ឆិកាតព្វ ភាវេតព្វ ។

បទថា **យេ យេ ធម្មា សច្ឆិកតា ហោន្តិ តេ តេ ធម្មា ផុសិតា ហោន្តិ** បានដល់ ធម៌ដែលធ្វើឲ្យជាក់ច្បាស់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់

ដោយជាអារម្មណ៍ រមែងជាធម៌ដែលពាល់ត្រូវហើយ ដោយការពាល់ត្រូវដោយជាអារម្មណ៍ ធម៌ដែលធ្វើឲ្យជាក់ច្បាស់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវការបានចំពោះ រមែងជាធម៌ដែលពាល់ត្រូវហើយ ដោយការពាល់ត្រូវដោយការបានចំពោះ ដោយប្រការដូច្នេះ ។៚

## អដ្ឋកថាសច្ចិកាតព្វនិទ្ទេស ចប់

## អដ្ឋកថា
## ហានភាគិយចតុក្កនិទ្ទេស

ឥឡូវនេះ ព្រោះសភាពដែលធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិនាស ជាដើម រមែងមានដោយប្រភេទការកំណត់សមាធិនីមួយៗ ហេតុនោះ ទើបព្រះសារីបុត្តសម្ដែងហានភាគិយចតុក្កៈដោយសភាពតែមួយដូចគ្នានោះឯង ។

ក្នុងបទទាំងនោះ បទថា **បឋមស្ស ឈានស្ស លាភឹ** បានដល់ របស់ព្រះយោគាវចរដែលបាននូវបឋមជ្ឈាន ។ បទថា **លាភឹ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។ **លាភោ** លោកពោលជា **លាភី** ព្រោះអត្ថថា មានការធ្វើឲ្យជាក់ច្បាស់ ។

សព្ទថា **សហគត** ក្នុងបទថា **កាមសហគតា** នេះ លោកបំណងយកសេចក្ដីថា ជាអារម្មណ៍ អធិប្បាយថា មានវត្ថុកាម និងកិលេសកាម ជាអារម្មណ៍ ។

បទថា **សញ្ញាមនសិការា** បានដល់ ជវនសញ្ញា និងមនសិការ ដោយការនឹកគិតដល់សញ្ញានោះ ។ សូម្បីមនសិការសម្បយុត្តដោយសញ្ញា ក៏ត្រឹមត្រូវ ។ បទថា **សមុទាចរន្តិ** បានដល់ រមែងប្រព្រឹត្តទៅ ។

បទថា **ធម្មោ** បានដល់ ធម្ម គឺបឋមជ្ឈាន ។ ព្រះយោគាវចរ កាលវិនាសចាកឈាន រមែងវិនាសដោយហេតុ ៣ ប្រការ គឺដោយកិលេសកម្រើក ១ ដោយអសប្បាយកិរិយា ១ ដោយការមិនប្រកបសេចក្ដីព្យាយាម ១ ។ កាលវិនាសដោយកិលេសកម្រើក រមែងវិនាសដោយរហ័ស កាលវិនាសដោយអសប្បាយកិរិយា ដោយអំណាចការប្រកបភាពជាអ្នកត្រេកអរ ក្នុង

*ការងារ ភាពជាអ្នកត្រេកអរក្នុងការនិយាយផ្ដេសផ្ដាស ភាពជាអ្នកត្រេកអរក្នុងការដេក ភាពជាអ្នកត្រេកអរក្នុងការច្រឡូកច្រឡំ ឈ្មោះថា វិនាសយឺត កាលមិនចូលឈានរឿយៗ ដោយបលិពោធ មានជំងឺ មានខ្វះខាតដោយបច្ច័យជាដើម កាលវិនាសដោយការមិនប្រកបសេចក្ដីព្យាយាម រមែងវិនាសយឺត ។ តែក្នុងទីនេះ ព្រះសារីបុត្ត កាលសម្ដែងហេតុដែលមានកម្លាំងប៉ុណ្ណោះ ទើបពោលដល់កិលេសកម្រើកតែម្យ៉ាង ។*

*ក៏កាលព្រះយោគាវចរវិនាសចាកទុតិយជ្ឈានជាដើម រមែងវិនាសស្ងួប្បដោយការពេញចិត្តក្នុងឈានជាន់ទាបៗ កម្រើក ។ សួរថា វិនាសដោយហេតុប្រមាណប៉ុណ្ណា ឆ្លើយថា ដោយហេតុប៉ុនដែលកាលមិនអាចនឹងចូលឈានបាន ។*

*បទថា* **តទនុធម្មតា** *បានដល់ ធម៌ដែលប្រព្រឹត្តទៅសមគួរ គឺធម៌ដែលសមគួរ ពាក្យនេះជាឈ្មោះរបស់ធម៌ គឺការពេញចិត្តដែលប្រព្រឹត្តទៅ ព្រោះធ្វើឈានឲ្យក្រៃលែង ។ ធម៌ដែលសមគួរនោះឯង ឈ្មោះថា* **អនុធម្មតា** ។ *សភាពជាធម៌សមគួរដល់ឈាននោះ ឈ្មោះថា* **តទនុធម្មតា** ។

*បទថា* **សតិ** *បានដល់ ការពេញចិត្ត ។ បទថា* **សន្តិដ្ឋតិ** *បានដល់ រមែងតាំងនៅ ។ មានពាក្យអធិប្បាយថា ការពេញចិត្តដែលប្រព្រឹត្តទៅតាមបឋមជ្ឈាននោះ នៅប្រព្រឹត្តទៅនៅឡើយ ។*

*បទថា* **អវិតក្កសហគតា** *បានដល់ មានទុតិយជ្ឈានជាអារម្មណ៍ ។ បទនេះ លោកហៅថា* **អវិតក្ក** *ព្រោះអត្ថថា ក្នុងទុតិយជ្ឈាននេះមិនមានវិតក្ក ។*

បទថា **និព្វិទាសហគតា** បានដល់ មានវិបស្សនាជាអារម្មណ៍ ។ ពិតហើយ វិបស្សនានោះ លោកហៅថា និព្វិទា ព្រោះនឿយណាយក្នុងសង្ខារទាំងឡាយ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងវិនយបិដក មហាវគ្គ ) ថា កាលបើនឿយណាយ ( យ៉ាងនេះហើយ ) ក៏ប្រាសចាកតម្រេក ដូច្នេះ ។

បទថា **វិរាគូបសញ្ហិតា** បានដល់ វិបស្សនាប្រកបដោយអរិយមគ្គ ។ ពិតហើយ វិបស្សនានោះដល់កំពូលហើយឲ្យសម្រេចការចេញ ( ចាកកិលេស ) ដោយមគ្គ ។ ព្រោះហេតុនោះ សញ្ញា និងមនសិការដែលមានវិបស្សនាជាអារម្មណ៍ ទើបហៅថា **វិរាគូបសញ្ហិតា** សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងវិនយបិដក មហាវគ្គ ) ថា ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ដូច្នេះ ។

បទថា **វិតក្កសហគតា** បានដល់ មានបឋមជ្ឈានជាអារម្មណ៍ ដោយអំណាចវិតក្ក ។

បទថា **ឧបេក្ខាសុខសហគតា** បានដល់ មានតតិយជ្ឈាន ជាអារម្មណ៍ ដោយអំណាចឧបេក្ខា គឺជាកណ្តាលក្នុងឈាននោះ និងដោយអំណាចសុខវេទនា ។

បទថា **បីតិសុខសហគតា** បានដល់ មានទុតិយជ្ឈានជាអារម្មណ៍ដោយអំណាចបីតិ និងសុខវេទនា ។

បទថា **អទុក្ខមសុខសហគតា** បានដល់ មានចតុត្ថជ្ឈានជាអារម្មណ៍ ដោយអំណាចឧបេក្ខាវេទនា ។ ពិតហើយ វេទនានោះ មិនមានទុក្ខ មិនមានសុខ ព្រោះហេតុនោះ ទើបលោកហៅថា **អទុក្ខមសុខវេទនា ។ ម** អក្ខរៈ

ក្នុងបទនេះ លោកពោលដោយអំណាចការក្លាប់បទ ។

បទថា **រូបសហគតា** បានដល់ មានរូបជ្ឈានជាអារម្មណ៍ ទោះបីមានធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិនាស ប្រព្រឹត្តទៅក្នុងចំណែកនៃការតាំងនៅ និងប្រព្រឹត្តទៅក្នុងចំណែកនៃការទម្លាយកិលេស របស់ព្រះយោគាវចរដែលតាំងនៅក្នុងនេវសញ្ញានាសញ្ញាយតនៈ លោកក៏មិនបានសម្ដែងនេវសញ្ញានាសញ្ញាយតនៈ ព្រោះមិនមានធម៌ប្រព្រឹត្តទៅ ក្នុងចំណែកនៃគុណវិសេស ។ លោកពោលថា សមាធិដែលជាលោកិយនេះ សូម្បីទាំងអស់ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិនាសដល់ព្រះយោគីអ្នកមានឥន្ទ្រិយទន់ខ្សោយ មានប្រក្រតីនៅដោយសេចក្ដីប្រមាទ ប្រព្រឹត្តទៅក្នុងចំណែកនៃការតាំងនៅ ដល់ព្រះយោគីដែលមានឥន្ទ្រិយទន់ខ្សោយ មានប្រក្រតីនៅដោយសេចក្ដីមិនប្រមាទ ប្រព្រឹត្តទៅក្នុងចំណែកនៃគុណវិសេសដល់ព្រះយោគី អ្នកមានឥន្ទ្រិយចាស់ក្លាដែលជាតណ្ហាចរិត ប្រព្រឹត្តទៅក្នុងចំណែកនៃការទម្លាយកិលេសដល់ព្រះយោគី អ្នកមានឥន្ទ្រិយចាស់ក្លាជាទិដ្ឋិចរិត ៕០៚

**អដ្ឋកថាហានភាគិយចតុក្កនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ៧៩ ] ការប្រុងត្រចៀកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួងជាអនត្តា បញ្ញា ជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ការប្រុងត្រចៀកថា រូបមិនទៀង ដោយអត្ថថា អស់ទៅ ជាទុក្ខ ដោយអត្ថថា ជាភ័យ ជាអនត្តា ដោយអត្ថថា មិនមានខ្លឹម បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរា មរណៈមិនទៀង ដោយអត្ថថា អស់ទៅ ជាទុក្ខ ដោយអត្ថថា ជាភ័យ ជាអនត្តា ដោយអត្ថថា មិនមានខ្លឹម បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួងជាអនត្តា បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

# អដ្ឋកថា

# លក្ខណត្តិកនិទ្ទេស

[ ៧៩ ] ឥឡូវនេះ ព្រោះលោកិយធម៌នីមួយៗ ត្រូវកម្ចាត់ដោយត្រៃលក្ខណ៍ ហេតុនោះ ទើបលោកសម្ដែងត្រៃលក្ខណ៍ដែលមានលក្ខណៈដូចគ្នា ។

ក្នុងបទទាំងនោះ បទថា **អនិច្ចំ ខយដ្ឋេន** បានដល់ រូប ឈ្មោះថា មិនទៀង ព្រោះការអស់ទៅក្នុងទីនោះៗ ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា មិនទៀង ព្រោះមានសេចក្ដីអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសចាករាគជាធម្មតា រលត់ទៅជាធម្មតា ។

បទថា **ទុក្ខំ ភយដ្ឋេន** បានដល់ ឈ្មោះថា ទុក្ខ ព្រោះការមានភ័យចំពោះមុខ ព្រោះថា វត្ថុណាមិនទៀង វត្ថុនោះ រមែងនាំមកនូវសភាពគួរខ្លាច ដូចនាំការខ្លាចមកដល់ទេវតាក្នុងសីហោបមសូត្រ ដូច្នោះ ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា **ទុក្ខ** ដោយអត្ថថា ជាតិ ជរា ព្យាធិ និងមរណៈជាវត្ថុគួរខ្លាច ។

បទថា **អនត្តា អសារកដ្ឋេន** បានដល់ ឈ្មោះថា អនត្តា ព្រោះមិនមានខ្លឹមសារក្នុងខ្លួនដែលកំណត់យ៉ាងនេះថា តួខ្លួនអ្នកអាស្រ័យ អ្នកធ្វើ អ្នកសោយ អ្នកមានអំណាចឯង ព្រោះថា វត្ថុណា មិនទៀង ជាទុក្ខ វត្ថុនោះមិនអាចតម្កល់នូវការមិនទៀងរបស់ខ្លួន ឬតម្កល់នូវការបៀតបៀន ព្រោះការកើត និងការរលត់បាន តើនឹងរកភាពដែលវត្ថុនោះជាអ្នកធ្វើជាដើម បានអំពីណា ។ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងវិនយបិដក មហាវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើរូបនេះ ជារបស់ខ្លួនពិតមែន រូបនេះ ក៏

មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជំងឺតម្កាត់ឡើយ ដូច្នេះ ។ អាចារ្យពួកមួយពោលថា ឈ្មោះថា អនត្តា ព្រោះមិនមានខ្លឹមសារក្នុងខ្លួន មិនមានខ្លឹមសារជានិច្ច ។ល។

## អដ្ឋកថាលក្ខណត្តិកនិទ្ទេស ចប់

# សុត្តន្តបិដក

[ ៨០ ] ការប្រុងត្រចៀកថា នេះទុក្ខអរិយសច្ច នេះទុក្ខសមុទយអរិយសច្ច នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ។

បណ្តាអរិយសច្ចទាំងនោះ ទុក្ខអរិយសច្ច តើដូចម្តេច ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ មរណៈក៏ជាទុក្ខ ការសោក ការខ្សឹកខ្សួល ការលំបាកកាយ ការអាក់អន់ចិត្ត ការចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ ការកប់ប្រសព្វដោយពួកសត្វ និងសង្ខារមិនជាទីស្រឡាញ់ ក៏ជាទុក្ខ ការព្រាត់ប្រាសចាកពួកសត្វ និងសង្ខារជាទីស្រឡាញ់ ក៏ជាទុក្ខ ចង់បានរបស់ណា មិនបានការមិនបាននោះក៏ជាទុក្ខ បើពោលដោយបង្រួញ ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។

បណ្តាធម៌ទាំងនោះ ជាតិ តើដូចម្តេច ។ ការកើត ការកើតព្រម ការចុះកាន់គភ៌ ការចម្រើនឡើង ការកើតចំពោះ ការកើតប្រាកដឡើងនៃខន្ធទាំងឡាយ ការបានចំពោះនូវអាយតនៈណា នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ នេះហៅថា ជាតិ ។

បណ្តាធម៌ទាំងនោះ ជរា តើដូចម្តេច ។ ជរា ការគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ការរួញថយអាយុ ការចាស់នៃឥន្ទ្រិយណា នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ នេះហៅថា ជរា ។

បណ្តាធម៌ទាំងនោះ មរណៈ តើដូចម្តេច ។ ការច្យុតិ ការឃ្លាត ការបែកធ្លាយ ការអន្តរធាន មច្ចុ សេចក្តីស្លាប់ កាលកិរិយា ការបែកធ្លាយទៅនៃ

ខន្ធ ការដាក់ចោលនូវសាកសព ការដាច់បង់ទៅនៃជីវិតិន្ទ្រិយណា នៃពួកសត្វនោះៗ ចាកសត្តនិកាយនោះៗ នេះហៅថា មរណៈ ។

[ ៨១ ] បណ្តាធម៌ទាំងនោះ ការសោក តើដូចម្តេច ។ ការសោក អាការសោកស្តាយ ភាពនៃការសោកស្តាយ ការស្ងួតស្ងប់ខាងក្នុង ការក្រៀមក្រំខាងក្នុង ការសញ្ជប់សញ្ជឹងនៃចិត្ត ការតូចចិត្ត សរ គឺសេចក្តីសោកណា នៃបុគ្គលដែលត្រូវសេចក្តីវិនាសចាកញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ នេះហៅថា សោក ។

បណ្តាធម៌ទាំងនោះ ការខ្សឹកខ្សួល តើដូចម្តេច ។ សេចក្តីខ្សឹកខ្សួល ការអណ្តឺតអណ្តក អាការជាទីខ្សឹកខ្សួល អាការជាទីអណ្តឺតអណ្តក ភាពនៃសេចក្តីខ្សឹកខ្សួល ភាពនៃសេចក្តីអណ្តឺតអណ្តក ការពោលរៀបរាប់ដោយវាចា ការពោលរៀបរាប់ដដែលៗ ការទួញយំ អាការជាទីទួញយំ ភាពនៃការទួញយំរបស់បុគ្គលដែលត្រូវសេចក្តីវិនាសចាកញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសនៃទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ នេះហៅថា ការខ្សឹកខ្សួល ។

បណ្តាធម៌ទាំងនោះ សេចក្តីទុក្ខ តើដូចម្តេច ។ សេចក្តីមិនសប្បាយកាយ សេចក្តីលំបាកកាយ ការទទួលរងមិនសប្បាយ ជាទុក្ខដែលកើតអំពីកាយ-

សម្ផស្ស អាការទទួលរងមិនសប្បាយ ជាទុក្ខដែលកើតអំពីកាយសម្ផស្សណា នេះហៅថា ទុក្ខ ។

បណ្ដាធម៌ទាំងនោះ ទោមនស្ស តើដូចម្ដេច ។ សេចក្ដីមិនសប្បាយចិត្ត ការលំបាកចិត្ត ការទទួលរងមិនសប្បាយ ជាទុក្ខដែលកើតអំពីមនោសម្ផស្ស អាការទទួលរងមិនសប្បាយ ជាទុក្ខដែលកើតអំពីមនោសម្ផស្សណា នេះហៅថា ទោមនស្ស ។

បណ្ដាធម៌ទាំងនោះ ឧបាយាស ( សេចក្ដីចង្អៀតចង្អល់ ) តើដូចម្ដេច ។ សេចក្ដីតានតឹង ការទង្គឹះ ភាពនៃសេចក្ដីតានតឹង ភាពនៃសេចក្ដីទង្គឹះណា របស់បុគ្គលដែលត្រូវសេចក្ដីវិនាសចាកញាតិប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសចាកភោគៈប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាស គឺរោគប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសចាកសីលប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសនៃទិដ្ឋិប៉ះពាល់ក្ដី ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ នេះហៅថា ឧបាយាស ។

[ ៨២ ] បណ្ដាធម៌ទាំងនោះ អប្បិយេហិសម្បយោគទុក្ខ ( ការកប់ប្រសព្វដោយសត្វ និងសង្ខារទាំងឡាយមិនជាទីស្រឡាញ់ក៏ជាទុក្ខ ) តើដូចម្ដេច ។ បុគ្គលនោះ ក្នុងលោកនេះ មានរូប សំឡេង ក្លិន រស ផស្សព្វណាមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ពុំនោះសោត ពួកជនណាជាអ្នកប្រាថ្នាសេចក្ដីវិនាស ប្រាថ្នាអំពើមិនជាប្រយោជន៍ ប្រាថ្នាសេចក្ដីមិនសប្បាយ ប្រាថ្នាសេចក្ដីមិនក្សេមចាកយោគៈ ដល់បុគ្គលនោះ ការជួបប្រទះ ការជួបជុំ ការកប់ប្រសព្វ ការច្រឡូកច្រឡំដោយអារម្មណ៍ទាំងនោះ ឬដោយបុគ្គលទាំង

នោះឯណា នេះហៅថា អប្បិយេហិសម្បយោគទុក្ខ ។

បណ្តាធម៌ទាំងនោះ បិយេហិវិប្បយោគទុក្ខ ( ការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ក៏ជាទុក្ខ ) តើដូចម្តេច ។ បុគ្គលនោះ មានរូប សំឡេង ក្លិន រស ផស្សៈណា ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ក្នុងលោកនេះ ពុំនោះសោត ពួកជនណា ទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសប្បាយ ប្រាថ្នានូវសេចក្តីក្សេមចាកយោគៈដល់បុគ្គលនោះ ការមិនជួបប្រទះ ការមិនជួបជុំ ការមិនកប់ប្រសព្វ ការមិនបានមូលមិត្តដោយអារម្មណ៍ ឬដោយពួកជនទាំងនោះឯណា នេះលោកហៅថា បិយេហិវិប្បយោគទុក្ខ ។

បណ្តាធម៌ទាំងនោះ បុគ្គលប្រាថ្នារបស់ណាមិនបាន ការដែលគេប្រាថ្នារបស់នោះមិនបាននោះ នាំមកនូវទុក្ខ តើដូចម្តេច ។ សត្វទាំងឡាយដែលមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ សូមឲ្យយើងទាំងឡាយ កុំមានជាតិជាធម្មតា ឬថា ជាតិមិនគប្បីមកដល់យើងទាំងឡាយ ដំណើរនុ៎ះ ពួកសត្វមិនគប្បីសម្រេចបានតាមប្រាថ្នាឡើយ ហេតុនេះឯង ទើបឈ្មោះថា បុគ្គលប្រាថ្នារបស់ណាមិនបាន ការដែលគេប្រាថ្នារបស់នោះមិនបាននោះឯង នាំមកនូវទុក្ខ ពួកសត្វមានជរាជាធម្មតា ។បេ។ ពួកសត្វមានព្យាធិជាធម្មតា ពួកសត្វមានមរណៈជាធម្មតា ពួកសត្វមានសោកបរិទេវទុក្ខទោមនស្សុបាយាសជាធម្មតា តែងមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះ

ថា ធ្វើដូចម្តេចហ្ន៎ សូមឲ្យយើងទាំងឡាយ កុំមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ការចង្អៀតចង្អល់ ឬថា សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ការចង្អៀតចង្អល់ មិនគប្បីមកដល់យើងទាំងឡាយឡើយ ដំណើរនុ៎ះ ពួកសត្វ មិនគប្បីសម្រេចបានតាមប្រាថ្នាឡើយ នេះឯង ឈ្មោះថា បុគ្គលប្រាថ្នារបស់ណាមិនបាន ការដែលគេប្រាថ្នារបស់នោះ មិនបាននោះ នាំមកនូវទុក្ខ ។

បណ្តាធម៌ទាំងនោះ បើដោយសេចក្តីបង្រួញ ឧបាទានក្ខន្ធទាំង ៥ នាំមកនូវទុក្ខ តើដូចម្តេច ។ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ទាំងនេះ ឈ្មោះថា ឧបាទានក្ខន្ធទាំង ៥ នាំមកនូវទុក្ខ ដោយសេចក្តីបង្រួញ នេះលោកហៅថា ទុក្ខអរិយសច្ច ។

# អដ្ឋកថា

# ទុក្ខសច្ចនិទ្ទេស

[ ៨០ ] ព្រះសារីបុត្ត បានសម្តែងចតុក្កអរិយសច្ច ដោយសភាពដូចគ្នា ព្រោះសច្ចៈទាំងឡាយ ទាក់ទងជាមួយគ្នា ដោយអត្ថថា ជារបស់ពិត ។

ក្នុងបទទាំងនេះ បទថា **តត្ថ** បានដល់ ក្នុងអរិយសច្ចទាំង ៤ នោះ ។ បទថា **កតមំ** បានដល់ ជាពាក្យសួរដើម្បីឆ្លើយឯង ។

បទថា **ទុក្ខំ អរិយសច្ចំ** បានដល់ ជាការសម្តែងធម៌ដែលសួរហើយ ។ ក្នុងបទថា **ជាតិបិ ទុក្ខា** ជាដើមនោះ លោកប្រកាសអត្ថនៃជាតិសព្ទ មិនមែនតិច ដូចលោកពោលថា ភព ត្រកូល ពួក សីល បញ្ញត្តិ លក្ខណៈ ប្រសូត បដិសន្ធិ លោកប្រកាសអត្ថនៃជាតិ ដោយប្រការដូច្នេះ ។

ពិតហើយ **ជាតិ** សព្ទ មកក្នុងអត្ថថា ភព ដូចក្នុងប្រយោគជាដើមថា **ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ** រឭកបាន ១ ជាតិខ្លះ ២ ជាតិ ដូច្នេះ ។

មកក្នុងអត្ថថា ត្រកូល ដូចក្នុងប្រយោគជាដើមថា **អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន** មិនដែលនរណាមួយ ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតឡើយ ដូច្នេះ ។

មកក្នុងអត្ថថា ពួក ដូចក្នុងប្រយោគជាដើមថា **អត្ថិ វិសាខេ និគណ្ឋា នាម សមណជាតិ** ម្នាលនាងវិសាខា ចុះនិគណ្ឋុបោសថៈ តើដូចម្តេច ។ ម្នាលនាងវិសាខា មានពួកសមណៈ ហៅថា និគណ្ឋៈ ដូច្នេះ ។

មកក្នុងអត្ថថា អរិយសីល ដូចក្នុងប្រយោគជាដើមថា **យតោហំ ភគិនិ**

**អរិយាយ ជាតិយា ជាតោ ឆាតិជាឆាមិ** នែនាង តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ ( បានជាអរិយបុគ្គល ) មិនដែលក្លែងផ្ដាច់ផ្ដិលជីវិតសត្វឡើយ ដូច្នេះ ។

មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ** មានស្មៅចិញ្ចៀន ១ សរសៃ ដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស ដូច្នេះ ។

មកក្នុងអត្ថថា សង្ខតលក្ខណៈ ដូចក្នុងប្រយោគជាដើមថា **ជាតិ ទ្វីហិ ខន្ធេហិ សង្គហិតា** ជាតិសង្គ្រោះដោយខន្ធ ២ ដូច្នេះ ។

មកក្នុងអត្ថថា ប្រសូត ដូចក្នុងប្រយោគជាដើមថា **សម្បតិជាតោ អានន្ទ ពោធិសត្តោ** ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ដូច្នេះ ។

មកក្នុងអត្ថថា បដិសន្ធិក្ខន្ធ ដូចក្នុងប្រយោគជាដើមថា **ភវប្បច្ចយា ជាតិ** ជាតិកើតមានព្រោះមានភពជាហេតុឬ **ជាតិបិ ទុក្ខា** កំណើត ( ទាំង ៤ មានជលាពុជជាដើម ) ជាកងទុក្ខ ដូច្នេះ ។ បើពោលដោយត្រង់ បានដល់ ការប្រាកដគ្រាដំបូង របស់ខន្ធទាំងឡាយដែលប្រាកដដល់សត្វ ដែលកើតក្នុងភពនោះៗ ។

បើសួរថា ព្រោះហេតុអ្វី ទើបជាតិជាទុក្ខ ឆ្លើយថា ព្រោះជាតិជាទីតាំងរបស់ទុក្ខ មិនមែនតិច ។ ទុក្ខមិនតិច គឺទុក្ខទុក្ខ វិបរិណាមទុក្ខ សង្ខារទុក្ខ បដិច្ឆន្នទុក្ខ អប្បដិច្ឆន្នទុក្ខ បរិយាយទុក្ខ និប្បរិយាយទុក្ខ ។ ក្នុងទុក្ខទាំងនេះ ទុក្ខវេទនាផ្លូវកាយ និងផ្លូវចិត្ត ហៅថា ទុក្ខទុក្ខ ព្រោះជាទុក្ខដោយសភាវៈ

និងដោយឈ្មោះ ។

សុខវេទនា ឈ្មោះថា វិបរិណាមទុក្ខ ព្រោះជាហេតុកើតទុក្ខដោយការប្រែប្រួល ។

ឧបេក្ខាវេទនា និងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ឈ្មោះថា សង្ខារទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើត និងការរលត់ ។

អាពាធផ្លូវកាយ ផ្លូវចិត្ត មានឈឺត្រចៀក ឈឺធ្មេញ ភាពក្តៅក្រហាយចិត្តកើតព្រោះរាគៈ កើតព្រោះទោសៈជាដើម ឈ្មោះថា បដិច្ឆន្នទុក្ខ ( សេចក្តីទុក្ខដែលបិទបាំង ) ព្រោះសួរ ទើបដឹង និងព្រោះការឈឺចាប់មិនប្រាកដ ។

អាពាធដែលមានសមុដ្ឋានអំពីទោស ៣២ ជាដើម ឈ្មោះថា អប្បដិច្ឆន្នទុក្ខ ទុក្ខមិនបិទបាំងព្រោះមិនត្រូវសួរ ក៏ដឹងបាននិងព្រោះមានការឈឺចាប់ប្រាកដ ។

ទុក្ខទាំងអស់ មានជាតិជាដើម ដែលពោលក្នុងសច្ចវិភង្គដ៏សេស វៀរទុក្ខទុក្ខ ឈ្មោះថា បរិយាយទុក្ខ គឺទុក្ខដោយអម ព្រោះជាទីតាំងនៃទុក្ខនោះៗ ។ ចំណែកទុក្ខទុក្ខ ហៅថា ជានិប្បរិយាយទុក្ខ គឺទុក្ខដោយត្រង់ ។

ក្នុងទុក្ខសច្ចវិភង្គនោះ ជាតិ ឈ្មោះថា ទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ក្នុងអបាយដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយឧបមាក្នុងពាលបណ្ឌិតសូត្រជាដើម និងទុក្ខមានមូល មកអំពីការឈានចុះកាន់គភ៌ជាដើម ដែលកើតក្នុងមនុស្សលោកសូម្បីជាសុគតិភូមិ ។ ក្នុងសេចក្តីនោះ ទុក្ខមានមូលមកអំពីការឈានចុះកាន់គភ៌ជាដើម មានអធិប្បាយដូចតទៅនេះថា ពិតណាស់ សត្វដែល

កើតក្នុងគភ៌មាតា មិនបានកើតក្នុងផ្កាឧប្បល ផ្កាឈូកក្រហម និងផ្កាឈូក-ស ជាដើម តាមពិតសត្វរមែងកើតក្នុងផ្ទៃដែលគួរខ្ពើមក្រៃលែង ដូចត្រាច់ទៅក្នុងព្រៃធំដែលមានក្លិនស្អុយច្រើន ផ្សាយដោយក្លិនសាកសពគ្រប់បែបយ៉ាង ទាំងងងឹតឈឹង ទាំងចង្អៀតក្រៃលែង ក្នុងកណ្តាលផ្ទៃពោះ និងឆ្អឹងទ្រនុងខ្នង ខាងក្រោមមានក្រពះ ខាងលើមានតម្រងបស្សាវៈ ដូចដង្កូវកើតក្នុងត្រីស្អុយ នំផ្អូម និងរណ្តៅសំរាមជាដើម ។ សត្វនោះកើតក្នុងពោះមាតាហើយ ក្តៅនំនៅក្នុងពោះមាតា ១០ ខែ វៀរចាកការបត់ ការលាតជាដើម ក្តៅដូចអាហារដាក់ក្នុងថង់ ដូចដុំម្សៅត្រូវចំហុយ រមែងសោយសេចក្តីទុក្ខក្រៃលែង នេះឈ្មោះថា ទុក្ខមានមូលមកអំពីការឈានចុះកាន់គភ៌ ។

សត្វនោះ ក្នុងខណៈដែលមាតាដួល ដើរ អង្គុយ ក្រោក ប្តូរឥរិយាបថជាដើម យ៉ាងប្រញាប់ប្រញាល់ រមែងសោយទុក្ខធ្ងន់ ព្រោះអាការមានការប្រានទៅ ទាញមក រុញទៅ រុញមកជាដើម ដូចកូនចៀមធ្លាក់ក្នុងដៃពួកអ្នកផឹកស្រា និងដូចកូនពស់ ធ្លាក់ក្នុងដៃរបស់អាលម្ពាយ ។ សត្វរមែងសោយទុក្ខធ្ងន់ក្នុងវេលាមាតាផឹកទឹកត្រជាក់ ប្រាកដដូចកើតក្នុងនរកត្រជាក់ ក្នុងវេលាមាតាលេបបបរ និងអាហារក្តៅជាដើម ប្រាកដដូចភ្លៀងរងើកភ្លើង ធ្លាក់ចុះមកក្នុងវេលាមាតាលេបរបស់ប្រៃ របស់ជូរជាដើម ប្រាកដដូចបានទទួលទោសមានការស្រោចដោយទឹកខារជាដើម នេះឈ្មោះថា ទុក្ខមានមូលមកអំពីការបរិហារគភ៌ ។

មួយទៀត សត្វរមែងសោយទុក្ខ ដោយការវះកាត់ជាដើមរបស់មាតា អ្នក

មានគតិ៍វង្វេងក្នុងទីដែលទុក្ខកើតដែលជាទីមិនគួរមើល សូម្បីនៃមិត្ត អាមាត្យ និងមិត្តជិតស្និទ្ធជាដើម នេះឈ្មោះថា ទុក្ខមានមូលមកអំពីការវិបត្តិនៃគតិ៍ ។

ទុក្ខរមែងកើតដល់សត្វអ្នកត្រូវខ្យល់កម្មជវាតរបស់មាតាដែលប្រសូត បក់បង្វិលក្បាលឲ្យទៅកាន់ទ្វារប្រសូត គួរឲ្យខ្លាចក្រៃលែង ដូចធ្លាក់ទៅក្នុងជ្រោះ ត្រូវទាញចេញអំពីទ្វារប្រសូត ដ៏ចង្អៀតក្រៃលែង ដូចដំរីធំត្រូវទាញអំពីប្រហោងសោ និងដូចសត្វនរក ត្រូវភ្នំក្នុងសង្ឃាតនរកកិនកម្ទេច នេះទុក្ខមានមូលមកពីការប្រសូតិ ។

ទុក្ខដូចទឹងចាក់ដោយចុងដែកស្រួច និងធូតដោយកាំបិតកោរ រមែងកើតដល់សត្វដែលកើតហើយ មានរាងកាយតូចខ្ចី ដូចជាដំបៅថ្មីៗ ក្នុងវេលាយកដៃចាប់ងូតទឹក លាងខ្លួន ជូតដោយកន្ទបជាដើម នេះឈ្មោះថា ទុក្ខមានមូលមកអំពីការចេញមកខាងក្រៅផ្ទៃម្តាយ ។

ក្នុងការប្រព្រឹត្តទៅខាងមុខ បន្ទាប់អំពីនេះ ទុក្ខរមែងមានដល់អ្នកបំផ្លាញខ្លួនដោយខ្លួនឯង ដែលប្រកបសេចក្តីព្យាយាម ដោយការធ្វើទារុណកម្មខ្លួន ធ្វើខ្លួនឲ្យក្តៅក្រហាយដោយអចេលកវត្តជាដើម ដែលអត់អាហារ និងចង-កឲ្យស្លាប់ដោយសេចក្តីក្រោធ នេះឈ្មោះថា ទុក្ខមានមូល មកអំពីការព្យាយាមរបស់ខ្លួន ។

ម្យ៉ាងទៀត ទុក្ខ រមែងកើតដល់បុគ្គលអ្នកសោយកម្ម មានការសម្លាប់ និងការចងជាដើម អំពីអ្នកដទៃ នេះឈ្មោះថា ទុក្ខមានមូលមកអំពីការព្យាយាមរបស់អ្នកដទៃ ។

ជាតិនេះ ជាទីតាំងរបស់ទុក្ខទាំងអស់នេះ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបលោកពោលថា

ប្រសិនបើ សត្វមិនគប្បីកើតក្នុងនរកទាំងឡាយសោត កម្មក្នុងនរកនោះ មានត្រូវភ្លើងដុតជាដើម មិនគប្បីញាំញីបុគ្គលនោះបាន ទុក្ខគប្បីបានទីពឹងក្នុងទីណា ព្រោះហេតុនោះ ទើបព្រះមុនីក្នុងធម្មវិន័យនេះ ពោលថា ជាតិជាទុក្ខ ។

ទុក្ខក្នុងពួកសត្វតិរច្ឆានមានមិនមែនតិច កើតព្រោះការវាត់ដោយគ្នាង ចាក់ដោយជន្លួញ វាយដោយដំបងជាដើម វៀរជាតិចេញ ទុក្ខគប្បីមានក្នុងសត្វនោះបានដូចម្តេច ព្រោះហេតុនោះ ទើបជាតិក្នុងពួកសត្វនោះ ឈ្មោះថា ជាទុក្ខ ។

ទុក្ខក្នុងប្រេតទាំងឡាយ ដែលវិចិត្រផ្សេងៗ កើតព្រោះសេចក្តីស្រេកឃ្លាន ខ្យល់ និងកម្តៅថ្ងៃជាដើម ព្រោះទុក្ខក្នុងបេតលោកទាំងនោះ រមែងមិនមានដល់សត្វដែលមិនកើត ព្រោះហេតុនោះ ទើបព្រះមុនីត្រាស់ថា ជាតិជាទុក្ខ ។

ទុក្ខក្នុងពួកអសុរក្នុងលោកន្តរនរកដែលងងឹតឈឹង ត្រជាក់ក្រៃលែង ព្រោះការកើតក្នុងលោកន្តរនរកនោះមិនមានទុក្ខ ក៏មានមិនបាន ហេតុនោះ ទើបជាតិនេះ ឈ្មោះថា ទុក្ខ ។

សត្វ កាលនៅក្នុងផ្ទៃមាតា ក៏ដូចនៅក្នុងគូថនរកយូរក្តី កាលចេញទៅខាងក្រៅក្តី រមែងជួបនូវទុក្ខ វៀរជាតិចេញ

ហើយ សូម្បីទុក្ខដ៏ខ្លាំងក្រៃលែង ក៏មិនមាន ព្រោះហេតុនោះ ទើបជាតិនេះ ឈ្មោះថា ទុក្ខ ។

ប្រយោជន៍អ្វីដែលត្រូវពោលច្រើន ទុក្ខណាសូម្បីបន្តិចបន្តួច មាននៅក្នុងទីណាក្នុងលោកនេះក្តី ទុក្ខនេះវៀរជាតិចេញហើយ ក៏មិនមានក្នុងកាលណាឡើយ ព្រោះហេតុនោះ ព្រះមានព្រះភាគ អ្នកស្វែងរកគុណធំ ទ្រង់ត្រាស់ដល់ជាតិនេះថា ជាទុក្ខ មុនទុក្ខដទៃទាំងអស់ ដូច្នេះ ។

ក្នុងបទថា **ជរាបិ ទុក្ខា** នេះ មានអធិប្បាយដូចតទៅនេះថា

ជរាមាន ២ យ៉ាង គឺលក្ខណៈរបស់សង្ខតៈ និងភាពជាខណ្ឌចាស់ ដែលទាក់ទងក្នុងភពមួយក្នុងសន្តតិដែលសន្មតិគ្នាថា មានធ្មេញបាក់ជាដើម ។ ក្នុងទីនេះ លោកបំណងយកជរានោះ ។ ជរានោះ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ និងព្រោះជាទីតាំងនៃទុក្ខ ។ ទុក្ខផ្លូវកាយ ផ្លូវចិត្តកើតឡើង មានបច្ច័យជាច្រើនថា អវយវៈតូចធំយុរយារ ឥន្ទ្រិយវិកលវិការ រូបប្រែប្រួលទៅ ភាពជាកំលោះក្រមុំវិនាសទៅ កម្លាំងថមថយ សតិបញ្ញាអន់ថយ ត្រូវអ្នកដទៃមើលងាយ ជរា ឈ្មោះថា ជាទីតាំងនៃទុក្ខនោះ ដោយហេតុនោះ ទើបលោក ពោលគាថានេះថា

ព្រោះអវយវៈយុរយារ ឥន្ទ្រិយពិការ ភាពជាកំលោះក្រមុំសាបសូន្យ កម្លាំងថមថយ សតិជាដើមអន់ថយ ដាច់នូវការជ្រះថ្លាអំពីកូនប្រពន្ធរបស់ខ្លួន ដល់នូវសភាពទន់ជ្រាយច្រើនឡើង

*សត្វបានទទួលទុក្ខផ្លូវកាយ ផ្លូវចិត្ត ទាំងអស់នោះ មានជាតិ
ជាហេតុ ព្រោះហេតុនោះ ទើបជាតិ ឈ្មោះថា ជាទុក្ខ ។*

*កាលលោកគួរពោលព្យាធិទុក្ខក្នុងលំដាប់នៃជរាទុក្ខ ក៏គប្បីជ្រាបថា លោក
មិនពោល ព្រោះព្យាធិទុក្ខលោកកាន់យកដោយសព្ទថា កាយិកទុក្ខនោះឯង ។*

*ក្នុងបទថា* **មរណម្បិ ទុក្ខំ** *នេះ មានអធិប្បាយដូចតទៅ*

*មរណៈមាន ២ យ៉ាង គឺមរណៈដែលលោកពោលសំដៅដល់លក្ខណៈ
នៃសង្ខតៈ ( ដូចលោកពោលក្នុងអភិធម្ម ធាតុកថា ) ថា ជរា និងមរណៈ
សង្គ្រោះដោយខន្ធ ២ ដូច្នេះ ។ និងលោកពោលសំដៅដល់ការដាច់ជីវិតិន្ទ្រិយ
ដែលទាក់ទងគ្នាក្នុងភពមួយ ( ដែលលោកពោលក្នុងសុត្តនិបាត ) ថា តែង
មានសេចក្តីភ័យ អំពីសេចក្តីស្លាប់ អស់កាលជានិច្ច ដូច្នេះ ។ ក្នុងទីនេះ
លោកបំណងយកសេចក្តីស្លាប់នោះ ។ ជាតិប្បច្ចយមរណៈ គឺការស្លាប់ព្រោះ
ជាតិជាបច្ច័យ ១ ឧបក្កមមរណៈ គឺការស្លាប់ព្រោះសេចក្តីព្យាយាម ១ សរ-
សមរណៈ គឺការស្លាប់ដោយសភាវៈ ( ស្លាប់ឯង ) ១ អាយុក្ខយមរណៈ
គឺការស្លាប់ព្រោះអស់អាយុ ១ បុញ្ញក្ខយមរណៈ គឺការស្លាប់ព្រោះអស់បុណ្យ
១ នេះជាឈ្មោះរបស់មរណៈទាំងអស់ ។ គប្បីជ្រាបប្រភេទ របស់សេចក្តី
ស្លាប់ក្នុងទីនេះទៀត គឺខណិកមរណៈ សេចក្តីស្លាប់មួយជួរខណៈ សម្មតិមរណៈ
សេចក្តីស្លាប់ដោយសន្មត សមុច្ឆេទមរណៈ សេចក្តីស្លាប់ដោយដាច់ខាត ។
ការបែកធ្លាយនៃរូបធម៌ និងអរូបធម៌ក្នុងបវត្តិកាល ឈ្មោះថា ខណិកមរណៈ ។*

*ពាក្យថា តិស្សៈស្លាប់ហើយ ផុស្សៈស្លាប់ហើយ ឈ្មោះថា សម្មតិមរណៈ*

ព្រោះមិនមានសត្វដោយបរមត្ថ ។

ពាក្យថា ស្រូវងាប់ហើយ ដើមឈើងាប់ហើយ ឈ្មោះថា សម្មតិមរណៈ ព្រោះមិនមានជីវិតិន្ទ្រិយ ។

កាលកិរិយាដែលមិនមានបដិសន្ធិ របស់ព្រះខីណាស្រព ឈ្មោះថា សមុច្ឆេទមរណៈ ។ សម្មតិមរណៈ និងសមុច្ឆេទមរណៈក្រៅពីនេះ វៀរ សម្មតិមរណៈ ដែលមានក្នុងលទ្ធិខាងក្រៅ និងសមុច្ឆេទមរណៈ លោកសង្គ្រោះដោយការកាត់ផ្តាច់នូវការពាក់ព័ន្ធ តាមដែលពោលហើយនោះឯង ។ មរណៈ ឈ្មោះថា ទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ ទើបលោកពោលគាថានេះថា

> ព្រោះការស្លាប់នេះអត់ធន់មិនបាន កែមិនបាន ជាទីតាំងនៃទុក្ខផ្លូវចិត្តរបស់បុគ្គលអ្នកជិតស្លាប់ដែលជាបុគ្គលថោកទាប ដែលតាមឃើញនិមិត្ត មានកម្មអាក្រក់ជាដើម បុគ្គលជាមនុស្សល្អដែលអត់ធន់មិនបាននូវការព្រាត់ប្រាស ដែលមានវត្ថុស្រឡាញ់ជាទីតាំងដោយមិនផ្សេងគ្នា ឬទុក្ខដែលកើតក្នុងសរីរៈ មានត្រូវខ្យល់ កាត់ទី-ត និងសរសៃជាដើម របស់សត្វទាំងពួងដែលត្រូវចាក់ដោត ហេតុនោះ មរណៈនេះ ទើបព្រះមានព្រះភាគត្រាស់ថា ជាទុក្ខដូចគ្នា ។

ការក្តៅក្រហាយនៃចិត្ត មានការសោកខាងក្នុង ជាលក្ខណៈរបស់បុគ្គលដែលត្រូវសេចក្តីវិនាសនៃញាតិជាដើមពាល់ត្រូវ ឈ្មោះថា **សោក** ក្នុង

ពាក្យថា **សោក** ជាដើម ។ សេចក្ដីសោក ឈ្មោះថា ជាទុក្ខ ព្រោះទុក្ខទុក្ខ និងព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ ទើបលោកពោលថា

សេចក្ដីសោក រមែងចាក់ទម្លុះហទយៈរបស់សត្វទាំងឡាយ ដូចត្រូវកូនសរដែលលាបដោយថ្នាំពិសមុត និងរមែងដុតរោលយ៉ាងខ្លាំងក្លា ដូចលំពែងដែលឆេះដោយភ្លើងមុត សេចក្ដីសោករមែងនាំមកនូវជំងឺតម្កាត់ និងសេចក្ដីទុក្ខច្រើនយ៉ាង មានប្រភេទ គឺការចាស់ និងការស្លាប់ ព្រោះហេតុនោះ ទើបហៅថា ជាទុក្ខ ។

ការកន្ទក់កន្ទេញរបស់បុគ្គល ដែលត្រូវសេចក្ដីវិនាសញាតិជាដើម ពាល់ត្រូវ ឈ្មោះថា បរិទេវៈ ។ បរិទេវៈ ឈ្មោះថា ជាទុក្ខ ព្រោះភាពជាសង្ខារទុក្ខ និងព្រោះជាទីតាំងនៃទុក្ខ ដោយហេតុនោះ ទើបលោកពោលគាថានោះថា

សត្វត្រូវសរ គឺសេចក្ដីសោកមុតហើយខ្សឹកខ្សួល រមែងបានទទួលទុក្ខធ្ងន់ក្រៃលែងឡើង ដែលជាទុក្ខកើតអំពីការស្ងួត-កបបូរមាត់ ពិដានហួសនឹងទ្រាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បរិទេវៈ ជាទុក្ខ ។

ទុក្ខផ្លូវកាយ ដែលមានលក្ខណៈបៀតបៀនកាយ ឈ្មោះថា ទុក្ខ ម្យ៉ាងទៀត ទុក្ខផ្លូវកាយ ឈ្មោះថា ជាទុក្ខ ព្រោះទុក្ខទុក្ខ និងព្រោះនាំមក ជាទុក្ខផ្លូវចិត្ត ដោយហេតុនោះ ទើបលោកពោលគាថានេះថា

ទុក្ខនេះ រមែងបៀតបៀនកាយ និងឲ្យចិត្តកើតទុក្ខខ្លាំងឡើង ព្រោះហេតុនោះ ទើបលោកពោលដោយវិសេសថា ទុក្ខ ។

ទុក្ខផ្លូវចិត្ត មានលក្ខណៈបៀតបៀនចិត្ត ឈ្មោះថា ទោមនស្ស ។ម្យ៉ាង ទៀត ទោមនស្ស ឈ្មោះថា ជាទុក្ខ ព្រោះជាទុក្ខទុក្ខ និងព្រោះនាំមកនូវទុក្ខ ផ្លូវកាយ ។ ពិតហើយ សត្វទាំងឡាយ ដែលបានទទួលទុក្ខផ្លូវចិត្តច្រើន រមែងសោយទុក្ខដ៏ច្រើន ដូចជារំសាយសក់ទួញយំ គក់ទ្រូង បម្រះននៀល ទៅមក បោកខ្លួន ចាប់សស្ត្រា ផឹកថ្នាំពុល ចង-ក លោតចូលគំនរភ្លើង ដោយហេតុនោះ ទើបលោកពោលគាថានេះថា

ព្រោះទោមនស្សបៀតបៀនចិត្ត រមែងនាំនូវការបៀតបៀនផ្លូវ
កាយមកទៀត ព្រោះហេតុនោះ ទើបបុគ្គលដែលប្រាសចាក
ទោមនស្ស ហៅទោមនស្សថា ជាទុក្ខ ។

ទោសៈនោះឯង ធ្វើឲ្យកើតទុក្ខផ្លូវចិត្តយ៉ាងក្រៃលែង របស់បុគ្គលដែល ត្រូវសេចក្ដីវិនាសញាតិជាដើមពាល់ត្រូវ ឈ្មោះថា ឧបាយាស ។ អាចារ្យ ពួកខ្លះពោលថា ឧបាយាសជាធម៌មួយដែលទាក់ទងដោយសង្ខារក្ខន្ធ ។ ឧបាយាស ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ព្រោះដុតរោលចិត្ត និងព្រោះការ លំបាកផ្លូវកាយ ដោយហេតុនោះ ទើបលោកពោលគាថានេះថា

ឧបាយាស រមែងធ្វើទុក្ខដ៏ពន្លឹកឲ្យកើត ព្រោះដុតរោលចិត្ត
និងព្រោះធ្វើកាយឲ្យលំបាក ព្រោះហេតុនោះ ទើបលោក
ពោលថា ឧបាយាស ជាទុក្ខ ។

មួយទៀត ក្នុងបទថា សោក បរិទេវ និងឧបាយាសនេះ គប្បីឃើញថា សោក ដូចទឹកក្ដៅនៅក្នុងភាជនៈដែលដុតភ្លើងតិចៗ គប្បីឃើញបរិទេវៈ ដូច

ទឹកក្តៅដែលផុលចេញអំពីកាជនៈ ដែលដុតភ្លើងខ្លាំង គប្បីឃើញឧបាយាស ដូចទឹកក្តៅដែលរីងស្ងួត ខាងក្នុងកាជនៈនោះឯង នៃទឹកដែលសល់អំពីផុលចេញ រហូតមិនអាចផុលចេញទៀត ។

ការនៅរួមជាមួយសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ ឈ្មោះថា អប្បិយសម្បយោគ ។ អប្បិយសម្បយោគ ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ ទើបលោកពោលគាថានេះថា

ទុក្ខដំបូង រមែងកើតក្នុងចិត្ត ព្រោះជួបប្រសព្វសត្វ និងសង្ខារ
មិនជាទីស្រឡាញ់ បន្ទាប់មក ទុក្ខដែលកើតព្រោះការប្រទូស្ត
រមែងមានក្នុងកាយនេះ ព្រោះហេតុនោះ ការនៅរួមជាមួយ
សត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ គប្បីជ្រាបថា ព្រះ
មានព្រះភាគ អ្នកស្វែងរកគុណធំ ត្រាស់ថា ជាទុក្ខ ព្រោះ
ជាទីតាំងនៃទុក្ខទាំងពីរ ។

ការព្រាត់ប្រាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ ឈ្មោះថា បិយវិប្បយោគ ។ បិយវិប្បយោគ ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ ទើបលោកពោលគាថានេះថា

បុគ្គលពាលទាំងឡាយ ប្រកបព្រមដោយសរ គឺសេចក្តីសោក
ព្រោះការព្រាត់ប្រាសចាកញាតិ និងសម្បត្តិជាដើម រមែងឈឺ
ចាប់ ព្រោះហេតុនោះ បិយវិប្បយោគនេះ ហៅថា ជាទុក្ខ ។

ក្នុងការមិនបានសមតាមសេចក្តីប្រាថ្នា គប្បីជ្រាបសេចក្តីដូចតទៅ

ការប្រាថ្នាក្នុងវត្ថុដែលមិនគប្បីបាន លោកពោលថា **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ** អធិប្បាយថា បុគ្គលកាលប្រាថ្នាដោយធម៌ក្នុងវត្ថុដែលមិនគប្បីបាន ក៏មិនបាន ការប្រាថ្នាក្នុងវត្ថុដែលមិនគប្បីបាននោះ ក៏ជាទុក្ខ ។ ការមិនបានសមតាមសេចក្តីប្រាថ្នា ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ ទើបលោកពោលគាថានេះថា

ទុក្ខដែលអំពីការអាក់អន់ រមែងកើតដល់សត្វទាំងឡាយ ក្នុងលោកនេះ ដោយមិនបានវត្ថុនោះៗ តាមប្រាថ្នា ព្រោះសេចក្តីប្រាថ្នាក្នុងវត្ថុដែលមិនគប្បីបាន ជាហេតុនៃទុក្ខនោះ ហេតុនោះទើបព្រះជិនស្រីត្រាស់ដល់ការមិនបានតាមប្រាថ្នាថា ជាទុក្ខ ។

ក្នុងបទថា **សង្ខិត្តេន បញ្ចុបាទានក្ខន្ធា** មានអធិប្បាយដូចតទៅនេះ បទថា **សង្ខិត្តេន** លោកពោលសំដៅដល់ទេសនា ។ ព្រោះបុគ្គលណាមួយមិនអាចសង្ខេបទុក្ខបានថា ទុក្ខមានប្រមាណមួយរយ ទុក្ខមានប្រមាណមួយពាន់ តែទេសនាអាចសង្ខេបបាន ។ ព្រោះហេតុនោះ កាលព្រះមានព្រះភាគទ្រង់សង្ខេបទេសនា ទើបត្រាស់យ៉ាងនេះថា ឈ្មោះថា ទុក្ខ មិនមែនវត្ថុដទៃណាទេ ដោយសង្ខេប ឧបាទានក្ខន្ធ ៥ ជាទុក្ខ ។

បទថា **បញ្ច** ជាពាក្យកំណត់ចំនួន ។ បទថា **ឧបាទានក្ខន្ធា** បានដល់ខន្ធដែលជាអារម្មណ៍របស់ឧបាទាន ។

ព្រះមានព្រះភាគជាតាទិបុគ្គល ត្រាស់ដល់ទុក្ខ មានជាតិជាដើមមិនត្រាស់ដល់ទុក្ខទាំងអស់ ក្រៅអំពីទុក្ខនេះហើយ ទុក្ខដទៃក៏

នៅមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ជាអ្នកស្វែងរកគុណធំ ទ្រង់សម្ដែងទីបំផុតរបស់ទុក្ខថា ដោយសង្ខេបឧបាទានក្ខន្ធទាំងនេះ ជាទុក្ខ ។

ពិតហើយ ជាតិជាដើមបៀតបៀនឧបាទានក្ខន្ធ ៥ នោះឯង ដោយប្រការផ្សេងៗ ដូចភ្លើងឆេះកំញម ដូចគ្រឿងប្រហារទម្លាយក្ដារបាយ ដូចរបោម និងមូសជាដើមខាំគោ ដូចអ្នកប្រូតស្រូវទម្លាយស្រែ ដូចចោរប្លន់អ្នកស្រុកទម្លាយអ្នកស្រុក រមែងកើតក្នុងឧបាទានក្ខន្ធនោះឯង ដូចស្មៅ និងវល្លិកើតលើផែនដី ដូចផ្កាឈើ ផ្លែឈើ និងស្លឹកឈើខ្ចី កើតក្នុងដើមឈើ ។

ជាតិជាទុក្ខក្នុងខាងដើមរបស់ឧបាទានក្ខន្ធ ជរាជាទុក្ខក្នុងចំណែកកណ្ដាល មរណៈជាទុក្ខក្នុងទីបំផុត សោកជាទុក្ខត្រូវដុតរោលដោយទុក្ខ ស្មើរតែនឹងស្លាប់បៀតបៀន បរិទេវៈជាទុក្ខដោយការយំរៀបរាប់ ព្រោះអត់ទ្រាំនូវសោកទុក្ខនោះមិនបាន ទុក្ខជាទុក្ខដោយការឈឺចាប់ផ្លូវកាយ ព្រោះប្រសព្វនឹងសម្ផស្សដែលមិនជាទីប្រាថ្នា ពោលគឺជាតុកម្រើក ទោមនស្សជាទុក្ខផ្លូវចិត្ត ព្រោះកើតបដិឃៈក្នុងទុក្ខផ្លូវកាយនោះ របស់បុថុជ្ជន អ្នកត្រូវទុក្ខផ្លូវកាយនោះ បៀតបៀនឧបាយាស ជាទុក្ខ ព្រោះក្រៀមក្រំចិត្តរបស់បុគ្គលដែលតានតឹងចិត្ត ព្រោះសេចក្ដីសោកជាដើម លិចលង់ ។

ការមិនបានតាមសេចក្ដីប្រាថ្នា ជាទុក្ខ ព្រោះបំផ្លាញសេចក្ដីប្រាថ្នារបស់បុគ្គលអ្នកជួបនូវការអស់សង្ឃឹម ឧបាទានក្ខន្ធដែលត្រូវកំណត់ ដោយប្រការផ្សេងៗ ដោយប្រការដូច្នេះ ឈ្មោះថា ទុក្ខ ព្រោះហេតុនោះ កាលសម្ដែងទុក្ខ

នោះមួយបែបៗ ដែលបុគ្គលណាមួយសូម្បីប្រើពេលវេលា អស់ច្រើនកប្ប ក៏មិនអាចពោលឲ្យអស់បាន ។ ដើម្បីសម្ដែងសង្ខេបនូវទុក្ខទាំងនោះ ក្នុងឧបាទានក្ខន្ធ ៥ គ្រប់ចំណែក ដូចសម្ដែងសង្ខេបនូវរសនៃទឹកក្នុងមហាសមុទ្ទ ក្នុងតំណក់តែមួយ ទើបព្រះថេរៈពោលព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគត្រាស់ថា បើពោលដោយបង្រួញ ឧបាទានក្ខន្ធ ៥ ជាទុក្ខ ដូច្នេះ ។

បទថា **តត្ថ កតមា ជាតិ** ជាដើម គប្បីជ្រាបបទភាជនីយដូចតទៅ

បទថា **តត្ថ** បានដល់ ក្នុងជាតិជាដើម ដែលពោលហើយ ក្នុងទុក្ខសច្ច-និទ្ទេស ។

បទថា **យា តេសំ តេសំ សត្តានំ** ជាពាក្យសម្ដែងទូទៅដល់សត្វជាច្រើនដោយសង្ខេប ។ កាលបើពោលយ៉ាងនេះ អស់មួយថ្ងៃថា ជាតិរបស់ទេវទត្ត ជាតិរបស់សោមទត្ត សត្វទាំងឡាយក៏មិនអស់ទៅ ការសម្ដែងសេចក្ដីដទៃទៀតទាំងអស់ ក៏មិនសម្រេចផល តែដោយបទពីរនេះ សត្វណាៗ មួយ ដែលមិនកំណត់ទុកមិនមាន ការសម្ដែងសេចក្ដីដទៃទៀតណាមួយមិនសម្រេចក៏មិនមាន ។

បទថា **តម្ហិ តម្ហិ** នេះ ជាពាក្យសម្ដែងទូទៅដល់ពួកសត្វជាច្រើនដោយគតិ និងជាតិ ។

បទថា **សត្តនិកាយេ** បានដល់ ក្នុងពួកសត្វទាំងឡាយ អធិប្បាយថា ក្នុងជំនុំសត្វ គឺក្នុងទីប្រជុំសត្វ ។

*បទថា* ***ជាតិ*** *លោកពោលដោយអំណាចនៃការកើត ។ បទនេះ ក្នុងទីនេះ ជាបឋមាវិកត្តិ ចុះក្នុងអត្ថសត្តមី ។*

*បទថា* ***សញ្ជាតិ*** *ពោលដោយអំណាចការកើតព្រម ។ បទនេះ លោកបន្ថែមឧបសគ្គ ។*

*បទថា* ***ឱក្កន្តិ*** *ពោលដោយអំណាចការឈានចុះ ។ម្យ៉ាងទៀត ឈ្មោះថា* ***ជាតិ*** *ដោយអត្ថថា កើត លោកពោលការកើតនោះដោយអាយតនៈនៅមិនទាន់បរិបូរណ៍ ។ ឈ្មោះថា* ***សញ្ជាតិ*** *ដោយអត្ថថា កើតព្រម លោកពោលការកើតព្រមនោះ ដោយអាយតនៈដែលបរិបូរណ៍ហើយ ។ ឈ្មោះថា* ***ឱក្កន្តិ*** *ដោយអត្ថថា ឈានចុះ លោកពោល* ***ឱក្កន្តិ*** *នោះ ដោយអំណាចរបស់អណ្ឌជៈ ( កើតក្នុងស៊ុត ) និងជលាពុជៈ ( កើតក្នុងផ្ទៃ ) ព្រោះថា សត្វទាំងនោះឈានចុះកាន់សម្បកស៊ុត និងស្បូន ។ សត្វឈានចុះរមែងបដិសន្ធិ ដូចចូលទៅ ។ ឈ្មោះថា* ***អភិនិព្វត្តិ*** *ដោយអត្ថថា ការកើតឡើង លោកពោល* ***អភិនិព្វត្តិ*** *នោះ ដោយអំណាចនៃសំសេទជៈ ( កើតពីញើសក្អែល ) និងឱបបាតិកៈ ( ឧប្បត្តិកឡើង ) ព្រោះសត្វទាំងនោះ ជាអ្នកប្រាកដកើតឡើងនេះ ជាសម្មតិកថា ។*

*ឥឡូវនេះ នឹងពោលដោយបរមត្ថ បទថា* ***ខន្ធានំ ធាតុភាវោ អាយតនានំ បដិលាភោ*** *ព្រោះថា ដោយបរមត្ថ ខន្ធនោះឯងប្រាកដ មិនមែនសត្វប្រាកដ ។ ក្នុងបទទាំងនេះ បទថា* ***ខន្ធានំ*** *គប្បីជ្រាបការកាន់យកខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព ខន្ធ ៥ ក្នុងបញ្ចវោការភព ។ បទ*

ថា **ធាតុភាវោ** បានដល់ ការកើតឡើង ។ បទថា **អាយតនានំ** គប្បីជ្រាប ការសង្គ្រោះដោយអំណាចអាយតនៈដែលកើតឡើងក្នុងភពនោះៗ ។

បទថា **បដិលាភោ** បានដល់ ការប្រាកដក្នុងការបន្ត ព្រោះថា អាយតនៈទាំងនោះ ដែលប្រាកដឡើងនោះឯង ឈ្មោះថា បានចំពោះហើយ ។

បទថា **អយំ វុច្ចតិ ជាតិ** បានដល់ នេះលោកពោលថា ជាតិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងជរានិទ្ទេសដូចតទៅនេះ បទថា **ជរា** ជាបឋមាវិភត្តិ ចុះក្នុងអត្ថសភាវៈ ។ បទថា **ជីរណតា** ជាការសម្តែងអាការ ។

បីបទ មានបទថា **ខណ្ឌិច្ចំ** ជាដើម ជាពាក្យសម្តែងកិច្ចដែលប្រាកដក្នុងខណៈកន្លងកាល កន្លងវ័យ ពីរបទក្រោយជាពាក្យសម្តែងការប្រក្រតី ។ ពិតហើយ ពាក្យនេះ លោកសម្តែងតាមសភាវៈដោយបទថា **ជរា**។ ព្រោះហេតុនោះ បទថា **ខណ្ឌិច្ចំ** នេះ ទើបជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃសភាវៈរបស់ជរានោះ ។

ដោយបទថា **ជីរណតា** នេះ លោកសម្តែងដោយអាការ ដោយហេតុនោះ ទើបបទនេះ ជាការសម្តែងអាការរបស់ជរានោះ ។

ដោយបទថា **ខណ្ឌិច្ចំ** នេះ លោកសម្តែងដោយកិច្ច គឺការដែលធ្មេញនិងក្រចកបាក់ក្នុងពេលកន្លងកាល កន្លងវ័យទៅ ។

ដោយបទថា **បាលិច្ចំ** នេះ លោកសម្តែងដោយកិច្ច គឺសភាពដែលសក់និងរោមទាំងឡាយស្កូវ ។

ដោយបទថា **វលិត្តចតា** នេះ លោកសម្តែងដោយកិច្ច គឺភាពដែលសាច់

*រីងស្ងួតហើយស្បែកជ្រីវជ្រួញ ព្រោះហេតុនោះ ៣ បទ របស់ជរានោះ ទើបជាការសម្ដែងដល់កិច្ច ក្នុងខណៈពេលវេលាកន្លងហួសទៅ ។ ដោយបទទាំង ៣ នោះ លោកសម្ដែងដល់ជរាដែលប្រាកដ ដែលឃើញបានច្បាស់ ដោយសម្ដែងភាពខុសប្រក្រតីទាំងនេះ ។ ផ្លូវទៅរបស់ជរាប្រាកដ ក្នុងធ្មេញជាដើម ដោយភាពជាអ្នកមានធ្មេញបាក់ជាដើម សូម្បីបិទភ្នែកក៏ដឹងបាន តែការចាស់នៃភាពជាអ្នកមានធ្មេញបាក់ជាដើម ដឹងមិនបាន ព្រោះជរាមិនគប្បីដឹងបានដោយភ្នែក ដូចផ្លូវទៅរបស់ទឹក ខ្យល់ ឬភ្លើង រមែងប្រាកដ ដ្បិតស្មៅ និងដើមឈើជាដើមបាក់គល់ ឬត្រូវភ្លើងឆេះ តែផ្លូវទៅនោះ មិនមែនទឹកជាដើមនោះឡើយ ។*

*ដោយបទទាំងនេះថា* **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** *លោកសម្ដែងតាមប្រក្រតី ពោល គឺការអស់ទៅនៃអាយុ និងការចាស់នៃឥន្ទ្រិយ ព្រោះអាយុវិនាសក្រៃលែងក្នុងខណៈពេលវេលាកន្លងទៅ ព្រោះហេតុនោះគប្បីជ្រាបថា បទទាំងពីរនេះ ជាការសម្ដែងភាពជាប្រក្រតីនៃជរានោះ ។*

*ក្នុងបទទាំងពីរនោះ ព្រោះអាយុរបស់អ្នកដល់ជរារមែងវិនាស ហេតុនោះទើបលោកពោលជរាដោយផលូបចារន័យ ដោយន័យបញ្ចាញផលថា* **អាយុ-នោ សំហានិ** *ការវិនាសនៃអាយុ ដូច្នេះ ។ មួយទៀត ក្នុងវេលាជាកំលោះឥន្ទ្រិយមានចក្ខុជាដើម ភ្លឺថ្លា អាចទទួលវិស័យរបស់ខ្លួន សូម្បីល្អិតសុខុមបានដោយងាយ សម្រាប់បុគ្គលដែលដល់ជរាហើយ ក៏ចាស់ ល្អក់កករ មិនស្រស់ថ្លា មិនអាចទទួលវិស័យរបស់ខ្លួន ដែលគ្រោតគ្រាតបាន ព្រោះហេតុ*

នោះ ទើបលោកពោលដោយបង្ហាញផលថា **ឥន្ទ្រិយានំ បរិចារកោ** ដូច្នេះ ។

លោកចង្អុលបង្ហាញជវៈយ៉ាងនេះ សូម្បីជវៈទាំងអស់ក៏មាន ២ យ៉ាង គឺជវៈប្រាកដ ១ ជវៈកំបាំង ១ ។ ក្នុងជវៈទាំងនោះ ជវៈក្នុងរូបធម៌ មានធ្មេញជាដើម ឈ្មោះថា ជវៈប្រាកដ ព្រោះសម្តែងភាពដែលធ្មេញបាក់ជាដើម ចំណែកជវៈក្នុងអរូបធម៌ ឈ្មោះថា ជវៈកំបាំង ព្រោះមិនសម្តែងការខុសប្រក្រតីបែបនោះ ។

ក្នុងជវៈនោះ សភាពដែលធ្មេញបាក់ជាដើម រមែងប្រាកដជាលក្ខណៈរបស់ធ្មេញជាដើមនោះឯង ។ បុគ្គលឃើញធ្មេញបាក់ជាដើមនោះដោយភ្នែក ហើយគិតដោយមនោទ្វារ ទើបដឹងជវៈថា ធ្មេញទាំងនេះត្រូវជវៈបំផ្លាញហើយ ដូចសម្លឹងមើលស្នែងគោជាដើម ដែលគេព្យួរក្នុងកន្លែងមានទឹក ក៏ដឹងថាខាងក្រោមមានទឹក ។ នៅមានជវៈផ្សេង ២ យ៉ាងទៀត គឺសវីចិជវៈ ជវៈដឹងបានងាយ ១ អវីចិជវៈ ជវៈដឹងបានលំបាក ១ ។ ក្នុងជវៈ ២ យ៉ាងនោះ ជវៈឈ្មោះថា អវីចិជវៈ ព្រោះដឹងការខុសគ្នានៃលក្ខណៈក្នុងចន្លោះៗ មានកែវមណីមាស ប្រាក់ កែវប្រពាល ព្រះចន្ទ ព្រះអាទិត្យជាដើម បានដោយលំបាក ដូចដឹងសត្វមានជីវិតក្នុងជំពូកមនុស្សសកៈ ( វ័យទន់ខ្សោយ ១០ ឆ្នាំ ) ជាដើមបានដោយលំបាក និងដូចដឹងវត្ថុដែលមិនមានជីវិត ក្នុងជំពូកផ្កាឈើ ផ្លែឈើ និងស្លឹកឈើជាដើម បានដោយលំបាក ដូច្នោះ ។ អធិប្បាយថា បានដល់និរន្តរជវៈ គឺជវៈជាប់បន្តគ្នាទៅ ។ ជវៈ ឈ្មោះថា សវីចិជវៈ ព្រោះដឹងការផ្សេងគ្នានៃលក្ខណៈជាដើម ក្នុងចន្លោះៗ ក្នុងវត្ថុដទៃក្រៅអំពីដែលពោលហើយ

នោះបានឆាយ ។

ក្នុងជរា ២ យ៉ាងនោះ សវីចិជរា គប្បីជ្រាបដោយអំណាចនៃឧបាទិន្នកៈ និងអនុបាទិន្នកៈយ៉ាងនេះថា ធ្មេញទឹកដោះ រមែងដុះឡើងដល់ក្មេងតូចជាគ្រាដំបូង តែធ្មេញទឹកដោះទាំងនោះមិនមាំទាំ ។ កាលណាធ្មេញទឹកដោះនោះ បាក់អស់ទៅ ធ្មេញថ្មីក៏ដុះឡើងទៀត ធ្មេញទាំងនោះដំបូងមានពណ៌ស កាលបើត្រូវខ្យល់ជរាប៉ះពាល់ក៏ប្រែទៅជាពណ៌ខ្មៅ ។ សក់គ្រាដំបូងមានពណ៌ក្រហមតពីនោះក៏ជាពណ៌ខ្មៅ ក្រោយមកក៏ជាពណ៌ស ។ សម្បុរក៏មានពណ៌ក្រហមព្រឿងៗ ។ កាលណាចម្រើនឡើងៗ ចំណែកនៃពណ៌សក៏ស ចំណែកពណ៌ខ្មៅក៏ប្រាកដជាពណ៌ខ្មៅ កាលណាត្រូវខ្យល់ជរាប៉ះខ្ទប់ ក៏មានស្នាមជ្រួញ ។ សំណាបក្នុងពេលព្រោះក៏មានពណ៌ស ក្រោយមកមានពណ៌ខៀវ កាលណាត្រូវខ្យល់ជរាប៉ះខ្ទប់ហើយ ក៏ជាពណ៌លឿង ។ គួរសម្តែងដល់ សូម្បីពូជស្វាយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមរណនិទ្ទេសដូចតទៅនេះ បទថា **ចុតិ** លោកពោលដោយអំណាចការឃ្លាតទៅ ។ បទនេះ ជាពាក្យពោលដល់ភាពស្មើគ្នានៃខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ។

បទថា **ចវនតា** ជាពាក្យចង្អុលដល់លក្ខណៈដែលពោលដល់ភាវៈ ។

បទថា **ភេទោ** ជាពាក្យសម្តែងដល់ការកើត ការរលត់នៃខន្ធដែលចុតិ ។

បទថា **អន្តរធានំ** ជាពាក្យសម្តែងដល់ការមិនមានទីតាំងដោយបរិយាយណាមួយនៃខន្ធដែលចុតិ ដែលបែកធ្លាយហើយ ដូចក្អមដែលបែក ។

បទថា **មច្ចុ មរណំ** បានដល់ សេចក្ដីស្លាប់ ពោល គឺដល់នូវការស្លាប់ មិនមែនស្លាប់មួយជួរខណៈ ។ មច្ចុដែលធ្វើនូវទីបំផុត ឈ្មោះថា **កាល** ការធ្វើកាលកិរិយានោះ ព្រោះហេតុនោះ ឈ្មោះថា **កាលកិរិយា** ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ លោកសម្ដែងដល់សេចក្ដីស្លាប់ដោយសន្មត ។

ឥឡូវនេះ ដើម្បីសម្ដែងដោយបរមត្ថ ទើបព្រះមានព្រះភាគត្រាស់ថា **ខន្ធានំ ភេទោ** ជាដើម ។ ពិតហើយ ដោយបរមត្ថ ខន្ធប៉ុណ្ណោះបែកធ្លាយ មិនមានសត្វណាមួយស្លាប់ ។ កាលខន្ធបែកធ្លាយ សត្វក៏ស្លាប់ កាលខន្ធបែកធ្លាយហើយទើបមានពាក្យពោលថា សត្វស្លាប់ហើយ ។ ក្នុងបទនេះ គប្បីជ្រាបការបែកធ្លាយនៃខន្ធ ដោយអំណាចនៃភពដែលមានខន្ធ ៤ និងខន្ធ ៥ គប្បីជ្រាបការដាក់ចុះនូវសាកសពដោយអំណាចនៃភពដែលមានខន្ធ ១ ។ ម្យ៉ាងទៀត គប្បីជ្រាបការបែកធ្លាយទៅនៃខន្ធ ដោយអំណាចនៃភពដែលមានខន្ធ ៤ គប្បីជ្រាបការដាក់ចុះនូវសាកសពដោយអំណាចនៃភពដែលមានខន្ធ ២ ទៀត ក្នុងភពដ៏សេស ព្រោះហេតុអ្វី ព្រោះសាកសព គឺរូបកាយមានក្នុងភព ២ ។ ម្យ៉ាងទៀត ព្រោះខន្ធសូម្បីក្នុងជាន់ចាតុម្មហារាជិកាក៏នឹងបែកធ្លាយបាន រមែងមិនបន្សល់អ្វីៗ ដូច្នោះ គប្បីជ្រាបការបែកធ្លាយនៃខន្ធ ដោយអំណាចនៃទេវតាទាំងនោះ គប្បីជ្រាបការដាក់ចុះនូវសាកសពក្នុងមនុស្សជាដើម ។ មួយទៀត ក្នុងបទនេះ លោកពោលដល់មរណៈ ព្រោះធ្វើការដាក់ចុះនូវសាកសពថា **កឡេវរស្ស និក្ខេបោ** ដូច្នេះ ។

ដោយបទនេះថា **ជីវិតិន្ទ្រិយស្សុបច្ឆេទោ** លោកសម្ដែងថា ឈ្មោះថា

**មរណា** រមែងមានដល់បុគ្គលដែលមានឥន្ទ្រិយប៉ុណ្ណោះ មិនមានដល់បុគ្គលដែលមិនមានឥន្ទ្រិយ ។ ចំណែកពាក្យថា ស្រូវងាប់ ដើមឈើងាប់ ត្រឹមតែជាវោហារប៉ុណ្ណោះ ។ តែដោយអត្ថ ពាក្យដូចពោលមកនេះ រមែងសម្តែងដល់ការអស់ទៅ និងការវិនាសទៅរបស់ស្រូវជាដើមនោះឯង ។

ម្យ៉ាងទៀត ឈ្មោះថា ជាតិ ជរា មរណៈទាំងនេះ រមែងត្រាច់ស្វែងរកចន្លោះរបស់សត្វទាំងឡាយនេះ ដូចបច្ចាមិត្តអ្នកមានបំណងអាក្រក់ ដូច្នោះ ។ ដូចជាបច្ចាមិត្ត ៣ នាក់ ស្វែងរកឱកាសរបស់បុរស បច្ចាមិត្តម្នាក់ពោលថា យើងនឹងពណ៌នាគុណរបស់ព្រៃឯណោះ ហើយនឹងនាំបុរសនោះទៅកាន់ព្រៃនោះ ខ្ញុំនឹងមិនប្រទូសរ៉ាយក្នុងបុរសនោះឡើយ ។ បច្ចាមិត្តទី ២ ពោលថា ក្នុងវេលាដែលអ្នកនាំបុរសនេះទៅហើយ ខ្ញុំនឹងវាយធ្វើឲ្យអស់កម្លាំង ខ្ញុំមិនធ្វើឲ្យដុនដាបក្នុងបុរសនេះឡើយ ។ បច្ចាមិត្តទី ៣ ពោលថា កាលណាអ្នកវាយធ្វើបុរសនេះឲ្យទុព្វលហើយ ការយកដាវកាត់ក្បាលជាការៈរបស់ខ្ញុំ កាលបច្ចាមិត្តទាំងនោះពោលយ៉ាងនេះហើយ ក៏បានធ្វើតាមនោះ ។

ក្នុងសេចក្តីនោះ មានឧបមាដូចតទៅនេះថា ការប្រាសចេញចាកប្រជុំរបស់សម្លាញ់ និងញាតិហើយឲ្យកើតក្នុងទីណាមួយ ដូចបច្ចាមិត្តទីមួយពណ៌នាគុណរបស់ព្រៃ ហើយនាំបុរសនោះទៅក្នុងព្រៃនោះ គប្បីជ្រាបថាជាកិច្ចរបស់ជាតិ ការជួលចុះក្នុងខន្ធដែលកើតហើយ ធ្វើឲ្យត្រូវអាស្រ័យអ្នកដទៃ និងដេកសម្រាកលើគ្រែ ដូចការវាយរបស់បច្ចាមិត្តទីពីរ ធ្វើឲ្យអស់កម្លាំង គប្បីជ្រាបថាជាកិច្ចរបស់ជរា ។ ការធ្វើឲ្យអស់ជីវិតដូចការដែលបច្ចាមិត្តទីបី យកដាវដ៏មុតកាត់

ក្បាល គប្បីជ្រាបថាជាកិច្ចរបស់មរណៈ ។

ម្យ៉ាងទៀត ក្នុងបទនេះ មានឧបមាដូចតទៅ ជាតិទុក្ខ គប្បីឃើញដូចការចូលទៅកាន់ផ្លូវមហាកន្តារដែលមានទោស ជរាទុក្ខ គប្បីឃើញដូចមនុស្សមិនមានបាយ និងទឹកក្នុងទីនោះ អស់កម្លាំង មរណទុក្ខ គប្បីឃើញដូចជាការដល់នូវសេចក្តីសាបសូន្យ និងសេចក្តីវិនាសដោយសត្វសាហាវជាដើម របស់បុគ្គលដែលអស់កម្លាំង អ្នកអស់សេចក្តីព្យាយាមក្នុងការផ្លាស់ប្តូរឥរិយាបថ ។

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុង **សោកនិទ្ទេស** ដូចតទៅនេះ ឈ្មោះថា **ព្យសន** ព្រោះអត្ថថា ដល់នូវការវិនាស អធិប្បាយថា លះបង់ គឺទម្លាយនូវប្រយោជន៍ ។ សេចក្តីវិនាសនៃញាតិទាំងឡាយ ឈ្មោះថា **ញាតិព្យសនំ** អធិប្បាយថា ការអស់ទៅនៃញាតិ គឺការវិនាសទៅនៃញាតិ ព្រោះចោរភ័យនិងរោគភ័យជាដើម ។ នូវការវិនាសនៃញាតិនោះ ។ បទថា **ផុដ្ឋស្ស** បានដល់ ដែលត្រូវលិចលង់ ត្រូវគ្របសង្កត់ដែលប្រកបព្រម ។ ក្នុងពាក្យដ៏សេស ក៏មានន័យនេះដូចគ្នា ។ តែការផ្សេងគ្នាមានដូចតទៅនេះថា សេចក្តីវិនាសនៃភោគៈទាំងឡាយ ឈ្មោះថា **ភោគព្យសនំ** អធិប្បាយថា ការអស់ទៅនៃសម្បត្តិ គឺការវិនាសនៃភោគៈ ដោយរាជភ័យ និងចោរភ័យជាដើម ។

ការវិនាសគឺរោគ ឈ្មោះថា **រោគព្យសនំ** ។ ពិតហើយ រោគ ឈ្មោះថា **ព្យសន** ព្រោះអត្ថថា ញុំាងការមិនមានរោគឲ្យអន្តរធាន ឲ្យវិនាសទៅ ។ ការវិនាសនៃសីល ឈ្មោះថា **សីលព្យសនំ** បទនេះ ជាឈ្មោះរបស់អ្នកទ្រុស្តសីល ។ ការវិនាស គឺទិដ្ឋិនោះឯង កើតឡើងហើយ ធ្វើសម្មាទិដ្ឋិឲ្យ

វិនាស ឈ្មោះថា **ទិដ្ឋិព្យសនំ** ។

មួយទៀត ក្នុងបទទាំងនេះ បទពីរខាងដើម មិនទាន់ជារបស់ពិត បទបីខាងក្រោយជារបស់ពិត ត្រូវកម្ចាត់ដោយត្រៃលក្ខណ៍ ។ មួយទៀត បីបទដំបូង ជាកុសលក៏មិនមែន ជាអកុសលក៏មិនមែន ។ ពីរបទ គឺ **សីលព្យសនំ** និង **ទិដ្ឋិព្យសនំ** ជាអកុសល ។

បទថា **អញ្ញតរញ្ញតរេន** បានដល់ ការវិនាសណាមួយ បណ្ដាការវិនាសនៃមិត្ត និងអមាត្យជាដើម ដែលខ្ជូនប្រកាន់មាំក្ដី មិនប្រកាន់មាំក្ដី ។

បទថា **សមន្នាគតស្ស** បានដល់ ជាប់តាមជានិច្ច មិនផុតទៅបាន ។

បទថា **អញ្ញតរញ្ញតរេន ទុក្ខធម្មេន** បានដល់ ហេតុឯណានីមួយដែលឲ្យកើតទុក្ខព្រោះសេចក្ដីសោក ។

បទថា **សោកោ** បានដល់ សេចក្ដីសោកដោយអំណាច សេចក្ដីសោកសៅ ។ បទនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃសភាវៈរបស់សេចក្ដីសោក ដែលកើតឡើងដោយហេតុទាំងនោះ ។

បទថា **សោចនា** បានដល់ អាការនៃសេចក្ដីសោក ។

បទថា **សោចិតត្តំ** បានដល់ ភាពជាអ្នកសោក ។ បទថា **អន្តោសោកោ** បានដល់ សេចក្ដីសោកនៅខាងក្នុង ។ បទទីពីរបន្ថែមឧបសគ្គ ។ ពិតហើយ សេចក្ដីសោកនោះ លោកពោលថា **អន្តោសោកោ អន្តោបរិសោកោ** ព្រោះកើតឡើងដូចរីងស្ងួត និងក្រៀមក្រំក្នុងខាងក្នុង ។

បទថា **ចេតសោ បរិជ្ឈាយនា** បានដល់ អាការដុតចិត្ត ។ ពិតហើយ

ព្រោះសេចក្ដីសោក កាលកើតឡើង រមែងដុតចិត្តដូចភ្លើងដុត ។ រមែងធ្វើឲ្យពោលថា ចិត្តរបស់ខ្ញុំត្រូវដុត ពន្លឺណាមួយមិនមានដល់ខ្ញុំឡើយ ។

ចិត្តមានទុក្ខ ឈ្មោះថា **ទុម្មន** ភាពនៃទុម្មនៈនោះឈ្មោះថា **ទោមនស្សំ** ។

ឈ្មោះថា **សោកសល្លំ** បានដល់ កូនសរ គឺសេចក្ដីសោក ដោយអត្ថថា ចូលទៅខាងក្នុង ។

គប្បីជ្រាបក្នុងបរិទេវនិទ្ទេសដូចតទៅនេះ ឈ្មោះថា **អាទេវោ** ព្រោះអត្ថថា ជាហេតុឲ្យយំរកយ៉ាងនេះថា កូនស្រីរបស់ខ្ញុំ កូនប្រុសរបស់ខ្ញុំ ។

ឈ្មោះថា **បរិទេវោ** ព្រោះអត្ថថា ជាហេតុប្រកាសគុណ ហើយយំរៀបរាប់ ។ លោកពោលពីរបទដទៃតមកទៀត ដោយសម្ដែងដល់អាការនៃពីរបទខាងដើមនោះឯង ។ បទថា **វាចា** បានដល់ ពាក្យនិយាយ ។ បទថា **បលាបោ** បានដល់ វាចាដែលឥតប្រយោជន៍ទទេៗ ឈ្មោះថា **វិប្បលាបោ** ព្រោះអត្ថថា រវើរវាយទៅដោយពោលបានបន្តិច ហើយក៏ពោលរឿងដទៃជាដើម ។ បទថា **លាលប្បោ** បានដល់ ពោលហើយពោលទៀត ។ អាការជាទីទួញយំ ឈ្មោះថា **លាលប្បនា** ។ ភាវៈជាទីទួញយំ ឈ្មោះថា **លាលប្បិតត្តំ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទុក្ខនិទ្ទេសដូចតទៅនេះ ឈ្មោះថា **កាយិកំ** ព្រោះអាស្រ័យកាយ ។ ឈ្មោះថា **អសាតំ** ដោយអត្ថថា មិនមានការរីករាយ ។ លោកបដិសេធ ការមិនសប្បាយផ្លូវចិត្ត ដោយបទថា **កាយិកំ** បដិសេធការសប្បាយផ្លូវកាយ ដោយបទថា **អសាតំ** ។ ការមិនសប្បាយ

ផ្លូវកាយនោះឯង ឈ្មោះថា **ទុក្ខំ** ដោយអត្ថថា ដល់នូវសេចក្ដីលំបាក អធិប្បាយថា សេចក្ដីមិនសប្បាយកាយនោះ កើតដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យលំបាក ។ មួយវិញទៀត ឈ្មោះថា **ទុក្ខំ** ព្រោះអត់ទ្រាំបានដោយលំបាក ។

បទថា **កាយសម្ផស្សជំ** បានដល់ កើតព្រោះកាយសម្ផស្ស ។

បទថា **អសាតំ ទុក្ខំ វេទយិតំ** បានដល់ ការសោយអារម្មណ៍ ដែលមិនសប្បាយ មិនមែនសោយអារម្មណ៍ដែលសប្បាយ ការសោយអារម្មណ៍ដែលជាទុក្ខ មិនមែនសោយអារម្មណ៍ដែលជាសុខ ។

បីបទបន្ទាប់មក លោកពោលជាឥត្ថីលិង្គ ។ ក្នុងបទនេះ មានអធិប្បាយយ៉ាងនេះថា កិរិយាសោយអារម្មណ៍ដែលមិនសប្បាយ មិនមែនកិរិយាសោយអារម្មណ៍ដែលសប្បាយ កិរិយាសោយអារម្មណ៍ដែលជាទុក្ខ មិនមែនកិរិយាសោយអារម្មណ៍ដែលជាសុខ ។ គប្បីជ្រាបយោជនាយ៉ាងនេះថា ការសោយអារម្មណ៍ដែលមិនសប្បាយជាទុក្ខផ្លូវកាយឯណា កិរិយាសោយអារម្មណ៍មិនសប្បាយជាទុក្ខ ដែលកើតអំពីកាយសម្ផស្សឯណា នេះហៅថា ទុក្ខ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទោមនស្សនិទ្ទេសដូចតទៅនេះ

ឈ្មោះថា **ទុម្មន** ព្រោះអត្ថថា ចិត្តអាក្រក់ មួយវិញទៀត ឈ្មោះថា **ទុម្មន** ព្រោះអត្ថថា ចិត្តគួរស្អប់ ព្រោះបានទទួលតែអារម្មណ៍អាក្រក់ ភាវៈនៃទុម្មនៈ ឈ្មោះថា **ទោមនស្ស** ។ ឈ្មោះថា **ចេតសិកំ** ព្រោះអាស្រ័យចិត្ត ។ បទថា **ចេតោសម្ផស្សជំ** បានដល់ កើតអំពីសម្ផស្សផ្លូវចិត្ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាយាសនិទ្ទេសដូចតទៅនេះ

*ឈ្មោះថា* **អាយាសោ** *ដោយអត្ថថា ចង្អៀតចង្អល់ចិត្ត ។ បទនេះ ជាឈ្មោះរបស់ការលំបាកផ្លូវចិត្ត ដែលប្រព្រឹត្តទៅក្នុងអាការរាយមាយទៅ និងមិនជួបប្រសព្វអារម្មណ៍ ។ ការចង្អៀតចង្អល់ចិត្តមានកម្លាំង ឈ្មោះថា* **ឧបាយាសោ** ។ *ភាវៈដែលចង្អៀតចង្អល់ចិត្ត ឈ្មោះថា* **អាយាសិតត្តំ** ។ *ភាវៈនៃសេចក្តីទង្គឹះ ឈ្មោះថា* **ឧបាយាសិតត្តំ** ។

*[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បិយសម្បយោគនិទ្ទេសដូចតទៅ*

*បទថា* **ឥធ** *បានដល់ ក្នុងលោកនេះ ។ បទថា* **យស្ស** *កាត់បទជា* **យេ អស្ស** ។ *បទថា* **អនិដ្ឋា** *បានដល់ មិនគួរស្វែងរក ។ ទោះស្វែងរកក៏ដោយ មិនគួរស្វែងរកក៏ដោយ ចូរលើកទុកចុះ ពាក្យនេះ ជាឈ្មោះរបស់អារម្មណ៍ដែលមិនគួរពេញចិត្ត ។ ឈ្មោះថា* **អកន្តា** *ព្រោះអត្ថថា មិនឈានចូលទៅក្នុងចិត្ត ។ ឈ្មោះថា* **អមនាបា** *ព្រោះអត្ថថា មិនឆ្អែតក្នុងចិត្ត ឬមិនធ្វើចិត្តឲ្យចម្រើន ។*

*បទថា* **រូបា** *ជាដើម ជាពាក្យសម្តែងដល់សភាវៈរបស់សង្ខារទាំងនោះ ។ ឈ្មោះថា* **អនត្ថកាមា** *ព្រោះអត្ថថា សង្ស័យ គឺប្រាថ្នារបស់មិនជាប្រយោជន៍ ។*

*ឈ្មោះថា* **អហិតកាមា** *ព្រោះអត្ថថា សង្ស័យ គឺមិនប្រាថ្នាវត្ថុមិនជាប្រយោជន៍ ។*

*ឈ្មោះថា* **អផាសុកាមា** *ព្រោះអត្ថថា សង្ស័យ គឺប្រាថ្នាសេចក្តីមិនសប្បាយ គឺនៅដោយលំបាក ។*

*ឈ្មោះថា* **អយោគក្ខេមកាមា** *ព្រោះអត្ថថា មិនសង្ស័យនូវការក្សេមចាកយោគៈ ៤ គឺការផុតភ័យ ការរួចផុត គឺសង្ស័យប្រាថ្នានូវការវិលវល់ដែលមាន*

ភ័យនៃយោគៈទាំង ៤ នោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងសេចក្ដីនេះយ៉ាងនេះថា ឈ្មោះថា **អនត្ថកាមា** ព្រោះមិនសង្ឃឹមវត្ថុជាប្រយោជន៍ ពោលគឺសេចក្ដីចម្រើននៃសទ្ធាជាដើម និងព្រោះសង្ឃឹមវត្ថុមិនជាប្រយោជន៍ ពោលគឺការវិនាសទៅនៃសទ្ធាជាដើមទាំងនោះៗ ឯង ។ ឈ្មោះថា **អហិតកាមា** ព្រោះមិនសង្ឃឹមប្រយោជន៍ដែលជាឧបាយ ចូលដល់សទ្ធាជាដើម និងព្រោះសង្ឃឹមវត្ថុមិនជាប្រយោជន៍ដែលជាឧបាយ ចូលដល់ការវិនាសសទ្ធាជាដើម ។

ឈ្មោះថា **អផាសុកកាមា** ព្រោះមិនសង្ឃឹម ការនៅសប្បាយ និងព្រោះសង្ឃឹម ការនៅមិនសប្បាយ ។ ឈ្មោះថា **អយោគក្ខេមកាមា** ព្រោះមិនសង្ឃឹមរួចផុតពីភ័យណាៗ និងព្រោះសង្ឃឹមការមានភ័យ ។

បទថា **សង្គតិ** បានដល់ ការទៅជាមួយគ្នា ។ បទថា **សមាគមោ** បានដល់ ការមកជាមួយគ្នា ។ បទថា **សមោធានំ** បានដល់ ការនៅរួមទាំងក្នុងវេលាឈរ វេលាអង្គុយជាដើម ។ បទថា **មិស្សីភាវោ** បានដល់ ការធ្វើកិច្ចទាំងពួងរួមគ្នា ។ បទនេះ យោជនាអធិប្បាយថា ដោយអំណាចសត្វ ។ តែគប្បីកាន់យកកិច្ចដែលបានដោយអំណាចនៃសង្ខារ ។ ការជួបនឹងសត្វ ឬសង្ខារដែលមិនជាទីស្រឡាញ់នោះ ដោយអត្ថ ឈ្មោះថា ធម៌ប្រការមួយមិនមាន លោកហៅថា ទុក្ខ ព្រោះជាទីតាំងនៃទុក្ខ សូម្បី ២ យ៉ាង ដល់សត្វដែលនៅរួមគ្នាជាមួយសត្វ ឬសង្ខារដែលមិនជាទីស្រឡាញ់ត្រឹមតែម្យ៉ាង ។

បិយវិប្បយោគនិទ្ទេស គប្បីជ្រាបដោយន័យផ្ទុយគ្នាជាមួយនឹងការដែលបានពោលហើយ ។ ក្នុងបទថា **មាតា វា** ជាដើម លោកពោលដើម្បីសម្ដែង

ដល់អ្នកសន្សំប្រយោជន៍ដោយសរុប ។

ក្នុងបទទាំងនោះ ឈ្មោះថា **មាតា** ព្រោះអត្ថថា ថ្នាក់ថ្នម ស្រឡាញ់ ។ ឈ្មោះថា **បិតា** ព្រោះអត្ថថា ប្រព្រឹត្តស្រឡាញ់ ។ ឈ្មោះថា **ភាតា** ព្រោះអត្ថថា រមែងសេពគប់ ។ ឈ្មោះថា **ភគិនី** ក៏ដូចគ្នា ។ ឈ្មោះថា **មិត្តា** ព្រោះអត្ថថា ជាទីស្រឡាញ់ ម្យ៉ាងទៀត ឈ្មោះថា **មិត្តា** ព្រោះអត្ថថា ដាក់ទុក គឺទុកចិត្តបានក្នុងអាថ៌កំបាំងទាំងពួង ។ ឈ្មោះថា **អមច្ចា** ព្រោះអត្ថថា រស់នៅជាមួយគ្នាដោយការនៅរួមគ្នា ក្នុងកិច្ចដែលគួរធ្វើ ។ ឈ្មោះថា **ញាតិ** ព្រោះអត្ថថា ដឹង គឺយល់យ៉ាងនេះថា បុគ្គលនេះជាមនុស្សខាងចំណែកយើង ។ ឈ្មោះថា **សាលោហិតា** ព្រោះអត្ថថា ទាក់ទងគ្នាខាងខ្សែស្រឡាយ ។ **ញាតិ** គឺមនុស្សខាងបិតា **សាលោហិត** គឺមនុស្សខាងមាតា ។ ម្យ៉ាងទៀត **ញាតិ** គឺមនុស្សខាងមាតាបិតា **សាលោហិត** គឺមនុស្សខាងឪពុកក្មេក ម្ដាយក្មេក ។ ការព្រាត់ប្រាសចាកសត្វ ឬសង្ខារដែលជាទីស្រឡាញ់នេះ ដោយអត្ថ ឈ្មោះថា ធម៌ប្រការមួយរមែងមិនមាន លោកពោលថា ទុក្ខ ព្រោះជាទីតាំងនៃទុក្ខសូម្បី ២ យ៉ាងដល់សត្វដែលព្រាត់ប្រាសចាកសត្វ ឬសង្ខារដែលជាទីស្រឡាញ់ត្រឹមតែម្យ៉ាង ។ ពាក្យនេះ ក្នុងទីនេះ ជាពាក្យក្នុងអដ្ឋកថាគ្រប់អន្លើ ។ តែគួរពោលថា វត្ថុដែលមិនជាទីស្រឡាញ់ និងជាទីស្រឡាញ់ លោកឲ្យពិសេសឡើងទៀត ដោយពាក្យថា ការជួប និងពាក្យថា ការព្រាត់ប្រាស ព្រោះសច្ចធម៌ទាំងឡាយ មានលក្ខណៈជារបស់ពិត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឥច្ឆិតាលាភនិទ្ទេស ដូចតទៅនេះ បទថា **ជាតិ-**

**ធម្មានំ** បានដល់ មានការកើតជាធម្មតា គឺមានការកើតជាប្រក្រតី ។ បទថា **ឥច្ឆា ឧប្បជ្ជតិ** បានដល់ មានតណ្ហាកើតឡើង ។ បទថា **អហោ វត** បានដល់ សេចក្តីប្រាថ្នា ។

បទថា **អស្សាម** បានដល់ គប្បីកើត ។ បទថា **ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ** បានដល់ ការមិនកើតជាធម្មតាដែលមាននៅក្នុងសាធុជន ដែលលះសមុទយៈបានហើយ ការមិនមកនៃជាតិដែលមានក្នុងលោកអ្នកបរិនិព្វានហើយ ដែលបុគ្គលប្រាថ្នាយ៉ាងនេះថា សូមយើងទាំងឡាយ កុំមានជាតិជាធម្មតា ជាតិកុំមកដល់យើងទាំងឡាយឡើយ នុះរមែងមិនកើតជាធម្មតាជាដើម ឈ្មោះថា មិនគប្បីដល់ដោយការប្រាថ្នាព្រោះវៀរមគ្គភាវនា ក៏មិនគប្បីដល់ សូម្បីដល់អ្នកប្រាថ្នាព្រោះគប្បីដល់បានដោយភាវនា សូម្បីដល់បុគ្គលដែលមិនប្រាថ្នា ។

បទថា **ឥទម្បិ** គឺ **ឯតម្បិ** ។ **អបិ** សព្ទ សំដៅដល់ពាក្យដែលសល់ខាងមុខ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាទានក្ខន្ធនិទ្ទេសដូចតទៅនេះ បទថា **សេយ្យថីទំ** ជានិបាត សេចក្តីនៃបទនោះថា ប្រសិនបើសួរថា ឧបាទានក្ខន្ធទាំងនោះដូចម្តេច ឆ្លើយថា ឧបាទានក្ខន្ធ គឺរូប ព្រោះហេតុនោះ ទើបឈ្មោះថា **រូបូបាទានក្ខន្ធោ** ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

**អដ្ឋកថាទុក្ខសច្ចនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ៨៣ ] បណ្តាអរិយសច្ចទាំងនោះ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ តណ្ហាណាជាកិលេសជាតិ នាំសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយនន្ទិរាគ ត្រេកត្រអាលក្នុងអារម្មណ៍នោះៗ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហានោះឯង កាលកើតឡើង តើកើតឡើងក្នុងអារម្មណ៍ណា កាលជាប់នៅ តើជាប់នៅក្នុងអារម្មណ៍ណា អារម្មណ៍ណា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើងក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ កាលជាប់នៅក៏ជាប់នៅក្នុងអារម្មណ៍នុ៎ះ ចុះអារម្មណ៍ដូចម្តេច មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក ចក្ខុមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតឡើងក្នុងចក្ខុនុ៎ះ កាលជាប់នៅ រមែងជាប់នៅក្នុងចក្ខុនុ៎ះ សោតៈក្នុងលោក ឃានៈក្នុងលោក ជិវ្ហាក្នុងលោក កាយក្នុងលោក មនៈមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងសោតៈជាដើមនុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងសោតៈជាដើមនុ៎ះ រូបទាំងឡាយ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងរូបនុ៎ះ កាលជាប់នៅក៏ជាប់នៅក្នុងរូបនុ៎ះ សទ្ទៈក្នុងលោក ។បេ។ ធម្មារម្មណ៍ក្នុងលោក ចក្ខុវិញ្ញាណក្នុងលោក ។បេ។ មនោ-វិញ្ញាណក្នុងលោក ចក្ខុសម្ផស្សក្នុងលោក ។បេ។ មនោសម្ផស្សក្នុងលោក វេទនាកើតអំពីចក្ខុសម្ផស្សក្នុងលោក ។បេ។ វេទនាកើតអំពីមនោសម្ផស្សក្នុងលោក រូបសញ្ញាក្នុងលោក ។បេ។ ធម្មសញ្ញាក្នុងលោក រូបសញ្ចេតនា ក្នុង

លោក ។បេ។ ធម្មសញ្ចេតនាក្នុងលោក រូបតណ្ហាក្នុងលោក ។បេ។ ធម្ម-តណ្ហាក្នុងលោក រូបវិតក្កក្នុងលោក ។បេ។ ធម្មវិតក្កក្នុងលោក រូបវិចារក្នុងលោក ។បេ។ ធម្មវិចារមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងសន្ទារម្មណ៍ជាដើមនុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងសន្ទារម្មណ៍ជាដើមនុ៎ះ នេះលោកហៅថា ទុក្ខ-សមុទយអរិយសច្ច ។

# អដ្ឋកថា

## សមុទយសច្ចនិទ្ទេស

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមុទយសច្ចនិទ្ទេសដូចតទៅនេះ បទថា **យាយំ តណ្ហា** បានដល់ តណ្ហានេះឯណា ។ បទថា **ពោនោព្ភវិកា** មានវិគ្គហៈថា ការធ្វើភពថ្មី ឈ្មោះថា **បុនព្ភវ** ឈ្មោះថា **ពោនោព្ភវិកា** ព្រោះអត្ថថា តណ្ហាមានការធ្វើភពថ្មីជាប្រក្រតី ។ មួ៉ាងទៀត ឈ្មោះថា **ពោនោព្ភវិកា** ព្រោះអត្ថថា រមែងឲ្យភពថ្មី រមែងប្រព្រឹត្តទៅក្នុងភពថ្មី រមែងឲ្យកើតភពរឿយៗ ។ តណ្ហានោះឲ្យភពថ្មីក៏មាន មិនឲ្យភពថ្មីក៏មាន ឲ្យប្រព្រឹត្តទៅក្នុងភពថ្មីក៏មាន មិនឲ្យប្រព្រឹត្តទៅក្នុងភពថ្មីក៏មាន ។ កាលឲ្យបដិសន្ធិហើយ តណ្ហាក៏ត្រឹមតែជាការឲ្យផលក្នុងខន្ធដែលកើតហើយ ។ តណ្ហាទាំង ៣ ប្រការនោះ រមែងបានឈ្មោះថា **ពោនោព្ភវិកា** ។ បាឋៈថា **ពោនព្ភវិកា** ក៏មាន ឯសេចក្តីក៏ដូចគ្នា ។

ឈ្មោះថា **នន្ទិរាគសហគតា** ព្រោះអត្ថថា តណ្ហាសហគតៈដោយនន្ទិរាគៈ ពោល គឺសេចក្តីពេញចិត្តដ៏ក្រៃលែង មានពាក្យអធិប្បាយថា តណ្ហាដល់នូវភាពតែមួយ ដោយអត្ថ ជាមួយនន្ទិរាគៈ ។

បទថា **តត្រ តត្រាភិនន្ទិនី** សេចក្តីថា តណ្ហាត្រេកអរក្រៃលែងក្នុងភពដែលអត្តភាពកើត ឬត្រេកអរក្នុងអារម្មណ៍នោះៗ មានរូបជាដើម អធិប្បាយថា ត្រេកអរក្រៃលែងក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ។ បាឋៈថា **តត្រ តត្រាភិនន្ទី** ក៏មានសេចក្តីថា ឲ្យត្រេកអរក្រៃលែងក្នុងអារម្មណ៍នោះៗ ។

*បទថា* **សេយ្យថីទំ** *ជានិបាត សេចក្ដីនៃបទនោះថា ប្រសិនបើសួរថា តណ្ហានោះដូចម្ដេច ។*

*បទថា* **កាមតណ្ហា** *បានដល់ តណ្ហាក្នុងកាម បទនេះ ជាឈ្មោះនៃរាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។*

*បទថា* **ភវតណ្ហា** *បានដល់ តណ្ហាក្នុងភព ។ បទនេះ ជាឈ្មោះរបស់រាគៈដែលសហគតៈដោយសស្សតទិដ្ឋិ ដែលកើតឡើងដោយសេចក្ដីប្រាថ្នាក្នុងភព គឺរាគៈក្នុងរូបភព អរូបភព និងសេចក្ដីជាប់ចិត្តក្នុងឈាន ។*

*បទថា* **វិភវតណ្ហា** *បានដល់ តណ្ហាក្នុងវិភវៈ គឺប្រាសចាកភព ។ បទនេះ ជាឈ្មោះរបស់រាគៈដែលសហគតៈដោយឧច្ឆេទទិដ្ឋិ ។*

*ឥឡូវនេះ ដើម្បីសម្ដែងទីកើតរបស់តណ្ហានោះដោយពិស្ដារ ទើបព្រះថេរៈពោលថា* **សា ខោ បនេសា** *ជាដើម ។*

*ក្នុងបទទាំងនោះ បទថា* **ឧប្បជ្ជតិ** *បានដល់ កើត ។ បទថា* **និវិសតិ** *បានដល់ តាំងនៅដោយអំណាចប្រព្រឹត្តទៅរឿយៗ គប្បីជ្រាបការភ្ជាប់សេចក្ដីថា តណ្ហា កាលកើត រមែងកើតក្នុងទីណា កាលតាំងនៅ រមែងតាំងនៅក្នុងទីណា ។*

*បទថា* **យំ លោកេ បិយរូបំ សាតរូបំ** *បានដល់ វត្ថុណាមានសភាពគួរស្រឡាញ់ និងមានសភាពផ្អែមល្ហែមក្នុងលោក ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទ មានថា* **ចក្ខុ លោកេ** *ជាដើមដូចតទៅ សត្វទាំងឡាយដែលប្រកាន់មាំដោយភាពជារបស់អញ ក្នុងចក្ខុជាដើម ក្នុងលោក តាំងនៅក្នុងវត្ថុដែលដល់ព្រម រមែងសម្គាល់បសាទទាំង ៥ គឺចក្ខុរបស់ខ្លួន*

ផូរផង់ដោយការកាន់យកនិមិត្ត ក្នុងកញ្ចក់ជាដើម ដូចសីហបញ្ជរធ្វើដោយកែវមណីដែលបុគ្គលបើកហើយត្រង់វិមានមាស រមែងសម្គាល់សោតៈ ដូចឡូតប្រាក់ និងដូចខ្សែស្នារ ។ រមែងសម្គាល់ឃានៈដែលសន្មតថា ប្រមុះខ្ពស់ដូចហរិតាលដែលបុគ្គលលញ់តាំងទុក រមែងសម្គាល់ជិវ្ហាដែលឲ្យរសផ្អែមស្និទ្ធ ដូចផ្ទាំងសំពត់កម្ពលក្រហម ។ រមែងសម្គាល់កាយ ដូចដើមសាលព្រឹក្ស និងដូចសសរទ្វៀនមាស ។ រមែងសម្គាល់ចិត្តធំក្រៃលែង មិនដូចចិត្តរបស់អ្នកដទៃ រមែងសម្គាល់រូប ដូចពណ៌ មានពណ៌មាស និងផ្កាកណិការជាដើម រមែងសម្គាល់សំឡេង ដូចសំឡេងរងាវរបស់សត្វករវិក និងដូចតាវៅ ដែលកំពុងត្រេកអរនឹងសំឡេងរបស់ខ្យល់កែវមណី ដែលផ្លុំយ៉ាងគ្រលួច រមែងសម្គាល់អារម្មណ៍ មានក្លិនជាដើម ដែលកើតពីសមុដ្ឋាន ៤ ដែលខ្លួនបានហើយថា អ្នកណាហ្ន៎ នឹងមានអារម្មណ៍បែបនេះ ។

កាលសត្វទាំងនោះសម្គាល់យ៉ាងនេះហើយ ចក្ខុជាដើមទាំងនោះ រមែងជាបិយរូប និងសាតរូប ។ កាលបើដូច្នោះ តណ្ហាដែលមិនទាន់កើតក្នុងបិយរូប និងសាតរូបនោះ រមែងកើតដល់សត្វទាំងនោះ និងដែលកើតឡើងហើយ រមែងតាំងនៅដោយអំណាចប្រព្រឹត្តទៅរឿយៗ ។ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា ចក្ខុមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតឡើងក្នុងចក្ខុនុ៎ះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧប្បជ្ជមានា** សេចក្តីថា កាលណាតណ្ហាកើត កាលនោះ តណ្ហា រមែងកើតក្នុងវត្ថុនេះ ។៚

**អដ្ឋកថាសមុទយសច្ចនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ៨៤ ] បណ្តាអរិយសច្ចទាំងនោះ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ ការរលត់ដោយអរិយមគ្គឥតសេសសល់ ការលះបង់ ការរលាស់ចេញ ការរួចស្រឡះ សេចក្តីមិនមានអាល័យ នៃតណ្ហានោះឯណា ក៏តណ្ហានោះឯង កាលបុគ្គលលះបង់ តើលះបង់ក្នុងអារម្មណ៍ណា កាលរលត់ទៅ តើរលត់ទៅក្នុងអារម្មណ៍ណា អារម្មណ៍ណា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលរលត់ទៅ រមែងរលត់ទៅក្នុងអារម្មណ៍នុ៎ះ ចក្ខុមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងចក្ខុនុ៎ះ កាលរលត់ទៅ រមែងរលត់ទៅក្នុងចក្ខុនុ៎ះ សោតៈក្នុងលោក ។បេ។ ធម្មវិចារ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងសោតៈជាដើមនុ៎ះ កាលរលត់ទៅ រមែងរលត់ទៅក្នុងសោតៈជាដើមនុ៎ះ នេះលោកហៅថា ទុក្ខនិរោធអរិយសច្ច ។

# អដ្ឋកថា

# និរោធសច្ចនិទ្ទេស

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិរោធសច្ចនិទ្ទេសដូចតទៅ ក្នុងបទនេះថា **យោ តស្សាយេវ តណ្ហាយ** មានវិនិច្ឆ័យដូចតទៅនេះថា កាលគួរពោលថា ការរលត់ទុក្ខនោះ ព្រោះទុក្ខរលត់ដោយការរលត់សមុទយៈ មិនមែនរលត់ដោយប្រការដទៃ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយនៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស័យ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ ( មានជាតិទុក្ខជាដើម ) នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ដូច្នេះ ។

ហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងទុក្ខនិរោធនោះ ទើបត្រាស់យ៉ាងនេះ ដើម្បីសម្តែងសមុទយនិរោធ ។ ពិតហើយ ព្រះតថាគតទាំងឡាយដែលមានការប្រព្រឹត្តស្មើដោយសីហៈ ព្រះតថាគតទាំងនោះ កាលនឹងទ្រង់រម្ងត់ទុក្ខ ហើយកាលនឹងទ្រង់សម្តែងការរម្ងត់ទុក្ខ ទ្រង់រមែងប្រព្រឹត្តទៅក្នុងហេតុ មិនប្រព្រឹត្តទៅក្នុងផល ។ ចំណែកពួកអន្យតិរ្ថិយជាអ្នកប្រព្រឹត្តវត្តសុនខ ពួកនោះកាលនឹងរម្ងត់ទុក្ខ និងកាលសម្តែងការរម្ងត់ទុក្ខ រមែងប្រព្រឹត្តទៅក្នុងផលដោយអត្តកិលមថានុយោគ ដោយការសម្តែងអត្តកិលមថានុយោគនោះ

ឯង មិនប្រព្រឹត្តទៅក្នុងហេតុ ហេតុនោះ កាលព្រះសាស្តា ទ្រង់ប្រព្រឹត្តទៅក្នុងហេតុ ព្រោះទ្រង់មានការប្រព្រឹត្តិស្មើដោយសីហៈ ទើបត្រាស់ព្រះពុទ្ធវចនៈថា **យោ តស្សាយេវ** ដូច្នេះជាដើម ។ សូម្បីព្រះធម្មសេនាបតី ក៏ពោលតាមលំដាប់ដែលព្រះសាស្តាត្រាស់នោះឯង ។

ក្នុងបទទាំងនោះ បទថា **តស្សាយេវ តណ្ហាយ** សេចក្តីថា នៃតណ្ហាដែលព្រះមានព្រះភាគត្រាស់ថា **ពោនោព្ភវិកា** តណ្ហាធ្វើឲ្យកើតកពថ្មី ហើយទ្រង់ចែកជាកាមតណ្ហាជាដើម និងទ្រង់ប្រកាសជាខាងក្រោយ ដោយការកើតឡើង ការតាំងនៅ ។

បទថា **អសេសវិរាគនិរោធោ** សេចក្តីថា មគ្គ ហៅថា **វិរាគ** ដូចព្រះមានព្រះភាគ ត្រាស់ថា **វិរាគា វិមុច្ចតិ** កាលបើនឿយណាយ ( យ៉ាងនេះហើយ ) ក៏ប្រាសចាកតម្រេក ដូច្នេះ ។ ការរលត់ដោយការប្រាសចាកតម្រេក ឈ្មោះថា **វិរាគនិរោធ** ។ ការរលត់ដោយប្រាសចាកតម្រេកដោយមិនសេសសល់ ដោយដកអនុស័យ ឈ្មោះថា **អសេសវិរាគនិរោធោ** ។ ម្យ៉ាងទៀត ដ្បិតលោកហៅការលះថា **វិរាគ** ព្រោះហេតុនោះ គប្បីឃើញការប្រកបអត្ថក្នុងបទនេះ យ៉ាងនេះថា ការលះដោយមិនមានសេសសល់ ការរលត់ដោយមិនសេសសល់ ។ តែដោយអត្ថ បទទាំងអស់ មានបទថា **អសេសវិរាគនិរោធោ** ជាដើម ទាំងនេះ ជាវេវចនៈនៃព្រះនិព្វាននោះឯង ។ ព្រោះថា ដោយបរមត្ថ ទ្រង់ពោលនិព្វានថា **ទុក្ខនិរោធំ អរិយសច្ចំ** ។ ព្រោះតណ្ហាមកដល់និព្វាននោះ រមែងប្រាសចាកតម្រេក គឺរមែងរលត់ដោយមិនមាន

សេសសល់ ហេតុនោះ ទើបនិព្វាននោះ ទ្រង់ពោលថា **តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ** ដូច្នេះ ។ មួយទៀត តណ្ហាមកដល់និព្វាន រមែងត្រូវលះបង់ ត្រូវកម្ចាត់បង់ ត្រូវបន្សាត់ រមែងមិនជាប់ក្នុងនិព្វាននេះ មិនមានអាល័យសូម្បីត្រឹមតែម្យ៉ាង បណ្ដាសេចក្ដីអាល័យក្នុងកាមគុណទាំងឡាយ ព្រោះហេតុនោះ ទើបទ្រង់ពោលនិព្វានថា **ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ** ការលះបង់ ការលោះចេញ ការរួចស្រឡះ សេចក្ដីមិនមានអាល័យ ។

ព្រោះព្រះនិព្វានមានតែមួយប៉ុណ្ណោះ តែឈ្មោះរបស់ព្រះនិព្វាននោះ មានមិនមែនតិច ដោយអំណាចជាបដិបក្ខចំពោះឈ្មោះ នៃសង្ខតធម៌ទាំងពួង ។ គឺមានឈ្មោះថា **អសេសវិរាគោ** ការប្រាសចាកតម្រេកដោយមិនមានសេសសល់ ១ **អសេសនិរោធោ** ការរម្ងត់ដោយមិនមានសេសសល់ ១ **ចាគោ** ការលះបង់ ១ **បដិនិស្សគ្គោ** ការលោះចេញ ១ **មុត្តិ** ការរួចស្រឡះ ១ **អនាលយោ** ការមិនអាល័យ ១ **រាគក្ខយោ** ការអស់រាគៈ ១ **ទោសក្ខយោ** ការអស់ទោសៈ ១ **មោហក្ខយោ** ការអស់មោហៈ ១ **តណ្ហក្ខយោ** ការអស់តណ្ហា ១ **អនុប្បាទោ** ការមិនកើត ១ **អប្បវត្តំ** ការមិនប្រព្រឹត្តទៅ ១ **អនិមិត្តំ** ការមិនមានគ្រឿងសម្គាល់ ១ **អប្បណិហិតំ** ការមិនមានទីតាំង ១ **អនាយូហនំ** ការមិនមានកម្មជាហេតុបដិសន្ធិ ១ **អប្បដិសន្ធិ** ការមិនបន្ត ១ **អនុបបត្តិ** ការមិនមានឧបបត្តិ ១ **អគតិ** ការមិនមានគតិ ១ **អជាតំ** ការមិនកើត ១ **អជរំ** ការមិនចាស់ ១ **អព្យាធិ** ការមិនឈឺ ១ **អមតំ** ការមិនស្លាប់ ១ **អសោកំ** ការមិនសោក ១ **អបរិទេវំ** ការមិនយំរៀបរាប់ ១

**អនុទាយាសំ** ការមិនក្រៀមក្រំចិត្ត ១ **អសង្កិលិដ្ឋំ** ការមិនសៅហ្មង ១ ជាដើម ។

ទ្រង់សម្តែងដល់ការកើតនៃតណ្ហាក្នុងវត្ថុណា ឥឡូវនេះ ដើម្បីសម្តែងការមិនមាននៃតណ្ហា ដែលត្រូវមគ្គកាត់ផ្តាច់ កាលមកដល់និព្វានហើយ ដល់នូវការមិនប្រព្រឹត្តទៅក្នុងវត្ថុនោះ ទើបព្រះសារីបុត្តពោលថា **សា ខោ បនេសា** ដូច្នេះជាដើម ។

ក្នុងបទនោះមានសេចក្តីថា ដូចបុរសឃើញននោងព្រៃដែលកើតក្នុងស្រែ ទើបស្វែងរកឫសដោយស្រាវមក អំពីខាងចុងហើយកាត់ចោល ននោងព្រៃនោះក្រៀមស្ងួតទៅដោយលំដាប់ហើយក៏អស់ទៅ បន្ទាប់អំពីនោះ គួរពោលថា ននោងព្រៃក្នុងស្រែនោះអស់ហើយ បាត់ទៅហើយ យ៉ាងណា តណ្ហាក្នុងចក្ខុជាដើម ក៏ដូចននោងព្រៃក្នុងស្រែយ៉ាងនោះ ។ តណ្ហានោះ ត្រូវកាត់ឫសគល់ដោយអរិយមគ្គហើយ មកដល់និព្វាន ក៏ដល់នូវការមិនប្រព្រឹត្តទៅ កាលតណ្ហាដល់នូវសភាពយ៉ាងនេះហើយ ក៏មិនប្រាកដក្នុងវត្ថុទាំងនោះ ដូចននោងព្រៃក្នុងស្រែ មិនប្រាកដដូច្នោះ ។

ម្យ៉ាងទៀត ដូចរាជបុរសនាំចោរមកអំពីព្រៃ ហើយសម្លាប់ត្រង់ទ្វារនគរទិសខាងត្បូង បន្ទាប់អំពីនោះ គួរពោលបានថា ចោរក្នុងព្រៃស្លាប់ហើយ ឬត្រូវសម្លាប់ហើយយ៉ាងណា តណ្ហាក្នុងចក្ខុជាដើមដូចចោរក្នុងព្រៃ តណ្ហានោះរលត់ទៅហើយក្នុងនិព្វាន ព្រោះមកដល់និព្វានទើបរលត់ទៅ ដូចចោរដែលមកដល់ទ្វារទិសខាងត្បូងហើយស្លាប់ ដូច្នោះ ។ តណ្ហារលត់ទៅយ៉ាងនេះ មិនប្រាកដ

ក្នុងវត្ថុទាំងនោះ ដូចចោរក្នុងព្រៃ ដោយហេតុនោះ ព្រះសារីបុត្ត កាលសម្តែងដល់ការរលត់តណ្ហានោះក្នុងចក្ខុជាដើមនោះ ទើបពោលពាក្យថា **ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ** ដូច្នេះជាដើម ។ ម្យ៉ាងទៀត លោកពោលថា ព្រោះកំណត់ដឹងវត្ថុដែលតណ្ហាកើត ទើបតណ្ហារលត់ទៅក្នុងវត្ថុដែលតណ្ហាកើត ដោយអំណាចការរលត់ទៅ ដោយមិនកើតព្រោះការមិនកើតតទៅទៀត ក្នុងវត្ថុដែលខ្លួនកំណត់ដឹងហើយ ។ មួយទៀតក្នុងបទនេះ លោកពោលថា តណ្ហា រមែងត្រូវលះបានដោយជាបដិបក្ខចំពោះការកើត រមែងរលត់ទៅដោយជាបដិបក្ខចំពោះការតាំងនៅ ។ល។

**អដ្ឋកថានិរោធសច្ចនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ៨៥ ] បណ្តាអរិយសច្ចទាំងនោះ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្តេច ។ អរិយមគ្គមានអង្គ ៨ នេះឯង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ការដឹងច្បាស់ក្នុងកងទុក្ខ ការដឹងច្បាស់ក្នុងហេតុជាទីកើតឡើងនៃកងទុក្ខ ការដឹងច្បាស់ក្នុងទីរលត់នៃកងទុក្ខ ការដឹងច្បាស់ក្នុងផ្លូវប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់កងទុក្ខនេះ លោកហៅថា សម្មាទិដ្ឋិ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាសង្កប្ប តើដូចម្តេច ។ នេក្ខម្មសង្កប្ប ( ការត្រិះរិះក្នុងការចេញចាកកាម ) អព្យាបាទសង្កប្ប ( ការត្រិះរិះក្នុងការមិនព្យាបាទ ) អវិហឹសាសង្កប្ប ( ការត្រិះរិះក្នុងការមិនបៀតបៀន ) នេះលោកហៅថា សម្មាសង្កប្ប ។

បណ្តាអរិយមគ្គទាំងនោះ សម្មាវាចា តើដូចម្តេច ។ ចេតនាជាហេតុវៀរចាកមុសាវាទ ចេតនាជាហេតុវៀរចាកបិសុណាវាចា ចេតនាជាហេតុវៀរចាកផរុសវាចា ចេតនាជាហេតុវៀរចាកសម្ផប្បលាបៈ នេះលោកហៅថា សម្មាវាចា ។

បណ្តាអរិយមគ្គទាំងនោះ សម្មាកម្មន្តៈ តើដូចម្តេច ។ ចេតនាជាហេតុវៀរចាកបាណាតិបាត ចេតនាជាហេតុវៀរចាកអទិន្នាទាន ចេតនាជាហេតុវៀរចាកកាមេសុមិច្ឆាចារ នេះលោកហៅថា សម្មាកម្មន្តៈ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាអាជីវៈ តើដូចម្តេច ។ អរិយសាវកក្នុងសាសនានេះ លះបង់ការចិញ្ចឹមជីវិតខុស សម្រេចនូវការចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតត្រូវ នេះលោកហៅថា សម្មាអាជីវៈ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ រមែងបង្កើតឆន្ទៈ ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្តដើម្បីញ៉ាំងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើងមិនឲ្យកើតឡើងបាន ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។បេ។ ដើម្បីញ៉ាំងពួកកុសលធម៌ ដែលមិនទាន់កើតឡើងឲ្យកើតឡើង ។បេ។ ភិក្ខុរមែងបង្កើតឆន្ទៈ ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្ត ដើម្បីស្ថិតនៅ ដើម្បីមិនឲ្យវិនាស ដើម្បីឲ្យចម្រើនក្រៃលែង ដើម្បីធំទូលាយ ដើម្បីចម្រើន ដើម្បីបំពេញនូវពួកកុសលធម៌ដែលកើតឡើងហើយ នេះលោកហៅថា សម្មាវាយាមៈ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះជាអ្នកពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ក្នុងវេទនាទាំងឡាយ ។បេ។ ក្នុងចិត្ត ។បេ។ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក នេះលោកហៅថា សម្មាសតិ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនា

នេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានសម្រេច បឋមជ្ឈានប្រកបដោយវិតក្ក វិចារ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងាត់ បានសម្រេចទុតិយជ្ឈាន ជាធម្មជាតកើតមានខាងក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្ក វិចារ ជាអ្នកព្រងើយកន្តើយផង មានស្មារតីដឹងខ្លួនផង ព្រោះលះបង់បីតិ រមែងទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរភិក្ខុនោះថា ជាអ្នកមានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានការនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ភិក្ខុនោះ ក៏បានសម្រេចតតិយជ្ឈាននោះ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ភិក្ខុនោះក៏បានសម្រេចចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា នេះលោកហៅថា សម្មាសមាធិ នេះលោកហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា នេះទុក្ខអរិយសច្ច នេះទុក្ខសមុទយអរិយសច្ច នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ បញ្ញាក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ យ៉ាងនេះឯង ។

# អដ្ឋកថា

# មគ្គសច្ចនិទ្ទេស

[ ៨៥ ] គប្បីវិនិច្ឆ័យក្នុងមគ្គសច្ចនិទ្ទេសដូចតទៅ

បទថា **អយមេវ** ជាពាក្យកំណត់ពិតប្រាកដ ដោយហាមមគ្គដទៃ ។ បទថា **អរិយោ** មានវិនិច្ឆ័យដូចតទៅ ឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសដែលត្រូវសម្លាប់ដោយមគ្គនោះៗ ព្រោះធ្វើភាពជាព្រះអរិយៈ និងព្រោះធ្វើការបានអរិយផល ។ ឈ្មោះថា **អដ្ឋង្គិក** ព្រោះអត្ថថា មគ្គនោះមានអង្គ ៨ ។ មគ្គមានអង្គ ៨ នោះ ត្រឹមតែជាអង្គប៉ុណ្ណោះ ដូចសេនាមានអង្គ ៤ ដូចតន្ត្រីមានអង្គ ៥ ផុតពីអង្គហើយ មានមិនបាន ។

ឥឡូវនេះ ព្រះសារីបុត្តកាលសម្តែងថា មគ្គត្រឹមតែជាអង្គប៉ុណ្ណោះ ផុតពីអង្គហើយ មានមិនបាន ទើបពោលពាក្យថា **សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ** ជាដើម ។

ក្នុងបទទាំងនោះ សម្មាទិដ្ឋិ មានការយល់ត្រូវជាលក្ខណៈ ។ សម្មាសង្កប្ប មានការលើកឡើងត្រូវជាលក្ខណៈ ។ សម្មាវាចា មានការកំណត់ត្រូវជាលក្ខណៈ ។ សម្មាកម្មន្តៈ មានការឲ្យតាំងឡើងត្រូវជាលក្ខណៈ ។ សម្មាអាជីវៈ មានការឲ្យផូរផង់ត្រូវជាលក្ខណៈ ។ សម្មាវាយាមៈ មានការផ្គងត្រូវជាលក្ខណៈ ។ សម្មាសតិ មានការប្រាកដត្រូវជាលក្ខណៈ ។ សម្មាសមាធិ មានការតាំងមាំត្រូវជាលក្ខណៈ ។

ក្នុងមគ្គទាំងនោះ មគ្គមួយៗ រមែងមានកិច្ច ៣ យ៉ាង គឺសម្មាទិដ្ឋិ រមែង

លះមិច្ឆាទិដ្ឋិ ព្រមទាំងកិលេស ដែលជាសត្រូវដល់ខ្លួន រមែងធ្វើនិរោធឲ្យជាអារម្មណ៍ និងរមែងឃើញសម្បយុត្តធម៌ ព្រោះមិនវង្វេងដោយអំណាចកម្ចាត់មោហៈដែលបិទបាំងសម្បយុត្តធម៌ទាំងឡាយបាន ។ សូម្បីសម្មាសង្កប្បជាដើម ក៏លះមិច្ឆាសង្កប្បជាដើមបានដូចគ្នា និងធ្វើនិព្វានឲ្យជាអារម្មណ៍ ។ តែបើពោលដោយការផ្សេងៗ គ្នា ក្នុងទីនេះ សម្មាសង្កប្ប លើកចិត្តឡើងកាន់សហជាតធម៌ដោយប្រពៃ សម្មាវាចា កំណត់យកដោយប្រពៃ សម្មាកម្មន្តៈ ឲ្យតាំងឡើងដោយប្រពៃ សម្មាអាជីវៈ ឲ្យផូរផង់ហើយដោយប្រពៃ សម្មាវាយាមៈ ផ្គងដោយប្រពៃ សម្មាសតិ ឲ្យប្រាកដដោយប្រពៃ សម្មាសមាធិ តាំងមាំដោយប្រពៃ ។

ម្យ៉ាងទៀត សម្មាទិដ្ឋិនេះ ក្នុងចំណែកខាងដើម មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា ក្នុងកាលនៃមគ្គមានខណៈតែមួយ មានអារម្មណ៍តែមួយ ។ តែដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាងថា **ទុក្ខេញាណំ** ជាដើម ។ សូម្បីសម្មាសង្កប្បជាដើម ក្នុងចំណែកខាងដើមក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា ក្នុងកាលនៃមគ្គមានខណៈតែមួយ មានអារម្មណ៍តែមួយ ។ ក្នុងមគ្គទាំងនោះ សម្មាសង្កប្បដោយកិច្ចរមែងមានឈ្មោះ ៣ យ៉ាង គឺ **នេក្ខម្មសង្កប្បោ** ជាដើម ។ មគ្គ ៣ មានសម្មាវាចាជាដើម ក្នុងចំណែកខាងដើមជាវិរតិខ្លះ ជាចេតនាខ្លះ តែក្នុងខណៈនៃមគ្គ ជាវិរតិតែម្យ៉ាង ពីរបទនេះ គឺសម្មាវាយាមៈ សម្មាសតិ ដោយកិច្ចរមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចសម្មប្បធាន និងសតិប្បដ្ឋាន ។ ចំណែកសម្មាសមាធិក្នុងចំណែកខាងដើមក្តី ក្នុងខណៈនៃមគ្គ

ក្តី ក៏ជាសម្មាសមាធិនោះឯង ។

ក្នុងធម៌ទាំង ៨ យ៉ាងនេះ ព្រះមានព្រះភាគទ្រង់សម្តែងសម្មាទិដ្ឋិទុកមុន ព្រោះជាធម៌មានឧបការៈច្រើនដល់ព្រះយោគាវចរ អ្នកបដិបត្តិដើម្បីដល់និព្វាន ព្រោះថា សម្មាទិដ្ឋិនេះព្រះមានព្រះភាគត្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ថា **បញ្ញាបជ្ជោតោ បញ្ញាសត្ថំ** គ្រឿងផ្ទះ គឺបញ្ញា គ្រឿងសស្ត្រា គឺបញ្ញា ដូច្នេះ ។ ព្រោះហេតុនោះ ព្រះយោគាវចរកម្ចាត់ភាពងងឹត គឺអវិជ្ជា ដោយសម្មាទិដ្ឋិនោះ ពោល គឺវិបស្សនាញាណក្នុងចំណែកខាងដើម ហើយសម្លាប់ចោរ គឺកិលេសបាន រមែងដល់និព្វានដោយក្សេមក្សាន្ត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងសម្មាទិដ្ឋិទុកមុន ។

ចំណែកសម្មាសង្កប្ប មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ក្នុងលំដាប់បន្ទាប់អំពីសម្មាទិដ្ឋិនោះ ដូចជាហិរញ្ញិកប្រើដៃត្រឡប់ទៅត្រឡប់មក មើលកហាបណៈដោយភ្នែក ក៏រមែងដឹងថា នេះក្លែងក្លាយ នេះមិនមែនក្លែងក្លាយយ៉ាងណា សូម្បីព្រះយោគាវចរក៏យ៉ាងនោះ ក្នុងចំណែកខាងដើម គិតហើយគិតទៀតដោយវិតក្ក សម្លឹងមើលដោយវិបស្សនាបញ្ញា រមែងដឹងថា ធម៌ទាំងនេះជាកាមាវចរ ទាំងនេះជារូបាវចរជាដើម ។ ឬដូចជាជាងឈើយកកាំបិតចាំងដើមឈើធំ ដែលបុរសចាប់ត្រង់ចុងហើយត្រឡប់ទៅត្រឡប់មក ឲ្យនាំយកទៅប្រើប្រាស់ក្នុងការងារយ៉ាងណា ព្រះយោគាវចរក៏យ៉ាងនោះ ប្រើបញ្ញាកំណត់ធម៌ដែលវិតក្ក ត្រិះរិះទៅមកហើយដោយន័យជាដើមថា ធម៌ទាំងនេះ ជាកាមាវចរ ទាំងនេះ ជារូបាវចរជា

ដើមហើយ នាំចូលទៅក្នុងការងារ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់សម្មាសង្កប្បក្នុងលំដាប់សម្មាទិដ្ឋិ ។ សម្មាសង្កប្ប ជាឧបការៈសូម្បីដល់សម្មាវាចា ដូចជាឧបការៈដល់សម្មាទិដ្ឋិដូច្នោះ ។ សមដូចព្រះកាមភូពោល ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ម្នាលគហបតី បុគ្គលត្រិះរិះពិចារណាជាមុនហើយ ទើបបញ្ចេញនូវវាចាជាខាងក្រោយ ដូច្នេះ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់សម្មាវាចា ក្នុងលំដាប់បន្ទាប់អំពីសម្មា-សង្កប្បនោះ ។

មួយទៀត ព្រោះជនទាំងឡាយ ចាត់ចែងការងារដោយវាចាមុនថា យើងនឹងធ្វើវត្ថុនេះៗ ហើយទើបប្រកបការងារក្នុងលោក ហេតុនោះ ទើបវាចា មានឧបការៈដល់ការធ្វើការងារផ្លូវកាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់សម្មាកម្មន្តៈ ក្នុងលំដាប់របស់សម្មាវាចា ។

ក៏ព្រោះអាជីវដ្ឋមកសីល ( សីលមានអាជីវៈជាគម្រប់ ៨ ) រមែងបរិបូរណ៍ដល់អ្នកលះបង់វចីទុច្ចរិត ៤ យ៉ាង កាយទុច្ចរិត ៣ យ៉ាង ហើយបំពេញសុចរិតទាំងពីរ មិនបរិបូរណ៍ដល់អ្នកបំពេញក្រៅអំពីនេះ ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់សម្មាអាជីវៈ ក្នុងលំដាប់បន្ទាប់អំពីធម៌ទាំងពីរនោះ ។

ព្រះមានព្រះភាគ ត្រាស់សម្មាវាយាមៈ ក្នុងលំដាប់បន្ទាប់អំពីសម្មា-អាជីវៈនោះ ដើម្បីសម្តែងថា បុគ្គលមានអាជីវៈបរិសុទ្ធហើយយ៉ាងនេះ មិនគួរធ្វើសេចក្តីត្រេកអរ ដោយហេតុមានប្រមាណប៉ុណ្ណោះថា អាជីវៈរបស់យើង

បរិសុទ្ធហើយប្រមាទ ដែលពិតគួរប្រារព្ធសេចក្ដីព្យាយាមនេះគ្រប់ឥរិយាបថ ។

បន្ទាប់អំពីនោះព្រះមានព្រះភាគដើម្បីទ្រង់សម្ដែងថា អ្នកដែលប្រារព្ធសេចក្ដីព្យាយាម គួរធ្វើសតិឲ្យប្រាកដដោយល្អ ក្នុងវត្ថុ ៤ យ៉ាង មានកាយជាដើម ទើបត្រាស់សម្មាសតិ ក្នុងលំដាប់បន្ទាប់អំពីសម្មាវាយាមៈនោះ ។

ព្រោះកាលសតិប្រាកដល្អយ៉ាងនេះហើយ ព្រះយោគាវចរស្វែងរកគតិនៃធម៌ដែលជាឧបការៈ និងមិនជាឧបការៈដល់សមាធិហើយ រមែងអាចធ្វើចិត្តឲ្យតាំងមាំក្នុងអារម្មណ៍តែមួយ ហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សម្មាសមាធិ ក្នុងលំដាប់បន្ទាប់អំពីសម្មាសតិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាទិដ្ឋិនិទ្ទេសដូចតទៅ

ព្រះសារីបុត្តសម្ដែងចតុសច្ចកម្មដ្ឋាន ដោយពាក្យថា **ទុក្ខេ ញាណំ** ដូច្នេះជាដើម ។

បណ្ដាសច្ចៈទាំង ៤ នោះ សច្ចៈ ២ ខាងដើមជាវដ្ដៈ ២ ខាងក្រោយជាវិវដ្ដៈ ។ ក្នុងសច្ចៈទាំងនោះសម្រាប់ភិក្ខុ ការកាន់យកកម្មដ្ឋានរមែងមានក្នុងវដ្ដៈ ការកាន់យករមែងមិនមានក្នុងវិវដ្ដៈ ។ ព្រោះព្រះយោគាវចររៀនសច្ចៈ ២ ខាងដើមក្នុងសម្នាក់អាចារ្យដោយសង្ខេបយ៉ាងនេះថា ខន្ធ ៥ ជាទុក្ខ តណ្ហាជាហេតុឲ្យកើតទុក្ខ និងដោយពិស្ដារថា ខន្ធ ៥ ដូចម្ដេច គឺរូបក្ខន្ធជាដើម ហើយទន្ទេញត្រឡប់ទៅមករឿយៗ ដោយវាចាធ្វើកម្មដ្ឋាន ។ ចំណែកក្នុងសច្ចៈ ២ ក្រៅអំពីនេះ ព្រះយោគាវចរធ្វើកម្មដ្ឋានដោយការស្ដាប់ប៉ុណ្ណោះ យ៉ាងនេះថា និរោធសច្ចគួរត្រូវការ គួរប្រាថ្នា គួរពេញចិត្ត មគ្គសច្ចគួរត្រូវការ គួរ

ប្រាថ្នា គួរពេញចិត្ត ។ ព្រះយោគាវចរនោះ កាលបើធ្វើកម្មដ្ឋានយ៉ាងនេះ រមែងចាក់ធ្លុះសច្ចៈ ៤ ដោយការចាក់ធ្លុះក្នុងគ្រាតែមួយ រមែងត្រាស់ដឹងដោយការត្រាស់ដឹងក្នុងគ្រាតែមួយ ។ រមែងចាក់ធ្លុះទុក្ខ ដោយការចាក់ធ្លុះដោយបរិញ្ញា រមែងសម្រេចសមុទយៈ ព្រោះការចាក់ធ្លុះដោយបហាន រមែងចាក់ធ្លុះនិរោធ ព្រោះការចាក់ធ្លុះដោយសច្ឆិកិរិយា រមែងចាក់ធ្លុះមគ្គ ព្រោះការចាក់ធ្លុះដោយភាវនា ។ រមែងត្រាស់ដឹងទុក្ខ ព្រោះការត្រាស់ដឹងដោយបរិញ្ញា ។បេ។ រមែងត្រាស់ដឹងមគ្គ ព្រោះការត្រាស់ដឹងដោយភាវនា ។

ខាងដើមភិក្ខុរមែងមានការចាក់ធ្លុះដោយការរៀន ការសាកសួរ ការស្ដាប់ ការចាំ និងការពិចារណាក្នុងសច្ចៈ ២ ( ទុក្ខសច្ច និងសមុទយសច្ច ) រមែងមានការចាក់ធ្លុះដោយការស្ដាប់តែម្យ៉ាងក្នុងសច្ចៈ ២ ( និរោធសច្ចៈ និងមគ្គសច្ចៈ ) ។ ក្នុងវេលាតមក ( ក្នុងខណៈនៃមគ្គ ) រមែងមានការចាក់ធ្លុះដោយកិច្ចក្នុងសច្ចៈ ៣ រមែងមានការចាក់ធ្លុះដោយអារម្មណ៍ក្នុងនិរោធ ។ ក្នុងសច្ចៈទាំងនោះ ការដឹងដោយការចាក់ធ្លុះ ទាំងអស់ជាលោកុត្តរ ការដឹងដោយការស្ដាប់ ការចាំ និងការពិចារណា ជាលោកិយ ជាកាមាវចរ ។ ចំណែកបច្ចវេក្ខណញ្ញាណ រមែងមានដល់មគ្គសច្ច នេះជាអាទិកម្មិក ។ ព្រោះហេតុនោះ ទើបលោកមិនពោលបច្ចវេក្ខណញ្ញាណនោះ ក្នុងទីនេះ ។ ម្យ៉ាងទៀត ការពិចារណាដោយការចងចិត្ត ការរួបរួម ការដាក់ចិត្តថា អញដឹងទុក្ខ អញលះសមុទយៈ អញធ្វើឲ្យជាក់ច្បាស់និរោធ អញចម្រើនភាវនា ដូច្នេះ រមែងមិនមានដល់ភិក្ខុនេះ ដែលកំណត់ទុកមុន ។ រមែងមានបាន តាំងអំពីខណៈ

កំណត់ ។ ចំណែកក្នុងវេលាតមក ទុក្ខ ឈ្មោះថា ភិក្ខុកំណត់ដឹងហើយ ។បេ។ មគ្គ ឈ្មោះថា ភិក្ខុចម្រើនហើយ ។ ក្នុងសច្ចៈទាំងនោះ សច្ចៈ ២ ជ្រាលជ្រៅ ព្រោះឃើញបានលំបាក សច្ចៈ ២ ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ។ ពិតហើយ ទុក្ខសច្ចប្រាកដដោយការកើតឡើង ក្នុងខណៈត្រូវដង្កត់ និងបន្ទាមុត ជាដើម ក៏ស្រែកថា ទុក្ខហ្ន៎ ។ សមុទយសច្ច ប្រាកដដោយការកើតឡើង ដោយចង់ទំពា ចង់បរិភោគជាដើម ។ ពោលដោយការចាក់ធ្លុះនូវលក្ខណៈ សច្ចៈទាំង ២ ឈ្មោះថា ជ្រាលជ្រៅ ។ សច្ចៈទាំងនោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាក ដោយប្រការដូច្នេះ ។ ការព្យាយាមដើម្បីឃើញសច្ចៈ ២ យ៉ាង ក្រៅពីនោះ ក៏ដូចឈោងដៃដើម្បីចាប់ភវគ្គព្រហ្ម ឬដូចយកជើងលូក ដើម្បីពាល់ត្រូវអវិចី និងដូចការទល់ចុងរោមទ្រាយ ដែលច្រៀកជាមួយរយចំណែក ។ សច្ចៈទាំងនោះ ឈ្មោះថា ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ដោយប្រការដូច្នេះ ។

ព្រះសារីបុត្តពោលពាក្យថា **ទុក្ខេ ញាណំ** ជាដើមនេះ សំដៅដល់ការកើតនៃញាណដែលជាចំណែកខាងដើម ក្នុងសច្ចៈ ៤ ដែលឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាក និងឈ្មោះថា ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ដោយការរៀនជាដើម ដោយប្រការដូច្នេះ តែក្នុងខណៈចាក់ធ្លុះញាណនោះ មានតែម្យ៉ាងប៉ុណ្ណោះ ។

ចំណែកអាចារ្យពួកដទៃពោលថា ញាណក្នុងសច្ចៈទាំងឡាយ មាន ៤ យ៉ាងគឺ **សុតមយញ្ញាណ** ញាណកើតពីការស្តាប់ ១ **វវត្ថានញ្ញាណ** ញាណ

កើតពីការកំណត់ ១ **សម្មសនញ្ញាណ** ញាណកើតពីការពិចារណា ១ **អភិសមយញ្ញាណ** ញាណកើតអំពីការត្រាស់ដឹង ១ ។

ក្នុងញាណទាំងនោះ **សុតមយញ្ញាណ** តើដូចម្ដេច ព្រះយោគាវចរស្ដាប់សច្ចៈ ៤ ដោយសង្ខេប ឬដោយពិស្ដារ រមែងដឹងថា នេះទុក្ខ នេះសមុទយៈ នេះនិរោធ នេះមគ្គ នេះឈ្មោះថា **សុតមយញ្ញាណ** ។

**វវត្ថានញ្ញាណ** តើដូចម្ដេច ព្រះយោគាវចរនោះ រមែងកំណត់អត្ថនៃធម៌ដែលស្ដាប់មកហើយ ដោយធម៌ និងដោយលក្ខណៈ ធ្វើនូវការសម្រេចចិត្តថា ធម៌ទាំងនេះ ទាក់ទងក្នុងសច្ចៈនេះ នេះជាលក្ខណៈរបស់សច្ចៈនេះ នេះឈ្មោះថា **វវត្ថានញ្ញាណ** ។

**សម្មសនញ្ញាណ** តើដូចម្ដេច ព្រះយោគាវចរនោះ កំណត់សច្ចៈ ៤ តាមលំដាប់យ៉ាងនេះហើយ កាន់យកទុក្ខប៉ុណ្ណោះ រមែងពិចារណារហូតដល់គោត្រភូញាណដោយភាពមិនទៀង ជាទុក្ខ ជាអនត្តា នេះឈ្មោះថា **សម្ម-សនញ្ញាណ** ។

**អភិសមយញ្ញាណ** តើដូចម្ដេច ព្រះយោគាវចរនោះត្រាស់ដឹងសច្ចៈ ៤ ដោយញាណមួយក្នុងខណៈលោកុត្តរមគ្គ មិនមុនមិនក្រោយ គឺរមែងត្រាស់ដឹងទុក្ខដោយការត្រាស់ដឹង ដោយការកំណត់ដឹង រមែងត្រាស់ដឹង **សមុទយ** ដោយការត្រាស់ដឹងដោយការលះ រមែងត្រាស់ដឹងនិរោធដោយការធ្វើឲ្យជាក់ច្បាស់ រមែងត្រាស់ដឹងមគ្គដោយការត្រាស់ដឹងដោយការចម្រើន នេះឈ្មោះថា **អភិសមយញ្ញាណ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាសង្កប្បនិទ្ទេសដូចតទៅនេះ ឈ្មោះថា **នេក្ខម្ម-សង្កប្បោ** ព្រោះអត្ថថា រលាស់ចេញទៅអំពីកាម ។

ឈ្មោះថា **អព្យាបាទសង្កប្បោ** ព្រោះអត្ថថា រលាស់ចេញទៅអំពីព្យាបាទ ។

ឈ្មោះថា **អវិហិង្សាសង្កប្បោ** ព្រោះអត្ថថា រលាស់ចេញទៅអំពីវិហិង្សា ។

ក្នុងវិតក្កទាំងនោះ នេក្ខម្មវិតក្កកើតឡើង ធ្វើនូវការទម្លាយផ្លូវ កាត់ផ្លូវរបស់កាមវិតក្ក អព្យាបាទវិតក្ក កើតឡើងធ្វើនូវការទម្លាយផ្លូវ កាត់នូវផ្លូវរបស់ព្យាបាទវិតក្ក អវិហិង្សាវិតក្ក កើតឡើង ធ្វើនូវការទម្លាយផ្លូវ កាត់ផ្លូវរបស់វិហិង្សាវិតក្ក ម្យ៉ាងទៀត នេក្ខម្មវិតក្ក អព្យាបាទវិតក្ក អវិហិង្សាវិតក្ក ជាសត្រូវរបស់កាមវិតក្ក ព្យាបាទវិតក្ក និងវិហិង្សាវិតក្ក ។

ក្នុងវិតក្កទាំងនោះ ព្រះយោគាវចរ រមែងពិចារណាកាមវិតក្ក ឬសង្ខារឯណានីមួយ ដើម្បីទម្លាយផ្លូវរបស់កាមវិតក្ក ។ ម្យ៉ាងទៀត ការត្រិះរិះសម្បយុត្តដោយវិបស្សនា ក្នុងខណៈនៃវិបស្សនារបស់ព្រះយោគាវចរនោះ កើតឡើងធ្វើការទម្លាយផ្លូវ កាត់ផ្លូវរបស់កាមវិតក្ក ដោយអំណាចតទង្គប្បហាន ឲ្យខ្វល់ខ្វាយក្នុងវិបស្សនាហើយ ឲ្យសម្រេចមគ្គ ។ ម្យ៉ាងទៀត ការត្រិះរិះសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់ព្រះយោគាវចរនោះ កើតឡើងធ្វើនូវការទម្លាយផ្លូវ កាត់ផ្លូវរបស់កាមវិតក្ក ដោយអំណាចសមុច្ឆេទប្បហាន ។ ព្រះយោគាវចររមែងពិចារណាព្យាបាទវិតក្ក ឬសង្ខារដទៃ ដើម្បីទម្លាយផ្លូវរបស់ព្យាបាទវិតក្ក ពិចារណាវិហិង្សាវិតក្ក ឬសង្ខារដទៃ ដើម្បីទម្លាយផ្លូវរបស់វិហិង្សាវិតក្ក ។

គប្បីប្រកបពាក្យទាំងពួងថា **អថស្ស វិបស្សនាក្ខណេ** ( ម្យ៉ាងទៀត ក្នុងខណៈនៃវិបស្សនារបស់ព្រះយោគាវចរនោះ ) ដោយន័យមុននោះឯង ។

កាលចែកអារម្មណ៍ ៣៨ ក្នុងបាលី សូម្បីកម្មដ្ឋានមួយ ឈ្មោះថា មិនជាសត្រូវដល់វិតក្ក ៣ មានកាមវិតក្កជាដើម រមែងមិនមាន ។ បឋមជ្ឈានក្នុងអសុភទាំងឡាយនោះឯង ជាសត្រូវរបស់កាមវិតក្កដោយចំណែកមួយ ។ ឈានពួក ៣ និងពួក ៤ ក្នុងមេត្តា ជាសត្រូវរបស់ព្យាបាទវិតក្ក ឈានពួក ៣ និងពួក ៤ ក្នុងករុណា ជាសត្រូវរបស់វិហិង្សាវិតក្ក ។ ព្រោះហេតុនោះ វិតក្កសម្បយុត្តដោយឈាន ក្នុងខណៈនៃការចូលសមាបត្តិរបស់ព្រះយោគាវចរដែលធ្វើការបរិកម្មអសុភកម្មដ្ឋាន ហើយចូល ឈានកើតឡើង ជាសត្រូវរបស់កាមវិតក្ក ដោយអំណាចវិក្ខម្ភនប្បហាន ។ ការត្រិះរិះសម្បយុត្តដោយវិបស្សនាក្នុងខណៈចម្រើនវិបស្សនា របស់ព្រះយោគាវចរដែលធ្វើឈានឲ្យជាបាទ ហើយចម្រើនវិបស្សនា កើតឡើង ជាសត្រូវរបស់កាមវិតក្ក ដោយអំណាចតទង្គប្បហាន ការត្រិះរិះសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់ព្រះយោគាវចរដែលខ្វល់ខ្វាយក្នុងវិបស្សនា ហើយសម្រេចមគ្គ កើតឡើងជាសត្រូវរបស់កាមវិតក្កដោយអំណាចសមុច្ឆេទប្បហាន ។ ការត្រិះរិះដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបថា លោកហៅថា **នេក្ខម្មសង្កប្បោ** ។

គប្បីប្រកបបទទាំងពួងថា ព្រះយោគាវចរធ្វើបរិកម្មក្នុងមេត្តា ធ្វើបរិកម្មក្នុងករុណា ហើយចូលឈានដោយន័យមុននោះឯង ។ ការត្រិះរិះដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបថា លោកហៅថា **អព្យាបាទសង្កប្បោ អវិហិង្ស-**

**សង្កប្បោ** ដូច្នេះ ។ នេក្ខម្មសង្កប្បទាំងនេះជាដើម ក្នុងចំណែកខាងដើមផ្សេងគ្នា ព្រោះការកើតឡើងដោយអំណាចវិបស្សនា និងឈានផ្សេងគ្នា តែក្នុងខណៈនៃមគ្គ ការត្រិះរិះជាកុសលតែម្យ៉ាងប៉ុណ្ណោះ កើតឡើងធ្វើអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះកាត់ផ្លូវនៃការត្រិះរិះ ដែលជាអកុសល ដែលកើតឡើងក្នុងឋានៈទាំង ៣ នេះ ។ នេះឈ្មោះថា សម្មាសង្កប្ប ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាវាចានិទ្ទេសដូចតទៅនេះថា ព្រោះព្រះយោគាវចរវៀរចាកមុសាវាទដោយចិត្តដទៃ វៀរចាកបិសុណាវាចាជាដើម ដោយចិត្តដទៃៗ ដូច្នោះ ក្នុងចំណែកខាងដើម ទើបការវៀរ ៤ យ៉ាងនេះផ្សេងគ្នា តែក្នុងខណៈនៃមគ្គ ការវៀរដែលជាកុសល ពោល គឺសម្មាវាចាតែម្យ៉ាងប៉ុណ្ណោះ កើតឡើង ធ្វើអង្គមគ្គឲ្យបរិបូណ៌ដោយអំណាច ឲ្យសម្រេចការមិនកើតឡើង ព្រោះកាត់ផ្លូវនៃចេតនា ៤ ដែលជាអកុសលដែលជាគ្រឿងទ្រុស្តសីល ពោល គឺមិច្ឆាវាចា ។ នេះឈ្មោះថា **សម្មាវាចា** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាកម្មន្តនិទ្ទេសដូចតទៅនេះថា ព្រោះព្រះយោគាវចរវៀរចាកបាណាតិបាតដោយចិត្តដទៃ វៀរចាកអទិន្នាទានដោយចិត្តដទៃ វៀរចាកមិច្ឆាចារដោយចិត្តដទៃ ហេតុនោះ ទើបក្នុងចំណែកខាងដើម ការវៀរ ៣ យ៉ាងនេះផ្សេងគ្នា តែក្នុងខណៈនៃមគ្គ ការវៀរដែលជាកុសល ពោលគឺសម្មាកម្មន្តៈតែម្យ៉ាងប៉ុណ្ណោះ កើតឡើងធ្វើអង្គមគ្គឲ្យបរិបូរណ៍ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះកាត់ផ្លូវនៃចេតនា ៣ ដែលជាអកុសលដែល

ជាគ្រឿងទ្រុស្តសីល ពោល គឺមិច្ឆាកម្មន្តៈ ។ នេះឈ្មោះថា សម្មាកម្មន្តៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាអាជីវនិទ្ទេសដូចតទៅនេះ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **អរិយសាវកោ** បានដល់ សាវករបស់ព្រះពុទ្ធដែលជាអរិយៈ ។ បទថា **មិច្ឆាអាជីវំ បហាយ** បានដល់ លះបង់អាជីវៈដែលលាមក ។ បទថា **សម្មាអាជីវេន** បានដល់ អាជីវៈដែលល្អដែលព្រះពុទ្ធទ្រង់សរសើរ ។ បទថា **ជីវិតំ កប្បេតិ** បានដល់ ញុំាងការប្រព្រឹត្តទៅរបស់ជីវិតឲ្យប្រព្រឹត្តទៅ ។

ព្រោះសាវកក្នុងសាសនានេះ វៀរចាកការកន្លងផ្លូវកាយទ្វារដោយចិត្តដទៃ វៀរចាកការកន្លងផ្លូវវចីទ្វារដោយចិត្តដទៃ ដូច្នោះ ក្នុងចំណែកខាងដើម អាជីវៈរមែងកើតឡើងក្នុងខណៈផ្សេងៗ គ្នា តែក្នុងខណៈនៃមគ្គ ការវៀរដែលជាកុសល ពោល គឺសម្មាអាជីវៈតែម្យ៉ាងប៉ុណ្ណោះ កើតឡើងធ្វើអង្គមគ្គឲ្យបរិបូរណ៍ ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះកាត់ផ្លូវនៃចេតនាជាគ្រឿងទ្រុស្តសីល គឺមិច្ឆាអាជីវៈដែលកើតឡើង ដោយអំណាចកម្មបថ ៧ ក្នុងទ្វារ ២ ។ នេះឈ្មោះថា **សម្មាអាជីវ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាវាយាមនិទ្ទេសដូចតទៅនេះ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុអ្នកបដិបត្តិក្នុងសាសនានេះ ។

បទថា **អនុប្បន្នានំ** បានដល់ ដែលមិនទាន់កើតឡើង ។ បទថា **បាបកានំ** បានដល់ លាមក ។ បទថា **អកុសលានំ ធម្មានំ** បានដល់ ធម៌ដែលកើតអំពីការមិនឈ្លាស ។ បទថា **អនុប្បាទាយ** បានដល់ ដើម្បីមិនឲ្យកើត

ឡើង ។

បទថា **ឆន្ទំ ជនេតិ** បានដល់ ញ៉ាំងឆន្ទៈក្នុងកុសល ពោល គឺភាពជាអ្នកប្រាថ្នានឹងធ្វើឲ្យកើត គឺឲ្យកើតឡើង ។ បទថា **វាយមតិ** បានដល់ ញ៉ាំងសេចក្ដីព្យាយាមឲ្យកើត គឺធ្វើនូវការប្រឹងប្រែង ។ បទថា **វីរិយំ អារភតិ** បានដល់ ធ្វើសេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ចិត្តំ បគ្គណ្ហាតិ** បានដល់ លើកចិត្តឡើងដោយសេចក្ដីព្យាយាមដែលកើតឡើង ព្រមគ្នានោះឯង ។ បទថា **បទហាតិ** បានដល់ ធ្វើសេចក្ដីព្យាយាម ជាទីតាំង ។ គប្បីប្រកបបទទាំង ៤ នេះ ដោយអាសេវនា គឺការសេពភាវនា គឺការចម្រើនពហុលីកម្ម គឺការធ្វើឲ្យច្រើន សាតច្ចកិរិយា គឺការធ្វើជាប់តគ្នាតាមលំដាប់ទៅ ។

បទថា **ឧប្បន្នានំ** បានដល់ ដល់នូវការមិនគួរនឹងពោលថា ដែលមិនទាន់កើតឡើង ។ បទថា **បហានាយ** បានដល់ ដើម្បីលះបង់ ។ បទថា **អនុប្បន្នានំ កុសលានំ ធម្មានំ** បានដល់ កុសលធម៌ដែលនៅមិនទាន់កើត ។

បទថា **ឧប្បាទាយ** បានដល់ ដើម្បីឲ្យកើតឡើង ។ បទថា **ឧប្បន្នានំ** បានដល់ ដែលកើតឡើងហើយ ។ បទថា **ឋិតិយា** បានដល់ ដើម្បីការតាំងនៅ ។ បទថា **អសម្មោសាយ** បានដល់ ដើម្បីការមិនវិនាស ។ បទថា **ភិយ្យោភាវាយ** បានដល់ ដើម្បីការចម្រើនរឿយៗ ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីភាពទូលំទូលាយ ។ បទថា **ភាវនាយ** បានដល់ ដើម្បីសេចក្ដីចម្រើន ។ បទថា **បារិបូរិយា** បានដល់ ដើម្បីភាពបរិបូរណ៍ ។

សម្មប្បធាន ៤ ពោល គឺសម្មាវាយាមៈទាំងនេះ ក្នុងចំណែកខាងដើម ជាលោកិយ ក្នុងខណៈនៃមគ្គជាលោកុត្តរ ។ តែក្នុងខណៈនៃមគ្គ សេចក្ដីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចធ្វើកិច្ច ៤ យ៉ាងឲ្យសម្រេច ។

ក្នុងសម្មប្បធានទាំងនោះ គប្បីជ្រាបសម្មប្បធានដែលជាលោកិយដោយន័យដែលលោកពោល ក្នុងកស្សបសំយុត្តនោះឯង ។ ក្នុងកស្សបសំយុត្តនោះ លោកពោលថា

> ម្នាលអាវុសោ សម្មប្បធានមាន ៤ ។ សម្មប្បធាន ៤ តើដូចម្ដេច[១] ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ធ្វើនូវសេចក្ដីព្យាយាមដុតកម្ដៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមកមិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្ដីព្យាយាមដុតកម្ដៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមកកើតឡើងដល់អាត្មាអញហើយ កាលបើអាត្មាអញមិនបានលះបង់ចេញទេ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្ដីព្យាយាមដុតកម្ដៅកិលេស ដោយគិតថា ពួកកុសលធម៌ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើមិនទាន់កើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្ដីព្យាយាម ដុតកម្ដៅ

---

១- ពាក្យនេះ បិដកខ្មែរ មិនមាន តែក្នុងអដ្ឋកថា មាន ។

កិលេស ដោយគិតថា ពួកកុសលធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា មិនទាន់កើតឡើង បានដល់ ដែលនៅមិនទាន់កើត ដោយការមិនប្រាកដ ឬដោយអារម្មណ៍ដែលមិនធ្លាប់សេព ។ ពិតហើយ អកុសលធម៌ដ៏លាមក ដែលមិនទាន់កើតក្នុងសង្សារ ដែលមិនដឹងខាងដើមនិងទីបំផុត រមែងមិនមានដោយប្រការដទៃ អកុសលធម៌ដែលមិនទាន់កើត កាលកើត ក៏រមែងជាអកុសលទាំងនោះនោះឯងកើតឡើង កាលលះក៏រមែងជាអកុសលធម៌ទាំងនោះ នោះឯងត្រូវលះ ។

ក្នុងបទនោះ កិលេសទាំងឡាយ រមែងមិនប្រាកដដោយអំណាចវត្ត ការសិក្សារៀនសូត្រ ធុតង្គ សមាធិ វិបស្សនា នវកម្ម និងភពឯណានីមួយដល់ភិក្ខុអង្គខ្លះ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ព្រោះភិក្ខុអង្គខ្លះជាអ្នកដល់ព្រមហើយដោយវត្ត កាលភិក្ខុនោះធ្វើខន្ធកវត្ត ៨០ មហាវត្ត ១៤ និងចេតិយង្គណវត្ត ពោធិយង្គណវត្ត បានីយមាឡកវត្ត ( តម្កល់ទឹកផឹកទុកក្នុងរោងមូល ) ឧបោសថាគារវត្ត អាគន្តុកវត្ត គមិកវត្ត កិលេសទាំងឡាយរមែងមិនបានឱកាស ។ តែខាងក្រោយ កាលភិក្ខុនោះលះវត្តទាំងឡាយ ទម្លាយវត្តត្រាច់ទៅ កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការមិនមានស្មារតី រមែងកើតឡើងបាន ដោយប្រការដូច្នេះ កិលេសទាំងឡាយដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុអង្គខ្លះ ជាអ្នកប្រកបដោយការសិក្សារៀនសូត្រ រមែងរៀននិកាយ ១ ខ្លះ និកាយ ២ ខ្លះ និកាយ ៣ ខ្លះ និកាយ ៤ ខ្លះ និកាយ ៥ ខ្លះ ។ កាលភិក្ខុនោះរៀន ស្វាធ្យាយ គិត ប្រាប់ សម្តែង ចង្អុលបង្ហាញព្រះត្រៃបិដកដែលជាពុទ្ធវចនៈដោយអត្ថ ដោយបាលី ដោយអនុសន្ធិ ដោយបទដើម បទចុង កិលេសទាំងឡាយរមែងមិនបានឱកាស ។ តែខាងក្រោយ កាលភិក្ខុនោះលះការរៀនគម្ពីរ ខ្ជិលច្រអូស កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការខ្វះស្មារតី រមែងកើតឡើងបាន ។ ដោយប្រការដូច្នេះ កិលេសទាំងឡាយដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុអង្គខ្លះ ជាអ្នកទ្រទ្រង់ធុតង្គ សមាទានប្រព្រឹត្តធុតង្គគុណ ១៣ កាលភិក្ខុនោះបដិបត្តិធុតង្គគុណ កិលេសទាំងឡាយរមែងមិនបានឱកាស ។ តែខាងក្រោយកាលភិក្ខុនោះលះបង់ធុតង្គចេញ វិលមកដើម្បីការប្រាថ្នាច្រើន ត្រាច់ទៅ កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការមិនមានស្មារតី រមែងកើតឡើង ។ ដោយប្រការដូច្នេះ កិលេសទាំងឡាយ ដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុអង្គខ្លះ ប្រព្រឹត្តវសីក្នុងសមាបត្តិ ៨ កាលភិក្ខុនោះនៅដោយអំណាចអាវជ្ជនវសីជាដើម ក្នុងបឋមជ្ឈានជាដើម កិលេសទាំងឡាយ រមែងមិនបានឱកាស ។ តែខាងក្រោយ កាលភិក្ខុនោះវិនាសចាកឈាន ឬលះបង់ឈានប្រកបរឿយៗ ក្នុងការនិយាយជាដើម កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការមិនមានស្មារតី រមែងកើតឡើង ។ ដោយប្រការដូច្នេះ

កិលេសទាំងឡាយដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែង កើតឡើង ។

ភិក្ខុអង្គ១ះ ជាអ្នកចម្រើនវិបស្សនា បដិបត្តិក្នុងអនុបស្សនា ៧ ឬមហា-វិបស្សនា ១៨ កាលភិក្ខុនោះបដិបត្តិយ៉ាងនេះ កិលេសទាំងឡាយ រមែងមិន បានឱកាស ។ តែខាងក្រោយកាលភិក្ខុនោះលះបង់ការបំពេញវិបស្សនា ច្រើន ទៅដោយការស្អិតស្អាងរាងកាយ កិលេសទាំងឡាយអាស្រ័យអយោនិសោ-មនសិការ និងការមិនមានស្មារតី រមែងកើតឡើង ដោយប្រការដូច្នេះ ។ កិលេសទាំងឡាយ ដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុរូប១ះ ជានវកម្មិកៈ ធ្វើការកសាងរោងឧបោសថ និងរោងឆាន់ជាដើម កាលបើភិក្ខុនោះ គិតដល់ឧបករណ៍ការកសាងរោងឧបោសថ និងរោងឆាន់ទាំង នោះ កិលេសទាំងឡាយ រមែងមិនបានឱកាស តែខាងក្រោយ កាលនវកម្ម របស់ភិក្ខុនោះសម្រេចហើយ ឬបោះបង់ចោល កិលេសទាំងឡាយ អាស្រ័យ អយោនិសោមនសិការ និងការមិនមានស្មារតី រមែងកើតឡើង ។ ដោយ ប្រការដូច្នេះ កិលេសទាំងឡាយ ដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុអង្គ១ះមកពីព្រហ្មលោកជាសត្វបរិសុទ្ធ កិលេសទាំងឡាយរមែងមិន បានឱកាសដោយការមិនធ្លាប់សេពរបស់ភិក្ខុនោះ តែខាងក្រោយកាលភិក្ខុនោះ បានសេពហើយ កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការ

មិនមានស្មារតី រមែងកើតឡើង ។ ដោយប្រការដូច្នេះ កិលេសទាំងឡាយ ដែលមិនទាន់កើត ដោយមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។ គប្បីជ្រាបភាពដែលកិលេសមិនទាន់កើត ដោយមិនទាន់ប្រាកដយ៉ាងនេះ ។

កិលេសមិនទាន់កើតដោយអារម្មណ៍ដែលមិនធ្លាប់សេពដូចម្តេច ភិក្ខុអង្គខ្លះ ក្នុងសាសនានេះ បានអារម្មណ៍ដែលគួរពេញចិត្តជាដើម ដែលមិនធ្លាប់សេពមកអំពីមុន កិលេសទាំងឡាយ មានរាគៈជាដើម អាស្រ័យអយោនិសោមនសិការ និងការមិនមានស្មារតីក្នុងអារម្មណ៍នោះ រមែងកើតឡើងដល់ភិក្ខុនោះ ។ ដោយប្រការដូច្នេះ កិលេសទាំងឡាយ ដែលមិនទាន់កើតដោយអារម្មណ៍ ដែលមិនធ្លាប់សេព ឈ្មោះថា រមែងកើតឡើង ។ កាលអកុសលធម៌ដែលមិនទាន់កើតឡើង និងកើតឡើងយ៉ាងនេះ ភិក្ខុឃើញសេចក្តីវិនាសរបស់ខ្លួន រមែងចម្រើនសម្មប្បធានប្រការខាងដើម ដោយការប្រកបភាវនា ក្នុងសតិប្បដ្ឋាន ដើម្បីការមិនកើតឡើងនៃអកុសលធម៌ ដែលមិនទាន់កើតទាំងនោះ កាលអកុសលធម៌ទាំងនោះ កើតឡើងហើយ ភិក្ខុឃើញសេចក្តីវិនាសរបស់ខ្លួន ព្រោះមិនលះអកុសលធម៌ទាំងនោះហើយ ទើបចម្រើនសម្មប្បធានប្រការទី ២ យ៉ាងនោះឯង ដើម្បីលះអកុសលធម៌ទាំងនោះ ។

ពាក្យថា **ពួកកុសលធម៌ដែលមិនទាន់កើតឡើង** បានដល់ សមថវិបស្សនា និងមគ្គ ។ ភិក្ខុឃើញការវិនាសរបស់ខ្លួន ព្រោះកុសលធម៌ទាំងនោះ ដែលមិនទាន់កើតហើយ ទើបចម្រើនសម្មប្បធានប្រការទី ៣ យ៉ាងនោះឯង ដើម្បីឲ្យកុសលធម៌ទាំងនោះកើតឡើង ។

ពាក្យថា ពួកកុសលធម៌ដែលកើតឡើង បានដល់ សមថវិបស្សនានោះឯង ។ ចំណែកមគ្គកើតតែម្តង ហើយរលត់ទៅ មិនប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសឡើយ ។ ព្រោះថា មគ្គនោះឲ្យបច្ច័យដល់ផលហើយ ក៏រលត់ទៅ ។ ភិក្ខុឃើញសេចក្តីវិនាសរបស់ខ្លួន ព្រោះសមថៈ និងវិបស្សនាទាំងនោះរលត់ទៅហើយ ទើបចម្រើនសម្មប្បធានប្រការទី ៤ យ៉ាងនោះឯង ដើម្បីការតាំងមាំនៃសមថៈ និងវិបស្សនាទាំងនោះ ។ ក្នុងខណៈនៃលោកុត្តរមគ្គ វីរិយៈមានតែម្យ៉ាងប៉ុណ្ណោះ ។

ភិក្ខុរមែងញុំាងកិច្ច គឺការមិនកើតឡើងនៃអកុសលធម៌ទាំងនោះ ដែលមិនទាន់កើតឡើង និងកិច្ច គឺការលះអកុសលធម៌ទាំងនោះ ដែលកើតឡើងហើយឲ្យសម្រេចដោយប្រការ ដែលអកុសលធម៌ពួកណាដែលមិនទាន់កើតឡើងយ៉ាងនេះនឹងគប្បីកើតឡើង អកុសលធម៌ទាំងនោះរមែងកើតឡើងមិនបាន ។

មួយទៀត ក្នុងពាក្យថា ដែលកើតឡើង នេះ ឧប្បន្ន គឺការដែលកើតឡើង មាន ៤ យ៉ាង គឺវត្តមានុប្បន្ន កើតឡើងកំពុងប្រព្រឹត្តទៅ ១ ភូតាបគតុប្បន្ន កើតឡើងសេពអារម្មណ៍ ហើយរលត់ទៅ ១ ឱកាសកតុប្បន្ន កើតឡើងធ្វើឱកាស ១ ភូមិលទ្ធុប្បន្ន កើតឡើងព្រោះបានភូមិ ១ ។

ក្នុងឧប្បន្នទាំងនោះ ធម៌ទាំងអស់ ពោល គឺការដល់ព្រមដោយឧប្បាទ ជរា ភង្គៈ ឈ្មោះថា វត្តមានុប្បន្ន ។

កុសល និងអកុសលដែលសោយរសនៃអារម្មណ៍ ហើយរលត់ទៅ ពោល គឺសោយហើយ ក៏រលត់ទៅ និងសង្ខតធម៌ដ៏សេស ដែលចូលដល់

លក្ខណៈ ៣ មានឧប្បាទជាដើមហើយ រលត់ទៅ ពោល គឺកើតហើយក៏រលត់ទៅ ឈ្មោះថា ភូតាបគតុប្បន្ន ។

កម្មដែលព្រះមានព្រះភាគត្រាស់ ដោយន័យថា **យានិស្ស តានិ បុព្វេកតានិ កម្មានិ** អំពើទាំងឡាយណាដែលគេធ្វើក្នុងកាលមុនជាដើម សូម្បីជាអតីត ក៏ឈ្មោះថា ឱកាសកតុប្បន្ន ព្រោះហាមវិបាកដទៃហើយធ្វើឱកាសដល់វិបាករបស់ខ្លួនតាំងនៅ ហើយវិបាកដែលធ្វើឱកាសយ៉ាងនោះ សូម្បីមិនទាន់កើតឡើង ក៏ឈ្មោះថា ឱកាសកតុប្បន្ន ព្រោះកាលធ្វើឱកាសយ៉ាងនោះហើយ នឹងកើតឡើងដោយពិតប្រាកដ ។

អកុសលដែលមិនទាន់ដកចេញក្នុងភូមិទាំងនោះ ឈ្មោះថា ភូមិលទ្ធុប្បន្ន ។

ម្យ៉ាងទៀត ក្នុងពាក្យនេះគប្បីជ្រាបការផ្សេងគ្នានៃភូមិ និងភូមិលទ្ធដូចតទៅ ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាអារម្មណ៍នៃវិបស្សនា ឈ្មោះថា ភូមិ កិលេសជាតិដែលគួរកើតក្នុងខន្ធទាំងនោះ ឈ្មោះថា ភូមិលទ្ធ ព្រោះហេតុថា កិលេសជាតិនោះបានភូមិ ព្រោះហេតុនោះ ទើបលោកពោលកិលេសជាតិថា ភូមិលទ្ធ ។ ភូមិនោះមិនកើតឡើងដោយអំណាចអារម្មណ៍ ។ ពិតហើយ ព្រោះប្រារព្ធខន្ធទាំងអស់ ទាំងក្នុងអតីត អនាគត និងខន្ធទាំងឡាយរបស់ព្រះខីណាស្រពដែលលោកកំណត់ដឹងហើយ កិលេសទាំងឡាយរមែងកើតឡើងដោយអំណាចអារម្មណ៍ ។ បើកិលេសជាតិនោះគប្បីឈ្មោះថាភូមិលទ្ធហើយ បុគ្គលណាមួយក៏គប្បីលះឫសគល់របស់ភពមិនបាន ព្រោះកិលេសជាតិនោះមិនជាវត្ថុដែលខ្លួនគប្បីលះបាន ។ តែគប្បីជ្រាបភូមិលទ្ធដោយអំណាចជាវត្ថុ ។

ពិតហើយ ខន្ធដែលមិនទាន់បានកំណត់ដោយវិបស្សនា កើតឡើងក្នុងភព ណាៗ កិលេសជាតិដែលជាមូលរបស់វដ្តៈ រមែងដេកត្រាំក្នុងខន្ធទាំងនោះ ចាប់តាំងអំពីខន្ធកើតឡើងក្នុងភពនោះៗ ។ គប្បីជ្រាបថា កិលេសជាតិនោះ ឈ្មោះថា ភូមិលទ្ធ ដោយអត្ថថា មិនទាន់លះបាន ។

ម្យ៉ាងទៀត ក្នុងខន្ធទាំងឡាយដែលជាភូមិនោះ ខន្ធទាំងឡាយរបស់បុគ្គល ដែលមានកិលេសដេកត្រាំ ដោយអត្ថថា មិនទាន់លះបាន ជាទីតាំងនៃកិលេស ទាំងនោះ ខន្ធទាំងឡាយដែលជារបស់អ្នកដទៃមិនជាទីតាំង ។ ម្យ៉ាងទៀត ខន្ធ ដែលជាអតីតប៉ុណ្ណោះ ជាទីតាំងនៃកិលេសដែលដេកត្រាំ ដោយមិនទាន់លះបាន ក្នុងខន្ធដែលជាអតីត ខន្ធក្រៅអំពីនេះ មិនជាទីតាំង ។ ខន្ធក្នុងអនាគតជាដើម ក៏មានន័យនេះ ។ មួយទៀត កាមាវចរក្ខន្ធប៉ុណ្ណោះជាទីតាំងរបស់កិលេសដែល ដេកត្រាំដោយមិនទាន់លះបានក្នុងកាមាវចរក្ខន្ធ ខន្ធក្រៅអំពីនេះមិនជាទីតាំង ។ ក្នុងរូបាវចរក្ខន្ធ និងអរូបាវចរក្ខន្ធក៏មានន័យនេះដូចគ្នា ។ មួយវិញទៀត ក្នុងព្រះ សោតាបន្នជាដើម កិលេសជាតិដែលជាមូលនៃវដ្តៈនោះៗ ក្នុងខន្ធរបស់ព្រះ អរិយបុគ្គលណាមួយ លះបានដោយមគ្គនោះៗ ខន្ធទាំងនោះរបស់ព្រះអរិយ-បុគ្គលនោះៗ មិនរាប់ថាជាភូមិ ព្រោះមិនជាទីតាំងនៃកិលេសដែលជាមូលរបស់ វដ្តៈ ដែលលះបានហើយនោះ ។ កម្មដែលបុថុជ្ជនធ្វើឯណានីមួយ រមែងជា កុសល ឬអកុសល ព្រោះលះកិលេសដែលជាមូលនៃវដ្តៈមិនទាន់បាន ដោយ ប្រការទាំងពួង ហេតុនោះ ទើបវដ្តៈរបស់បុថុជ្ជននោះវិលទៅ ព្រោះនៅមានកម្ម និងកិលេសជាបច្ច័យនោះឯង កិលេសជាតិដែលជាមូលរបស់វដ្តៈនោះ របស់

បុគ្គលនោះៗ មិនគួរពោលថា មានក្នុងរូបក្ខន្ធប៉ុណ្ណោះ មិនមានក្នុងវេទនាខន្ធជាដើម ឬមានក្នុងវិញ្ញាណក្ខន្ធប៉ុណ្ណោះ មិនមានក្នុងរូបក្ខន្ធជាដើម ។

ព្រោះហេតុអ្វី ព្រោះកិលេសជាតិ ដេកត្រាំក្នុងខន្ធទាំង ៥ ដោយមិនប្លែកគ្នា ។ សេចក្តីនេះដូចម្តេច ដូចរសដីជាដើមមានក្នុងដើមឈើ ។ កាលដើមឈើធំតាំងនៅលើផែនដី អាស្រ័យរសដី និងរសទឹក ដុះដាលពេញអាកាសដោយឫស ដើម មែកតូចធំ ស្លឹកខ្ចី ស្លឹកចាស់ ផ្កា និងផ្លែ ព្រោះរសដី និងរសទឹកនោះ ជាបច្ច័យបន្តពូជរបស់ដើមឈើដោយការដុះតៗ គ្នាមក តាំងនៅរហូតអស់កប្ប ព្រោះដីជាដើមនោះ មិនគួរពោលថា មានក្នុងឫសប៉ុណ្ណោះ មិនមានក្នុងដើមជាដើម ឬមានក្នុងផ្លែប៉ុណ្ណោះ មិនមានក្នុងឫសជាដើម ។

ព្រោះហេតុអ្វី ព្រោះរសដីជាដើមជ្រួតជ្រាបក្នុងឫសជាដើមទាំងអស់ដោយមិនប្លែកគ្នា ដូចបុរសម្នាក់ មិនពេញចិត្តផ្កា និងផ្លែជាដើមរបស់ដើមឈើនោះ ទើបដំបន្ទាពិស ឈ្មោះថា មណ្ឌូកកណ្តកៈក្នុង ៤ ទិស ពេលនោះ ដើមឈើនោះ ត្រូវបន្ទាពិសនោះមុតក៏មិនអាចបន្តទៅទៀតបាន ដោយមិនចេញផ្លែតាមប្រក្រតី ព្រោះរសដីរសទឹកអស់ហើយយ៉ាងណា កុលបុត្តដែលនឿយណាយក្នុងការប្រព្រឹត្តទៅនៃខន្ធក៏ដូច្នោះដូចគ្នា រមែងផ្តើមចម្រើនមគ្គ ៤ ក្នុងសន្តានរបស់ខ្លួនដូចបុរសនោះប្រកបបន្ទាពិសក្នុងដើមឈើក្នុងទិសទាំង ៤ ដូច្នោះ ។

កាលបើដូច្នោះ ខន្ធសន្តានរបស់កុលបុត្តនោះត្រូវសម្ផស្សពិស គឺមគ្គ ៤ នោះ ប៉ះពាល់ហើយ ក្លាយជាប្រភេទរបស់កម្មទាំងពួង មានកាយកម្មជាដើម ដែលចូលដល់ត្រឹមសភាវៈរបស់កិរិយា ព្រោះកិលេសដែលជាឫសគល់ របស់

វដ្តៈអស់ហើយ ដោយប្រការទាំងពួង មិនអាចនឹងបន្តសន្តាន ក្នុងភពដទៃបាន ដោយមិនកើតក្នុងភពថ្មីតទៅជាធម្មតា អស់សេចក្តីប្រកាន់ បរិនិព្វាន ដោយការរម្ងត់វិញ្ញាណចុងក្រោយ ឥតសេសសល់ ដូចភ្លើងមិនមានកំញមដូច្នោះ ។ គប្បីជ្រាបការផ្សេងគ្នារបស់ភូមិ និងភូមិលទ្ធយ៉ាងនេះ ។

ឧប្បន្នមាន ៤ យ៉ាង ម្យ៉ាងទៀត គឺសមុទាចារុប្បន្ន វត្តដែលកើតឡើងកំពុងប្រព្រឹត្តទៅ ១ អារម្មណាធិគ្គហិតុប្បន្ន កើតដោយការកាន់យកអារម្មណ៍ ១ អវិក្ខម្ភិតុប្បន្ន កើតដោយការមិនសង្កត់សង្កិន ១ អសមូហតុប្បន្ន កើតដោយការមិនដកចេញ ១ ក្នុងឧប្បន្នទាំងនោះ វត្តមានុប្បន្ននោះឯង ឈ្មោះថា សមុទាចារុប្បន្ន ។

កាលអារម្មណ៍មកកាន់គន្លងនៃចក្ខុជាដើម កិលេសជាតិដែលមិនទាន់កើតក្នុងចំណែកខាងដើម ក៏ហៅថា អារម្មណាធិគ្គហិតុប្បន្ន ដោយកើតឡើងព្រោះកាន់យកអារម្មណ៍នោះឯង នឹងកើតឡើងដោយពិត ក្នុងពេលក្រោយ ។ កិលេសជាតិដែលមិនបានសង្កត់សង្កិន ដោយអំណាចសមថៈ និងវិបស្សនាឯណាមួយ សូម្បីមិនឡើងកាន់ការបន្តនៃចិត្ត ក៏ឈ្មោះថា អវិក្ខម្ភិតុប្បន្ន ព្រោះមិនមានហេតុដែលនឹងហាមការកើតបាន ។ កិលេសជាតិ សូម្បីសង្កត់សង្កិនដោយអំណាចសមថៈ និងវិបស្សនា ក៏ហៅថា អសមូហតុប្បន្ន ព្រោះមិនទាន់ដកចេញដោយអរិយមគ្គ ព្រោះមិនកន្លងផុតការកើតជាធម្មតា ។

គប្បីជ្រាបថា អារម្មណាធិគ្គហិតុប្បន្ន អវិក្ខម្ភិតុប្បន្ន អសមូហតុប្បន្ន ទាំងបីនេះ រមែងសង្គ្រោះបានដោយភូមិលទ្ធនោះឯង ។

ដោយប្រការដូច្នេះ ក្នុងឧប្បន្នធម៌មានប្រភេទដូចពោលហើយនេះ ឧប្បន្នធម៌ ពោល គឺវត្តមានភូតាបគត ឱកាសកត សមុទាចារ ដែលមគ្គញ្ញាណណាមួយមិនគប្បីលះ ព្រោះមិនត្រូវសម្លាប់ដោយមគ្គ ។ មួយទៀត លោកិយញ្ញាណ និងលោកុត្តរញ្ញាណនោះៗ កើតឡើងធ្វើភាពជាឧប្បន្ននៃឧប្បន្ន ពោល គឺភូមិលទ្ធ អារម្មណាធិគ្គហិត អវិក្ខម្ភិត អសមូហត ឲ្យវិនាសទៅ ដូច្នោះ ទើបឧប្បន្នទាំងអស់នោះ ជាធម្មជាតគប្បីលះបាន ដោយប្រការដូច្នេះ ។ មគ្គរមែងលះកិលេសពួកណា ទ្រង់សំដៅយកកិលេសទាំងនោះ ទើបត្រាស់ថា **ឧប្បន្នានំ** ។

កាលបើយ៉ាងនេះ ក្នុងខណៈនៃមគ្គ ការចម្រើនដើម្បីការកើតឡើងនៃកុសលដែលមិនទាន់កើត រមែងមានដូចម្តេច ដើម្បីការតាំងមាំនៃកុសលដែលកើតឡើងហើយដូចម្តេច ដើម្បីសម្រេចមគ្គនោះឯង ។ មគ្គ កាលប្រព្រឹត្តទៅ លោកឲ្យឈ្មោះថា មិនធ្លាប់កើត ព្រោះមិនធ្លាប់កើតមកអំពីមុន ។ ពិតហើយ បុគ្គលមកកាន់ស្ថានទីដែលមិនធ្លាប់មក ឬសោយអារម្មណ៍ដែលមិនធ្លាប់សោយ រមែងពោលថា ខ្ញុំមកកាន់ទីដែលមិនធ្លាប់មក ខ្ញុំសោយអារម្មណ៍ ដែលមិនធ្លាប់សោយ ដូច្នេះ ។ ការប្រព្រឹត្តទៅនៃមគ្គនោះឯង ឈ្មោះថា **ឋិតិ** ព្រោះហេតុនោះ គួរពោលថា ចម្រើនដើម្បីការតាំងមាំ ។ សេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ ក្នុងខណៈនៃលោកុត្តរមគ្គ របស់ភិក្ខុនោះ រមែងបានឈ្មោះ ៤ យ៉ាង មាន **អនុប្បន្នានំ ចាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ** ជាដើម ។ នេះជាកថាពោលដោយសម្មប្បធាន ក្នុងខណៈនៃលោកុត្តរមគ្គ ។ ក្នុងទីនេះ

លោកសម្ដែងសម្មប្បធាន ជាលោកិយផង លោកុត្តរផង លាយឡំគ្នា ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាសតិនិទ្ទេសដូចតទៅ បទថា **កាយេ** បានដល់ក្នុងរូបកាយ ។ ក្នុងទីនេះ រូបកាយ លោកបំណងយកថាជាកាយ ( ពួក ) ដូចជាហត្ថិកាយ ពួកដំរី រថកាយ ពួករថជាដើម ដោយអត្ថថា ជាទីប្រជុំនៃអវយវៈធំតូច និងធម៌ទាំងឡាយ មានសក់ជាដើម ។ មួយទៀត ឈ្មោះថា **កាយ** ដោយអត្ថថា ជាទីកើតនៃវត្ថុដែលគួរខ្ពើមទាំងឡាយ ដូចដែលឈ្មោះថា កាយ ដោយអត្ថថា ជាទីប្រជុំដូច្នោះ ។ រូបកាយនោះ ឈ្មោះថា កាយ ព្រោះជាទីកើតនៃវត្ថុគួរខ្ពើម គឺគួរខ្ពើមក្រៃលែង ។ ពាក្យថា ជាទីកើត បានដល់ ប្រទេសដែលកើត ។ ក្នុងពាក្យនោះ មានអធិប្បាយថា ឈ្មោះថា ជាទីកើត ព្រោះអត្ថថា វត្ថុទាំងឡាយរមែងកើតអំពីកាយនោះ ។ អ្វីកើត គឺវត្ថុគួរខ្ពើមមានសក់ជាដើមកើត ។ ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីកើតរបស់វត្ថុគួរខ្ពើម ដោយប្រការដូច្នេះ ។

បទថា **កាយានុបស្សី** បានដល់ ពិចារណាឃើញកាយ ជាប្រក្រតី ឬពិចារណាឃើញនូវកាយ ។ សូម្បីពោលថា **កាយេ** ( ក្នុងកាយ ) ហើយនៅប្រារព្ធកាយ ជាលើកទី ២ ទៀតថា **កាយានុបស្សី** ( ពិចារណាឃើញកាយ ) គប្បីជ្រាបថា លោកពោលដើម្បីសម្ដែងការកំណត់ និងចែកក្រុមដោយមិនលាយឡំគ្នា ។ ដោយហេតុនោះ ទើបមិនមែន **កាយេ វេទនានុបស្សី** ឬ **កាយេ ចិត្តធម្មានុបស្សី** ដែលពិតជា **កាយេ កាយានុបស្សី** នោះឯង

ព្រោះហេតុនោះ ទើបលោកសម្តែងការកំណត់ដោយមិនលាយឡំគ្នា ដោយការសម្តែងអាការនៃការពិចារណា ឃើញកាយក្នុងវត្ថុ គឺកាយនោះឯង ។ មួយទៀត ភិក្ខុពិចារណាឃើញធម៌ឯណានីមួយ ផុតចាកអវយវៈតូចធំក្នុងកាយក៏មិនមែន ពិចារណាឃើញស្ត្រី និងបុរស ក្រៅពីសក់ និងរោមជាដើម ក៏មិនមែន ។ មួយវិញទៀត ក្នុងទីនេះសូម្បីក្នុងកាយ ពោលគឺទីប្រជុំនៃភូតរូប និងឧបាទាយរូប មានសក់ និងរោមជាដើម ភិក្ខុពិចារណាឃើញធម៌ឯណានីមួយផុតចាកភូតរូប និងឧបាទាយរូប ក៏មិនមែន ដែលពិតពិចារណាឃើញការប្រជុំអវយវៈតូចធំដូចពិចារណាឃើញគ្រឿងប្រកបរបស់រថ ពិចារណាឃើញការប្រជុំសក់ និងរោមជាដើម ដូចពិចារណាឃីញចំណែករបស់នគរ ពិចារណាឃើញការប្រជុំភូតរូប និងឧបាទាយរូបដូចញែកដើមចេក ស្លឹកចេក និងត្រយូងចេកចេញអំពីគ្នា និងដូចលាតបាតដៃទទេ ព្រោះហេតុនោះ ទើបលោកសម្តែងការចែកចេញអំពីដុំ ( ឃនៈ ) ដោយការសម្តែងដោយប្រការផ្សេងគ្នារបស់វត្ថុ ពោលគឺកាយដោយអំណាចការប្រជុំគ្នានោះឯង ។ ពិតហើយ ក្នុងបទនេះកាយក្តី ស្រីក្តី ប្រុសក្តី ធម៌ណាមួយដទៃក្តី ផុតចាកការប្រជុំគ្នាតាមដែលពោលហើយ រមែងមិនប្រាកដ ។ តែក្នុងហេតុត្រឹមតែការប្រជុំនៃធម៌តាមដែលពោលហើយនោះឯង ទើបសត្វទាំងឡាយ ធ្វើនូវការប្រកាន់ខុសនោះៗ ។ ដោយហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

បុគ្គលឃើញវត្ថុណា វត្ថុនោះ ឈ្មោះថា គេឃើញហើយ
ក៏មិនមែន វត្ថុណា ដែលឃើញហើយ ឈ្មោះថា រមែងមិន

ឃើញវត្ថុនោះ បុគ្គលវង្វេង កាលមិនឃើញរមែងជាប់ កាល
ជាប់ រមែងមិនរួចផុត ដូច្នេះ ។

លោកពោលយ៉ាងនេះ ដើម្បីសម្តែងការចែកឃនៈជាដើម ។ ម្យ៉ាងទៀត ពាក្យថា ជាដើម ក្នុងពាក្យនេះ គប្បីជ្រាបសេចក្តីដូចតទៅ ភិក្ខុនេះពិចារណាឃើញកាយក្នុងកាយនោះឯង មិនមែនពិចារណាឃើញធម៌ដទៃឡើយ ។ មានពាក្យអធិប្បាយដូចម្តេច មានពាក្យអធិប្បាយថា មិនមែនពិចារណាឃើញភាពជារបស់ទៀង ជាសុខ ជាតួខ្លួន ជារបស់ស្អាតក្នុងកាយនេះដែលជារបស់មិនទៀង ជាទុក្ខ មិនមែនជាតួខ្លួន និងជារបស់មិនស្អាត ដូចឃើញទឹកក្នុងពេលថ្ងៃបណ្តើរកូន ដែលមិនមានទឹកដូច្នោះ សេចក្តីពិតពិចារណាឃើញកាយ អធិប្បាយថា ពិចារណាឃើញការប្រជុំនៃអាការដែលមិនទៀង ជាទុក្ខ មិនមែនតួខ្លួន និងជារបស់មិនស្អាតនោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ដល់កាយណា ដែលមានខ្យល់អស្សាសបស្សាសៈជាខាងដើម និងមានឆ្អឹងដែលបែកជាលម្អិតតូចធំជាទីបំផុត ក្នុងមហាសតិប្បដ្ឋានសូត្រ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ។បេ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ និងកាយណាដែលព្រះសារីបុត្ត ពោលក្នុងសតិប្បដ្ឋានកថាខាងមុខថា បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវពួកដី ថាមិនទៀង ពួកទឹក ពួកភ្លើង ពួកខ្យល់ ពួកសក់ ពួករោម ពួកសម្បុរថ្ងៃ ពួកស្បែក ពួកសាច់ ពួកឈាម ពួកសរសៃ ពួកឆ្អឹង ពួកខួរក្នុង

ធ្វើង ថាមិនទៀង ដូច្នេះ ភិក្ខុពិចារណាឃើញកាយក្នុងកាយ ដោយពិចារណាឃើញកាយទាំងអស់នោះ ក្នុងកាយនេះឯង ។

មួយវិញទៀត គប្បីឃើញអត្ថយ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយ ពោលគឺការប្រជុំនៃធម៌ មានសក់ជាដើម ក្នុងកាយដោយមិនពិចារណាវត្ថុណាមួយ ដែលគួរប្រកាន់ក្នុងកាយយ៉ាងនេះថា អញ ឬរបស់អញ តែពិចារណាឃើញការប្រជុំនៃធម៌ផ្សេងៗ មានសក់ និងរោមជាដើមនោះៗ ឯង ។ មួយវិញទៀត គប្បីឃើញអត្ថយ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ ដោយពិចារណាឃើញកាយ ពោលគឺការប្រជុំនៃអាការ មានអនិច្ចលក្ខណៈជាដើម ទាំងអស់ដែលមានន័យមកហើយ ខាងមុខដោយលំដាប់ថា ពិចារណាឃើញកាយនេះ ថាមិនទៀង មិនមែនថាទៀងទេ ដូច្នេះ ។ នេះជាសេចក្ដីទូទៅក្នុងសតិប្បដ្ឋាន ៤ ។

បទថា **កាយេ កាយានុបស្សី** បានដល់ ពិចារណាឃើញកាយឯណានីមួយ ក្នុងកាយដូចដែលបានពោលជាចំណែកច្រើន មានអស្សាសកាយ និងបស្សាសកាយជាដើម ។

បទថា **វិហរតិ** នេះ សំដែងដល់ការប្រកបវិហារធម៌ណាមួយ ក្នុងវិហារធម៌ គឺឥរិយាបថ ៤ ។ អធិប្បាយថា ភិក្ខុផ្លាស់ការនឿយហត់ក្នុងឥរិយាបថមួយ ដោយឥរិយាបថដទៃ ហើយធ្វើខ្លួនមិនឲ្យដួល គឺឲ្យប្រព្រឹត្តទៅ ។

ពាក្យថា **អាតាបី** នេះ សំដែងដល់ការប្រកបសេចក្ដីព្យាយាម ដែលកំណត់កាយ ។ ព្រោះភិក្ខុនោះ ជាអ្នកប្រកបដោយសេចក្ដីព្យាយាម ដែលលោក

ពោលថា អាតាបៈ ព្រោះដុតកិលេសក្នុងភព ៣ ក្នុងសម័យនោះ ហេតុនោះ ទើបលោកពោលថា **អាតាបី** ដូច្នេះ ។

បទថា **សម្បជានោ** បានដល់ ជាអ្នកប្រកបដោយញាណ ពោល គឺ សម្បជញ្ញៈដែលកំណត់កាយ ។

បទថា **សតិមា** បានដល់ ដែលប្រកបដោយសតិ កំណត់កាយ ។ ក៏ព្រោះភិក្ខុនេះកំណត់អារម្មណ៍ដោយសតិហើយ ពិចារណាឃើញដោយបញ្ញា ។ ពិតហើយ អ្នកមិនមានសតិ នឹងពិចារណាឃើញមិនបានឡើយ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាងដូច្នេះ ហេតុនោះ ក្នុងពាក្យនេះ ទើបលោកពោលដល់កម្មដ្ឋាន គឺកាយានុបស្សនាសតិប្បដ្ឋាន ដោយន័យត្រឹមតែប៉ុណ្ណោះថា **កាយេ កាយានុបស្សី វិហរតិ** ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះការរួញរាខាងក្នុង ធ្វើអន្តរាយដល់បុគ្គលមិនមានសេចក្តីព្យាយាម មិនមានសម្បជញ្ញៈ រមែងវង្វេងក្នុងការកំណត់ឧបាយ និងក្នុងការវៀរវត្ថុមិនជាឧបាយ បុគ្គលមិនមានសតិរមែងប្រព្រឹត្តទៅមិនបាន ដែលនឹងមិនបោះបង់វត្ថុដែលជាឧបាយ និងមិនប្រកាន់ វត្ថុដែលមិនជាឧបាយ ដោយហេតុនោះ ទើបកម្មដ្ឋាននោះមិនសម្រេចដល់ភិក្ខុនោះ ហេតុនោះ គប្បីជ្រាបថា កម្មដ្ឋាននោះ រមែងសម្រេចដោយអានុភាពរបស់ធម៌ទាំងឡាយណា ដើម្បីសម្តែងដល់ធម៌ទាំងឡាយនោះ ទើបត្រាស់សេចក្តីនេះថា **អាតាបី សម្បជានោ**

**សតិមា** ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកាយានុបស្សនាសតិប្បដ្ឋាន និងអង្គប្រកបហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងអង្គនៃបហាន ទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិនេយ្យ** បានដល់ កម្ចាត់ដោយតទង្គវិន័យ ឬវិក្ខម្ភនវិន័យ ។

បទថា **លោកេ** សេចក្តីថា កាយណាកំណត់ក្នុងកាលមុន កាយនុ៎ះឯង ឈ្មោះថា លោក ក្នុងទីនេះ ដោយអត្ថថា បែកធ្លាយទៅ លះបង់អភិជ្ឈា និងទោមនស្ស ក្នុងលោកនោះចេញ ។

ម្យ៉ាងទៀត ព្រោះភិក្ខុនោះ រមែងលះបង់អភិជ្ឈា និងទោមនស្ស ក្នុងចំណែកត្រឹមតែកាយប៉ុណ្ណោះក៏មិនមែន រមែងលះសូម្បីវេទនាជាដើមទៀតផង ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងវិភង្គថា ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក ដូច្នេះ ។ គប្បីជ្រាបថា ទ្រង់ត្រាស់បទនេះ ដោយការពង្រីកសេចក្តីនូវធម៌ទាំងនោះ ព្រោះធម៌ទាំងនោះ រាប់បញ្ចូលក្នុងលោក ។

ព្រះមានព្រះភាគត្រាស់ ( ក្នុងអភិធម្ម វិភង្គ ) ថា បណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ កាយនោះឯង ឈ្មោះថា លោក ដូច្នេះ ។ នេះជាពាក្យអធិប្បាយក្នុងបទថា **លោកេ** នេះ ។ បទថា **អភិជ្ឈាទោមនស្សំ** ជាពាក្យសមាស ។ ក្នុងវាងបាឋៈក្នុងសំយុត្តនិកាយ និងអង្គុត្តរនិកាយ អាចារ្យទាំងឡាយពោលទុកផ្សេងគ្នា ។ ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា ជាហេតុឲ្យជន

ទាំងឡាយសម្ងំន គឺប្រាថ្នា ឬសម្ងំនឯង ឬត្រឹមតែជាការសម្ងំនប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងបទថា **អភិជ្ឈាទោមនស្សំ** នេះ ព្រោះកាមច្ឆន្ទៈ សង្គ្រោះចូលជាមួយអភិជ្ឈាសព្ទ ព្យាបាទសង្គ្រោះចូលជាមួយទោមនស្សសព្ទ ហេតុនោះគប្បីជ្រាបថា ត្រាស់ដល់ការលះនីវរណៈ ដោយសម្តែងដល់ធម៌ទាំងពីរដែលជាធម៌មានកម្លាំងទាក់ទងក្នុងនីវរណៈ ។

ម្យ៉ាងទៀត ក្នុងបទនេះពោលដោយការផ្សេងគ្នា ត្រាស់ដល់ការលះសេចក្តីត្រេកអរដែលជាមូលនៃកាយសម្បត្តិ ដោយកម្ចាត់អភិជ្ឈា លះនូវការមិនត្រេកអរដែលជាមូលនៃកាយវិបត្តិ ដោយកម្ចាត់ទោមនស្ស ម្យ៉ាងទៀត ត្រាស់ការលះសេចក្តីត្រេកអរក្នុងកាយដោយកម្ចាត់អភិជ្ឈា លះនូវការមិនត្រេកអរក្នុងការអប់រំកាយ ដោយកម្ចាត់ទោមនស្ស លះនូវការបន្ថែមនូវការស្អាត និងសេចក្តីសុខជាដើម ដែលមិនជាការពិតក្នុងកាយដោយកម្ចាត់អភិជ្ឈា លះនូវការនាំចេញនូវការមិនស្អាត មិនសុខជាដើម ដែលជារបស់ពិតក្នុងកាយដោយកម្ចាត់ទោមនស្ស ឈ្មោះថា ទ្រង់សម្តែងអានុភាពនៃសេចក្តីព្យាយាម និងសមត្ថភាពនៃសេចក្តីព្យាយាមរបស់ព្រះយោគាវចរ ដោយពាក្យនោះ ។ អានុភាពនៃសេចក្តីព្យាយាមនេះ គឺព្រះយោគាវចរជាអ្នកផុតចាកសេចក្តីត្រេកអរ មិនត្រេកអរ អត់សង្កត់នូវការមិនត្រេកអរ និងការត្រេកអរ និងជាអ្នកវៀរចាកការបន្ថែមក្នុងវត្ថុដែលមិនពិត និងការនាំចេញនូវវត្ថុដែលពិត ។ មួយទៀត ព្រះយោគាវចរនោះជាអ្នកផុតចាកការត្រេកអរ មិនត្រេកអរ ជាអ្នកអត់សង្កត់ការមិនត្រេកអរនិងការត្រេកអរ មិនបន្ថែមក្នុងវត្ថុដែលមិនពិត និងមិនកម្ចាត់វត្ថុ

ដែលពិតជាអ្នកអាចក្នុងសេចក្តីព្យាយាម ដោយប្រការដូច្នេះ ។

ន័យមួយទៀត ក្នុងបទថា **កាយេ កាយានុបស្សី** នេះ ត្រាស់ដល់កម្មដ្ឋាននៃអនុបស្សនា ក្នុងបទថា **វិហរតិ** នេះ ត្រាស់ដល់ការបរិហារកាយរបស់ភិក្ខុអ្នកបំពេញកម្មដ្ឋានដោយវិហារធម៌ ដូចពោលហើយ ។ គប្បីជ្រាបថា ក្នុងបទថា **អាតាបី** ជាដើម ត្រាស់ដល់សម្មប្បធានដោយការព្យាយាម ត្រាស់កម្មដ្ឋានដែលមានប្រយោជន៍ទាំងអស់ ឬឧបាយនៃការបរិហារកម្មដ្ឋានដោយសតិសម្បជញ្ញៈ ត្រាស់សមថៈដែលបានដោយអំណាចកាយានុបស្សនាដោយសតិ ត្រាស់វិបស្សនាដោយសម្បជញ្ញៈ ត្រាស់ផលរបស់ភាវនាដោយកម្ចាត់អភិជ្ឈា និងទោមនស្ស ។

ម្យ៉ាងទៀត ក្នុងបទថា **វេទនាសុ វេទនានុបស្សី** គប្បីជ្រាបការប្រកបសេចក្តីក្នុងបទនៃវេទនាជាដើម ដូចតទៅនេះថា ដោយប្រកបតាមដែលប្រកបបានដោយន័យដូចពោលហើយ ក្នុងកាយានុបស្សនានោះឯង ។ អត្ថដែលមិនទូទៅមានដូចតទៅនេះ ភិក្ខុពិចារណាឃើញវេទនាឯណានីមួយ ដោយការមិនទៀងជាដើម មួយបែបៗ ទៅក្នុងវេទនាទាំងឡាយមានច្រើនប្រភេទ មានសុខវេទនាជាដើម ពិចារណាឃើញចិត្តមួយដួងៗ ដោយភាពមិនទៀងជាដើម មួយបែបៗ ទៅក្នុងចិត្តមាន ១៦ ប្រភេទ មានចិត្តប្រកបដោយរាគៈជាដើម ពិចារណាឃើញធម៌នីមួយៗ ដោយការមិនទៀងជាដើម មួយបែបៗ ទៅក្នុងធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស វៀរកាយវេទនា និងចិត្ត ឬពិចារណាឃើញធម៌មាននីវរណៈជាដើម ដោយន័យដូចពោលហើយ ក្នុងសតិប្បដ្ឋានសូត្រ ។

ម្យ៉ាងទៀត ក្នុងបទទាំងនេះគប្បីជ្រាបថា បទថា **កាយេ** ជាឯកវចនៈ ព្រោះសរីរៈ មានមួយ ។ បទថា **ចិត្តេ** ជាឯកវចនៈ ទ្រង់ធ្វើដោយកាន់យកជាតិ ព្រោះមិនមានការផ្សេងនៃសភាវៈរបស់ចិត្ត ។ ម្យ៉ាងទៀត ភិក្ខុពិចារណាឃើញវេទនាជាដើមដោយប្រការណា ភិក្ខុកាលពិចារណាដោយប្រការនោះ គប្បីជ្រាបថា ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ពិចារណាឃើញចិត្តក្នុងចិត្ត ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ។ គប្បីពិចារណាឃើញវេទនាដូចម្តេច គប្បីពិចារណាឃើញសុខវេទនា ដោយភាពជាទុក្ខ គប្បីពិចារណាឃើញទុក្ខវេទនាដោយភាពដូចជាសរ គប្បីពិចារណាឃើញអទុក្ខមសុខវេទនាដោយភាពជារបស់មិនទៀង ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា

> អ្នកឯណាបានឃើញសុខវេទនា ថាជាទុក្ខវេទនាវិញ បានឃើញ
> ទុក្ខវេទនា ថាជាកូនសរ បានឃើញអទុក្ខមសុខវេទនានោះ
> ថាជាសភាវៈមិនទៀងទៅវិញ ។ បើភិក្ខុបានឃើញដោយប្រពៃ
> ( រមែង ) កំណត់ដឹងនូវវេទនាទាំងឡាយ ដូច្នេះ ។

មួយទៀត គប្បីពិចារណាឃើញវេទនាទាំងអស់ដោយភាពជាទុក្ខ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា **យំកិញ្ចិ វេទយិតំ សព្វន្តំ ទុក្ខស្មិន្តិ វទាមិ** តថាគតពោលថា អារម្មណ៍ឯណានីមួយដែលបុគ្គលសោយហើយ អារម្មណ៍ទាំងអស់នោះ ក៏ជាទុក្ខ ។

ម្យ៉ាងទៀត គប្បីពិចារណាឃើញដោយភាពជាសុខខ្លះ ទុក្ខខ្លះ ។ ដូចព្រះ

នាងធម្មទិន្នាថេរីពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

សុខវេទនាមានកិរិយាស្ថិតនៅជដែល ដែលជាសុខមានការប្រែប្រួលទៅវិញជាទុក្ខ ទុក្ខវេទនាមានកិរិយាស្ថិតនៅជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញជាសុខ ឯអទុក្ខមសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹង ជាទុក្ខ ដូច្នេះ ។

តែក៏គួរពិចារណាវេទនាដោយអំណាចអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចិត្ត និងធម៌ដូចតទៅនេះ

គប្បីពិចារណាឃើញចិត្តជាមុន ដោយអំណាចនៃការផ្សេងគ្នា និងប្រភេទនៃអារម្មណ៍ អធិបតី សហជាត ភូមិ កម្ម វិបាក និងកិរិយាជាដើមនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម និងនៃចិត្ត ១៦ ប្រភេទ មានចិត្តប្រកបដោយរាគៈជាដើម ។ គប្បីពិចារណាធម៌ទាំងឡាយដោយអំណាចនៃលក្ខណៈរបស់ខ្លួន និងសាមញ្ញលក្ខណៈនៃសុញ្ញតាធម៌នៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម និងនៃធម៌ដែលមាន និងមិនមានជាដើម ។ ម្យ៉ាងទៀត ក្នុងបទនេះ អភិជ្ឈា និងទោមនស្សក្នុងលោក ពោលគឺកាយដែលភិក្ខុលះបានហើយ ភិក្ខុនោះ ក៏ឈ្មោះថា លះអវិជ្ជា និងទោមនស្សនោះក្នុងលោក មានវេទនាជាដើមបានផងក៏ពិត តែក៏ត្រាស់ក្នុងទីទាំងពួង ដោយអំណាចបុគ្គលផ្សេងគ្នា និងដោយអំណាចការចម្រើនសតិប្បដ្ឋាន ដែលមានក្នុងខណៈផ្សេងគ្នា ។ ម្យ៉ាងទៀត កាលលះបានក្នុងចំណែកមួយហើយ សូម្បីក្នុងចំណែកដ៏សេស

ក៏ឈ្មោះថា លះបានផងដែរ ដោយហេតុនោះ គប្បីជ្រាបថា ទ្រង់ត្រាស់យ៉ាងនេះ ដើម្បីសម្ដែងការលះអភិជ្ឈា និងទោមនស្សនោះ ក្នុងលោកនោះ ។

សតិប្បដ្ឋានទាំង ៤ នេះ រមែងបានក្នុងចិត្តផ្សេងៗ គ្នាក្នុងចំណែកខាងដើម ដោយប្រការដូច្នេះ ។ ភិក្ខុរមែងកំណត់កាយ ដោយចិត្តដទៃ កំណត់វេទនា ដោយចិត្តដទៃ កំណត់ចិត្តដោយចិត្តដទៃ កំណត់ធម៌ទាំងឡាយដោយចិត្តដទៃ តែក្នុងខណៈលោកុត្តរមគ្គ សតិប្បដ្ឋាន ៤ រមែងបានក្នុងចិត្តតែមួយប៉ុណ្ណោះ ។

សតិសម្បយុត្តដោយវិបស្សនារបស់បុគ្គលដែលកំណត់កាយ តាំងពីដើម ឈ្មោះថា កាយានុបស្សនា ។ បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា កាយានុបស្សី ។ សតិសម្បយុត្តដោយមគ្គក្នុងខណៈនៃមគ្គ របស់បុគ្គលអ្នកខ្វល់ខ្វាយក្នុងវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា កាយានុបស្សនា បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា កាយានុបស្សី ។ សតិសម្បយុត្តដោយវិបស្សនារបស់បុគ្គលដែលកំណត់វេទនា កំណត់ចិត្ត កំណត់ធម៌ទាំងឡាយ ឈ្មោះថា ធម្មានុបស្សនា បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា ធម្មានុបស្សី ។ សតិសម្បយុត្តដោយមគ្គក្នុងខណៈនៃមគ្គ របស់បុគ្គលដែលខ្វល់ខ្វាយក្នុងវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា ធម្មានុ-បស្សនា បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា ធម្មានុបស្សី ។

ការសម្ដែងយ៉ាងនេះ រមែងតាំងនៅក្នុងបុគ្គល ។ តែសតិកំណត់កាយដែលជាគ្រឿងលះការយល់ខុសក្នុងកាយថា ស្អាត រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា កាយានុបស្សនា ។ សតិកំណត់វេទនាដែលជាគ្រឿង

លះការយល់ខុសក្នុងវេទនាថាជាសុខ រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា វេទនានុបស្សនា ។ សតិកំណត់ចិត្តដែលជាគ្រឿងលះការយល់ខុសក្នុងចិត្ត ថាជារបស់ទៀង រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តានុបស្សនា សតិកំណត់ធម៌ដែលជាគ្រឿងលះការយល់ខុសក្នុងធម៌ទាំងឡាយ ថាជាតួខ្លួន រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា ធម្មានុបស្សនា ។ សតិសម្បយុត្ត ដោយមគ្គតែម្យ៉ាង រមែងបានឈ្មោះ ៤ ដោយការញុំាងកិច្ច ៤ ឲ្យសម្រេចដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា តែក្នុងខណៈលោកុត្តរមគ្គ សតិប្បដ្ឋាន ៤ រមែងបានក្នុងចិត្តមួយប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាសមាធិនិទ្ទេសដូចតទៅ

បទថា **វិវិច្ចេវ កាមេហិ** បានដល់ ស្ងាត់ វៀរ ចៀសចេញចាកកាមទាំងឡាយ ។ គប្បីជ្រាបថា **ឯវ** អក្ខរៈក្នុងបទនេះ មានសេចក្តីថា ពិតប្រាកដ ។ ព្រោះ **ឯវ** អក្ខរៈមានសេចក្តីថា ពិតប្រាកដ ហេតុនោះ ទើបសម្តែងដល់ភាពដែលកាមមិនមានក្នុងខណៈចូលដល់បឋមជ្ឈាន ជាបដិបក្ខចំពោះបឋមជ្ឈាននោះ និងការសម្រេចបឋមជ្ឈាននោះដោយការលះបង់កាមនោះឯង ។ សេចក្តីនេះដូចម្តេច ព្រោះកាលធ្វើសេចក្តីពិតប្រាកដ ( កំណត់ ) យ៉ាងនេះថា **វិវិច្ចេវ កាមេហិ** បឋមជ្ឈាននេះ រមែងប្រាកដ កាមទាំងឡាយជាបដិបក្ខចំពោះឈាននេះពិតប្រាកដ កាលនៅមានកាម ឈាននេះ រមែងប្រព្រឹត្តទៅមិនបាន ។ ដូចសភាពងងឹត នៅមានពន្លឺប្រទីបក៏បំភ្លឺទៅមិនដល់ ។ ការសម្រេចឈាន

នោះដោយការលះបង់កាមនោះឯង ដូចការដល់ត្រើយនាយដោយការលះបង់ត្រើយអាយ ព្រោះហេតុនោះ ទើប **ឯវ** អក្ខរៈ ធ្វើនូវភាពពិតប្រាកដ ។

ក្នុងបទនោះ មានពាក្យសួរថា ព្រោះហេតុអ្វី ទើបត្រាស់ **ឯវ** អក្ខរៈនេះក្នុងបទដំបូងប៉ុណ្ណោះ មិនត្រាស់ក្នុងបទក្រោយ ភិក្ខុសូម្បីមិនស្ងាត់ចាកអកុសលធម៌ ក៏នឹងចូលឈានបានឬ សេចក្តីនោះមិនគួរយល់យ៉ាងនោះ ព្រោះថា ទ្រង់ត្រាស់ **ឯវ** អក្ខរៈហើយក្នុងបទដំបូង ព្រោះការរលាស់ចេញចាកកាមនោះ ។ ម្យ៉ាងទៀត ឈាននេះជាគ្រឿងរលាស់ចេញចាកកាមទាំងឡាយនោះឯង ព្រោះឈានកន្លងកាមធាតុ និងព្រោះជាបដិបក្ខចំពោះកាមរាគ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ ( ក្នុងឥតិវុត្តកៈ ) ថា ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់ នេក្ខម្មៈដូច្នេះ ។ សូម្បីក្នុងបទក្រោយក៏គប្បីពោល **ឯវ** អក្ខរៈដូចដែលព្រះមានព្រះភាគ ទ្រង់នាំ **ឯវ** អក្ខរៈ មកត្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) នេះថា ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈទី ២ ( គឺសកទាគាមី ) ក៏មានតែក្នុងសាសនានេះ ដូច្នេះ ព្រោះថា បុគ្គលណាមួយមិនស្ងាត់ចាកអកុសលធម៌ ពោលគឺនីវរណៈ សូម្បីដទៃចាកកាមនេះ ក៏មិនអាចចូលឈានបាន ព្រោះហេតុនោះ គប្បីឃើញ **ឯវ** អក្ខរៈនេះក្នុងបទពីរយ៉ាងនេះថា **វិវិច្ចេវ កាមេហិ វិវិច្ចេវ អកុសលេហិ** ដូច្នេះ ។ ក្នុងបទពីរនេះ តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និស្សរណវិវេក និងចិត្តវិវេក កាយវិវេក ឧបធិវិវេក រមែងសង្គ្រោះដោយពាក្យទូទៅនេះថា **វិវិច្ច** ក៏ពិត តែក៏គប្បី

ឃើញកាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក ក្នុងចំណែកខាងដើម គប្បីឃើញ កាយវិវេក ចិត្តវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និងនិស្សរណវិវេក ក្នុងខណៈនៃលោកុត្តរមគ្គ ។

លោកពោលដល់វត្ថុកាមពួកណា ក្នុងមហានិទ្ទេស ដោយន័យជាដើមថា ពួកវត្ថុកាមដូចម្តេច ។ រូបជាទីគាប់ចិត្ត ដូច្នេះ ។ និងលោកពោលដល់ កិលេសកាមពួកណា ក្នុងមហានិទ្ទេស និងក្នុងវិភង្គយ៉ាងនេះថា ឆន្ទៈ ឈ្មោះ ថា កាម រាគៈ ឈ្មោះថា កាម ឆន្ទរាគៈ ឈ្មោះថា កាម ការត្រិះរិះ ឈ្មោះ ថា កាម រាគៈ ឈ្មោះថា កាម ការត្រិះរិះ និងរាគៈ ឈ្មោះថា កាម ដូច្នេះ ។ គប្បីឃើញថា កាមទាំងអស់នោះ លោកសង្គ្រោះហើយនោះឯង ដោយ ពាក្យថា **កាមេហិ** នេះ ។ កាលបើយ៉ាងនេះ អត្ថរបស់បទថា **វិវិច្ចេវ កាមេហិ** បានដល់ ស្ងាត់ចាកវត្ថុកាមនោះឯងក៏គួរ ។ ដោយបទនោះ ឈ្មោះ ថា លោកពោលដល់កាយវិវេក ។

អត្ថរបស់បទថា **វិវិច្ច អកុសលេហិ ធម្មេហិ** បានដល់ ស្ងាត់ចាកអំពី កិលេសកាម ឬអកុសលទាំងអស់ ដូច្នេះក៏គួរ ។ ដោយបទនោះ ឈ្មោះថា លោកពោលដល់ ចិត្តវិវេក ។ មួយវិញទៀត ក្នុងពីរបទនេះ ដោយបទដំបូង ឈ្មោះថា ប្រកាសការលះកាមសុខ ព្រោះពោលដល់ការស្ងាត់ចាកវត្ថុកាម ដោយបទទីពីរ ឈ្មោះថា ប្រកាសការកំណត់នេក្ខម្មសុខ ព្រោះពោលដល់ ការស្ងាត់ចាកកិលេសកាម ។ ម្យ៉ាងទៀត ព្រោះពោលដល់ការស្ងាត់ចាកវត្ថុ- កាម និងកិលេសកាម គប្បីជ្រាបថា បណ្តាបទទាំងនោះ ដោយបទដំបូង ឈ្មោះ

ថា ប្រកាសការលះវត្ថុដែលសៅហ្មង ដោយបទទី ២ ឈ្មោះថា ប្រកាសការលះសេចក្ដីសៅហ្មង ។ ដោយបទដំបូង ឈ្មោះថា ប្រកាសការលះបង់ហេតុនៃសេចក្ដីឡេះឡោះ ដោយបទទី ២ ឈ្មោះថា ប្រកាសការលះហេតុនៃភាពជាបុគ្គលពាល និងដោយបទដំបូង ឈ្មោះថា ប្រកាសសេចក្ដីបរិសុទ្ធដោយការប្រកប ( ការមិនសម្លាប់សត្វជាដើម ) ដោយបទទី ២ ឈ្មោះថា ប្រកាសការជម្រះអធ្យាស្រ័យ ។ បណ្ដាកាមដែលពោលក្នុងបទថា **កាមេហិ** នេះ ក្នុងចំណែកវត្ថុកាម មានន័យប្រមាណប៉ុណ្ណេះ ។

ចំណែកក្នុងកិលេសកាម មានន័យដូចតទៅនេះថា កាមច្ឆន្ទៈនោះឯងមានច្រើនប្រភេទដោយបទជាដើមយ៉ាងនេះថា ឆន្ទៈ និងរាគៈ លោកបំណងថាជាកាម ។ កាមច្ឆន្ទៈនោះ សូម្បីទាក់ទងក្នុងអកុសល ក៏ត្រាស់ដោយឡែក ក្នុងវិភង្គដោយន័យជាដើមថា ត្រង់ពាក្យថា ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ សេចក្ដីថា បណ្ដាធម៌ទាំងនោះ កាមទាំងឡាយ តើដូចម្ដេច ។ ឆន្ទៈ ឈ្មោះថា កាមដូច្នេះ ព្រោះជាបដិបក្ខចំពោះអង្គឈានខាងលើ ម្យ៉ាងទៀត ត្រាស់ក្នុងបទដំបូង ព្រោះជាកិលេសកាម ត្រាស់ក្នុងបទទីពីរ ព្រោះទាក់ទងក្នុងអកុសល ។

មួយវិញទៀត មិនត្រាស់ថា **កាមតោ** ចាកកាម ត្រាស់ថា **កាមេហិ** ព្រោះកាមនោះមានច្រើនប្រភេទ កាលធម៌ពួកដទៃដែលជាអកុសល នៅមានទ្រង់ត្រាស់នីវរណៈទាំងឡាយនោះឯងក្នុងវិភង្គ ដោយន័យជាដើមថា បណ្ដាធម៌ទាំងនោះ ពួកធម៌ជាអកុសល តើដូចម្ដេច ។ កាមច្ឆន្ទៈ ដូច្នេះ ព្រោះ

សម្តែងដល់ភាពជាសត្រូវ និងជាបដិបក្ខចំពោះអង្គឈានខាងលើ ។ ពិតហើយ នីវរណៈទាំងឡាយជាសត្រូវដល់អង្គឈាន អង្គឈានទាំងឡាយនោះឯងក៏ជាបដិបក្ខដល់នីវរណៈទាំងនោះ អធិប្បាយថា កម្ចាត់ធ្វើឲ្យវិនាស ។ ពិតហើយ ព្រះមហាកច្ចានត្ថេរ ពោលទុកក្នុងគម្ពីរបិដកថា សមាធិជាបដិបក្ខដល់កាមច្ឆន្ទៈ បីតិជាបដិបក្ខដល់ព្យាបាទ វិតក្កជាបដិបក្ខដល់ថីនមិទ្ធៈ សុខជាបដិបក្ខដល់ឧទ្ធច្ចកុក្កុច្ចៈ វិចារជាបដិបក្ខដល់វិចិកិច្ឆា ដូច្នេះ ។

ក្នុងបទនេះ ដោយបទថា **វិវិច្ចេវ កាមេហិ** នេះ ជាការត្រាស់ដល់ការស្ងាត់ដោយការសង្កត់កាមច្ឆន្ទៈ ដោយបទថា **វិវិច្ច អកុសលេហិ ធម្មេហិ** នេះ ជាការត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិននីវរណៈទាំង ៥ ។ ដោយការកាន់យកហើយ មិនកាន់យកទៀត ពាក្យដំបូង ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនកាមច្ឆន្ទៈ ដោយបទទី ២ ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិននីវរណៈដ៏សេស ។ ម្យ៉ាងទៀត ក្នុងអកុសលមូល ៣ ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនលោភៈ ដែលមានប្រភេទនៃកាមគុណ ៥ ជាអារម្មណ៍ ដោយពាក្យដំបូង ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនទោសៈ និងមោហៈដែលមានប្រភេទនៃអាឃាតវត្ថុជាដើម ជាអារម្មណ៍ដោយបទទី ២ ។ ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយ មានឱឃៈជាដើម ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនកាមោឃៈ កាមយោគៈ កាមាសវៈ កាមុបាទាន អភិជ្ឈាកាយគន្ថៈ និងកាមរាគសំយោជនៈ ដោយបទដំបូង ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនឱឃៈ យោគៈ អាសវៈ ឧបាទាន

គន្ថៈ និងសំយោជនៈដ៏សេសដោយបទទី ២ ។ ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនតណ្ហា និងកិលេសដែលសម្បយុត្តដោយតណ្ហានោះ ដោយបទដំបូង ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនអវិជ្ជា និងកិលេសដែលសម្បយុត្តដោយអវិជ្ជានោះ ដោយបទទី ២ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថាទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនចិត្តុប្បាទ ៨ ដែលសម្បយុត្តដោយលោភៈ ដោយបទដំបូង ទ្រង់ត្រាស់ដល់ការស្ងាត់ដោយការសង្កត់សង្កិនចិត្តុប្បាទដែលជាអកុសល ៤ ដ៏សេសដោយបទទី ២ ។

កាលទ្រង់សម្តែងអង្គដែលបឋមជ្ឈាន លះបានដោយពាក្យមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងអង្គប្រកប ទើបត្រាស់ថា **សវិតក្កំ សវិចារំ** ជាដើម ។ ក្នុងបទទាំងនោះ វិតក្កមានការលើកចិត្តទុកក្នុងអារម្មណ៍ជាលក្ខណៈ ។ វិចារមានការឈ្ងេចឈ្ងីអារម្មណ៍ជាលក្ខណៈ ។ ម្យ៉ាងទៀត កាលវិតក្ក និងវិចារទាំងនោះ មិនទាន់បែកចាកគ្នាក្នុងចិត្តុប្បាទណាមួយ ការដែលចិត្តធ្លាក់ចុះកាន់អារម្មណ៍ដំបូង ឈ្មោះថា វិតក្ក ដោយអត្ថថា ជាធម៌គ្រោតគ្រាត និងដោយអត្ថថា ជាធម៌ដល់មុន ដូចវាយជួង ការពាក់ព័ន្ធក្នុងអារម្មណ៍ឈ្មោះថា វិចារ ដោយអត្ថថា ជាធម៌ល្អិត និងដោយសភាពឈ្ងេចឈ្ងីអារម្មណ៍ដូចសំឡេងរំពងរបស់ជួង ។ ម្យ៉ាងទៀត ក្នុងវិតក្ក និងវិចារទាំងនេះ វិតក្កមានការផ្សាយទៅក្នុងអារម្មណ៍ មានចិត្តបម្រះនទៀលក្នុងខណៈកើតដំបូង ដូចបក្សីបំណងទីងហើរទៅក្នុងអាកាស ទទះស្លាប និងដូចឃ្មុំតាមក្លិនក្រអូប ហើរទៅទំត្រង់ផ្កាឈូក ដូច្នោះ ។ វិចារមានការប្រព្រឹត្តទៅយ៉ាងស្ងប់ មានចិត្តមិន

បម្រះនទៀលពេក ដូចបក្សីដែលហើរឡើងទៅក្នុងអាកាស សន្ធឹងស្លាបហើរទៅ ដូចឃ្មុំទំត្រង់ផ្កាឈូក ឈ្វេចឈ្វីលើផ្កាឈូក ដូច្នោះ ។

ក្នុងអដ្ឋកថា ទុកនិបាតពោលថា វិតក្កប្រព្រឹត្តទៅដោយការលើកចិត្តទុកក្នុងអារម្មណ៍ ដូចបក្សីធំហើរទៅក្នុងអាកាស យកស្លាបទាំងពីរទទួលខ្យល់ ធ្វើស្លាបទាំងពីរហើរទៅ ដូច្នោះ វិចារប្រព្រឹត្តទៅដោយឈ្វេចឈ្វីអារម្មណ៍ ដូចបក្សីទទះស្លាបដើម្បីវាយខ្យល់ ហើយហើរទៅដូច្នោះ ។ ពាក្យនោះរមែងសមគួរក្នុងការប្រព្រឹត្តទៅ ដោយការពាក់ព័ន្ធក្នុងអារម្មណ៍ ។ តែការផ្សេងគ្នានៃវិតក្ក និងវិចារនោះប្រាកដក្នុងឈានទី ១ និងឈានទី ២ ។ម្យ៉ាងទៀត វិតក្កដូចដៃដែលចាប់យ៉ាន់ណែន វិចារដូចដៃដែលដុសខាត់របស់បុគ្គលដែលចាប់ភាជនៈសំរឹទ្ធដែលមានមន្ទិល គឺប្រែះដោយដៃម្ខាង ទុកយ៉ាន់ណែននោះ ហើយយកច្រាស់ ធ្វើដោយកន្ទុយសត្វ ជ្រលក់ប្រេងដែលផ្សំជាមួយលម្អិត ដុសដោយដៃម្ខាងទៀត ។ ម្យ៉ាងទៀត វិតក្កដូចដៃដែលសូន វិចារដូចដៃដែលរំកិលទៅក្នុងទីផ្សេងៗ របស់ស្មូនឆ្នាំងដែលប្រើក្ដារយន្តធ្វើភាជនៈ ។ម្យ៉ាងទៀត វិតក្កលើកចិត្តទុកក្នុងអារម្មណ៍ ដូចបន្ទាដែលដោតត្រង់កណ្ដាល វិចារឈ្វេចឈ្វីអារម្មណ៍ ដូចបន្ទាដែលបង្វិលខាងក្រៅរបស់បុគ្គល ដែលធ្វើវង្វង់ ។ ឈាននេះរមែងប្រព្រឹត្តទៅជាមួយវិតក្ក និងវិចារដូចដើមឈើ រមែងប្រព្រឹត្តទៅជាមួយផ្កា និងផ្លែ ព្រោះហេតុនោះ ទើបឈាននេះ ហៅថា **សវិតក្កំ សវិចារំ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វិវេកជំ** នេះ ដូចតទៅ ការស្ងាត់ គឺ

វិវេក អធិប្បាយថា ប្រាសចាកនីវរណៈ ។ ម្យ៉ាងទៀត ឈ្មោះថា វិវេក ព្រោះអត្ថថា ស្ងាត់ បានដល់ ស្ងាត់ចាកនីវរណៈ អធិប្បាយថា ក្រុមនៃធម៌ ដែលសម្បយុត្តដោយឈាន ឈ្មោះថា **វិវេកជំ** ព្រោះអត្ថថា កើតអំពីវិវេក នោះ ឬកើតក្នុងវិវេកនោះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **បីតិសុខំ** នេះ ដូចតទៅ ឈ្មោះថា **បីតិ** ព្រោះអត្ថថា ឲ្យឆ្អែតចិត្ត បីតិនោះ មានការឆ្អែតជាលក្ខណៈ ។ បីតិនោះ មាន ៥ យ៉ាង គឺខុទ្ទកាបីតិ បីតិតិចតួច ១ ខណិកាបីតិ បីតិមួយជួរខណៈ ១ ឱក្កន្តិកាបីតិ បីតិជារយៈៗ ១ ឧព្វេង្គាបីតិ បីតិធ្វើឲ្យអណ្តែតឡើង ១ ផរណា-បីតិ បីតិផ្សាយជ្រួតជ្រាប ១ ។

ក្នុងបីតិទាំងនោះខុទ្ទកាបីតិ អាចធ្វើឲ្យត្រឹមតែព្រឺរោមក្នុងរាងកាយប៉ុណ្ណោះ ។ ខណិកាបីតិ ដូចគ្នានឹងផ្លេកបន្ទោរភ្លឹបភ្លែតៗ ។ ឱក្កន្តិកាបីតិ ធ្វើរាងកាយឲ្យឆ្អែត ហើយបាត់ទៅ ដូចរលកបោកច្រាំង ។ ឧព្វេង្គាបីតិ មានកម្លាំងធ្វើឲ្យកាយ អណ្តែតឡើងទៅក្នុងអាកាសមួយរយៈ ។ ផរណាបីតិ មានកម្លាំងក្រៃលែង ។ ពិតហើយ កាលផរណាបីតិនោះកើតឡើង សរីរៈទាំងមូលជ្រួតជ្រាបទៅ ដូច បស្សាវៈ ពេញតម្រងមូត្រ និងដូចជ្រោះភ្នំ ពេញដោយជំនន់ទឹកធំ ។ បីតិ ៥ យ៉ាងនោះ កាលកាន់យកគភ៌ ដល់នូវការចាស់ក្លាដោយជុំវិញ រមែងញុំាងបស្សទ្ធិ ២ យ៉ាង គឺកាយបស្សទ្ធិ និងចិត្តបស្សទ្ធិឲ្យបរិបូរណ៍ ។ បស្សទ្ធិ កាលកាន់ យកគភ៌ ដល់នូវការចាស់ក្លាដោយជុំវិញរមែងញុំាងសុខ ២ យ៉ាង គឺកាយិក-សុខ និងចេតសិកសុខឲ្យបរិបូរណ៍ ។ សុខកាលកាន់យកគភ៌ ដល់នូវការចាស់

ក្លាដោយជុំវិញ រមែងញ៉ាំងសមាធិ ៣ យ៉ាង គឺខណិកសមាធិ ឧបចារសមាធិ និងអប្បនាសមាធិឲ្យបរិបូរណ៍ ។ ក្នុងបីតិទាំងនោះ បីតិដែលលោកបំណង យកក្នុងអត្ថនេះ បានដល់ ផរណាបីតិដែលជាហេតុរបស់អប្បនាសមាធិ ចម្រើន លូតលាស់ ដល់នូវការប្រកបព្រមនៃសមាធិ ។

ម្យ៉ាងទៀត ឈ្មោះថា សុខ ព្រោះអត្ថថា ជាធម្មជាតធ្វើបុគ្គលឲ្យដល់សុខ អធិប្បាយថា សុខកើតដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យដល់នូវសុខ ។ ម្យ៉ាងទៀត សេចក្ដីសប្បាយ ឈ្មោះថា សុខ ធម្មជាតណារមែងទំពាស៊ីដោយល្អ និងជីកការបៀតបៀនផ្លូវកាយ និងចិត្ត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា សុខ បទនេះ ជាឈ្មោះរបស់សោមនស្សវេទនា ។ សេចក្ដីសុខនោះមានការសប្បាយជាលក្ខណៈ ។ កាលបីតិ និងសុខមិនប្រាសចាកគ្នា ក្នុងចិត្តណាមួយ សេចក្ដីត្រេកអរក្នុងការបានអារម្មណ៍ដែលគួរប្រាថ្នាជាបីតិ ការសោយរសនៃអារម្មណ៍ដែលបានហើយជាសុខ ។

បីតិមាននៅក្នុងទីណា សេចក្ដីសុខ រមែងមានក្នុងទីនោះ ។ សេចក្ដីសុខមានក្នុងទីណា បីតិមិនប្រាកដថា មានក្នុងទីនោះទេ ។ បីតិសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ សុខសង្គ្រោះចូលក្នុងវេទនាខន្ធ ។ បីតិដូចជាការបានឃើញ បានស្ដាប់ថា មានទឹកនៅជាយព្រៃរបស់អ្នកដំណើរដែលនឿយហត់ ក្នុងផ្លូវកន្ដារ សុខដូចការចូលទៅអាស្រ័យក្នុងម្លប់ព្រៃ និងការផឹកទឹក ។ ពាក្យនេះ គប្បីជ្រាបថា លោកពោល ព្រោះប្រាកដក្នុងសម័យនោះៗ ។ បីតិនេះ និងសុខនេះ មានដល់ឈាននោះ ឬមានក្នុងឈាននោះ ព្រោះហេតុនោះ ទើបឈាននេះ

ហៅថា **បីតិសុខំ** ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត បីតិផង សុខផង ឈ្មោះថា **បីតិសុខំ** ដូចធម៌ និងវិន័យជាដើម បីតិ និងសុខដែលកើតអំពីវិវេក រមែងមានដល់ឈាននោះ ឬមានក្នុងឈាននោះ ព្រោះហេតុនោះ ទើបឈាននោះ ឈ្មោះថា មានបីតិ និងសុខកើតអំពីវិវេកយ៉ាងនេះ ។ បីតិ និងសុខក្នុងញាណនេះ ក៏កើតអំពីវិវេកនោះឯងដូចគ្នានឹងឈាន ។ មួយវិញទៀត បីតិ និងសុខ មានដល់ឈាននោះ ព្រោះហេតុនោះ ការធ្វើជាអលោបសមាស ( សមាសដែលមិនលុបវិភត្តិ ) ហើយពោលថា **វិវេកជំ បីតិសុខំ** ដោយបទមួយប៉ុណ្ណោះ ដូច្នេះក៏គួរ ។

បទថា **បឋមំ** ឈ្មោះថា បឋម ព្រោះលំដាប់នៃការរាប់ ឈ្មោះថា បឋម ព្រោះអត្ថថា កើតមុនខ្វះ ។ បទថា **ឈានំ** ឈានមាន ២ យ៉ាង គឺអារម្មណូបនិជ្ឈាន ១ លក្ខណូបនិជ្ឈាន ១ ក្នុងឈាន ២ យ៉ាងនោះ សមាបត្តិ ៨ ចូលទៅសម្លឹងអារម្មណ៍ មានបឋវីកសិណជាដើម ព្រោះហេតុនោះ ទើបដល់នូវការរាប់ថា អារម្មណូបនិជ្ឈាន ។ ចំណែកវិបស្សនា មគ្គ និងផល ឈ្មោះថា លក្ខណូបនិជ្ឈាន ។

ក្នុងវិបស្សនា មគ្គ និងផលទាំងនោះ វិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះចូលទៅសម្លឹងនូវលក្ខណៈ មានអនិច្ចលក្ខណៈជាដើម មគ្គ ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះកិច្ចដែលវិបស្សនាធ្វើសម្រេចដោយមគ្គ ចំណែកផល ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះអត្ថថា ចូលទៅសម្លឹងនិរោធសច្ចដែលជាលក្ខណៈដ៏ពិត ។ ក្នុងឈានទាំងពីរនោះក្នុងទីនេះ ក្នុងចំណែកខាងដើម

បំណងយកអារម្មណូបនិជ្ឈាន ក្នុងខណៈនៃលោកុត្តរមគ្គ បំណងយកលក្ខ-ណូបនិជ្ឈាន ព្រោះហេតុនោះ គប្បីជ្រាបថា ឈ្មោះថា ឈាន ព្រោះចូលទៅសម្លឹងអារម្មណ៍ ចូលទៅសម្លឹងលក្ខណៈ និងព្រោះដុតកិលេសដែលជាសត្រូវ ។

បទថា **ឧបសម្បជ្ជ** បានដល់ ចូលដល់ អធិប្បាយថា ដល់ហើយ ។ម្យ៉ាងវិញទៀត អធិប្បាយថា ឲ្យចូលដល់ហើយ គឺឲ្យសម្រេចហើយ ។

បទថា **វិហរតិ** បានដល់ ជាអ្នកមានការដល់ព្រមដោយឈាន មានប្រការដូចពោលហើយ ដោយធម៌ជាគ្រឿងនៅក្នុងឥរិយាបថ ដ៏សមគួរដល់ឈាននោះ ញ៉ាំងកាប្រព្រឹត្តទៅនៃអត្តភាពឲ្យសម្រេច ។

ក្នុងបទថា **វិតក្កវិចារានំ វូបសមា** នេះ មានអធិប្បាយថា ព្រោះស្ងប់រម្ងាប់ គឺឈានកន្លងអង្គឈានពីរយ៉ាងនេះ គឺវិតក្ក និងវិចារ អធិប្បាយថា ព្រោះមិនប្រាកដក្នុងខណៈទុតិយជ្ឈាន ។ ក្នុងបទនោះធម៌ គឺបឋមជ្ឈានសូម្បីទាំងអស់ មិនមានក្នុងទុតិយជ្ឈាន ពិតហើយ ផស្សៈជាដើម ក្នុងបឋមជ្ឈានដទៃនោះឯង ក្នុងទុតិយជ្ឈាននេះ ក៏ដទៃក៏ពិត តែគប្បីជ្រាបថា លោកពោលយ៉ាងនេះថា **វិតក្កវិចារានំ វូបសមា** ដើម្បីសម្តែងថា ការសម្រេចឈានពួកដទៃចាកបឋមជ្ឈាន មានទុតិយជ្ឈានជាដើម រមែងមានព្រោះឈានកន្លងអង្គគ្រោតគ្រាត ។

ក្នុងបទថា **អជ្ឈត្តំ** នេះ បំណងយកខាងក្នុងខ្លួន ព្រោះហេតុនោះ ទើបមានអធិប្បាយថា កើតក្នុងខ្លួន គឺកើតឡើងក្នុងសន្តានរបស់ខ្លួន ។

បទថា **សម្បសាទនំ** មាននិទ្ទិច្ច័យថា សទ្ធាលោកហៅថា **សម្បសាទនំ** ។

សូម្បីឈានក៏ជា **សម្បសាទនំ** ព្រោះប្រកបដោយសេចក្តីផូរផង់ ដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ។ ម្យ៉ាងវិញទៀត ព្រោះឈាននោះធ្វើចិត្តឲ្យផូរផង់ ព្រោះប្រកបដោយសេចក្តីផូរផង់ និងព្រោះចូលទៅស្ងប់ការកម្រើកនៃវិតក្កវិចារ ហេតុនោះ ទើបលោកពោលថា **សម្បសាទនំ** ។ ក្នុងអត្ថវិកប្បនេះ គប្បីជ្រាបការភ្ជាប់បទយ៉ាងនេះថា **សម្បសាទនំ ចេតសោ** ចំណែកក្នុងអត្ថវិកប្បខាងមុខ គប្បីប្រកបបទថា **ចេតសោ** នេះ ជាមួយនឹងបទ **ឯកោ-ទិភាវំ** ។

ក្នុងសេចក្តីនោះមានយោជនាដូច្នេះថា ឈ្មោះថា **ឯកោទិ** ព្រោះអត្ថថា ជាធម៌ឯកផុសឡើង អធិប្បាយថា ជាធម៌ប្រសើរ ប្រសើរបំផុតផុសឡើង ព្រោះវិតក្កវិចារមិនគ្របសង្កត់ ។ ពិតណាស់បុគ្គលដែលប្រសើរក៏ហៅថា បុគ្គលឯកក្នុងលោកឬធម៌ដែលវៀរចាកវិតក្កវិចារៈក៏គួរហៅថា ជាធម៌ឯកមិនមានពីរដូច្នេះដែរ ។ ម្យ៉ាងទៀត ឈ្មោះថា **ឧទិ** ព្រោះញុំាងសម្បយុត្តធម៌ឲ្យកើតឡើង អធិប្បាយថា ឲ្យតាំងឡើង ។ ធម៌នោះជាធម៌ឯក ដោយអត្ថថា ប្រសើរបំផុតផង និងជា **ឧទិ** ផង ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកោទិ** ។ បទនេះជាឈ្មោះរបស់សមាធិ ។ ទុតិយជ្ឈាននេះ ឈ្មោះថា ជាធម៌ឯកផុសឡើង ព្រោះញុំាងឯកោទិសមាធិនេះឲ្យកម្រើក ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រោះឯកោទិនេះ មានដល់ចិត្ត មិនមែនដល់សត្វ មិនមែនដល់ជីវៈ ហេតុនោះ ទើបទុតិយជ្ឈាន ហៅថា **ចេតសោ ឯកោទិភាវំ** ។

សួរថា សទ្ធានេះ និងសមាធិដែលបានឈ្មោះថា ឯកោទិនេះ មានសូម្បី

ក្នុងបឋមជ្ឈានមិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបទ្រង់ត្រាស់ទុតិ-យជ្ឈាននេះប៉ុណ្ណោះថា **សម្បសាទនំ ចេតសោ ឯកោទិភាវំ។** ខ្ញុំនឹងឆ្លើយថា ព្រោះបឋមជ្ឈាននោះមិនទាន់ផូរផង់ល្អ ព្រោះនៅមានការកម្រើកនៃវិតក្កវិចារ ដូចទឹករញ្ជួយដោយរលកតូចធំ ព្រោះហេតុនោះ សូម្បីមានសទ្ធា បឋមជ្ឈាន ក៏មិនត្រាស់ថា **សម្បសាទនំ។** ម្យ៉ាងទៀត សមាធិក្នុងបឋមជ្ឈាននេះ ក៏មិនប្រាកដដោយល្អ ព្រោះមិនទាន់ផូរផង់ ព្រោះហេតុនោះ ទើបបឋមជ្ឈាន មិនត្រាស់ថា **ឯកោទិភាវំ** ។

តែក្នុងឈាននេះ សទ្ធាមានកម្លាំងបានឱកាសហើយ ព្រោះមិនមានការពាក់ព័ន្ធដោយវិតក្ក និងវិចារ សមាធិក៏ប្រាកដច្បាស់ ព្រោះបានសទ្ធាដែលមានកម្លាំងជាសម្លាញ់នោះឯង ។ ព្រោះហេតុនោះ ទុតិយជ្ឈាននេះប៉ុណ្ណោះ គប្បីជ្រាបថា ត្រាស់ហើយ ដោយប្រការដូច្នេះ ។

បទថា **អវិតក្កំ អវិចារំ** នេះ មានវិនិច្ឆ័យថា ឈ្មោះថា **អវិតក្កំ** ព្រោះអត្ថថា វិតក្ក មិនមានក្នុងឈាននេះ ឬមិនមានដល់ឈាននេះ ព្រោះលះបានហើយដោយភាវនា ។ ឈ្មោះថា **អវិចារំ** ក៏ដោយន័យនេះដូចគ្នា ។

ក្នុងសេចក្តីនេះ បើមានអ្នកសួរថា ដោយពាក្យនេះថា **វិតក្កវិចារានំ វូបសមា** រម្ងាប់នូវវិតក្ក វិចារ អត្ថក៏បរិបូណ៌ហើយមិនមែនឬ កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបត្រាស់ថា **អវិតក្កំ អវិចារំ** មិនមានវិតក្ក មិនមានវិចារទៀត ។ ឆ្លើយថា សេចក្តីនេះយ៉ាងនោះឯង ។ អត្ថនេះបរិបូរណ៍ហើយនោះឯង តែពាក្យថា **អវិតក្កវិចារានំ វូបសមា** នេះ មិនបានសបញ្ជាក់ថា មិន

មានវិតក្ក មិនមានវិចារនោះ ខ្ញុំបានពោលហើយមិនមែនឬ ថាព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ព្រោះរម្ងាប់វិតក្ក វិចារ ក៏ដើម្បីសម្តែងថា ការសម្រេចឈានដទៃអំពីបឋមជ្ឈាន មានទុតិយជ្ឈានជាដើម រមែងមានព្រោះឈានកន្លងអង្គគ្រោតគ្រាត ។

ម្យ៉ាងវិញទៀត ពាក្យនេះ ( ព្រោះរម្ងាប់វិតក្កវិចារ ) ជាពាក្យសម្តែងដល់ហេតុនៃការផូរផង់ និងភាពជាធម៌ឯក ផុសឡើងយ៉ាងនេះថា ទុតិយជ្ឈាននេះឈ្មោះថា មានការផូរផង់ព្រោះរម្ងាប់វិតក្កវិចារ មិនមែនផូរផង់ព្រោះកិលេសដែលកម្រើកតាមកាលស្ងប់ និងឈ្មោះថា ជាធម៌ឯកផុសឡើងព្រោះវិតក្កវិចារស្ងប់ មិនដូចឧបចារជ្ឈាន ព្រោះទុតិយជ្ឈាននេះ លះនីវរណៈបាន និងមិនដូចបឋមជ្ឈាន ព្រោះអង្គឈានប្រាកដច្បាស់ និងជាពាក្យសម្តែងដល់ហេតុនៃការមិនមានវិតក្ក មិនមានវិចារ យ៉ាងនេះថា ទុតិយជ្ឈាននេះ ឈ្មោះថា មិនមានវិតក្ក មិនមានវិចារ ព្រោះវិតក្កវិចាររម្ងាប់ដូចគ្នា មិនមែនព្រោះមិនមានដូចតតិយជ្ឈាន និងចតុត្ថជ្ឈាន និងដូចចក្ខុវិញ្ញាណជាដើម មិនមែនសម្តែងត្រឹមការមិនមានវិតក្ក និងវិចារ តែពាក្យនេះថា **អវិតក្កំ អវិចារំ** ជាពាក្យសម្តែងត្រឹមតែការមិនមានវិតក្ក និងវិចារប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលត្រាស់ពាក្យដំបូងហើយ ក៏នៅតែត្រាស់ពាក្យក្រោយទៀតដោយពិត ។

បទថា **សមាធិជំ** អធិប្បាយថា ដែលកើតអំពីសមាធិក្នុងបឋមជ្ឈាន ឬអំពីសមាធិដែលសម្បយុត្តហើយ ។ ក្នុងបទនោះ បឋមជ្ឈានកើតអំពីសមាធិដែលសម្បយុត្តហើយក៏ពិត តែសមាធិនេះឯងគួរពោលថា សមាធិបាន ព្រោះ

*មិនញាប់ញ័រ និងព្រោះផូរផង់ដោយល្អ ដោយវៀរការកម្រើកនៃវិតក្កវិចារ ព្រោះហេតុនោះ ដើម្បីពណ៌នាដល់គុណរបស់ឈាននេះ ទើបទុតិយជ្ឈាននេះប៉ុណ្ណោះ ទ្រង់ត្រាស់ថា មានតែបីតិ និងសុខដែលកើតអំពីសមាធិ ដូច្នេះ ។ បទថា* **បីតិសុខំ** *នេះ មានន័យដូចពោលហើយនោះឯង ។ បទថា* **ទុតិយំ** *ឈ្មោះថា* **ទុតិយ** *ព្រោះជាលំដាប់នៃការរាប់ឈាននេះ ឈ្មោះថា ទុតិយៈ ព្រោះកើតលើកទី ២ ក៏មាន ។*

*បទថា* **បីតិយា ច វិរាគា** *សេចក្តីថា ការខ្ពើម ឬការឈានកន្លងបីតិមានប្រការដូចពោលហើយ ឈ្មោះថា* **វិរាគ** *។* **ច** *សព្ទក្នុងចន្លោះបទទាំងពីរនោះ ជាសម្បិណ្ឌនត្ថ ចុះក្នុងអត្ថថា រួម ។* **ច** *សព្ទនោះ រមែងរួមសេចក្តីស្ងប់ ឬរួមការស្ងប់នៃវិតក្ក និងវិចារ ។ ក្នុងបទនោះ កាលណា* **ច** *សព្ទរួមការស្ងប់នោះឯង កាលនោះ គប្បីជ្រាបការប្រកបសេចក្តីដូច្នេះថា ព្រោះបីតិប្រាសទៅ និងព្រោះការស្ងប់បន្ថែមឡើងបន្តិចបន្តួច ។ ក្នុងការប្រកបសេចក្តីនេះ វិរាគៈ មានការខ្ពើមជាអត្ថ ព្រោះហេតុនោះ គប្បីឃើញសេចក្តីនេះថា ព្រោះខ្ពើម និងឈានកន្លងបីតិ តែកាលណា* **ច** *សព្ទរួមការស្ងប់នៃវិតក្កវិចារ កាលនោះ គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ព្រោះប្រាសចាកបីតិ និងព្រោះស្ងប់វិតក្កវិចារ បន្ថែមបានបន្តិចបន្តួចទៀត ។ ក្នុងការប្រកបសេចក្តីនេះ វិរាគៈមានការឈានកន្លងជាអត្ថ ព្រោះហេតុនោះ គប្បីឃើញអត្ថនេះថា ព្រោះឈានកន្លងបីតិ និងព្រោះស្ងប់វិតក្ក និងវិចារ ។*

*វិតក្កវិចារទាំងនេះស្ងប់ហើយ ក្នុងទុតិយជ្ឈានក៏ពិត ប៉ុន្តែដើម្បីសម្តែងមគ្គ*

និងដើម្បីពណ៌នាគុណរបស់ឈានទនេះ ទើបលោកពោលបទនេះ ។ ពិតហើយ កាលលោកពោលថា **វិតក្កវិចារានំ វូបសមា** ឈានទនេះ រមែងប្រាកដថា ការស្ងប់នេះ មានវិតក្កវិចារស្ងប់ ជាមគ្គនៃឈាននេះដោយពិតប្រាកដ ។ មួយវិញទៀត ការលះសក្កាយទិដ្ឋិជាដើម ដែលមិនបានលះក្នុងអរិយមគ្គទី ៣ ដែលត្រាស់ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) យ៉ាងនេះថា លះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ ដូច្នេះ ។ ជាការពោលសរសើរដែលឲ្យកើតឧស្សាហៈដល់អ្នកខ្វល់ខ្វាយដើម្បីសម្រេចអរិយមគ្គទី ៣ នោះ យ៉ាងណា ការស្ងប់វិតក្កវិចារដែលមិនបានស្ងប់ ក្នុងតតិយជ្ឈាននេះ ដែលនាំមកពោលដល់ រមែងជាការពោលសរសើរយ៉ាងនោះដូចគ្នា ដោយហេតុនោះ ទើបពោលអត្ថនេះថា ព្រោះកន្លងបង់នូវបីតិ និងព្រោះរម្ងាប់វិតក្កវិចារ ដូច្នេះ ។

ក្នុងបទថា **ឧបេក្ខកោ ច វិហរតិ** នេះ មានវិគ្គហៈដូច្នេះថា ឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា ឃើញដោយការចូលដល់ ។ អធិប្បាយថា ឃើញស្មើៗ គឺឃើញដោយមិនធ្លាក់ទៅក្នុងចំណែកណាមួយ ។ បុគ្គលដែលមានការដល់ព្រមក្នុងតតិយជ្ឈាន ព្រោះប្រកបដោយឧបេក្ខានោះ ដែលបរិសុទ្ធបរិបូរណ៍ មានកម្លាំង ហៅថា **ឧបេក្ខកោ** ។

ឧបេក្ខាមាន ១០ យ៉ាង គឺឆឡង្គុបេក្ខា ១ ព្រហ្មវិហារុបេក្ខា ១ ពោជ្ឈង្គុបេក្ខា ១ វីរិយុបេក្ខា ១ សង្ខារុបេក្ខា ១ វេទនុបេក្ខា ១ វិបស្សនុបេក្ខា ១ តត្រមជ្ឈត្តុបេក្ខា ១ ឈានុបេក្ខា ១ បារិសុទ្ធុបេក្ខា ១ ។

ក្នុងឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខា គឺឧបេក្ខាដែលជាអាការនៃការមិន

លះបង់ភាពប្រក្រតីដ៏បរិសុទ្ធក្នុងគន្លងអារម្មណ៍ ៦ ទាំងដែលគួរប្រាថ្នា និង មិនគួរប្រាថ្នាក្នុងទ្វារ ៦ របស់ព្រះខីណាស្រព ដែលមកហើយ ( អង្គុត្តរ-និកាយ ឆក្កនិបាត ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រព[១] ក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនត្រេកអរ មិនអាក់អន់ ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈ ដូច្នេះ ។

ព្រហ្មវិហារុបេក្ខា គឺឧបេក្ខាដែលជាអាការនៃភាពកណ្តាល ក្នុងសត្វទាំងឡាយ ដែលមកហើយ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) យ៉ាងនេះថា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ដូច្នេះ ។

ពោជ្ឈង្គុបេក្ខា គឺឧបេក្ខាដែលជាអាការនៃភាពកណ្តាលក្នុងធម៌ដែលកើតរួមគ្នា ដែលមកហើយ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) យ៉ាងនេះថា ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ដូច្នេះ ។

វីរិយុបេក្ខា គឺឧបេក្ខាដែលបានដល់សេចក្តីព្យាយាម ដែលមិនប្រារព្ធខ្លាំងក្លាពេក មិនធូរថយពេកដែលមកហើយ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) យ៉ាងនេះថា ក្នុងកាលដ៏គួរធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ដូច្នេះ ។

សង្ខារុបេក្ខា គឺឧបេក្ខាដែលមានភាពជាកណ្តាលក្នុងការមិនប្រកាន់មាំនូវការតាំងនៅក្នុងការពិចារណានីវរណៈជាដើម ដែលមកហើយ ( ក្នុងខុទ្ទក-និកាយ បដិសម្ភិទាមគ្គ ) យ៉ាងនេះថា សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចសមថៈ សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចនៃវិបស្សនា ។ សង្ខារុបេក្ខា ៨

---

១- បិដកខ្មែរ មិនមានពាក្យថា ជាខីណាស្រពនេះទេ តែអដ្ឋកថា មាន ។

កើតដោយអំណាចសមថៈ សង្ខារុបេក្ខា ១០ កើតដោយអំណាចវិបស្សនា ដូច្នេះ ។

វេទនុបេក្ខា គឺឧបេក្ខាដែលសន្មតថា ជាអទុក្ខមសុខវេទនា ដែលមកហើយ ( ក្នុងអភិធម្ម ធម្មសង្គណិ ) យ៉ាងនេះថា **យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ** ចិត្តជាកាមាវចរកុសល ប្រកបដោយឧបេក្ខា ហើយកើតឡើងក្នុងសម័យណា ដូច្នេះ ។

វិបស្សនុបេក្ខា គឺឧបេក្ខាជាកណ្តាល ក្នុងការពិចារណា ដែលមកហើយ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) យ៉ាងនេះថា អាត្មាអញ លះបង់នូវខន្ធបញ្ចកៈនោះ ភិក្ខុនោះ បាននូវឧបេក្ខាយ៉ាងនេះ ដូច្នេះ ។

តត្រមជ្ឈត្តុបេក្ខា គឺឧបេក្ខាដែលនាំសហជាតធម៌ទៅរួមគ្នា ដែលមកហើយ ក្នុងយេវាបនកធម៌ មានឆន្ទៈជាដើម ។

ឈានុបេក្ខា គឺឧបេក្ខាដែលញុំាងធម៌ដែលមិនឲ្យធ្លាក់ទៅក្នុងចំណែកណាមួយ ឲ្យកើតក្នុងឈាននោះសូម្បីជាសុខដ៏ក្រៃលែង ដែលមកហើយ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) យ៉ាងនេះថា ប្រកបដោយឧបេក្ខាផង ដូច្នេះ ។

បារិសុទ្ធុបេក្ខា គឺឧបេក្ខាដែលមិនខ្វល់ខ្វាយក្នុងការស្ងប់ចាកធម៌ជាសត្រូវ បរិសុទ្ធចាកធម៌ជាសត្រូវទាំងអស់ ដែលមកហើយ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) យ៉ាងនេះថា ចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខាមានសតិដ៏បរិសុទ្ធ ដូច្នេះ ។

ក្នុងឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា

តត្រមជ្ឈត្តុបេក្ខា ឈានុបេក្ខា និងបរិសុទ្ធុបេក្ខា ដោយអត្ថ ដូចគ្នាតែមួយ គឺជាតត្រមជ្ឈត្តុបេក្ខា ។ តែឧបេក្ខានោះ ផ្សេងគ្នា ដោយការផ្សេងគ្នានៃការកំណត់នោះៗ ដូចការផ្សេងគ្នារបស់មនុស្សម្នាក់ ដោយភាពជាកុមារ ជាកំលោះ ជាមនុស្សចាស់ ជាសេនាបតី ជាព្រះរាជាជាដើម ព្រោះហេតុនោះ គប្បីជ្រាបថា ក្នុងឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខា មានក្នុងឈានណា ក្នុងឈាននោះ មិនមានពោជ្ឈង្គុបេក្ខាជាដើម ឬថា ក្នុងឈានណា មានពោជ្ឈង្គុបេក្ខា ក្នុងឈាននោះ មិនមានឆឡង្គុបេក្ខាជាដើម ។

ភាពដូចគ្នាដោយអត្ថរបស់ឧបេក្ខាទាំងនោះ យ៉ាងណា សូម្បីរបស់សង្ខារុ-បេក្ខា និងវិបស្សនុបេក្ខាក៏យ៉ាងនោះ ។ ពិតហើយ ឧបេក្ខានោះ គឺបញ្ញានោះឯង ដោយកិច្ច បែកចេញជាពីរយ៉ាង ។ ដូចកាលបុរសកាន់ឈើដែលមានសណ្ឋានដូចជើងពពែ ស្វែងរកពស់ដែលលូនចូលទៅកាន់ផ្ទះក្នុងវេលាល្ងាច ឃើញពស់នោះដេកត្រង់គំនរអង្កាម ទើបសម្លឹងមើលថា ពស់ ឬមិនមែនពស់ ឃើញឆ្នូត ៣ ក៏អស់សង្ស័យ ភាពជាកណ្តាលក្នុងការពិចារណាថា ពស់ ឬមិនមែនពស់ រមែងកើតឡើងយ៉ាងណា កាលភិក្ខុចម្រើនវិបស្សនា ឃើញត្រៃលក្ខណ៍ដោយវិបស្សនាញាណ ភាពជាកណ្តាលក្នុងការពិចារណាការមិនទៀងជាដើមនៃសង្ខារ រមែងកើតឡើងក៏យ៉ាងនោះ នេះជាវិបស្សនុបេក្ខា ។ មួយវិញទៀត កាលបុរសនោះយកឈើ ដែលមានសណ្ឋានដូចជើងពពែ ចាប់ពស់យ៉ាងណែន គិតថា បើដូច្នោះ អាត្មាអញមិនប្រទូស្តពស់នេះ និងមិនឲ្យពស់នេះចឹក គប្បីលែងទៅហើយ រកវិធីលែងពស់នោះទៅ ក្នុងខណៈចាប់នោះ រមែង

មានភាពជាកណ្តាលយ៉ាងណា ភាពជាកណ្តាលក្នុងការប្រកាន់សង្ខារ របស់ភិក្ខុអ្នកឃើញភព ៣ ដូចត្រូវភ្លើងឆេះទូទៅហើយ ព្រោះឃើញត្រៃលក្ខណ៍ ក៏យ៉ាងនោះ នេះជាសង្ខារុបេក្ខា ។ កាលវិបស្សនុបេក្ខាសម្រេចហើយ សូម្បីសង្ខារុបេក្ខា ក៏ឈ្មោះថា សម្រេចហើយ ដោយប្រការដូច្នេះ ។

មួយវិញទៀត ដោយបទនេះ ឧបេក្ខានេះ ចែកជាពីរដោយកិច្ច ពោលគឺភាពជាកណ្តាល ក្នុងការពិចារណា និងភាពជាកណ្តាលក្នុងការប្រកាន់ ។ ចំណែកវីរិយុបេក្ខា និងវេទនុបេក្ខា ដោយអត្ថ ផ្សេងគ្នា និងផ្សេងអំពីឧបេក្ខាដ៏សេសផងដែរ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ ព្រះសារីបុត្តត្ថេរពោលថា

> ឧបេក្ខា ១០ ដោយពិស្តារ គឺមជ្ឈត្តុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា ឆឡង្គុបេក្ខា ឈានុបេក្ខា បារិសុទ្ធុបេក្ខា វិបស្សនុបេក្ខា សង្ខារុបេក្ខា វេទនុបេក្ខា និងវីរិយុបេក្ខា ឧបេក្ខាដោយសង្ខេបមាន ៤ ប៉ុណ្ណោះ ពោលដោយមជ្ឈត្តុបេក្ខាជាដើមមាន ៦ ពោលដោយបញ្ញាមាន ២ ពោលដោយព្យែកមាន ២ ទៀត ( វីរិយុបេក្ខា និងវេទនុបេក្ខា ) ។

ក្នុងឧបេក្ខាទាំងនោះ ក្នុងទីនេះ បំណងយកឈានុបេក្ខា ។ ឈានុបេក្ខានោះ មានលក្ខណៈជាកណ្តាល ។ ក្នុងអធិការនេះ បើមានអ្នកសួរថា ឧបេក្ខានេះ ដោយអត្ថ រមែងជាតត្រមជ្ឈត្តុបេក្ខាមិនមែនឬ មួយវិញទៀត ឧបេក្ខានោះ មាន ក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន ព្រោះហេតុនោះ ក្នុងឈាននោះ ក៏គួរ

ពោលដល់ឧបេក្ខាយ៉ាងនេះថា **ឧបេក្ខកោ ច វិហរតិ** ព្រោះហេតុអ្វី ទើបលោកមិនពោលដល់ឧបេក្ខានោះ ឆ្លើយថា ព្រោះកិច្ចមិនប្រាកដច្បាស់ ដ្បិតថា កិច្ចរបស់ឧបេក្ខានោះ ក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ មិនទាន់ប្រាកដច្បាស់ ព្រោះត្រូវវិតក្កជាដើមគ្របសង្កត់ តែក្នុងអធិការនេះ ឧបេក្ខានេះ មានកិច្ចប្រាកដច្បាស់ ព្រោះមិនត្រូវវិតក្ក វិចារ បីតិគ្របសង្កត់ ដូចងើបក្បាលឡើងបាន ព្រោះហេតុនោះ ទើបលោកពោល ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **សតោ ច សម្បជានោ** ដូចតទៅ ឈ្មោះថា **សតោ** ព្រោះអត្ថថា រឭកបាន ។ ឈ្មោះថា **សម្បជានោ** ព្រោះអត្ថថា ដឹងទូទៅ ហេតុនោះ សតិ និងសម្បជញ្ញៈ លោកពោលសំដៅបុគ្គល ។ ក្នុងបទទាំងនោះ សតិមានការរឭកបានជាលក្ខណៈ ។ សម្បជញ្ញៈមានការមិនវង្វេងជាលក្ខណៈ ។ ក្នុងបទថា **សតោ ច សម្បជានោ** នោះ សតិសម្បជញ្ញៈនេះ មានក្នុងឈានខាងដើមៗ ក៏ពិត តែកាលបុគ្គលមិនមានស្មារតី មិនមានសម្បជញ្ញៈ សូម្បីត្រឹមតែឧបចារៈក៏សម្រេចមិនបាន នឹងចាំបាច់និយាយថ្វីដល់អប្បនា ។ ព្រោះឈានទាំងនោះគ្រោតគ្រាត ទើបការប្រព្រឹត្តទៅនៃចិត្តបានងាយ ដូចការដើរទៅរបស់បុរសលើផ្ទាំងថ្ម ទើបកិច្ចរបស់សតិសម្បជញ្ញៈក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ មិនប្រាកដច្បាស់ ព្រោះឈាននេះល្អិតដោយសារលះអង្គគ្រោតគ្រាត ទើបត្រូវការប្រព្រឹត្តទៅនៃចិត្តយ៉ាងនេះ ដែលសតិសម្បជញ្ញៈធ្វើកិច្ចផងហើយ ដូចការដើរទៅរបស់បុរសក្នុងទីមានមុខកាំបិត ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលសតិសម្បជញ្ញៈ

ក្នុងតតិយជ្ឈានទេះប៉ុណ្ណោះ ។ មានពាក្យអធិប្បាយបន្ថែមដូច្នេះថា កូនគោជាប់តាមមេ ត្រូវនាំចេញទៅចាកមេគោ ដែលបុគ្គលមិនរាំងប្រយ័ត្ន រមែងចូលទៅរកមេគោដូចដើមទៀតយ៉ាងណា សុខក្នុងតតិយជ្ឈានទេះក៏យ៉ាងនេះ ត្រូវនាំចេញចាកបីតិដែលសតិសម្បជញ្ញៈមិនរក្សា គប្បីចូលទៅរកបីតិទៀតនោះឯង គប្បីសម្បយុត្តជាមួយបីតិនោះឯង ។ សត្វទាំងឡាយ រមែងត្រេកអរស្វះក្នុងសេចក្តីសុខ សេចក្តីសុខនេះ មានរសផ្អែមក្រៃលែង ព្រោះមិនមានសុខក្រៃលែងជាងនោះ ។ តែក្នុងតតិយជ្ឈាននេះ មិនមានសេចក្តីត្រេកអរក្នុងសុខក៏ដោយ អានុភាពរបស់សតិសម្បជញ្ញៈ មិនមែនមានដោយអានុភាពដទៃ ព្រោះហេតុនោះ ដើម្បីសម្តែងអត្ថពិសេសនេះ គប្បីជ្រាបថា លោកពោលសតិសម្បជញ្ញៈនេះ ក្នុងតតិយជ្ឈាននេះប៉ុណ្ណោះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះ **សុខញ្ច កាយេន បដិសំវេ-ទេតិ** ដូចតទៅ ភិក្ខុដែលមានការដល់ព្រមដោយតតិយជ្ឈាន រមែងមិនមានការជាប់ជំពាក់ចិត្ត ក្នុងការសោយសុខដោយពិត សូម្បីដូច្នោះ ព្រោះសុខដែលសម្បយុត្តដោយនាមកាយរបស់ភិក្ខុនោះ ឬព្រោះរូបកាយរបស់ភិក្ខុនោះត្រូវរូបដែលប្រណីតក្រៃលែងដែលមានសុខ ដែលសម្បយុត្តដោយនាមកាយនោះជាសមុដ្ឋាន ពាល់ត្រូវសម្ផស្សហើយ ភិក្ខុសូម្បីចេញចាកឈាន ក៏គប្បីសោយសេចក្តីសុខបាន ហេតុនោះ កាលទ្រង់សម្តែងអត្ថនេះ ទើបត្រាស់ថា **សុខញ្ច កាយេន បដិសំវេទេតិ** ដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទនេះ **យន្តំ អរិយា អាចិក្ខន្តិ**

**ឧបេក្ខកោ សតិមា សុខវិហារី** ដូចតទៅ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមរមែងប្រាប់ រមែងសម្តែង រមែងបញ្ញត្តិ រមែងតែងតាំង រមែងបើកផ្ទារ រមែងចែក រមែងធ្វើឲ្យងាយ រមែងប្រកាស អធិប្បាយថា រមែងសរសើរបុគ្គល ដែលដល់ព្រមដោយតតិយជ្ឈាននោះ ព្រោះហេតុនៃឈានណា ព្រោះការណ៍នៃឈានណា ។ សរសើរដូចម្តេច សរសើរថាជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខ ។ ក្នុងបទនេះ គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ភិក្ខុចូលតតិយជ្ឈាននោះ សង្វំនៅ ដូច្នេះ ។

ព្រោះហេតុអ្វី ទើបព្រះអរិយៈទាំងនោះ សរសើរបុគ្គលនោះយ៉ាងនេះ ព្រោះជាអ្នកគួរដល់ការសរសើរ ។ ព្រោះថា បុគ្គលនេះ ជាអ្នកមានឧបេក្ខាក្នុងតតិយជ្ឈាន ដែលមានសុខគួរពេញចិត្តក្រៃលែង សូម្បីដល់នូវការពេញបរិបូណ៌ដោយសុខ ក៏មិនត្រូវសេចក្តីជាប់ជំពាក់ក្នុងសុខ ក្នុងឈាននោះទាញទុក ។ ឈ្មោះថា **សតិមា** ព្រោះមានសតិប្រាកដដោយប្រការដែលបីតិមិនកើតឡើង ព្រោះសោយសុខ មិនសៅហ្មងដែលអរិយជនប្រាថ្នា និងដែលអរិយជនសេពនោះឯងដោយនាមកាយ ហេតុនោះ ទើបជាបុគ្គលគួរដល់ការសរសើរ ហេតុនោះ គប្បីជ្រាបថា ព្រោះជាអ្នកគួរដល់ការសរសើរ ព្រះអរិយទាំងឡាយកាលប្រកាសគុណទាំងនោះ ដែលជាហេតុគួរដល់ការសរសើរយ៉ាងនេះ ទើបសរសើរបុគ្គលនោះ យ៉ាងនេះថា **ឧបេក្ខកោ សតិមា សុខវិហារី** ដូច្នេះ ។

បទថា **តតិយំ** ឈ្មោះថា **តតិយ** ព្រោះលំដាប់នៃការរាប់ ។ ឈ្មោះថា **តតិយ** ព្រោះកើតជាលើកទី ៣ ក៏មាន ។

*បទថា **សុខស្ស ច បហានា ទុក្ខស្ស ច បហានា** បានដល់ ព្រោះលះបង់សុខផ្លូវកាយ និងលះបង់ទុក្ខផ្លូវកាយ ។*

*បទថា **បុព្វេវ** បានដល់ ការលះនោះឯង មានក្នុងកាលមុននោះឯង មិនមែនមានក្នុងខណៈចតុត្ថជ្ឈាន ។ បទថា **សោមនស្សទោមនស្សានំ អត្ថង្គមា** បានដល់ ព្រោះរម្ងត់សោមនស្ស និងទោមនស្សទាំងពីរនេះ គឺសុខផ្លូវចិត្ត និងទុក្ខផ្លូវចិត្ត ក្នុងកាលមុននោះឯង អធិប្បាយថា ព្រោះលះ ។*

*ទាំងពីរនោះ នឹងលះបានពេលណា លះបានក្នុងខណៈឧបចារៈនៃឈានទាំង ៤ ពិតហើយ សោមនស្សលះបានក្នុងខណៈឧបចារៈនៃឈានទី ៤ ប៉ុណ្ណោះ ទុក្ខទោមនស្ស និងសុខ លះបានក្នុងខណៈឧបចារៈនៃឈានទី ១ ទី ២ និងទី ៣ ។ គប្បីជ្រាបការលះសុខ ទុក្ខ សោមនស្ស និងទោមនស្សទាំងនោះ ដែល មិនបានត្រាស់តាមលំដាប់នៃការលះ តែត្រាស់ក្នុងចតុត្ថជ្ឈាននេះ តាមលំដាប់នៃឧទ្ទេសនៃឥន្ទ្រិយទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គ ។*

*មានពាក្យសួរថា បើសុខ ទុក្ខ សោមនស្ស និងទោមនស្សទាំងនេះលះបានក្នុងខណៈឧបចារៈនៃឈាននោះៗ សោត កាលបើយ៉ាងនោះ ហេតុអ្វី ទើបត្រាស់ការរលត់ទុក្ខក្នុងឈាននោះឯង ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ចុះទុក្ខិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ រមែងចូលកាន់បឋមជ្ឈាន ។ ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅ ឥតមានសេសសល់ ។ ទោមនស្សិន្ទ្រិយ ... សុខិន្ទ្រិយ ... មួយវិញទៀត*

សោមនស្សិន្ទ្រិយ កើតឡើងក្នុងទីឯណា រមែងរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។ សោមនស្សិន្ទ្រិយ កើតឡើងហើយ ក្នុងចតុត្ថជ្ឈាននុ៎ះ ទើបរលត់ទៅឥតមានសេសសល់ ដូច្នេះ ។ ឆ្លើយថា ព្រោះជាការរលត់វិសេសក្រៃលែង ។ ពិតហើយ ការរលត់ទុក្ខិន្ទ្រិយជាដើមទាំងនោះ ក្នុងបឋមជ្ឈានជាដើម ជាការរលត់វិសេសក្រៃលែង មិនមែនជាការរលត់ធម្មតា ។ ចំណែកការរលត់ក្នុងខណៈនៃឧបចារៈមិនមែនជាការរលត់វិសេសក្រៃលែង ។ ពិតហើយ ទុក្ខិន្ទ្រិយសូម្បីរលត់ក្នុងឧបចារៈនៃបឋមជ្ឈាន ដែលមានអាវជ្ជនៈផ្សេងៗ ក៏គប្បីកើតឡើងបាន ដោយត្រូវរបោម និងមូសជាដើមខាំ ឬដោយការលំបាកដែលមានអាសនៈមិនរាបស្មើ តែខាងក្នុងអប្បនាកើតឡើងមិនបានឡើយ ។

ម្យ៉ាងទៀត ទុក្ខិន្ទ្រិយជាដើមនេះ សូម្បីរលត់ហើយក្នុងឧបចារៈ ក៏ឈ្មោះថា រលត់មិនទាន់ល្អ ព្រោះមិនទាន់ត្រូវធម៌ដែលជាបដិបក្ខកម្ចាត់ ។ តែខាងក្នុងអប្បនាកាយទាំងអស់ ឈមចុះកាន់សេចក្ដីសុខដោយការផ្សាយទៅនៃបីតិ បុគ្គលមានកាយ ដែលឈមចុះកាន់សេចក្ដីសុខហើយ ទុក្ខិន្ទ្រិយ ឈ្មោះថា រលត់ដោយល្អ ព្រោះត្រូវធម៌ដែលជាបដិបក្ខកម្ចាត់ ។ ម្យ៉ាងទៀត ទោមនស្សិន្ទ្រិយ សូម្បីលះបានហើយ ក្នុងឧបចារៈនៃទុតិយជ្ឈានដែលមានអាវជ្ជនៈផ្សេងៗ នោះឯង ក៏ព្រោះកាលនៅមានសេចក្ដីលំបាកកាយ និងការចង្អៀតចង្អល់ចិត្ត ដែលមានវិតក្កវិចារជាបច្ច័យ ទោមនស្សិន្ទ្រិយនោះ រមែងកើតឡើងបាន ។ កាលវិតក្កវិចារមិនមាន រមែងកើតឡើងមិនបាន ។ ម្យ៉ាងទៀត ទោមនស្សិន្ទ្រិយ

រមែងកើតឡើងក្នុងទីណា ក្នុងទីនោះ កាលមានវិតក្កវិចារ រមែងកើតឡើង ។ វិតក្កវិចារ មិនទាន់លះបានក្នុងឧបចារៈនៃទុតិយជ្ឈាន ព្រោះហេតុនោះ ទើបទោមនស្សិន្ទ្រិយ កើតឡើងក្នុងឧបចារៈនៃទុតិយជ្ឈាននោះ តែក្នុងទុតិយជ្ឈាន រមែងមិនកើតឡើងទេ ព្រោះលះបច្ច័យបានហើយ ។ សុខិន្ទ្រិយដែលលះបានហើយក្នុងឧបចារៈនៃតតិយជ្ឈាន ក៏គប្បីកើតឡើងបាន ដល់កាយដែលត្រូវរូបប្រណីតដែលមានបីតិជាសមុដ្ឋានពាល់ត្រូវហើយ តែក្នុងតតិយជ្ឈានកើតឡើងមិនបានឡើយ ព្រោះក្នុងតតិយជ្ឈាន បីតិដែលជាបច្ច័យនៃសេចក្តីសុខ រមែងរលត់ដោយប្រការទាំងពួង ។ សោមនស្សិន្ទ្រិយ ដែលលះបានហើយក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏គប្បីកើតឡើងព្រោះមានសត្រូវនៅជិត និងព្រោះមិនឈានកន្លងដោយប្រពៃ ព្រោះមិនមានឧបេក្ខាដែលដល់អប្បនា តែក្នុងចតុត្ថជ្ឈានកើតឡើងមិនបានឡើយ ហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ជ្រើសពូថា មិនមានសេសសល់ទុកក្នុងទីនោះៗ យ៉ាងនេះថា ទុក្ខិន្ទ្រិយកើតឡើង ក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ។

ក្នុងសេចក្តីនេះ បើមានអ្នកសួរថា កាលបើយ៉ាងនោះ វេទនាសូម្បីលះបានហើយក្នុងឧបចារៈនៃឈាននោះៗ យ៉ាងនេះ ហេតុអ្វី ទើបនាំមករួមក្នុងទីនេះទៀត ឆ្លើយថា ដើម្បីកំណត់បានដោយងាយ ។ ពិតហើយ អទុក្ខមសុខវេទនាដែលត្រាស់ក្នុងបទនេះថា **អទុក្ខមសុខំ** ជាវេទនាដែលល្អិតដឹងបានលំបាក បុគ្គលណាមួយ មិនអាចកំណត់បានងាយ ព្រោះហេតុនោះ ទើបរួមវេទនាទាំងអស់នោះ ដើម្បីកំណត់បានងាយ ដូចអ្នកចិញ្ចឹមគោ នាំគោទាំងអស់ មករួម

គ្នាក្នុងក្រោលតែមួយ ដើម្បីនឹងចាប់គោកាចដែលមិនមានអ្នកណាអាចចូលទៅចាប់បានតាមគាប់ចិត្ត ស្រេចហើយទើបឲ្យគោចេញម្តងមួយ ប្រាប់ឲ្យចាប់គោកាចនោះដែលមកដល់តាមលំដាប់ថា នេះគោនោះចូរចាប់វា ។ កាលសម្តែងវេទនាទាំងនេះ ដែលរួបរួមយ៉ាងនេះហើយ ក៏អាចកំណត់វេទនានេះបានថា វត្ថុណាមិនមែនសុខ មិនមែនទុក្ខ មិនមែនសោមនស្ស មិនមែនទោមនស្ស វត្ថុនេះ ជាអទុក្ខមសុខវេទនា ។

ម្យ៉ាងវិញទៀត គប្បីជ្រាបថា លោកពោលដល់វេទនាទាំងនេះ ក៏ដើម្បីសម្តែងបច្ច័យនៃចេតោវិមុត្តិ ដែលជាអទុក្ខមសុខវេទនា ។ ព្រោះថា ការលះសុខវេទនា និងទុក្ខវេទនាជាដើម ជាបច្ច័យដល់ចេតោវិមុត្តិនោះ ។ ដូចព្រះសារីបុត្តពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិមានបច្ច័យ ៤ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខ ១ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ នេះឯង ដូច្នេះ ។

ម្យ៉ាងវិញទៀត លោកពោលដល់សក្កាយទិដ្ឋិជាដើម ដែលលះបានហើយក្នុងមគ្គដទៃថា លះបានហើយក្នុងតតិយមគ្គនោះ ដើម្បីពណ៌នាគុណរបស់អនាគាមិមគ្គយ៉ាងណា គប្បីជ្រាបថា វេទនាទាំងនោះ លោកពោលក្នុងចតុត្ថជ្ឈាននេះ ក៏ដើម្បីពណ៌នាគុណរបស់ឈាននេះក៏យ៉ាងនោះ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ក្នុងចតុត្ថជ្ឈាននេះ លោកពោលវេទនាប៉ុណ្ណោះ ដើម្បីសម្តែងភាពដែលរាគៈ ទោសៈ មានក្នុងទីឆ្ងាយ ព្រោះសម្លាប់បច្ច័យបាន ។

ពិតហើយ ក្នុងវេទនាទាំងនោះ សុខវេទនាជាបច្ច័យនៃសោមនស្សវេទនា សោមនស្សវេទនាជាបច្ច័យនៃរាគៈ ទុក្ខវេទនាជាបច្ច័យនៃទោមនស្សវេទនា ទោមនស្សវេទនា ជាបច្ច័យនៃទោសៈ ។ម្យ៉ាងទៀត រាគៈ ទោសៈ ព្រមទាំងបច្ច័យ ត្រូវកម្ចាត់បង់ហើយ ព្រោះសម្លាប់សុខវេទនាជាដើមបាន ព្រោះហេតុនោះ ទើបរាគៈ និងទោសៈ មានក្នុងទីឆ្ងាយ ។

បទថា **អទុក្ខមសុខំ** ឈ្មោះថា **អទុក្ខំ** ព្រោះមិនមានទុក្ខ ឈ្មោះថា **អសុខំ** ព្រោះមិនមានសុខ ។ ដោយបទនេះលោកសម្តែងវេទនាទី ៣ ដែលជាបដិបក្ខចំពោះទុក្ខ និងសុខ ក្នុងចតុត្ថជ្ឈានទេះ មិនមែនសម្តែងត្រឹមតែការមិនមានទុក្ខ និងសុខ ។ អទុក្ខមសុខវេទនា ឈ្មោះថា វេទនាទី ៣ លោកពោលថា ឧបេក្ខាក៏មាន ។ ឧបេក្ខាវេទនានោះ មានការសោយអារម្មណ៍ផ្ទុយគ្នានឹងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាលក្ខណៈ ។

បទថា **ឧបេក្ខាសតិបារិសុទ្ធឹ** បានដល់ ការបរិសុទ្ធនៃសតិដែលឧបេក្ខាឲ្យកើត ព្រោះថា សតិបរិសុទ្ធដោយល្អក្នុងឈានទេះ សេចក្តីបរិសុទ្ធនៃសតិនោះដែលឧបេក្ខាធ្វើ មិនមែនវត្ថុដទៃធ្វើ ព្រោះហេតុនោះ ទើបលោកពោលចតុត្ថជ្ឈានទេះថា **ឧបេក្ខាសតិបារិសុទ្ធឹ** ។ សេចក្តីបរិសុទ្ធនៃសតិក្នុងចតុត្ថជ្ឈានទេះ មានព្រោះឧបេក្ខាណា ឧបេក្ខានោះ ដោយអត្ថ គប្បីជ្រាបថា បានដល់ **តត្រមជ្ឈត្តុបេក្ខា** ។ មួយវិញទៀត ក្នុងឈានទេះ មិនមែនសតិបរិសុទ្ធដោយឧបេក្ខាតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិតសូម្បីសម្បយុត្តធម៌ទាំងអស់ ក៏បរិសុទ្ធផងដែរ តែទ្រង់ត្រាស់ទេសនាដោយបំណាងដល់សតិជាសំខាន់ ។ ក្នុងបទទាំង

នោះ ឧបេក្ខាវេទនានេះ មាននៅក្នុងឈាន ៣ ខាងក្រោមក៏ពិត តែព្រះចន្ទ គឺតត្រមជ្ឈត្តុបេក្ខានេះ សូម្បីនៅក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម ក៏មិនបរិសុទ្ធ ព្រោះត្រូវតេជះនៃធម៌ដែលជាសត្រូវ មានវិតក្កជាដើម គ្របសង្កត់ និងព្រោះមិនបានរាត្រី គឺឧបេក្ខាវេទនាដែលសមគ្នា ដូចព្រះចន្ទសូម្បីមាននៅក្នុងពេលថ្ងៃក៏មិនបរិសុទ្ធ មិនផូរផង់ ព្រោះត្រូវពន្លឺនៃព្រះអាទិត្យក្នុងពេលថ្ងៃគ្របសង្កត់ និងព្រោះមិនបានរាត្រីដែលសមគ្នាដោយជាសភាពចូលគ្នាបាន ឬដោយជាឧបការៈដល់ខ្លួន ។

មួយវិញទៀត កាលព្រះចន្ទ គឺតត្រមជ្ឈត្តុបេក្ខានោះមិនបរិសុទ្ធ សហជាតធម៌មានសតិជាដើម ក៏ឈ្មោះថា មិនបរិសុទ្ធផងដែរ ដូចរស្មីរបស់ព្រះចន្ទដែលមិនបរិសុទ្ធក្នុងពេលថ្ងៃ ដូច្នោះ ។ ព្រោះហេតុនោះ ក្នុងឈានទាំងនោះ សូម្បីឈានមួយក៏មិនត្រាស់ថា **ឧបេក្ខាសតិបារិសុទ្ធិ** ។ តែក្នុងទីនេះ ព្រះចន្ទ គឺតត្រមជ្ឈត្តុបេក្ខានេះ ព្រោះមិនមានតេជះនៃធម៌ដែលជាសត្រូវ មានវិតក្កជាដើមគ្របសង្កត់ និងព្រោះបានរាត្រី គឺឧបេក្ខាវេទនាដែលសមគ្នា ទើបបរិសុទ្ធក្រៃលែងព្រោះព្រះចន្ទ គឺតត្រមជ្ឈត្តុបេក្ខានោះបរិសុទ្ធ សូម្បីជាសហជាតធម៌មានសតិជាដើម ក៏ឈ្មោះថា បរិសុទ្ធ ដូចរស្មីរបស់ព្រះចន្ទបរិសុទ្ធ ដូច្នោះ ។ ព្រោះហេតុនោះ គប្បីជ្រាបថា ឈាននេះឯង ទ្រង់ត្រាស់ថា មានសតិបរិសុទ្ធ ព្រោះឧបេក្ខា ។ បទថា **ចតុត្ថំ** ឈ្មោះថា **ចតុត្ថ** ព្រោះជាលំដាប់នៃការរាប់ ឈ្មោះថា **ចតុត្ថ** ព្រោះកើតជាលើកទី ៤ ក៏មាន ។

ឈានទាំង ៤ នេះ ផ្សេងគ្នាក្នុងចំណែកខាងដើមខ្លះ ក្នុងខណៈនៃមគ្គខ្លះ ។

ក្នុងចំណែកខាងដើមផ្សេងគ្នាដោយអំណាចសមាបត្តិ ក្នុងខណៈនៃមគ្គផ្សេងគ្នាដោយអំណាចមគ្គផ្សេងៗ ។ ពិតហើយ សម្រាប់ព្រះយោគាវចរអង្គខ្លះ បឋមមគ្គមានក្នុងបឋមជ្ឈាន ទុតិយមគ្គជាដើម ក៏មានក្នុងបឋមជ្ឈាន ឬមាននៅក្នុងឈានឯណានីមួយ ក្នុងទុតិយជ្ឈានជាដើម ។ សម្រាប់ព្រះយោគាវចររូបខ្លះ បឋមមគ្គ មានក្នុងឈានឯណានីមួយ នៃទុតិយជ្ឈានជាដើម សូម្បីទុតិយមគ្គជាដើម ក៏មាននៅក្នុងឈានឯណានីមួយ នៃទុតិយជ្ឈានជាដើម ឬមាននៅក្នុងបឋមជ្ឈាន ។

មគ្គសូម្បីទាំង ៤ យ៉ាង ដូចគ្នាខ្លះ មិនដូចគ្នាខ្លះ ដូចគ្នាក្នុងចំណែកខ្លះដោយអំណាចរបស់ឈាន ដោយប្រការដូច្នេះ ។ ការផ្សេងគ្នានៃមគ្គនោះ រមែងមានដោយកំណត់ឈានជាបាទ ។ ពិតហើយ កាលអ្នកបានបឋមជ្ឈានចេញចាកបឋមជ្ឈានហើយ ឃើញច្បាស់មគ្គដែលកើតឡើងហើយ រមែងមានក្នុងបឋមជ្ឈាន ចំណែកអង្គនៃមគ្គ និងពោជ្ឈង្គ ឈ្មោះថា បរិបូរណ៍ហើយ ក្នុងបឋមជ្ឈាននេះ ។ កាលបុគ្គលបានទុតិយជ្ឈាន ចេញពីទុតិយជ្ឈានហើយ ឃើញច្បាស់មគ្គដែលកើតឡើងហើយ រមែងមានក្នុងទុតិយជ្ឈាន ចំណែកអង្គនៃមគ្គក្នុងទុតិយជ្ឈាននេះមាន ៧ យ៉ាង[១]។ កាលបុគ្គលបានតតិយជ្ឈាន ចេញអំពីតតិយជ្ឈានហើយ ឃើញច្បាស់មគ្គដែលកើតឡើងហើយ រមែងមានក្នុងតតិយជ្ឈាន ចំណែកអង្គនៃមគ្គក្នុងតតិយជ្ឈាននេះ មាន ៧ យ៉ាង ពោជ្ឈង្គមាន ៦ យ៉ាង ។ ន័យនេះ រមែងបានតាំងអំពីចតុត្ថជ្ឈាន រហូតដល់នេវសញ្ញា-

---

១- មិនមានសម្មាសង្កប្ប ដ្បិតទុតិយជ្ឈាន មិនមានវិតក្ក ( អ្នកប្រែ ) ។

នាសញ្ញាយតនជ្ឈាន ។ ក្នុងអរូបជ្ឈាន ចតុក្កជ្ឈាន និងបញ្ចកជ្ឈាន រមែងកើតឡើងបាន ។ មួយវិញទៀត ចតុក្កជ្ឈាន និងបញ្ចកជ្ឈាននោះឯង លោកពោលថា ជាលោកុត្តរ មិនមែនជាលោកិយ ។ ក្នុងពាក្យនេះ លោកពោលដូចម្តេច ក្នុងពាក្យនេះមានអធិប្បាយថា ភិក្ខុណាចេញចាកឈានណា មានបឋមជ្ឈានជាដើម បានសោតាបត្តិមគ្គហើយ ចម្រើនអរូបសមាបត្តិ កើតហើយក្នុងអរូបជ្ឈាន មគ្គ ៣ ដែលមានឈាននោះជាបាទរបស់ភិក្ខុនោះ រមែងកើតក្នុងអរូបជ្ឈាននោះ ។ ឈានដែលជាបាទនោះឯង រមែងកំណត់ដោយប្រការដូច្នេះ ។ ចំណែកព្រះថេរៈអន្លខ្លះពោលថា ខន្ធដែលជាអារម្មណ៍របស់វិបស្សនា រមែងកំណត់ ។ អន្លខ្លះពោលថា អជ្ឈាស្រ័យរបស់បុគ្គល រមែងកំណត់ អន្លខ្លះពោលថា វិបស្សនាដែលជាវុដ្ឋានគាមិនី រមែងកំណត់ ។

ក្នុងពាក្យរបស់លោកទាំងនោះ មានកថាតាមលំដាប់យ៉ាងនេះ មគ្គដែលកើតឡើងដល់ព្រះសុក្ខវិបស្សកៈ ដោយកំណត់វិបស្សនាខ្លះ មគ្គដែលមិនធ្វើឈានឲ្យជាបាទ កើតឡើងដល់អ្នកបានសមាបត្តិខ្លះ មគ្គដែលភិក្ខុធ្វើបឋមជ្ឈានឲ្យជាបាទ ហើយពិចារណាសង្ខារបក្តិចបន្តចឲ្យកើតឡើងខ្លះ រមែងមានក្នុងបឋមជ្ឈានទាំងនោះ ។ ក្នុងមគ្គទាំងអស់ ពោជ្ឈង្គមាន ៧ អង្គមគ្គមាន ៨ អង្គឈានមាន ៥ ។ វិបស្សនាដែលជាចំណែកខាងដើម របស់មគ្គទាំងនោះ សហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ ក្នុងវេលាចេញដល់នូវសភាពជាសង្ខារុបេក្ខា សហគតៈដោយសោមនស្សតែម្យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ចកន័យដូចតទៅនេះថា ឈានមានអង្គ ៤ មាន

អង្គ ៣ និងមានអង្គ ២ រមែងមានតាមលំដាប់ក្នុងមគ្គដែលភិក្ខុធ្វើទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានឲ្យជាបាទហើយឲ្យកើតឡើង ។ ក្នុងឈានទាំងអស់ អង្គមគ្គមាន ៧ ក្នុងឈានទី ៤ពោជ្ឈង្គមាន ៦ ។ ការផ្សេងគ្នានេះ រមែងមានដោយការកំណត់ឈានជាបាទ និងដោយការកំណត់វិបស្សនា ។ ពិតហើយ វិបស្សនាជាចំណែកខាងដើម របស់ឈានទាំងនោះ សហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ វិបស្សនាដែលជាវុដ្ឋានគាមិនី សហគតៈដោយសោមនស្សប៉ុណ្ណោះ ។

ចំណែកក្នុងមគ្គដែលធ្វើបញ្ចមជ្ឈានឲ្យជាបាទហើយកើតឡើង អង្គឈានមាន ២ ដោយអំណាចនៃឧបេក្ខា និងចិត្តេកគ្គតា ពោជ្ឈង្គមាន ៦ អង្គនៃមគ្គមាន ៧ ។ ការផ្សេងគ្នានេះ រមែងមានដោយអំណាចការកំណត់ទាំងពីរ ។

ពិតហើយ ក្នុងន័យនេះ វិបស្សនាក្នុងចំណែកខាងដើម សហគតៈដោយសោមនស្ស ឬសហគតៈដោយឧបេក្ខាវិបស្សនាដែលជាវុដ្ឋានគាមិនី សហគតៈដោយឧបេក្ខាប៉ុណ្ណោះ ។ សូម្បីក្នុងមគ្គដែលធ្វើអរូបជ្ឈានឲ្យជាបាទហើយ ឲ្យកើតឡើង ក៏ន័យនេះដូចគ្នា ។ ចំណែកក្នុងទីនេះ ក្នុងចតុក្កន័យ ព្រោះមិនមានទុតិយជ្ឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ គប្បីនាំទុតិយជ្ឈាននោះចេញទៅ ហើយប្រកបដោយអំណាចឈានដ៏សេស ។ សមាបត្តិដែលចេញក្នុងទីដែលជិតនៃមគ្គ ដែលចេញចាកឈានដែលជាបាទយ៉ាងនេះហើយ ពិចារណាសង្ខារឯណានីមួយ ធ្វើឲ្យកើតឡើង រមែងធ្វើមគ្គឲ្យមានសភាពដូចគ្នានឹងខ្លួន ដូចសត្វទន្សងធ្វើពណ៌ឲ្យដូចពណ៌ផែនដី ដូច្នោះ ។

ក្នុងវាទៈរបស់ព្រះថេរៈអង្គទី ២ មានដូច្នេះថា មគ្គរមែងដូចគ្នានឹងសមាបត្តិដែលភិក្ខុចេញហើយ ពិចារណាដល់ធម៌ក្នុងសមាបត្តិកើតឡើង ។ សូម្បីក្នុងវាទៈរបស់ព្រះថេរនោះ គប្បីជ្រាបការកំណត់វិបស្សនាដោយន័យដូចពោលហើយនោះឯង ។

ក្នុងវាទៈរបស់ព្រះថេរៈអង្គទី ៣ មានដូច្នេះថា មគ្គរមែងដូចគ្នានឹងឈានដែលភិក្ខុធ្វើឲ្យជាបាទ ពិចារណាធម៌ក្នុងឈានហើយ ឲ្យកើតឡើង តាមសមគួរដល់អជ្ឈាស្រ័យរបស់ខ្លួន ។ ឈាននោះ វៀរឈានដែលជាបាទ ឬឈានដែលពិចារណាហើយ រមែងមិនសម្រេចដោយត្រឹមតែអជ្ឈាស្រ័យប៉ុណ្ណោះ ។ មួយវិញទៀត ក្នុងវាទៈរបស់ព្រះថេរៈនេះ ក៏គប្បីជ្រាបការកំណត់វិបស្សនាដោយន័យដូចពោលហើយនោះឯង ។

បទថា **អយំ វុច្ចតិ សម្មាសមាធិ** សេចក្តីថា ភាពដែលចិត្តមានអារម្មណ៍តែមួយក្នុងឈានទាំង ៤ នេះ ក្នុងចំណែកខាងដើមជាលោកិយ ក្នុងចំណែកខាងចុងជាលោកុត្តរ ហៅឈ្មោះថា សម្មាសមាធិ ។ ព្រះធម្មសេនាបតីសារីបុត្ត សម្តែងមគ្គសច្ចដោយអំណាចលោកិយ និងលោកុត្តរដោយប្រការដូច្នេះ ។

ក្នុងមគ្គសច្ចនោះ អង្គមគ្គទាំងអស់ក្នុងលោកិយមគ្គ ជាអារម្មណ៍ឯណានីមួយក្នុងអារម្មណ៍ ៦ តាមសមគួរ ។ ចំណែកក្នុងលោកុត្តរ មគ្គសម្មាទិដ្ឋិគឺបញ្ញាចក្ខុដែលដកអវិជ្ជានុស័យ ដែលមាននិព្វានជាអារម្មណ៍របស់អរិយសាវកដែលប្រព្រឹត្តទៅហើយ ដោយការចាក់ធ្លុះសច្ចៈ ៤ សម្មាសង្កប្ប គឺការកំណត់

ចិត្តឲ្យមាំទាំក្នុងបទនៃនិព្វានដែលដកមិច្ឆាសង្កប្ប ៣ យ៉ាង ដែលសម្បយុត្ត ដោយសម្មាទិដ្ឋិនោះ របស់បុគ្គលមានទិដ្ឋិដល់ព្រមហើយយ៉ាងនោះ សម្មាវាចា គឺចេតនាជាគ្រឿងវៀរមិច្ឆាវាចាដែលដកវចីទុច្ចរិត ៤ យ៉ាង ដែលសម្បយុត្ត ដោយសម្មាទិដ្ឋិ និងសម្មាសង្កប្បនោះ របស់បុគ្គលដែលឃើញ និងត្រិះរិះយ៉ាង នោះ សម្មាកម្មន្តៈ គឺចេតនាជាគ្រឿងវៀរមិច្ឆាកម្មន្តៈ ដែលកាត់មិច្ឆាកម្មន្តៈ ៣ យ៉ាងដែលសម្បយុត្តដោយសម្មាវាចានោះ របស់អ្នកវៀរយ៉ាងនោះ សម្មា-អាជីវៈ គឺចេតនាជាគ្រឿងវៀរចាកមិច្ឆាអាជីវៈ ដែលកាត់នូវការបោកបញ្ឆោតជា ដើមដែលសម្បយុត្តដោយសម្មាកម្មន្តៈនោះ ដែលជាការផ្ទេរផង់របស់វាចា និង កម្មន្តៈទាំងនោះ របស់អរិយសាវកនោះ សម្មាវាយាមៈ គឺការប្រារព្ធសេចក្តី ព្យាយាមដែលសម្បយុត្តដោយសម្មាវាចា សម្មាសម្មន្តៈ និងសម្មាអាជីវៈនោះ ដែលសមគួរដល់សម្មាវាចាជាដើមនោះ ដែលកាត់នូវការខ្ជិលច្រអូស និងដែល ឲ្យសម្រេចដោយមិនឲ្យអកុសលកើតឡើង លះអកុសលដែលកើតឡើង ធ្វើ កុសលដែលមិនទាន់កើតឲ្យកើតឡើង តាំងមាំក្នុងកុសលដែលកើតឡើងហើយ របស់បុគ្គល ដែលតាំងនៅក្នុងសីលភូមិ ពោលគឺសម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈនោះ សម្មាសតិ គឺភាពដែលចិត្តមិនវង្វេងដែលសម្បយុត្តដោយ សម្មាវាយាមៈនោះ ដែលលះបង់មិច្ឆាសតិ និងដែលឲ្យសម្រេចការពិចារណា កាយក្នុងកាយជាដើម របស់បុគ្គលដែលព្យាយាមយ៉ាងនេះ សម្មាសមាធិ គឺ ភាពដែលចិត្តមានអារម្មណ៍តែមួយ ដែលសម្បយុត្តដោយសម្មាសតិនោះដែល កម្ចាត់មិច្ឆាសមាធិរបស់បុគ្គលដែលគ្រប់គ្រងចិត្ត តាំងចិត្តដោយល្អ ដោយ សតិដ៏ប្រសើរយ៉ាងនេះ ។ នេះគឺអដ្ឋង្គិកមគ្គដ៏ប្រសើរ ជាលោកុត្តរ ។

មគ្គណា មួយអន្ទើដោយលោកិយមគ្គដែលដល់នូវការរាប់ថាជាទុក្ខនិរោធគាមិនីបដិបទានោះ មគ្គនោះ បានដល់ អវិជ្ជា និងចរណៈ ព្រោះសង្គ្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បដោយវិជ្ជា សង្គ្រោះធម៌ដ៏សេសដោយចរណៈ ។ មួយវិញទៀត បានដល់ សមថៈ និងវិបស្សនា ព្រោះសង្គ្រោះធម៌ទាំងពីរយ៉ាងនោះដោយវិបស្សនាយាន សង្គ្រោះធម៌ក្រៅអំពីនោះដោយសមថយាន ។ បានដល់ ខន្ធ ៣ និងសិក្ខា ៣ ព្រោះសង្គ្រោះធម៌ទាំងពីរនោះ ដោយបញ្ញាខន្ធ សង្គ្រោះធម៌ ៣ យ៉ាង ក្នុងលំដាប់ធម៌នោះដោយសីលក្ខន្ធ សង្គ្រោះធម៌ ៣ យ៉ាងដ៏សេសដោយសមាធិក្ខន្ធ និងសង្គ្រោះ ( ធម៌តាមលំដាប់ទាំងនេះ ) ដោយអធិប្បញ្ញាសិក្ខា អធិសីលសិក្ខា និងអធិចិត្តសិក្ខា ។ ព្រះអរិយសាវកប្រកបព្រមហើយដោយមគ្គ ជាអ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ដូចបុគ្គលដើរផ្លូវឆ្ងាយប្រកបដោយភ្នែកអាចឃើញបាន និងដោយជើងអាចដើរបាន វៀរទីបំផុត ២ យ៉ាង គឺ វៀរកាមសុខល្លិកានុយោគ ដោយវិបស្សនាយាន វៀរអត្តកិលមថានុយោគដោយសមថយាន បដិបត្តិមជ្ឈិមប្បដិបទា ទម្លាយគំនរមោហៈដោយបញ្ញាខន្ធ ទម្លាយគំនរទោសៈដោយសីលក្ខន្ធ ទម្លាយគំនរលោភៈដោយសមាធិក្ខន្ធ ដល់នូវសម្បត្តិ ៣ គឺបញ្ញាសម្បទាដោយអធិប្បញ្ញាសិក្ខា សីលសម្បទាដោយអធិសីលសិក្ខា សមាធិសម្បទាដោយអធិចិត្តសិក្ខាហើយ ធ្វើឲ្យជាក់ច្បាស់នូវនិព្វានដែលជាអមតៈ ។ រមែងជាអ្នកឈមចុះកាន់អរិយភូមិ ពោលគឺសម្មត្តនិយាមដែលវិចិត្រដោយធម្មរតនៈ គឺពោធិបក្ខិយធម៌ ៣៧ មានលម្អក្នុងខាងដើម កណ្ដាល និងទីបំផុត ដោយប្រការដូច្នេះ ៕

**អដ្ឋកថាមគ្គសច្ចនិទ្ទេស ចប់**

# អដ្ឋកថា
# សច្ចបកិណ្ណកៈ

ក្នុងសច្ចៈទាំងឡាយ ៤ នោះ ទុក្ខសច្ច មានការបៀតបៀនជាលក្ខណៈ សមុទយសច្ច មានភាពជាដែនកើតជាលក្ខណៈ និរោធសច្ច មានការស្ងប់ជាលក្ខណៈ មគ្គសច្ចមានការនាំចេញជាលក្ខណៈ ម្យ៉ាងវិញទៀត អរិយសច្ច មានបវត្តិ ( ការប្រព្រឹត្តទៅ ) មានបវត្តកៈ ( អ្នកឲ្យប្រព្រឹត្តទៅ ) មាននិវត្តិ ( ការមិនប្រព្រឹត្តទៅ ) និងមាននិវត្តកៈ ( ហេតុមិនប្រព្រឹត្តទៅ ) ជាលក្ខណៈ ដោយលំដាប់អរិយសច្ច មានសង្ខតៈ មានតណ្ហា មានអសង្ខតៈ និងមានទស្សនៈជាលក្ខណៈ ។

បើមានពាក្យសួរថា ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់អរិយសច្ច ៤ មិនលើសមិនខ្វះ ឆ្លើយថា ព្រោះមិនមានសច្ចៈដទៃ និងព្រោះមិនគួរដកសច្ចៈណាមួយចេញ ព្រោះថា វត្ថុដទៃក្រៅអំពីអរិយសច្ច ៤ នេះ ដែលលើស ឬអរិយ-សច្ចទាំងនោះ គប្បីដកចេញសូម្បីតែមួយ រមែងកើតឡើងមិនបាន ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍គប្បីមកក្នុងទីនេះ ពោលថា នេះមិនមែនទុក្ខអរិយសច្ច ទុក្ខអរិយសច្ចដទៃ ខ្ញុំនឹងបញ្ញត្តទុក្ខអរិយសច្ចដទៃ វៀរទុក្ខអរិយសច្ចដែលព្រះសមណគោតម សម្តែងហើយ សេចក្តីនោះ មិនមែនជាឋានៈ មិនមែនជាហេតុ ដូច្នេះជាដើម ។

នឹងសមដូចព្រះតម្រាស់មួយកន្លែងទៀត ( សំយុត្តនិកាយ មហាវារវគ្គ ) ថា

ម្នាលភិក្ខុ ទោះបីសមណៈ ឬព្រាហ្មណ៍ឯណានីមួយ គប្បីពោលយ៉ាងនេះថា

សេចក្ដីទុក្ខណា ដែលព្រះសមណគោតមត្រាស់ហើយ សេចក្ដីទុក្ខនុ៎ះមិនមែនជាអរិយសច្ចទី ១ ទេ យើងនឹងបដិសេធនូវសេចក្ដីទុក្ខដែលចាត់ជាអរិយសច្ចទី ១ នោះហើយ បញ្ញត្តសេចក្ដីទុក្ខដទៃថាជាអរិយសច្ចទី ១ ដូច្នេះវិញ ហេតុនុ៎ះមិនមានឡើយ ដូច្នេះជាដើម ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគ កាលទ្រង់ប្រាប់បវត្តិ ( ការប្រព្រឹត្តទៅ គឺទុក្ខ ) ទ្រង់ប្រាប់ព្រមដោយហេតុ និងប្រាប់និវត្តិព្រមដោយឧបាយ គឺមគ្គ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់អរិយសច្ច ៤ ដោយភាពជាធម៌ក្រៃលែងនោះ នៃបវត្តិ និងនិវត្តិ និងនៃហេតុទាំង ២ ប្រការ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ដល់អរិយសច្ច ៤ ដោយអំណាចនៃតណ្ហាវត្ថុ តណ្ហា តណ្ហានិរោធ និងឧបាយរម្ងត់តណ្ហា និងសេចក្ដីអាល័យ ការត្រេកអរក្នុងសេចក្ដីអាល័យ ការដកនូវសេចក្ដីអាល័យ និងឧបាយក្នុងការដកនូវសេចក្ដីអាល័យដែលគួរកំណត់ដឹង គួរលះបង់ គួរធ្វើឲ្យជាក់ច្បាស់ និងគួរធ្វើឲ្យកើត ។

ម្យ៉ាងទៀត ក្នុងអរិយសច្ចនេះ ទ្រង់ត្រាស់ទុក្ខសច្ចជាប្រការទី ១ ព្រោះទុក្ខសច្ចដឹងបានងាយ ព្រោះជារបស់គ្រោតគ្រាត និងព្រោះជារបស់ទូទៅដល់សត្វទាំងពួង ។ ត្រាស់សមុទយសច្ច បន្តអំពីទុក្ខសច្ចនោះ ដើម្បីសម្ដែងដល់ហេតុនៃទុក្ខសច្ចនោះ បន្ទាប់អំពីនោះ ត្រាស់និរោធសច្ច ដើម្បីឲ្យដឹងថា ការរលត់ផលព្រោះការរលត់ហេតុ ត្រាស់មគ្គសច្ចក្នុងទីបំផុតដើម្បីសម្ដែងឧបាយឲ្យសម្រេចនិរោធសច្ចនោះ ។ មួយវិញទៀត ទ្រង់ត្រាស់ទុក្ខសច្ចមុន ដើម្បី

ឲ្យកើតសេចក្តីសង្វេគដល់សត្វទាំងឡាយ ដែលត្រូវចងដោយសេចក្តីពេញចិត្ត ក្នុងសេចក្តីសុខក្នុងភព ត្រាស់សមុទយសច្ច ក្នុងលំដាប់បន្ទាប់អំពីទុក្ខសច្ចនោះ ដើម្បីឲ្យដឹងថា ទុក្ខនោះដែលសមុទយៈមិនធ្វើហើយ រមែងមិនមកដល់ រមែងមិនមានចាកការនិម្មិតរបស់ព្រះឥស្សរជាដើម តែរមែងមានអំពីសមុទយៈនេះ ត្រាស់និរោធសច្ច បន្ទាប់អំពីនោះ ដើម្បីឲ្យកើតសេចក្តីក្សេម ដោយការឃើញឧបាយជាគ្រឿងរលាស់ចេញ របស់បុគ្គលដែលស្វែងរកឧបាយ ជាគ្រឿងរលាស់ចេញចាកទុក្ខ ដែលមានសេចក្តីសង្វេគ ព្រោះត្រូវទុក្ខមួយអន្ទើដោយហេតុគ្របសង្កត់ បន្ទាប់អំពីនោះ ត្រាស់មគ្គដែលឲ្យដល់និរោធ ដើម្បីសម្រេចការរលត់ នេះជាលំដាប់របស់អរិយសច្ចទាំងនោះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអរិយសច្ចទាំងនេះ គួរឃើញទុក្ខសច្ចដូចជាភារៈ គួរឃើញសមុទយសច្ចៈដូចការទូលភារៈ គួរឃើញនិរោធសច្ច ដូចការដាក់ចុះនូវភារៈ គួរឃើញមគ្គសច្ច ដូចឧបាយដាក់ចុះនូវភារៈ ។

ម្យ៉ាងវិញទៀត គួរឃើញទុក្ខសច្ចដូចជារោគ គួរឃើញសមុទយសច្ចដូចជាហេតុរបស់រោគ គួរឃើញនិរោធសច្ចៈដូចជាការស្ងប់របស់រោគ គួរឃើញមគ្គសច្ចដូចជាថ្នាំកែរោគ ។ ម្យ៉ាងទៀត គួរឃើញទុក្ខសច្ច ដូចស្រុកកើតទុរ្ភិក្ស គួរឃើញសមុទយសច្ច ដូចជាការមិនមានភ្លៀង គួរឃើញនិរោធសច្ច ដូចការបាននូវម្ហូបអាហារដោយងាយ គួរឃើញមគ្គសច្ច ដូចជាភ្លៀងធ្លាក់ត្រូវតាមរដូវកាល ។ ម្យ៉ាងទៀត គប្បីប្រកបអរិយសច្ចទាំងនេះ ហើយជ្រាបដោយការប្រៀបធៀបដោយបុគ្គលមានពៀរ ហេតុរបស់ពៀរ ការកម្ចាត់នូវពៀរ ឧបាយ

កម្ចាត់នូវពៀរ ប្រៀបធៀបដោយដើមឈើពុល ឫសដើមឈើ ការបំផ្លាញឫស និងឧបាយកម្ចាត់ឫសនៃដើមឈើនោះ ប្រៀបធៀបដោយភ័យ ហេតុរបស់ភ័យ ការមិនមានភ័យ និងឧបាយដើម្បីសម្រេចដល់ការមិនមានភ័យនោះ ។ ប្រៀបធៀបដោយត្រើយអាយ អន្លង់ទឹកធំ ត្រើយនាយ និងសេចក្ដីព្យាយាមឲ្យដល់ត្រើយនាយនោះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបសច្ចៈទាំងអស់នេះ ដោយបរមត្ថថា ទទេ ព្រោះមិនមានអ្នកសោយ អ្នកធ្វើ អ្នករម្លត់ និងអ្នកទៅ ។ ដោយហេតុនោះ ទើបលោកពោលថា សេចក្ដីពិត ទុក្ខប៉ុណ្ណោះមាន តែមិនមានបុគ្គលណាមួយដល់នូវសេចក្ដីទុក្ខ បុគ្គលអ្នកធ្វើមិនមាន តែកិរិយា គឺការធ្វើមាន ការរម្លត់មាន តែបុគ្គលអ្នករម្លត់មិនមាន ផ្លូវមានតែអ្នកដើរ មិនមាន ។

ម្យ៉ាងទៀត លោកពោលថា ការទទេក្នុងសច្ចៈ ៤ ទាំងនោះ គប្បីជ្រាបយ៉ាងនេះថា សច្ចៈ ២ ខាងដើម ទទេចាកការទៀង ការស្អាត សេចក្ដីសុខ និងតួខ្លួន អមតបទ ( និរោធ ) ទទេចាកអត្តា មគ្គ ទទេចាកការទៀង សេចក្ដីសុខ និងអត្តា ។

ម្យ៉ាងទៀត សច្ចៈ ៣ យ៉ាង ទទេចាកនិរោធ ឯនិរោធក៏ទទេចាកសច្ចៈ ៣ យ៉ាងដ៏សេស ។ ម្យ៉ាងទៀត ក្នុងសច្ចៈទាំង ៤ នេះ សច្ចៈដែលជាហេតុទទេចាកសច្ចៈដែលជាផល ព្រោះមិនមានទុក្ខក្នុងសមុទយៈ និងព្រោះមិនមាននិរោធក្នុងមគ្គ ហេតុមិនរួមគភ៌ជាមួយផល ដូចបកតិរបស់ពួកបកតិវាទី ។ ម្យ៉ាងទៀត ផលក៏ទទេចាកហេតុ ព្រោះទុក្ខ និងសមុទយៈ និរោធ និងមគ្គរួមគ្នា

ជាក្រុមមិនបាន ផលនោះ មិនបានរួមក្នុងហេតុជាហេតុជាផល ដូចផលកើតអំពីហេតុ ២ របស់ពួកសមវាយវាទី ។ ដោយហេតុនោះ ទើបលោកពោលថា ក្នុងសច្ចៈ ៤ នេះ សច្ចៈ ៣ ទទេចាកនិរោធ និរោធក៏ទទេចាកសច្ចៈ ៣ នោះ សច្ចៈដែលជាហេតុ ទទេចាកសច្ចៈដែលជាផល សូម្បីសច្ចៈដែលជាផល ក៏ទទេចាកសច្ចៈដែលជាហេតុនោះ ។

សច្ចៈទាំងអស់មានចំណែកស្មើគ្នានិងគ្នាដោយភាពជាសេចក្តីពិត ដោយទទេចាកខ្លួន និងដោយមានការចាក់ធ្លុះ ធ្វើបានលំបាក សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលអានន្ទ អ្នកសម្គាល់ហេតុនោះដូចម្តេច អំពើដូចម្តេចហ្ន៎ដែលបុគ្គលធ្វើបានដោយកម្រក្រៃលែងផង ហេតុកើតឡើងព្រមដោយកម្រផង ។ ជនណាបាញ់សរ តាមរន្ធចន្លោងដ៏តូចអំពីចម្ងាយឲ្យចេញទៅតៗ គ្នា មិនឲ្យដាច់ ឬក៏ជនណាបាញ់ទម្លុះនូវចុងនៃចុងរោមកន្ទុយដែលប្រៀកជា ៧ ចម្រៀក ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាបាញ់ទម្លុះនូវចុងនៃចុងរោមកន្ទុយ ដែលប្រៀកជា ៧ ចម្រៀក ហេតុនុ៎ះដែលបុគ្គលធ្វើបានដោយកម្រ ឬជាហេតុកើតឡើងព្រមដោយកម្រ ។ ម្នាលអានន្ទ ពួកជនណា ចាក់ធ្លុះតាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ចាក់ធ្លុះតាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ពួកជនទាំងនោះ ទើបឈ្មោះថា ចាក់ធ្លុះនូវហេតុដែលបុគ្គលចាក់ធ្លុះបានដោយកម្រ ដូច្នេះ ។

សច្ចៈទាំងឡាយមានចំណែកមិនស្មើគ្នា ដ្បិតកំណត់ដោយលក្ខណៈរបស់ខ្លួន ។ សច្ចៈពីរខាងដើម មានចំណែកស្មើគ្នា ព្រោះជ្រាលជ្រៅ ដោយអត្ថថា

ឈមចុះបានលំបាក ព្រោះជាលោកិយ និងព្រោះមានអាសវៈ មានចំណែកមិនស្មើគ្នា ព្រោះផ្សេងគ្នាដោយជាហេតុ និងជាផល និងព្រោះគួរកំណត់ដឹង និងគួរលះ ។ សូម្បីអរិយសច្ចៈពីរខាងក្រោយក៏មានចំណែកស្មើគ្នា ព្រោះលំបាកឈមចុះដោយភាពជាធម៌ជ្រាលជ្រៅ ព្រោះជាលោកុត្តរ និងព្រោះមិនមានអាសវៈ មានចំណែកមិនស្មើគ្នា ព្រោះផ្សេងគ្នាដោយភាពជាវិស័យ និងព្រោះជាវិសយី ( ផ្លូវទៅកាន់ដែននោះ ) និងព្រោះគួរធ្វើឲ្យជាក់ច្បាស់ និងគួរធ្វើឲ្យកើត ។ អរិយសច្ចទី ១ និងទី ៣ ក៏មានចំណែកស្មើគ្នាដោយអាងថាជាផលដូចគ្នា មានចំណែកមិនស្មើគ្នា ព្រោះជាសង្ខតៈ និងអសង្ខតៈ ។ អរិយសច្ចទី ២ និងទី ៤ ក៏មានចំណែកស្មើគ្នា ដោយអាងថាជាហេតុដូចគ្នា មានចំណែកមិនស្មើគ្នា ព្រោះជាកុសល និងអកុសលដោយចំណែកមួយ ។ សច្ចៈទី ១ និងទី ៤ មានចំណែកស្មើគ្នា ព្រោះជាសង្ខតធម៌ដូចគ្នា មានចំណែកមិនស្មើគ្នា ព្រោះជាលោកិយ និងលោកុត្តរ អរិយសច្ចទី ២ និងទី ៣ មានចំណែកស្មើគ្នា ព្រោះជាសេក្ខៈក៏មិនមែន អសេក្ខៈក៏មិនមែន មានចំណែកមិនស្មើគ្នា ព្រោះជាធម៌មានអារម្មណ៍ និងជាធម៌មិនមានអារម្មណ៍ លោកពោលថា បណ្ឌិតអ្នកមានបញ្ញា គប្បីដឹងឃើញច្បាស់នូវភាពដែលអរិយសច្ចទាំងឡាយមានចំណែកស្មើគ្នា និងមានចំណែកមិនស្មើគ្នា ដោយប្រការ និងដោយន័យយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអរិយសច្ចនេះ ទុក្ខទាំងអស់មានតែម្យ៉ាង ដោយការប្រព្រឹត្តទៅ មាន ២ យ៉ាង ដោយនាម និងរូប មាន ៣ យ៉ាង ដោយប្រភេទនៃភព

ដែលកើត គឺកាមភព រូបភព និងអរូបភព មាន ៤ យ៉ាង ដោយប្រភេទនៃអាហារ ៤ មាន ៥ យ៉ាង ដោយប្រភេទរបស់ឧបាទានក្ខន្ធ ៥ ។

សមុទយៈ មានតែម្យ៉ាងដោយឲ្យវដ្តៈប្រព្រឹត្តទៅ មាន ២ យ៉ាងដោយសម្បយុត្ត និងមិនសម្បយុត្តដោយទិដ្ឋិ មាន ៣ យ៉ាង ដោយប្រភេទនៃកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា មាន ៤ យ៉ាងព្រោះជាធម៌ដែលមគ្គ ៤ គប្បីលះ មាន ៥ យ៉ាង ដោយប្រភេទនៃការត្រេកអរក្រៃលែងក្នុងរូបជាដើម មាន ៦ យ៉ាង ដោយប្រភេទនៃពួកតណ្ហា ៦ ។

និរោធមានតែម្យ៉ាង ព្រោះជាអសង្ខតធាតុ តែដោយបរិយាយមាន ២ យ៉ាង គឺជាសឧបាទិសេសៈ និងអនុបាទិសេសៈ មាន ៣ យ៉ាង ដោយចូលទៅស្ងប់ភព ទាំង ៣ មាន ៤ យ៉ាង ព្រោះគួរបាក់ចុះដោយមគ្គទាំង ៤ មាន ៥ យ៉ាង ដោយចូលទៅស្ងប់សេចក្តីត្រេកអរក្រៃលែង ៥ មាន ៦ យ៉ាង ដោយប្រភេទនៃការអស់ទៅនូវពួកតណ្ហា ៦ ។

មគ្គមានតែម្យ៉ាង ព្រោះគួរចម្រើន មាន ២ យ៉ាង ដោយប្រភេទនៃសមថៈ និងវិបស្សនា ឬដោយប្រភេទនៃទស្សនៈ និងភាវនា មាន ៣ យ៉ាង ដោយប្រភេទនៃខន្ធ ៣ ពិតហើយ មគ្គនេះ ព្រោះជាសប្បទេសធម៌ ទើបសង្គ្រោះដោយខន្ធ ៣ ( សីលក្ខន្ធ សមាធិខន្ធ បញ្ញាខន្ធ ) ដែលជានិប្បទេសធម៌ ដូចជានគរ សង្គ្រោះរួមចូលដោយរាជាណាចក្រដូច្នោះ ដូចលោកពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខ ខន្ធទាំង ៣ ប្រការ លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខ

តែអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ម្នាលអាវុសោវិសាខ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ។ មគ្គមាន ៤ យ៉ាងសង្គ្រោះដោយសោតាបត្តិមគ្គជាដើម ។

ម្យ៉ាងទៀត សច្ចៈទាំងអស់មានតែម្យ៉ាង ព្រោះជាធម៌ពិត ឬព្រោះជាធម៌គួរដឹងក្រៃលែង មាន ២ យ៉ាង ព្រោះជាលោកិយ និងលោកុត្តរ ឬព្រោះជាសង្ខតៈ និងអសង្ខតៈ មាន ៣ យ៉ាង ព្រោះជាធម៌ដែលសោតាបត្តិមគ្គ និងមគ្គ ៣ ខាងលើគប្បីប្រហារ ព្រោះជាធម៌ដែលសោតាបត្តិមគ្គ និងមគ្គ ៣ ខាងលើមិនគប្បីប្រហារ និងព្រោះជាធម៌ដែលសោតាបត្តិមគ្គ និងមគ្គ ៣ ខាងលើ គប្បីប្រហារក៏មិនមែន មិនគប្បីប្រហារក៏មិនមែន មាន ៤ យ៉ាង ដោយភាពជាធម៌គួរកំណត់ដឹង គួរលះ គួរធ្វើឲ្យជាក់ច្បាស់ និងគួរចម្រើន ។ ព្រះសម្ពុទ្ធទ្រង់ដឹងវិធីរបស់អរិយសច្ច ដែលដឹងបានដោយលំបាក ដោយប្រភេទដ៏អនេក ដើម្បីប្រយោជន៍ និងដើម្បីសេចក្តីសុខ ដោយប្រការដូច្នេះ ។ល៕

**អដ្ឋកថាសច្ចបកិណ្ណកៈ ចប់**

ឥឡូវនេះ ព្រះធម្មសេនាបតីបង្អុលបង្ហាញសច្ចចតុក្កៈ ក្នុងទីបំផុតតាមលំដាប់ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងហើយនោះឯង ហើយសម្តែងសរុបសុតមយញ្ញាណ ដោយសច្ចចតុក្កៈថា **តំ ញាតដ្ឋេន ញាណំ** ដូច្នេះជាដើម ឈ្មោះថា **ញាណំ** ដូច្នេះជាដើម ព្រះធម្មសេនាបតីសម្តែងសរុបអរិយសច្ចទាំងអស់ ដែលលោកពោលក្នុងកាលមុនថា **សោតាវធានេ បញ្ញា សុតមយេ ញាណំ** ដោយប្រការដូច្នេះ ។

## អដ្ឋកថាសុតមយញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ៨៦ ] បញ្ញាក្នុងការស្តាប់ហើយសង្រួម ឈ្មោះថា សីលមយញ្ញាណ តើដូចម្តេច សីល ៥ គឺបរិយន្តបារិសុទ្ធិសីល ១ អបរិយន្តបារិសុទ្ធិសីល ១ បរិបុណ្ណបារិសុទ្ធិសីល ១ អបរាមដ្ឋបារិសុទ្ធិសីល ១ បដិប្បស្សទ្ធិបារិសុទ្ធិ-សីល ១ ។

បណ្តាសីលទាំង ៥ នោះ បរិយន្តបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់អនុបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទមានទីបំផុត នេះឈ្មោះថា បរិយន្តបារិសុទ្ធិសីល ។

អបរិយន្តបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់ឧបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទមិនមានទីបំផុត នេះឈ្មោះថា អបរិយន្តបារិសុទ្ធិសីល ។

បរិបុណ្ណបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់កល្យាណបុថុជ្ជនទាំងឡាយ ដែលប្រកបក្នុងកុសលធម៌ ជាអ្នកបំពេញក្នុងអសេក្ខបរិយន្តសីល មិនស្តាយកាយ និងជីវិត ជាអ្នកមានជីវិតលះបង់ហើយ នេះឈ្មោះថា បរិបុណ្ណបារិសុទ្ធិសីល ។

អបរាមដ្ឋបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់សេក្ខបុគ្គល ៧ ពួក នេះឈ្មោះថា អបរាមដ្ឋបារិសុទ្ធិសីល ។

បដិប្បស្សទ្ធិបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់ព្រះខីណាស្រពជាសាវ័កនៃព្រះតថាគត របស់ព្រះបច្ចេកពុទ្ធ របស់ព្រះតថាគតជាអរហន្តសម្មា-សម្ពុទ្ធ នេះឈ្មោះថា បដិប្បស្សទ្ធិបារិសុទ្ធិសីល ។

[ ៨៧ ] សីលមានទីបំផុតក៏មាន សីលមិនមានទីបំផុតក៏មាន ។ បណ្ដាសីលទាំង ២ យ៉ាងនោះ សីលមានទីបំផុតនោះ តើដូចម្ដេច ។ សីលមានលាភជាទីបំផុតក៏មាន សីលមានយសជាទីបំផុតក៏មាន សីលមានញាតិជាទីបំផុតក៏មាន សីលមានអវយវៈ ជាទីបំផុតក៏មាន សីលមានជីវិតជាទីបំផុតក៏មាន ។

សីលមានលាភជាទីបំផុតនោះ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃលាភ ព្រោះលាភជាបច្ច័យ ព្រោះលាភជាហេតុ នេះឈ្មោះថា សីលមានលាភជាទីបំផុត ។

សីលមានយស ជាទីបំផុតនោះ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃយស ព្រោះយសជាបច្ច័យ ព្រោះយសជាហេតុ នេះឈ្មោះថា សីលមានយសជាទីបំផុត ។

សីលមានញាតិជាទីបំផុតនោះ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃញាតិ ព្រោះញាតិជាបច្ច័យ ព្រោះញាតិជាហេតុ នេះឈ្មោះថា សីលមានញាតិជាទីបំផុត ។

សីលមានអវយវៈជាទីបំផុតនោះ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃអវយវៈ ព្រោះអវយវៈជាបច្ច័យ ព្រោះអវយវៈជាហេតុ នេះឈ្មោះថា សីលមានអវយវៈជាទីបំផុត ។

សីលមានជីវិតជាទីបំផុតនោះ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ

ប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃជីវិត ព្រោះជីវិតជាបច្ច័យ ព្រោះជីវិតជាហេតុ នេះឈ្មោះថា សីលមានជីវិតជាទីបំផុត ។ សីលទាំងឡាយមានសភាពយ៉ាងនេះ ជាសីលដាច់ សីលធ្លុះ សីលពពាល សីលពព្រុស មិនមែនជាសីលរបស់អ្នកជា មិនមែនជាសីលដែលវិញ្ញូជនសរសើរទេ ជាសីលដែលតណ្ហា និងទិដ្ឋិបរាមសអង្អែល ជាសីលមិនប្រព្រឹត្តទៅដើម្បីសមាធិ មិនមែនជាទីតាំងនៃសេចក្តីមិនក្តៅក្រហាយ មិនមែនជាទីតាំងនៃបាមោជ្ជ មិនមែនជាទីតាំងនៃបីតិ មិនមែនជាទីតាំងនៃបស្សទ្ធិ មិនមែនជាទីតាំងនៃសុខ មិនមែនជាទីតាំងនៃសមាធិ មិនមែនជាទីតាំងនៃយថាភូតញ្ញាណទស្សនៈ មិនមែនប្រព្រឹត្តទៅដើម្បីនិព្វិទាដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីការត្រាស់ដឹង ដើម្បីនិព្វានឡើយ នេះឈ្មោះថា សីលមានទីបំផុត ។

[ ៨៨ ] សីលមិនមានទីបំផុតនោះ តើដូចម្តេច ។ សីលមិនមានលាភជាទីបំផុតក៏មាន សីលមិនមានយសជាទីបំផុតក៏មាន សីលមិនមានញាតិជាទីបំផុតក៏មាន សីលមិនមានអវយវៈជាទីបំផុតក៏មាន សីលមិនមានជីវិតជាទីបំផុតក៏មាន ។

សីលមិនមានលាភជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញុំាងចិត្តឲ្យកើតឡើងដើម្បីប្រព្រឹត្តកន្លងសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃលាភ ព្រោះលាភជាបច្ច័យ ព្រោះដំណើរលាភទេ តើបុគ្គលនោះនឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះឈ្មោះថា សីលមិនមានលាភជាទីបំផុត ។

សីលមិនមានយសជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញុំាងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃយស ព្រោះយសជាបច្ច័យ ព្រោះដំណើរយសទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេច នេះឈ្មោះថា សីលមិនមានយសជាទីបំផុត ។

សីលមិនមានញាតិជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញុំាងចិត្តឲ្យកើតឡើង ដើម្បីកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃញាតិ ព្រោះញាតិជាបច្ច័យ ព្រោះដំណើរញាតិទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះឈ្មោះថា សីលមិនមានញាតិជាទីបំផុត ។

សីលមិនមានអវយវៈជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញុំាងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃអវយវៈ ព្រោះអវយវៈជាបច្ច័យ ព្រោះដំណើរអវយវៈទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះឈ្មោះថា សីលមិនមានអវយវៈជាទីបំផុត ។

សីលមិនមានជីវិតជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញុំាងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃជីវិត ព្រោះជីវិតជាបច្ច័យ ព្រោះដំណើរជីវិត តើបុគ្គលនោះនឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះឈ្មោះថា សីលមិនមានជីវិតជាទីបំផុត ។

សីលទាំងឡាយបែបនេះ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស

ជាសីលរបស់អ្នកជា ជាសីលដែលវិញ្ញូជនសរសើរ ជាសីលដែលមិនមានតណ្ហា និងទិដ្ឋិបៀតបៀនអង្អែល ប្រព្រឹត្តទៅដើម្បីសមាធិ ជាទីតាំងនៃសេចក្តីមិនក្តៅក្រហាយ ជាទីតាំងនៃបាមោជ្ជ ជាទីតាំងនៃបីតិ ជាទីតាំងនៃបស្សទ្ធិ ជាទីតាំងនៃសុខ ជាទីតាំងនៃសមាធិ ជាទីតាំងនៃយថាភូតញ្ញាណទស្សនៈ ប្រព្រឹត្តទៅដើម្បីនិព្វិទាដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន នេះឈ្មោះថា សីលមិនមានទីបំផុត ។

[ ៨៩ ] អ្វី ឈ្មោះថា សីល សីលមានប៉ុន្មាន សីលមានសមុដ្ឋានដូចម្តេច សីលជាទីប្រជុំចុះនៃធម៌អ្វីខ្លះ ។

សំណួរថា អ្វី ឈ្មោះថា សីល ចេតនា ឈ្មោះថា សីល ចេតសិក ឈ្មោះថា សីល សេចក្តីសង្រួម ឈ្មោះថា សីល ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល ។

សំណួរថា សីលមានប៉ុន្មាន សីលមាន ៣ គឺកុសលសីល ១ អកុសល-សីល ១ អព្យាកតសីល ១ ។

សំណួរថា សីលមានសមុដ្ឋានដូចម្តេច កុសលសីល មានកុសលចិត្តជាសមុដ្ឋាន អកុសលសីល មានអកុសលចិត្តជាសមុដ្ឋាន អព្យាកតសីល មានអព្យាកតចិត្តជាសមុដ្ឋាន ។

សំណួរថា សីលជាទីប្រជុំចុះនៃធម៌អ្វីខ្លះ សីលជាទីប្រជុំចុះនៃការសង្រួម សីលជាទីប្រជុំចុះនៃការមិនប្រព្រឹត្តកន្លង សីលជាទីប្រជុំចុះនៃចេតនាដែលកើតហើយក្នុងសភាពដូច្នោះ ។ សីល ដោយអត្ថថា បិទនូវបាណាតិបាត សីល

ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវអទិន្នាទាន សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវកាមេសុមិច្ឆាចារ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវមុសាវាទ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវបិសុណាវាចា សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវផរុសវាចា សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវសម្ផប្បលាបៈ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវអភិជ្ឈា សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវព្យាបាទ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវមិច្ឆាទិដ្ឋិ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវព្យាបាទដោយអព្យាបាទ សីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង សីល ដោយអត្ថថា បិទនូវថីនមិទ្ធៈដោយអាលោកសញ្ញា នូវឧទ្ធច្ចៈដោយសេចក្តីមិនរវើរវាយ នូវវិចិកិច្ឆាដោយកិរិយាកំណត់ធម៌ នូវអវិជ្ជាដោយញាណ នូវអរតិដោយបាមោជ្ជ នូវនីវរណៈទាំងឡាយដោយបឋមជ្ឈាន នូវវិតក្ក និងវិចារដោយទុតិយជ្ឈាន នូវបីតិដោយតតិយជ្ឈាន នូវសុខ និងទុក្ខដោយចតុត្ថជ្ឈាន នូវរូបសញ្ញា បដិឃ-សញ្ញា និងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ នូវអាកាសានញ្ចា-យតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ នូវវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ នូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវ-

សញ្ញានាសញ្ញាយតនសមាបត្តិ នូវសេចក្តីសម្គាល់ថា ទៀង ដោយការពិចារណាឃើញថា មិនទៀង នូវសេចក្តីសម្គាល់ថា សុខ ដោយការពិចារណាឃើញថា ទុក្ខ នូវសេចក្តីសម្គាល់ថា ខ្លួន ដោយការពិចារណាឃើញថា មិនមែនខ្លួន នូវតម្រេក ដោយការពិចារណាឃើញថា គួរនឿយណាយចាករាគៈ ដោយការពិចារណាឃើញថា ប្រាសចាករាគៈ នូវការកើតឡើង ដោយការពិចារណាឃើញថា រលត់ នូវសេចក្តីប្រកាន់ ដោយការពិចារណាឃើញថា គួររលាស់ចោលនូវសេចក្តីសម្គាល់ថា រឹងប៉ឹង ដោយការពិចារណាឃើញថា អស់ទៅ នូវការប្រមូលមក ដោយការពិចារណាឃើញថា សូន្យទៅ នូវសេចក្តីសម្គាល់ថា ស្ថិតស្ថេរ ដោយការពិចារណាឃើញថា ប្រែប្រួលនូវគ្រឿងចំណាំ ដោយការពិចារណាឃើញថា មិនមានគ្រឿងចំណាំ នូវសេចក្តីប្រាថ្នា ដោយការពិចារណាឃើញថា មិនគួរប្រាថ្នា នូវសេចក្តីប្រកាន់មាំ ដោយការពិចារណាឃើញថា សូន្យ នូវសេចក្តីប្រកាន់មាំ និងការប្រកាន់ស្អិតថា ខ្លឹមសារ ដោយអធិប្បញ្ញា និងធម្មវិបស្សនា នូវសេចក្តីប្រកាន់មាំ ព្រោះការវង្វេងខ្លាំងដោយយថាភូតញ្ញាណទស្សនៈ នូវសេចក្តីប្រកាន់មាំ ដោយសេចក្តីអាល័យ ដោយការពិចារណាឃើញថា ទោស នូវការមិនពិចារណា ព្រោះការឃើញដោយការពិចារណានូវសេចក្តីប្រកាន់មាំ ព្រោះកិលេសជាគ្រឿងប្រកប ដោយការពិចារណាឃើញនូវធម៌ជាគ្រឿងបើក ( គោត្រភូញាណ ) នូវពួកកិលេសដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ នូវពួកកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ នូវពួកកិលេសដ៏ល្អិត ដោយអនាគា-

មិមគ្គ នូវពួកកិលេសទាំងអស់ ដោយអរហត្តមគ្គ នូវសីល ដោយអត្ថថា សង្រួម នូវសីល ដោយអត្ថថា មិនប្រព្រឹត្តកន្លង ។

[ ៩០ ] សីល ៥ គឺការលះបង់បាណាតិបាត ឈ្មោះថា សីល ១ ការវៀរ ឈ្មោះថា សីល ១ ចេតនា ឈ្មោះថា សីល ១ សេចក្តីសង្រួម ឈ្មោះថា សីល ១ ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល ១ ពួកសីលមានសភាពយ៉ាងនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនក្តៅក្រហាយចិត្ត ប្រព្រឹត្តទៅដើម្បីបាមោជ្ជ ប្រព្រឹត្តទៅដើម្បីបីតិ ប្រព្រឹត្តទៅដើម្បីបស្សទ្ធិ ប្រព្រឹត្តទៅដើម្បីសោមនស្ស ប្រព្រឹត្តទៅដើម្បីសេព ប្រព្រឹត្តទៅដើម្បីភាវនា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យច្រើន ប្រព្រឹត្តទៅដើម្បីអលង្ការ ប្រព្រឹត្តទៅដើម្បីបរិក្ខារ ប្រព្រឹត្តទៅដើម្បីបរិវារ ប្រព្រឹត្តទៅដើម្បីបំពេញ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន សេចក្តីបរិសុទ្ធ គឺការសង្រួមនូវសីលទាំងឡាយមានសភាពយ៉ាងនេះ ឈ្មោះថា អធិសីល ចិត្តដែលតាំងនៅក្នុងសេចក្តីបរិសុទ្ធ គឺការសង្រួម មិនដល់នូវការរាយមាយ សេចក្តីបរិសុទ្ធ គឺការមិនរាយមាយ ឈ្មោះថា អធិចិត្ត បុគ្គលឃើញដោយប្រពៃនូវសេចក្តីបរិសុទ្ធ គឺការសង្រួម ឃើញដោយប្រពៃនូវសេចក្តីបរិសុទ្ធ គឺការមិនរាយមាយ សេចក្តីបរិសុទ្ធ គឺការឃើញ ឈ្មោះថា អធិប្បញ្ញា អត្ថនៃសេចក្តីសង្រួមណាក្នុងសំវរបារិសុទ្ធិនោះ នេះឈ្មោះថា អធិសីលសិក្ខា អត្ថនៃសេចក្តីមិនរាយមាយណា ក្នុងអវិក្ខេបបារិសុទ្ធិនោះ នេះឈ្មោះថា អធិចិត្តសិក្ខា អត្ថនៃសេចក្តីឃើញណាក្នុង

ទស្សនបារិសុទ្ធិនោះ នេះឈ្មោះថា អធិប្បញ្ញាសិក្ខា បុគ្គលកាលពិចារណា នូវសិក្ខាទាំង ៣ នេះទើបសិក្សា កាលដឹងទើបសិក្សា កាលឃើញទើបសិក្សា កាលពិចារណាឃើញទើបសិក្សា កាលតាំងចិត្តទើបសិក្សា កាលចុះចិត្តស៊ប់ដោយសទ្ធាទើបសិក្សា កាលផ្គងទុកនូវព្យាយាមទើបសិក្សា កាលប្រុងនូវស្មារតីទើបសិក្សា កាលតាំងចិត្តទុកទើបសិក្សា កាលដឹងច្បាស់ដោយបញ្ញាទើបសិក្សា កាលដឹងចំពោះនូវធម៌ដែលគប្បីដឹងច្បាស់ទើបសិក្សា កាលកំណត់ដឹងនូវទុក្ខសច្ចៈដែលគប្បីកំណត់ដឹងទើបសិក្សា កាលលះបង់នូវសមុទយសច្ចៈដែលគប្បីលះបង់ទើបសិក្សា កាលចម្រើននូវមគ្គសច្ចៈដែលគប្បីចម្រើនទើបសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ ដែលគប្បីធ្វើឲ្យជាក់ច្បាស់ទើបសិក្សា ។

[ ៩១ ] សីល ៥ គឺការលះបង់នូវបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ នូវកាមច្ឆន្ទៈដោយនេក្ខម្មៈ នូវព្យាបាទដោយអព្យាបាទ នូវថីនមិទ្ធៈដោយអាលោកសញ្ញា នូវឧទ្ធច្ចៈដោយការមិនរាយមាយ នូវវិចិកិច្ឆាដោយការកំណត់នូវធម៌ នូវអវិជ្ជាដោយញាណ នូវអរតិដោយបាមោជ្ជ នូវនីវរណៈទាំងឡាយដោយបឋមជ្ឈាន នូវវិតក្ក វិចារដោយទុតិយជ្ឈាន នូវបីតិដោយតតិយជ្ឈាន នូវសុខ និងទុក្ខដោយចតុត្ថជ្ឈាន នូវរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញាដោយអាកាសានញ្ចាយតនសមាបត្តិ នូវអាកាសានញ្ចាយតនសញ្ញាដោយវិញ្ញាណញ្ចាយតនសមាបត្តិ នូវសេចក្តីសម្គាល់ ក្នុងវិញ្ញាណញ្ចាយតនៈ

ដោយអាកិញ្ចញ្ញាយតនសមាបត្តិ នូវសេចក្តីសម្គាល់ ក្នុងអាកិញ្ចញ្ញាយតនៈ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ នូវសេចក្តីសម្គាល់ថាទៀង ដោយការពិចារណាឃើញថាមិនទៀង នូវសេចក្តីសម្គាល់ថាសុខ ដោយការពិចា-រណាឃើញថាជាទុក្ខ នូវសេចក្តីសម្គាល់ថាខ្លួន ដោយការពិចារណាឃើញថាមិនមែនខ្លួន នូវសេចក្តីត្រេកត្រអាលដោយការពិចារណាឃើញថា គួរនឿយណាយ នូវរាគៈដោយការពិចារណាឃើញថាប្រាសចាករាគៈ នូវការកើតឡើងដោយការពិចារណាឃើញថារលត់ទៅ នូវសេចក្តីប្រកាន់ដោយការពិចារណាឃើញថា គួររលាស់ចោល នូវសេចក្តីសម្គាល់ថារឹងប៉ឹងដោយការពិចារណាឃើញថាអស់ទៅ នូវការប្រមូលមកដោយការពិចារណាឃើញថាសូន្យទៅ នូវសេចក្តីសម្គាល់ថាស្ថិតស្ថេរ ដោយការពិចារណាឃើញថា ប្រែប្រួលនូវគ្រឿងចំណាំ ដោយការពិចារណាឃើញថា មិនមានគ្រឿងចំណាំ នូវសេចក្តីប្រាថ្នាដោយការពិចារណាឃើញថា មិនគួរប្រាថ្នា នូវការប្រកាន់មាំ ដោយការពិចារណាឃើញថាសូន្យ នូវសេចក្តីប្រកាន់មាំ និងសេចក្តីប្រកាន់ស្អិតថា មានខ្លឹមសារ ដោយអធិប្បញ្ញា និងធម្មវិបស្សនា នូវសេចក្តីប្រកាន់មាំ ព្រោះសេចក្តីវង្វេងខ្លាំង ដោយយថាភូតញ្ញាណទស្សនៈ នូវសេចក្តីប្រកាន់មាំ ព្រោះអាល័យ ដោយការពិចារណាឃើញថា ជាទោស នូវការមិនពិចារណា ដោយការឃើញ ដោយការពិចារណា នូវសេចក្តីប្រកាន់មាំ ព្រោះកិលេសជាគ្រឿងប្រកបទុក ដោយការពិចារណាឃើញ នូវធម៌ជាគ្រឿងបើក ( គោត្រភូញាណ ) នូវពួកកិលេស ដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ

នូវកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ នូវពួកកិលេសដ៏ល្អិត ដោយអនាគាមិមគ្គ នូវកិលេសទាំងអស់ ដោយអរហត្តមគ្គ ឈ្មោះថា សីល ១ ការវៀរបង់ ឈ្មោះថា សីល ១ ចេតនា ឈ្មោះថា សីល ១ ការសង្រួម ឈ្មោះថា សីល ១ ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល ១ ។ សីលមានសភាពយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីការមិនក្តៅក្រហាយចិត្ត ប្រព្រឹត្តទៅដើម្បីបាមោជ្ជ ប្រព្រឹត្តទៅដើម្បីបីតិ ប្រព្រឹត្តទៅដើម្បីបស្សទ្ធិ ប្រព្រឹត្តទៅដើម្បីសោមនស្ស ប្រព្រឹត្តទៅដើម្បីអាសេវនៈ ប្រព្រឹត្តទៅដើម្បីភាវនា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យច្រើន ប្រព្រឹត្តទៅដើម្បីគ្រឿងអលង្ការ ប្រព្រឹត្តទៅដើម្បីគ្រឿងបរិក្ខារ ប្រព្រឹត្តទៅដើម្បីបរិវារ ប្រព្រឹត្តទៅដើម្បីការបំពេញ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន សេចក្តីបរិសុទ្ធ គឺការសង្រួមនូវសីល មានសភាពយ៉ាងនេះ ឈ្មោះថា អធិសីល ចិត្តដែលតាំងនៅក្នុងសេចក្តីបរិសុទ្ធ គឺសេចក្តីសង្រួម មិនដល់នូវសេចក្តីរាយមាយ សេចក្តីបរិសុទ្ធ គឺសេចក្តីមិនរាយមាយ ឈ្មោះថា អធិចិត្ត បុគ្គលឃើញដោយប្រពៃនូវសេចក្តីបរិសុទ្ធ គឺការសង្រួម ឃើញដោយប្រពៃនូវសេចក្តីបរិសុទ្ធ គឺការមិនរាយមាយ សេចក្តីបរិសុទ្ធ គឺការឃើញ ឈ្មោះថា អធិប្បញ្ញា សេចក្តីសង្រួមណាក្នុងសំវរបារិសុទ្ធិនោះ នេះឈ្មោះថា អធិសីលសិក្ខា សេចក្តីមិនរាយមាយណាក្នុងអវិក្ខេបបារិសុទ្ធិនោះ នេះឈ្មោះថា អធិចិត្តសិក្ខា សេចក្តីឃើញណាក្នុងទស្សនបារិសុទ្ធិនោះ នេះឈ្មោះថា អធិ-

ប្បញ្ញាសិក្ខា បុគ្គលកាលពិចារណាឃើញនូវសិក្ខាទាំង ៣ នេះ ទើបសិក្សា កាលដឹងទើបសិក្សា កាលឃើញទើបសិក្សា កាលពិចារណាឃើញច្បាស់ ទើបសិក្សា កាលតាំងចិត្តទុកទើបសិក្សា កាលចុះចិត្តស៊ប់ដោយសទ្ធា ទើបសិក្សា កាលផ្គងទុកនូវសេចក្តីព្យាយាមទើបសិក្សា កាលប្រុងស្មារតីទើបសិក្សា កាលតម្កល់ចិត្តទុកដោយប្រពៃទើបសិក្សា កាលដឹងដោយបញ្ញាទើបសិក្សា កាលដឹងចំពោះនូវធម៌ដែលគប្បីដឹងចំពោះទើបសិក្សា កាលកំណត់ដឹងនូវទុក្ខ-សច្ចៈដែលគប្បីកំណត់ដឹងទើបសិក្សា កាលលះបង់នូវសមុទយសច្ចៈដែលគួរលះបង់ទើបសិក្សា កាលចម្រើននូវមគ្គសច្ចៈដែលគប្បីចម្រើនទើបសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ ដែលគប្បីធ្វើឲ្យជាក់ច្បាស់ទើបសិក្សា ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកហៅថា បញ្ញាក្នុងការស្តាប់ ហើយសង្រួម ឈ្មោះថា សីលមយញ្ញាណ ។

# អដ្ឋកថា

## សីលមយញ្ញាណនិទ្ទេស

[ ៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីលមយញ្ញាណនិទ្ទេសដូចតទៅ

បទថា **បញ្ច** គឺការកំណត់ចំនួន ។ បទថា **សីលានិ** ជាការសម្តែងធម៌ដែលកំណត់ ។ បទថា **បរិយន្តបារិសុទ្ធិសីលំ** ជាពាក្យសម្តែងសីល ៥ ដោយសរុប ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បរិយន្តបារិសុទ្ធិ** ជាដើមដូចតទៅ សេចក្តីបរិសុទ្ធ ឈ្មោះថា **បរិយន្ត** ព្រោះភាពបរិសុទ្ធមានទីបំផុត គឺមានកំណត់ដោយការរាប់ ដូចសំពត់ ហៅថា ខៀវ ព្រោះមានពណ៌ខៀវ ម្យ៉ាងទៀត កាលដល់សីលរបស់ឧបសម្បន្នហើយ ឈ្មោះថា មានទីបំផុត ព្រោះអត្ថថា មានទីបំផុត គឺអវសាន ព្រោះជាសភាវៈដល់ទីបំផុតនៃសីលរបស់អនុបសម្បន្ន ។ ម្យ៉ាងទៀត កាលគួរពោលថា **សបរិយន្តា** គប្បីជ្រាបថា លោកលុប **ស** អក្ខរៈចេញ ដូចលុប **ឧ** អក្ខរៈ ក្នុងបទនេះថា **ឧកំ ឧកាសយា បរិសន្តិ** ពួកសត្វទឹកចូលទៅក្នុងទឹកវិញ ដូច្នេះ ។ សេចក្តីបរិសុទ្ធ ឈ្មោះថា បារិសុទ្ធិ ទីបំផុតនោះផង សេចក្តីបរិសុទ្ធផង ឈ្មោះថា បរិយន្តបារិសុទ្ធិ សីល ពោល គឺបរិយន្តបារិសុទ្ធិ ឈ្មោះថា បរិយន្តបារិសុទ្ធិសីល ។

ដោយផ្ទុយគ្នាជាមួយនឹងការពោលហើយ សេចក្តីបរិសុទ្ធមិនមានទីបំផុត ឈ្មោះថា **អបរិយន្ត**។ ឈ្មោះថា **អបរិយន្ត** ព្រោះទីបំផុតនៃសេចក្តីបរិសុទ្ធនោះមិនមានខ្លះ ទីបំផុតនៃសេចក្តីបរិសុទ្ធនោះចម្រើនហើយខ្លះ ។

ឈ្មោះថា **បរិបុណ្ណា** ដោយអត្ថថា មិនខ្វះ ជាបទដ្ឋាននៃអរិយមគ្គ ព្រោះមិនដាច់ ចាប់ផ្តើមអំពីសមាទាន ព្រោះសូម្បីដាច់ក៏ធ្វើឲ្យជាប់វិញបាន និងព្រោះវៀរចាកមន្ទិល សូម្បីត្រឹមតែចិត្តុប្បាទ និងព្រោះបរិសុទ្ធ ដូចកែវមណីដែលបរិសុទ្ធ និងដូចមាសដែលដុសខាត់យ៉ាងល្អ ដូច្នោះ ។

ឈ្មោះថា **អបរាមដ្ឋ** ព្រោះលះបានដោយទិដ្ឋិ ព្រោះការស្ទាបអង្អែលដោយទិដ្ឋិមិនពាល់ត្រូវហើយ ម្យ៉ាងទៀត ឈ្មោះថា **អបរាមដ្ឋ** ព្រោះអ្នកចោទណាមួយមិនអាចពោលបានថា នេះជាទោសក្នុងការទ្រុស្តសីល របស់លោក ។ ឈ្មោះថា **បដិប្បស្សទ្ធិ** ព្រោះស្ងប់សេចក្តីក្រវល់ក្រវាយទាំងពួងក្នុងខណៈអរហត្តផល ។

បទថា **អនុបសម្បន្នានំ** មានវិនិច្ឆ័យថា ឈ្មោះថា **ឧបសម្បន្នំ** ព្រោះដល់ព្រមក្រៃលែងដោយសីលសម្បទា ដោយការសមាទាន មិនមានចំណែកសល់ ។ មិនមែនឧបសម្បន្ន ឈ្មោះថា អនុបសម្បន្ន ។ របស់អនុបសម្បន្នទាំងនោះ ។ ក្នុងបទថា **បរិយន្តសិក្ខាបទានំ** នេះ មានអធិប្បាយដូចតទៅ ឈ្មោះថា **សិក្ខា** ដោយអត្ថថា គួរសិក្សា ឈ្មោះថា **បទ** ដោយអត្ថថា ចំណែក អធិប្បាយថា ចំណែកដែលគួរសិក្សា ។ ម្យ៉ាងទៀត កុសលធម៌ទាំងអស់ ឈ្មោះថា **សិក្ខា** តាំងនៅក្នុងសីលហើយ គួរសម្រេចភូមិដែលខ្ពស់ឡើង សីលទាំងឡាយ ឈ្មោះថា **បទ** ដោយអត្ថថា ជាទីតាំងនៃសិក្ខាទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **សិក្ខាបទ** ព្រោះជាចំណែកនៃសិក្ខាទាំងឡាយ ឈ្មោះថា **បរិយន្តសិក្ខាបទ** ព្រោះមានសិក្ខាបទជាទីបំផុត ។ របស់

អនុបសម្បន្ន អ្នកមានសិក្ខាបទមានទីបំផុតទាំងនោះ ។ ម្យ៉ាងទៀត ក្នុងបទនេះ ទីបំផុតមាន ២ យ៉ាង គឺទីបំផុតដោយសិក្ខាបទ ១ ទីបំផុតដោយកាល ១ ។ ទីបំផុតដោយសិក្ខាបទ តើដូចម្តេច ឧបាសក ឧបាសិកា មានសិក្ខាបទ ១ ២ ៣ ៤ ៥ ៨ ឬ ១០ តាមដែលសមាទាន សិក្ខមានា សាមណេរ សាមណេរី មានសិក្ខាបទ ១០ នេះឈ្មោះថា ទីបំផុតដោយសិក្ខាបទ ។

ទីបំផុតដោយកាល តើដូចម្តេច ឧបាសក ឧបាសិកាទាំងឡាយ ឲ្យទាន រមែងសមាទានសីលក្នុងកាល អង្គាសអាហារជាទីបំផុត ទៅវិហារហើយរមែង សមាទានសីល មានបរិវេណវិហារជាទីបំផុត កំណត់យប់ ១ ថ្ងៃ ១ យប់ ២ ថ្ងៃ ២ យប់ ៣ ថ្ងៃ ៣ ឬក្រៃលែងជាងនោះ ហើយសមាទានសីល នេះ ឈ្មោះថា ទីបំផុតដោយកាល ។

ក្នុងទីបំផុត ២ យ៉ាងនេះ សីលដែលសមាទានធ្វើសិក្ខាបទឲ្យជាទីបំផុត រមែងរម្ងាប់ទៅដោយការកន្លងល្មើស ឬស្លាប់ សីលដែលសមាទានធ្វើទីបំផុត ដោយកាល រមែងរម្ងាប់ទៅដោយការឈានកន្លងកាលនោះៗ ។

បទថា **អបរិយន្តសិក្ខាបទធំ** លោកពោលថា

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសសំវរវិន័យទាំងនេះទុក ប្រាំបួន ពាន់ប្រាំបីរយកោដិ និងប្រាំលានសាមសិបប្រាំមួយកោដិ និង ដទៃៗ ទៀត ទ្រង់បញ្ញត្តសិក្ខាក្នុងសំវរវិន័យ ដោយមាតិកា បេយ្យាល ។

ឈ្មោះថា **អបរិយន្ត** ព្រោះសិក្ខាបទទាំងនោះមិនមានទីបំផុត ដោយការ

សមាទានមិនមានសេសសល់នូវសិក្ខាបទ សូម្បីមានទីបំផុត ដោយការរាប់យ៉ាងនេះ ដោយការមានទីបំផុតដែលមិនទាន់ឃើញ ព្រោះលាភ យស ញាតិ អវយវៈ និងជីវិត និងដោយការមិនមានការកំណត់សីល ដែលគួររក្សាតទៅខាងមុខ ឈ្មោះថា **អបរិយន្តសិក្ខាបទា** ព្រោះអនុបសម្បន្នមានសិក្ខាបទមិនមានទីបំផុត ។ របស់អ្នកមានសិក្ខាបទ មិនមានទីបំផុតទាំងនោះ ។ ម្យ៉ាងទៀត អធិប្បាយថា របស់ឧបសម្បន្នដែលមានសិក្ខាបទ មានទីបំផុតចម្រើនហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បុថុជ្ជនកល្យាណកានំ** ជាដើមដូចតទៅ សូម្បីមិនផុតលក្ខណៈនៃបុថុជ្ជន តាមដែលលោកពោលថា

ឈ្មោះថា បុថុជ្ជន ព្រោះមានកិលេសក្រាស់កើតឡើងជាដើម
និងព្រោះជននេះ ឈ្មោះថា បុថុជ្ជន ព្រោះឈមចុះខាងក្នុង
របស់ជនដែលមានកិលេសក្រាស់ ។

ឈ្មោះថា កល្យាណបុថុជ្ជន ដែលតាំងនៅក្នុងភាពជាកល្យាណបុថុជ្ជន ដោយឈានកន្លងភាពជាបុថុជ្ជន ដែលល្ងង់ខ្លៅ ដោយការគប់រកអ្នកមានកល្យាណធម៌ ក្នុងបុថុជ្ជន ២ ពួក ដែលលោកពោលថា

ព្រះសម្ពុទ្ធដែលមានផៅពង្សដូចព្រះអាទិត្យ ត្រាស់ដល់បុថុជ្ជន ២ ប្រភេទ គឺអន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។

អធិប្បាយថា បុថុជ្ជនដែលជាមនុស្សល្អ ។ ម្យ៉ាងទៀត ពួកមនុស្សល្អក្នុងពួកបុថុជ្ជន ឈ្មោះថា កល្យាណបុថុជ្ជន ។ **កុសល** សព្ទ ក្នុងបទនេះថា **កុសលធម្មេ យុត្តានំ** រមែងប្រាកដក្នុងការមិនមានរោគ ការមិនមានទោស

*ការឈ្លាស និងផលនៃសេចក្ដីសុខ ។* **កុសល** *សព្ទ ប្រាកដក្នុងអត្ថថា មិនមានរោគ ដូចក្នុងប្រយោគជាដើមថា* **កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ** *ព្រះអង្គមានសេចក្ដីសុខស្រួលទេឬ ព្រះអង្គមិនមានជំងឺតម្កាត់ទេឬ ដូច្នេះ ។*

*ប្រាកដក្នុងអត្ថថា មិនមានទោស ដូចក្នុងប្រយោគជាដើមថា* **កតមោ បន ភន្តេ កាយសមាចារោ កុសលោ យោ ខោ មហារាជ កាយ–សមាចារោ អនវជ្ជោ** *បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារជាកុសលតើដូចម្ដេច ។ បពិត្រមហារាជ កាយសមាចារមិនមានទោស ដូច្នេះ ។ និងដូចប្រយោគមួយទៀតថា* **បុន ចបរំ ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ កុសលេសុ ធម្មេសុ** *បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ក្នុងកុសលធម៌ទាំងឡាយដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ដូច្នេះ ។*

*ប្រាកដក្នុងអត្ថថា ឈ្លាស ដូចក្នុងប្រយោគជាដើមថា* **កុសលោ ត្វំ រថស្ស អង្គបច្ចង្គានំ** *ទ្រង់ជាបុគ្គលឈ្លាសក្នុងអវយវៈតូចធំទាំងឡាយនៃរថដែរឬទេ ដូច្នេះ ។ និងប្រយោគមួយទៀតថា* **កុសលា នច្ចគីតស្ស សិក្ខិតា ចាតុរិត្ថិយោ** *ស្ត្រីបួនជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង បានសិក្សា ( ក្នុងកិច្ចស្ត្រី ) ដូច្នេះ ។*

*ប្រាកដក្នុងអត្ថថា ផលនៃសេចក្ដីសុខ ដូចក្នុងប្រយោគជាដើមថា* **កុស–លានំ ធម្មានំ សមាទានហេតុ** *ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ*

យ៉ាងនេះ ដូច្នេះ ។ និងដូចប្រយោគមួយទៀតថា **កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា** ព្រោះហេតុបានធ្វើ បានសន្សំដូច្នេះ ។ **កុសល** សព្ទ ក្នុងទីនេះ សមគួរក្នុងការមិនមានរោគខ្លះ ក្នុងការមិនមានទោសខ្លះ ក្នុងផល នៃសេចក្តីសុខខ្លះ ។ ចំណែកការអធិប្បាយក្នុងពាក្យថា **កុសល** សព្ទ មាន ដូចតទៅនេះ ឈ្មោះថា កុសល ព្រោះអត្ថថា ទម្លាយ ធ្វើឲ្យញាប់ញ័រ ធ្វើឲ្យកម្រើក កម្ចាត់ធម៌ដ៏លាមកគួរខ្ពើម ។

ម្យ៉ាងវិញទៀត ឈ្មោះថា **កុស** ព្រោះអត្ថថា រមែងនៅ គឺរមែងប្រព្រឹត្ត ទៅដោយអាការគួរខ្ពើម ឈ្មោះថា **កុសល** ព្រោះអត្ថថា កម្ចាត់ គឺកាត់ផ្តាច់ អាការដែលគួរខ្ពើមទាំងនោះ ម្យ៉ាងវិញទៀត ឈ្មោះថា **កុស** ព្រោះធ្វើឲ្យ ស្រាលស្តើងដោយធ្វើឲ្យអស់នូវអាការគួរខ្ពើមទាំងឡាយ បានដល់ **ញាណ** ។ ឈ្មោះថា កុសល ព្រោះអត្ថថា គួរកម្ចាត់ គួរកាន់យក គួរឲ្យប្រព្រឹត្តទៅ ដោយកុសញ្ញាណនោះ ម្យ៉ាងវិញទៀត ស្បូវក្លាំង រមែងមុតដៃសូម្បីទាំងពីរ ខាង យ៉ាងណា សូម្បីកុសលធម៌ទាំងនេះ ក៏រមែងកាត់ចំណែកសៅហ្មង ដែលមានក្នុងចំណែកទាំងពីរ គឺដោយការកើតហើយ និងមិនទាន់កើតយ៉ាង នោះ ព្រោះហេតុនោះ ទើបឈ្មោះថា កុសល ព្រោះអត្ថថា រមែងកាត់ដូច ស្បូវក្លាំង ដូច្នោះ ។

ម្យ៉ាងវិញទៀតឈ្មោះថា **កុសល** ដោយអត្ថថា មិនមានរោគ ដោយអត្ថ ថា មិនមានទោស ឬដោយអត្ថថា កើត ព្រោះភាពជាអ្នកឈ្លាស ។ តែក្នុង ទីនេះ ព្រោះបំណងយកវិបស្សនាកុសលប៉ុណ្ណោះ ហេតុនោះ ដើម្បីលះបង់ធម៌

ដ៏សេស ហើយសម្តែងវិបស្សនាកុសលប៉ុណ្ណោះ គប្បីជ្រាបថា លោកធ្វើជាឯកវចនៈក្នុងបទថា **កុសលធម្មេ** ក្នុងកុសលធម៌ដូច្នេះ អធិប្បាយថា ប្រកបហើយក្នុងកុសលធម៌គឺវិបស្សនាព្រោះធ្វើជាប់តគ្នា និងព្រោះធ្វើដោយសេចក្តីគោរព ។

ក្នុងបទថា **សេក្ខបរិយន្តេ បរិបូរការីនំ** នេះ មានអត្ថដូចតទៅនេះ ឈ្មោះថា ព្រះសេក្ខៈ ព្រោះកើតក្នុងសិក្ខា ៣ ខ្លះ ព្រោះធម៌ទាំងនេះរបស់ព្រះសេក្ខៈ ៧ ពួកខ្លះ ព្រោះព្រះសេក្ខៈទាំងឡាយ រមែងសិក្សាដោយខ្លួនឯងខ្លះ ។ បានដល់ ធម៌ គឺសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផលនិងអរហត្តមគ្គ ។ ឈ្មោះថា **សេក្ខបរិយន្ត** ព្រោះអត្ថថា មានសេក្ខធម៌ក្នុងទីបំផុត គឺក្នុងអវសាន ឬមានសេក្ខធម៌ដែលជាទីបំផុត គឺមានកំណត់ ។ គប្បីភ្ជាប់សេចក្តីថា ក្នុងធម៌ដែលជាទីបំផុតរបស់ព្រះសេក្ខៈនោះ ។ ឈ្មោះថា **បរិបូរការិនោ** ព្រោះអត្ថថា កល្យាណបុថុជ្ជន រមែងធ្វើកុសលធម៌ឲ្យពេញដោយជុំវិញ គឺឲ្យបរិបូរណ៍ ឬឈ្មោះថា **បរិបូរការិនោ** ព្រោះអត្ថថា មានការធ្វើឲ្យពេញដោយជុំវិញ គឺធ្វើឲ្យបរិបូរណ៍ ។ របស់កល្យាណបុថុជ្ជនទាំងនោះ ដែលធ្វើឲ្យបរិបូរណ៍ ក្នុងបដិបទាធម៌ដែលជាទីបំផុតរបស់ព្រះសេក្ខៈ ដែលជាចំណែកខាងដើមនៃសោតាបត្តិមគ្គ ដោយការធ្វើវិបស្សនាឲ្យបរិបូរណ៍ ។

ក្នុងបទនេះថា **កាយេ ច ជីវិតេ ច អនបេក្ខានំ** មានសេចក្តីដូចតទៅ បទថា **កាយេ** បានដល់ ក្នុងសរីរៈ ពិតហើយ សរីរៈ ហៅថា កាយ

ព្រោះជាប្រភពកើតនៃកោដ្ឋាស មានសក់ជាដើម ដែលគួរខ្ពើម និងព្រោះជាទីមកនៃរោគច្រើនរយ មានរោគភ្នែកជាដើម ។

បទថា **ជីវិតេ** បានដល់ ជីវិតិន្ទ្រិយ ។ ជីវិតិន្ទ្រិយនោះ ហៅថា ជីវិត ព្រោះអត្ថថា ជាហេតុឲ្យរស់នៅ ។ ឈ្មោះថា **អនបេក្ខា** ព្រោះអត្ថថា កល្យាណបុថុជ្ជនទាំងនោះ មិនមានអាល័យ អធិប្បាយថា អស់នូវការជាប់ជំពាក់ ។ របស់កល្យាណបុថុជ្ជនទាំងនោះ ដែលមិនអាល័យក្នុងរាងកាយ និងក្នុងជីវិតនោះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលសម្តែងហេតុនៃភាពជាអ្នកមិនអាល័យក្នុងរាងកាយ និងជីវិតនៃកល្យាណបុថុជ្ជនទាំងនោះ ទើបពោលថា **បរិច្ចត្តជីវិ-តានំ** ។ ពិតហើយ កល្យាណបុថុជ្ជនទាំងនោះជាអ្នកមិនអាល័យក្នុងរាងកាយ សូម្បីលំបាកក្នុងជីវិត សូម្បីវិនាសដោយការលះបង់ជីវិត របស់ខ្លួនដល់ព្រះមានព្រះភាគ ឬដល់អាចារ្យ ។

បទថា **សត្តន្នំ សេក្ខានំ** បានដល់ របស់ព្រះអរិយបុគ្គល ៧ ពួក មានលោកដែលតាំងនៅក្នុងសោតាបត្តិមគ្គជាដើម ដែលបានឈ្មោះថា **សេក្ខ** ព្រោះត្រូវសិក្សា ។

បទថា **តថាគតសាវកានំ** បានដល់ សាវករបស់ព្រះតថាគត ។ ពិតហើយ ព្រះអរិយបុគ្គល ៨ ពួក ឈ្មោះថា សាវក ព្រោះអត្ថថា ស្តាប់ទេសនា ការទូន្មានរបស់ព្រះមានព្រះភាគដោយគោរព ដោយតាំងបសាទដែលមិនញាប់ញ័រ ព្រោះកើតក្នុងជាតិដែលជាអរិយៈក្នុងទីបំផុតនៃការស្តាប់ ។

ក្នុងព្រះអរិយបុគ្គលទាំងនោះ ព្រះសារីបុត្តកាលនឹងសម្ដែងឲ្យវិសេស ដល់អ្នកតាំងនៅក្នុងអរហត្តផលប៉ុណ្ណោះ ទើបពោលថា **ខីណាសវានំ** ដូច្នេះ អធិប្បាយថា របស់អ្នកមានអាសវៈទាំងពួងអស់ហើយ ដោយអរហត្ត-មគ្គញ្ញាណ ។

បទថា **បច្ចេកពុទ្ធានំ** មានវិគ្គហៈថា ឈ្មោះថា **បច្ចេកពុទ្ធ** ព្រោះអត្ថថា ជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ មិនមានអាចារ្យ អាស្រ័យហេតុនោះៗ ត្រាស់ដឹងអរិយសច្ច ៤ របស់ព្រះបច្ចេកពុទ្ធទាំងឡាយបែបនោះ ។

ក្នុងបទនេះថា **តថាគតានំ** មានសេចក្ដីដូចតទៅនេះ ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ដោយហេតុ ៨ ប្រការ គឺទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងមកហើយយ៉ាងនោះ ព្រោះអត្ថថា យាងទៅហើយយ៉ាងនោះ ព្រោះអត្ថថា ត្រាស់ដឹងលក្ខណៈដែលពិត ព្រោះអត្ថថា ត្រាស់ដឹងធម៌ដែលពិតតាមសេចក្ដីពិត ព្រោះទ្រង់ឃើញវត្ថុដែលពិត ព្រោះទ្រង់ត្រាស់តែសេចក្ដីពិត ព្រោះទ្រង់ធ្វើយ៉ាងនោះ ព្រោះអត្ថថា គ្របសង្កត់ ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងមកហើយយ៉ាងនោះ តើដូចម្ដេច ដូចព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គមុនៗ ដែលដល់នូវសេចក្ដីខ្វល់ខ្វាយ ដើម្បីប្រយោជន៍ដល់លោកទាំងមូល យាងមកហើយ ។ មានពាក្យអធិប្បាយដូចម្ដេច អធិប្បាយថា ព្រះមានព្រះភាគទាំងឡាយ អង្គមុនៗ យាងមកហើយ ដោយអភិនិហារណា សូម្បីព្រះមានព្រះភាគនៃយើងទាំងឡាយ ក៏យាងមកហើយ ដោយអភិនិហារនោះដូចគ្នា ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគអង្គមុនៗ ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ បានដល់ ទាន សីល នេក្ខម្មៈ បញ្ញា វីរិយៈ ខន្តិ សច្ចៈ អធិដ្ឋាន មេត្តា ឧបេក្ខា ទ្រង់បរិច្ចាគមហាបរិច្ចាគទាំង ៥ នេះ គឺបរិច្ចាគអវយវៈ ១ នេត្រ ១ ទ្រព្យ ១ រាជសម្បត្តិ ១ បុត្តភរិយា ១ ទ្រង់បំពេញញាតត្ថចរិយា ដោយទ្រង់ប្រាប់ធម៌ដែលគួរប្រកបក្នុងខាងដើម និងគួរប្រព្រឹត្តក្នុងខាងដើមជាដើម ហើយដល់ទីបំផុតនៃពុទ្ធចរិយា យាងមកហើយ ព្រះមានព្រះភាគនៃយើងទាំងឡាយ ក៏យាងមកហើយយ៉ាងនោះ ។ ម្យ៉ាងវិញទៀត ព្រះមានព្រះភាគអង្គមុនៗ ទ្រង់ចម្រើន ទ្រង់បរិបូរដោយសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ យាងមកហើយដោយប្រការណា សូម្បីព្រះមានព្រះភាគនៃយើងទាំងឡាយ ក៏យាងមកហើយដោយប្រការនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ។

ព្រះមុនីទាំងឡាយ មានព្រះទីបង្ករសម្ពុទ្ធជាដើម ដល់នូវភាព
ជាព្រះសព្វញ្ញូ យាងមកហើយក្នុងលោកនេះ ដោយប្រការណា
សូម្បីព្រះសក្យមុនី អ្នកមានចក្ខុនេះ ក៏យាងមកហើយ ដោយ
ប្រការនោះ ដោយហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា
តថាគត ។

ព្រះមានព្រះភាគព្រះនាមថា តថាគត ព្រោះអត្ថថា ទ្រង់យាងទៅហើយយ៉ាងនោះ តើដូចម្ដេច ព្រះមានព្រះភាគអង្គមុនៗ ដែលប្រសូតហើយភ្លាម ទ្រង់

យាងទៅដោយប្រការណា ព្រះមានព្រះភាគ ក៏យាងទៅដោយប្រការនោះ ។ ព្រះមានព្រះភាគទាំងឡាយនោះយាងទៅហើយ ដូចម្តេច ដ្បិតថា ព្រះមានព្រះភាគទាំងឡាយនោះ ប្រសូតហើយភ្លាម ប្រតិស្ឋានព្រះបាទទាំងពីរ លើផែនដី បែរព្រះភក្ត្រទៅទិសឧត្តរ យាងទៅដោយព្រះបាទ ៧ ជំហាន សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋានលើផែនដីដោយព្រះបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសខាងជើង ទ្រង់ស្តេចដោយព្រះបាទបាន ៧ ជំហាន កាលគេកំពុងបាំងស្វេតច្ឆត្រថ្វាយ ទ្រង់ក្រឡេកមើលគ្រប់ទិសទាំងអស់ ទើបបញ្ចេញអាសភិវាចាថា អាត្មាអញជាកំពូលរបស់លោក អាត្មាអញជាបុគ្គលចម្បងជាងលោក អាត្មាអញជាបុគ្គលប្រសើរជាងសត្វលោក ជាតិនេះជាជាតិទីបំផុត ឥឡូវនេះ មិនមានភពថ្មីទៀតឡើយ ដូច្នេះ ។

ការយាងទៅរបស់ព្រះពោធិសត្វនោះ បានឈ្មោះថា ជាសេចក្តីដ៏ពិតប្រាកដដែលជាបុព្វនិមិត្តនៃការត្រាស់ដឹងធម៌ដ៏វិសេសជាអនេក ។ ប្រការដែលព្រះពោធិសត្វនោះប្រសូតភ្លាម ប្រតិស្ឋានព្រះបាទទាំងគូ នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ របស់ព្រះពោធិសត្វនោះ ការបែរព្រះភក្ត្រទៅកាន់ទិសឧត្តរជាបុព្វនិមិត្តនៃការបាននូវលោកុត្តរទាំងអស់ របស់ព្រះពោធិសត្វនោះ ការឈានព្រះបាទ ៧ ជំហាន ជាបុព្វនិមិត្តនៃការបានពោជ្ឈង្គរតនៈ ៧ ការលើកចាមរឡើង ដូចពោល ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) នេះថា ចាមរទាំងឡាយមានដងជាវិការនៃមាស សំយុងចុះ ដូច្នេះ ជាបុព្វនិមិត្តនៃការញាំញីតិរ្ថិយ

ទាំងអស់ ។ ការបាំងស្វេតច្ឆត្រ ជាបុព្វនិមិត្តនៃការបានស្វេតច្ឆត្រដ៏ប្រសើរប្រាសចាកមន្ទិលដោយការផុត ដោយអរហត្តមគ្គ ការក្រឡេកមើលទិសទាំងពួង ជាបុព្វនិមិត្តនៃការបានអនាវរណញ្ញាណ គឺភាពជាព្រះសព្វញ្ញូ ការបន្លឺនូវវាចាដ៏អង់អាច ជាបុព្វនិមិត្តនៃការប្រព្រឹត្តទៅនៃធម្មចក្រដ៏ប្រសើរដែលបុគ្គលណាមួយជំទាស់មិនបាន ។ ព្រះមានព្រះភាគអង្គនេះ ក៏យាងទៅយ៉ាងនោះ ។ម្យ៉ាងទៀត ការយាងរបស់ព្រះពោធិសត្វនោះ បានជាសេចក្តីពិតដោយភាពជាបុព្វនិមិត្តនៃការសម្រេចធម្មវិសេសទាំងនោះឯង ។ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

ព្រះគោតមពោធិសត្វ ប្រសូតភ្លាម ទ្រង់ក៏ប៉ះផែនដីដោយព្រះបាទទាំងគូ ទ្រង់ឈាន ៧ ជំហាន ដូចគោមេហ្វូងកើតភ្លាមក៏ដើរបាន ឯពួកទេវតាក៏នាំគ្នាបាំងស្វេតច្ឆត្រ ។ ព្រះគោតមនោះកាលយាងទៅ ៧ ជំហាន ទ្រង់ក្រឡេកមើលទិស ដោយស្មើជុំវិញ ទ្រង់បន្លឺវាចាប្រកបដោយអង្គ ៨ ដូចសីហៈឈរនៅលើកំពូលភ្នំ បន្លឺសីហនាទ ដូច្នោះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងទៅហើយយ៉ាងនោះដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគអង្គមុនៗ យ៉ាងណា សូម្បីព្រះមានព្រះភាគអង្គនេះក៏យ៉ាងនោះដូចគ្នា ទ្រង់លះកាមច្ឆន្ទៈដោយនេក្ខម្មៈ ។បេ។ លះនីវរណៈដោយបឋមជ្ឈាន ។បេ។ លះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ។បេ។ លះ

កិលេសទាំងអស់ដោយអរហត្តមគ្គ ហើយយាងទៅ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងទៅហើយយ៉ាងនោះ ដោយប្រការដូច្នេះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ត្រាស់ដឹងលក្ខណៈដែលពិត តើដូចម្ដេច លក្ខណៈដែលពិត គឺបឋវីធាតុ មានការរឹងជាលក្ខណៈ អាបោធាតុមានការហូរជាលក្ខណៈ តេជោធាតុមានការក្ដៅជាលក្ខណៈ វាយោធាតុមានការបក់ទៅមកជាលក្ខណៈ អាកាសធាតុមានការប៉ះមិនបានជាលក្ខណៈ វិញ្ញាណធាតុ មានការដឹងច្បាស់ជាលក្ខណៈ ។

រូប មានការបែកធ្លាយជាលក្ខណៈ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ សញ្ញាមានការចាំជាលក្ខណៈ សង្ខារមានការតាក់តែងជាលក្ខណៈ វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ ។

វិតក្ក មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ វិចារ មានការឈ្លេចឈ្លីអារម្មណ៍ជាលក្ខណៈ បីតិមានការផ្សាយទៅជាលក្ខណៈ សុខមានការត្រេកអរជាលក្ខណៈ ឯកគ្គតាមានការមិនរាយមាយជាលក្ខណៈ ផស្សៈមានការពាល់ត្រូវជាលក្ខណៈ ។

សទ្ធិន្ទ្រិយមានការបង្អោនចិត្តជឿជាលក្ខណៈ វីរិយិន្ទ្រិយមានការផ្គងជាលក្ខណៈ សតិន្ទ្រិយមានការតាំងមាំជាលក្ខណៈ សមាធិន្ទ្រិយមានការមិនរាយមាយជាលក្ខណៈ បញ្ញិន្ទ្រិយមានការដឹងទូទៅជាលក្ខណៈ ។

សទ្ធាពល មានការមិនញាប់ញ័រក្នុងការមិនជឿជាលក្ខណៈ វីរិយពល មានការមិនញាប់ញ័រក្នុងការខ្ជិលច្រអូសជាលក្ខណៈ សតិពល មានការមិន

ញាប់ញ័រក្នុងការវង្វេងជាលក្ខណៈ សមាធិពលមានការមិនញាប់ញ័រក្នុងការរាយមាយជាលក្ខណៈ បញ្ញាពលមានការមិនញាប់ញ័រក្នុងអវិជ្ជាជាលក្ខណៈ ។

សតិសម្ពោជ្ឈង្គ មានការតាំងមាំជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គ មានការពិចារណាជាលក្ខណៈ វីរិយសម្ពោជ្ឈង្គ មានការផ្គងជាលក្ខណៈ បីតិ-សម្ពោជ្ឈង្គ មានការផ្សាយទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាលក្ខណៈ សមាធិសម្ពោជ្ឈង្គ មានការមិនរាយមាយជាលក្ខណៈ ឧបេក្ខា-សម្ពោជ្ឈង្គ មានការពិចារណាជាលក្ខណៈ ។

សម្មាទិដ្ឋិមានការឃើញជាលក្ខណៈ សម្មាសង្កប្បមានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ សម្មាវាចាមានការកំណត់ជាលក្ខណៈ សម្មាកម្មន្តៈមានការតាំងឡើងជាលក្ខណៈ សម្មាអាជីវៈមានការផូរផង់ជាលក្ខណៈ សម្មា-វាយាមៈ មានការផ្គងជាលក្ខណៈ សម្មាសតិ មានការចូលទៅតាំងមាំជាលក្ខណៈ សម្មាសមាធិ មានការមិនរាយមាយជាលក្ខណៈ ។

អវិជ្ជា មានការមិនដឹងជាលក្ខណៈ សង្ខារមានការគិត ( ចេតនា ) ជាលក្ខណៈ វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ នាមមានការបង្អោនទៅជាលក្ខណៈ រូបមានការបែកធ្លាយជាលក្ខណៈ សឡាយតនៈមានការជាប់តគ្នាជាលក្ខណៈ ផស្សៈមានការពាល់ត្រូវជាលក្ខណៈ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ តណ្ហាមានភាពជាហេតុជាលក្ខណៈ ឧបាទានមានការប្រកាន់មាំជាលក្ខណៈ ភពមានការប្រមូលមក ( អាយូហនៈ ) ជាលក្ខណៈ ជាតិមានការកើតជាលក្ខណៈ ជរាមានការគ្រាំគ្រាជាលក្ខណៈ ការស្លាប់មាន

ការឃ្លាតទៅជាលក្ខណៈ ។

ធាតុមានភាពជារបស់សូន្យជាលក្ខណៈ អាយតនៈមានការជាប់តគ្នាជាលក្ខណៈ សតិប្បដ្ឋានមានការតាំងមាំជាលក្ខណៈ សម្មប្បធានមានការផ្តើមប្រារព្ធជាលក្ខណៈ ឥទ្ធិបាទមានការសម្រេចជាលក្ខណៈ ឥន្ទ្រិយមានភាពជាធំជាលក្ខណៈ ពលមានភាពមិនញាប់ញ័រជាលក្ខណៈ ពោជ្ឈង្គមានការនាំចេញជាលក្ខណៈ មគ្គមានភាពជាហេតុជាលក្ខណៈ ។

សច្ចៈមានការពិតជាលក្ខណៈ សមថៈមានភាពមិនរាយមាយជាលក្ខណៈ វិបស្សនាមានការតាមពិចារណាឃើញជាលក្ខណៈ សមថៈ និងវិបស្សនាមានភាពជារសតែមួយជាលក្ខណៈ យុគលធម៌មានការមិនឈានកន្លងនូវគ្នានិងគ្នាជាលក្ខណៈ ។

សីលវិសុទ្ធិមានសំវរៈជាលក្ខណៈ ចិត្តវិសុទ្ធិមានការមិនរាយមាយជាលក្ខណៈ ទិដ្ឋិវិសុទ្ធិមានការឃើញជាលក្ខណៈ ។ ខយញ្ញាណមានការផ្តាច់ផ្តិលជាលក្ខណៈ អនុប្បាទញ្ញាណមានការស្ងប់ជាលក្ខណៈ ។

ឆន្ទៈមានភាពជាឫសគល់ជាលក្ខណៈ មនសិការមានសមុដ្ឋានជាលក្ខណៈ ផស្សៈមានការប្រជុំគ្នាជាលក្ខណៈ វេទនាមានការប្រជុំចុះជាលក្ខណៈ សមាធិមានភាពជាប្រធានជាលក្ខណៈ សតិមានភាពជាធំជាលក្ខណៈ បញ្ញាមានការដឹងក្រៃលែងជាងនោះជាលក្ខណៈ វិមុត្តិមានភាពជាខ្លឹមជាលក្ខណៈ អមតនិព្វានមានចុងបំផុតជាលក្ខណៈ ទាំងអស់នេះ គឺសេចក្តីពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ត្រាស់ដឹងលក្ខណៈដែលពិតនោះដោយ

ញាណគតិ គឺទ្រង់ដល់ សម្រេចដល់ មិនក្លាំងក្លាត់ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា សម្រេចលក្ខណៈដែលពិត ដោយប្រការដូច្នេះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ត្រាស់ដឹងធម៌ដែលពិតតាមសេចក្តីពិត តើដូចម្តេច អរិយសច្ច ៤ ឈ្មោះថា ធម៌ដែលពិត ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះ ជារបស់ពិតមិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ធម្មជាត ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ដូច្នេះ ។ បណ្ឌិតគប្បីឲ្យពិស្តារ ។ម្យ៉ាងវិញទៀត ព្រោះព្រះមានព្រះភាគ ត្រាស់ដឹងអរិយសច្ចទាំងនោះ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត ។ **គត** សព្ទ ក្នុងទីនេះ មានន័យថា ត្រាស់ដឹង ។

ម្យ៉ាងវិញទៀត ជរា និងមរណៈកើតឡើង ប្រាកដឡើងព្រោះជាតិជាបច្ច័យ ជាអត្ថ ជាសេចក្តីពិតប្រាកដ មិនជាយ៉ាងដទៃ ។បេ។ សង្ខារទាំងឡាយកើតឡើង ប្រាកដឡើង អវិជ្ជាជាបច្ច័យ ជាអត្ថ ជាសេចក្តីពិតប្រាកដ មិនជាយ៉ាងដទៃ ។ ពិតហើយ អវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ជាអត្ថ ជាសេចក្តីពិតប្រាកដ មិនជាយ៉ាងដទៃ ។បេ។ ជាតិជាបច្ច័យដល់ជរា និងមរណៈ ជាអត្ថ ជាសេចក្តីពិតប្រាកដ មិនជាយ៉ាងដទៃ ។ ព្រះមានព្រះភាគត្រាស់ដឹងធម៌ទាំងពួងនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ត្រាស់ដឹងធម៌ដែលពិត

តាមសេចក្តីពិត ដោយប្រការដូច្នេះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ឃើញវត្ថុដែលពិត តើដូចម្តេច ព្រះមានព្រះភាគទ្រង់ឃើញរូបារម្មណ៍ ដែលមកកាន់គន្លងចក្ខុក្នុងចក្ខុទ្វាររបស់សត្វទាំងឡាយប្រមាណមិនបាន ក្នុងលោកធាតុដែលប្រមាណមិនបាន ក្នុងលោកព្រមទាំងទេវលោក ។បេ។ ប្រព្រឹត្តទៅជាមួយនឹងទេវតា និងមនុស្សដែលមានដោយប្រការទាំងពួង ។ ម្យ៉ាងវិញទៀត រូបារម្មណ៍នោះដែលព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ឃើញ ទ្រង់ចែកដោយន័យ ៥២ ដោយវារៈ ១៣ ដោយឈ្មោះច្រើនយ៉ាង ដោយន័យ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ថា រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតរូបទាំង ៤ ជាវត្ថុដែលអាចឃើញបានប្រកបដោយការប៉ះពាល់ ជាពណ៌ខៀវ លឿង ដូច្នេះជាដើម ដោយអំណាចនៃអារម្មណ៍ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាជាដើម ឬដោយអំណាចនៃបទតាមតែរកបានក្នុងអារម្មណ៍ដែលឃើញ ដែលបានឮ ដែលបានដឹងច្បាស់ ជាសេចក្តីពិត មិនក្លាំងក្លាត់ ។ ក្នុងសំឡេងជាដើមដែលមកកាន់គន្លងក្នុងសោតទ្វារជាដើម ក៏ន័យនេះ ។ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក ។បេ។ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះមិនស្ថិតនៅក្នុងតថាគតទេ ដូច្នេះ ។ ទ្រង់ព្រះនាម

ថា តថាគត ព្រោះទ្រង់ឃើញវត្ថុដែលពិត ដោយប្រការដូច្នេះ ។ ក្នុងពាក្យនោះ គប្បីជ្រាបការកើតនៃបទថា តថាគត ក្នុងអត្ថថា ឃើញវត្ថុដែលពិតនោះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ត្រាស់តែសេចក្តីពិត តើដូចម្តេច ប្រការដែលព្រះមានព្រះភាគ គង់លើអបរាជិតបល្ល័ង្កត្រង់ពោធិមណ្ឌល ក្នុងវេលារាត្រី ទ្រង់ញាំញីអំបែងក្បាលមារទាំង ៤ ហើយត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏កំពូល និងប្រការដែលព្រះសាស្តាស្តេចបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងវេលារាត្រី និងប្រការដែលព្រះមានព្រះភាគត្រាស់សុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ ក្នុងបឋមពោធិកាលខ្លះ ក្នុងមជ្ឈិមពោធិកាលខ្លះ ក្នុងបច្ឆិមពោធិកាលខ្លះ ក្នុងវេលាប្រមាណ ៤៥ ឆ្នាំ ក្នុងរវាងនេះទាំងអស់នោះ ទាំងដោយអត្ថ ទាំងដោយព្យញ្ជនៈ មិនមានទោស មិនគួរតិះដៀល មិនខ្វះមិនលើស បរិបូរណ៍ដោយអាការទាំងពួង ញាំញីនូវសេចក្តីស្រវឹង រាគៈ ទោសៈ មោហៈ មិនមានការក្លាំងក្លាត់ សូម្បីត្រឹមតែប៉ុនចុងរោមសត្វ ក្នុងពាក្យទូន្មានទាំងនោះ ទាំងអស់នោះជាសេចក្តីពិត ដូចប្រថាប់ដោយត្រាមួយ ដូចវាល់ដោយនាឡិមួយ និងដូចថ្លឹងដោយជញ្ជីងមួយ ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសម្តែង ហៅ ចង្អុលបង្ហាញនូវហេតុណាក្នុងចន្លោះនុ៎ះ ហេតុទាំងអស់នោះសុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយ បានជាគេហៅថា ព្រះ

តថាគត ដូច្នេះ ។ **គត** សព្ទក្នុងទីនេះ មានអត្ថថា ពោល ។ ទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់តែសេចក្តីពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត វាចា ឈ្មោះថា **អាគទ** អធិប្បាយថា ការពោល ។ ពាក្យពោលរបស់ព្រះតថាគត ជាសេចក្តីពិត មិនប្រែប្រួល ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** ផ្លាស់ **ទ** អក្ខរៈជា **ត** អក្ខរៈ ហេតុនោះ គប្បីជ្រាបពាក្យសម្រេចក្នុងអត្ថនេះ ដោយប្រការដូច្នេះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើយ៉ាងនោះ តើដូចម្តេច ពិតហើយ កាយរបស់ព្រះមានព្រះភាគ រមែងអនុលោមតាមវាចា វាចារមែងអនុលោមតាមកាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ជាបុគ្គលពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ។ អធិប្បាយថា វាចារបស់ព្រះមានព្រះភាគយ៉ាងនេះយ៉ាងណា សូម្បីកាយក៏ទៅគឺប្រព្រឹត្តទៅយ៉ាងនោះ ។ ម្យ៉ាងទៀត ទ្រង់ព្រះនាមថា តថាគត ព្រោះកាយយ៉ាងណា វាចាក៏ទៅ គឺប្រព្រឹត្តទៅយ៉ាងនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគត ថាយ៉ាងណាធ្វើយ៉ាងនោះ ធ្វើយ៉ាងណាថាយ៉ាងនោះ ថាយ៉ាងណាធ្វើយ៉ាងនោះ ធ្វើយ៉ាងណាថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា តថាគត ដូច្នេះ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើយ៉ាងនោះ ដោយប្រការដូច្នេះ ។

ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា គ្របសង្កត់ តើដូចម្តេច ព្រះតថាគតទ្រង់គ្របសង្កត់សព្វសត្វ ក្នុងលោកធាតុដែលប្រមាណមិនបាន ក្នុង

ទទឹង ខាងលើ មានភវគ្គព្រហ្មជាទីបំផុត ខាងក្រោម ដល់អវិចី ដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ ។ ព្រះតថាគតនោះ ថ្លឹងមិនបាន ប្រមាណមិនកើត ព្រះតថាគតមិនមានបុគ្គលប្រៀប មិនមានបុគ្គលផ្ទឹម ទ្រង់ ជាអគ្គបុគ្គល ជារាជាក្រៃលែងជាងរាជា ជាទេវតាក្រៃលែងជាងទេវតា ជា សក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម ដោយហេតុនោះ ទើប ព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុ ទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាច គ្របសង្កត់លោក ព្រមទាំងទេវលោក ។បេ។ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា តថាគត ដូច្នេះ ។

ក្នុងបទនោះ គប្បីជ្រាបបទដែលសម្រេចដូចតទៅនេះ ព្រះតថាគត ទ្រង់ ព្រះនាមថា **អគទោ** គឺដូចជាថ្នាំដ៏វិសេស ។ នោះគឺអ្វី គឺទេសនាវិលាស និង ការចម្រើនបុណ្យ ។ ពិតហើយ ព្រះតថាគតនោះ ទ្រង់មានអានុភាពច្រើន ទ្រង់គ្របសង្កត់លទ្ធិរបស់អ្នកដទៃទាំងអស់ ក្នុងលោក ព្រមទាំងទេវលោកបាន ដូចគ្រូពស់បង្ក្រាបពស់បានដោយថ្នាំពិសេសដូច្នោះ ។ ដោយហេតុនេះ ព្រះ តថាគត មានថ្នាំពិសេសដែលសម្រេចដោយទេសនាវិលាស និងសម្រេចដោយ បុណ្យដែលជាសេចក្ដីពិត មិនវិបរិតក្នុងការគ្របសង្កត់លោកទាំងពួង ព្រោះ ហេតុនោះ គប្បីជ្រាបថា ទ្រង់ព្រះនាមថា តថាគត ព្រោះផ្លាស់ **ទ** អក្ខរៈ ជា **ត** អក្ខរៈ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា គ្របសង្កត់ ដោយ ប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ទ្រង់យាងទៅហើយដោយសេចក្ដីពិតខ្ទះ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ទ្រង់យាងទៅកាន់សេចក្ដីពិតខ្ទះ ។ បទថា **គតោ** បានដល់ ឈានចុះហើយ កន្លងទៅហើយ សម្រេចហើយ យាងទៅហើយ ។

ក្នុងបទទាំងឡាយនោះ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងទៅ គឺឈានចុះកាន់លោកទាំងអស់ ដោយសេចក្ដីពិត គឺតីរណប្បរិញ្ញា ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងទៅ គឺកន្លងទៅហើយនូវហេតុឲ្យកើតលោកដោយសេចក្ដីពិត គឺបហានប្បរិញ្ញា ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងទៅ គឺសម្រេចការរម្ងត់លោកដោយសេចក្ដីពិត គឺសច្ឆិកិរិយា ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា យាងទៅ គឺទៅហើយកាន់សេចក្ដីពិត គឺលោកនិរោធគាមិនីបដិបទា ។ ដោយហេតុនោះ ពាក្យណាដែលព្រះមានព្រះភាគត្រាស់ហើយ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ លោក ( គឺទុក្ខសច្ច ) តថាគតបានត្រាស់ដឹងហើយ តថាគតផុតចាកលោក ( គឺទុក្ខសច្ច ) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធ តថាគតបានត្រាស់ដឹងហើយ លោកនិរោធ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំង

ទេវលោក ។បេ។ តថាគតបានដឹងជាក់ស្តែងហើយដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា តថាគត ដូច្នេះ ។ គប្បីជ្រាបអត្ថរបស់ពាក្យថា តថាគតនោះ ដោយប្រការដូច្នេះ ។ ពាក្យនេះ ក៏ត្រឹមតែជាគន្លងក្នុងការសម្តែងភាពជាតថាគតរបស់ព្រះតថាគតប៉ុណ្ណោះ ។ ព្រះតថាគតប៉ុណ្ណោះគប្បីពណ៌នាភាពជាតថាគតរបស់ព្រះតថាគត ( ផងគ្នា ) បាន ដោយប្រការទាំងពួង ។ ក៏ព្រោះព្រះពុទ្ធទាំងពួង ជាអ្នកមានគុណប៉ុនគ្នា ស្មើគ្នាដោយគុណរបស់ព្រះតថាគត ហេតុនោះ ទើបព្រះសារីបុត្តពោលថា **តថាគតាធំ** ដោយអំណាចនៃព្រះពុទ្ធទាំងអស់ ។

បទថា **អរហាធ្ណាធំ** សេចក្តីថា ព្រះតថាគតជាព្រះអរហន្ត ព្រោះទ្រង់ឆ្ងាយចាកកិលេសទាំងឡាយ ព្រោះកម្ចាត់សត្រូវ និងកាច់បំបាក់នូវកាំនៃចក្រទាំងឡាយ ព្រោះជាអ្នកគួរដល់នូវបច្ច័យជាដើម ព្រោះមិនមានការធ្វើបាបក្នុងទីស្ងាត់ ។ ពិតហើយ ព្រះតថាគតនោះ ជាអ្នកឆ្ងាយ គឺតាំងនៅឆ្ងាយសែនឆ្ងាយ អំពីកិលេសទាំងពួង ព្រោះទ្រង់លះកិលេស មួយអន្លើដោយវាសនាដោយមគ្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហន្ត ។

ព្រះតថាគតទ្រង់ជានាថៈនោះ ឈ្មោះថា ទ្រង់ឆ្ងាយចាកកិលេស
ព្រោះមិនប្រកបដោយកិលេស និងមិនប្រកបដោយទោស ទាំង
ឡាយ ដោយហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា អរហន្ត ។

ម្យ៉ាងវិញទៀត ព្រះតថាគតទ្រង់កម្ចាត់សត្រូវ គឺកិលេសទាំងនោះ ដោយមគ្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហន្ត ព្រោះទ្រង់កម្ចាត់សត្រូវ គឺ

កិលេសទាំងឡាយក៏មាន ។

ព្រោះព្រះនាថៈ ទ្រង់កម្ចាត់សត្រូវ គឺរាគៈជាដើម សូម្បីទាំងអស់ដោយសស្ត្រា គឺបញ្ញា ហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា អរហន្ត ។

ម្យ៉ាងវិញទៀត សង្សារចក្ក មានដុំសម្រេចដោយអវិជ្ជា និងភវតណ្ហា មានគ្រឿងតាក់តែង គឺបុណ្យជាដើមជាកាំ មានជរា និងមរណៈជាខ្នងកង់ មានក្ងៅសម្រេចមកអំពីហេតុ គឺអាសវៈ ប្រកបជាមួយនឹងតួរថ គឺភព ៣ ប្រព្រឹត្តទៅដោយកាលដែលមិនមានខាងដើម ព្រះតថាគត ប្រថាប់ឈរលើផែនដី គឺសីល ដោយព្រះបាទ គឺវិរិយៈ ត្រង់ពោធិមណ្ឌល ទ្រង់កាន់ប៉ូវថៅ គឺព្រះញាណ ដែលធ្វើកម្មឲ្យអស់ទៅដោយព្រះហស្ត គឺសទ្ធា ហើយទ្រង់កម្ចាត់កាំទាំងអស់ នៃសង្សារចក្កនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហន្ត ព្រោះកម្ចាត់នូវកាំទាំងឡាយ ។

ព្រោះព្រះលោកនាថ ទ្រង់កម្ចាត់នូវកង់នៃសង្សារចក្កដោយដាវ គឺព្រះញាណ ព្រោះហេតុនោះ ទើបព្រះលោកនាថនោះ បណ្ឌិតថ្វាយព្រះនាមថា អរហន្ត ។

ម្យ៉ាងវិញទៀត ព្រះតថាគតគួរទទួលនូវបច្ច័យ មានចីវរជាដើម និងការបូជាដ៏ពិសេស ព្រោះទ្រង់ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ដោយហេតុនោះឯង កាលព្រះតថាគតកើតឡើងហើយ ទេវតា និងមនុស្សដែលមានសក្តិធំ គ្រប់ពួកមិនធ្វើការបូជាក្នុងទីដទៃឡើយ ។ សេចក្តីពិតយ៉ាងនោះ សហម្បតីព្រហ្មបូជាព្រះ

តថាគតដោយកម្រងរតនៈ ប្រមាណប៉ុនភ្នំសិនេរុ ទេវតាពួកដទៃ និងមនុស្ស ទាំងឡាយ មានព្រះបាទពិម្ពិសារ និងព្រះបាទកោសលជាដើម បូជាហើយតាមកម្លាំង ។ ម្យ៉ាងវិញទៀត ព្រះបាទអសោកមហារាជលះបង់រាជទ្រព្យ ៩៦ កោដិ ហើយសាងវិហារ ៨៤០០០ ក្នុងជម្ពូទ្វីបទាំងអស់ ឧទ្ទិសចំពោះព្រះមានព្រះភាគសូម្បីស្តេចបរិនិព្វានហើយ នឹងចាំបាច់ពោលថ្វីដល់ការបូជាវិសេស យ៉ាងដទៃ ព្រោះហេតុនោះ ទើបព្រះតថាគត ទ្រង់ព្រះនាមថា អរហន្ត ព្រោះសមគួរដល់បច្ច័យជាដើម ។

ព្រះលោកនាថនេះ សមគួរទទួលការបូជាដ៏វិសេស មួយអន្លើ
ដោយបច្ច័យទាំងឡាយ ហេតុនោះ ទើបព្រះជិនស្រីសមគួរ
ទ្រទ្រង់នូវព្រះនាមថា អរហន្ត ដែលសមគួរដល់អត្ថក្នុងលោក ។

ម្យ៉ាងទៀត ព្រះតថាគតនោះ មិនថា ក្នុងកាលណាមួយឡើយ ទ្រង់រមែងមិនធ្វើដូចបុគ្គលពាលទាំងឡាយក្នុងលោកពួកណាមួយ ដែលសម្គាល់ខ្លួនថាជាបណ្ឌិត ធ្វើបាបក្នុងទីស្ងាត់ដោយខ្លាចថា មិនបានទទួលការសរសើរ ព្រោះហេតុនោះ ទើបព្រះតថាគតទ្រង់ព្រះនាមថា អរហន្ត ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ។ ឈ្មោះថា ទីស្ងាត់ក្នុងការធ្វើបាប រមែងមិនមានដល់ព្រះតថាគត ដែលជាតាទិបុគ្គល ព្រោះហេតុនោះ ទើបព្រះតថាគតនោះ ប្រាកដព្រះនាមថា អរហន្ត ព្រោះមិនមានទីស្ងាត់ ។

លោកពោលសរុបសេចក្តីទាំងអស់យ៉ាងនេះថា ព្រះមុនីនោះ ព្រោះទ្រង់ជាអ្នកឆ្ងាយចាកកិលេស ១ ព្រោះទ្រង់កម្ចាត់សត្រូវ គឺកិលេស ១ ព្រោះកាច់

បំបាក់នូវកាំ គឺសង្សារចក្រ ១ ព្រោះទ្រង់សមគួរដល់បច្ច័យជាដើម ១ ព្រោះទ្រង់មិនធ្វើបាបក្នុងទីស្ងាត់ ១ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា អរហន្ត ។

ព្រោះព្រះពុទ្ធទាំងពួងជាអ្នកមានគុណប៉ុនគ្នា ស្មើគ្នាដោយគុណនៃភាពជាព្រះអរហន្ត ហេតុនោះ ទើបព្រះសារីបុត្តពោលថា **អរហន្តានំ** ដោយអំណាចនៃព្រះពុទ្ធទាំងអស់ ។

បទថា **សម្មាសម្ពុទ្ធានំ** សេចក្តីថា ឈ្មោះថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។ ពិតហើយ ព្រះតថាគតត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ ដោយព្រះអង្គឯង គឺត្រាស់ដឹងធម៌ដែលគួរដឹងក្រៃលែងដោយភាពជាធម៌ ដែលគួរដឹងក្រៃលែង ត្រាស់ដឹងធម៌ដែលគួរកំណត់ដឹង ដោយភាពជាធម៌ដែលគួរកំណត់ដឹង ត្រាស់ដឹងធម៌ដែលគួរលះដោយភាពជាធម៌ដែលគួរលះ ត្រាស់ដឹងធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយភាពជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងធម៌ដែលគួរចម្រើន ដោយភាពជាធម៌ដែលគួរចម្រើន ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា

> ធម្មជាតដែលគួរដឹងច្បាស់ តថាគតបានដឹងច្បាស់ហើយ ធម្មជាតដែលគួរចម្រើន តថាគតបានចម្រើនហើយ ធម្មជាតដែលគួលះបង់ តថាគតក៏បានលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគត ឈ្មោះថា ព្រះពុទ្ធ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះតថាគត ត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ដោយការលើកបទនីមួយៗ មកពោលយ៉ាងនេះថា ចក្ខុ ជាទុក្ខសច្ច បុរិមតណ្ហា ( តណ្ហាដែលសម្រេចមកអំពីភពមុន ) ដែលជាហេតុតាំងឡើងនៃចក្ខុនោះ ដោយភាពជាឫសគល់ និងជាហេតុ ជាសមុទយសច្ច ភាពដែលចក្ខុ និងបុរិមតណ្ហាទាំងពីរប្រព្រឹត្តទៅមិនបាន ជានិរោធសច្ច បដិបទាដែលដឹងទូទៅដល់ការរលត់ជាមគ្គសច្ច ។ ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ និងចិត្តក៏មានន័យនេះ ។ ដោយន័យនេះឯង គប្បីប្រកបអាយតនៈ ៦ មានរូបជាដើម គំនរវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម ផស្សៈ ៦ មានចក្ខុសម្ផស្សជាដើម វេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម សញ្ញា ៦ មានរូបសញ្ញាជាដើម ចេតនា ៦ មានរូបសញ្ចេតនាជាដើម គំនរតណ្ហា ៦ មានរូបតណ្ហាជាដើម វិតក្ក ៦ មានរូបវិតក្កជាដើម វិចារ ៦ មានរូបវិចារជាដើម ខន្ធ ៥ មានរូបក្ខន្ធជាដើម កសិណ ១០ អនុស្សតិ ១០ សញ្ញា ១០ គឺឧទ្ធុមាតកសញ្ញាជាដើម អាការ ៣២ មានសក់ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩ មានកាមភពជាដើម ឈាន ៤ មានបឋមជ្ឈានជាដើម អប្បមញ្ញា ៤ មានមេត្តាភាវនាជាដើម អរូបសមាបត្តិ ៤ និងអង្គបដិច្ចសមុប្បាទ មានជរាមរណៈៈជាដើម ដោយបដិលោម មានអវិជ្ជាជាដើម ដោយអនុលោម ។

ក្នុងសេចក្ដីនោះ មានវាចាប្រកបសេចក្ដីនៃពាក្យនីមួយៗ ដូចតទៅនេះថា ព្រះតថាគតត្រាស់ដឹង ត្រាស់ដឹងតាម ចាក់ធ្លុះនូវធម៌ទាំងពួង ដោយប្រពៃ ដោយព្រះអង្គឯង ដោយការលើកបទនីមួយៗ មកពោលយ៉ាងនេះថា ជរា

មរណៈ ជាទុក្ខសច្ច ជាតិ ជាសមុទយសច្ច ការរលាស់ចេញទៅនូវធម៌ទាំងពីរ គឺជរាមរណៈ និងជាតិ ជានិរោធសច្ច បដិបទាដែលដឹងទូទៅដល់ការរម្ងត់ ជាមគ្គសច្ច ។ ព្រះតថាគតទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងវត្ថុដែលគួរទូន្មានឯណានីមួយ ដែលមានទាំងពួងដោយប្រពៃ ដោយព្រះអង្គឯងដោយវិមោក្ខន្តិកញ្ញាណ ។ ឯការចែកវិមោក្ខន្តិកញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធនោះ នឹងមានច្បាស់ខាងមុខ ។ ព្រោះព្រះពុទ្ធទាំងពួងមានគុណប៉ុនគ្នា ស្មើគ្នាដោយគុណរបស់ព្រះសម្មាសម្ពុទ្ធ ហេតុនោះ ទើបព្រះសារីបុត្តពោលថា **សម្មាសម្ពុទ្ធានំ** ដោយអំណាចនៃព្រះពុទ្ធទាំងអស់ ។

[ ៨៧ ] ឥឡូវនេះ ក្នុងសីល ២ ពួក គឺបរិយន្តបារិសុទ្ធិសីល សីលបរិសុទ្ធមានទីបំផុត ១ អបរិយន្តបារិសុទ្ធិសីល សីលបរិសុទ្ធមិនមានទីបំផុត ១ ព្រះសារីបុត្តដើម្បីញែកសម្តែងសីលនីមួយៗ ចេញជា ៥ ចំណែក ទើបពោលពាក្យជាដើមថា **អត្ថិ សីលំ បរិយន្តំ អត្ថិ សីលំ អបរិយន្តំ។** ក្នុងសីល ៣ យ៉ាងក្រៅអំពីនេះ ( បរិបុណ្ណបារិសុទ្ធិសីល អបរាមដ្ឋបារិសុទ្ធិសីល បដិបស្សទ្ធិបារិសុទ្ធិសីល ) មិនមានការផ្សេងគ្នាយ៉ាងនោះ ។

ក្នុងបទទាំងនោះ បទថា **លាភបរិយន្តំ** បានដល់ ឈ្មោះថា មានទីបំផុតព្រោះលាភ ព្រោះសីលមានទីបំផុត គឺដាច់ព្រោះលាភ ។ សូម្បីបទដ៏សេសក៏យ៉ាងនេះ ។

ក្នុងបទថា **យសោ** នេះ បានដល់ បរិវារ ។ បទថា **ឥធ** បានដល់ ក្នុងលោកនេះ ។ បទថា **ឯកច្ចោ** បានដល់ បុគ្គលម្នាក់ ។

បទថា **លាភហេតុ** បានដល់ ហេតុ គឺលាភ ឈ្មោះថា **លាភហេតុ** អធិប្បាយថា ព្រោះហេតុ គឺលាភនោះ ។ ពាក្យនេះ ជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថថា ហេតុ ។ បទថា **លាភប្បច្ចយា លាភការណា** ជាវេវចនៈរបស់បទថា **លាភហេតុ** នោះឯង ។

ហេតុនោះឯង ហៅថា បច្ច័យ ព្រោះផលនោះអាស្រ័យកើត និងហៅថា ការណៈ ព្រោះឲ្យធ្វើការកើតឡើងនៃផល ។ បទថា **យថាសមាទិន្នំ** បានដល់ សិក្ខាបទណាមួយដែលខ្លួនសមាទានហើយ គឺទទួលហើយ ។ បទថា **វីតិក្កមតិ** បានដល់ ប្រព្រឹត្តកន្លង ។

បទថា **ឯវរូបានិ** បានដល់ មានសភាពយ៉ាងនេះ អធិប្បាយថា មានប្រការដូចពោលហើយ ។

បទថា **សីលានិ** បានដល់ ជាសីលរបស់គ្រហស្ថក្តី សីលរបស់បព្វជិតក្តី សីលដែលមានសិក្ខាបទមួយខាងដើម ឬខាងចុងដាច់ ឈ្មោះថា **ខណ្ឌានិ** សីលដាច់ ដូចសំពត់សាដកដែលដាច់ជាយ ។ សីលដែលមានសិក្ខាបទមួយដាច់ត្រង់កណ្តាល ឈ្មោះថា **ឆិទ្ទានិ** សីលធ្លុះ ដូចសំពត់សាដក ធ្លុះត្រង់កណ្តាល ។ សីលដែលមានសិក្ខាបទ ២ ឬ ៣ ដាច់រៀងគ្នាតាមលំដាប់ ឈ្មោះថា **សពលានិ** ពពាល ដូចមេគោដែលមានសម្បុរខ្នងខ្មៅផង ក្រហមផងជាដើមឯណានីមួយដោយមានពណ៌មិនដូចគ្នា មានសណ្ឋានវែង និងមូលជាដើមតាំងឡើងត្រង់ខ្នង ឬត្រង់ពោះ ។ សីលដែលមានសិក្ខាបទមួយៗ ដាច់ទៅក្នុងចន្លោះៗ ឈ្មោះថា **កម្មាសានិ** ពព្រុស ដូចមេគោមានពណ៌អុចៗ មិនដូចគ្នា

ក្នុងចន្លោះៗ ។ ម្យ៉ាងទៀត ពោលដោយមិនផ្សេងគ្នា សីលទាំងអស់ ឈ្មោះថា ដាច់ ធ្លុះ ពពាល ពព្រុះ ព្រោះត្រូវមេថុនសំយោគ ៧ យ៉ាង និងត្រូវធម៌ដ៏លាមក មានសេចក្ដីក្រោធនិងការចងសេចក្ដីក្រោធទុកជាដើមទម្លាយហើយ ។

សីលទាំងនោះ ឈ្មោះថា **ន ភុជិស្សានិ** មិនមែនជាសីលរបស់អ្នកជា ព្រោះធ្វើការៈផុតចាកភាពជាទាសៈនៃតណ្ហា ហើយជាអ្នកជា ។ ឈ្មោះថា **ន វិញ្ញុប្បសត្ថានិ** ព្រោះវិញ្ញូជន មានព្រះពុទ្ធជាដើមមិនសរសើរ ។ ឈ្មោះថា **បរាមដ្ឋានិ** ព្រោះត្រូវតណ្ហា និងទិដ្ឋិពាល់ត្រូវហើយ ឬព្រោះបុគ្គលណាមួយអាចពោលទោសបានថា នេះជាទោសក្នុងសីលរបស់អ្នក ។ ឈ្មោះថា **អសមាធិសំវត្តនិកានិ** ព្រោះមិនធ្វើឧបចារសមាធិ ឬអប្បនាសមាធិឲ្យប្រព្រឹត្តទៅ ម្យ៉ាងទៀត ព្រោះមិនធ្វើមគ្គសមាធិ ឬផលសមាធិឲ្យប្រព្រឹត្តទៅ បាឋៈថា **ន សមាធិសំវត្តនិកានិ** ដូច្នេះក៏មាន ។

ចំណែកអាចារ្យពួកខ្លះ ពណ៌នាសេចក្ដីយ៉ាងនេះថា ឈ្មោះថា **ខណ្ឌានិ** ព្រោះមិនជាទីតាំងនៃកុសលធម៌ទាំងឡាយ ឈ្មោះថា **ឆិទ្ទានិ** ក៏យ៉ាងនោះ ។ ឈ្មោះថា **សពលានិ** ព្រោះមានពណ៌ផ្សេងៗ គ្នា ឈ្មោះថា **កម្មាសានិ** ក៏យ៉ាងនោះ ។ ឈ្មោះថា **ន ភុជិស្សានិ** ព្រោះដល់នូវភាពជាទាសៈរបស់តណ្ហា ។ ឈ្មោះថា **ន វិញ្ញុប្បសត្ថានិ** ព្រោះត្រូវអ្នកប្រាជ្ញតិះដៀល ។ ឈ្មោះថា **បរាមដ្ឋានិ** ព្រោះត្រូវតណ្ហាពាល់ត្រូវ ។ ឈ្មោះថា **អសមាធិសំវត្តនិកានិ** ព្រោះជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ។

បទថា **ន អវិប្បដិសារវត្ថុកានិ** សេចក្ដីថា ជាទីតាំងនៃសេចក្ដីមិនក្ដៅ

ក្រហាយមិនមាន ព្រោះនាំមកនូវសេចក្ដីក្ដៅក្រហាយ ។

បទថា ន **ចាមុជ្ជវត្ថុកានិ** បានដល់ មិនជាទីតាំងនៃបីតិយ៉ាងទន់ ដែលមិនកើតសេចក្ដីក្ដៅក្រហាយ ព្រោះមិននាំបីតិយ៉ាងទន់នោះមក ។ សូម្បីក្នុងបទដ៏សេសក៏គប្បីប្រកបយ៉ាងនេះ ។

បទថា ន **បីតិវត្ថុកានិ** បានដល់ មិនជាទីតាំងនៃបីតិយ៉ាងខ្លាំង ដែលកើតអំពីបីតិយ៉ាងទន់ ។

បទថា ន **បស្សទ្ធិវត្ថុកានិ** បានដល់ មិនជាទីតាំងនៃសេចក្ដីរម្ងាប់កាយនិងចិត្តដែលកើតអំពីបីតិដ៏ខ្លាំងនោះ ។

បទថា ន **សុខវត្ថុកានិ** បានដល់ មិនជាទីតាំងនៃសេចក្ដីសុខផ្លូវកាយនិងផ្លូវចិត្តដែលកើតអំពីសេចក្ដីស្ងប់ ។

បទថា ន **សមាធិវត្ថុកានិ** បានដល់ មិនជាទីតាំងនៃសមាធិដែលកើតអំពីសេចក្ដីសុខ ។

បទថា ន **យថាភូតញ្ញាណទស្សនវត្ថុកានិ** បានដល់ មិនជាទីតាំងនៃយថាភូតញ្ញាណទស្សនៈដែលមានសមាធិជាបទដ្ឋាន ។

ក្នុងបទថា ន **ឯកន្តនិព្វិទាយ** ជាដើម គប្បីនាំ ន អក្ខរៈ មកប្រកបសូម្បីក្នុងបទដ៏សេស ដោយន័យជាដើមថា **ន វិរាគាយ ។**

ម្យ៉ាងវិញទៀត បាឋៈ មាន ន អក្ខរៈក្នុងបទជាដើមថា **ន វិរាគាយ ។** ក្នុងបទទាំងនោះ បទថា **ឯកន្តនិព្វិទាយ** គប្បីភ្ជាប់សេចក្ដីថា សីលទាំងឡាយរមែងមិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ក្នុងវដ្តៈដោយចំណែកមួយ ។

សូម្បីបទដ៏សេស ក៏គប្បីប្រកបយ៉ាងនេះ ។

បទថា **វិរាគាយ** បានដល់ ដើម្បីការប្រាសចាកតម្រេកក្នុងវដ្ដៈ ។ បទថា **និរោធាយ** បានដល់ ដើម្បីសេចក្ដីរលត់នៃវដ្ដៈ ។ បទថា **ឧបសមាយ** បានដល់ ដើម្បីសេចក្ដីស្ងប់នៃវដ្ដៈដោយអំណាចការមិនកើតទៀតនៃវដ្ដៈដែលត្រូវរម្ងត់ហើយ ។ បទថា **អភិញ្ញាយ** បានដល់ ដើម្បីសេចក្ដីដឹងដ៏ក្រៃលែងនៃវដ្ដៈ ។ បទថា **សម្ពោធាយ** បានដល់ ដើម្បីការភ្ញាក់ចាកវដ្ដៈដោយប្រាសចាកការដេកលក់ គឺកិលេស ។ បទថា **និព្វានាយ** បានដល់ ដើម្បីនិព្វានដែលជាអមតៈ ។

[ ៨៨ ] បទថា **យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមាយ** បានដល់ ដើម្បីការកន្លងសិក្ខាបទ តាមដែលខ្លួនសមាទានហើយ ក្នុងបទនេះ លោកប្រកបជាទុតិយាវិភត្តិ ដោយវិភត្តិវិបល្លាស ។ បទថា **ចិត្តម្បិ ន ឧប្បាទេតិ** លោកពោលដើម្បីសម្ដែងភាពដែលសីលបរិសុទ្ធក្រៃលែង ដោយសេចក្ដីបរិសុទ្ធនៃចិត្តុប្បាទ ។ សីលមិនមែនដាច់ដោយត្រឹមតែការគិត ។ បទថា **កឹ សោ វីតិក្កមិស្សតិ** បានដល់ បុគ្គលនោះនឹងធ្វើការកន្លង ដើម្បីអ្វី អធិប្បាយថា បុគ្គលនោះនឹងមិនធ្វើការកន្លងនោះឯង ។ បទជាដើមថា **អខណ្ឌានិ** សីលមិនដាច់ គប្បីជ្រាបដោយន័យផ្ទុយគ្នា តាមដែលពោលហើយ ។ បាឋៈថា **ន ខណ្ឌានិ** ដូច្នេះក៏មាន ។ ក្នុងបទថា **ឯកត្តនិព្វិទាយ** ជាដើម គប្បីប្រកបដោយន័យជាដើមថា **ឯកន្តេន វដ្ដេ និព្វិន្ទនត្ថាយ** ដើម្បីសេចក្ដីនឿយណាយក្នុងវដ្ដៈដោយចំណែកមួយ ។ម្យ៉ាងទៀត ក្នុងបទទាំងនេះ បទថា **និព្វិទាយ**

បានដល់ វិបស្សនា ។ បទថា **វិរាគាយ** បានដល់ មគ្គ ។ បទថា **និរោធាយ ឧបសមាយ** បានដល់ និព្វាន ។ បទថា **អភិញ្ញាយ សម្ពោធាយ** បានដល់ មគ្គ ។ បទថា **និព្វានាយ** បានដល់ និព្វាននោះឯង ។

គប្បីជ្រាបកថាកំណត់យ៉ាងនេះថា លោកពោលវិបស្សនា ក្នុងឋានៈ ១ មគ្គក្នុងឋានៈ ២ និព្វានក្នុងឋានៈ ៣ ។ តែដោយបរិយាយបទទាំងអស់នេះ ជាវេវចនៈរបស់មគ្គខ្លះ ជាវេវចនៈរបស់និព្វានខ្លះ ។

[ ៨៩ ] ឥឡូវនេះ ព្រះសារីបុត្តកាលសម្តែងប្រភេទរបស់សីល ដែលមានដោយអំណាចបរិយន្តបារិសុទ្ធិសីល និងអបរិយន្តបារិសុទ្ធិសីល ហើយដើម្បីសម្តែងប្រភេទរបស់សីលដោយអំណាចធម៌ ជាតិ បច្ច័យ សម្បយុត្តដដែលទៀត ទើបពោលពាក្យថា **កឹ សីលំ** ដូច្នេះជាដើម ។

ក្នុងបទនោះ ឈ្មោះថា **សមុដ្ឋានំ** ព្រោះអត្ថថា ជាហេតុតាំងឡើង ។ បទនេះជាឈ្មោះរបស់បច្ច័យ ។ ឈ្មោះថា **កឹសមុដ្ឋានំ** ព្រោះអត្ថថា សីលនោះមានអ្វីជាសមុដ្ឋាន ។ ឈ្មោះថា **កតិធម្មសមោធានំ** ព្រោះអត្ថថា សីលនោះជាទីប្រជុំ ជាទីប្រមូលមកនូវធម៌អ្វី ។ បទថា **ចេតនា សីលំ** បានដល់ចេតនារបស់អ្នកវៀរចាកបាណាតិបាតជាដើម ឬរបស់អ្នកបំពេញវត្តបដិបត្តិ ។ បទថា **ចេតសិកំ សីលំ** បានដល់ ចេតនាវៀររបស់អ្នកវៀរចាកបាណាតិបាតជាដើម ។ម្យ៉ាងទៀត ចេតនា ឈ្មោះថា ជាសីល បានដល់ ចេតនាក្នុងកម្មបថ ៧ របស់អ្នកវៀរចាកបាណាតិបាតជាដើម ។ ចេតសិក ឈ្មោះថា សីល បានដល់ ធម៌ គឺអនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិដែលលោកពោលដោយ

ន័យ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ជាដើមថា ភិក្ខុនោះក៏លះបង់នូវអភិជ្ឈា ក្នុងលោក គឺបញ្ចុបាទានក្ខន្ធ មានចិត្តប្រាសចាកអភិជ្ឈា ដូច្នេះ ។

ក្នុងបទថា **សំវរោ សីលំ** គប្បីជ្រាបថា សំវរៈមាន ៥ យ៉ាង គឺបាតិ-មោក្ខសំវរៈ សេចក្តីសង្រួមក្នុងបាតិមោក្ខ ១ សតិសំវរៈ សេចក្តីសង្រួមដោយសតិ ១ ញាណសំវរៈ សេចក្តីសង្រួមដោយញាណ ១ ខន្តិសំវរៈ សេចក្តីសង្រួមដោយខន្តី ១ វីរិយសំវរៈ សេចក្តីសង្រួមដោយការព្យាយាម ១ ។ ក្នុងការសង្រួម ៥ យ៉ាងនោះ ( ព្រះតម្រាស់ក្នុងអភិធម្មវិភង្គថា ) គឺជាអ្នកព្រមព្រៀងមូលមិត្រដោយការសង្រួមក្នុងបាតិមោក្ខនេះ នេះឈ្មោះថា បាតិមោក្ខ-សំវរៈ ។ ( ព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាតថា ) រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ នេះឈ្មោះថា សតិសំវរៈ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា

> ( ព្រះមានព្រះភាគដោះស្រាយថា ម្នាលអជិតៈ ) សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះ ដោយបញ្ញា ។ នេះឈ្មោះថា ញាណសំវរៈ សូម្បីការសេពបច្ច័យ ក៏សង្គ្រោះចូលក្នុងពាក្យនេះដូចគ្នា ។

ការសង្រួមមកហើយដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា អត់ធន់ចំពោះត្រជាក់ ក្តៅជាដើម នេះឈ្មោះថា ខន្តិសំវរៈ ។ សេចក្តី

សង្រួមមកហើយ ដោយន័យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា បំផ្លាញនូវកាមវិតក្ក ដែលកើតឡើងហើយជាដើម នេះឈ្មោះថា វីរិយសំវរ សូម្បីអាជីវបារិសុទ្ធិសីល ក៏សង្គ្រោះចូលក្នុងបទនេះដូចគ្នា ។ សេចក្តីសង្រួម ទាំង ៥ ប្រការនេះ និងចេតនាវៀរចាកវត្ថុដែលមកដល់ របស់កុលបុត្តអ្នកខ្លាចបាបឯណា ទាំងអស់នេះ គប្បីជ្រាបថា ជាសំវរសីល ដោយប្រការដូច្នេះ ។

បទថា **អវីតិក្កមោ សីលំ** បានដល់ ការមិនឈានកន្លងផ្លូវកាយ និងផ្លូវវាចារបស់អ្នកសមាទានសីល ។ ការឆ្លើយបញ្ហាថា **កឹ សីលំ** នេះ មានប្រមាណប៉ុណ្ណេះ ។

ក្នុងការឆ្លើយបញ្ហាថា **កតិ សីលានិ** សីលមានប៉ុន្មាន គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ព្រោះប្រក្រតីរបស់សត្វទាំងឡាយនោះៗ ក្នុងលោក លោកហៅថា **សីលំ** ក្នុងបទនេះថា **កុសលសីលំ អកុសលសីលំ អព្យាកតសីលំ** ដែលអាចារ្យទាំងឡាយពោលសំដៅដល់ថា បុគ្គលនេះ មានសេចក្តីសុខជាប្រក្រតី បុគ្គលនេះ មានសេចក្តីទុក្ខជាប្រក្រតី បុគ្គលនេះ មានការឈ្លោះទាស់ទែងជាប្រក្រតី បុគ្គលនេះ មានការតែងខ្លួនជាប្រក្រតី ហេតុនោះ ដោយបរិយាយនោះ សូម្បីអកុសលសីល ក៏លោកពោលថាជាសីល ដោយការលើកអត្ថនោះមកពោល តែសីលនោះ មិនមែនសីលដែលលោកបំណងយកក្នុងទីនេះ ព្រោះបទថា **សុត្វាន សំវរេ បញ្ញា** បញ្ញាក្នុងការស្តាប់ហើយសង្រួម[១] ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះចិត្តដែលសម្បយុត្តជាសមុដ្ឋានរបស់សីល ដែលជា

---

១- បិដកលេខ ៦៩ ទំព័រ ១ ។

ប្រភេទមានចេតនាជាដើម ហេតុនោះ ទើបព្រះសារីបុត្តពោលបទថា **កុសលចិត្តសមុដ្ឋានំ កុសលសីលំ** ជាដើម ។

បទថា **សំវរសមោធានំ សីលំ** បានដល់ ខន្ធដែលសម្បយុត្តដោយការសង្រួម ។ ពិតហើយ ខន្ធទាំងនោះ ប្រកបព្រម គឺលាយឡំគ្នាជាមួយសេចក្ដីសង្រួម ព្រោះហេតុនោះ ទើបហៅថា ជាទីប្រជុំនៃសំវរៈ បទថា **អវីតិក្កម-សមោធានំ សីលំ** ក៏គប្បីជ្រាបយ៉ាងនេះ ។

បទថា **តថាភាវេ ជាតចេតនា សមោធានំ សីលំ** បានដល់ ខន្ធដែលសម្បយុត្តដោយចេតនាដែលកើតក្នុងការសង្រួម ក្នុងការមិនឈានកន្លង ។ ម្យ៉ាងទៀត ព្រោះលោកបំណងយកធម៌ ដែលសម្បយុត្តជាមួយនឹងចេតនានោះក្នុងចិត្ត សូម្បីទាំងបី ហេតុនោះ គប្បីជ្រាបថា លោកមិនចង្អុលបង្ហាញសីលដែលជាទីប្រជុំនៃចេតសិកផ្សេងអំពីគ្នា ព្រោះសូម្បីចេតសិក លោកក៏សង្គ្រោះដោយការប្រជុំនៃចេតនា ។ ធម៌ទាំងឡាយ មានចេតនាជាដើម លោកពោលថា **សីលំ** ក្នុងខាងក្រោយ ។ គប្បីជ្រាបថា លោកពោលត្រិកៈនេះដើម្បីសម្ដែងថា ធម៌ទាំងនោះ មិនមែនសីលតែម្យ៉ាង ។ សូម្បីធម៌ដែលសម្បយុត្តជាមួយនឹងសីលនោះ ក៏ជាសីលដូចគ្នា ។

ឥឡូវនេះ ព្រោះចេតនា និងចេតសិក ជាការសង្រួម និងការមិនឈានកន្លងនោះឯង មិនមែនញែកចេញចាកគ្នា ហេតុនោះ កាលព្រះសារីបុត្ត ប្រកបការសង្រួម និងការមិនឈានកន្លងដោយលំដាប់ទៅ រហូតដល់អរហត្តមគ្គ ទើបពោលបទជាដើមថា **ចាណាតិបាតំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ**

ដូច្នេះ ។ ព្រោះការវៀរចាកបាណាតិបាតជាដើម រមែងរាំងវត្ថុជាសត្រូវរៀងៗខ្លួន និងរមែងមិនឈានកន្លងវត្ថុដែលជាសត្រូវនោះ ហេតុនោះ ឈ្មោះថា សីល ព្រោះអត្ថថា សង្រួម ដោយការសង្រួម និងឈ្មោះថា សីល ព្រោះអត្ថថា មិនឈានកន្លង ដោយការមិនឈានកន្លង ។

ក្នុងបទទាំងនោះ បទថា **បាណាតិបាតំ សំវរដ្ឋេន** បានដល់ ឈ្មោះថា សីល ព្រោះអត្ថថា បិទបាណាតិបាត ។ សីលប្រការនោះគឺអ្វី គឺការវៀរចាកបាណាតិបាត ។ ម្យ៉ាងទៀត ការវៀរចាកបាណាតិបាតនោះ កាលរាំងបាណាតិបាតនោះឯង រមែងមិនឈានកន្លងបាណាតិបាតនោះ ព្រោះហេតុនោះ ឈ្មោះថា សីល ព្រោះអត្ថថា មិនឈានកន្លង ។ ការវៀរចាកអទិន្នាទានជាដើម អនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ បណ្ឌិតគប្បីប្រកបយ៉ាងនេះដូចគ្នានោះឯង ។ ក្នុងអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម ការធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះ ឈ្មោះថា បាណាតិបាត អធិប្បាយថា ការប្រហារសត្វ ការសម្លាប់សត្វ ។

ម្យ៉ាងទៀត ក្នុងបទថា **បាណោ** នេះ ដោយវោហារ បានដល់ សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ។ ចេតនាដែលតាំងឡើង ដើម្បីសម្លាប់របស់បុគ្គលដែលសម្គាល់ក្នុងសត្វមានជីវិតនោះថា មានជីវិត ដែលប្រព្រឹត្តទៅក្នុងទ្វារណាមួយនៃកាយទ្វារ និងវចីទ្វារ ដែលធ្វើសេចក្តីព្យាយាមក្នុងការផ្តាច់បង់ជីវិតិន្ទ្រិយ ឈ្មោះថា បាណាតិបាត បណ្តាសត្វទាំងឡាយ មានសត្វតិរច្ឆានជាដើមដែលមិនមានគុណ បាណាតិបាតនោះ ក៏មានទោសតិចក្នុងសត្វតូចៗ មាន

ទោសច្រើនក្នុងសត្វធំៗ ។ ព្រោះហេតុអ្វី ព្រោះប្រើសេចក្ដីព្យាយាមច្រើន ។ កាលមានសេចក្ដីព្យាយាមស្មើគ្នា ក៏មានទោសច្រើនក្នុងសត្វដែលធំ ។ ក្នុងមនុស្សជាដើមដែលមានគុណ គប្បីជ្រាបថា បាណាតិបាតមានទោសតិច ក្នុងមនុស្សមានគុណតិច មានទោសច្រើន ក្នុងមនុស្សដែលមានគុណច្រើន ។ កាលរាងកាយ និងគុណស្មើគ្នា បាណាតិបាតមានទោសតិច ព្រោះកិលេស និងសេចក្ដីព្យាយាមតិច មានទោសច្រើន ព្រោះកិលេស និងសេចក្ដីព្យាយាមខ្លាំងក្លា ។

បាណាតិបាតនោះ មានអង្គ ៥ គឺ **បាណោ** សត្វមានជីវិត ១ **បាណសញ្ញិតា** ដឹងថាសត្វមានជីវិត ១ **វធកចិត្តំ** ចិត្តគិតនឹងសម្លាប់ ១ **ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ១ **តេនមរណំ** សត្វស្លាប់ ដោយសេចក្ដីព្យាយាមនោះ ១ ។

ការកាន់យករបស់ដែលគេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** មានពាក្យអធិប្បាយថា ការនាំទ្រព្យបុគ្គលដទៃទៅ ការលួច ការលួចដូចជាចោរ ( ប្លន់ ) ។ ក្នុងបទទាំងនោះ បទថា **អទិន្នំ** បានដល់ ទ្រព្យដែលអ្នកដទៃហួងហែង ។ អ្នកដទៃដល់នូវការធ្វើបានតាមបំណងក្នុងវត្ថុណា ជាអ្នកមិនគួរបានទទួលអាជ្ញា និងមិនគួរត្រូវតិះដៀល ចេតនាដែលតាំងឡើងគិតនឹងលួចរបស់បុគ្គលដែលសម្គាល់ក្នុងវត្ថុដែលបុគ្គលដទៃហួងហែងនោះថា បុគ្គលដទៃហួងហែង ដែលប្រព្រឹត្តទៅក្នុងទ្វារឯណានីមួយនៃកាយទ្វារ និងវចីទ្វារ ដែលធ្វើសេចក្ដីព្យាយាមដែលនឹងកាន់យករបស់ ដែលបុគ្គលដទៃហួងហែងនោះ ឈ្មោះថា អទិន្នាទាន ។ អទិន្នាទាននោះ មានទោសតិច ក្នុងទ្រព្យអ្នកដទៃដែលអន់

ថយ មានទោសច្រើន ក្នុងទ្រព្យដែលប្រណីត ។ ព្រោះហេតុអ្វី ព្រោះវត្ថុប្រណីត ។ បើវត្ថុស្មើគ្នាមានទោសច្រើន ក្នុងវត្ថុដែលជាទ្រព្យរបស់បុគ្គលដែលក្រៃលែងដោយគុណ មានទោសតិច ក្នុងវត្ថុដែលជាទ្រព្យរបស់បុគ្គល ដែលមានគុណតិច ដោយប្រៀបធៀបបុគ្គលដែលក្រៃលែងដោយគុណនោះៗ ។

អទិន្នាទាននោះមានអង្គ ៥ គឺ **បរបរិគ្គហិតំ** ទ្រព្យដែលបុគ្គលដទៃហួងហែង ១ **បរបរិគ្គហិតសញ្ញិតា** ដឹងថាបុគ្គលដទៃហួងហែង ១ **ថេយ្យចិត្តំ** ចិត្តគិតនឹងលួច ១ **ឧបក្កមោ** ព្យាយាមនឹងលួច ១ **តេន ហរណំ** នាំទៅដោយសេចក្តីព្យាយាមនោះ ១ ។

បទថា **កាមេសុ** បានដល់ ការប្រព្រឹត្តក្នុងមេថុន ។ បទថា **មិច្ឆាចារោ** បានដល់ ការប្រព្រឹត្តលាមកដែលត្រូវតិះដៀលដោយចំណែកមួយ ។ តែដោយលក្ខណៈ ចេតនាដែលឈានកន្លងឋានៈដែលមិនគួរដល់ ( អគមនីយដ្ឋាន ) ដែលប្រព្រឹត្តក្នុងកាយទ្វារ ដោយបំណងនឹងសេពអសទ្ធម្ម ឈ្មោះថា **កាមេសុ-មិច្ឆាចារ** ។ ក្នុងបទនោះ ស្ត្រី ២០ ពួក បានដល់ ស្រីដែលមាតាថែរក្សាជាដើម ១០ ពួក គឺស្រីដែលម្តាយថែរក្សា ១ ស្រីដែលឪពុកថែរក្សា ១ ស្រីដែលម្តាយឪពុកថែរក្សា ១ ស្រីដែលបងប្អូនប្រុសថែរក្សា ១ ស្រីដែលបងប្អូនស្រីថែរក្សា ១ ស្រីដែលពួកញាតិថែរក្សា ១ ស្រីដែលជនមានគោត្តវង្សស្មើគ្នាថែរក្សា ១ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នាថែរក្សា ១ ស្រីដែលប្រុសថែរក្សា ១ អាជ្ញាដែលស្តេចអគ្គណា ១ ទ្រង់តាំងទុកដូច្នេះថា បើបុរសណាមករួមនឹងស្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណោះដល់បុរសនោះ ១ ។ និងកិរិយា

១០ ពួក មានកិរិយា ដែលបុរសលោះនឹងទ្រព្យជាដើម គឺកិរិយាដែលបុរសលោះនឹងទ្រព្យ ១ ប្រុសជាទីស្រឡាញ់របស់ស្រី ឲ្យស្រីជាទីស្រឡាញ់នៅរួមជាមួយ ១ កិរិយាដែលប្រុសឲ្យភោគៈ ១ កិរិយាដែលប្រុសឲ្យសំពត់ស្លៀកដណ្តប់ ១ កិរិយាដែលញាតិចាប់ដៃផ្គុំជាមួយនឹងបុរស ជ្រលក់ក្នុងកាជន៍ទឹកហើយគេផ្សំឲ្យនៅរួមជាមួយ ១ កិរិយាដែលប្រុសដាក់ទ្រនូលឲ្យ ១ ស្រីដែលប្រើប្រាស់ជាខ្ញុំផង ជាកិរិយាផង ១ ស្រីដែលធ្វើការឈ្នួលផង ជាកិរិយាផង ១ ស្រីដែលគេចាប់ពីកងទ័ពយកមកធ្វើជាកិរិយា ១ ស្រីដែលប្រុសបាននៅរួមគ្នាមួយរំពេចនោះ ១ ឈ្មោះថា អគមនីយដ្ឋានរបស់បុរសទាំងឡាយ ។ បណ្តាស្រីទាំងឡាយ បុរសដទៃឈ្មោះថាជាអគមនីយដ្ឋានរបស់ស្រី ១២ ពួក គឺស្រីដែលប្រុសថែរក្សា និងអាជ្ញាដែលស្តេចអង្គណាមួយ ទ្រង់តាំងទុក ដូច្នេះថា បើបុរសណាមករួមនឹងស្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណេះដល់បុរសនោះ រួមជា ២ ពួក និងកិរិយាដែលបុរសលោះនឹងទ្រព្យជាដើម ១០ ពួក ( រួមជា ១២ ពួក ) ។

ម្យ៉ាងទៀត មិច្ឆាចារនោះមានទោសតិច ក្នុងអគមនីយដ្ឋានដែលមិនមានគុណ មានសីលជាដើម មានទោសច្រើន ក្នុងអគមនីយដ្ឋានដែលសម្បូរដោយគុណ មានសីលជាដើម ។

មិច្ឆាចារ មានអង្គ ៤ គឺ **អគមនីយវត្ថុ** វត្ថុដែលមិនគួរដល់ ១ **តស្មឹ សេវនចិត្តំ** ចិត្តគិតនឹងសេពក្នុងវត្ថុដែលមិនគួរដល់នោះ ១ **សេវនបយោគោ** ព្យាយាមនឹងសេព ១ **មគ្គេនមគ្គបដិបត្តិអធិវាសនំ** មគ្គនិងមគ្គដល់គ្នា ១ ។

បទថា **មុសា** បានដល់ វចីបយោគ ឬកាយបយោគដែលកាច់បំបាក់នូវប្រយោជន៍របស់អ្នកដែលបំណងនឹងនិយាយឲ្យខុស ។

ចេតនាដែលតាំងឡើងញុំាងកាយបយោគ និងវចីបយោគ ក្នុងការពោលឲ្យអ្នកដទៃយល់ខុសដោយបំណងពោលឲ្យឃ្លៀងឃ្លាត ឈ្មោះថា មុសាវាទ ។ ន័យម្យ៉ាងទៀត បទថា **មុសា** បានដល់ រឿងមិនពិត មិនមែន ។ បទថា **វាទោ** បានដល់ ការឲ្យអ្នកដទៃដឹងរឿងមិនពិត មិនមែននោះ ថាជារឿងពិត រឿងមែន តែដោយលក្ខណៈ ចេតនាដែលញុំាងការពោលយ៉ាងនោះ ឲ្យតាំងឡើង របស់បុគ្គលដែលបំណងឲ្យអ្នកដទៃ ដឹងរឿងមិនពិត ថាជារឿងពិត ឈ្មោះថា មុសាវាទ ។ មុសាវាទនោះ មានទោសតិច ព្រោះប្រយោជន៍ដែលកាច់បំបាក់តិច មានទោសច្រើន ព្រោះប្រយោជន៍ដែលកាច់បំបាក់ច្រើន ។ ម្យ៉ាងវិញទៀត សម្រាប់ពួកគ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅដោយន័យជាដើមថា មិនមាន ព្រោះបំណងមិនឲ្យទ្រព្យរបស់ខ្លួន មានទោសតិច បើជាសាក្សីពោលដើម្បីកាច់បំបាក់ប្រយោជន៍ មានទោសច្រើន ។ សម្រាប់បព្វជិត មុសាវាទដែលបព្វជិតបានប្រេង ឬសប្បិតិច ហើយពោលហួសការពិតដោយបំណងនឹងសើចលេងថា ថ្ងៃនេះ ក្នុងស្រុកមានប្រេងហូរដូចស្ទឹង មានទោសតិច ចំណែកមុសាវាទរបស់ពួកជនដែលពោលដល់វត្ថុដែលខ្លួនមិនឃើញ ថាឃើញ មានទោសច្រើន ។

មុសាវាទ មានអង្គ ៤ គឺ **អតថំ វត្ថុ** រឿងមិនពិត ១ **វិសំវាទនចិត្តំ** ចិត្តគិតនឹងនិយាយឲ្យខុស ១ **តជ្ជោ វាយាមោ** ព្យាយាមកើតពីចិត្តគិត

និយាយឲ្យខុសនោះ ១ **បរស្ស តទត្ថាវិជាននំ** អ្នកដទៃដឹងសេចក្តីរបស់ពាក្យនោះ ១ ។ វាចាដែលធ្វើខ្លួនឲ្យជាទីស្រឡាញ់ផង ធ្វើបុគ្គលដទៃឲ្យទទេក្នុងហទយៈរបស់បុគ្គលដែលខ្លួនពោលផង ឈ្មោះថា **បិសុណា វាចា** ។ វាចាដែលធ្វើខ្លួនឯងខ្លះ អ្នកដទៃខ្លះឲ្យគ្រោតគ្រាត វាចាខ្លួនឯង ក៏គ្រោតគ្រាតមិនពីរោះស្តាប់ ឬមិនមានសេចក្តីសុខដល់ចិត្ត ឈ្មោះថា **ផរុសា វាចា** ។ វាចាដែលនិយាយរោយរាយឡេះឡោះមិនមានប្រយោជន៍ ឈ្មោះថា **សម្ផប្ប-លាបោ** ។ សូម្បីចេតនាដែលជាមូលហេតុរបស់បិសុណាវាចាជាដើមទាំងនោះក៏បានឈ្មោះថា បិសុណាវាចាជាដើម ។ ចេតនានោះឯង លោកបំណងយកក្នុងទីនេះ ។ ក្នុងបទថា **បិសុណា វាចា** នោះ ចេតនារបស់អ្នកមានចិត្តសៅហ្មងដែលញុំាងកាយបយោគ និងវចីបយោគឲ្យតាំងឡើង ដើម្បីបំបែកអ្នកដទៃ ឬដើម្បីបំណងឲ្យខ្លួនជាទីស្រឡាញ់ ឈ្មោះថា **បិសុណា វាចា** ។ បិសុណាវាចានោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលត្រូវបំបែកមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះបុគ្គលដែលត្រូវបំបែក មានគុណច្រើន ។

បិសុណាវាចាមានអង្គ ៤ គឺ **ភិន្ទិតព្វោ បរោ** អ្នកដទៃដែលត្រូវបំបែក ១ **ភេទបុរេក្ខារតា វា បិយកម្យតា វា** បំណងនឹងបំបែកថា មនុស្សទាំងនេះនឹងប្រព្រឹត្តទៅផ្សេងៗ ឬបំណងឲ្យជាទីស្រឡាញ់ថា អញនឹងជាទីស្រឡាញ់នឹងជាទីស្និទ្ធស្នាល ១ **តជ្ជោ វាយាមោ** សេចក្តីព្យាយាម កើតអំពីបំណងនោះ ១ **តស្ស តទត្ថាវិជាននំ** បុគ្គលនោះដឹងសេចក្តីនោះ ១ ។

កាលអ្នកដទៃមិនទាន់បែកគ្នា កម្មបថក៏មិនដាច់ កាលគេបែកគ្នាហើយ ទើបកម្មបថដាច់ ។

ចេតនាគ្រោតគ្រាតដែលតាំងឡើងដោយចំណែកមួយ ដែលញ៉ាំងកាយ-បយោគ និងវចីបយោគ ដែលកាត់នូវសេចក្តីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **ផរុសា វាចា ។** បយោគ សូម្បីកាត់សេចក្តីស្រឡាញ់ ក៏មិនមែនជាផរុសវាចាព្រោះចិត្តទន់ភ្លន់ ។ ពិតហើយ មាតាបិតាក្នុងកាលខ្លះ និយាយនឹងកូនតូចយ៉ាងនេះថា សូមឲ្យចោរចាប់ពួកឯងកាប់ជាកំណាត់តូចធំចុះ ដូច្នេះ ។ តែសេចក្តីពិត មាតាបិតាមិនប្រាថ្នាសូម្បីឲ្យស្លឹកឈូកធ្លាក់លើសីសៈរបស់កូនតូចទាំងនោះឡើយ ។ រីឯអាចារ្យ និងឧបជ្ឈាយ៍ក្នុងកាលខ្លះ ពោលនឹងពួកកូនសិស្សយ៉ាងនេះថា ពួកអ្នកទាំងនេះ មិនមានហិរិឱត្តប្បៈដល់គ្នាសោះឡើយ ចូរបណ្តេញចេញឲ្យអស់ទៅ ប៉ុន្តែតាមការពិត អាចារ្យ និងឧបជ្ឈាយ៍ប្រាថ្នាឲ្យកូនសិស្សទាំងនោះ ដល់ព្រមដោយការសិក្សារៀនសូត្រ និងសម្រេចធម៌ដូចគ្នានោះឯង ។ ព្រោះចិត្តទន់ភ្លន់មិនជាផរុសវាចាយ៉ាងណា ព្រោះវាចាផ្អែមល្ហែមមិនជាផរុសវាចាយ៉ាងនោះក៏មិនមែន ពិតហើយវាចារបស់បុគ្គលដែលបំណងឲ្យស្លាប់ថា ពួកអ្នកចូរឲ្យបុគ្គលនេះដេកឲ្យសប្បាយចុះ មិនជាផរុសវាចាក៏មិនមែន ព្រោះចិត្តគ្រោតគ្រាត ទើបវាចានោះ ជាផរុសវាចា វាចាគ្រោតគ្រាតនោះមានទោសតិច ព្រោះអ្នកដែលពោលសំដៅដល់នោះជាអ្នកមានគុណតិច មានទោសច្រើន ព្រោះអ្នកដែលពោលសំដៅដល់នោះ មានគុណច្រើន ។

ផរុសវាចា មានអង្គ ៣ គឺ **អក្កោសិតព្វោ បរោ** អ្នកដទៃដែលត្រូវជេរ

១ **កុបិតចិត្តំ** មានចិត្តក្រោធខឹង ១ **អក្កោសនា** ការជេរ ១ ។

ចេតនាជាអកុសល តាំងឡើងដែលញុំាងកាយបយោគ និងវចីបយោគ ដើម្បីឲ្យដឹងរឿងឥតប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** ។ សម្ផប្បលាបៈនោះមានទោសតិចព្រោះអាសេវនៈតិច មានទោសច្រើនព្រោះអាសេវនៈច្រើន ។

សម្ផប្បលាបៈមានអង្គ ២ គឺ **ភារតយុទ្ធសីតាហរណាទិនិរត្ថកកថា-បុរេក្ខារតា** បំណងពោលរឿងដែលឥតប្រយោជន៍ មានរឿងភារតយុទ្ធ និងរឿងដណ្តើមនាងសីតាជាដើម ១ **តថារូបិកថាកថនំ** ការពោលរឿងយ៉ាងនោះ ១ ។

កាលអ្នកដទៃមិនកាន់យករឿងនោះ កម្មបថក៏នៅមិនទាន់ដាច់ កាលអ្នកដទៃកាន់យកពាក្យនិយាយរោយរាយនោះ ទើបកម្មបថដាច់ ។

ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា សម្លឹង អធិប្បាយថា ផ្តោតចំពោះភណ្ឌៈរបស់អ្នកដទៃ ប្រព្រឹត្តទៅដោយបង្អោនក្នុងភណ្ឌៈនោះ ។ អភិជ្ឈានោះ មានលក្ខណៈសម្លឹងភណ្ឌៈរបស់អ្នកដទៃ យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ទើបភណ្ឌៈនេះជារបស់អញ អភិជ្ឈានោះមានទោសតិច និងមានទោសច្រើនដូចអទិន្នាទាន ។

អភិជ្ឈា មានអង្គ ២ គឺ **បរភណ្ឌំ** ភណ្ឌៈរបស់អ្នកដទៃ ១ **អត្តនោបរិណាមនំ** បង្អោនមកដើម្បីខ្លួន ១ ។

កាលសេចក្តីលោភ ក្នុងវត្ថុដែលជារបស់អ្នកដទៃ សូម្បីកើតឡើងហើយកម្មបថក៏នៅមិនទាន់ដាច់ ដរាបណាមិនទាន់បង្អោនមកដើម្បីខ្លួនថា ធ្វើម្តេចហ្ន៎ ទើបភណ្ឌៈនេះ ជារបស់អញ ។

ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ញុំាំងប្រយោជន៍ និងសេចក្តីសុខឲ្យដល់សេចក្តីវិនាស ។ ព្យាបាទនោះ មានការប្រទូស្តចិត្តដើម្បីសេចក្តីវិនាសដល់អ្នកដទៃជាលក្ខណៈ មានទោសតិច និងមានទោសច្រើនដូចផរុសវាចា ។

ព្យាបាទ មានអង្គ ២ គឺ **បរសត្តោ** សត្វដទៃ ១ **តស្ស វិនាសចិន្តា** គិតឲ្យសត្វដទៃនោះវិនាស ១ ។

កាលសេចក្តីក្រោធដែលមានសត្វដទៃជាទីតាំងកើតឡើងហើយ កម្មបថក៏មិនទាន់ដាច់ ដរាបណាមិនទាន់គិតឲ្យសត្វនោះវិនាសថា ធ្វើម្តេចហ្ន៎ បុគ្គលនេះ គប្បីវិនាសអន្តរធានហ្ន៎ ដូច្នេះ ។

ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា យល់ខុសដោយមិនមានការកាន់យកតាមសេចក្តីពិត ។ មិច្ឆាទិដ្ឋិនោះ មានលក្ខណៈឃើញវិបរិតដោយន័យថា ទានដែលឲ្យហើយមិនមានផលជាដើម មិច្ឆាទិដ្ឋិ មានទោសតិច និងទោសច្រើនដូចសម្ផប្បលាបៈម្យ៉ាងវិញទៀត អនិយតទិដ្ឋិមានទោសច្រើន ។

មិច្ឆាទិដ្ឋិ មានអង្គ ២ គឺ **វត្ថុនោ គហិតាការវិបរីតតា** ចិត្តប្រែប្រួលដោយអាការខុសអំពីវត្ថុដែលពិត ១ **យថា តំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ** គំនិតដែលយល់ខុសនោះឃើញយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះ ថាជាត្រូវ ១ ។

ក្នុងមិច្ឆាទិដ្ឋិនោះ កម្មបថដាច់ រមែងមានដោយនត្ថិកទិដ្ឋិ អហេតុកទិដ្ឋិ អកិរិយទិដ្ឋិ មិនមែនដាច់ដោយទិដ្ឋិដទៃ ។ អកុសលកម្មបថទាំង ១០ នេះ គប្បីជ្រាបវិនិច្ឆ័យដោយអាការ ៥ គឺដោយធម៌ ១ ដោយកោដ្ឋាស គឺចំណែក ១

ដោយអារម្មណ៍ ១ ដោយវេទនា ១ ដោយមូល ១ ។

ក្នុងអាការទាំងនោះ ពាក្យថា ដោយធម៌ ក្នុងអកុសលកម្មបថទាំងនោះ អកុសលកម្មបថ ៧ តាមលំដាប់ ( ពី ១ ដល់ ៧ ) អង្គធម៌ គឺចេតនានោះឯង អកុសលកម្មបថ ៣ មានអភិជ្ឈាជាដើម អង្គធម៌ជាធម៌ដែលសម្បយុត្តដោយចេតនា ។

ពាក្យថា ដោយកោដ្ឋាស អកុសលកម្មបថ ៨ គឺអកុសលកម្មបថ ៧ តាមលំដាប់ និងមិច្ឆាទិដ្ឋិជាកម្មបថតែម្យ៉ាង មិនមែនជាមូល ។ អភិជ្ឈា និងព្យាបាទជាកម្មបថផង ជាមូលផង ។ ពិតហើយ ពោលដោយមូល អភិជ្ឈាជាលោភៈជាអកុសលមូល ព្យាបាទជាទោសៈ ជាអកុសលមូល ។

ពាក្យថា ដោយអារម្មណ៍ បាណាតិបាតមានសង្ខារជាអារម្មណ៍ដោយមានជីវិតិន្ទ្រិយជាអារម្មណ៍ ។ អទិន្នាទាន មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។ មិច្ឆាចារ មានសង្ខារជាអារម្មណ៍ដោយអំណាចផោដ្ឋព្វៈ អាចារ្យពួកខ្លះពោលថា មានសត្វជាអារម្មណ៍ដូច្នេះក៏មាន ។ មុសាវាទ មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។ បិសុណាវាចាក៏យ៉ាងនោះ ។ ផរុសវាចាមានសត្វជាអារម្មណ៍តែម្យ៉ាង ។ សម្ផប្បលាបៈ មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ដោយអំណាចរូបដែលបានឃើញ សំឡេងដែលបានឮ ក្លិនរស សម្ផស្សដែលបានដឹង និងធម៌ដែលបានជ្រាប ។ អភិជ្ឈាក៏ដូច្នោះ ។ ព្យាបាទមានសត្វជាអារម្មណ៍តែម្យ៉ាង ។ មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍តែម្យ៉ាង ដោយអំណាចធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

ពាក្យថា ដោយវេទនា បាណាតិបាតជាទុក្ខវេទនា ។ ពិតហើយ ព្រះរាជាទ្រង់ឃើញចោរ សូម្បីទ្រង់សើចត្រាស់ថា នែអ្នក ពួកអ្នកចូរទៅសម្លាប់វាចុះ ដូច្នេះក៏ពិត តែចេតនាដែលសម្រេចចិត្តរបស់ព្រះរាជាទាំងឡាយ ក៏សម្បយុត្តដោយទុក្ខពិត ។ អទិន្នាទានមានវេទនា ៣ ព្រោះអទិន្នាទាននោះជាសុខវេទនាដល់អ្នកឃើញកណ្ឌះរបស់អ្នកដទៃហើយត្រេកអរលួចយកទៅ ជាទុក្ខវេទនាដល់អ្នកភ័យខ្លាចលួចយកទៅ ម្យ៉ាងទៀត កាលពិចារណាវិបាក និងផលដែលហូរមកក៏ជាទុក្ខវេទនា ជាអទុក្ខមសុខវេទនាដល់បុគ្គលដែលតាំងនៅក្នុងភាពជាកណ្តាលក្នុងវេលាលួចយកទៅ ។ មិច្ឆាចារ មានវេទនា ២ គឺសុខវេទនា និងឧបេក្ខាវេទនា ឧបេក្ខាវេទនា រមែងមិនមានក្នុងចិត្ត ដែលសម្រេចធ្វើ ។ មុសាវាទមានវេទនា ៣ ដោយន័យដូចពោលហើយក្នុងអទិន្នាទាននោះឯង ។ បិសុណាវាចាក៏យ៉ាងនោះ ។ ផរុសវាចា ជាទុក្ខវេទនា ។ សម្ផប្បលាបៈមានវេទនា ៣ ។ កាលបុគ្គលដទៃឲ្យសាធុការលើកសំពត់ជាដើមគ្រវី ឬក្នុងវេលាដែលគេត្រេកអរ ពោលរឿងដណ្តើមនាងសីតា និងការតយុទ្ធជាដើម បុគ្គលនោះរមែងមានសុខវេទនា កាលបុគ្គលម្នាក់ដែលឲ្យថ្លៃឈ្នួលមុនហើយ តែក្រោយមកពោលថា ចូរអ្នកនិយាយតាំងអំពីដើមចុះ បុគ្គលនោះ រមែងមានទុក្ខវេទនាក្នុងវេលាដែលកើតទោមនស្សពោល ដោយគិតថា អញនឹងពោលរឿងបន្តិចបន្តួចជាប់តគ្នាទៅមិនឲ្យមានសេសសល់ ឬនឹងមិនពោលហ្ន៎ រមែងជាអទុក្ខមសុខវេទនាដល់អ្នកពោលជាកណ្តាលៗ ។ អភិជ្ឈា មានវេទនា ២ ដោយអំណាចនៃសុខវេទនា និងអទុក្ខមសុខវេទនា ។ មិច្ឆាទិដ្ឋិក៏យ៉ាងនោះ ។

ព្យាបាទ ជាទុក្ខវេទនា ។

បទថា ដោយមូល បាណាតិបាតមានមូល ២ គឺទោសមូល និងមោហមូល ។ អទិន្នាទាន មានមូល ២ គឺទោសមូល និងមោហមូល ឬលោភមូល និងមោហមូល ។ មិច្ឆាចារ មានមូល ២ គឺលោភមូល និងមោហមូល ។ មុសាវាទ មានមូល ២ គឺទោសមូល និងមោហមូល ឬលោភមូល និងមោហមូល ។ បិសុណាវាចា និងសម្ផប្បលាបៈក៏យ៉ាងនោះ ។ ផរុសវាចា មានមូល ២ គឺទោសមូល និងមោហមូល ។ អភិជ្ឈាមានមូល ១ គឺមោហមូល ព្យាបាទក៏យ៉ាងនោះ ។ មិច្ឆាទិដ្ឋិ មានមូល ២ គឺលោភមូល និងមោហមូល ដោយប្រការដូច្នេះ ។

ឈ្មោះថា កុសលកម្មបថ មាន ១០ យ៉ាង គឺការវៀរចាកបាណាតិបាតជាដើម និងអនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ។ ឈ្មោះថា វិរតិ ព្រោះអត្ថថាជាហេតុវៀរចាកបាណាតិបាតជាដើម ឬការវៀរឯង ឬត្រឹមតែវៀរប៉ុណ្ណោះ ។ វិរតិដែលសម្បយុត្តដោយកុសលចិត្ត របស់អ្នកវៀរចាកបាណាតិបាតជាដើមដោយប្រភេទ មាន ៣ យ៉ាង គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។

ក្នុងវិរតិ ៣ យ៉ាងនោះ វិរតិដែលកើតដល់អ្នកមិនបានសមាទានសិក្ខាបទដែលពិចារណាដល់ជាតិ វ័យ ពាហុសច្ចៈជាដើមរបស់ខ្លួនហើយ មិនឈានកន្លងវត្ថុដែលមកដល់ ដោយគិតថា ការធ្វើបាបបែបនេះ មិនសមគួរដល់អញដូច្នេះ ឈ្មោះថា សម្បត្តវិរតិ ។ម្យ៉ាងទៀត វិរតិ ដែលកើតដល់អ្នកបាន

សមាទានសិក្ខាបទ ហ៊ានលះបង់សូម្បីជីវិតរបស់ខ្លួន ក៏មិនឈានកន្លងវត្ថុក្នុងវេលាសមាទានសិក្ខាបទ និងក្នុងវេលាតទៅ ឈ្មោះថា សមាទានវិរតិ ។ វិរតិដែលសម្បយុត្តដោយអរិយមគ្គ ឈ្មោះថា សមុច្ឆេទវិរតិ ។ សូម្បីចិត្តគិតថា អញនឹងសម្លាប់សត្វជាដើម ក៏មិនបានកើតដល់ព្រះអរិយបុគ្គល តាំងពីការកើត សមុច្ឆេទវិរតិ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យកុសលកម្មបថទាំងនេះ ដូចអកុសលកម្មបថដោយអាការ ៥ យ៉ាង គឺដោយធម៌ ១ ដោយកោដ្ឋាស ១ ដោយអារម្មណ៍ ១ ដោយវេទនា ១ ដោយមូល ១ ។

ក្នុងអាការទាំងនោះ ពាក្យថា ដោយធម៌ ក្នុងកុសលកម្មបថទាំងនោះ កុសលកម្មបថ ៧ តាមលំដាប់កើតបានទាំងចេតនា កើតបានទាំងវិរតិ កុសលកម្មបថ ៣ ខាងចុង ជាធម៌សម្បយុត្តដោយចេតនាប៉ុណ្ណោះ ។

ពាក្យថា ដោយកោដ្ឋាស ធម៌ ៧ យ៉ាង តាមលំដាប់ជាកម្មបថប៉ុណ្ណោះ មិនមែនជាមូល ធម៌ ៣ ខាងចុង ជាកម្មបថផង ជាមូលផង ។ ពិតហើយ ពោលដោយមូល អនភិជ្ឈាជាអលោភៈ ជាកុសលមូល អព្យាបាទជាអទោសៈ ជាកុសលមូល សម្មាទិដ្ឋិជាអមោហៈ ជាកុសលមូល ។

ពាក្យថា ដោយអារម្មណ៍ អារម្មណ៍របស់បាណាតិបាតជាដើមនោះឯង ជាអារម្មណ៍របស់កុសលកម្មបថទាំងនោះ ។ ចេតនាវៀរចាកវត្ថុ ដែលគប្បីឈានកន្លង ឈ្មោះថា វេរមណី ។ អរិយមគ្គ មាននិព្វានជាអារម្មណ៍ រមែងលះកិលេសទាំងឡាយយ៉ាងណា កម្មបថទាំងនោះ មានជីវិតិន្ទ្រិយជាដើម

ជាអារម្មណ៍ រមែងលះភាពជាអ្នកទ្រុស្តសីល មានបាណាតិបាតជាដើម ក៏យ៉ាងនោះ ។

ពាក្យថា ដោយវេទនា កុសលកម្មបថទាំងអស់ ជាសុខវេទនា ឬឧបេក្ខាវេទនា ។ ពិតហើយ ពោលដល់កុសលហើយ ទុក្ខវេទនា រមែងមិនមាន ។

ពាក្យថា ដោយមូល កុសលកម្មបថ ៧ តាមលំដាប់ មានមូល ៣ គឺ អលោភមូល អទោសមូល អមោហមូល របស់អ្នកវៀរដោយចិត្ត ដែលជាញាណសម្បយុត្ត ។ មានមូល ២ គឺអលោភមូល អទោសមូល របស់អ្នកវៀរដោយចិត្តដែលជាញាណវិប្បយុត្ត ។ អនភិជ្ឈា មានមូល ២ គឺអទោសមូល អមោហមូល របស់អ្នកវៀរដោយចិត្តដែលជាញាណសម្បយុត្ត ។ មានមូល ១ គឺអទោសមូល របស់អ្នកវៀរដោយចិត្តដែលជាញាណវិប្បយុត្ត ។ ចំណែកអលោភៈ មិនជាមូលរបស់ខ្លួនដោយខ្លួនឯង ។ សូម្បីក្នុងអព្យាបាទក៏មានន័យដូចគ្នា ។ សម្មាទិដ្ឋិ មានមូល ២ គឺអលោភមូល អទោសមូលនោះឯង ។

ព្រះសារីបុត្ត កាលសម្ដែងសីលដោយអំណាចនៃកុសលកម្មបថ ១០ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្ដែងធម៌ ៣៧ មាននេក្ខម្មៈជាដើម មានអរហត្តមគ្គជាទីបំផុត ទើបពោលថា **នេក្ខម្មេន កាមច្ឆន្ទំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ** ដូច្នេះជាដើម ។ ក្នុងបទនោះមានអធិប្បាយថា ព្រោះភិក្ខុសង្រួមគឺមិនឈានកន្លងកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ហេតុនោះ ទើបនេក្ខម្មៈជាសីល ។ម្យ៉ាងវិញទៀត អធិប្បាយថា នេក្ខម្មៈ ជាតតិយាវិភត្តិ ចុះក្នុងអត្ថបឋមាវិភត្តិ ។

ក្នុងបទដ៏សេស ក៏មានន័យនេះ ។ តែក្នុងបាលី លោកសម្តែងនេក្ខម្មៈ និង អព្យាបាទ ហើយសង្ខេបបទដ៏សេស ព្រោះមានន័យដូចបានពោលហើយ ខាងដើម ទើបសម្តែងអរហត្តមគ្គប៉ុណ្ណោះក្នុងទីបំផុត ។

[ ៩០ ] ព្រះសារីបុត្ត លុះសម្តែងសីលដោយអំណាចការសង្រួម និងការមិនឈានកន្លងយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងប្រភេទនៃសីលទាំងពីរយ៉ាងនោះ ទើបពោលបទថា **បញ្ច សីលានិ បាណាតិបាតស្ស បហានំ សីលំ** ដូច្នេះជាដើម ។ ក្នុងបទនេះ គប្បីប្រកបសេចក្តីថា ការលះបាណាតិបាតជាសីល ការវៀរចាកបាណាតិបាតជាសីល ចេតនាជាបដិបក្ខចំពោះបាណាតិបាតជាសីល ការសង្រួមក្នុងបាណាតិបាតជាសីល ការមិនឈានកន្លងបាណាតិបាតជាសីល ។

ឈ្មោះថា ធម៌ណាមួយក្រៅអំពីការមិនធ្វើបាណាតិបាតជាដើម ដូចពោលហើយ ឲ្យកើតឡើង ឈ្មោះថា **បហានំ** រមែងមិនមាន ព្រោះការលះនោះៗ ឈ្មោះថា ជាទីទ្រ ដោយអត្ថថា ជាទីតាំងនៃកុសលធម៌នោះៗ និងឈ្មោះថាជាទីរួបរួម ព្រោះមិនធ្វើឲ្យខ្ចាត់ខ្ចាយ ហេតុនោះ ទើបលោកពោលថា **សីលំ** ដោយអត្ថថា ជាឫសគល់ ពោលគឺជាគ្រឿងទ្រ និងជាទីរួបរួម ដូចពោលហើយក្នុងខាងដើមនោះឯង ។ ធម៌ ៤ យ៉ាងក្រៅពីនេះ លោកពោលសំដៅដល់សភាពដែលប្រព្រឹត្តទៅរបស់ចិត្ត ដោយអំណាចការវៀរចាកបាណាតិបាតនោះ ដោយការសង្រួមក្នុងបាណាតិបាតជាដើមនោះ ដោយអំណាចចេតនាដែលសម្បយុត្ត ដោយការវៀរចាក និងការសង្រួមទាំងពីរនោះ និងដោយអំណាច

ការមិនឈានកន្លងរបស់អ្នកមិនឈានកន្លងបាណាតិបាតជាដើមនោះៗ ។

ម្យ៉ាងវិញទៀត សូម្បីការលះក៏នៅមានដោយប្រក្រតីនោះឯង ។ សេចក្តីនេះដូចម្តេច ឈ្មោះថា **បហានំ** ព្រោះអត្ថថា រមែងជាហេតុលះធម៌ដែលជាសត្រូវ មានបាណាតិបាតជាដើម ឬលះធម៌ដែលជាសត្រូវនោះ ។ បហាននោះគឺអ្វី គឺកុសលក្ខន្ធទាំងអស់ ។ តែអាចារ្យពួកដទៃកាន់យកត្រឹមពាក្យថា ក្នុងនេក្ខម្មៈជាដើមវេរមណីជាសីលហើយ ទើបពោលថា ឈ្មោះថា វិរតិ ដែលជានិយតធម៌ និងជាយេវាបនកធម៌ ( ធម៌ដែលលោកពោលនៅសេសសល់ ) មាននៅសូម្បីក្នុងកុសលទាំងអស់ ក្នុងទីនេះមិនជាយ៉ាងនោះ ។ លោកពោលអបរិយន្តសីលប៉ុណ្ណោះក្នុងសីល ២ យ៉ាង គឺបរិយន្តសីល និងអបរិយន្តសីលធ្វើឲ្យពិសេសដោយបទ ៥ មានបហានជាដើម ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះសារីបុត្តពោលថា **ឯវរូបានិ សីលានិ ចិត្តស្ស អវិប្បដិសារាយ សំវត្តន្តិ ។បេ។ សច្ចិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អវិប្បដិសារាយ សំវត្តន្តិ** សេចក្តីថា រមែងប្រព្រឹត្តទៅដោយប្រពៃដើម្បីការមិនក្តៅក្រហាយ ព្រោះព្រះបាលី ( ក្នុងវិនយបិដក បរិវារ ) ថា សេចក្តីសង្រួមដើម្បីប្រយោជន៍ ដល់សេចក្តីមិនក្តៅក្រហាយចិត្ត និងបាលី ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) ថា ម្នាលអានន្ទពួកសីលជាកុសល មានអវិប្បដិសារៈ ( សេចក្តីមិនក្តៅក្រហាយ ) ជាប្រយោជន៍ មានអវិប្បដិសារៈជាអានិសង្ស ដូច្នេះ ។ ប្រព្រឹត្តទៅដើម្បីបាមោជ្ជព្រោះបាលី ( ក្នុងវិនយបិដក បរិវារ ) ថា សេចក្តីមិនក្តៅក្រហាយចិត្ត ដើម្បី

ប្រយោជន៍ដល់បាមោជ្ជ និងបាលី ( ក្នុងបដិសម្ភិទាមគ្គ ) ថា កាលបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនងថាមិនទៀង បាមុជ្ជរមែងកើត ដូច្នេះ ។ ប្រព្រឹត្តទៅដើម្បីបីតិ ព្រោះបាលី ( ក្នុងវិនយបិដក បរិវារ ) ថា បាមោជ្ជដើម្បីប្រយោជន៍ដល់បីតិ និងបាលី ( ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ) ថា កាលបើមានបាមោជ្ជហើយ បីតិក៏កើតឡើង ដូច្នេះ ។ ប្រព្រឹត្តទៅដើម្បីបស្សទ្ធិ ព្រោះបាលី ( ក្នុងវិនយបិដក បរិវារ ) ថា បីតិដើម្បីប្រយោជន៍ដល់បស្សទ្ធិ និងបាលី ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយរមែងស្ងប់ស្ងាត់ ដូច្នេះ ។ ប្រព្រឹត្តទៅដើម្បីសោមនស្ស ព្រោះបាលី ( ក្នុងវិនយបិដក បរិវារ ) ថា បស្សទ្ធិដើម្បីប្រយោជន៍ដល់សុខ និងបាលី ( ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ) ថា កាលបើមាននាមកាយស្ងប់រម្ងាប់ហើយរមែងទទួលសេចក្តីសុខ ដូច្នេះ ។ ព្រោះសេចក្តីសុខផ្លូវចិត្ត លោកពោលថាជាសោមនស្ស ។

បទថា **អាសេវនាយ** មានវិគ្គហៈថា ការសេពយ៉ាងធ្ងន់ ឈ្មោះថា ការសេពដោយអើពើ ។ សួរថា សេពអ្វី ឆ្លើយថា សេពសេចក្តីសុខ ដែលសម្រេចហើយ ព្រោះសេចក្តីសុខ លោកពោលដោយពាក្យថា សោមនស្សក្នុងលំដាប់ ។ សមាធិរមែងសម្រេចហើយដោយសេចក្តីសុខនោះ ព្រោះបាលី ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា លុះប្រកបសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ដូច្នេះ ។ សេពសមាធិដែលសម្រេចហើយ ដោយប្រការដូច្នេះ ។ រមែងប្រព្រឹត្តទៅដើម្បីការសេពដោយអើពើនូវសមាធិនោះ អធិប្បាយថា សីល

ទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីឲ្យសមាធិស្អាតជំនាញ និងមានកម្លាំង ។

បទថា **ភាវនាយ** បានដល់ ដើម្បីសេចក្ដីចម្រើនរបស់សមាធិនោះឯង ។ បទថា **ពហុលកម្មាយ** បានដល់ ដើម្បីធ្វើសមាធិនោះឯងរឿយៗ ។ ប្រព្រឹត្តទៅដើម្បីអលង្ការ ព្រោះជាមូលហេតុនៃការប្រព្រឹត្តទៅ មានការមិនក្ដៅក្រហាយជាដើម ឲ្យសម្រេចជាគ្រឿងប្រដាប់ មានសទ្ធិន្ទ្រិយជាដើម របស់សមាធិ ។ ប្រព្រឹត្តទៅដើម្បីជាបរិក្ខារ ព្រោះឲ្យសម្រេចសម្ភាររបស់សមាធិ មានការមិនក្ដៅក្រហាយជាដើម ។ **បរិក្ខារ** សព្ទ ក្នុងបទនេះ មានអត្ថថា អង្គប្រកប ដូចក្នុងប្រយោគជាដើមថា **យេ ច ខោ ឥមេ បព្ពជិតេន ជីវិតបរិក្ខារា សមុ-ទានេតព្វា** គ្រឿងបម្រុងជីវិត ( គឺចីវរ បិណ្ឌបាត សេនាសនៈ និងគិលា-នប្បច្ចយភេសជ្ជបរិក្ខារណាមួយនេះ ) ដែលបព្វជិតគប្បីប្រមូលមក ដូច្នេះ ។

មានអត្ថថា គ្រឿងប្រដាប់ ដូចក្នុងប្រយោគជាដើមថា **រថោ សីល-បរិក្ខារោ ឈានក្ខោ ចក្កវីរិយោ** រថ គឺអរិយមគ្គ ( នោះ ) មានសីលជាគ្រឿងពាស មានឈានជាកេ□មានវីរិយៈជាកង□ដូចេ□ ។

មានអត្ថថា បរិវារ ដូចក្នុងប្រយោគជាដើមថា **សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ** នគរនៃស្ដេចជាទីបំផុតនៃដែនដែលរៀបចំល្អហើយដោយនគរបរិក្ខារ ៧ យ៉ាង ដូច្នេះ ។ តែក្នុងទីនេះ លោកពោលបរិក្ខារសព្ទ មានអត្ថថា របស់ប្រើ ព្រោះគ្រឿងប្រដាប់ និងបរិវារញែកគ្នាហើយ ។ម្យ៉ាងវិញទៀត អត្ថថា អង្គប្រកប គឺអត្ថថា ជាបច្ច័យ ។ ប្រព្រឹត្តទៅដើម្បីបរិវារ ដោយឲ្យសម្រេចធម្មសម្បត្តិ មានផស្សៈជាដើមដែលសម្បយុត្តដោយសមាធិ ដោយ

ភាពជាមូលហេតុនោះឯង ។ ប្រព្រឹត្តទៅដើម្បីបំពេញ ព្រោះឲ្យសម្រេចភាពបរិបូរណ៍ ដោយឲ្យដល់ភាពជាបទដ្ឋាននៃសមាធិ និងវិបស្សនា និងដោយឲ្យដល់ភាពជាអ្នកជំនាញ ។

ព្រះសារីបុត្ត កាលសម្តែងសមាធិ ដែលបរិបូរណ៍ដោយអាការទាំងពួង ដោយមានសីលជាឧបនិស្ស័យយ៉ាងនេះហើយ ឥឡូវនេះ កាលសម្តែងយថាភូតញ្ញាណទស្សនៈជាដើម ដែលជាបទដ្ឋានរបស់សមាធិ ដែលមានសីលជាមូល ព្រោះបាលី ( ក្នុងបដិសម្ភិទាមគ្គ ) ថា កាលបើចិត្តតម្កល់មាំ បុគ្គលរមែងដឹង រមែងឃើញតាមពិត កាលបុគ្គលដឹង ឃើញតាមពិត រមែងនឿយណាយ កាលបុគ្គលនឿយណាយ រមែងធុញទ្រាន់ បុគ្គលផុតស្រឡះ ព្រោះតែការធុញទ្រាន់ ដូច្នេះ ។ ទើបពោលបទថា **ឯកត្តនិព្វិទាយ** ជាដើម កាលសម្តែងការនឿយណាយហើយ ក៏ឈ្មោះថា សម្តែងយថាភូតញ្ញាណទស្សនៈ ដែលជាបទដ្ឋាននៃសេចក្តីនឿយណាយនោះ ។ កាលយថាភូតញ្ញាណទស្សនៈនោះនៅមិនទាន់សម្រេច ការនឿយណាយក៏មិនទាន់សម្រេច ។ បទទាំងនោះមានអត្ថដូចបានពោលហើយនោះឯង ។ តែក្នុងទីនេះ យថាភូតញ្ញាណទស្សនៈ បានដល់ ការកំណត់នាមរូប ព្រមទាំងបច្ច័យ ។

ព្រះសារីបុត្ត កាលសម្តែងដល់ប្រយោជន៍របស់សីលដែលមានអមតមហានិព្វានជាទីបំផុតយ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្តែងភាពដែលសីលនោះ ជាអធិសីលសិក្ខា និងសម្តែងអធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ដែលមានអធិសីលសិក្ខាជាមូលទើបពោលបទថា **ឯវរូបានំ សីលានំ សំវរបារិសុទ្ធិ**

**អធិសីលំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ សេចក្តីបរិសុទ្ធ គឺការសង្រួម ឈ្មោះថា **សំវរបារិសុទ្ធិ** ការបរិសុទ្ធដោយការសង្រួមនៃសីលដែលអាស្រ័យវិវដ្ដៈដែលជាសីលមិនមានទីបំផុតបែបនេះ ហៅថា ជាអធិសីល ព្រោះជាសីលក្រៃលែងជាងសីលដ៏សេស ព្រោះអាស្រ័យវិវដ្ដៈ ។

បទថា **សំវរបារិសុទ្ធិយា ឋិតំ ចិត្តំ** សេចក្តីថា ចិត្តដែលតាំងនៅក្នុងសេចក្តីបរិសុទ្ធដោយការសង្រួមសីលបែបនេះ រមែងមិនដល់នូវការរាយមាយ ព្រោះនាំការមិនក្តៅក្រហាយជាដើម មកដោយល្អ អធិប្បាយថា តាំងមាំនៅក្នុងសមាធិ ។

សេចក្តីបរិសុទ្ធ គឺការមិនរាយមាយ ឈ្មោះថា **អវិក្ខេបបារិសុទ្ធិ** ។ សមាធិដែលជាចំណែកនៃការបោក់ច្ចុះវៀរចាកមន្ទិលទាំងពួង ហៅថា **អធិចិត្តំ** ព្រោះជាសមាធិក្រៃលែងជាងសមាធិដ៏សេស ។ ក្នុងបទនេះ លោកសម្តែងសមាធិដោយសំដៅដល់ចិត្តជាធំ ។

បទថា **សំវរបារិសុទ្ធឹ សម្មា បស្សតិ** សេចក្តីថា រមែងឃើញការសង្រួមសីលដែលបរិសុទ្ធដោយប្រពៃ ដោយអំណាចនៃញាតប្បរិញ្ញា និងតីរណប្បរិញ្ញា រមែងឃើញសមាធិដ៏បរិសុទ្ធ ពោលគឺអវិក្ខេបបារិសុទ្ធិ ដោយប្រពៃនោះឯង ។ កាលព្រះយោគាវចរឃើញយ៉ាងនោះ សេចក្តីបរិសុទ្ធ ពោល គឺការឃើញ ឈ្មោះថា ទស្សនបារិសុទ្ធិ ។

ទស្សនបារិសុទ្ធិនោះឯង ហៅថា អធិប្បញ្ញា ព្រោះជាបញ្ញាក្រៃលែងជាងបញ្ញាដ៏សេស ។

បទថា **យោ តត្ថ** បានដល់ ក្នុងការសង្រួម ការមិនរាយមាយ និងទស្សនៈនោះ ។ បទថា **សំវរដ្ឋោ** បានដល់ ភាវៈនៃការសង្រួម ។

គប្បីជ្រាបការមិនរាយមាយ និងការឃើញក៏យ៉ាងនោះដូចគ្នា ។ សិក្ខាគឺអធិសីលនោះឯង ឈ្មោះថា **អធិសីលសិក្ខា** ។ សូម្បីសិក្ខាក្រៅអំពីនោះ ក៏គប្បីជ្រាបយ៉ាងនេះ ។

ព្រះសារីបុត្តកាលសម្តែងសិក្ខា ៣ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងដល់លំដាប់របស់សិក្ខាទាំងនោះឲ្យបរិបូរណ៍ ទើបពោលបទថា **ឥមា តិស្សោ សិក្ខាយោ អាវជ្ជេន្តោ សិក្ខតិ** ដូច្នេះជាដើម ។ បទនោះ មានអធិប្បាយដូចតទៅនេះថា ព្រះយោគាវចរសូម្បីកាលនឹកដល់ ដើម្បីញុំាងសិក្ខានីមួយៗ ឲ្យបរិបូរណ៍ ក៏ឈ្មោះថា សិក្សា លុះនឹកដល់ហើយ សូម្បីដឹងថា សិក្ខាឈ្មោះយ៉ាងនេះ ក៏ឈ្មោះថា សិក្សា លុះដឹងហើយ សូម្បីឃើញញយៗ ក៏ឈ្មោះថា សិក្សា លុះឃើញហើយ សូម្បីពិចារណាតាមដែលឃើញ ក៏ឈ្មោះថា សិក្សា កាលពិចារណាហើយ សូម្បីតាំងមាំធ្វើចិត្តមិនឲ្យញាប់ញ័រក្នុងសិក្ខានោះ ក៏ឈ្មោះថា សិក្សា សូម្បីធ្វើកិច្ចរបស់ខ្លួនដោយសទ្ធា វីរិយៈ សតិ សមាធិ និងបញ្ញាដែលសម្បយុត្តដោយសិក្ខានោះៗ ក៏ឈ្មោះថា សិក្សា កាលធ្វើកិច្ចនោះៗ សូម្បីក្នុងកាលមានសេចក្តីដឹងដ៏ក្រៃលែង ក្នុងវត្ថុដែលគួរដឹងក្រៃលែងជាដើម ក៏ឈ្មោះថា សិក្សាសិក្ខាទាំង ៣ យ៉ាង ។

[ ៩១ ] បទថា **បញ្ច សីលានិ** ជាដើម មួយទៀត មានសេចក្តីដូចបានពោលហើយនោះឯង ។ ម្យ៉ាងវិញទៀត គប្បីជ្រាបសេចក្តី ក្នុងបទថា

**អរហាត្តមគ្គេន សព្វកិលេសានំ** ដូចតទៅនេះថា បទទាំងនោះត្រឹមត្រូវហើយ ព្រោះមិនមានការក្តៅក្រហាយជាដើម និងព្រោះមានការសេពដោយអើពើជាដើម ដោយល្អរបស់ព្រះអរហន្តទាំងឡាយ ។

គប្បីប្រកបបទថា **ឯកគ្គចិត្តានំ** ជាដើម ក្នុងខណៈនៃមគ្គនោះឯង ដូចសតិប្បដ្ឋាន និងសម្មប្បធាន ។

គប្បីប្រកបពាក្យទាំងពីរនេះថា **សំវរចារិសុទ្ធី សម្មា បស្សតិ អវិក្ខេបចារិសុទ្ធី សម្មា បស្សតិ** ដោយអំណាចនៃវិបស្សនាដើម្បីប្រយោជន៍ដល់ផលសមាបត្តិ ។ ចំណែកពាក្យទីពីរ រមែងត្រឹមត្រូវ ដោយអំណាចនៃវិបស្សនាដើម្បីប្រយោជន៍ដល់និរោធសមាបត្តិ ។ ក្នុងពាក្យទាំង ៥ មានពាក្យថា **អារជ្ជេន្តោ សិក្ខតិ** ជាដើម គប្បីជ្រាបថា លោកពោលថា **សិក្ខតិ** ព្រោះមានសីលក្ខន្ធរបស់ព្រះអសេក្ខៈជាដើម ជាសភាវៈ ព្រោះព្រះអរហន្តមិនមានវត្ថុដែលត្រូវសិក្សា ។

បទថា **សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ** ជាដើម លោកពោលសំដៅដល់ខណៈនៃមគ្គនោះឯង ។ គប្បីប្រកបពាក្យសូម្បីដទៃ ដែលលោកពោលដោយអំណាចនៃឧបចារៈ អប្បនា វិបស្សនា និងមគ្គតាមដែលប្រកបបាន ។

## អដ្ឋកថាសីលមយញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
## បឋមភាគ

*សូមនមស្ការ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

*[ ៩២ ] បញ្ញាក្នុងការសង្រួមហើយតម្កល់ទុក ឈ្មោះថា សមាធិភាវនាមយញ្ញាណ តើដូចម្តេច សមាធិ ១ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ។ សមាធិ ២ គឺលោកិយសមាធិ ១ លោកុត្តរសមាធិ ១ ។ សមាធិ ៣ គឺ សមាធិប្រកបដោយវិតក្ក ប្រកបដោយវិចារ ១ សមាធិដែលមិនមានវិតក្ក មានតែវិចារ ១ សមាធិដែលមិនមានវិតក្ក មិនមានវិចារ ១ ។ សមាធិ ៤ គឺសមាធិគប់រកនូវសេចក្តីសាបសូន្យ ១ សមាធិគប់រកនូវការតាំងនៅ ១ សមាធិគប់រកនូវគុណវិសេស ១ សមាធិគប់រកនូវការទម្លាយកិលេស ១ ។ សមាធិ ៥ គឺការផ្សាយនៃបីតិ ១ ការផ្សាយនៃសេចក្តីសុខ ១ ការផ្សាយនៃចិត្ត ១ ការផ្សាយនៃពន្លឺ ១ ការកំណត់នូវការពិចារណា ១ ។ សមាធិ ៦ គឺចិត្តជាឯកគ្គតាដោយអំណាចពុទ្ធានុស្សតិ ឈ្មោះថា អវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតា ដោយអំណាចធម្មានុស្សតិ ឈ្មោះថា អវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតាដោយអំណាចនៃសង្ឃានុស្សតិ ឈ្មោះថា អវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតាដោយអំណាចនៃសីលានុស្សតិ ឈ្មោះថា អវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតាដោយអំណាចនៃចាគានុស្សតិ ឈ្មោះថា អវិក្ខេបសមាធិ ១ ចិត្តជា*

ឯកគ្គតាដោយអំណាចនៃទេវតានុស្សតិ ឈ្មោះថា អវិក្ខេបសមាធិ ១ ។ សមាធិ ៧ គឺភាពនៃសេចក្ដីឈ្លាសវៃ ក្នុងសមាធិ ១ ភាពនៃសេចក្ដីឈ្លាសវៃក្នុងការចូលកាន់សមាធិ ១ ភាពនៃសេចក្ដីឈ្លាសវៃ ក្នុងការតាំងនៅក្នុងសមាធិ ១ ភាពនៃសេចក្ដីឈ្លាសវៃ ក្នុងការចេញចាកសមាធិ ១ ភាពនៃសេចក្ដីឈ្លាសវៃក្នុងសេចក្ដីស្រួលក្នុងសមាធិ ១ ភាពនៃសេចក្ដីឈ្លាសវៃក្នុងអារម្មណ៍នៃសមាធិ ១ ភាពនៃសេចក្ដីឈ្លាសវៃក្នុងការប្រមូលមកនូវសមាធិ ១ ។ សមាធិ ៨ គឺចិត្តជាឯកគ្គតាដោយអំណាចនៃបឋវីកសិណ ឈ្មោះថា អវិក្ខេបសមាធិ ១ ដោយអំណាចនៃអាបោកសិណ ១ ។បេ។ ដោយអំណាចនៃតេជោកសិណ ១ ដោយអំណាចនៃវាយោកសិណ ១ ដោយអំណាចនៃនីលកសិណ ១ ដោយអំណាចនៃបីតកសិណ ១ ដោយអំណាចនៃលោហិតកសិណ ១ ចិត្តជាឯកគ្គតាដោយអំណាចនៃឱទាតកសិណ ឈ្មោះថា អវិក្ខេបសមាធិ ១ ។ សមាធិ ៩ គឺរូបាវចរសមាធិជាន់ទាប ១ ជាន់កណ្ដាល ១ ជាន់ខ្ពស់ ១ អរូបាវចរសមាធិជាន់ទាប ១ ជាន់កណ្ដាល ១ ជាន់ខ្ពស់ ១ សុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ សមាធិ ១០ គឺចិត្តជាឯកគ្គតាដោយអំណាចនៃឧទ្ធុមាតកសញ្ញា ឈ្មោះថា អវិក្ខេបសមាធិ ១ ដោយអំណាចនៃវិនីលកសញ្ញា ១ ។បេ។ ដោយអំណាចវិបុព្វកសញ្ញា ១ ដោយអំណាចវិច្ឆិទ្ទកសញ្ញា ១ ដោយអំណាចវិក្ខាយិតកសញ្ញា ១ ដោយអំណាចវិក្ខិត្តកសញ្ញា ១ ដោយអំណាចហតវិក្ខាយិតកសញ្ញា ១ ដោយអំណាចលោហិតកសញ្ញា ១ ដោយអំណាចបុឡុវកសញ្ញា ១ ចិត្តជាឯកគ្គតាដោយអំណាចអដ្ឋិកសញ្ញា ឈ្មោះថា

អវិក្ខេបសមាធិ ១ នេះសមាធិ ៥៥ ។

[ ៩៣ ] ម្យ៉ាងទៀត អត្ថក្នុងសមាធិនៃសមាធិមាន ២៥ គឺសមាធិ ដោយអត្ថថា កំណត់ ១ សមាធិ ដោយអត្ថថា ជាបរិវារ ១ សមាធិ ដោយអត្ថថា ពេញលេញ ១ សមាធិ ដោយអត្ថថា មានអារម្មណ៍តែមួយ ១ សមាធិ ដោយអត្ថថា មិនរាយមាយ ១ សមាធិ ដោយអត្ថថា មិនប្រាសចាកខ្លឹមសារ ១ សមាធិ ដោយអត្ថថា មិនល្អក់ ១ សមាធិ ដោយអត្ថថា មិនញាប់ញ័រ ១ សមាធិ ដោយអត្ថថា ផុតស្រឡះ ១ ភាពនៃចិត្តតាំងនៅដោយអំណាចនៃការតាំងនៅក្នុងអារម្មណ៍តែមួយ ឈ្មោះថា សមាធិ ១ សភាវៈដែលស្វែងរកនូវការស្ងប់ ឈ្មោះថា សមាធិ ១ សភាវៈដែលមិនស្វែងរកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌ស្វែងរកនូវការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌មិនស្វែងរកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ សភាវៈដែលកាន់យកនូវការស្ងប់ ឈ្មោះថា សមាធិ ១ សភាវៈដែលមិនកាន់យកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌កាន់យកនូវការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌មិនកាន់យកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ សភាវៈដែលដើរទៅកាន់ការស្ងប់ ឈ្មោះថា សមាធិ ១ សភាវៈដែលមិនដើរទៅកាន់ធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌ដែលដើរទៅកាន់ការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌ដែលមិនដើរទៅកាន់ធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ សភាវៈដែលផុតនូវការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌ដែលផុតនូវធម៌ប្រាស

ចាកការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌ដែលដុតនូវការស្ងប់ ឈ្មោះថា សមាធិ ១ ភាពនៃធម៌ដែលដុតនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថា សមាធិ ១ ធម៌មានសភាពស្ងប់ផង មានប្រយោជន៍ផង មានសេចក្តីសុខផង ឈ្មោះថា សមាធិ នេះអត្ថក្នុងសមាធិរបស់សមាធិ ២៥ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការសង្រួម ហើយតម្កល់ទុក ឈ្មោះថា សមាធិភាវនាមយញ្ញាណ ។

# អដ្ឋកថា

## សមាធិការនាមយញ្ញាណនិទ្ទេស

[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិការនាមយញ្ញាណនិទ្ទេសដូចតទៅ ព្រះសារីបុត្ត កាលសម្ដែងប្រភេទរបស់សមាធិ ផ្ដើមតាំងអំពីពួក ១ រហូតដល់ពួក ១០ ទើបពោលបទថា **ឯកោ សមាធិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ចិត្តស្ស ឯកគ្គតា** សេចក្ដីថា ឈ្មោះថា **ឯកគ្គ** ព្រោះអត្ថថា មានអារម្មណ៍ដ៏ប្រសើរ គឺយ៉ាងខ្ពង់ខ្ពស់ ព្រោះមិនមានការរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ ភាពនៃ **ឯកគ្គ** នោះ ឈ្មោះថា **ឯកគ្គតា** ដើម្បីសម្ដែងថា ឯកគ្គតានោះ មានដល់ចិត្ត មិនមែនមានដល់សត្វ ទើបលោកពោលថា **ចិត្តស្ស** ។

ក្នុងពួកទី ២ បទថា **លោកិយោ** មានវិនិច្ឆ័យថា វដ្ដៈ ហៅថា **លោក** ដោយអត្ថថា បែកធ្លាយ សមាធិប្រកបហើយក្នុងលោក ដោយភាពជាសមាធិទាក់ទងនៅក្នុងវដ្ដៈនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **លោកិយ** ។

បទថា **លោកុត្តរោ** មានវិគ្គហៈថា ឈ្មោះថា **ឧត្តរ** ព្រោះឆ្លងឡើងហើយ ឈ្មោះថា **លោកុត្តរ** ព្រោះឆ្លងចាកលោកដោយភាពជាសមាធិ មិនទាក់ទងនៅក្នុងលោក ។

ក្នុងពួក ៣ ឈ្មោះថា **សវិតក្កសវិចារោ** ព្រោះសមាធិនោះ មានវិតក្កផង មានវិចារផង ។ សមាធិមិនមានវិតក្ក មិនមានវិចារ ក៏មានទំនងដូចគ្នា ។

ក្នុងសមាធិដែលមានវិតក្កៈ និងវិចារ ឈ្មោះថា **វិចារមត្តោ** ព្រោះអត្ថថា មានត្រឹមតែវិចារប៉ុណ្ណោះជាប្រមាណ អធិប្បាយថា សមាធិមិនដល់នូវការប្រកបរួមគ្នាជាមួយវិតក្កៈ ក្រៃលែងជាងវិចារ ។ ឈ្មោះថា **អវិតក្កវិចារ-មត្តោ** ព្រោះអត្ថថា សមាធិនោះមិនមានវិតក្កៈ មានត្រឹមតែវិចារ ។ សូម្បីក្នុងសមាធិ ៣ យ៉ាង អាចារ្យពួកខ្លះក៏ពោលកាត់ចេញ ។

ពួក ៤ ពួក ៥ មានអធិប្បាយទុកហើយ ។ ក្នុងពួក ៦ សតិនោះឯង ព្រោះកើតឡើងរឿយៗ ទើបឈ្មោះថា **អនុស្សតិ** ម្យ៉ាងទៀត ឈ្មោះថា **អនុស្សតិ** ព្រោះការរឭកសមគួរដល់កុលបុត្តអ្នកបួសដោយសទ្ធា ព្រោះឲ្យប្រព្រឹត្តទៅក្នុងឋានៈដែលគួរឲ្យប្រព្រឹត្តទៅខ្លះ **អនុស្សតិ** ដែលកើតឡើងប្រារព្ធព្រះពុទ្ធ ឈ្មោះថា **ពុទ្ធានុស្សតិ** បទនេះ ជាឈ្មោះរបស់សតិ ដែលមានគុណព្រះពុទ្ធជាអរហន្តជាដើមជាអារម្មណ៍ ។ ឈ្មោះថា **អវិក្ខេបោ** ព្រោះអត្ថថា មិនរាយមាយ ដ្បិតជាបដិបក្ខចំពោះការរាយមាយដែលបានដល់ **ឧទ្ធច្ចៈ** គឺភាពដែលចិត្តមានអារម្មណ៍តែមួយ ដោយអំណាចពុទ្ធានុស្សតិនោះ ។

អនុស្សតិដែលកើតឡើង ព្រោះប្រារព្ធព្រះធម៌ ឈ្មោះថា **ធម្មានុស្សតិ** បទនេះ ជាឈ្មោះនៃសតិមានគុណរបស់ព្រះធម៌ មាន **ស្វាក្ខាតោ** ជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងប្រារព្ធព្រះសង្ឃ ឈ្មោះថា **សង្ឃានុស្សតិ** បទនេះ ជាឈ្មោះរបស់សតិ ដែលមានគុណរបស់ព្រះសង្ឃ មាន **សុបដិបន្នោ** ជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងប្រារព្ធសីល ឈ្មោះថា **សីលានុស្សតិ** បទនេះ ជាឈ្មោះរបស់សតិ មានគុណរបស់សីល មានសីលរបស់ខ្លួនមិនដាច់ ជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងប្រារព្ធចាគៈ ឈ្មោះថា **ចាគានុស្សតិ** បទនេះ ជាឈ្មោះរបស់សតិ មានគុណរបស់ចាគៈ មានភាពដែលខ្លួនលះបង់ទៅហើយជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងប្រារព្ធទេវតាទាំងឡាយ ឈ្មោះថា **ទេវតានុស្សតិ** បទនេះ ជាឈ្មោះរបស់សតិ មានគុណ មានសទ្ធាជាដើម របស់ខ្លួនជាអារម្មណ៍ ដោយតាំងទេវតាទុកក្នុងឋានៈជាបន្ទាល់ ។

ក្នុងពួក ៧ បទថា **សមាធិកុសលតា** បានដល់ សភាពជាអ្នកឈ្លាសក្នុងសមាធិដែលមានច្រើនប្រភេទ ដោយប្រភេទ មានសមាធិ ១ ជាដើមថា នេះជាសមាធិយ៉ាងនេះ នេះជាសមាធិយ៉ាងនេះ ។ បទនេះ ជាឈ្មោះរបស់បញ្ញាកំណត់ដឹងសមាធិ ។ ភាពជាអ្នកច្លាតដោយវិធីធ្វើឲ្យសមាធិកើត ក៏ឈ្មោះថា ភាពជាអ្នកឈ្លាសក្នុងសមាធិ ។

បទថា **សមាធិស្ស សមាបត្តិកុសលតា** បានដល់ ភាពជាអ្នកឈ្លាសក្នុងការចូលសមាធិដែលធ្វើឲ្យកើតហើយ ។ ពាក្យនោះ លោកពោលដល់ភាពជាអ្នកជំនាញក្នុងការចូលសមាធិ ។

បទថា **សមាធិស្ស ឋិតិកុសលតា** បានដល់ ភាពជាអ្នកឈ្លាសក្នុងការតាំងនៅក្នុងសមាធិដែលចូលហើយតាមគាប់ចិត្ត ដោយអំណាចការបន្តគ្នា

ទៅ ។ ពាក្យនេះលោកពោលដល់ភាពជាអ្នកជំនាញក្នុងការអធិដ្ឋាន ។ ម្យ៉ាង វិញទៀត កាលព្រះយោគាវចរនោះ ញុំាងអាការទាំងនោះឲ្យដល់ព្រម ដោយ ការកាន់យកនិមិត្ត រមែងសម្រេចត្រឹមតែអប្បនាប៉ុណ្ណោះ មិនយឺតយូរ ។ ចំណែកឋានៈដែលយឺតយូរ រមែងមានព្រោះជម្រះធម៌ដែលជាអន្តរាយ ដល់ សមាធិល្អហើយ ។ ពិតហើយ ភិក្ខុណាគ្របសង្កត់កាមច្ឆន្ទៈ ដោយការ ពិចារណាទោសរបស់កាមជាដើម ដោយល្អមិនបាន ការធ្វើសេចក្ដីក្រោតក្រោត ផ្លូវកាយឲ្យស្ងប់ដោយល្អដោយកាយបស្សទ្ធិមិនបាន បន្ទោបង់ថីនមិទ្ធៈដោយ មនសិការដល់អារម្ភធាតុ ( សេចក្ដីព្យាយាម ) ឲ្យល្អមិនបាន ដកឧទ្ធច្ចកុក្កុច្ចៈ ដោយមនសិការដល់សមថនិមិត្តឲ្យល្អមិនបាន ជម្រះធម៌ដែលជាអន្តរាយរបស់ សមាធិឲ្យល្អមិនបានហើយចូលឈាន ភិក្ខុនោះរមែងចេញចាកឈាន ដោយ រហ័សដូចភមរជាតិ ចូលទៅកាន់កន្លែងដែលមិនស្អាត និងដូចព្រះរាជាចូលទៅ កាន់ឧទ្យានដែលស្មោគគ្រោគរមែងចេញទៅដោយរហ័ស ។ ចំណែកភិក្ខុណា ជម្រះធម៌ដែលជាអន្តរាយដល់សមាធិបានល្អហើយចូលឈាន ភិក្ខុនោះរមែង ចូលឈានខាងក្នុងសមាបត្តិបាន រហូតអស់ថ្ងៃ ដូចភមរជាតិចូលទៅកាន់ទី អាស្រ័យដែលស្អាត និងដូចព្រះរាជាចូលទៅកាន់ឧទ្យានដែលល្អស្អាត រមែង នៅបានរហូតអស់ថ្ងៃ ។ ដូចបុរាណាចារ្យពោលថា

ព្រះយោគាវចរ អ្នកមានឆន្ទៈ ធ្វើនូវបាមោជ្ជក្នុងវិវេក គប្បី
បន្ទោបង់នូវសេចក្ដីពេញចិត្តក្នុងកាមទាំងឡាយ ការអាក់អន់
ការរាយមាយ ការរួញរា និងសេចក្ដីសង្ស័យជាគម្រប់ ៥ ដូច

*ព្រះរាជាចូលទៅកាន់ទីដែលស្អាត ទ្រង់គប្បីពេញព្រះហឫទ័យក្នុងទីនោះ ។*

*ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា ភាពជាអ្នកឈ្លាសក្នុងការញុំាងវិធីនោះឲ្យដល់ព្រម ហើយធ្វើសមាធិឲ្យតាំងនៅយូរ ព្រោះលោកពោលថា ព្រះយោគាវចរដែលបំណងនឹងឲ្យសមាធិ តាំងនៅបានយូរ គប្បីជម្រះធម៌ដែលជាសត្រូវហើយ សឹមចូលឈាន ។ បទថា* **សមាធិស្ស វុដ្ឋានកុសលតា** *បានដល់ ភាពជាអ្នកឈ្លាសក្នុងការចេញចាកសមាធិ ដោយការចេញចាកសមាធិដែលប្រព្រឹត្តទៅហើយតាមការពេញចិត្ត ដោយការបន្តគ្នាទៅក្នុងវេលាតាមដែលកំណត់នោះឯង ។ គប្បីជ្រាបថា លោកធ្វើជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ ដូចក្នុងប្រយោគជាដើមថា* **យស្មា ហិ ធម្មំ បុរិសោ វិជញ្ញា** *បុរសចេះដឹងនូវធម៌ ( អំពីសម្នាក់ ) នៃអាចារ្យណា ដូច្នេះ ។ ដោយពាក្យនេះ លោកពោលដល់ភាពជាអ្នកជំនាញក្នុងការចេញចាកសមាធិ ។*

*បទថា* **សមាធិស្ស កល្លតាកុសលតា** *សេចក្តីថា ការមិនមានជំងឺ ការមិនមានរោគ ឈ្មោះថា* **កល្លតា។** *អ្នកឈឺ លោកហៅថា* **អកល្លក** *សូម្បីក្នុងវិន័យលោកក៏ពោលថា* **នាហំ ភន្តេ អកល្លកោ** *បពិត្រលោកម្ចាស់ ខ្ញុំមិនឈឺទេ ដូច្នេះ ។ ភាពជាអ្នកឈ្លាសក្នុងការធ្វើនូវការមិនមានអាពាធនៃសមាធិ ដោយការមិនមានសេចក្តីប្រាថ្នាដ៏លាមក ដែលជាសត្រូវនៃការបានឈាន ដូចដែលលោកពោលក្នុងអនង្គណសូត្រ និងវត្ថសូត្រ ( វត្ថូបមសូត្រ ) និងដោយការប្រាសចាកឧបក្កិលេសនៃចិត្ត មានអភិជ្ឈាជាដើម*

ឈ្មោះថា ភាពជាអ្នកឈ្លាសវៃក្នុងសេចក្ដីស្រួលក្នុងសមាធិ អធិប្បាយថា ភាពជាអ្នកឈ្លាសក្នុងការវៀរចាកនូវអាពាធ គឺកិលេស ។

ម្យ៉ាងទៀត បទថា **កល្លតា** បានដល់ ភាពជាអ្នកគួរដល់ការងារ ព្រោះពាក្យថា **កល្ល** ជាពាក្យពោលដោយអមនៃ **កម្មញ្ញតា** ដូចលោកពោលថា **យា ចិត្តស្ស អកល្យតា អកម្មញ្ញតា** ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារណានៃចិត្ត ដូច្នេះ និងព្រះតម្រាស់ថា **កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ** មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ ដូច្នេះ ។ **កល្ល** សព្ទក្នុងបទនេះមានសេចក្ដីថា គួរដល់ការងារ ។ ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា ភាពជាអ្នកឈ្លាសក្នុងការធ្វើសមាធិឲ្យគួរដល់ការងារ ដោយការទូន្មានចិត្តដោយអាការទាំង ១៤ យ៉ាងនេះ គឺដោយអនុលោមនៃកសិណ ១ ដោយបដិលោមនៃកសិណ ១ ដោយអនុលោមបដិលោមនៃកសិណ ១ ដោយអនុលោមនៃឈាន ១ ដោយបដិលោមនៃឈាន ១ ដោយអនុលោម-បដិលោមនៃឈាន ១ ដោយការកន្លងឈាន ១ ដោយការកន្លងកសិណ ១ ដោយការកន្លងឈាន និងកសិណ ១ ដោយការប្ដូរអង្គ ១ ដោយការប្ដូរអា-រម្មណ៍ ១ ដោយការប្ដូរអង្គ និងអារម្មណ៍ ១ ដោយការកំណត់អង្គ ១ ដោយការកំណត់អារម្មណ៍ ១ ឬដោយអាការ ១៥ បន្ថែមពាក្យថា ដោយកំណត់អង្គ និងអារម្មណ៍ ។

បទថា **សមាធិស្ស គោចរកុសលតា** សេចក្ដីថា ភាពជាអ្នកឈ្លាសក្នុងគោចរ គឺក្នុងអារម្មណ៍ មានកសិណជាដើមនៃសមាធិ គឺភាពជាអ្នកឈ្លាស

ក្នុងអារម្មណ៍ទាំងនោះ ដោយអំណាចការធ្វើនូវការនឹកដល់បានតាមប្រាថ្នា កាល បំណងនឹងចូលឈាននោះៗ ។ ដោយពាក្យនេះ លោកពោលដល់ភាពជាអ្នក ជំនាញក្នុងការនឹកគិត ដោយអំណាចការនឹកគិតដល់កសិណ ។

ម្យ៉ាងវិញទៀត ភាពជាអ្នកឈ្លាសក្នុងគោចរនៃសមាធិដោយអំណាចការ ផ្សាយកសិណទៅក្នុងចំណែកនៃទិសនោះៗ និងដោយអំណាចតាំងនៅបានយូរ នៃកសិណដែលពាល់ត្រូវហើយយ៉ាងនេះ ។

បទថា **សមាធិស្ស អភិនីហារកុសលតា** សេចក្តីថា ភាពជាអ្នកឈ្លាស ក្នុងការបង្អោនទៅ គឺក្នុងការនាំទៅនូវសមាធិទាបៗ ដោយការបង្អោនចូលទៅ កាន់ភាពជាសមាធិខ្ពស់ៗ ដោយឯកត្តន័យ ។ ពិតហើយ ឧបចារជ្ឈានដែល ដល់ភាពជំនាញហើយ រមែងបង្អោនចូលទៅដើម្បីប្រយោជន៍ដល់បឋមជ្ឈាន ឬដើម្បីប្រយោជន៍ដល់វិបស្សនា បឋមជ្ឈានជាដើមក៏យ៉ាងនោះ រមែងបង្អោន ចូលទៅ ដើម្បីប្រយោជន៍ដល់ទុតិយជ្ឈានជាដើម ឬដើម្បីប្រយោជន៍ដល់ វិបស្សនា ចតុត្ថជ្ឈានរមែងបង្អោនទៅ ដើម្បីប្រយោជន៍ដល់អរូបសមាបត្តិ ឬ ដើម្បីប្រយោជន៍ដល់អភិញ្ញា ឬដើម្បីប្រយោជន៍ដល់វិបស្សនា អាកាសានញ្ចា-យតនៈជាដើម រមែងបង្អោនចូលទៅ ដើម្បីប្រយោជន៍ដល់វិញ្ញាណញ្ចាយតនៈ ជាដើម ឬដើម្បីប្រយោជន៍ដល់វិបស្សនា ភាពជាអ្នកឈ្លាសក្នុងការបង្អោនទៅ នៃសមាធិក្នុងឈាននោះៗ យ៉ាងនេះ ដោយប្រការដូច្នេះ ។ ព្រោះបញ្ញា ឈ្មោះ ថា ភាពជាអ្នកឈ្លាស បញ្ញានោះ មិនមែនសមាធិ ហេតុនោះ គប្បីជ្រាបថា សមាធិ ៧ យ៉ាង លោកពោលដោយអំណាចនៃបញ្ញា ដែលនាំទៅកាន់

*សមាធិ ។*

*ចំណែកអាចារ្យពួកខ្លះ ពោលអត្ថនៃពាក្យទាំងនោះយ៉ាងនេះថា បទថា* **សមាធិកុសលតា** *បានដល់ ភាពជាអ្នកឈ្លាសក្នុងមនសិការដែលជាហេតុឲ្យចិត្តមិនរាយមាយ ។ បទថា* **សមាបត្តិកុសលតា** *បានដល់ ភាពជាអ្នកឈ្លាសក្នុងមនសិការដែលជាហេតុឲ្យអន្តឈាន ប្រាកដដល់អ្នកចូលឈាន ។ បទថា* **ឋិតិកុសលតា** *បានដល់ ភាពជាអ្នកឈ្លាសក្នុងមនសិការ ដែលជាហេតុឲ្យសមាធិចុះស៊ុបមិនរាយមាយ ។ បទថា* **វុដ្ឋានកុសលតា** *បានដល់ ដឹងការចេញចាកនីវរណៈក្នុងបឋមជ្ឈាន ដឹងការចេញចាកអង្គក្នុងឈាន ៣ ដឹងការចេញចាកអារម្មណ៍ក្នុងអរូបសមាបត្តិ ដឹងការចេញចាកសេចក្តីរាយមាយក្នុងអារម្មណ៍ ដែលមានប្រមាណក្រៃលែង ដឹងការចេញចាកសេចក្តីពេញចិត្តរបស់ខ្លួន ក្នុងកាលមានទីបំផុត និងក្នុងកាលមានកិច្ច ដែលគួរធ្វើក្នុងគ្រាចុងក្រោយ ។ បទថា* **កល្លតាកុសលតា** *បានដល់ ដឹងថា សមាធិគួរដល់ការងារ ព្រោះចិត្តសប្បាយ រាងកាយសប្បាយ អាហារសប្បាយ សេនាសនៈសប្បាយ និងបុគ្គលសប្បាយ ។ បទថា* **គោចរកុសលតា** *បានដល់ សេចក្តីដឹងដើម្បីធ្វើការកំណត់អារម្មណ៍ សេចក្តីដឹងដើម្បីធ្វើការផ្សាយទៅកាន់ទិស សេចក្តីដឹងដើម្បីធ្វើឲ្យចម្រើន ។ បទថា* **អភិនីហារកុសលតា** *បានដល់ បង្អោននាំចិត្តចូលទៅដោយយោនិសោមនសិការ ក្នុងសមាធិនោះៗ កាលឧបចារៈដល់នូវភាពជំនាញហើយ រមែងនាំចិត្តចូលទៅក្នុងបឋមជ្ឈាន រមែងនាំចិត្តចូលទៅក្នុងឈានខ្ពស់ៗ ក្នុងអភិញ្ញា ក្នុងអរូបសមាបត្តិ និងក្នុងវិបស្សនា ។ ភាពជា*

អ្នកឈ្លាសក្នុងការបង្អោនទៅក្នុងសមាធិនោះៗ ដោយប្រការដូច្នេះ ។

ក្នុងពួក ៨ មានអត្ថដូចពោលហើយ ។ ក្នុងពួក ៩ បទថា **រូបាវចរោ** មានវិនិច្ឆ័យដូចតទៅនេះថា ធម៌ដែលទាក់ទងក្នុងរូបាវចរធម៌ ដែលពោល ( ក្នុងអភិធម្ម ធម្មសង្គណិ ) ដោយន័យជាដើមថា ពួកធម៌ជារូបាវចរ តើដូចម្តេច ។ ខាងក្រោម កំណត់យកព្រហ្មបារិសជ្ជា[1]ជាទីបំផុត ខាងលើ កំណត់យកអកនិដ្ឋទេវលោកជាទីបំផុត ។ ក្នុងសេចក្តីនេះ មានអត្ថនៃពាក្យដូចតទៅ ឈ្មោះថា **រូបាវចរ** ព្រោះអត្ថថា **រូប** បានដល់ រូបក្ខន្ធរមែងត្រាច់ទៅក្នុងរូបភពនេះ មិនមែនកាមភព ។ ព្រោះថា សូម្បីរូបក្ខន្ធ លោកក៏ពោលថា **រូប** ដូចពាក្យ ( ក្នុងអភិធម្ម យមកៈ ) ថា **រូបក្ខន្ធោ រូបំ** រូបក្ខន្ធហៅថារូបឬជាដើម ។ ម្យ៉ាងទៀត រូបព្រហ្មនោះ មាន ១៦ ជាន់ គឺព្រហ្មបារិសជ្ជៈ ១ ព្រហ្មបុរោហិត ១ មហាព្រហ្ម ១ បរិត្តាភា ១ អប្បមាណាភា ១ អាភស្សរា ១ បរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហា ១ អសញ្ញីសត្ត ១ វេហប្ផលា ១ អវិហា ១ អតប្បា ១ សុទស្សា ១ សុទស្សី ១ អកនិដ្ឋា ១ ។

លំនៅ ពោលគឺរូបាវចរភពនោះ លោកពោលថា **រូប** ព្រោះលុបបទខាងក្រោយ ឈ្មោះថា **រូបាវចរ** ព្រោះត្រាច់ទៅក្នុងរូបនោះ ។ ម្យ៉ាងវិញទៀត **រូប** គឺរូបភព ឈ្មោះថា **រូបាវចរ** ព្រោះត្រាច់ទៅក្នុងរូបភពនោះ ។ ពិតហើយ សមាធិនេះត្រាច់ទៅសូម្បីក្នុងកាមភព កាលដែលត្រាច់ទៅក្នុងទីដទៃ លោកក៏ពោលថា រូបាវចរភព ដូចសត្វដំរីបានឈ្មោះថា សង្គាមាវចរ ព្រោះត្រាច់ទៅ

---

១- បិដកខ្មែរ មិនមានពាក្យថា ព្រហ្មបារិសជ្ជានេះទេ តែក្នុងអដ្ឋកថា មាន ។

ក្នុងសង្គ្រាមសូម្បីត្រាច់ទៅក្នុងនគរក៏ហៅថា **សង្គាមាវចរ** ដូចសត្វទាំងឡាយដែលត្រាច់ទៅលើគោកនិងត្រាច់ទៅក្នុងទឹក សូម្បីសត្វទាំងនោះ នៅក្នុងទីមិនមែនគោកមិនមែនទឹកក៏ហៅថា ត្រាច់ទៅលើគោកឬត្រាច់ទៅក្នុងទឹកដូច្នោះ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **រូបាវចរ** ព្រោះញុំាងបដិសន្ធិឲ្យត្រាច់ទៅក្នុងរូប គឺរូបភព ។

បទថា **ហីនោ** បានដល់ ថោកទាប ។ ភពត្រង់កណ្តាលរបស់សមាធិថោកទាប និងសមាធិប្រណីត ឈ្មោះថា **មជ្ឈោ** បាឋៈថា **មជ្ឈិមោ** ក៏មាន ឯសេចក្តីក៏ដូចគ្នា សមាធិនាំទៅកាន់ភាពជាប្រធាន ឈ្មោះថា **បណីតោ** សេចក្តីថា ប្រសើរខ្ពង់ខ្ពស់ ។ គប្បីជ្រាបសមាធិទាំងនោះដោយអំណាចការប្រមូលមក ។ ក្នុងខណៈប្រមូលនៃសមាធិណា ឆន្ទៈ វិរិយៈ ចិត្ត ឬវីមំសាថោកទាបសមាធិនោះ ឈ្មោះថា **ហីន** ។ ធម៌ទាំងនោះនៃសមាធិណាជាកណ្តាល សមាធិនោះ ឈ្មោះថា **មជ្ឈិម** ។ ធម៌ទាំងនោះនៃសមាធិណាប្រណីត សមាធិនោះឈ្មោះថា **បណីត** ឬសមាធិត្រឹមតែឲ្យកើតឡើង ឈ្មោះថា **ហីន** ការចម្រើនមិនសូវល្អ ឈ្មោះថា **មជ្ឈិម** ការចម្រើនយ៉ាងល្អក្រៃលែង ដល់ភាពជំនាញឈ្មោះថា **បណីត** ។ អរូបាវចរសមាធិ គប្បីជ្រាបទំនងដូចគ្នា តាមន័យដូចពោលហើយ ក្នុងរូបាវចរសមាធិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **សុញ្ញតោ សមាធិ** ដូចតទៅនេះថាកាលចេញចាកមគ្គដែលកើតហើយ ដោយអនត្តានុបស្សនានៃព្រះយោគាវចរដែលឃើញតាមលំដាប់នៃវិបស្សនាថា សង្ខារទាំងឡាយទាំងពួង មិនទៀង

ជាទុក្ខ ជាអនត្តា ព្រោះវិបស្សនានោះ ប្រព្រឹត្តទៅក្នុងសង្ខារទាំងឡាយដែលវៀរចាកតួខ្លួនដោយភាពជារបស់ទទេ ហេតុនោះ ទើបឈ្មោះថា សុញ្ញតវិបស្សនា ។ អរិយមគ្គសមាធិដែលសម្រេចដោយសុញ្ញតវិបស្សនានោះ ឈ្មោះថា សុញ្ញតសមាធិ អធិប្បាយថា សមាធិដែលប្រព្រឹត្តទៅហើយដោយអំណាចភាពទទេ ។ ពិតហើយ សមាធិនោះ រមែងប្រព្រឹត្តទៅដោយអាការដែលវិបស្សនាប្រព្រឹត្តទៅហើយ ។ កាលចេញចាកមគ្គដែលកើតហើយដោយអនិច្ចានុបស្សនា ព្រោះវិបស្សនានោះ ប្រព្រឹត្តទៅដោយអំណាចជាបដិបក្ខចំពោះនិមិត្តថាទៀង ព្រោះហេតុនោះ ទើបឈ្មោះថា អនិមិត្តវិបស្សនា ។ អរិយមគ្គសមាធិសម្រេចដោយអនិមិត្តវិបស្សនានោះ ឈ្មោះថា អនិមិត្តសមាធិ អធិប្បាយថា សមាធិដែលវៀរចាកនិមិត្តថាទៀង ។ ពិតហើយ សមាធិនោះរមែងប្រព្រឹត្តទៅដោយអាការដែលវិបស្សនាប្រព្រឹត្តទៅហើយ ។ កាលការចេញចាកមគ្គកើតហើយដោយទុក្ខានុបស្សនា ព្រោះវិបស្សនានោះ ប្រព្រឹត្តទៅដោយអំណាចជាបដិបក្ខចំពោះការតាំងនៅ ហេតុនោះ ទើបឈ្មោះថា អប្បណិហិតវិបស្សនា ។ អរិយមគ្គសមាធិដែលសម្រេចដោយអប្បណិហិតវិបស្សនានោះ ឈ្មោះថា អប្បណិហិតសមាធិ អធិប្បាយថា សមាធិដែលវៀរចាកការតាំងនៅ ។ ពិតហើយ សមាធិនោះ រមែងប្រព្រឹត្តទៅដោយអាការដែលវិបស្សនាប្រព្រឹត្តទៅហើយ ។ គប្បីជ្រាបថា សូម្បីផលសមាធិ ៣ ក៏យ៉ាងនោះឯង គឺលោកកាន់យកដោយសមាធិទាំង ៣ នោះឯង តែលោកមិនលើកយកប្រភេទនៃសមាធិ មានសមាធិថោកទាបជាដើម ព្រោះលោកុត្តរសមាធិ ជាសមាធិដែលប្រណីត ។

ក្នុងពួក ១០ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧទ្ធុមាតកសញ្ញាវសេន** ជាដើម ដូចតទៅនេះ ឈ្មោះថា **ឧទ្ធុមាត** ព្រោះហើមប៉ោងដោយប៉ោងឡើងតាមលំដាប់តាំងអំពីអស់ជីវិតហើយ ដូចជង់ប៉ោងដោយខ្យល់ ។ ឧទ្ធុមាតៈនោះឯង ឈ្មោះថា **ឧទ្ធុមាតក** ។ម្យ៉ាងទៀត ឈ្មោះថា **ឧទ្ធុមាតក** ព្រោះអត្ថថា ហើមប៉ោងគួរខ្ពើម ព្រោះជាវត្ថុបដិកូល បទនេះជាឈ្មោះរបស់សាកសពមានសភាពបែបនោះ ។

សាកសពដែលមានពណ៌ខៀវជាំ ហៅថា **វិនីល** វិនីលៈនោះឯង ឈ្មោះថា **វិនីលក** ។ ម្យ៉ាងទៀត ឈ្មោះថា **វិនីលក** ព្រោះអត្ថថា ពណ៌ខៀវគួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះ ជាឈ្មោះនៃសាកសពមានពណ៌ក្រហមក្នុងកន្លែងដែលមានសាច់ច្រើន មានពណ៌ស ក្នុងកន្លែងដែលបៀមខ្ទុះដោយច្រើន មានពណ៌ខៀវដោយច្រើនក្នុងទីដែលមានពណ៌ខៀវ ដូចសំពត់ដណ្តប់ពណ៌ខៀវ ។

ខ្ទុះហូរចេញក្នុងកន្លែងដែលស្បែកប្រេះបែក ឈ្មោះថា **វិបុព្វ** វិបុព្វៈនោះឯង ឈ្មោះថា **វិបុព្វក** ។ ម្យ៉ាងទៀត ឈ្មោះថា **វិបុព្វក** ព្រោះអត្ថថា ខ្ទុះហូរគួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះ ជាឈ្មោះនៃសាកសពមានសភាពបែបនោះ ។

សាកសពដែលត្រូវកាត់ដាច់ជា ២ កំណាត់ ហៅថា **វិច្ឆិទ្ទ** វិច្ឆិទ្ទៈនោះឯង ឈ្មោះថា **វិច្ឆិទ្ទក** ។ ម្យ៉ាងទៀត ឈ្មោះថា **វិច្ឆិទ្ទក** ព្រោះអត្ថថា សាកសពដែលដាច់ជាកំណាត់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះជាឈ្មោះនៃសាក

សពដែលដាច់ពាក់កណ្តាល ។

សាកសព ឈ្មោះថា **វិក្ខាយិត** ព្រោះត្រូវឆ្កែស្រុក និងចចកជាដើមខាំស៊ី ដោយអាការផ្សេងៗ ខាងនេះ និងខាងនោះ កាលគួរពោលថា **វិក្ខាយិត** លោកពោលថា **វិក្ខាយិតក** វិក្ខាយិតៈនោះឯង ឈ្មោះថា **វិក្ខាយិតក** ម្យ៉ាងវិញទៀត ឈ្មោះថា **វិក្ខាយិតក** ព្រោះអត្ថថា សាកសពដែលត្រូវសត្វខាំស៊ីគួរខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះ ជាឈ្មោះនៃសាកសពមានសភាពបែបនោះ ។

សាកសពដែលខ្ចាត់ខ្ចាយទៅក្នុងទីផ្សេងៗ ឈ្មោះថា **វិក្ខិត្ត** វិក្ខិត្តៈនោះឯង ឈ្មោះថា **វិក្ខិត្តក** ម្យ៉ាងទៀត ឈ្មោះថា **វិក្ខិត្តក** ព្រោះអត្ថថា សាកសពខ្ចាត់ខ្ចាយទៅគួរខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះជាឈ្មោះនៃសាកសពដែលខ្ចាត់ខ្ចាយទៅអំពីទីនោះៗ យ៉ាងនេះ គឺដៃទៅដោយឡែក ជើងទៅដោយឡែក ក្បាលទៅដោយឡែក ។

សាកសព ឈ្មោះថា **ហតវិក្ខិត្តក** ព្រោះអត្ថថា សាកសពនោះត្រូវកាប់ចិញ្ច្រាំ និងខ្ចាត់ខ្ចាយទៅ ដោយន័យមុននោះឯង ។ បទនេះជាឈ្មោះនៃសាកសពដែលត្រូវកាប់ចិញ្ច្រាំដោយសស្ត្រា ត្រង់អវយវៈតូចធំដោយអាការ ដូចស្នាមជើងក្អែក ហើយខ្ចាត់ខ្ចាយទៅដោយន័យដូចពោលហើយ ។

សាកសព ឈ្មោះថា **លោហិតក** ព្រោះអត្ថថា ឈាមហូរស្រោចទៅក្នុងទីផ្សេងៗ បទនេះជាឈ្មោះនៃសាកសពដែលប្រឡាក់ពាសពេញដោយឈាម ។

ដង្កូវលោកហៅថា **បុឡុវ** សាកសព ឈ្មោះថា **បុឡុវក** ព្រោះអត្ថថា

មានដង្កូវរុងជញ្ជក់ ។ បទនេះជាឈ្មោះនៃសាកសពដែលពេញទៅដោយដង្កូវ ។

ឆ្អឹងនោះឯង ឈ្មោះថា **អដ្ឋិក** ម្យ៉ាងទៀត ឈ្មោះថា **អដ្ឋិក** ព្រោះអត្ថថា ឆ្អឹងគួរខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះជាឈ្មោះនៃគ្រោងឆ្អឹងខ្លះ ឆ្អឹងមួយកំណាត់ខ្លះ ។ ទាំងនេះជាឈ្មោះនៃនិមិត្តដែលកើត ព្រោះអាស្រ័យសាកសពដែលជាឧទ្ធុមាតកៈជាដើមខ្លះ នៃឈានដែលបានហើយក្នុងនិមិត្តទាំងឡាយខ្លះ ។ តែក្នុងទីនេះ សញ្ញាដែលកើតឡើងដោយអំណាចអប្បនាកំណត់អាការក្នុងនិមិត្តនៃសាកសពដែលហើមប៉ោងថាជារបស់គួរខ្ពើម ឈ្មោះថា **ឧទ្ធុមាតកសញ្ញា** ដោយអំណាចនៃឧទ្ធុមាតកសញ្ញានោះ ឈ្មោះថា **ឧទ្ធុមាតកសញ្ញាវសេន** សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **បញ្ចបញ្ញាស សមាធិ** លោកពោលដោយអំណាចនៃធម៌ពួកមួយជាដើម ។

[ ៩៣ ] ព្រះសារីបុត្ត កាលសម្តែងដល់ប្រភេទនៃសមាធិដោយអំណាចពួកមួយជាដើមយ៉ាងនេះហើយ ឥឡូវនេះ លោកបំណងនឹងសម្តែងសមាធិដោយបរិយាយដទៃទៀត ទើបសម្តែងប្រារព្ធបរិយាយដទៃថា **អបិច** ដូច្នេះហើយពោលបទជាដើមថា **បញ្ចវីសតិ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សមាធិស្ស សមាធិដ្ឋា** បានដល់ សភាពក្នុងសភាវៈដែលជាសមាធិនៃសមាធិ សមាធិនោះរមែងមានដោយសភាពណា សភាពទាំងនោះ ឈ្មោះថា ជាអត្ថក្នុងសមាធិនោះ ។ បទថា **បរិគ្គហដ្ឋេន សមាធិ** បានដល់ ព្រោះសមាធិដែលឥន្ទ្រិយមានសទ្ធិន្ទ្រិយជាដើមកំណត់កាន់យក ហេតុនោះ ទើបឈ្មោះថា សមាធិដោយសភាពដែលសទ្ធិន្ទ្រិយជាដើមកំណត់កាន់យក ។ ម្យ៉ាងទៀត ឥន្ទ្រិយទាំងនោះ

ឯងរមែងជាបរិវារនៃគ្នានិងគ្នា ហើយរមែងជាឥន្ទ្រិយបរិបូណ៌ដោយការបំពេញភាវនា ។ ព្រោះហេតុនោះ ទើបឈ្មោះថា **បរិវារដ្ឋេន** ព្រោះអត្ថថា ឥន្ទ្រិយជាបរិវារនៃគ្នានិងគ្នា ឈ្មោះថា **បរិបូរដ្ឋេន** ព្រោះអត្ថថា សទ្ធិន្ទ្រិយជាដើមបរិបូណ៌ ឈ្មោះថា **ឯកគ្គដ្ឋេន** ព្រោះអត្ថថា មានអារម្មណ៍ដូចគ្នាតែមួយ ព្រោះសម្លឹងអារម្មណ៍តែមួយ ដោយអំណាចការតាំងមាំនៃឥន្ទ្រិយទាំងនោះឯង ឈ្មោះថា **អវិក្ខេបដ្ឋេន** ព្រោះអត្ថថា មិនរាយមាយ ព្រោះសម្លឹងការមិនមានទូវការរាយមាយក្នុងអារម្មណ៍ផ្សេងៗ គប្បីជ្រាបថា លោកមិនកាន់យកអត្ថថា ការផ្គងសេចក្ដីព្យាយាម និងអត្ថថា មិនរាយមាយ ដែលធ្លាប់ប្រាវព្ធមកហើយក្នុងទីនេះ ព្រោះលោកុត្តរនោះឯងគួរសម្រេចដោយការកំណត់កាន់យកវីរិយពលយ៉ាងខ្លាំងក្លា និងព្រោះលោកុត្តរមគ្គមិនមានការរាយមាយ ដោយអំណាចសេចក្ដីវិនាស ។ ឈ្មោះថា **អនាវិលដ្ឋេន សមាធិ** ព្រោះមិនមានកិលេសផ្សាយឡើង ។ ឈ្មោះថា **អនិញ្ជនដ្ឋេន សមាធិ** ព្រោះការមិនញាប់ញ័រ ។ ឈ្មោះថា **វិមុត្តដ្ឋេន សមាធិ** ព្រោះផុតចាកកិលេសដោយការសង្កត់សង្កិន ឬដោយការកាត់ផ្ដាច់ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ ។

បទថា **ឯកត្តុបដ្ឋានវសេន ចិត្តស្ស ឋិតត្តា** សេចក្ដីថា ព្រោះចិត្តតាំងមាំដោយមិនញាប់ញ័រក្នុងអារម្មណ៍ ដោយអំណាចការតាំងមាំយ៉ាងមាំទាំក្នុងអារម្មណ៍តែមួយដោយការប្រកបសមាធិនោះឯង ។ គប្បីជ្រាបថា ក្នុង ៨ គូ ៣ គូទាំងនេះ គឺ **ឯសតិ នេសតិ** ជាគូ ១ **អាទិយតិ នាទិយតិ** ជាគូ ១ **បជិបជ្ជតិ នប្បជិបជ្ជតិ** ជាគូ ១ នេះ លោកពោលហើយ ដោយអំណាចនៃ

ឧបចារៈដែលទន់ កណ្តាល និងមានប្រមាណក្រៃលែងក្នុងចំណែកមុនអំពីវិថីនៃអប្បនា គប្បីជ្រាបគូនេះថា **ឈាយតិ ឈាបេតិ** លោកពោលហើយដោយអំណាចនៃឧបចារៈក្នុងវិថីនៃអប្បនា ។ គប្បីជ្រាបថា ទាំង ៤ គូនេះ គឺ **ឋបិតត្តា នេសិតត្តា** ជាគូ ១ **អាធិន្នត្តា អនាធិន្នត្តា** ជាគូ ១ **បដិបន្នត្តា នប្បដិបន្នត្តា** ជាគូ ១ **ឈាតត្តា ន ឈាបិតត្តា** ជាគូ ១ លោកពោលហើយដោយអំណាចនៃអប្បនា ។

ក្នុងបទទាំងនោះ បទថា **សមំ** ក្នុងបទថា **សមំ ឋសតីតិ សមាធិ** ជាដើម បានដល់ អប្បនា ។ ពិតហើយ អប្បនានោះឈ្មោះថា **សម** ព្រោះស្ងប់ គឺញុំាងធម៌ដែលជាសត្រូវឲ្យវិនាសទៅ ។ ម្យ៉ាងទៀត ឈ្មោះថា **សម** ព្រោះកើតពីការមិនមានសេចក្តីមិនស្ងប់ ដែលជាសត្រូវ ។ **សមាធិ** រមែងស្វែងរកសេចក្តីស្ងប់នោះ គឺរមែងស្វែងរកដោយអធ្យាស្រ័យ ។ **ឥតិ** សព្ទ ជាការណត្ថៈ ប្រែថា ព្រោះហេតុនោះ អធិប្បាយថា ព្រោះស្វែងរកសេចក្តីស្ងប់ ហេតុនោះទើបឈ្មោះថា **សមាធិ** ។ បទថា **វិសមំ នេសតិ** បានដល់ មិនស្វែងរកសេចក្តីមិនស្ងប់ ពោល គឺសឹកសត្រូវរបស់ឈាននោះៗ ។

ពិតហើយ សមាធិដែលជាចំណែកខាងដើម ដែលជាសមាធិទន់ខ្សោយ ឈ្មោះថា **សមំ ឋសតិ វិសមំ នេសតិ** ( ស្វែងរកនូវការស្ងប់មិនស្វែងរកនូវធម៌ប្រាសចាកការស្ងប់ ) ព្រោះជាសមាធិខាងដើម ។ សមាធិដែលជាកណ្តាល ឈ្មោះថា **សមំ អាធិយតិ វិសមំ នាធិយតិ** ( កាន់យកនូវការស្ងប់មិនកាន់យកនូវធម៌ប្រាសចាកការស្ងប់ ) ព្រោះជាសមាធិមាំទាំ ។ សមាធិមានប្រមាណ

ក្រៃលែង ឈ្មោះថា **សមំ បដិបជ្ជតិ វិសមំ ឧប្បដិបជ្ជតិ** ( ដើរទៅកាន់ការស្ងប់ មិនដើរទៅកាន់ធម៌ប្រាសចាកការស្ងប់ ) ព្រោះជាសមាធិ ជិតវិថីនៃអប្បនា ។

បទថា **សមំ ឈាយតិ** ជាការរំាចកនបុំសកលិង្គ សេចក្តីថា សម្លឹងស្មើ ឬសម្លឹងដោយអាការស្ងប់ ពិតហើយ សមាធិក្នុងវិថីនៃអប្បនា រមែងប្រព្រឹត្តទៅដោយអាការស្ងប់ ព្រោះស្ងប់ដោយប្រាសចាកធម៌ដែលជាសត្រូវ និងព្រោះតាំងនៅដោយភាពជាសមាធិឧបការៈដល់អប្បនាដែលស្ងប់ហើយ ។

ម្យ៉ាងទៀត បទថា **ឈាយតិ** មានអត្ថថា រុងរឿង ដូចក្នុងប្រយោគជាដើមថា **ឯតេ មណ្ឌលមាឡេ ទីបា ឈាយន្តិ សព្វរត្តឹ** ន៉ុះន៏ ប្រទីបទាំងឡាយដែលគេអុជតាំងនៅក្នុងរោង មានសណ្ឋានមូលអស់រាត្រី **សព្វរត្តិយោ ច តេលប្បទីបោ ឈាយតិ** ប្រទីបប្រេងរមែងឆេះរុងរឿងអស់រាត្រី **តេលប្បទីបោ ចេត្ថ ឈាយេយ្យ** ប្រទីបប្រេងគប្បីឆេះរុងរឿងក្នុងទីនេះ ។ បាឋៈថា **សមំ ជាយតិ** ដូច្នេះក៏មាន អធិប្បាយថា សមាធិ រមែងកើតដោយអាការស្ងប់ បាឋៈមុនល្អជាង ព្រោះភាពជាគូថា **ឈាយតិ** និង **ឈាបេតិ** ។

ម្យ៉ាងទៀត បទថា **ឈាបេតិ** មានអត្ថថា ដុត ។ ព្រោះថា សមាធិនោះឈ្មោះថា រមែងដុតធម៌ដែលជាសត្រូវដោយធ្វើឲ្យឃ្លាតឆ្ងាយ ។ លោកពោលអប្បនាសមាធិ ដោយបទជាដើមថា **ឯសិតត្តា នេសិតត្តា** ព្រោះការស្វែងរក និងការមិនស្វែងរកជាដើម សម្រេចដោយអប្បនា ។

បទថា **សមំ ឈាតត្តា** បានដល់ ព្រោះរុងរឿងស្មើ ។ បាឋៈថា **សមំ ជាតត្តា** ព្រោះកើតស្មើក៏មាន ។ សភាពក្នុងភាពជាសមាធិនៃសមាធិទាំង

២៥ នេះ គឺសមាធិ ១៦ ដោយអំណាចនៃគូ ៨ និងសមាធិ ៩ ខាងដើម ដោយប្រការដូច្នេះ ។

ក្នុងបទនេះថា **សមោ ច ហិតោ ច សុខោ ចាតិ សមាធិ** លោកពោលដើម្បីឲ្យសម្រេចអត្ថនៃសមាធិដែលសម្រេចហើយដោយអាការ ២៥ ។ ក្នុងបទទាំងនោះ បទថា **សមោ** មកអំពីអត្ថថា **សម** សព្ទ ឬ **សំ** សព្ទ ។ ពិតហើយ សមាធិនោះ ឈ្មោះថា **សមោ** ព្រោះវៀរចាកការមិនស្ងប់ ដែលញុំាងធម៌ជាសត្រូវឲ្យកម្រើក ។

បទថា **ហិតោ** មកអំពីអត្ថថា **អាធិ** សព្ទ អធិប្បាយថា តាំងនៅក្នុងអារម្មណ៍ គឺឲ្យតាំងនៅដោយធ្វើការមិនញាប់ញ័រ ។ ដោយពាក្យទាំងពីរ មានពាក្យអធិប្បាយថា ឈ្មោះថា **សមាធិ** ព្រោះស្ងប់ និងតាំងមាំ ។ បទថា **សុខោ** ឈ្មោះថា **សុខ** ព្រោះអត្ថថា ស្ងប់ ។ សូម្បីសមាធិ ដែលសហគតៈដោយឧបេក្ខា លោកក៏កាន់យកដោយ **សុខ** សព្ទ ដែលមានអត្ថថា ស្ងប់នោះ ព្រោះលោកពោល ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះសេចក្តីសុខដ៏ល្អិតឧត្តម និងថាឧបេក្ខា លោកពោលថា សុខនោះឯង ព្រោះស្ងប់ ដូច្នេះ ។ លោកពោលសមាធិទាំងអស់ ក្នុងទីនេះ ដោយមិនមានកំណត់ ទើបឈ្មោះថា លោកពោលហេតុនៃការតាំងមាំដោយ **សុខ** សព្ទនោះ ។ គប្បីជ្រាបពាក្យអធិប្បាយថា ព្រោះសមាធិជាសេចក្តីស្ងប់ ហេតុនោះ ទើបសមាធិតាំងមាំក្នុងអារម្មណ៍តែមួយ ដោយប្រការដូច្នេះ ។៚

**អដ្ឋកថាសមាធិភាវនាមយញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ៩៤ ] បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ តើដូចម្តេច អវិជ្ជាជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃគ្រឿងកំណត់ផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបផង ជាទីតាំងនៃកង្វល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផងរបស់សង្ខារទាំងឡាយ នេះអវិជ្ជាជាបច្ច័យដោយអាការ ៩ យ៉ាង សង្ខារទាំងឡាយកើតឡើងព្រោះបច្ច័យ ធម៌ទាំង ២ នុ៎ះ សុទ្ធតែកើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាទីតាំងនៃការកើតឡើងរបស់សង្ខារទាំងឡាយអស់អតីតកាលផង អវិជ្ជាជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃនិមិត្តផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបព្រមផង ជាទីតាំងនៃកង្វល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផង របស់សង្ខារទាំងឡាយអស់អនាគតកាលផង នេះអវិជ្ជាជាបច្ច័យដោយអាការ ៩ យ៉ាង សង្ខារទាំងឡាយកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ កើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ សង្ខារទាំងឡាយ ជាទីតាំងនៃការកើតឡើងរបស់វិញ្ញាណ ។បេ។ វិញ្ញាណជាទីតាំងនៃការកើតឡើងរបស់នាមរូប នាមរូបជាទីតាំងនៃការកើតឡើងរបស់អាយតនៈប្រាំមួយ អាយតនៈប្រាំមួយជាទីតាំងនៃការកើតឡើងរបស់ផស្សៈ ផស្សៈជាទីតាំងនៃការកើតឡើងរបស់វេទនា វេទនាជាទីតាំងនៃការកើតឡើងរបស់តណ្ហា តណ្ហាជាទីតាំងនៃការកើតឡើង របស់

ឧបាទាន ឧបាទានជាទីតាំងនៃការកើតឡើងរបស់ភព ភពជាទីតាំងនៃការកើតឡើងរបស់ជាតិ ជាតិជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃនិមិត្តផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបព្រមផង ជាទីតាំងនៃកន្លល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផងរបស់ជរា និងមរណៈ នេះជាតិជាបច្ច័យដោយអាការ ៩ យ៉ាង ជរា និងមរណៈកើតឡើងព្រោះបច្ច័យ ធម៌ទាំងឡាយពីរនុ៎ះ កើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិ-តិញ្ញាណ ជាតិជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តិទៅផង ជាទីតាំងនៃនិមិត្តផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបព្រមផង ជាទីតាំងនៃកន្លល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផងរបស់ជរា និងមរណៈ អស់អតីតកាលផង អស់អនាគតកាលផង នេះជាតិជាបច្ច័យដោយអាការ ៩ យ៉ាង ជរា និងមរណៈកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ កើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

[ ៩៥ ] អវិជ្ជាជាហេតុ សង្ខារទាំងឡាយ កើតឡើងព្រោះហេតុ ធម៌ទាំងពីរនុ៎ះសុទ្ធតែកើតឡើងព្រោះហេតុ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាហេតុ សង្ខារទាំងឡាយកើតឡើង ព្រោះហេតុ ធម៌ទាំងពីរនុ៎ះសុទ្ធតែកើតឡើងព្រោះហេតុ អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិ-

តិញ្ញាណ សង្ខារទាំងឡាយជាហេតុ វិញ្ញាណកើតឡើងព្រោះហេតុ វិញ្ញាណជាហេតុ នាម និងរូបកើតឡើង ព្រោះហេតុ នាម និងរូបជាហេតុ អាយតនៈប្រាំមួយកើតឡើង ព្រោះហេតុ អាយតនៈប្រាំមួយជាហេតុ ផស្សៈកើតឡើង ព្រោះហេតុ ផស្សៈជាហេតុ វេទនាកើតឡើងព្រោះហេតុ វេទនាជាហេតុ តណ្ហាកើតឡើងព្រោះហេតុ តណ្ហាជាហេតុ ឧបាទានកើតឡើងព្រោះហេតុ ឧបាទានជាហេតុ ភពកើតឡើងព្រោះហេតុ ភពជាហេតុ ជាតិកើតឡើងព្រោះហេតុ ជាតិជាហេតុ ជរា និងមរណៈកើតឡើងព្រោះហេតុ ធម៌ទាំងពីរនុ៎ះសុទ្ធតែកើតឡើងព្រោះហេតុ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ជាតិជាហេតុ ជរា និងមរណៈកើតឡើងព្រោះហេតុ ធម៌ទាំងពីរនុ៎ះសុទ្ធតែកើតឡើងព្រោះហេតុអស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

[ ៩៦ ] អវិជ្ជាជាគ្រឿងអាស្រ័យ សង្ខារកើតឡើងព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាគ្រឿងអាស្រ័យ សង្ខារកើតឡើងព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យអស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ សង្ខារជាគ្រឿងអាស្រ័យ វិញ្ញាណកើតឡើងព្រោះគ្រឿងអាស្រ័យ វិញ្ញាណជាគ្រឿងអាស្រ័យ នាម និងរូបកើតឡើងព្រោះគ្រឿងអាស្រ័យ នាម និងរូបជាគ្រឿងអាស្រ័យ អាយតនៈប្រាំមួយ

កើតឡើង ព្រោះគ្រឿងអាស្រ័យ អាយតនៈប្រាំមួយជាគ្រឿងអាស្រ័យ ផស្សៈកើតឡើងព្រោះគ្រឿងអាស្រ័យ ផស្សៈជាគ្រឿងអាស្រ័យ វេទនាកើតឡើងព្រោះគ្រឿងអាស្រ័យ វេទនាជាគ្រឿងអាស្រ័យ តណ្ហាកើតឡើងព្រោះគ្រឿងអាស្រ័យ តណ្ហាជាគ្រឿងអាស្រ័យ ឧបាទានកើតឡើងព្រោះគ្រឿងអាស្រ័យ ឧបាទានជាគ្រឿងអាស្រ័យ ភពកើតឡើងព្រោះគ្រឿងអាស្រ័យ ភពជាគ្រឿងអាស្រ័យ ជាតិកើតឡើងព្រោះគ្រឿងអាស្រ័យ ជាតិជាគ្រឿងអាស្រ័យ ជរា និងមរណៈកើតឡើងព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ជាតិជាគ្រឿងអាស្រ័យ ជរា និងមរណៈកើតឡើងព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យអស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

[ ៩៧ ] អវិជ្ជាជាបច្ច័យ សង្ខារទាំងឡាយកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះសុទ្ធតែកើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាបច្ច័យ សង្ខារកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះសុទ្ធតែកើតឡើងព្រោះបច្ច័យអស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ សង្ខារជាបច្ច័យ វិញ្ញាណកើតឡើងព្រោះបច្ច័យ វិញ្ញាណជាបច្ច័យ នាម និងរូបកើតឡើងព្រោះបច្ច័យ នាម និងរូបជាបច្ច័យ អាយតនៈប្រាំមួយកើតឡើង ព្រោះ

បច្ច័យ អាយតនៈប្រាំមួយជាបច្ច័យ ផស្សៈកើតឡើងព្រោះបច្ច័យ ផស្សៈជាបច្ច័យ វេទនាកើតឡើងព្រោះបច្ច័យ វេទនាជាបច្ច័យ តណ្ហាកើតឡើងព្រោះបច្ច័យ តណ្ហាជាបច្ច័យ ឧបាទានកើតឡើងព្រោះបច្ច័យ ឧបាទានជាបច្ច័យ ភពកើតឡើងព្រោះបច្ច័យ ភពជាបច្ច័យ ជាតិកើតឡើងព្រោះបច្ច័យ ជាតិជាបច្ច័យ ជរា និងមរណៈកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ជាតិជាបច្ច័យ ជរា និងមរណៈកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះបច្ច័យអស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

[ ៩៨ ] ក្នុងកម្មភពមុន មោហៈ គឺអវិជ្ជា ការប្រមូលមក គឺសង្ខារ សេចក្តីប្រាថ្នា គឺតណ្ហា កិរិយាប្រកាន់មាំ គឺឧបាទាន ចេតនា គឺភព ធម៌ទាំង ៥ យ៉ាងនេះ ក្នុងកម្មភពមុនជាបច្ច័យនៃបដិសន្ធិក្នុងបច្ចុប្បន្នភពនេះ បដិសន្ធិក្នុងបច្ចុប្បន្នភពនេះជាវិញ្ញាណ ការចុះកាន់គភ៌ គឺនាម និងរូប បសាទ គឺអាយតនៈ សភាពដែលបុគ្គលពាល់ត្រូវ គឺផស្សៈ ការទទួលអារម្មណ៍ គឺវេទនា ធម៌ទាំង ៥ យ៉ាងនេះក្នុងឧបបត្តិភពនេះ ប្រព្រឹត្តទៅព្រោះបច្ច័យរបស់កម្ម ដែលបុគ្គលធ្វើទុកហើយក្នុងកាលមុន ព្រោះតែអាយតនៈចាស់ក្នុងបច្ចុប្បន្ននេះ មោហៈ គឺអវិជ្ជា ការប្រមូល គឺសង្ខារ សេចក្តីប្រាថ្នា គឺតណ្ហា ការប្រកាន់មាំ គឺឧបាទាន ចេតនា គឺភព ធម៌ទាំង ៥ យ៉ាងនេះ ក្នុងកម្មភពជាបច្ចុប្បន្ននេះ ជាបច្ច័យនៃបដិសន្ធិក្នុងអនាគត បដិសន្ធិក្នុងអនាគតជាវិញ្ញាណ ការចុះកាន់គភ៌គឺនាម និង

រូប បសាទ គឺអាយតនៈ ធម៌ដែលបុគ្គលពាល់ត្រូវ គឺផស្សៈ ការទទួលអារម្មណ៍ គឺវេទនា ធម៌ទាំង ៥ យ៉ាងនេះ ក្នុងឧបបត្តិភព ជាអនាគតប្រព្រឹត្តទៅ ព្រោះបច្ច័យនៃកម្ម ដែលបុគ្គលធ្វើទុកហើយក្នុងបច្ចុប្បន្នភពនេះ បុគ្គលដឹង ឃើញ យល់ ត្រាស់ដឹងនូវសង្ខេប ៤ កាល ៣ សន្ធិ ៣ នេះ និងបដិច្ចសមុប្បាទដោយអាការ ២០ យ៉ាង ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

## អដ្ឋកថា

## ធម្មដ្ឋិតិញ្ញាណនិទ្ទេស

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងធម្មដ្ឋិតិញ្ញាណនិទ្ទេសដូចតទៅនេះ ក្នុងបទថា **អវិជ្ជា សង្ខារានំ ឧប្បាទដ្ឋិតិ** ជាដើម មានអធិប្បាយដូចតទៅ ឈ្មោះថា **ឋិតិ** ព្រោះអត្ថថា អវិជ្ជាជាហេតុនៃសង្ខារទាំងឡាយ ។ ឋិតិនោះគឺអ្វី គឺអវិជ្ជា ព្រោះថា អវិជ្ជានោះជាទីតាំង គឺជាហេតុនៃការកើត គឺការកើតឡើងនៃសង្ខារទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **ឧប្បាទដ្ឋិតិ** ។

ឈ្មោះថា **បវត្តដ្ឋិតិ** ព្រោះអត្ថថា ជាហេតុនៃការប្រព្រឹត្តទៅនៃសង្ខារទាំងឡាយដែលកើតឡើងហើយ អធិប្បាយថា ពិតហើយ អានុភាពនៃកិច្ចរបស់បច្ច័យដែលឲ្យកើត រមែងមានក្នុងខណៈដែលឲ្យកើតនោះឯងក៏ពិត តែព្រោះសង្ខារទាំងឡាយដែលបច្ច័យនោះឲ្យកើតនោះឯងប្រព្រឹត្តទៅ ទើបឈ្មោះថា ជាហេតុនៃការប្រព្រឹត្តទៅក្នុងខណៈរបស់ខ្លួន ឬជាហេតុនៃការប្រព្រឹត្តទៅដោយអំណាចសន្តតិ ។ ម្យ៉ាងទៀត បទថា **បវត្តំ** នេះ ជាភាវនាម ប្រើក្នុងនបុំសកលិង្គ ព្រោះហេតុនោះ **បវត្តំ** ក៏គឺ **បវត្តិ** ដូចគ្នាតែមួយដោយអត្ថ ។ តែព្រោះ **បវត្តិ** សព្ទ ប្រាកដហើយ ទើបលោកពោលអត្ថប្រកបដោយ **បវត្ត** សព្ទនោះ ព្រោះ **ឋិតិ** សព្ទ ប្រើសូម្បីក្នុងអត្ថថា ទីតាំង ដើម្បីសម្ដែងថា **ឋិតិ** សព្ទក្នុងទីនេះមិនមែនប្រើក្នុងអត្ថថា ទីតាំង តែប្រើក្នុងអត្ថថា ជាហេតុ ទើបលោកពោលថា **និមិត្តដ្ឋិតិ** អធិប្បាយថា **ឋិតិ** ជាគ្រឿងសម្គាល់ គឺជាហេតុ ។ អវិជ្ជាមិនមែនត្រឹមតែជាគ្រឿងសម្គាល់ ( និមិត្ត ) តែម្យ៉ាងប៉ុណ្ណោះទេ ដែល

ពិត ព្រះសារីបុត្ត កាលសម្តែងភាពដែលអវិជ្ជាអាចជាបច្ច័យថា រមែងប្រមូលមក រមែងព្យាយាម ហាក់ដូចជាមានសេចក្តីខ្វល់ខ្វាយក្នុងការឲ្យកើតសង្ខារ ទើបពោលថា **អាយូហនដ្ឋិតិ** អធិប្បាយថា **ឋិតិ** ជាហេតុប្រមូលមក ។ ព្រោះអវិជ្ជាឲ្យសង្ខារកើតឡើង ឈ្មោះថា ប្រកបក្នុងការកើត អធិប្បាយថា ព្យាយាម អវិជ្ជាឲ្យសង្ខារប្រព្រឹត្តទៅ ឈ្មោះថា ពាក់ព័ន្ធក្នុងការប្រព្រឹត្តទៅ អធិប្បាយថា ចងព័ន្ធ ហេតុនោះ ទើបលោកពោលថា **សញ្ញោគដ្ឋិតិ** ជាទីតាំងនៃការប្រកប **បលិពោធដ្ឋិតិ** ជាទីតាំងនៃកង្វល់ អធិប្បាយថា **ឋិតិ** ជាហេតុប្រកប ជាហេតុកង្វល់ ។ ព្រោះអវិជ្ជាឲ្យសង្ខារកើត ឈ្មោះថា ជាហេតុកើត ព្រោះអត្ថថា ជាមូលហេតុនៃការកើត និងការប្រព្រឹត្តទៅ ទើបឈ្មោះថា **សមុទយដ្ឋិតិ** ព្រោះឋិតិជាហេតុឲ្យកើត អធិប្បាយថា **ឋិតិ** ជាមូលហេតុ ។ អវិជ្ជានោះឯងលោកពោលថា **ហេតុដ្ឋិតិ** ជាទីតាំងនៃហេតុ **បច្ចយដ្ឋិតិ** ជាទីតាំងនៃបច្ច័យ ព្រោះជាបច្ច័យឲ្យកើត ក្នុងការកើតឡើងនៃសង្ខារទាំងឡាយ ព្រោះជាបច្ច័យឧបត្ថម្ភក្នុងបវត្តិកាល អធិប្បាយថា **ឋិតិ** ជាទីតាំងនៃហេតុ **ឋិតិ** ជាទីតាំងនៃបច្ច័យ ។ លោកហៅបច្ច័យដែលឲ្យកើតថា ជាហេតុ បច្ច័យដែលឧបត្ថម្ភថា ជាទីតាំងនៃបច្ច័យ ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីប្រកបយ៉ាងនេះ ។

ក្នុងបទនេះថា **ភវោ ជាតិយា ជាតិ ជរាមរណស្ស** គប្បីជ្រាបថា លោកពោលដល់ពាក្យដែលប្រកបដោយអំណាចការកើតថា **ឧប្បាទដ្ឋិតិ** ជាទីតាំងនៃការកើតឡើង **សញ្ញោគដ្ឋិតិ** ជាទីតាំងនៃការប្រកបព្រម **ហេតុដ្ឋិតិ**

ជាទីតាំងនៃហេតុដោយបរិយាយ ដោយអំណាចនៃខន្ធទាំងឡាយ ដែលមានជាតិ ជរា និងមរណៈ តែអាចារ្យពួកខ្លះពណ៌នាសេចក្តីក្នុងបទនេះ ដោយន័យជាដើមយ៉ាងនេះថា ហេតុនៃការកើត ឈ្មោះថា **ឧប្បាទដ្ឋិតិ** ។ បទថា **អវិជ្ជា បច្ចយោ** លោកសម្ដែងសេចក្តីដែលអវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ព្រោះសូម្បីអវិជ្ជាក៏កើតអំពីបច្ច័យ ដើម្បីនឹងសម្ដែងការកំណត់បច្ច័យ របស់អវិជ្ជានោះ ទើបលោកពោលថា **ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា** ដូច្នេះ ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីប្រកបយ៉ាងនេះ ។ ចំណែកបទថា **ជាតិ បច្ចយោ ជរាមរណំ បច្ចយសមុប្បន្នំ** លោកពោលដោយអម ។ បទថា **អតីតម្បិ អទ្ធានំ** បានដល់ កាលដែលកន្លងទៅហើយក្តី ។ បទថា **អនាគតម្បិ អទ្ធានំ** បានដល់ កាលដែលមិនទាន់មកដល់ ។ សូម្បីក្នុងបទទាំង ២ ក៏ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃអច្ចន្តសំយោគ ( ប្រែថា រហូត ឬអស់ ) ។

[ ៩៥-៩៧ ] ឥឡូវនេះ ព្រះសារីបុត្តលះអាការទាំង ៩ នោះ ហើយប្រកបសម្ដែងវារៈ ៣ ថា **អវិជ្ជា ហេតុ សង្ខារា ហេតុសមុប្បន្នា** ជាដើមដោយពាក្យថា ហេតុ បដិច្ច និងបច្ចយោបន្ទាប់អំពីវារៈនៃអាការ ៩ ។ ក្នុងវារៈនៃអាការ ៩ លោកពោលបច្ច័យដោយអំណាចជនកប្បច្ច័យ និងឧបត្ថម្ភកប្បច្ច័យ ។ តែក្នុងទីនេះ ព្រោះហេតុវារៈ និងបច្ចយវារៈញែកគ្នា ភាពដែលអវិជ្ជាជាជនកប្បច្ច័យគប្បីជ្រាបថាជាហេតុ ភាពដែលអវិជ្ជាជាឧបត្ថម្ភកប្បច្ច័យគប្បីជ្រាបថាជាបច្ច័យដោយបច្ច័យ មានអវិជ្ជាជាដើម សូម្បីតែម្យ៉ាង ក៏កើត

ជា ២ យ៉ាងបាន ។

បទថា **អវិជ្ជា បដិច្ច** ក្នុងបដិច្ចវារៈមានវិគ្គហៈថា ឈ្មោះថា **បដិច្ច** ព្រោះអត្ថថា អវិជ្ជាគប្បីដល់ គប្បីទៅចំពោះមុខដោយសង្ខារទាំងឡាយ ព្រោះសង្ខារទាំងឡាយសម្ព័ន្ធដល់អវិជ្ជាក្នុងការកើតរបស់ខ្លួន ដោយពាក្យនេះ ឈ្មោះថាលោកពោលដល់ភាពដែលអវិជ្ជាអាចឲ្យសង្ខារកើត ។ បទថា **សង្ខារា បដិច្ចសមុប្បន្នា** បានដល់ សង្ខារទាំងឡាយអាស្រ័យអវិជ្ជា គឺបែរមុខដោយប្រព្រឹត្តទៅចំពោះនូវអវិជ្ជានោះ បានដល់ មិនលះហើយ កើតឡើងជានិច្ច ។ សូម្បីបទដ៏សេស ក៏គប្បីប្រកបតាមសមគួរដល់លិង្គយ៉ាងនេះ ។ ម្យ៉ាងទៀតបាឋៈថា **អវិជ្ជា បដិច្ច** ( អវិជ្ជាអាស្រ័យបច្ច័យប្រព្រឹត្តទៅ ) ដោយអំណាចការខ្វល់ខ្វាយ តែសេចក្តីក្នុងបទនេះ គប្បីប្រកបដោយបាឋៈដ៏សេសថា អវិជ្ជាអាស្រ័យបច្ច័យរបស់ខ្លួនប្រព្រឹត្តទៅ ។ សូម្បីក្នុងបទដ៏សេស ក៏យ៉ាងនោះ ។ ក្នុងវារៈទាំង ៤ យ៉ាងនេះ លោកសម្តែងនូវធម្មដ្ឋិតិញ្ញាណ ដោយអំណាចនៃអង្គ ១១ មានអវិជ្ជាជាដើម ព្រោះធម្មដ្ឋិតិញ្ញាណ គួរសម្តែងដោយអំណាចបច្ច័យនៃអង្គបដិច្ចសមុប្បាទ ១២ នោះឯង តែលោកមិនសម្តែងដោយអំណាចជរាមរណៈនោះ ព្រោះជរាមរណៈតាំងនៅក្នុងទីបំផុត ។ ព្រោះជរា និងមរណៈក៏ជាបច្ច័យដល់សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសៈ ធម្មដ្ឋិ-តិញ្ញាណ រមែងគួរនោះឯងដោយអំណាចជរាមរណៈនោះ ដែលពិចារណាធ្វើជរាមរណៈឲ្យជាបច្ច័យដល់សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសៈទាំងនោះ ។

[ ៩៨ ] ឥឡូវនេះ ព្រះសារីបុត្តបំណាងនឹងចែកអង្គបដិច្ចសមុប្បាទ ១២ ទាំងនោះឯងដោយអាការ ២០ ហើយសម្តែងសង្ខេប ៤ កាល ៣ សន្ធិ ៣ ហើយសម្តែងធម្មដ្ឋិតិញ្ញាណ ទើបពោលពាក្យថា **បុរិមកម្មភវស្មឹ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បុរិមកម្មភវស្មឹ** បានដល់ ក្នុងកម្មភពដែលមានក្នុងកាលមុន អធិប្បាយថា ក្នុងកម្មភពដែលធ្វើក្នុងអតីតជាតិ ។ បទថា **មោហោ អវិជ្ជា** បានដល់ ការវង្វេងក្នុងទុក្ខជាដើម ក្នុងកាលនោះឯណា បុគ្គលអ្នកវង្វេងដោយការវង្វេងឯណា រមែងធ្វើកម្មការវង្វេងនោះ ឈ្មោះថា អវិជ្ជា ។ បទថា **អាយូហនា សង្ខារា** សេចក្តីថា ចេតនាជំបូងរបស់អ្នកធ្វើកម្មនោះដូចចេតនាជំបូងដែលកើតឡើងដល់អ្នកគិតថា អញនឹងឲ្យទាន ហើយត្រៀមទេយ្យទានមួយខែខ្លះ មួយឆ្នាំខ្លះ ។ ចេតនារបស់បុគ្គលដែលដាក់ទក្ខិណា ( ទេយ្យទាន ) លើដៃរបស់បដិគ្គាហក ហៅថា ភព ។ ម្យ៉ាងទៀត ក្នុងអាវជ្ជនៈ ១ ចេតនាក្នុងជវនៈ ៦ ឈ្មោះថា អាយូហនសង្ខារ ចេតនាក្នុងជវនៈទី ៧ ឈ្មោះថា ភព ។ ម្យ៉ាងទៀត ចេតនាណាមួយ ឈ្មោះថា ភព ធម៌ដែលសម្បយុត្តជាមួយចេតនានោះ ឈ្មោះថា អាយូហនសង្ខារ ។

បទថា **និកន្តិ តណ្ហា** បានដល់ កាម គឺសេចក្តីប្រាថ្នាក្នុងផល គឺក្នុងឧបបត្តិភពរបស់អ្នកធ្វើកម្ម ឈ្មោះថា **តណ្ហា**។ បទថា **ឧបគមនំ ឧបាទានំ** សេចក្តីថា ការប្រកាន់ គឺការប្រកាន់មាំដែលជាបច្ច័យនៃកម្មភពដែលប្រព្រឹត្តទៅហើយថា កាលធ្វើកម្មនេះនឹងសម្រេចតាមបំណងដូច្នេះក្តី អញធ្វើកម្មនេះ

ហើយ នឹងបានសោយកាម ក្នុងឋានៈនោះដូច្នេះក្តី អត្តា គឺតួខ្លួនដាច់សូន្យ ក៏ឈ្មោះថា ដាច់សូន្យដោយល្អដូច្នេះក្តី មានសេចក្តីសុខប្រាសចាកសេចក្តីក្តៅក្រហាយដូច្នេះក្តី បំពេញសីលវត្តបានដោយងាយស្រួលដូច្នេះក្តី នេះឈ្មោះថា ឧបាទាន ។ បទថា **ចេតនា ភវោ** បានដល់ ចេតនាដែលពោលហើយក្នុងទីបំផុតនៃកម្មដែលប្រមូលមក ឈ្មោះថា ភព ។

បទថា **បុរិមកម្មភវស្មឹ** បានដល់ អវិជ្ជាដែលប្រព្រឹត្តទៅក្នុងកម្មភពដែលធ្វើក្នុងអតីតជាតិ ។ បទថា **ឥធ បដិសន្ធិយា បច្ចយា** បានដល់ ជាបច្ច័យនៃបដិសន្ធិក្នុងបច្ចុប្បន្ន ។ បទថា **ឥធ បដិសន្ធិ វិញ្ញាណំ** បានដល់ធម្មជាតដែលលោកពោលថាជាបដិសន្ធិ ព្រោះកើតឡើងដោយអំណាចនៃការបន្តគ្នាក្នុងរវាងភពនៃភពបច្ចុប្បន្ន ឈ្មោះថា វិញ្ញាណ ។ បទថា **ឱក្កន្តិ នាមរូបំ** បានដល់ ការឈានចុះក្នុងគភ៌នៃរូបធម៌ និងអរូបធម៌ដូចមកហើយចូលទៅ នេះឈ្មោះថា នាមរូប ។ បទថា **បសាទោ អាយតនំ** បានដល់ ភាពដែលរូបថ្លា នេះជាអាយតនៈ ។ លោកធ្វើជាឯកវចនៈ ដោយកាន់យកប្រភពកើត ។ ដោយបទនេះ លោកពោលដល់អាយតនៈ ៥ មានចក្ខាយតនៈជាដើម ។

គប្បីជ្រាបថា សូម្បីមនាយតនៈលោកក៏ពោលដោយពាក្យថា **បសាទ** ព្រោះមនាយតនៈក្នុងទីនេះជាវិបាក ដោយពាក្យអធិប្បាយ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះ មានរស្មីផ្សាយចេញ ប៉ុន្តែចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុកៈ ចូលមកធ្វើឲ្យសៅហ្មងដូច្នេះ ក្នុងព្រះបាលីនេះ លោកបំណងយកភវង្គចិត្ត និងព្រោះមនាយតនៈ

នោះថា ព្រោះមិនមានកិលេសផ្សាយឡើង ។ បទថា **ផុដ្ឋោ ផស្សោ** បានដល់ចំណែកដែលពាល់ត្រូវអារម្មណ៍កើតឡើង នេះឈ្មោះថា ផស្សៈ ។ បទថា **វេទយិតំ វេទនា** បានដល់ ការសោយវិបាកដែលកើតរួមជាមួយបដិសន្ធិវិញ្ញាណក្តី ជាមួយផស្សៈដែលមានសឡាយតនៈជាបច្ច័យក្តី នេះឈ្មោះថា វេទនា ។ បទថា **ឥធុបបត្តិភវស្មឹ បុរេកតស្ស កម្មស្ស បច្ចយា** សេចក្តីថា ធម៌ទាំងឡាយ ក្នុងវិបាកភពដែលជាបច្ចុប្បន្ន រមែងប្រព្រឹត្តទៅដោយបច្ច័យនៃកម្មដែលធ្វើក្នុងអតីតជាតិ ។

បទថា **ឥធ បរិបក្កត្តា អាយតនានំ** នេះ លោកសំដែងមោហៈជាដើម ក្នុងការធ្វើកម្មរបស់បុគ្គលមានអាយតនៈចាស់ក្លាដោយជុំវិញ ។ បទថា **អាយតឹ បដិសន្ធិយា** បានដល់ ជាបច្ច័យដល់បដិសន្ធិ ក្នុងអនាគតកាល ។ បទថា **អាយតឹ បដិសន្ធិ វិញ្ញាណំ** ជាដើម មានអត្ថដូចបានពោលហើយ ។

លោកកាន់យកអាការទាំង ២០ នេះ ដោយអង្គនៃបដិច្ចសមុប្បាទ ១២ តើដូចម្តេច លោកពោលធម៌ទាំង ២ នេះ គឺអវិជ្ជា សង្ខារ ដោយសរុបថាជាហេតុក្នុងអតីត ។ ក៏ព្រោះបុគ្គលមិនមានបញ្ញារមែងតក់ស្លុត តក់ស្លុតហើយរមែងប្រកាន់មាំ ភពរមែងមាន ព្រោះការប្រកាន់មាំរបស់បុគ្គលនោះជាបច្ច័យហេតុនោះ ទើបលោកកាន់យកតណ្ហា ឧបាទាន និងភពដោយធម៌ទាំង ២ ដែលកាន់យកហើយទាំងនោះ ។ លោកពោលដោយសរុប ដល់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនាក្នុងបច្ចុប្បន្ន ។ តណ្ហា ឧបាទាន និងភព លោកពោលដោយសរុបថា ជាហេតុក្នុងបច្ចុប្បន្ន ។ កាលកាន់យកភពហើយ សង្ខារ

ទាំងឡាយ ដែលជាចំណែកខាងដើមនៃភពនោះ ឬដែលសម្បយុត្តដោយភពនោះ ឈ្មោះថា កាន់យកហើយនោះឯង ឯសង្ខារទាំងឡាយដែលសម្បយុត្តដោយភពនោះ ក៏ឈ្មោះថា កាន់យកហើយដោយតណ្ហា និងឧបាទានសព្វ ៗ ម្យ៉ាងវិញទៀត លោកកាន់យកធម្មជាតដែលជាហេតុឲ្យបុគ្គលល្ងង់ខ្លៅធ្វើកម្មថា ជាអវិជ្ជា ។ លោកពោលសរុបធម៌ ២ យ៉ាង គឺជាតិ ជរា មរណៈ ក្នុងអនាគត អនាគតផល ៥ មានវិញ្ញាណជាដើម ឈ្មោះថា កាន់យកហើយដោយជាតិ ជរា មរណៈ សព្វនោះឯង ។ ពិតហើយ ជាតិ ជរា មរណៈ រមែងមានដល់អនាគតផល ៥ មានវិញ្ញាណជាដើមទាំងនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា កាន់យកអាការ ២០ ដោយអង្គ ១២ ដោយប្រការដូច្នេះ ។

លោកពោលសេចក្តីនេះដោយគាថាថា

អតីតហេតុ ៥ បច្ចុប្បន្នផល ៥ បច្ចុប្បន្នហេតុ ៥ អនាគតផល ៥ ។

បទថា **ឥតិមេ** កាត់បទជា **ឥតិ ឥមេ**។ បាឋៈថា **ឥតិ ឥមេ** ដូច្នេះ ក៏មាន ។ បទថា **ចតុសង្ខេបេ** បានដល់ នូវគំនរ ៤ ។ ធម៌ជាហេតុ ៥ ក្នុងអតីត ជាហេតុសង្ខេប ១ ។ ធម៌ជាផល ៥ ក្នុងបច្ចុប្បន្នជាផលសង្ខេប ១ ។ ធម៌ជាហេតុ ៥ ក្នុងបច្ចុប្បន្នជាហេតុសង្ខេប ១ ។ ធម៌ជាផល ៥ ក្នុងអនាគតជាផលសង្ខេប ១ ។ បទថា **តយោ អទ្ធេ** បានដល់ នូវកាល ៣ ។ អតីតកាល គប្បីជ្រាបដោយអំណាចបញ្ចកៈទី ១ បច្ចុប្បន្នកាល គប្បីជ្រាបដោយអំណាចបញ្ចកៈទី ២ និងទី ៣ អនាគតកាលគប្បីជ្រាបដោយអំណាច

បញ្ចកៈទី ៤ ។

បទថា **តិសន្ធឹ** ឈ្មោះថា **តិសន្ធិ** ព្រោះអត្ថថា មានសន្ធិ ៣ ។ នូវសន្ធិ ៣ នោះ ។ អធិប្បាយថា សន្ធិ ( តំណ ) នៃហេតុ និងផល ១ មានក្នុងរវាងនៃហេតុក្នុងអតីត និងផលក្នុងបច្ចុប្បន្ន សន្ធិនៃផល និងហេតុ ១ មានក្នុងរវាងនៃផលបច្ចុប្បន្ន និងហេតុក្នុងអនាគត សន្ធិនៃហេតុ និងផល ១ មានក្នុងរវាងនៃហេតុក្នុងបច្ចុប្បន្ន និងផលក្នុងអនាគត ។

តែពោលដោយអំណាចមកហើយក្នុងបាលីនៃបដិច្ចសមុប្បាទ ( ដូច្នេះថា ) អវិជ្ជា និងសង្ខារ ជាសង្ខេបទី ១ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនាជាសង្ខេបទី ២ តណ្ហា ឧបាទាន និងភពជាសង្ខេបទី ៣ ជាតិ និងជរាមរណៈ ជាសង្ខេបទី ៤ ។ អង្គ ២ គឺអវិជ្ជា និងសង្ខារជាអតីតកាល ធម៌ ៨ មានវិញ្ញាណជាដើម មានភពជាទីបំផុត ជាបច្ចុប្បន្នកាល អង្គ ២ គឺជាតិ និងជរាមរណៈជាអនាគតកាល សន្ធិនៃហេតុ និងផល ១ មានក្នុងរវាងនៃសង្ខារ និងវិញ្ញាណ សន្ធិនៃផល និងហេតុ ១ មានក្នុងរវាងនៃវេទនា និងតណ្ហា សន្ធិនៃហេតុ និងផល ១ មានក្នុងរវាងនៃភព និងជាតិ ។ បទថា **វីសតិយា អាការេហិ** បានដល់ ដោយអាការ ២០ ។ គប្បីជ្រាប់សេចក្ដីថា ព្រះយោគាវចរ រមែងដឹងបដិច្ចសមុប្បាទដែលមានសង្ខេប ៤ កាល ៣ សន្ធិ ៣ ដោយអាការ ២០ ដូច្នេះ ។ បទថា **ជានាតិ** បានដល់ រមែងដឹងដោយញាណក្នុងការផ្ដើម ភាវនាដោយទំនងដូចគ្នានឹងសុតៈ គឺការស្ដាប់ ។

បទថា **បស្សតិ** បានដល់ រមែងឃើញដោយញាណនោះឯង ដោយធ្វើ

វត្ថុដែលដឹងហើយនោះឯង ដូចឃើញដោយភ្នែក និងធ្វើវត្ថុដែលពាល់ត្រូវហើយ ដូចប៉ះផ្លែកន្ទួតព្រៃលើបាតដៃ ។ បទថា **អញ្ញាតិ** បានដល់ រមែងធ្វើការស្និទ្ធស្នាលដោយព្រំដែនដែលឃើញហើយដឹងដោយញាណ ។ អត្ថនៃព្រំដែនក្នុងទីនេះ គឺអាការ ។ បទថា **បដិវិជ្ឈតិ** បានដល់ ឲ្យដល់នូវការសម្រេចដោយការបំពេញការនាំឲ្យបរិបូណ៌ ធ្វើនូវការចាក់ធ្លុះដោយញាណនោះឯង ។ ម្យ៉ាងទៀត រមែងដឹងដោយអំណាចលក្ខណៈរបស់ខ្លួន រមែងឃើញដោយអំណាចកិច្ចរបស់ខ្លួន រមែងដឹងទូទៅដោយអំណាចអាការប្រាកដ រមែងចាក់ធ្លុះដោយអំណាចជាហេតុជិត ។

ក្នុងបទទាំងនោះ គប្បីជ្រាបធម៌ជាបច្ច័យថាជាបដិច្ចសមុប្បាទ ។ គប្បីជ្រាបធម៌ដែលកើតឡើងដោយបច្ច័យនោះៗ ថា ជាបដិច្ចសមុប្បន្នធម៌ ( ធម៌ដែលអាស្រ័យបច្ច័យកើតឡើង ) ។ បើសួរថា ដឹងបានដូចម្តេច ឆ្លើយថា គប្បីដឹងបានដោយព្រះពុទ្ធវចនៈ ។ ព្រោះក្នុងសូត្រពោលដោយការសម្តែងបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិច្ចសមុប្បាទយ៉ាងនេះថា

> ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បាទធម៌ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យ ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ ឥទប្បច្ច័យនោះ តែងស្ថិតនៅជាធម្មតា តថាគតត្រាស់ដឹង យល់ច្បាស់នូវបច្ច័យនោះ

លុះត្រាស់ដឹងយល់ច្បាស់ហើយ ទើបប្រាប់ សម្តែង ពន្យល់ តែងតាំង បើក បង្ហាញ ចែករំលែក ធ្វើឲ្យរាក់ ហើយប្រាប់ ថែមថា អ្នកទាំងឡាយ ចូរមើលចុះ ។ ម្នាលភិក្ខុទាំងឡាយ ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យ ។បេ។ ម្នាលភិក្ខុទាំង ឡាយ ជាតិកើតមានព្រោះភពជាបច្ច័យ ... ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ព្រះតថាគត កើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ។បេ។ ធ្វើឲ្យរាក់ ហើយប្រាប់ថែមថា អ្នកទាំងឡាយ ចូរមើលចុះ ។ ម្នាលភិក្ខុ ទាំងឡាយ សង្ខារទាំងឡាយកើតមានព្រោះអវិជ្ជាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណាជារបស់ពិត ទៀងទាត់ មិន ប្រែប្រួល មានសភាវៈនេះជាបច្ច័យក្នុងធម៌នោះ ម្នាលភិក្ខុទាំង ឡាយ នេះហៅថា បដិច្ចសមុប្បាទធម៌ ដោយប្រការដូច្នេះឯង ។

ព្រះមានព្រះភាគ ត្រាស់ធម៌ដែលជាបច្ច័យនោះឯង ដោយវេវចនៈទាំង ឡាយ មានសេចក្តីពិតជាដើម ថាជាបដិច្ចសមុប្បាទ ព្រោះហេតុនោះ ទើប បដិច្ចសមុប្បាទ មានភាពជាបច្ច័យដល់ធម៌ទាំងឡាយ មានជរា និងមរណៈ ជាដើមជាលក្ខណៈ មានការពាក់ព័ន្ធជាមួយទុក្ខជាកិច្ច មានផ្លូវខុសជាអាការ ប្រាកដ មានបច្ច័យពិសេសរបស់ខ្លួនជាហេតុជិត ព្រោះសូម្បីខ្លួនឯង ក៏មាន បច្ច័យ ។

ពាក្យថា ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី បាន

ដល់ កាលទ្រង់កើតក្តី មិនទាន់កើតក្តី អធិប្បាយថា កាលព្រះតថាគតទាំងឡាយ ទ្រង់កើតហើយក្តី ទ្រង់មិនទាន់កើតហើយក្តី ។ ពាក្យថា ធាតុនោះ ... តែងស្ថិតនៅជាធម្មតា បានដល់ សភាពនៃបច្ច័យនោះ តាំងនៅដូចដើម អធិប្បាយថា ក្នុងកាលណាៗ ធាតុនោះនឹងមិនជាបច្ច័យដល់ជាតិ ជរា និង មរណៈមិនមានឡើយ ។ ពាក្យថា ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ ឥទប្បច្ច័យនោះ បានដល់ មានជាតិជាបច្ច័យនោះឯង ។ ក៏ព្រោះជាតិជាបច្ច័យ ធម៌ដែលអាស្រ័យបច្ច័យកើតឡើង ពោល គឺជរា និងមរណៈ រមែងតាំងនៅព្រោះទាក់ទងគ្នាជាមួយជាតិនោះ ។ ជាតិជាបច្ច័យនោះឯង រមែងកំណត់ធម៌ គឺជរា មរណៈ ព្រោះហេតុនោះ ទើបជាតិហៅថា ធម្មដ្ឋិតិ ធម្មនិយាម ដូច្នេះ ។ ជាតិនោះឯងជាបច្ច័យដល់ជរា និងមរណៈនេះ ព្រោះហេតុនោះ ទើបឈ្មោះថា ឥទប្បច្ចយៈ ឥទប្បច្ចយៈនោះឯង ឈ្មោះថា ឥទប្បច្ចយតា ។ ពាក្យថា បច្ច័យនោះ បានដល់ បច្ច័យនោះ ។ ពាក្យថា ត្រាស់ដឹង បានដល់ ត្រាស់ដឹងដោយញាណ ។ ពាក្យថា យល់ច្បាស់ បានដល់ យល់ច្បាស់ដោយញាណ ។ ពាក្យថា ប្រាប់ បានដល់ ទ្រង់ពោល ។ ពាក្យថា សម្តែង បានដល់ ទ្រង់ចង្អុលបង្ហាញ ។ ពាក្យថា ពន្យល់ បានដល់ ទ្រង់ឲ្យដឹង ។ ពាក្យថា តែងតាំង បានដល់ ទ្រង់តាំងនៅក្នុងញាណមុខ ។ ពាក្យថា បើក បានដល់ ទ្រង់បើកសម្តែង ។ ពាក្យថា ចែករលែក បានដល់ ទ្រង់សម្តែងដោយចែក ។ ពាក្យថា ធ្វើឲ្យរាក់ បានដល់ ធ្វើឲ្យប្រាកដ ។ ពាក្យថា ដោយប្រការដូច្នេះឯង ( **ឥតិ ខោ** ) ខែជា **ឯវំ ខោ** ។ ពាក្យថា ក្នុងធម៌នោះ បានដល់ ក្នុងពាក្យថា ជរាមរណៈ

កើតមានព្រោះជាតិជាបច្ច័យជាដើមនោះឯង ។

ក្នុងបដិច្ចសមុប្បាទនេះ ទ្រង់ត្រាស់ថា ពិត ព្រោះធម៌នោះៗ កើតដោយបច្ច័យនោះៗ មិនលើសមិនខ្វះនោះឯង ។ ទ្រង់ត្រាស់ថា ទៀងទាត់ ព្រោះមិនមានការមិនកើតនៃធម៌ដែលកើតពីបច្ច័យនោះ សូម្បីមួយខណៈក្នុងបច្ច័យដែលចូលដល់សេចក្តីព្រមព្រៀង ។ ទ្រង់ត្រាស់ថា មិនប្រែប្រួល ព្រោះមិនមានការកើតឡើងនៃធម៌ដទៃចាកបច្ច័យ គឺធម៌ដទៃ ។ ទ្រង់ត្រាស់ថា ឥទប្បច្ច័យ ព្រោះជាបច្ច័យដល់ជរា និងមរណៈជាដើម តាមដែលពោលហើយនោះឯង ឬព្រោះជាទីរួមនៃបច្ច័យ ។

ក្នុងបទនោះ មានពាក្យអធិប្បាយដូចតទៅនេះ បច្ច័យនៃធម៌ទាំងនោះ ឈ្មោះថា ឥទប្បច្ច័យ ឥទប្បច្ច័យនោះឯង ឈ្មោះថា ឥទប្បច្ចយតា ម្យ៉ាងទៀត ការរួមឥទប្បច្ច័យទាំងឡាយ ឈ្មោះថា ឥទប្បច្ចយតា ។ តែក្នុងទីនេះ គប្បីជ្រាបលក្ខណៈដោយសព្ទសាស្ត្រ ៕

## អដ្ឋកថាធម្មដ្ឋិតិញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ៩៩ ] បញ្ញាក្នុងការបង្រួញនូវពួកធម៌ ជាអតីត អនាគត និងបច្ចុប្បន្ន ហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ តើដូចម្ដេច ។ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី រូបណាក្នុងទីឆ្ងាយ ឬទីជិតក្ដី បុគ្គលកំណត់ទុកនូវរូបទាំងអស់នោះថាមិនទៀង ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកថាជាទុក្ខ ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកថាមិនមែនខ្លួន ឈ្មោះថា សម្មសនញ្ញាណ ១ វេទនាណាមួយ ។បេ។ សញ្ញាណាមួយ សង្ខារណាមួយ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី វិញ្ញាណណាក្នុងទីឆ្ងាយ ឬទីជិតក្ដី បុគ្គលកំណត់ទុកនូវវិញ្ញាណទាំងអស់នោះថាមិនទៀង ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកថាជាទុក្ខ ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកថាមិនមែនខ្លួន ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកនូវចក្ខុ ។បេ។ កំណត់ទុកនូវជរា និងមរណៈ ជាអតីត អនាគត បច្ចុប្បន្នថាមិនទៀង ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកថាជាទុក្ខ ឈ្មោះថា សម្មសនញ្ញាណ ១ កំណត់ទុកថាមិនមែនខ្លួន ឈ្មោះថា សម្មសនញ្ញាណ ១ ។

[ ១០០ ] រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ឈ្មោះថា ទុក្ខ ដោយអត្ថថា គួរខ្លាច ឈ្មោះថា អនត្តា ដោយអត្ថថា មិនមានខ្លឹម ហេតុនោះ បញ្ញាក្នុងការបង្រួញ ហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។

ជរា និងមរណៈជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ឈ្មោះថា ទុក្ខ ដោយអត្ថថា គួរខ្លាច ឈ្មោះថា មិនមែនខ្លួន ដោយអត្ថថា មិនមានខ្លឹម ហេតុនោះ បញ្ញាក្នុងការបង្រួញ ហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ ។

[ ១០១ ] រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះគ្រឿងអាស្រ័យ មានការអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសចាកតម្រេកជាធម្មតា រលត់ទៅជាធម្មតា ហេតុនោះ បញ្ញាក្នុងការបង្រួញហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរា និងមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើង ព្រោះគ្រឿងអាស្រ័យ មានការអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសចាកតម្រេកជាធម្មតា រលត់ទៅជាធម្មតា ហេតុនោះ បញ្ញាក្នុងការបង្រួញហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ ។

[ ១០២ ] ជរា និងមរណៈមាន ព្រោះជាតិជាបច្ច័យ កាលជាតិមិនមាន ជរា និងមរណៈក៏មិនមាន ហេតុនោះ បញ្ញាក្នុងការបង្រួញ ហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ ជរា និងមរណៈមាន ព្រោះជាតិជាបច្ច័យ កាលបើជាតិមិនមាន ជរា និងមរណៈក៏មិនមាន អស់អតីតកាលផង អស់អនាគត-កាលផង ហេតុនោះ បញ្ញាក្នុងការបង្រួញហើយកំណត់ទុក ឈ្មោះថា សម្ម-សនញ្ញាណ ជាតិមានព្រោះភពជាបច្ច័យ កាលបើភពមិនមាន ។បេ។ ភពមាន

ព្រោះឧបាទានជាបច្ច័យ កាលបើឧបាទានមិនមាន ភពក៏មិនមាន ឧបាទានមាន ព្រោះតណ្ហាជាបច្ច័យ កាលបើតណ្ហាមិនមាន ឧបាទានក៏មិនមាន តណ្ហាមាន ព្រោះវេទនាជាបច្ច័យ កាលបើវេទនាមិនមាន តណ្ហាក៏មិនមាន វេទនាមាន ព្រោះផស្សៈជាបច្ច័យ កាលបើផស្សៈមិនមាន វេទនាក៏មិនមាន ផស្សៈមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ កាលបើអាយតនៈ ៦ មិនមាន ផស្សៈក៏មិនមាន អាយតនៈ ៦ មាន ព្រោះនាម និងរូបជាបច្ច័យ កាលបើនាម និងរូបមិនមាន អាយតនៈ ៦ ក៏មិនមាន នាម និងរូបមាន ព្រោះវិញ្ញាណជាបច្ច័យ កាលបើវិញ្ញាណមិនមាន នាម និងរូបក៏មិនមាន វិញ្ញាណមាន ព្រោះសង្ខារជាបច្ច័យ កាលបើសង្ខារមិនមាន វិញ្ញាណក៏មិនមាន សង្ខារមាន ព្រោះអវិជ្ជាជាបច្ច័យ កាលបើអវិជ្ជាមិនមាន សង្ខារក៏មិនមាន ហេតុនោះ បញ្ញាក្នុងការបង្រួញហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ សង្ខារមាន ព្រោះអវិជ្ជាជាបច្ច័យ កាលបើអវិជ្ជាមិនមាន សង្ខារក៏មិនមាន អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការបង្រួញហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការបង្រួញហើយកំណត់ទុកនូវពួកធម៌ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា សម្មសនញ្ញាណ ។

# អដ្ឋកថា

# សម្មសនញ្ញាណនិទ្ទេស

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មសនញ្ញាណនិទ្ទេសដូចតទៅ បទថា **យំកិញ្ចិ** បានដល់ កំណត់កាន់យកមិនមានសេសសល់ ។ បទថា **រូបំ** បានដល់ ជាការកំណត់ការជាប់ជំពាក់យ៉ាងក្រៃលែង ។ លោកធ្វើការកំណត់ដោយមិនមានសេសសល់នូវរូប ដោយពាក្យទាំងពីរនេះ ។ កាលបើដូច្នោះ ព្រះសារីបុត្ត រមែងប្រារព្ធការចែករូបនោះដោយជារូបដែលជាអតីតជាដើម ។ រូបនោះ រូបខ្លះជាអតីត រូបខ្លះមានប្រភេទជាអនាគតជាដើម ។ សូម្បីក្នុងវេទនាជាដើមក៏មានន័យនេះ ។ ក្នុងបទនោះ រូប ឈ្មោះថា ជាអតីត ៤ យ៉ាង ដោយអំណាចនៃកាល ការបន្តសម័យ និងខណៈ រូបអនាគត និងបច្ចុប្បន្នក៏យ៉ាងនោះ ។

ក្នុង ៤ យ៉ាងនោះ ពោលដោយអំណាចនៃកាលមុន រូបក្នុងកាលមុនអំពីបដិសន្ធិក្នុងភពមួយរបស់រូបមួយ ជាអតីត ។ បន្ទាប់អំពីចុតិទៅជាអនាគត ក្នុងរវាងទាំងពីរនៃបដិសន្ធិ និងចុតិជាបច្ចុប្បន្ន ។

ពោលដោយអំណាចនៃការបន្ត រូបដែលមានឧតុតែម្យ៉ាងដែលជាសភាគគ្នាជាសមុដ្ឋាន និងមានអាហារតែម្យ៉ាងជាសមុដ្ឋាន សូម្បីប្រព្រឹត្តទៅដោយការប្រព្រឹត្តទៅមុន ឬក្រោយក៏ជាបច្ចុប្បន្ន រូបដែលមានឧតុ និងអាហារដែលជាវិសភាគគ្នាជាសមុដ្ឋានមុននោះទៅ ជាអតីត ក្រោយនោះទៅ ជាអនាគត ។ រូបដែលកើតអំពីចិត្តដែលមានវីថិចិត្ត ១ ជវនចិត្ត ១ សមាបត្តិ ១ កាលជា

សមុដ្ឋាន ជាបច្ចុប្បន្ន មុននោះទៅ ជាអតីត ក្រោយនោះទៅ ជាអនាគត ។ ការផ្សេងគ្នានៃរូបដែលជាអតីតជាដើមនៃរូប ដែលមានកម្មជាសមុដ្ឋានដោយអំណាចការបន្តចំពោះរមែងមិនមាន តែគប្បីជ្រាបភាពដែលរូបជាអតីតជាដើមនៃរូបដែលមានកម្មជាសមុដ្ឋាននោះ ដោយអំណាចការឧបត្ថម្ភនៃរូបដែលមានឧតុ អាហារ និងចិត្តជាសមុដ្ឋាននោះឯង ។

ពោលដោយអំណាចនៃសម័យ រូបដែលប្រព្រឹត្តទៅដោយអំណាចការបន្តគ្នាក្នុងសម័យទាំងឡាយ មានមួយស្របក់ ពេលព្រឹក ពេលល្ងាច ពេលយប់ និងពេលថ្ងៃជាដើម ដែលមានក្នុងសម័យនោះៗ ឈ្មោះថា បច្ចុប្បន្ន ។ មុនអំពីនោះ ជាអតីត ក្រោយអំពីនោះ ជាអនាគត ។

ពោលដោយអំណាចនៃខណៈ រូបដែលទាក់ទងក្នុងខណៈ ៣ មានឧប្បាទក្ខណៈជាដើម ជាបច្ចុប្បន្ន មុនអំពីនោះ ជាអនាគត ក្រោយអំពីនោះ ជាអតីត ។ ម្យ៉ាងទៀត រូបមានកិច្ចដែលជាហេតុ ជាបច្ច័យកន្លងទៅហើយ ជាអតីត រូបមានកិច្ចដែលជាហេតុចប់ហើយ តែមានកិច្ចជាបច្ច័យមិនទាន់ចប់ ជាបច្ចុប្បន្ន រូបដែលមិនទាន់ដល់ព្រមនូវកិច្ចទាំងពីរ ជាអនាគត ។ ម្យ៉ាងទៀត រូបក្នុងខណៈនៃកិច្ចរបស់ខ្លួន ជាបច្ចុប្បន្ន មុននោះ ជាអនាគត ក្រោយនោះ ជាអតីត ម្យ៉ាងទៀត ក្នុងពាក្យនេះ កថាពោលដោយខណៈជាដើម ជាកថាត្រង់ កថាដ៏សេស ជាកថាអម ។

បទថា **អជ្ឈត្តំ** បានដល់ ក្នុងខ្លួន ៥ យ៉ាង ក្នុងទីនេះ លោកបំណងយកខន្ធខាងក្នុងរបស់ខ្លួនឯង ព្រោះហេតុនោះ រូបដែលកើតចំពោះបុគ្គលដែល

ប្រព្រឹត្តទៅក្នុងសន្តានរៀងៗ ខ្លួន គប្បីជ្រាបថា ជាខាងក្នុង ។

តែរូបខាងក្រៅអំពីនោះ ដែលទាក់ទងដោយឥន្ទ្រិយក្តី មិនទាក់ទងដោយឥន្ទ្រិយក្តី ឈ្មោះថា ខាងក្រៅ ។

បទថា **ឱឡារិកំ** បានដល់ រូប ១២ យ៉ាង គឺចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដែលបានដល់បឋវី តេជោ វាយោ ឈ្មោះថា គ្រោតគ្រាត ព្រោះកំណត់កាន់យកបានដោយអំណាចការប៉ះខ្ទប់ ។ ចំណែករូបដែលសល់ ១៦ យ៉ាង គឺអាបោធាតុ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ហទយវត្ថុ ឱជា អាកាសធាតុ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបលហុតា រូបមុទុតា រូបកម្មញ្ញតា ឧបចយៈ សន្តតិ ជរតា អនិច្ចតា ឈ្មោះថា ល្អិត ព្រោះកំណត់កាន់យកមិនបានដោយអំណាចការប៉ះខ្ទប់ ។

ក្នុងបទនេះថា **ហីនំ វា បណីតំ វា** ភាពជារូបថោកទាប ឬប្រណីត មានទាំងដោយអម និងដោយត្រង់ ក្នុងបទនោះ រូបរបស់ព្រហ្មជាន់សុទស្សី ជារូបថោកទាបជាងរូបរបស់ព្រហ្មជាន់អកនិដ្ឋ រូបរបស់ព្រហ្មជាន់សុទស្សីនោះៗ ឯង ប្រណីតជាងរូបរបស់ព្រហ្មជាន់សុទស្សា គប្បីជ្រាបសភាពថោកទាប និងប្រណីត ដោយអម រហូតដល់រូបរបស់សត្វនរកដោយអាការយ៉ាងនេះ ។ តែបើពោលដោយត្រង់ រូបដែលមានអកុសលវិបាកកើតឡើង ជារូបថោកទាប រូបដែលជាកុសលវិបាកកើតឡើង ជារូបប្រណីត ។

ក្នុងបទថា **យំ ទូរេ សន្តិកេ វា** នេះ រូបណាល្អិត រូបនោះឯង ឈ្មោះថា ឆ្ងាយ ព្រោះមានសភាពចាក់ធ្លុះបានដោយលំបាក ។ រូបណាគ្រោតគ្រាត

រូបនោះ ឈ្មោះថា ជិត ព្រោះមានសភាពចាក់ដូះបានងាយ ។

ក្នុងបទនេះថា **សព្វំ រូបំ អនិច្ចតោ វវត្ថេតិ ឯកំ សម្មសនំ ទុក្ខតោ វវត្ថេតិ ឯកំ សម្មសនំ អនត្តតោ វវត្ថេតិ ឯកំ សម្មសនំ** សេចក្តីថា ភិក្ខុនេះ កំណត់រូបទាំងអស់ដែលមិនបានចង្អុលបង្ហាញ ដោយកំណត់ពិតប្រាកដយ៉ាងនេះថា រូបណាមួយដោយឱកាស ១១ យ៉ាង គឺដោយតិកៈនៃរូបមានអតីតជាដើម និងដោយពួកពីរ ៤ ពួក មានរូបខាងក្នុងជាដើម ហើយកំណត់រូបទាំងពួងដោយភាពជារបស់មិនទៀងរមែងពិចារណាថា រូបមិនទៀង ពិចារណាដូចម្តេច ពិចារណាដោយន័យដែលព្រះសារីបុត្ត ពោលហើយខាងមុខ ។

[ ១០០ ] សមដូចព្រះសារីបុត្តពោលថា **រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន** រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀងដោយអត្ថថា អស់ទៅ ព្រោះហេតុនោះ ភិក្ខុនោះរមែងពិចារណាថា រូបជាអតីតអស់ទៅក្នុងអតីតនោះឯង រូបនោះមិនអាចមកដល់ភពនេះ ព្រោះហេតុនោះទើបឈ្មោះថា មិនទៀង ព្រោះអត្ថថា អស់ទៅ រូបដែលជាអនាគតនឹងកើតក្នុងភពជាលំដាប់តទៅ សូម្បីរូបនោះក៏នឹងអស់ទៅក្នុងភពនោះៗ ឯង នឹងមិនទៅកាន់ភពដទៃអំពីភពនោះ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ព្រោះអត្ថថា អស់ទៅ រូបដែលជាបច្ចុប្បន្ន រមែងអស់ទៅក្នុងភពនេះឯង រមែងមិនទៅអំពីភពនេះ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ព្រោះអត្ថថា អស់ទៅ រូបដែលជាខាងក្នុង ក៏អស់ទៅក្នុងខាងក្នុងនោះឯង មិនទៅកាន់ចំណែកខាង

ក្រៅ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ព្រោះអត្ថថា អស់ទៅ ។ សូម្បីរូបខាងក្រៅគ្រោតគ្រាត និងល្អិត ថោកទាប ប្រណីត មាននៅក្នុងទីឆ្ងាយ មាននៅក្នុងទីជិតក៏អស់ទៅក្នុងទីនោះៗ ឯង រមែងមិនទៅកាន់ទីឆ្ងាយ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ព្រោះអត្ថថា អស់ទៅ ។ សូម្បីការពិចារណាទាំងអស់នេះ ក៏ជាសម្មសនញ្ញាណ ម្យ៉ាងដោយអំណាចនៃបទនេះថា **អនិច្ចំ ខយដ្ឋេន** តែដោយប្រភេទ មាន ១១ យ៉ាង ។

ម្យ៉ាងទៀត ភិក្ខុរមែងពិចារណារូបនោះទាំងអស់ថា **ទុក្ខំ ភយដ្ឋេន** ។ បទថា **ភយដ្ឋេន** បានដល់ ព្រោះមានភ័យចំពោះមុខ ។ ពិតហើយ វត្ថុដែលមិនទៀង រមែងនាំមកនូវភ័យដូចភ័យរបស់ពួកទេវតាក្នុងសីហោបមសូត្រ ។ ព្រោះហេតុនោះ សូម្បីការពិចារណានេះ ក៏ជាសម្មសនញ្ញាណមួយយ៉ាង ដោយអំណាចនៃបទនេះថា **ទុក្ខំ ភយដ្ឋេន** តែដោយប្រភេទ មាន ១១ យ៉ាង ។

ម្យ៉ាងទៀត ភិក្ខុរមែងពិចារណាថា រូបជាទុក្ខយ៉ាងណា រូបទាំងអស់នោះក៏ជាអនត្តា ព្រោះអត្ថថា មិនមានខ្លឹមសារ ក៏យ៉ាងនោះ ។ បទថា **អសារកដ្ឋេន** បានដល់ ព្រោះមិនមានសារៈក្នុងខ្លួនដែលកំណត់យ៉ាងនេះថា តួខ្លួន អ្នកអាស្រ័យ អ្នកធ្វើ អ្នកសោយដែលមានអំណាចដោយខ្លួនឯង ។ ពិតហើយ ធម៌ណាមិនទៀង ធម៌នោះជាទុក្ខ ធម៌នោះមិនអាចហាមការមិនទៀង ឬការបៀតបៀន ការកើត និងការវិនាសនៃតួខ្លួនបាន ភាវៈដែលរូបនោះជាអ្នកធ្វើជាដើមនឹងមានអំពីណា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងវិនយបិដក មហាវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ រូបនេះ

ជារបស់ខ្លួនពិតមែន រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជំនឺតម្កាត់ឡើយ ដូច្នេះ ។ ព្រោះហេតុនោះ ការពិចារណានេះ ទើបជាសម្មសនញ្ញាណមួយយ៉ាងដោយអំណាចនៃបទនេះថា **អនត្តា អសារកដ្ឋេន** ឈ្មោះថា អនត្តា ដោយអត្ថថា មិនមានខ្លឹម ឯដោយប្រភេទ មាន ១១ យ៉ាង ។ ក្នុងវេទនាជាដើមក៏មានន័យនោះដូចគ្នា ។ ដោយប្រការដូច្នេះ ក្នុងខន្ធ ៥ ធ្វើខន្ធនីមួយៗ ១១ យ៉ាង ទើបជាសម្មសនញ្ញាណ ៥៥ ទើបរួមជាសម្មសនញ្ញាណ ១៦៥ យ៉ាង ដោយអំណាចអនុបស្សនា ៣ គឺដោយការមិនទៀង ៥៥ ដោយភាពជាទុក្ខ ៥៥ ដោយភាពជាអនត្តា ៥៥ ។

តែអាចារ្យពួកខ្លះរួមយកសូម្បីពាក្យថា **សព្វំ រូបំ សព្វំ វេទនំ សព្វំ សញ្ញំ សព្វេ សង្ខារេ សព្វំ វិញ្ញាណំ** ទើបពោលថា ក្នុងខន្ធ ៥ ធ្វើខន្ធនីមួយៗ ១២ យ៉ាង ទើបជាសម្មសនញ្ញាណ ៦០ ដោយអនុបស្សនា ៣ ទើបរួមជាសម្មសនញ្ញាណ ១៨០ យ៉ាង ។

ម្យ៉ាងទៀត ក្នុងការចែកអតីតជាដើម គប្បីជ្រាបភាពដែលវេទនាជាអតីត អនាគត និងបច្ចុប្បន្នដោយអំណាចនៃសន្តតិ និងដោយអំណាចនៃខណៈជាដើម ។ ក្នុងបទនោះ ពោលដោយអំណាចនៃការបន្តវេទនា ដែលទាក់ទងក្នុងវីថិចិត្ត ១ ជវនចិត្ត ១ សមាបត្តិ ១ និងប្រព្រឹត្តទៅដោយការប្រកបជាមួយអារម្មណ៍ ១ ជាបច្ចុប្បន្ន មុនអំពីនោះជាអតីត ក្រោយអំពីនោះ ជាអនាគត ពោលដោយអំណាចខណៈជាដើម វេទនាដែលទាក់ទងក្នុងខណៈ ៣ ប្រព្រឹត្តទៅខាងដើម ខាងចុង កណ្តាល និងធ្វើកិច្ចរបស់ខ្លួនជាបច្ចុប្បន្ន មុនអំពី

នោះជាអតីត ក្រោយអំពីនោះជាអនាគត ។ គប្បីជ្រាបសេចក្តីផ្សេងគ្នានៃវេទនាខាងក្នុង និងខាងក្រៅ ដោយអំណាចវេទនាដែលកើតខាងក្នុងខ្លួននោះឯង ។

គប្បីជ្រាបសភាពគ្រោតគ្រាត និងសភាពដែលល្អិតរបស់វេទនា ដោយអំណាចនៃជាតិ សភាវៈ បុគ្គល លោកិយ និងលោកុត្តរ ដែលលោកពោលក្នុងវិភង្គ ដោយន័យជាដើមថា វេទនាជាអកុសល ហៅថា ឱឡារិកវេទនា វេទនាជាកុសល និងអព្យាក្រឹត ហៅថា សុខុមវេទនា ដូច្នេះ ។ លំដាប់ដំបូងពោលដោយអំណាចនៃជាតិ អកុសលវេទនាប្រព្រឹត្តទៅមិនស្ងប់រម្ងាប់ ព្រោះជាហេតុធ្វើវត្ថុដែលមានទោស និងដោយការក្តៅក្រហាយព្រោះកិលេស ព្រោះហេតុនោះ ទើបជាវេទនាគ្រោតគ្រាតជាងកុសលវេទនា ជាវេទនាគ្រោតគ្រាតជាងវិបាកាព្យាកតវេទនា ដោយមានការខ្វល់ខ្វាយ មានឧស្សាហៈ មានវិបាក មានការក្តៅក្រហាយ ព្រោះកិលេស និងមានទោស ជាវេទនាគ្រោតគ្រាតជាងកិរិយាព្យាកតវេទនាដោយមានវិបាក មានការក្តៅក្រហាយព្រោះកិលេស មានការបៀតបៀន និងមានទោស ។ ចំណែកកុសលវេទនា និងអព្យាកតវេទនាជាវេទនាល្អិតជាងអកុសលវេទនា ដោយបរិយាយដូចពោលហើយ ។ កុសល-វេទនា និងអកុសលវេទនា សូម្បីទាំងពីរយ៉ាងក៏ជាវេទនាគ្រោតគ្រាតជាងវេទនាដែលជាអព្យាកតៈទាំងពីរយ៉ាង ( វិបាក និងកិរិយា ) តាមដែលប្រកបដោយមានសេចក្តីខ្វល់ខ្វាយ មានឧស្សាហៈ និងមានវិបាក ។ សូម្បីវេទនាជាអព្យា-កតៈទាំង ២ យ៉ាង ក៏ជាវេទនាល្អិតជាងវេទនាទាំងនោះ ដោយបរិយាយដូចពោលហើយ ។ គប្បីជ្រាបវេទនាគ្រោតគ្រាត និងល្អិត ដោយអំណាចនៃជាតិ

ដោយប្រការដូច្នេះ ។

ពោលដោយអំណាចសភាវៈ ទុក្ខវេទនាជាវេទនាគ្រោតគ្រាតជាងវេទនា ២ យ៉ាង ក្រៅអំពីនេះ ព្រោះមិនមានការពេញចិត្ត មានការផ្សាយទៅ មានការកម្រើក មានការធ្វើឲ្យតក់ស្លុត និងមានការគ្របសង្កត់ តែវេទនា ២ ក្រៅអំពីនេះជាវេទនាល្អិតជាងទុក្ខវេទនាដែលប្រកប ព្រោះមានសេចក្ដីសុខ មានភាពល្អិត មានភាពប្រណីត មានការពេញចិត្ត និងមានភាពជាកណ្ដាល ។ សុខវេទនា និងទុក្ខវេទនាទាំង ២ យ៉ាង ជាវេទនាគ្រោតគ្រាតជាងអទុក្ខមសុខវេទនា ព្រោះមានការផ្សាយទៅ មានការធ្វើឲ្យតក់ស្លុត មានការកម្រើក និងមានការប្រាកដ អទុក្ខមសុខវេទនានោះ ល្អិតជាងវេទនាទាំងពីរយ៉ាងនោះ ដោយបរិយាយដូចពោលហើយ ។ គប្បីជ្រាបភាពដែលវេទនាគ្រោតគ្រាត និងល្អិត ដោយអំណាចសភាវៈ ដោយប្រការដូច្នេះ ។

ពោលដោយអំណាចបុគ្គល វេទនារបស់អ្នកមិនចូលសមាបត្តិ ជាវេទនាគ្រោតគ្រាតជាងវេទនារបស់អ្នកចូលសមាបត្តិ ព្រោះចិត្តរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ វេទនាក្រៅអំពីនេះ ជាវេទនាល្អិតដោយបរិយាយផ្ទុយគ្នា ។ គប្បីជ្រាបភាពដែលវេទនាគ្រោតគ្រាត និងល្អិតដោយអំណាចបុគ្គល ដោយប្រការដូច្នេះ ។

ពោលដោយអំណាចលោកិយ និងលោកុត្តរ វេទនាដែលមានអាសវៈជាលោកិយ លោកិយវេទនាទាំងនោះ ជាវេទនាគ្រោតគ្រាតជាងវេទនាដែលមិនមានអាសវៈ ព្រោះជាហេតុកើតអាសវៈ ជាទីតាំងនៃឱឃៈ ជាទីតាំងនៃយោគៈ

ជាទីតាំងនៃគន្ថៈ ជាទីតាំងនៃនីវរណៈ ជាទីតាំងនៃឧបាទាន មានសេចក្តីសៅហ្មង និងជារបស់ទូទៅដល់បុថុជ្ជន ម្យ៉ាងទៀត វេទនាដែលមិនមានអាសវៈ ជាវេទនាល្អិតជាងវេទនាដែលមានអាសវៈ ដោយបរិយាយផ្សេងគ្នា ។ គប្បីជ្រាបភាពដែលវេទនាគ្រោតគ្រាត និងល្អិត ដោយអំណាចលោកិយ និងលោកុត្តរ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ គួរចៀសវាងការលាយឡំគ្នាដោយអំណាចជាតិជាដើម ។ ព្រោះថា វេទនាដែលសម្បយុត្តដោយកាយវិញ្ញាណ ដែលជាអកុសលវិបាក សូម្បីជាវេទនាល្អិត ព្រោះជាអព្យាកតៈដោយអំណាចជាតិ ក៏ជាវេទនាគ្រោតគ្រាតដោយអំណាចភាវៈជាដើម ។ ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម វិភង្គ ) ថា

> វេទនាជាអព្យាក្រឹត ហៅថា សុខុមវេទនា វេទនាជាទុក្ខ ហៅថា ឱឡារិកវេទនា វេទនារបស់បុគ្គលអ្នកមិនមានសមាបត្តិ ហៅថា ឱឡារិកវេទនា វេទនារបស់បុគ្គលអ្នកមានសមាបត្តិ ហៅថា សុខុមវេទនា វេទនាប្រកបដោយអាសវៈ ហៅថា ឱឡារិក-វេទនា វេទនាមិនមានអាសវៈ ហៅថា សុខុមវេទនា ដូច្នេះ ។

សូម្បីសុខវេទនាជាដើម ក៏ដូចទុក្ខវេទនា ព្រោះថា សូម្បីវេទនាទាំងនោះ ជាវេទនាគ្រោតគ្រាតដោយអំណាចជាតិ ជាវេទនាល្អិតដោយអំណាចភាវៈជាដើម ព្រោះហេតុនោះ គប្បីជ្រាបភាពដែលវេទនាទាំងឡាយ ជាវេទនាគ្រោតគ្រាត និងល្អិតដោយប្រការដែលមិនមានការលាយឡំគ្នា ដោយអំណាចជាតិជាដើម ។ ពោលដោយអំណាចជាតិ អព្យាកតវេទនាជាវេទនាល្អិតជាង

កុសលវេទនា និងអកុសលវេទនា ។ មិនគួរពោលត្រូវការផ្សេងគ្នា ដោយអំណាចសភាវៈជាដើមយ៉ាងនេះថា វេទនាទាំងនោះ អព្យាកតវេទនា តើដូចម្ដេច ជាទុក្ខវេទនា ឬជាសុខវេទនា ជាវេទនារបស់អ្នកចូលសមាបត្តិ ឬជាវេទនារបស់អ្នកមិនចូលសមាបត្តិ ជាវេទនាដែលមានអាសវៈ ឬជាវេទនាដែលមិនមានអាសវៈ ក្នុងបទទាំងពួងក៏មានន័យនេះ ។

ម្យ៉ាងវិញទៀត ព្រោះបាលី ( ក្នុងអភិធម្ម វិភង្គ ) ថា មួយទៀត ឱឡារិកវេទនា បើប្រៀបផ្ទឹមនឹងវេទនានោះៗ បណ្ឌិតគប្បីជ្រាបថាជាសុខុមវេទនាដែរ ដូច្នេះ ។ ក្នុងអកុសលវេទនាជាដើម វេទនាដែលសហគតៈដោយទោសៈគ្រោតគ្រាតជាងវេទនាដែលសហគតៈដោយលោភៈ ព្រោះដុតទីអាស្រ័យដូចភ្លើង វេទនាដែលសហគតៈដោយលោភៈល្អិត ។ វេទនាដែលសហគតៈដោយទោសៈដែលជានិយតៈជាវេទនាគ្រោតគ្រាត ដែលជាអនិយតៈជាវេទនាល្អិត ។ វេទនាដែលជានិយតៈតាំងនៅមួយកប្បជាវេទនាគ្រោតគ្រាត ក្រៅអំពីនោះជាវេទនាល្អិត ។ ក្នុងវេទនាដែលតាំងនៅមួយកប្ប វេទនាដែលជាអសង្ខារិកជាវេទនាគ្រោតគ្រាត ក្រៅអំពីនេះជាវេទនាល្អិត ។ ម្យ៉ាងទៀត វេទនាដែលសហគតៈដោយលោភៈសម្បយុត្តដោយទិដ្ឋិ ជាវេទនាគ្រោតគ្រាត ក្រៅអំពីនេះជាវេទនាល្អិត ។ វេទនានោះ ជានិយតៈតាំងនៅមួយកប្បជាអសង្ខារិក ជាវេទនាគ្រោតគ្រាត ក្រៅអំពីនេះ ជាវេទនាល្អិត ។ ម្យ៉ាងទៀត ពោលដោយមិនប្លែកគ្នា អកុសលវេទនាដែលមានវិបាកច្រើន ជាវេទនាគ្រោតគ្រាត ដែលមានវិបាកតិចជាវេទនាល្អិត ។ ចំណែកកុសលវេទនាដែលមានវិបាកតិច ជា

វេទនាគ្រោតគ្រាត ដែលមានវិបាកច្រើន ជាវេទនាល្អិត ។

ម្យ៉ាងទៀត វេទនាដែលជាកាមាវចរកុសលជាវេទនាគ្រោតគ្រាត ដែលជារូបាវចរកុសលជាវេទនាល្អិត ដែលជាអរូបាវចរកុសលល្អិតជាងនោះ ដែលជាលោកុត្តរកុសល ល្អិតជាងនោះទៀត ។ ម្យ៉ាងទៀត វេទនាដែលជាកាមាវចរកុសលសម្រេចដោយទានជាវេទនាគ្រោតគ្រាត ដែលសម្រេចដោយសីលជាវេទនាល្អិត ។ សូម្បីសម្រេចដោយសីល ក៏ជាវេទនាគ្រោតគ្រាត ដែលសម្រេចដោយភាវនាជាវេទនាល្អិតជាងនោះ ។ សូម្បីសម្រេចដោយភាវនាដែលជាទុហេតុកៈ ក៏ជាវេទនាគ្រោតគ្រាត ។ ដែលជាតិហេតុកៈ ជាវេទនាល្អិត ។ សូម្បីជាតិហេតុកៈជាសសង្ខារិកៈ ក៏ជាវេទនាគ្រោតគ្រាត ដែលជាអសង្ខារិកៈជាវេទនាល្អិត ។ ម្យ៉ាងទៀត វេទនាដែលជារូបាវចរកុសល ដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈានជាវេទនាគ្រោតគ្រាត ។បេ។ ដែលជាបញ្ចមជ្ឈានជាវេទនាល្អិត ។ វេទនាដែលជាអរូបាវចរកុសល ដែលសម្បយុត្តដោយអាកាសានញ្ចាយតនៈជាវេទនាគ្រោតគ្រាត ។បេ។ ដែលសម្បយុត្តដោយនេវសញ្ញានាសញ្ញាយតនៈជាវេទនាល្អិត ។ វេទនាដែលជាលោកុត្តរកុសលដែលសម្បយុត្តដោយសោតាបត្តិមគ្គជាវេទនាគ្រោតគ្រាត ។បេ។ ដែលសម្បយុត្តដោយអរហត្តមគ្គ ជាវេទនាល្អិត ។ ក្នុងវេទនាដែលជាវិបាក និងកិរិយារបស់ភូមិនោះៗ និងក្នុងវេទនាដែលលោកពោលទុក ដោយអំណាចនៃទុក្ខវេទនាជាដើម វេទនារបស់អ្នកមិនចូលសមាបត្តិជាដើម វេទនាដែលមានអាសវៈជាដើមក៏មានន័យនេះ ។ ម្យ៉ាងទៀត ពោលដោយអំណាចនៃឱកាស ទុក្ខវេទនា

ក្នុងនរកជាវេទនាគ្រោតគ្រាត ទុក្ខវេទនាក្នុងកំណើតតិរច្ឆានជាវេទនាល្អិត ។បេ។ ទុក្ខវេទនាក្នុងសួគ៌ជាន់បរនិម្មិតវសវត្តីជាវេទនាល្អិត ។ ម្យ៉ាងទៀត គប្បីប្រកប សុខវេទនាតាមសមគួរក្នុងបទទាំងពួង ដូចទុក្ខវេទនាដែរ ។ ម្យ៉ាងទៀត ពោលដោយអំណាចនៃវត្ថុ វេទនាឯណានីមួយមានវត្ថុថោកទាប ជាវេទនាគ្រោតគ្រាត ដែលមានវត្ថុប្រណីតជាវេទនាល្អិត ។ ក្នុងប្រភេទនៃវេទនាដែលថោកទាប និងប្រណីត គប្បីឃើញថា វេទនាណាគ្រោតគ្រាត វេទនានោះជាវេទនាថោកទាប វេទនាណាល្អិតវេទនានោះ ជាវេទនាប្រណីត ។

ចំណែកបទថា វេទនាមានក្នុងទីឆ្ងាយ និងជិត មានវិនិច្ឆ័យដូចតទៅនេះថា ព្រះមានព្រះភាគ ទ្រង់បានចែកវេទនាទុកក្នុងវិភង្គដោយន័យជាដើមថា វេទនាជាអកុសល ឆ្ងាយអំពីវេទនាជាកុសល និងអព្យាក្រឹត វេទនាជាអកុសល តាំងនៅក្នុងទីជិតនៃវេទនាជាអកុសល ដូច្នេះ ។ ហេតុនោះ ទើបអកុសលវេទនាមានក្នុងទីឆ្ងាយ ជាងកុសលវេទនា និងអព្យាកតវេទនា ព្រោះជាវិសភាគគ្នាដោយមិនទាក់ទងគ្នា និងដោយមិនលាយឡំគ្នា វេទនាជាកុសល និងអព្យាក្រឹតមានក្នុងទីឆ្ងាយ ជាងអកុសលដូចគ្នា ។ ក្នុងវារៈទាំងពួង ក៏មានន័យនេះ ។ បទនេះថា វេទនាជាអកុសលតាំងនៅក្នុងទីជិតនៃវេទនាជាអកុសល ដោយជាសភាគគ្នា ដោយទាក់ទងគ្នា និងប្រឡូកប្រឡំគ្នា ជាកថាមុខដោយពិស្តារក្នុងការចែកវេទនាដែលជាអតីតជាដើម ។ តែបទនេះ សញ្ញាសញ្ញាជាដើមដែលសម្បយុត្តដោយវេទនានោះៗ គប្បីជ្រាបយ៉ាងនេះដូចគ្នា ។

ម្យ៉ាងទៀត ក្នុងទីនេះ លោកុត្តរធម៌ពួកណាមកហើយក្នុងធម៌ទាំងឡាយ មាន

វេទនាជាដើមដែលសង្គ្រហទុកក្នុងបេយ្យាលថា **ចក្ខុ ។បេ។ ជរាមរណំ** ធម៌ទាំងឡាយនោះ មិនគប្បីកាន់យកក្នុងអធិការនេះ ព្រោះមិនចាត់ជាសម្មសនញ្ញាណ ។ ធម៌ទាំងនោះ លោកពោលដោយអំណាចការសម្តែងធម៌ ដែលលោកសង្គ្រោះដោយបទនោះៗ តែម្យ៉ាង និងដោយន័យដែលមកហើយ ក្នុងអភិញ្ញេយ្យនិទ្ទេស ។ ម្យ៉ាងទៀត ធម៌ពួកណាចាត់ជាសម្មសនញ្ញាណ ក្នុងធម៌ទាំងនោះ ធម៌ពួកណាប្រាកដដល់ញាណណារមែងដល់ការកំណត់កាន់យកបានដោយងាយ ក្នុងធម៌ទាំងនោះ គប្បីប្រារព្ធសម្មសនញ្ញាណដោយញាណនោះ ។ គប្បីជ្រាបថា លោកពោលដល់សម្មសនញ្ញាណ ដោយអំណាចនៃធម៌ទាំងនោះដោយបរិយាយ សូម្បីក្នុងការមិនមានសម្មសនញ្ញាណដោយឡែក ដោយអំណាចជាតិ ជរា និងមរណៈថា កាលពិចារណាធម៌ដែលមានជាតិ ជរា និងមរណៈហើយ សូម្បីជាតិ ជរា និងមរណៈទាំងនោះ ក៏ឈ្មោះថា ពិចារណាហើយ ។

សូម្បីមិនប៉ះពាល់ប្រភេទនៃ **អជ្ឈត្ត** ជាដើម ព្រោះលោកពោលសម្មសនញ្ញាណ ដោយអំណាចនៃអតីតត្តិកៈប៉ុណ្ណោះ និងសូម្បីកំណត់ដោយអំណាចនៃអតីតត្តិកៈនោះឯងហើយ ក៏គប្បីធ្វើការពិចារណា ( សម្មសនញ្ញាណ ) ដោយភាពជារបស់មិនទៀងជាដើមនោះឯងដោយន័យថា កំណត់ ( នូវជរា និងមរណៈ ) ជាអតីត អនាគត បច្ចុប្បន្នថា មិនទៀងជាដើម ។

[ ១០១ ] ព្រោះរូបដែលមិនទៀង មានប្រភេទដែលបច្ច័យតាក់តែងជាដើមដោយពិតប្រាកដ ។ ដោយហេតុនោះ ដើម្បីសម្តែងបរិយាយ ឬដើម្បីសម្តែងការប្រព្រឹត្តទៅនៃមនសិការដោយអាការផ្សេងៗ នៃរូប ទើបព្រះសារីបុត្តពោល

បទថា **រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ សង្ខតំ** ជាដើម ។ ពិតហើយ រូបនោះ ឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា មានហើយមិនមានវិញ ឈ្មោះថា **អនិច្ចំ** ព្រោះមានទីបំផុត គឺការមិនទៀង ឬព្រោះមានខាងដើម និងខាងចុង ឈ្មោះថា **សង្ខតំ** ព្រោះត្រូវបច្ច័យទាំងឡាយប្រជុំតាក់តែង ឈ្មោះថា **បដិច្ច-សមុប្បន្នំ** ព្រោះអាស្រ័យបច្ច័យទាំងឡាយកើតឡើងព្រមគ្នា គឺរួមគ្នា ។ ដោយបទនេះ ព្រះសារីបុត្ត សម្តែងដល់សេចក្តីមិនខ្វល់ខ្វាយនៃបច្ច័យទាំងឡាយ សូម្បីក្នុងកាលរូបដែលបច្ច័យតាក់តែងស្រេចហើយ ។

បទថា **ខយធម្មំ** បានដល់ អស់ទៅជាធម្មតា អស់ទៅជាប្រក្រតី ។ បទថា **វយធម្មំ** បានដល់ មានការវិនាសទៅជាធម្មតា ។ រូបនេះ មានការអស់ទៅជាធម្មតា ដោយអំណាចការអស់ទៅដោយការស្រោលស្តើង ក៏មិនមែន តែមានការទៅប្រាសតែម្យ៉ាងជាប្រក្រតី ។ សូម្បីការស្រោលស្តើងនៃរបស់ដែលមានច្រើន ក៏ហៅថា ការអស់ទៅក្នុងលោក ។ បទថា **វិរាគធម្មំ** បានដល់ រូបនេះមានការវិនាសទៅដោយការទៅក្នុងទីណាមួយ ក៏មិនមែន តែមានការឃ្លានកន្លងសភាវៈ ជាប្រក្រតីតែម្យ៉ាង ។ ដូចលោកពោលថា ការខ្ចីមរអើមក្តី ការឃ្លានកន្លងក្តី ឈ្មោះថា **វិរាគ** ។ បទថា **និរោធធម្មំ** បានដល់ រូបនេះ មិនមែនវិលមកទៀតដោយឃ្លានកន្លងសភាវៈ គប្បីជ្រាបថា លោកពោលដល់បទក្រោយៗ ដោយអំណាចពង្រីកបទមុនៗ ថា មានការរលត់ទៅជាប្រក្រតី ដោយការរលត់សេចក្តីមិនវិលត្រឡប់មកទៀតតែម្យ៉ាង ។

ម្យ៉ាងទៀត គប្បីប្រកបថា រូបមានការអស់ទៅជាធម្មតា ដោយអំណាចការ

រលត់រូបដែលទាក់ទងក្នុងភពមួយ មានការវិនាសទៅជាធម្មតា ដោយអំណាចការអស់ទៅនៃរូបដែលទាក់ទងដោយសន្តតិមួយ ។ រូបមានការបែកធ្លាយទៅជាធម្មតា ដោយអំណាចខណៈរលត់នៃរូប មានការរលត់ជាធម្មតាដោយអំណាចការមិនកើតឡើងដដែលទៀត នៃការអស់ទៅ សូន្យទៅ និងប្រាសទៅជាធម្មតាទាំងបី ។

ក្នុងបទថា **ជរាមរណំ អធិច្ចំ** ជាដើម សេចក្តីថា ជរា និងមរណៈមិនមែនមិនទៀង តែជរា និងមរណៈ ឈ្មោះថា មិនទៀង ព្រោះខន្ធទាំងឡាយមានការមិនទៀងជាសភាវៈ មានចាស់ និងស្លាប់ ។ សូម្បីក្នុងពាក្យថា ត្រូវបច្ច័យតាក់តែងជាដើម ក៏មានន័យនេះដូចគ្នា ។ ក្នុងការដែលជាតិមិនទៀងជាដើមក្នុងវាងបេយ្យាល ក៏មានន័យនេះដូចគ្នា ។

[ ១០២ ] បទថា **ជាតិប្បច្ចយា ជរាមរណំ** ជាដើមនោះ លោកមិនបានពោលដោយអំណាចវិបស្សនា លោកពោលត្រឹមតែម្យ៉ាង ដោយបរិយាយថា សម្មសនញ្ញាណ រមែងមានដោយសង្ខេបបដិច្ចសមុប្បាទ ដោយអំណាចអង្គនីមួយៗ ហើយកំណត់ តែនោះមិនមែនកលាបសម្មសនញ្ញាណ នោះជាធម្មដ្ឋិតិញ្ញាណប៉ុណ្ណោះ ។ បទថា **អសតិ ជាតិយា** នេះ លោកធ្វើជាលិង្គ-វិបល្លាស អធិប្បាយថា **អសន្តិយា ជាតិយា**។ បទថា **អសតិ សង្ខារេសុ** លោកធ្វើជាវចនវិបល្លាស អធិប្បាយថា **អសន្តេសុ សង្ខារេសុ**។ បទថា **ភវប្បច្ចយា ជាតិ អសតិ** គប្បីប្រកបដោយន័យជាដើមថា ព្រោះភពជាបច្ច័យ ទើបមានជាតិ កាលបើភពមិនមាន ជាតិក៏មិនមាន ។៚

**អដ្ឋកថាសម្មសនញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[១០៣] បញ្ញាក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថា ឧទយព្វយានុបស្សនាញាណ តើដូចម្តេច ។ រូបជាបច្ចុប្បន្នកើតហើយ ការចម្រើនឡើងនៃរូបនោះ ជាលក្ខណៈនៃការកើត ការសូន្យទៅជាលក្ខណៈនៃការប្រែប្រួល ឈ្មោះថា អនុបស្សនាញាណ វេទនាកើតហើយ សញ្ញាកើតហើយ សង្ខារកើតហើយ វិញ្ញាណកើតហើយ ចក្ខុកើតហើយ ។បេ។ ភពជាបច្ចុប្បន្នកើតហើយ ការចម្រើនឡើងនៃភពនោះ ជាលក្ខណៈនៃការកើត ការសូន្យទៅ ជាលក្ខណៈនៃការប្រែប្រួល ឈ្មោះថា អនុបស្សនាញាណ ។

[ ១០៤ ] បុគ្គលកាលឃើញនូវការចម្រើនឡើងនៃបញ្ចក្ខន្ធ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន បុគ្គលកាលឃើញនូវការចម្រើនឡើងនៃបញ្ចក្ខន្ធ រមែងឃើញនូវលក្ខណៈ ២៥ កាលឃើញនូវការសូន្យទៅរមែងឃើញនូវលក្ខណៈ ២៥ កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ រមែងឃើញនូវលក្ខណៈ ៥០ ។

[ ១០៥ ] បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន បុគ្គលកាលឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការចម្រើនឡើង និងសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន ។ បុគ្គល

កាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការសូន្យទៅ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការចម្រើនឡើង និងសូន្យទៅ រមែងឃើញលក្ខណៈ ១០ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការសូន្យទៅ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ រមែងឃើញលក្ខណៈ ១០ ។

[ ១០៦ ] បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអវិជ្ជា ១ ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃតណ្ហា ១ ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូបព្រោះកើតឡើងនៃកម្ម ១ ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអាហារ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈនៃការកើត ឈ្មោះថា ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ១ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ ។

[ ១០៧ ] បុគ្គលកាលឃើញនូវការសូន្យទៅ ( នៃរូបក្ខន្ធ ) រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយ

អត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃរូបព្រោះរលត់ទៅនៃអវិជ្ជា ១ ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃរូបព្រោះរលត់ទៅនៃតណ្ហា ១ ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃកម្ម ១ ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃរូបព្រោះរលត់ទៅនៃអាហារ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថា ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ១ បុគ្គលកាលឃើញនូវការសូន្យទៅនៃរូបក្ខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ បុគ្គលកាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ ( នៃរូបក្ខន្ធ ) រមែងឃើញលក្ខណៈទាំង ១០ នេះឯង ។

[ ១០៨ ] បុគ្គលកាលឃើញនូវការចម្រើននៃវេទនាខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវេទនាព្រោះកើតឡើងនៃអវិជ្ជា ១ ឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវេទនាព្រោះកើតឡើងនៃតណ្ហា ១ ឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃកម្ម ១ ឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈកើតឡើង ឈ្មោះថា ឃើញនូវការចម្រើន

ឡើងនៃវេទនាខន្ធ ១ បុគ្គលកាលឃើញនូវការបម្រើនឡើងនៃវេទនាខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ ។

[ ១០៩ ] បុគ្គលកាលឃើញនូវការសូន្យទៅ ( នៃវេទនាខន្ធ ) រមែងឃើញលក្ខណៈ ៥ តើដូចម្ដេច ។ បុគ្គលឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវេទនាព្រោះរលត់ទៅនៃអវិជ្ជា ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវេទនាព្រោះរលត់ទៅនៃតណ្ហា ឃើញនូវការសូន្យទៅនៃវេទនា-ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃកម្ម ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវេទនាព្រោះរលត់ទៅនៃផស្សៈ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថា ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ១ បុគ្គលកាលឃើញនូវការសូន្យទៅនៃវេទនាខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ បុគ្គលកាលឃើញនូវការបម្រើនឡើង និងការសូន្យទៅ ( នៃវេទនាខន្ធ ) រមែងឃើញលក្ខណៈទាំង ១០ នេះឯង ។

[ ១១០ ] បុគ្គលកាលឃើញនូវការបម្រើនឡើងនៃសញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្ដេច ។ បុគ្គលឃើញនូវការបម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវិញ្ញាណព្រោះកើតឡើងនៃអវិជ្ជា ១ ឃើញនូវការបម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃ

តណ្ហា ១ ឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃកម្ម ១ ឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃនាម និងរូប ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈកើត ឈ្មោះថា ឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ១ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ ។

[ ១១១ ] បុគ្គលកាលឃើញនូវការសូន្យទៅ ( នៃវិញ្ញាណ ) រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវិញ្ញាណព្រោះរលត់ទៅនៃអវិជ្ជា ១ ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវិញ្ញាណព្រោះរលត់ទៅនៃតណ្ហា ១ ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវិញ្ញាណព្រោះរលត់ទៅនៃកម្ម ១ ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃនាម និងរូប មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថា ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ១ បុគ្គលកាលឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ រមែងឃើញនូវលក្ខណៈ ៥ នេះ កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ តែងឃើញនូវលក្ខណៈ ១០ នេះ កាលឃើញនូវការចម្រើនឡើងនៃខន្ធទាំង

៥ តែងឃើញនូវលក្ខណៈ ២៥ នេះ កាលឃើញនូវការសូន្យទៅ តែងឃើញនូវលក្ខណៈ ២៥ នេះ កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ តែងឃើញនូវលក្ខណៈ ៥០ នេះ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញាក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថា ឧទយព្វយានុបស្សនាញាណ ។ រូបក្ខន្ធកើតឡើងព្រោះអាហារ ខន្ធដ៏សេស គឺវេទនា សញ្ញា សង្ខារ កើតឡើងព្រោះផស្សៈ វិញ្ញាណក្ខន្ធកើតឡើងព្រោះនាម និងរូប ។

# អដ្ឋកថា

## ឧទយព្វយញ្ញាណនិទ្ទេស

[ ១០៣-១០៦ ] ឥឡូវនេះ ព្រះយោគាវចរដែលដល់នូវត្រើយនៃសម្ម-សនញ្ញាណដែលពោលហើយតាមលំដាប់ ដោយការបំពេញការនាឲ្យមាំទាំដោយន័យផ្សេងៗ ហើយតាំងនៅ ពិចារណាឃើញសង្ខារទាំងឡាយពួកណា ដោយជារបស់មិនទៀងជាដើម ក្នុងពាក្យជាដើមថា **ជាតំ រូបំ** ក្នុងនិទ្ទេសនៃឧទយព្វ-យានុបស្សនាញាណដែលព្រះសារីបុត្តពោល ដើម្បីកំណត់សង្ខារទាំងឡាយនោះដោយការកើតឡើង និងការសូន្យទៅ ហើយពិចារណាឃើញដោយភាពជារបស់មិនទៀងជាដើម រូបកើតហើយដោយបច្ច័យទាំងឡាយតាមសមគួរដល់ខ្លួនដោយអំណាចការបន្ត ។ និព្វត្តិលក្ខណៈ គឺការកើត ការកើតឡើង អាការកើតថ្មីនៃរូប ដែលកើតហើយនោះ ឈ្មោះថា **ឧទយ** ។ វិបរិណាមលក្ខណៈ គឺការអស់ទៅ ការរលត់ទៅ ឈ្មោះថា **វយ**។ ការពិចារណារឿយៗ ឈ្មោះថា អនុបស្សនា អធិប្បាយថា ឧទយព្វយានុបស្សនាញាណ ។ សូម្បីក្នុងវេទនាជាដើមក៏មានន័យនេះដូចគ្នា ។ ព្រះសារីបុត្តមិនពោលដល់ជាតិ ជរា និងមរណៈព្រោះជាតិ ជរា និងមរណៈ មិនមានការកើត និងការវិនាសហើយ លោកធ្វើបេយ្យាលថា **ជាតំ ចក្ខុំ ។បេ។ ជាតោ ភវោ** ដូច្នេះ ព្រោះការកើតឡើងនិងការវិនាសដែលបុគ្គលមានជាតិ ជរា និងមរណៈនោះឯង គួរកំណត់កាន់យក ។ ព្រះយោគាវចរនោះ កាលពិចារណាឃើញការកើត និងការវិនាសនៃខន្ធ ៥ យ៉ាងនេះ រមែងដឹងយ៉ាងនេះ គឺឃើញថា ការរួមជាគំនរក្តី ការសន្សំ

ក្តី នៃខន្ធទាំងនេះដែលមិនទាន់កើត មុនអំពីការកើតឡើងមិនមាន ឈ្មោះថា ការមកនៃខន្ធទាំងឡាយដែលកំពុងកើតឡើងដោយរួមជាគំនរ ឬដោយការសន្សំ រមែងមិនមាន ឈ្មោះថា ការទៅកាន់ទិសតូចធំនៃខន្ធដែលកំពុងរលត់ រមែងមិនមាន ឈ្មោះថា ការតាំងចុះនៃខន្ធដែលរលត់ទៅហើយ ដោយរួមជាគំនរ ដោយសន្សំ ដោយរក្សាក្នុងទីមួយកន្លែង រមែងមិនមាន ដូចកាលដេញពិណ សំឡេងពិណក៏កើត មិនមែនមានការសន្សំអំពីមុន សំឡេងកាលកើតក៏មិនមានការសន្សំ ការទៅកាន់ទិសតូចធំរបស់សំឡេងពិណដែលកំពុងរលត់ទៅក៏មិនមាន សំឡេងពិណដែលរលត់ហើយ រមែងមិនមានការសន្សំក្នុងទីណាមួយ ដែលពិតសំឡេងពិណអាស្រ័យពិណ ស្នូកពិណ និងសេចក្តីព្យាយាមដ៏សមគួររបស់មនុស្ស មិនមានហើយគង់មានបាន កាលមានហើយគង់វិនាសបានយ៉ាងណា ធម៌មានរូប និងមិនមានរូបទាំងអស់ក៏យ៉ាងនោះ មិនមានហើយ គង់មានបាន កាលមានហើយ គង់វិនាសបាន ។

ព្រះសារីបុត្ត កាលសម្តែងការឃើញការកើត និងការវិនាស ដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងដោយពិស្តារ ទើបសួរដល់ចំនួនដោយរួមជាគំនរដោយបទថា **បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ** បុគ្គលកាលឃើញនូវការចម្រើនឡើងនៃបញ្ចក្ខន្ធ តើឃើញលក្ខណៈប៉ុន្មានជាដើម ហើយឆ្លើយចំនួនដោយរួមជាគំនរដោយបទថា **បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ បញ្ចវីសតិ លក្ខណានិ បស្សតិ** បុគ្គលកាលឃើញនូវការចម្រើនឡើងនៃបញ្ចក្ខន្ធ រមែងឃើញនូវលក្ខណៈ ២៥ ជាដើម ហើយសួរ

ដល់ចំនួនដោយការចែកទៀតដោយបទថា **រូបក្ខន្ធស្ស ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ** បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ តើឃើញលក្ខណៈប៉ុន្មានជាដើម ហើយឆ្លើយចំនួនដោយការចែកដោយបទថា **រូបក្ខន្ធស្ស ឧទយំ បស្សន្តោ បញ្ច លក្ខណានិ បស្សតិ** បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ ជាដើម ហើយសួរការចែកលក្ខណៈទៀត ដោយបទថា **រូបក្ខន្ធស្ស ឧទយំ បស្សន្តោ កតមានិ បញ្ច លក្ខណានិ បស្សតិ** បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ហើយទើបឆ្លើយតទៅ ។

ក្នុងបទទាំងនោះ បទថា **អវិជ្ជាសមុទយា រូបសមុទយោ** សេចក្តីថា កាលមានអវិជ្ជាដូចពោលហើយថា មោហៈក្នុងកម្មភពមុនជាអវិជ្ជា ទើបរូបកើតឡើងក្នុងភពនេះ ។ បទថា **បច្ចយសមុទយដ្ឋេន** សេចក្តីថា ដោយភាពដែលបច្ច័យកើតឡើង ។ ក្នុងទីនេះ អវិជ្ជា តណ្ហា កម្ម ជាបច្ច័យអតីតដែលជាហេតុនៃបដិសន្ធិក្នុងភពនេះ ។ កាលកាន់យកអវិជ្ជា តណ្ហា កម្មទាំង ៣ យ៉ាងនេះហើយ ក៏ឈ្មោះថា កាន់យកសង្ខារ និងឧបាទានផងនោះឯង ។

បទថា **អាហារសមុទយា** បានដល់ ព្រោះកវឡិង្ការាហារ មានកម្លាំងក្នុងបច្ច័យដែលប្រព្រឹត្តទៅ ទើបកាន់យកអាហារនោះឯង ។ កាលកាន់យកអាហារនោះហើយ ក៏ឈ្មោះថា កាន់យកឧតុ និងចិត្តដែលជាហេតុនៃការប្រព្រឹត្តទៅផងដូចគ្នា ។

បទថា **និព្វត្តិលក្ខណំ** បានដល់ ការកើតឡើងនៃរូបដោយអំណាចនៃអទ្ធា

គឺកាល សន្តតិ គឺការបន្ត និងខណៈម្យ៉ាងទៀត ការកើតឡើងនោះឯង លោកពោលថា លក្ខណៈ ព្រោះជាលក្ខណៈនៃសង្ខតធម៌ ។

បទថា **បញ្ច លក្ខណានិ** បានដល់ លក្ខណៈទាំង ៥ នេះ គឺអវិជ្ជា តណ្ហា កម្ម អាហារ និងការកើត ។ ពិតហើយ សូម្បីធម៌ ៤ យ៉ាង មានអវិជ្ជាជាដើម ក៏ឈ្មោះថា លក្ខណៈ ព្រោះអត្ថថា ជាគ្រឿងកំណត់ការកើតឡើងនៃរូប ។ ចំណែកការកើតឡើង ក៏ជាលក្ខណៈនៃសង្ខតធម៌នោះឯង ឈ្មោះថា លក្ខណៈ ព្រោះអត្ថថា ជាគ្រឿងកំណត់ថា សូម្បីការកើតនោះ ក៏ជាសង្ខតធម៌ ។

[ ១០៧ ] បទថា **អវិជ្ជានិរោធា រូបនិរោធោ** សេចក្ដីថា កាលអវិជ្ជាក្នុងភពនេះដែលជាបច្ច័យដល់ភពក្នុងអនាគតរលត់ទៅហើយ ដោយអរហត្ត-មគ្គញ្ញាណ រូបក្នុងអនាគតរមែងមិនកើត គឺរលត់ព្រោះមិនមានបច្ច័យ ។

បទថា **បច្ចយនិរោធដ្ឋេន** បានដល់ ដោយភាពដែលបច្ច័យរលត់ ។ ម្យ៉ាងទៀត ការរលត់ក្នុងទីនេះ ជាការរលត់អវិជ្ជា តណ្ហា និងកម្មក្នុងលោកនេះ ដែលជាបច្ច័យនៃបដិសន្ធិក្នុងអនាគត ។

បទថា **អាហារនិរោធា រូបនិរោធោ** បានដល់ ព្រោះកវឡិង្ការាហារដែលជាបច្ច័យដល់ការប្រព្រឹត្តទៅ មិនមាន ទើបរូបដែលមានអាហារនោះជាសមុដ្ឋាន មិនមាន ។

បទថា **វិបរិណាមលក្ខណំ** បានដល់ ការរលត់នៃរូបដោយអំណាចនៃអទ្ធាសន្តតិ និងខណៈ ការរលត់នោះ លោកពោលថា លក្ខណៈ ព្រោះជាលក្ខណៈ

នៃសង្ខតធម៌ ។ បទថា **បញ្ច លក្ខណានិ** ក្នុងបទនេះ បានដល់ ការរលត់ ៤ យ៉ាង គឺការមិនមាននៃអវិជ្ជា តណ្ហា កម្ម និងអាហារ ការប្រែប្រួល ១ រួមជាគម្រប់ ៥ ។ ក្នុងវេទនាខន្ធជាដើម ក៏មានន័យនេះ ។ ការផ្សេងគ្នាមានដូច្នេះ គឺការឃើញការកើត និងការវិនាសនៃអរូបក្ខន្ធមានបានដោយអំណាចនៃអទ្ធា និងសន្តតិ មិនមែនដោយអំណាចនៃខណៈ ។ ផស្សៈ ជាបច្ច័យដល់ការប្រព្រឹត្តទៅនៃវេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ព្រោះផស្សៈនោះរលត់ ទើបវេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធរលត់ ។ នាមរូបជាបច្ច័យដល់ការប្រព្រឹត្តទៅនៃវិញ្ញាណក្ខន្ធ ព្រោះនាមរូបនោះរលត់ ទើបវិញ្ញាណក្ខន្ធរលត់ ។

ចំណែកអាចារ្យពួកមួយពោលថា ព្រះសារីបុត្តមិនពោលថែកអតីតជាដើម ក្នុងការឃើញការកើតឡើង និងការវិនាសដោយបច្ច័យ ៤ យ៉ាង ហើយកាន់យកត្រឹមតែភាវៈដែលកំពុងកើតឡើងថា នាមរូបកើតឡើងព្រោះអវិជ្ជាជាដើម ដោយអំណាចស្មើគ្នាទាំងអស់ មិនមែនកាន់យកការកើតឡើង ។ កាន់យកត្រឹមតែភាវៈដែលមិនកើតឡើងថា ព្រោះអវិជ្ជាជាដើមរលត់ ទើបនាមរូបរលត់ មិនមែនកាន់យកការរលត់ ។ លោករមែងកាន់យកការកើត ការរលត់នៃខន្ធទាំងឡាយជាបច្ចុប្បន្ន ក្នុងការឃើញការកើត និងការវិនាសដោយខណៈ ។

អ្នកចម្រើនវិបស្សនា កាលចម្រើនវិបស្សនាដាក់ចិត្តដល់ការកើត និងការរលត់ដោយបច្ច័យជាបឋម ក្នុងខណៈចម្រើនវិបស្សនា លះបង់ធម៌ ៤ មានអវិជ្ជាជាដើម កំណត់ខន្ធទាំងឡាយ ដែលមានការកើត និងការរលត់នោះឯង ហើយរមែងឃើញការកើតឡើង និងការរលត់នៃខន្ធទាំងនោះ ។ កាលបុគ្គល

បម្រើនវិបស្សនាយ៉ាងនេះ ឃើញការកើតឡើង និងការរលត់ដោយពិស្តារ គឺដោយបច្ច័យ និងដោយលក្ខណៈថា ការកើតឡើងនៃរូបជាដើមយ៉ាងនេះ ការកន្លងទៅយ៉ាងនេះ រូបជាដើមកើតឡើងយ៉ាងនេះ វិនាសទៅយ៉ាងនេះ ញាណដឹងថា ធម៌ទាំងនេះមិនមានហើយមាន មានហើយវិនាសដោយអាការយ៉ាងនេះ ជាញាណបរិសុទ្ធជាងប្រភេទរបស់សច្ចៈ បដិច្ចសមុប្បាទន័យ និងលក្ខណៈរមែងប្រាកដ ។ ព្រះយោគាវចរនោះ រមែងឃើញការកើតឡើងនៃខន្ធទាំងឡាយ ព្រោះអវិជ្ជាជាដើមកើត និងឃើញការរលត់នៃខន្ធទាំងឡាយ ព្រោះអវិជ្ជាជាដើមរលត់ នេះជាការឃើញការកើតឡើង និងការរលត់ដោយបច្ច័យ របស់ព្រះយោគាវចរនោះ ។ ម្យ៉ាងទៀត ព្រះយោគាវចរកាលឃើញលក្ខណៈការកើតឡើង និងលក្ខណៈការប្រែប្រួល ឈ្មោះថា រមែងឃើញការកើតឡើង និងការរលត់នៃខន្ធទាំងឡាយ នេះជាការឃើញការកើតឡើង និងការរលត់ ដោយខណៈរបស់ព្រះយោគាវចរនោះ ។ ពិតហើយ លក្ខណៈការកើតឡើង រមែងមានក្នុងខណៈនៃការកើតឡើងនោះឯង ឯលក្ខណៈការប្រែប្រួល ក៏រមែងមានក្នុងខណៈនៃការបែកធ្លាយ ។

ដោយប្រការដូច្នេះ កាលព្រះយោគាវចរនោះឃើញការកើតឡើង និងការរលត់ដោយចំណែកពីរ គឺដោយបច្ច័យ និងដោយខណៈ សមុទយសច្ចរមែងប្រាកដដោយឃើញការកើតឡើងដោយបច្ច័យ ព្រោះឈមចុះដល់ធម៌ដែលឲ្យកើត ។ ទុក្ខសច្ច រមែងប្រាកដដោយការឃើញការកើតឡើង ដោយខណៈ ព្រោះឈមចុះកាន់ជាតិទុក្ខ ។ និរោធសច្ច រមែងប្រាកដដោយការឃើញការ

រលត់ដោយបច្ច័យ ព្រោះឈមចុះកាន់ការមិនកើតឡើងនៃធម៌ទាំងឡាយដែលមានបច្ច័យដោយការមិនកើតនៃបច្ច័យ ។ ទុក្ខសច្ចនោះឯង រមែងប្រាកដដោយការឃើញការរលត់ដោយខណៈ ព្រោះឈមចុះកាន់មរណទុក្ខ ។ ការឃើញការកើតឡើង និងការរលត់ឯណារបស់ព្រះយោគាវចរនោះ ការឃើញនេះ ជាលោកិយមគ្គ ព្រោះហេតុនោះ មគ្គសច្ចរមែងប្រាកដ ព្រោះកម្ចាត់ការវង្វេងក្នុងការឃើញការកើតឡើង និងការរលត់នោះ ។

ម្យ៉ាងទៀត បដិច្ចសមុប្បាទដែលជាអនុលោម រមែងប្រាកដដល់ព្រះយោគាវចរនោះ ដោយការឃើញការកើតឡើងដោយបច្ច័យ ព្រោះឈមចុះ គឺដឹងថា កាលបើបច្ច័យមានអវិជ្ជាជាដើមនេះកើតហើយ ផលមានសង្ខារជាដើមនេះក៏កើតឡើង ដូច្នេះ ។ បដិច្ចសមុប្បាទជាបដិលោម រមែងប្រាកដដោយការឃើញការរលត់ដោយបច្ច័យ ព្រោះឈមចុះ គឺដឹងថា ផលមានសង្ខារជាដើមនេះតែងរលត់ទៅមិនសល់ ព្រោះរលត់នៃបច្ច័យ មានអវិជ្ជាជាដើមនេះ ដូច្នេះ ។ ម្យ៉ាងវិញទៀត ធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើង រមែងប្រាកដដោយការឃើញការកើតឡើង និងការរលត់ដោយខណៈ ព្រោះឈមចុះកាន់លក្ខណៈនៃសង្ខតធម៌ ។ ពិតហើយ ធម៌ទាំងឡាយដែលមានការកើត និងការរលត់ជាសង្ខតធម៌ ឯសង្ខតធម៌ទាំងនោះ អាស្រ័យគ្នាកើតឡើង ។

ម្យ៉ាងទៀត ឯកត្តន័យ រមែងប្រាកដដល់ព្រះយោគាវចរនោះ ដោយការឃើញការកើតដោយបច្ច័យ ព្រោះចាក់ដុះការមិនដាច់សូន្យនៃសន្តាន ដោយសម្ពន្ធគ្នាដោយហេតុ និងផល ពេលនោះ ព្រះយោគាវចររមែងលះឧច្ឆេទទិដ្ឋិបាន

យ៉ាងល្អ ។ នានត្តន័យ រមែងប្រាកដដោយការឃើញការកើតឡើង ដោយខណៈ ព្រោះចាក់ធ្លុះនូវការកើតឡើងនៃធម៌ថ្មីៗ ពេលនោះ ព្រះយោវចររមែងលះសស្សតទិដ្ឋិបានយ៉ាងល្អ ។ម្យ៉ាងទៀត អព្យាបារន័យ ( ន័យនៃការមិនខ្វល់ខ្វាយ ) រមែងប្រាកដដល់ព្រះយោគាវចរនោះ ដោយការឃើញការកើតឡើងដោយបច្ច័យ ព្រោះចាក់ធ្លុះនូវធម៌ទាំងឡាយ មិនប្រព្រឹត្តទៅក្នុងអំណាច ។ ពេលនោះ ព្រះយោគាវចររមែងលះអត្តទិដ្ឋិបានយ៉ាងល្អ ។ ម្យ៉ាងវិញទៀត **ឯវំធម្មតា** ន័យ ( ន័យជាធម្មតាយ៉ាងនេះ ) រមែងប្រាកដដោយការឃើញការកើតឡើងដោយបច្ច័យ ព្រោះចាក់ធ្លុះនូវការកើតឡើងនៃផល ដោយសមគួរដល់បច្ច័យ ពេលនោះ ព្រះយោគាវចរ រមែងលះអកិរិយទិដ្ឋិបានយ៉ាងល្អ ។

ម្យ៉ាងទៀត អនត្តលក្ខណៈ រមែងប្រាកដដល់ព្រះយោគាវចរនោះដោយការឃើញការកើតឡើងដោយបច្ច័យ ព្រោះចាក់ធ្លុះនូវភាពដែលធម៌ទាំងឡាយប្រព្រឹត្តទៅទាក់ទងជាមួយបច្ច័យ ដោយមិនចាំបាច់ប្រើសេចក្តីព្យាយាម ។ អនិច្ចលក្ខណៈ រមែងប្រាកដដោយការឃើញការកើត និងការរលត់ដោយខណៈ ព្រោះចាក់ធ្លុះនូវការមានហើយ ត្រឡប់ជាមិនមាន និងព្រោះចាក់ធ្លុះនូវការស្ងាត់ចាកទីបំផុតខាងដើម និងខាងចុង សូម្បីទុក្ខលក្ខណៈក៏រមែងប្រាកដ ព្រោះចាក់ធ្លុះនូវការបៀតបៀនដោយការកើត និងការរលត់ សូម្បីសភាវលក្ខណៈ ក៏រមែងប្រាកដ ព្រោះចាក់ធ្លុះនូវការកំណត់ការកើត និងការរលត់ សូម្បីការប្រព្រឹត្តទៅមួយជួរខណៈនៃសង្ខតលក្ខណៈ ក៏រមែងប្រាកដក្នុងសភាវលក្ខណៈ ព្រោះចាក់ធ្លុះនូវការមិនមានការរលត់ ក្នុងខណៈនៃការកើត និងការមិនមានការកើត

ក្នុងខណៈនៃការរលត់ ។

សង្ខារទាំងឡាយថ្មីជានិច្ច រមែងប្រាកដថា ធម៌ទាំងនេះ ឈ្មោះយ៉ាងនេះ ដែលមិនធ្លាប់កើតក៏កើត ដែលកើតហើយ ក៏រលត់ទៅដល់ព្រះយោគាវចរនោះ ដែលចាក់ធ្លុះក្នុងលក្ខណៈនៃសច្ចៈ និងបដិច្ចសមុប្បាទន័យដែលប្រាកដច្បាស់ ហើយយ៉ាងនេះ ។ សង្ខារទាំងឡាយមិនមែនប្រាកដថ្មីជានិច្ចតែម្យ៉ាងទេ សង្ខារទាំងឡាយ រមែងប្រាកដដូចតំណក់ទឹកសន្សើមក្នុងវេលាព្រះអាទិត្យរះ ដូចពពុះទឹក ដូចគំនូសក្នុងទឹក ដូចគ្រាប់ស្នែលើចុងដែកស្រួច និងដូចផ្លេកបន្ទោរ រមែងប្រាកដថា មិនមានខ្លឹម មិនមានសារៈ ដូចមាយាថ្ងៃបណ្ដើរកូន ការយល់សប្តិ រងើកភ្លើងដែលគ្រវីទៅជុំវិញនគរគន្ធព្វ ក្រពេញទឹក និងដើមចេកជាដើម ដែលតាំងនៅបានបន្តិចបន្តួច ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះយោគាវចរនោះ រមែងដល់នូវការរាប់ថា អ្នកបំពេញវិបស្សនា ព្រោះសម្រេចវិបស្សនាញាណយ៉ាងទន់ទី ១ ដែលឈ្មោះថា ឧទយព្វយានុបស្សនា ដែលចាក់ធ្លុះលក្ខណៈ ៥០ ដោយអាការនេះថា វត្ថុដែលមានការវិនាសជាធម្មតា រមែងកើតឡើង ឯវត្ថុដែលកើតឡើងហើយ រមែងចូលដល់ការវិនាស ហើយតាំងនៅ ។ វិបស្សនូបក្កិលេស ១០ មានឱភាសជាដើម រមែងកើតដល់ព្រះយោគាវចរដែលតាំងនៅក្នុងញាណនេះ ព្រះយោគាវចរដែលមិនឈ្លាស ក្នុងការកើតឡើងនៃវិបស្សនូបក្កិលេសពួកណា រមែងជាអ្នកមានការសម្គាល់ក្នុងវិបស្សនូបក្កិលេសថាជាមគ្គញ្ញាណ កាន់យកវត្ថុដែលមិនមែនជាមគ្គនោះឯងថាជាមគ្គ ជាបុគ្គលត្រូវឧបក្កិលេសរឹតរុំក្រលែង ។ ចំណែកព្រះយោគាវចរដែលឈ្លាសលើកវិបស្សនាឡើង ក្នុងឧបក្កិលេសទាំងនោះ រំសាយចោលនូវ

ការរីតរុំ គឺឧបក្កិលេស ហើយកំណត់មគ្គ និងមិនមែនមគ្គថា ធម៌ទាំងនេះ មិនមែនមគ្គ ចំណែកវិបស្សនាញាណដែលប្រព្រឹត្តទៅតាមវិថី ផុតចាកឧបក្កិលេស ជាមគ្គ ។ ញាណដែលដឹងថា ជាមគ្គ និងមិនមែនមគ្គយ៉ាងនេះ ហើយតាំងនៅរបស់ព្រះយោគាវចរនោះ ឈ្មោះថា មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ធ្វើនូវការកំណត់សច្ចៈ ៤ ដោយញាណនោះ ។ សេចក្តីនេះដូចម្តេច សេចក្តីថា កាលមានការកំណត់នាមរូប ឈ្មោះថា ធ្វើនូវការកំណត់ទុក្ខសច្ច ដោយការកំណត់នាមរូបដែលជាទិដ្ឋិវិសុទ្ធិ ដែលពោលហើយដោយពាក្យថា ធម្មដ្ឋិតិញ្ញាណនោះឯង ព្រោះមានការកំណត់បច្ច័យ ឈ្មោះថា ធ្វើនូវការកំណត់សមុទយសច្ច ដោយការកំណត់បច្ច័យដែលជាកង្ខាវិតរណវិសុទ្ធិ ម្យ៉ាងទៀត ដោយឧទយព្វយានុបស្សនា ឈ្មោះថា ធ្វើការកំណត់ទុក្ខសច្ចដោយការឃើញការកើត និងការរលត់ដោយខណៈ ឈ្មោះថា ធ្វើនូវការកំណត់សមុទយសច្ច ដោយការឃើញការកើត ដោយបច្ច័យ ឈ្មោះថា ធ្វើនូវការកំណត់និរោធសច្ច ដោយការឃើញការរលត់ដោយបច្ច័យ ឈ្មោះថា ធ្វើនូវការកំណត់មគ្គសច្ច ដោយកម្ចាត់ការវង្វេង ក្នុងការឃើញការកើត និងការរលត់របស់ព្រះយោគាវចរនោះថា នេះ គឺមគ្គដែលជាលោកិយ និងដោយការកាត់ផ្តាច់ ( ចែក ) នូវមគ្គបានត្រឹមត្រូវរបស់ព្រះយោគាវចរ ដែលពិចារណាឃើញក្នុងមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនេះ ។ ដោយប្រការដូច្នេះ ទើបឈ្មោះថា ធ្វើនូវការកំណត់សច្ចៈ ៤ ដោយញាណដែលជាលោកិយ ៗ។ល។

**អដ្ឋកថាឧទយព្វយញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១១២ ] បញ្ញាក្នុងការពិចារណាឃើញនូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ តើដូចម្ដេច ។ ចិត្តមានរូបជាអារម្មណ៍កើតឡើងហើយបែកធ្លាយទៅវិញ បុគ្គលពិចារណាឃើញនូវការបែកធ្លាយនៃចិត្តនោះ ព្រោះពិចារណានូវអារម្មណ៍នោះ ។ ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញដូចម្ដេច ។ ពិចារណាឃើញថាមិនទៀង មិនមែនពិចារណាឃើញថាទៀងទេ ពិចារណាឃើញថាជាទុក្ខ មិនមែនពិចារណាឃើញថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនពិចារណាឃើញថាខ្លួនទេ នឿយណាយ មិនរីករាយ ធុញទ្រាន់ មិនត្រេកអរ រម្ងត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក បុគ្គលកាលពិចារណាឃើញថាមិនទៀង ក៏លះបង់នូវសញ្ញាថាទៀង កាលពិចារណាឃើញថាជាទុក្ខ ក៏លះបង់នូវសញ្ញាថាជាសុខ កាលពិចារណាឃើញថាមិនមែនខ្លួន ក៏លះបង់នូវសញ្ញាថាខ្លួន កាលនឿយណាយ ក៏លះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ ក៏លះបង់នូវតម្រេក កាលរម្ងត់ ក៏លះបង់នូវការកើតឡើង កាលរលាស់ចោល ក៏លះបង់នូវសេចក្ដីប្រកាន់ ។

[ ១១៣ ] ចិត្ត មានវេទនាជាអារម្មណ៍ ។បេ។ មានសញ្ញាជាអារម្មណ៍ មានសង្ខារជាអារម្មណ៍ មានវិញ្ញាណជាអារម្មណ៍ ។បេ។ ចិត្ត មានជរា និងមរណៈជាអារម្មណ៍ កើតឡើងហើយបែកធ្លាយទៅវិញ បុគ្គលពិចារណាឃើញនូវការបែកធ្លាយនៃចិត្តនោះ ព្រោះការពិចារណានូវអារម្មណ៍នោះ ។ ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញដូចម្ដេច ។ បុគ្គលពិចារណាឃើញថាមិនទៀង មិនមែនពិចារណាឃើញថាទៀងទេ ពិចារណាឃើញថាជាទុក្ខ

មិនមែនពិចារណាឃើញថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនពិចារណាឃើញថាខ្លួនទេ នឿយណាយ មិនរីករាយ ធុញទ្រាន់ មិនត្រេកអរ រម្ងត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក បុគ្គលកាលពិចារណាឃើញថាមិនទៀង ក៏លះបង់នូវសញ្ញាថាទៀង កាលពិចារណាឃើញថាជាទុក្ខ ក៏លះបង់នូវសញ្ញាថាជាសុខ កាលពិចារណាឃើញថា មិនមែនខ្លួន ក៏លះបង់នូវសញ្ញាថាខ្លួន កាលនឿយណាយ ក៏លះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ ក៏លះបង់នូវតម្រេក កាលរម្ងត់ ក៏លះបង់នូវការកើតឡើង កាលរលាស់ចោល ក៏លះបង់នូវសេចក្ដីប្រកាន់ ។

[ ១១៤ ] ការរំកិលចិត្តចាកវត្ថុមុន ទៅកាន់វត្ថុផ្សេងវិញក្តី ការវិវដ្តនៃចិត្តដោយបញ្ញាក្តី កម្លាំង គឺការរំពឹងរក ( នូវការបែកធ្លាយ ) ក្តី ឈ្មោះថា ការពិចារណាឃើញ ( នូវការបែកធ្លាយ ) ការកំណត់នូវសភាពទាំងពីរថាតែមួយ ដោយការប្រព្រឹត្តតាមអារម្មណ៍ ភាពនៃបុគ្គលមានចិត្តចុះស៊ប់ ក្នុងការរលត់ ឈ្មោះថា ពិចារណាឃើញនូវលក្ខណៈនៃការសូន្យ ការពិចារណានូវអារម្មណ៍ក្តី បុគ្គលឃើញនូវការបែកធ្លាយក្តី ការប្រាកដឡើងថាសូន្យក្តី ឈ្មោះថា ការពិចារណាឃើញដោយបញ្ញាដ៏ក្រៃលែង ភិក្ខុអ្នកឈ្លាសវៃក្នុងអនុបស្សនាទាំង ៣ ផង ក្នុងវិបស្សនាទាំង ៤ ផង រមែងមិនញាប់ញ័រក្នុងទិដ្ឋិទាំងឡាយផ្សេងៗ ព្រោះខ្លួនជាអ្នកឈ្លាសវៃ ក្នុងការប្រាកដទាំង ៣ ។

ដែលឈ្មោះថា ញាណនោះ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការដឹងនូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ ។

# អដ្ឋកថា

## ភង្គានុបស្សនាញាណនិទ្ទេស

[ ១១២-១១៣ ] ព្រះយោគាវចរនោះ តាំងនៅក្នុងឧទយព្វយានុបស្សនាញាណហើយ លុះដឹងឧទយព្វយានុបស្សនាញាណ ដែលប្រព្រឹត្តទៅតាមវីថិ ដែលផុតចាកឧបក្កិលេស ដោយការកំណត់មគ្គ និងមិនមែនមគ្គ ថាជាមគ្គ ដូច្នេះហើយ ប្រារព្ធឧទយព្វយានុបស្សនាញាណទៀត ដើម្បីធ្វើមគ្គនោះឲ្យបរិសុទ្ធដោយល្អ ដោយកំណត់ត្រៃលក្ខណ៍ ហើយពិចារណាសង្ខារទាំងឡាយ ដែលកំណត់ដោយការកើត និងការរលត់ ដោយសភាពជារបស់មិនទៀងជាដើម ។ ញាណនោះរបស់ព្រះយោគាវចរនោះ ជាញាណចាស់ក្លា រមែងនាំទៅយ៉ាងនេះ សង្ខារទាំងឡាយ រមែងប្រាកដឆាប់រហ័ស កាលញាណចាស់ក្លានាំទៅ កាលសង្ខារទាំងឡាយប្រាកដរហ័ស ញាណឈានកន្លងការកើតហើយ កាលការរលត់មាន ក៏តាំងនៅបាន ។ ម្យ៉ាងទៀត ព្រោះបង្អោនទៅកាន់និរោធ ញាណ លះបង់ការកើត ហើយតាំងសតិមាំក្នុងការរលត់នោះឯង ភង្គានុបស្សនាញាណ រមែងកើតឡើងក្នុងទីនេះ ។ ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃញាណនោះថា បទថា **រូបារម្មណតា ចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ** បានដល់ ចិត្តដែលមានរូបជាអារម្មណ៍កើតឡើងហើយ រលត់ទៅ ។ ម្យ៉ាងវិញទៀត អធិប្បាយថា ចិត្តកើតឡើង ក្នុងការមានរូបជាអារម្មណ៍ហើយរលត់ទៅ ។

បទថា **តំ អារម្មណំ បដិសង្ខា** សេចក្តីថា ពិចារណា គឺដឹងរូបារម្មណ៍នោះ ហើយឃើញដោយការអស់ទៅ ដោយការសូន្យទៅ ។ បទថា **តស្ស**

**ចិត្តស្ស ភង្គំ អនុបស្សតិ** សេចក្តីថា រូបារម្មណ៍នោះ ដែលចិត្តណាឃើញដោយការអស់ទៅ ដោយការសូន្យទៅ ព្រះយោគាវចរ រមែងពិចារណាឃើញការបែកធ្លាយនៃចិត្តនោះដោយចិត្តដទៃ ។ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា ព្រះយោគាវចររមែងពិចារណាឃើញទាំងពីរយ៉ាង គឺចិត្តដែលដឹងហើយ និងញាណ ។ ក្នុងពាក្យថា ចិត្តនេះ លោកបំណងយកសម្បយុត្តចិត្ត ។ បទថា **អនុបស្សតិ** សេចក្តីថា រមែងឃើញតាម គឺឃើញរឿយៗដោយអាការមិនមែនតិច ។ ដោយហេតុនោះ ទើបព្រះសារីបុត្តពោលថា **អនុបស្សតីតិ កថំ អនុបស្សតិ អនិច្ចតោ អនុបស្សតិ** ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញដូចម្តេច ពិចារណាឃើញថាមិនទៀង ដូច្នេះជាដើម ។

ក្នុងបទនោះ មានអធិប្បាយដូចតទៅនេះថា ព្រោះទីបំផុតដោយភាពជារបស់មិនទៀង ឈ្មោះថា ភង្គ ហេតុនោះ ព្រះយោគាវចរអ្នកចម្រើនកង្ខានុបស្សនារមែងពិចារណាឃើញរូបទាំងអស់ ដោយភាពជារបស់មិនទៀង មិនមែនដោយភាពជារបស់ទៀងទេ ។ បន្ទាប់អំពីនោះ ពិចារណាឃើញរូបនោះឯង ដោយភាពជាទុក្ខ មិនមែនដោយភាពជាសុខទេ ព្រោះវត្ថុដែលមិនទៀងជាទុក្ខ និងវត្ថុដែលជាទុក្ខ ជាអនត្តា ។ រមែងពិចារណាឃើញ ដោយភាពជាអនត្តា មិនមែនដោយភាពជាអត្តាទេ ។

ម្យ៉ាងទៀត ព្រោះវត្ថុណា មិនទៀង ជាទុក្ខ ជាអនត្តា វត្ថុនោះ មិនគួរត្រេកអរ វត្ថុណា មិនគួរត្រេកអរ មិនគួរតម្រេកក្នុងវត្ថុនោះ ហេតុនោះ ព្រះយោគាវចរ រមែងនឿយណាយ មិនមែនពេញចិត្ត រមែងប្រាសចាកតម្រេក

មិនមែនតម្រេកក្នុងរូបដែលឃើញនោះថា **អនិច្ចំ ទុក្ខំ អនត្តា** ដោយទំនង ដូចគ្នានឹងកង្ខានុបស្សនាញាណ ។

ព្រះយោគាវចរនោះ ប្រាសចាកតម្រេកយ៉ាងនេះ រមែងពិចារណាដោយញាណ ដែលត្រឹមតែជាលោកិយ អធិប្បាយថា មិនកើតឡើង មិនធ្វើឲ្យកើតឡើង ។ ម្យ៉ាងទៀត ព្រះយោគាវចរនោះប្រាសចាកតម្រេកយ៉ាងនេះហើយ រមែងរម្លត់ សូម្បីរូបដែលមិនឃើញ ដូចរូបដែលឃើញដោយអំណាច **អន្វយញ្ញាណ** ( ញាណដែលបន្តគ្នា ) មិនមែនឲ្យកើតឡើង ។ អធិប្បាយថា ព្រះយោគាវចរ ធ្វើទុកក្នុងចិត្តដោយការរលត់នោះឯង រមែងឃើញការរលត់របស់រូបនោះ មិន មែនឃើញការកើតឡើង ។ ព្រះយោគាវចរនោះបដិបត្តិយ៉ាងនេះហើយ រមែង លះបង់ មិនមែនកាន់យក ។ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ការពិចារណាឃើញភាពមិនទៀងជាដើម នេះហៅថា ជាការលះបង់ដោយ ការបរិច្ចាគ និងលះបង់ដោយការស្ទុះទៅ ព្រោះលះបង់កិលេសចាកខន្ធ និង អភិសង្ខារដោយតទង្គប្បហាន និងព្រោះស្ទុះទៅក្នុងព្រះនិព្វាន ដែលផ្ទុយគ្នា ជាមួយនឹងកិលេសនោះ ដោយបង្អោនទៅក្នុងនិព្វាននោះ ដោយការឃើញ ទោសនៃសង្ខតធម៌ ។

ព្រោះដូច្នោះ ភិក្ខុអ្នកប្រកបដោយអនុបស្សនានោះ រមែងលះបង់កិលេស ទាំងឡាយ និងរមែងស្ទុះទៅក្នុងនិព្វាន ដោយន័យដូចពោលហើយ ។ ប្រកាន់ កិលេសដោយអំណាចធ្វើឲ្យកើតឡើង ក៏មិនមែន កាន់យកសង្ខតធម៌ជា អារម្មណ៍ ដោយអំណាចមានប្រក្រតីឃើញថា មិនមានទោស ក៏មិនមែន

ដោយហេតុនោះ ទើបលោកពោលថា **បដិនិស្សជ្ជតិ នោ អាទិយតិ** រមែង លះបង់ចោល រមែងមិនកាន់យក ។

ឥឡូវនេះ ដើម្បីសម្ដែងការលះធម៌ដោយញាណទាំងនោះ របស់ព្រះយោគាវចរនោះ ទើបព្រះសារីបុត្តពោលថា **អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ** បុគ្គលកាលពិចារណាឃើញថា មិនទៀង ក៏លះបង់សញ្ញាថាទៀង ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **នន្ទឹ** បានដល់ តណ្ហាដែលមានបីតិ ។ បទថា **រាគំ** បានដល់ តណ្ហាដ៏សេស ។ បទថា **សមុទយំ** បានដល់ ការកើតឡើងនៃរាគៈ ។ ម្យ៉ាងទៀត បានដល់ ការកើតឡើងនៃរូប ។

បទថា **អាទានំ** បានដល់ ការប្រកាន់ដោយកិលេសទាំងឡាយ ដោយអំណាចធ្វើឲ្យកើតឡើង ។ គប្បីជ្រាបបទថា **វេទនារម្មណតា** ជាដើម ដោយន័យដូចពោលហើយ ក្នុងទីនេះ និងក្នុងកាលមុន ។

[ ១១៤ ] ម្យ៉ាងទៀត គប្បីជ្រាបក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **វត្ថុសង្កមនា** សេចក្ដីថា ការឈានទៅកាន់វត្ថុដទៃពីបុរិមវត្ថុ ដោយឃើញការរលត់របស់ចិត្ត ដែលឃើញការរលត់របស់ខន្ធនីមួយៗ ក្នុងខន្ធទាំងឡាយមានរូបក្ខន្ធជាដើម ហើយឃើញការរលត់ទៅ ។ បទថា **បញ្ញាយ ច វិវដ្ដនា** បានដល់ លះបង់ការកើតឡើង ហើយតាំងនៅក្នុងការវិនាស ។ បទថា **អាវជ្ជនា ពលញ្ចេវ** បានដល់ ភាពជាអ្នកអាចរំពឹងរកក្នុងលំដាប់នោះឯង ដើម្បីឃើញការរលត់របស់ខន្ធនីមួយៗ ក្នុងខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ឃើញការរលត់របស់ចិត្ត ដែលមានការរលត់ជាអារម្មណ៍ទៀត ។ បទថា

**បដិសង្ខា វិបស្សនា** បានដល់ ការពិចារណាអារម្មណ៍នេះ ឈ្មោះថា ភង្គា-នុបស្សនា ។ បទថា **អារម្មណអន្វយេន ឧភោ ឯកវវត្ថនា** សេចក្ដីថា ការកំណត់ធម៌ ២ ប្រការ ដោយសភាពតែមួយយ៉ាងនេះថា សង្ខារក្នុងអតីតបែកធ្លាយហើយ សូម្បីក្នុងអនាគត ក៏នឹងបែកធ្លាយ ដូចសង្ខារនេះ បែកធ្លាយដោយអនុលោមតាម គឺទៅតាមអារម្មណ៍ដែលឃើញហើយដោយប្រចក្ស ។ សូម្បីបុរាណាចារ្យក៏ពោលថា

*ភិក្ខុអ្នកមានការឃើញបរិសុទ្ធ ក្នុងសង្ខារដែលជាបច្ចុប្បន្ន រមែងបង្អោនទាំការឃើញបរិសុទ្ធនោះទៅ ពិចារណាសង្ខារដែលជាអតីត និងអនាគតថា សង្ខារទាំងឡាយសូម្បីទាំងអស់ ក៏មានប្រក្រតីបែកធ្លាយទៅ ដូចតំណក់ទឹកសន្សើមដែលត្រូវស្ងួតទៅក្នុងកាលព្រះអាទិត្យរះឡើង ដូច្នោះ ។*

បទថា **និរោធេ អធិមុត្តតា** សេចក្ដីថា ការបង្អោនទៅក្នុងភាពជាអ្នកចុះចិត្តស៊ប់ ភាពទេរទៅ ភាពឱនទៅ ភាពជម្រាលទៅក្នុងការរលត់ ពោលគឺការបែកធ្លាយនោះឯង ព្រោះធ្វើការកំណត់ធម៌ទាំងពីរបំណែក ដោយភាពតែមួយ ដោយអំណាចការបែកធ្លាយយ៉ាងនេះ ។

បទថា **វយលក្ខណវិបស្សនា** អធិប្បាយថា វិបស្សនានេះ ឈ្មោះថា វយលក្ខណវិបស្សនា ។ បទថា **អារម្មណញ្ច បដិសង្ខា** បានដល់ ដឹងអា-រម្មណ៍ មានរូបជាដើមជាមុន ។ បទថា **ភង្គញ្ច អនុបស្សតិ** សេចក្ដីថា ឃើញការរលត់របស់អារម្មណ៍នោះ ហើយពិចារណាឃើញការរលត់របស់អារម្មណ៍

នោះ និងរបស់ចិត្ត ។ បទថា **សុញ្ញតោ ច ឧបដ្ឋានំ** បានដល់ កាលព្រះយោគាវចរនោះពិចារណាឃើញការរលត់របស់ចិត្តយ៉ាងនេះ ការប្រាកដដោយភាពជារបស់សូន្យថា សង្ខារទាំងឡាយរមែងបែកធ្លាយ ការបែកធ្លាយនៃសង្ខារទាំងនោះ គឺការស្លាប់មិនមានអ្វីដទៃឡើយ រមែងសម្រេច ។ ដោយហេតុនោះទើបបុរាណាចារ្យពោលថា

ខន្ធទាំងឡាយ រមែងរលត់មិនមានអ្វីដទៃ គឺមិនមានសត្វបុគ្គល
ការបែកធ្លាយនៃខន្ធ លោកហៅថា មរណៈ អ្នកមិនប្រមាទ
ឃើញការអស់ទៅនៃខន្ធទាំងនោះ ដោយឧបាយ ដូចជាងកែវ
យកពេជ្រចោះកែវមណី ដូច្នោះ ។

បទថា **អធិប្បញ្ញា វិបស្សនា** អធិប្បាយថា ការពិចារណាអារម្មណ៍ ការពិចារណាឃើញការរលត់ និងការប្រាកដដោយភាពជារបស់សូន្យ ឈ្មោះថា អធិប្បញ្ញាវិបស្សនា ( ការឃើញច្បាស់ដោយអធិប្បញ្ញា ) ។ បទថា **កុសលោ តីសុ អនុបស្សនាសុ** បានដល់ ភិក្ខុអ្នកឈ្លាសក្នុងអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ។ បទថា **ចតូសុ ច វិបស្សនាសុ** បានដល់ក្នុងវិបស្សនា ៤ មាននិព្វិទានុបស្សនាជាដើម ។ បទថា **តយោ ឧបដ្ឋានេ កុសលតា** បានដល់ ព្រោះភាពជាអ្នកឈ្លាសក្នុងសេចក្តីប្រាកដ ៣ ប្រការនេះ គឺដោយការអស់ទៅ ដោយការវិនាសទៅ និងដោយភាពជារបស់សូន្យទៅ ។

បទថា **នានាទិដ្ឋីសុ ន កម្បតិ** បានដល់ មិនញាប់ញ័រក្នុងទិដ្ឋិមានប្រការផ្សេងៗ មានសស្សតទិដ្ឋិជាដើម ។ ព្រះយោគាវចរនោះ មិនញាប់ញ័រយ៉ាងនេះ

មានមនសិការប្រព្រឹត្តទៅហើយថា វត្ថុដែលមិនទាន់រលត់រមែងរលត់ទៅ វត្ថុដែលមិនទាន់បែកធ្លាយ រមែងបែកធ្លាយទៅ ហើយលះបង់និមិត្តដែលប្រព្រឹត្តទៅក្នុងការកើតឡើង និងការតាំងនៅ រមែងឃើញចំពោះនូវការបែកធ្លាយនៃសង្ខារទាំងពួង ដូចភាជនៈទុព្វលកំពុងបែក ដូចធូលីល្អិតកំពុងខ្ចាត់ខ្ចាយ ដូចគ្រាប់ល្ងត្រូវលីង ។ ព្រះយោគាវចរនោះ រមែងឃើញថា សង្ខារទាំងឡាយទាំងពួង រមែងបែកធ្លាយទៅ ដូចបុរសអ្នកមានភ្នែកល្អ ឈរលើមាត់ស្រះបោក្ខរណី ឬឈរលើមាត់ស្ទឹង កាលបើភ្លៀងធំធ្លាក់ចុះមក គប្បីឃើញពពុះទឹកធំៗ កើតឡើងលើផ្ទៃទឹក ហើយក៏បែកធ្លាយទៅដោយរហ័ស ដូច្នោះ ។ ព្រះមានព្រះភាគ ត្រាស់ ( ក្នុងធម្មបទ ) សំដៅដល់ព្រះយោគាវចរ មានសភាពបែបនោះថា

> បុគ្គលឃើញពពុះទឹក យ៉ាងណា ឃើញព្រេញថ្ងៃ យ៉ាងណា
> ស្ដេចមច្ចុមិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះ
> ទេ ដូច្នេះ ។

កាលបើព្រះយោគាវចរនោះ ឃើញរឿយៗ យ៉ាងនេះថា សង្ខារទាំងឡាយទាំងពួងរមែងបែកធ្លាយទៅ ដូច្នេះ ភង្គានុបស្សនាញាណមានអានិសង្ស ៨ ជាបរិវារ រមែងមានកម្លាំង ។ អានិសង្សទាំង ៨ នេះ គឺការលះភវទិដ្ឋិ ១ ការលះសេចក្ដីពេញចិត្តក្នុងជីវិត ១ ការប្រកបសេចក្ដីខ្វល់ខ្វាយសព្វកាល ១ ការមានអាជីវបារិសុទ្ធិ ១ ការលះសេចក្ដីខ្វល់ខ្វាយក្នុងការធ្វើបាប ១ ការប្រាសចាកភ័យ ១ ការបានខន្តិ និងសោរច្ចៈ ១ ការអត់ធន់ក្នុងការត្រេកអរ

មិនត្រេកអរ ១ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

ព្រះមុនីអ្នកឃើញសង្ខារទាំងឡាយ បែកធ្លាយទៅរឿយៗ លុះ
ឃើញអានិសង្ស ៨ ដែលមានការលះភវទិដ្ឋិជាដើម ទាំងនេះ
ថាជាធម៌ដ៏ខ្ពស់បំផុត ដើម្បីសម្រេចអមតៈ គឺព្រះនិព្វាន រមែង
ពិចារណាសង្ខារនោះរឿយៗ ដូចបុគ្គលមានសំពត់ជួតក្បាល
ដែលត្រូវភ្លើងឆេះ ដូច្នោះ ។ល។

## អដ្ឋកថាភង្គានុបស្សនាញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ១១៥ ] បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឈ្មោះថា អាទីនវញ្ញាណ តើដូចម្តេច ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការកើតជាភ័យ ឈ្មោះថា អាទីនវញ្ញាណ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការប្រព្រឹត្តជាភ័យ ឈ្មោះថា អាទីនវញ្ញាណ ថានិមិត្តជាភ័យ ។បេ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការប្រមូលមកជាភ័យ ថាបដិសន្ធិជាភ័យ ថាគតិជាភ័យ ថាការប្រព្រឹត្តជាភ័យ ថាការកើតជាភ័យ ថាជាតិជាភ័យ ថាជរាជាភ័យ ថាព្យាធិជាភ័យ ថាមរណៈជាភ័យ ថាសោកជាភ័យ ថាការខ្សឹកខ្សួលជាភ័យ ថាការចង្អៀតចង្អល់ចិត្តជាភ័យ ឈ្មោះថា អាទីនវញ្ញាណ ។ ញាណក្នុងសន្តិបទ ( បទស្ងប់រម្ងាប់ ) ថា ការមិនកើតជាសេចក្តីក្សេម ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្តជាសេចក្តីក្សេម ។បេ។ ញាណក្នុងសន្តិបទថា សេចក្តីមិនចង្អៀតចង្អល់ចិត្តជាសេចក្តីក្សេម ញាណក្នុងសន្តិបទថា ការកើតជាភ័យ ការមិនកើតឡើងជាសេចក្តីក្សេម ញាណក្នុងសន្តិបទថា ការប្រព្រឹត្តជាភ័យ ការមិនប្រព្រឹត្តជាសេចក្តីក្សេម ។បេ។ ញាណក្នុងសន្តិបទថា ការចង្អៀតចង្អល់ចិត្តជាភ័យ ការមិនចង្អៀតចង្អល់ចិត្តជាសេចក្តីក្សេម បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការកើតជាទុក្ខ ឈ្មោះថា អាទីនវញ្ញាណ ។បេ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការចង្អៀតចង្អល់ចិត្ត ជាទុក្ខ ឈ្មោះថា អាទីនវញ្ញាណ ញាណក្នុងសន្តិបទថា ការមិនកើតជាសុខ ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្តជាសុខ ។បេ។ ញាណក្នុងសន្តិបទថា ការមិនចង្អៀតចង្អល់ចិត្តជាសុខ ។

[ ១១៦ ] ញាណក្នុងសន្តិបទថា ការកើតជាទុក្ខ ការមិនកើតជាសុខ

ញាណក្នុងសន្តិបទថា ការប្រព្រឹត្តជាទុក្ខ ការមិនប្រព្រឹត្តជាសុខ ។បេ។ ញាណក្នុងសន្តិបទថា ការបង្អៀតបង្អល់ចិត្តជាទុក្ខ ការមិនបង្អៀតបង្អល់ចិត្តជាសុខ ។

[ ១១៧ ] បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការកើតប្រកបដោយអាមិសៈ ឈ្មោះថា អាទីនវញ្ញាណ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការប្រព្រឹត្តប្រកបដោយអាមិសៈ ឈ្មោះថា អាទីនវញ្ញាណ ។បេ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការបង្អៀតបង្អល់ចិត្ត ប្រកបដោយអាមិសៈ ឈ្មោះថា អាទីនវញ្ញាណ ញាណក្នុងសន្តិបទថា ការមិនកើតមិនប្រកបដោយអាមិសៈ ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្តមិនប្រកបដោយអាមិសៈ ។បេ។ ញាណក្នុងសន្តិបទថា ការមិនបង្អៀតបង្អល់ចិត្ត មិនប្រកបដោយអាមិសៈ ញាណក្នុងសន្តិបទថា ការកើតប្រកបដោយអាមិសៈ ការមិនកើតមិនប្រកបដោយអាមិសៈ ញាណក្នុងសន្តិបទថា ការប្រព្រឹត្តប្រកបដោយអាមិសៈ ការមិនប្រព្រឹត្តមិនប្រកបដោយអាមិសៈ ។បេ។ ញាណក្នុងសន្តិបទថា ការបង្អៀតបង្អល់ចិត្ត ប្រកបដោយអាមិសៈ ការមិនបង្អៀតបង្អល់ចិត្ត មិនប្រកបដោយអាមិសៈ ។

[ ១១៨ ] បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការកើតជាសង្ខារ ឈ្មោះថា អាទីនវញ្ញាណ ។បេ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ថាការបង្អៀតបង្អល់ចិត្តជាសង្ខារ ឈ្មោះថា អាទីនវញ្ញាណ ញាណក្នុងសន្តិបទថា ការមិនកើតជានិព្វាន ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្តជានិព្វាន ។បេ។ ញាណក្នុងសន្តិបទថា ការមិនបង្អៀតបង្អល់ចិត្តជានិព្វាន ញាណក្នុងសន្តិបទថា ការ

កើតជាសង្ខារ ការមិនកើតជានិព្វាន ញាណក្នុងសន្តិបទថា ការប្រព្រឹត្តជាសង្ខារ ការមិនប្រព្រឹត្តជានិព្វាន ។បេ។ ញាណក្នុងសន្តិបទថា ការចង្អៀតចង្អល់ចិត្តជាសង្ខារ ការមិនចង្អៀតចង្អល់ចិត្តជានិព្វាន ។

[ ១១៩ ] បុគ្គលឃើញនូវការកើត នូវការប្រព្រឹត្ត នូវនិមិត្ត នូវការប្រមូលមក និងបដិសន្ធិថាជាទុក្ខ នេះឈ្មោះថា អាទីនវញ្ញាណ បុគ្គលឃើញនូវការមិនកើត នូវការមិនប្រព្រឹត្ត នូវការមិនមាននិមិត្ត នូវការមិនប្រមូលមក និងការមិនបដិសន្ធិថាជាសុខ នេះឈ្មោះថា ញាណក្នុងសន្តិបទ អាទីនវញ្ញាណនេះ តែងកើតក្នុងឋាន ៥ ញាណក្នុងសន្តិបទនេះ តែងកើតក្នុងឋាន ៥ បុគ្គល រមែងដឹងច្បាស់នូវញាណទាំង ១០ ( នេះឯង ) ភាពនៃបុគ្គលអ្នកឈ្លាសវៃ ក្នុងញាណទាំង ២ ទើបមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ ។

ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឈ្មោះថា អាទីនវញ្ញាណ ។

# អដ្ឋកថា

# អាទីនវញ្ញាណនិទ្ទេស

[ ១១៥-១១៩ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាទីនវញ្ញាណនិទ្ទេស ដូចតទៅនេះ បទថា **ឧប្បាទោ** បានដល់ ការកើតឡើងក្នុងលោកនេះ ព្រោះកម្មចាស់ជាបច្ច័យ ។ បទថា **បវត្តំ** បានដល់ ការប្រព្រឹត្តទៅនៃសង្ខារតាមដែលកើតឡើងហើយ ។ បទថា **និមិត្តំ** បានដល់ គឺសង្ខារនិមិត្តទាំងអស់ ។ បទថា **អាយូហនា** បានដល់ កម្មដែលជាហេតុនៃបដិសន្ធិតទៅ ។ បទថា **បដិសន្ធិ** បានដល់ ការកើតតទៅ ។ បទថា **គតិ** បានដល់ គតិដែលជាហេតុឲ្យបដិសន្ធិ ។ បទថា **និព្វត្តិ** បានដល់ ការកើតឡើងនៃខន្ធទាំងឡាយ ។ បទថា **ឧបបត្តិ** បានដល់ ការប្រព្រឹត្តទៅនៃវិបាក ដែលត្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណិ ) យ៉ាងនេះថា នៃបុគ្គលអ្នកចូល ( កាន់សមាបត្តិ ) ឬបុគ្គលដែលកើតហើយដូច្នេះ ។

បទថា **ជាតិ** បានដល់ ជាតិមានភពជាបច្ច័យ ដែលជាបច្ច័យដល់ជរាជាដើម ។ ដោយត្រង់ ជាតិ គឺការប្រាកដគ្រាដំបូងនៃខន្ធទាំងឡាយ ដែលប្រាកដដល់សត្វដែលកើតក្នុងភពនោះៗ ។ បទថា **ជរា** បានដល់ ការចាស់ ដែលដឹងទូទៅថា ធ្មេញបាក់ជាដើម នៃខន្ធសន្តានដែលទាក់ទងគ្នាក្នុងសន្តតិក្នុងភពមួយ ។ បទថា **សោកោ** បានដល់ សេចក្ដីក្ដៅក្រហាយចិត្តរបស់អ្នកដែលត្រូវសេចក្ដីវិនាសញាតិជាដើមពាល់ត្រូវហើយ ។ បទថា **បរិទេវោ** បានដល់ ការយំរៀបរាប់របស់បុគ្គលដែលត្រូវការវិនាសញាតិជាដើម ពាល់ត្រូវហើយ ។

បទថា **ឧបាយាសោ** បានដល់ សេចក្ដីចង្អៀតចង្អល់ចិត្តយ៉ាងខ្លាំង គឺទោសៈដែលកើតពីទុក្ខតាមផ្លូវចិត្តយ៉ាងខ្លាំង របស់បុគ្គលដែលត្រូវសេចក្ដីវិនាសញាតិជាដើម ពាល់ត្រូវហើយ ។

ម្យ៉ាងទៀត ក្នុងទីនេះ លោកពោលដល់ធម៌ ៥ មានការប្រាកដឡើងជាដើម ដោយអំណាចជាទីតាំងនៃអាទីនវញ្ញាណ លោកពោលធម៌ដ៏សេសដោយអំណាចជាវេវចនៈរបស់ធម៌ទាំង ៥ ប្រការនោះ ។ ពីរបទនេះ គឺនិព្វត្តិ និងជាតិ ជាវេវចនៈនៃឧប្បាទ និងបដិសន្ធិ ។ ពីរបទនេះ គឺគតិ និងឧបបត្តិ ជាវេវចនៈនៃបវត្តៈជរាជាដើម ជាវេវចនៈនៃនិមិត្ត ។ ដោយហេតុនោះ ទើបព្រះសារីបុត្តពោលថា

> បុគ្គលឃើញនូវការកើត នូវការប្រព្រឹត្ត នូវនិមិត្ត នូវការប្រមូលមក និងបដិសន្ធិថាជាទុក្ខ នេះឈ្មោះថា អាទីនវញ្ញាណ ។ និងថា អាទីនវញ្ញាណនេះ តែងកើតក្នុងឋានៈ ៥ ដូច្នេះ ។

ម្យ៉ាងវិញទៀត បទថា **ភយន្តិ** ក្នុងគ្រប់បទ កាត់បទជា **ភយំ ឥតិ** ។ បទថា **ភយំ** ឈ្មោះថា **ភយ** ព្រោះមានភ័យចំពោះមុខ ដោយប្រកបដោយការបៀតបៀន ។ បទថា **ឥតិ** ជាការសម្ដែងហេតុនៃភយតូបដ្ឋានញ្ញាណ ។

ចំណែកបទថា **អនុប្បាទោ ខេមន្តិ សន្តិបទេ ញាណំ** ជាដើម លោកពោលដើម្បីសម្ដែងញាណ ដែលជាចំណែកផ្ទុយនៃអាទីនវញ្ញាណ ។ ម្យ៉ាងទៀត បទនេះ លោកពោលដើម្បីឲ្យកើតការក្សេមនៃចិត្តថា ការផុតភ័យ ការមិនមានទោសទាំងពីរនៅមាននៅឡើយដល់បុគ្គលដែលមានចិត្តតក់ស្លុត ព្រោះ

ឃើញទោសដោយប្រាកដថាជាភ័យ ។ ម្យ៉ាងទៀត ព្រោះធម៌ ៥ យ៉ាង មានការប្រាកដឡើងជាដើម ប្រាកដច្បាស់ដោយភាពជាភ័យដល់បុគ្គលណា ចិត្តរបស់បុគ្គលនោះ រមែងបង្អោនទៅកាន់ធម៌ដែលជាបដិបក្ខចំពោះធម៌ ៥ យ៉ាងនោះ ហេតុនោះ គប្បីជ្រាបថា ពាក្យនេះ លោកពោលដើម្បីសម្តែងដល់អានិសង្សរបស់អាទីនវញ្ញាណដែលសម្រេចហើយ ដោយអំណាចប្រាកដដោយភាពជាភ័យ ។

បទថា **អនុប្បាទោ អប្បវត្តំ** ជាដើម បានដល់ និព្វាននោះឯង ។ បទថា **សន្តិបទេ** បានដល់ ក្នុងចំណែកនៃសន្តិ គឺក្នុងនិព្វាន ។ ពិតហើយ សូម្បីញាណដែលកើតឡើងកាន់យកត្រឹមតែឈ្មោះថា សន្តិបទ ដោយអំណាចការបានស្តាប់មក លោកក៏ពោលថា **សន្តិបទេ ញាណំ** ដូច្នេះ ។

បទថា **ឧប្បាទោ ភយំ អនុប្បាទោ ខេមំ** ជាដើម លោកសង្ខេបញាណទាំងពីរដោយអំណាចជាចំណែកផ្ទុយគ្នានិងគ្នា ហើយកាន់យកញាណ ដែលកើតឡើងពោល ។ ម្យ៉ាងទៀត ក្នុងបទនេះព្រោះវត្ថុណាជាភ័យ វត្ថុនោះជាទុក្ខពិតប្រាកដ ។ ហើយវត្ថុណាជាទុក្ខ វត្ថុនោះឈ្មោះថា មានអាមិស ព្រោះមិនផុតចាកអាមិស គឺវដ្ដៈ អាមិស គឺលោកៈ និងអាមិស គឺកិលេស ។ ម្យ៉ាងទៀត វត្ថុណាមានអាមិស វត្ថុនោះ ត្រឹមតែជាសង្ខារប៉ុណ្ណោះ ។ ហេតុនោះទើបលោកពោលបទថា **ឧប្បាទោ ទុក្ខន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ** ជាដើម ។

សូម្បីយ៉ាងនោះ គប្បីជ្រាបការផ្សេងគ្នាក្នុងបទនេះ ដោយអំណាចការ

ប្រព្រឹត្តទៅដោយការផ្សេងគ្នា ដោយអាការយ៉ាងនេះ គឺដោយអាការគួរខ្លាច ដោយអាការជាទុក្ខ ដោយអាការមានអាមិស ដោយអាការជាសង្ខារ ។

លោកមិនបានសម្ដែងដល់លិង្គនៃពាក្យថា **ឧប្បាទោ** ជាដើមថា **ឧប្បាទោ ភយំ ទុក្ខំ សាមិសំ សង្ខារា** ៩ ការកើតជាភ័យ ជាទុក្ខ ជាអាមិស និងជាសង្ខារ ហើយទើបពោលសម្ដែងដល់លិង្គរបស់ខ្លួន ដូចប្រយោគជាដើមថា **នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ** ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ ដូច្នេះ ។

ម្យ៉ាងទៀត បទថា **សង្ខារា** គប្បីជ្រាបថា លោកមិនបានសម្ដែងថា មានតែម្យ៉ាង ទើបធ្វើជាពហុវចនៈ ដូចក្នុងប្រយោគជាដើមថា **អប្បច្ចយា ធម្មា អសង្ខតា ធម្មា** ពួកធម៌មិនមានបច្ច័យ ពួកធម៌ឥតបច្ច័យតាក់តែង ដូច្នេះ ។ ឬព្រោះកើតឡើងជាដើម ជាចំណែកមួយនៃសង្ខារ ទើបលោកធ្វើជាពហុវចនៈ សូម្បីក្នុងចំណែកមួយនៃសង្ខារជាច្រើន ដូចក្នុងប្រយោគជាដើមថា **ឧត្តរេ បញ្ចាលា ទក្ខិណេ បញ្ចាលា** អ្នកស្រុកបញ្ចាលនគរក្នុងទិសឧត្តរ អ្នកស្រុកបញ្ចាលនគរក្នុងទិសទក្សិណ ដូច្នេះ ។

បទថា **ខេមំ សុខំ និរាមិសំ និព្វានំ** បានដល់ និព្វាននោះឯង តែលោកពោលជា ៤ យ៉ាង ដោយជាចំណែកផ្ទុយចំពោះអាការដូចពោលហើយ ។ បទថា **ទស ញាណេ បជានាតិ** បានដល់ ព្រះយោគាវចរកាលដឹងអាទីនវញ្ញាណរមែងដឹង រមែងចាក់ធ្លុះ រមែងធ្វើឲ្យជាក់ច្បាស់នូវញាណ ១០ គឺញាណ ៥ ដែលមានការប្រាកដឡើងជាដើមជាទីតាំង ញាណ ៥ ដែលមានការមិន

ប្រាកដឡើងជាដើមជាទីតាំង ។ បទថា **ទ្វិន្នំ ញាណានំ កុសលតា** បានដល់ព្រោះភាពជាអ្នកឈ្លាសក្នុងញាណទាំងពីរយ៉ាងនេះ គឺអាទីនវញ្ញាណ និងសន្តិបទញ្ញាណ ។ បទថា **នានាទិដ្ឋីសុ ន កម្បតិ** បានដល់ មិនញាប់ញ័រក្នុងទិដ្ឋិទាំងឡាយដែលប្រព្រឹត្តទៅហើយ ដោយអំណាចនិព្វាន ដែលជាទិដ្ឋធម៌ដ៏ប្រសើរជាដើម ។ល។

## អដ្ឋកថាអាទីនវញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ១២០ ] បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ ឈ្មោះថា សង្ខារុបេក្ខាញាណ តើដូចម្តេច ។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយក្នុងការកើត ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយក្នុងការប្រព្រឹត្ត ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងនិមិត្ត ។បេ។ សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងការប្រមូលមក សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងបដិសន្ធិ សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងគតិ សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងការវិលមក សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងការកើត សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងជាតិ សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងជរា សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងព្យាធិ សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងមរណៈ សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងសេចក្តីសោក សេចក្តីប្រាថ្នាដើម្បីរួច ... ក្នុងការខ្សឹកខ្សួល បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ ក្នុងសេចក្តីចង្អៀតចង្អល់ចិត្ត ឈ្មោះថា សង្ខារុបេក្ខាញាណ ។

[ ១២១ ] បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើតជាទុក្ខ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្តជាទុក្ខ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា និមិត្តជាទុក្ខ ឈ្មោះថា

សង្ខារុបេក្ខាញាណ ។បេ។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្តជាទុក្ខ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើតជាភ័យ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្តជាភ័យ ឈ្មោះថា សង្ខារុបេក្ខាញាណ ។បេ។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្តជាភ័យ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

[ ១២២ ] បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើតប្រកបដោយអាមិសៈ ឈ្មោះថា សង្ខារុ-បេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្តប្រកបដោយអាមិសៈ ឈ្មោះថា សង្ខារុ-បេក្ខាញាណ ។បេ។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្ត ប្រកបដោយអាមិសៈ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើតជាសង្ខារ ឈ្មោះថា សង្ខារុបេក្ខា-ញាណ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្តជាសង្ខារ ឈ្មោះថា សង្ខារុបេក្ខាញាណ ។បេ។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ

ថា សេចក្តីចង្អៀតចង្អល់ចិត្តជាសង្ខារ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

[ ១២៣ ] ការកើតឡើងចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថា សង្ខារុបេក្ខា សង្ខារ និងឧបេក្ខាទាំង ២ នុ៎ះចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថា សង្ខារុបេក្ខា ការប្រព្រឹត្តចាត់ជាសង្ខារ ។បេ។ និមិត្តចាត់ជាសង្ខារ ការប្រមូលមកចាត់ជាសង្ខារ បដិសន្ធិចាត់ជាសង្ខារ គតិចាត់ជាសង្ខារ ការវិលមកចាត់ជាសង្ខារ ការកើតចាត់ជាសង្ខារ ជាតិចាត់ជាសង្ខារ ជរាចាត់ជាសង្ខារ ព្យាធិចាត់ជាសង្ខារ មរណៈចាត់ជាសង្ខារ សេចក្តីសោកចាត់ជាសង្ខារ សេចក្តីខ្សឹកខ្សួលចាត់ជាសង្ខារ សេចក្តីចង្អៀតចង្អល់ចិត្ត ចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថា សង្ខារុបេក្ខា សង្ខារ និងឧបេក្ខា ទាំង ២ នុ៎ះ ចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថា សង្ខារុបេក្ខា ។

[ ១២៤ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ដោយអាការប៉ុន្មានយ៉ាង ។ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ដោយអាការ ៨ យ៉ាង ។ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន ដោយអាការប៉ុន្មានយ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់សេក្ខបុគ្គល ដោយអាការប៉ុន្មានយ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់អសេក្ខបុគ្គល ដោយអាការប៉ុន្មានយ៉ាង ។

ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន ដោយអាការ ២ យ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គលដោយអាការ ៣ យ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់អសេក្ខបុគ្គលដោយអាការ ៣ យ៉ាង ។

[ ១២៥ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន ដោយអាការ ២ យ៉ាង ដូចម្តេចខ្លះ ។ បុថុជ្ជនត្រេកអរចំពោះសង្ខារុបេក្ខា ឬពិចារណាឃើញនូវសង្ខារុបេក្ខានេះ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន ដោយអាការ ២ យ៉ាង ។

ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ដូចម្តេចខ្លះ ។ សេក្ខបុគ្គល ត្រេកអរចំពោះសង្ខារុបេក្ខា ឬពិចារណាឃើញនូវសង្ខារុបេក្ខា ឬក៏ចូលកាន់ផលសមាបត្តិដោយការពិចារណានេះ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់សេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ។

ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់អសេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ដូចម្តេចខ្លះ ។ អសេក្ខបុគ្គលពិចារណាឃើញនូវសង្ខារុបេក្ខា ឬចូលកាន់ផលសមាបត្តិដោយការពិចារណា ឬក៏រំពឹងមើលនូវសង្ខារុបេក្ខានោះ ហើយនៅដោយសុញ្ញតវិហារធម៌ក្តី ដោយអនិមិត្តវិហារធម៌ក្តី ដោយអប្បណិហិត-វិហារធម៌ក្តីនេះ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់អសេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ។

[ ១២៦ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជនក្តី របស់សេក្ខបុគ្គលក្តី មានភាពតែមួយ តើដូចម្តេច ។ កាលបុថុជ្ជនត្រេកអរចំពោះសង្ខារុបេក្ខា ចិត្តនឹងសៅហ្មង វិបស្សនាការនាក៏មានគ្រោះថ្នាក់ ការត្រាស់ដឹង ( នូវសច្ចធម៌ ) ក៏មានសេចក្តីអន្តរាយ បដិសន្ធិតទៅទៀត ក៏មានបច្ច័យ កាលសេក្ខបុគ្គល ត្រេកអរចំពោះសង្ខារុបេក្ខា ចិត្តនឹងសៅហ្មង វិបស្សនា

ការនៅក៏មានគ្រោះថ្នាក់ ការត្រាស់ដឹងនូវគុណជាតដ៏ខ្ពង់ខ្ពស់ ក៏មានអន្តរាយ បដិសន្ធិតទៅទៀត ក៏មានបច្ច័យ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជនក្តី របស់សេក្ខបុគ្គលក្តី មានភាពតែមួយ ដោយអត្ថថា ត្រេកអរចំពោះ យ៉ាងនេះឯង ។

[ ១២៧ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខ-បុគ្គល និងរបស់អសេក្ខបុគ្គលមានភាពតែមួយ តើដូចម្តេច ។ បុថុជ្ជនពិចា-រណាឃើញនូវសង្ខារុបេក្ខា ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាមិនមែនខ្លួនក្តី សេក្ខបុគ្គលពិចារណាឃើញនូវសង្ខារុបេក្ខា ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាមិនមែនខ្លួនក្តី អសេក្ខបុគ្គលពិចារណាឃើញនូវសង្ខារុបេក្ខា ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាមិនមែនខ្លួនក្តី ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពតែមួយ ដោយអត្ថថា ពិចារណាឃើញ យ៉ាងនេះឯង ។

[ ១២៨ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខ-បុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ បុថុជ្ជនមានសង្ខារុបេក្ខាជាកុសល សេក្ខបុគ្គលក៏មានសង្ខារុបេក្ខាជាកុសលដែរ ឯអសេក្ខបុគ្គលមានសង្ខារុបេក្ខាជាអព្យាក្រឹត ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថា ជាកុសល និងអព្យាក្រឹត យ៉ាងនេះឯង ។

[ ១២៩ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខ-

បុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្ដេច ។ បុថុជ្ជនមានសង្ខារុបេក្ខាដែលខ្លួនដឹងច្បាស់ក្នុងកាលខ្លះ មិនដឹងច្បាស់ក្នុងកាលខ្លះ ឯសេក្ខ-បុគ្គលមានសង្ខារុបេក្ខាដែលខ្លួនដឹងច្បាស់ក្នុងកាលខ្លះ អសេក្ខបុគ្គលមានសង្ខារុបេក្ខា ដែលខ្លួនដឹងច្បាស់ដោយចំណែកមួយ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជនរបស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថា ដឹងច្បាស់ផង ដោយអត្ថថា មិនដឹងច្បាស់ផង យ៉ាងនេះឯង ។

[ ១៣០ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខ-បុគ្គល និងរបស់អសេក្ខបុគ្គលមានភាពផ្សេងគ្នា តើដូចម្ដេច ។ បុថុជ្ជនឃើញច្បាស់នូវសង្ខារុបេក្ខាព្រោះមិនទាន់ឆ្អែត សេក្ខបុគ្គលក៏ឃើញច្បាស់នូវសង្ខា-រុបេក្ខាព្រោះមិនទាន់ឆ្អែតដែរ ឯអសេក្ខបុគ្គល ឃើញច្បាស់នូវសង្ខារុបេក្ខាព្រោះឆ្អែត ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថា ឆ្អែតផង មិនឆ្អែតផង យ៉ាងនេះឯង ។

[ ១៣១ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខ-បុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្ដេច ។ បុថុជ្ជនឃើញច្បាស់នូវសង្ខារុបេក្ខា ដើម្បីលះបង់នូវសញ្ញោជនៈ ៣ ដើម្បីប្រយោជន៍ដល់ការបាននូវសោតាបត្តិមគ្គ សេក្ខបុគ្គល ឃើញច្បាស់នូវសង្ខារុបេក្ខា ដើម្បីប្រយោជន៍ដល់ការបាននូវគុណវិសេសតទៅទៀត ព្រោះបានលះបង់នូវ

សញ្ញោជនៈ ៣ ឯអសេក្ខបុគ្គលឃើញច្បាស់នូវសង្ខារុបេក្ខា ដើម្បីប្រយោជន៍ដល់សុខវិហារធម៌ក្នុងបច្ចុប្បន្ន ព្រោះបានលះបង់នូវកិលេសទាំងអស់ហើយ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថា លះបង់ផង មិនទាន់លះបង់ផង យ៉ាងនេះឯង ។

[ ១៣២ ] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ សេក្ខបុគ្គលតែងត្រេកអរចំពោះសង្ខារុបេក្ខា ឬពិចារណានូវសង្ខារុបេក្ខា ឬក៏ចូលផលសមាបត្តិដោយការពិចារណា ឯអសេក្ខបុគ្គល តែងពិចារណាឃើញនូវសង្ខារុបេក្ខា ឬចូលកាន់ផលសមាបត្តិដោយការពិចារណា ឬក៏រំពឹងមើលនូវសង្ខារុបេក្ខានោះ ហើយនៅដោយសុញ្ញតវិហារធម៌ក្តី ដោយអនិមិត្តវិហារធម៌ក្តី ដោយអប្បណិហិតវិហារធម៌ក្តី ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គលមានភាពផ្សេងគ្នា ដោយអត្ថថា ជាវិហារសមាបត្តិយ៉ាងនេះឯង ។

[ ១៣៣ ] សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចសមថៈ សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចវិបស្សនា ។ សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈ សង្ខារុបេក្ខា ១០ កើតដោយអំណាចវិបស្សនា ។

សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈ តើដូចម្តេច ។ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយចំពោះនីវរណៈទាំងឡាយ ដើម្បីប្រយោជន៍ដល់ការបាននូវបឋមជ្ឈាន ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺការពិចារណា

និងការព្រងើយកន្តើយចំពោះវិតក្ក និងវិចារ ដើម្បីប្រយោជន៍ដល់ការបាននូវទុតិយជ្ឈាន ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណានិងការព្រងើយកន្តើយចំពោះបីតិដើម្បីប្រយោជន៍ដល់ការបាននូវតតិយជ្ឈាន ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ ចំពោះសុខ និងទុក្ខ ដើម្បីប្រយោជន៍ដល់ការបាននូវចតុត្ថជ្ឈាន ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ ចំពោះរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយចំពោះអាកាសានញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយចំពោះវិញ្ញាណញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយចំពោះអាកិញ្ចញ្ញាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ នេះសង្ខារុបេក្ខា ៨ កើតឡើងដោយអំណាចសមថៈ ។

[ ១៣៤ ] សង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចវិបស្សនា តើដូចម្តេច ។ បញ្ញា គឺការពិចារណានិងការព្រងើយកន្តើយនូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្ត ដើម្បីប្រយោជន៍ដល់

ការបាននូវសោតាបត្តិមគ្គ ឈ្មោះថា សង្ខារុបេក្ខាញាណ ១ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយនូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្ត ដើម្បីប្រយោជន៍ដល់សោតាបត្តិផល-សមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ ១ ដើម្បីប្រយោជន៍ដល់ការបាននូវសកទាគាមិមគ្គ ។បេ។ ១ ដើម្បីប្រយោជន៍ដល់សកទាគាមិផលសមាបត្តិ ។បេ។ ១ ដើម្បីប្រយោជន៍ដល់ការបានអនាគាមិមគ្គ ១ ដើម្បីប្រយោជន៍ដល់អនា-គាមិផលសមាបត្តិ ១ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយនូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្តដើម្បីប្រយោជន៍ដល់អរហត្តមគ្គ ឈ្មោះថា សង្ខារុបេក្ខាញាណ ១ ដើម្បីប្រយោជន៍ដល់អរ-ហត្តផលសមាបត្តិ ។បេ។ ១ ដើម្បីប្រយោជន៍ដល់សុញ្ញតវិហារសមាបត្តិ ។បេ។ ១ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយនូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្តដើម្បីប្រយោជន៍ដល់អនិមិត្តវិហារសមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ ១ នេះសង្ខារុបេក្ខាទាំង ១០ កើតឡើងដោយអំណាចវិបស្សនា ។

[ ១៣៥ ] សង្ខារុបេក្ខាជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ សង្ខារុបេក្ខាជាកុសល ១៥ សង្ខារុបេក្ខាជាអព្យាក្រឹត ៣

សង្ខារុបេក្ខាជាអកុសល មិនមានទេ ។

បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ ឈ្មោះថា សង្ខារុ-បេក្ខា មាន ៨ ជាភូមិរបស់ចិត្ត គឺសង្ខារុបេក្ខា ២ ជាភូមិរបស់បុថុជ្ជន សង្ខារុបេក្ខា ៣ ជាភូមិរបស់សេក្ខបុគ្គល សង្ខារុបេក្ខា ៣ ជាភូមិរបស់អសេក្ខបុគ្គល ជាសង្ខារុបេក្ខាដែលចិត្តប្រាសចេញ សង្ខារុបេក្ខា ៨ ជាបច្ច័យនៃអប្បនាសមាធិ សង្ខារុ-បេក្ខា ១០ ជាភូមិរបស់ញាណ សង្ខារុបេក្ខា ១៨ ជាបច្ច័យរបស់វិមោក្ខ ៣ អាការទាំង ១៨ នេះ បុគ្គលនោះបានសន្សំហើយដោយបញ្ញា បុគ្គលអ្នកឈ្លាសវៃ ក្នុងសង្ខារុបេក្ខាទាំងឡាយ រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ ។

ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា គឺសេចក្តីប្រាថ្នា ដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

# អដ្ឋកថា

## សង្ខារុបេក្ខាញាណនិទ្ទេស

[ ១២០-១២៣ ] ក្នុងសង្ខារុបេក្ខាញាណនិទ្ទេស ការកើតឡើង ( ឧប្បាទោ ) ជាដើម មានអត្ថដូចពោលហើយនោះឯង ។

បទថា **ទុក្ខន្តិ ភយន្តិ សាមិសន្តិ សង្ខារា** ជាពាក្យសម្តែងហេតុ នៃញាណដែលរួចផុតចាកការកើតឡើងជាដើម ។ ម្យ៉ាងទៀត ព្រះសារីបុត្តកាលសម្តែងដល់សង្ខារុបេក្ខាញាណដោយលក្ខណៈយ៉ាងនេះហើយ ឥឡូវនេះដើម្បីសម្តែងដោយអត្ថ ទើបពោលបទថា **ឧប្បាទោ សង្ខារា តេ សង្ខារេ អជ្ឈុបេក្ខតីតិ សង្ខារុបេក្ខា** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សង្ខារេ អជ្ឈុបេក្ខតិ** សេចក្តីថា កាលព្រះយោគាវចរនោះ ផ្តើមចម្រើនវិបស្សនា លះសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរកលក្ខណៈ ព្រោះឃើញត្រៃលក្ខណ៍ដោយវិបស្សនាញាណហើយ ឃើញភព ៣ ដូចភ្លើងឆេះដោយទូទៅហើយ មានសភាពជាកណ្តាល ក្នុងការកាន់យកសង្ខារវិបស្សនាញាណនោះ រមែងឃើញសង្ខារទាំងនោះដោយពិសេស និងវៀរចាកការកាន់យកហើយឃើញ គឺសម្លឹងមើល ព្រោះហេតុនោះ ទើបឈ្មោះថា សង្ខារុបេក្ខាញាណ ដូចលោកពោលថា បុគ្គលឈ្មោះពិសេសក្នុងលោកឈ្មោះថា រមែងឈ្មោះដ៏ក្រៃលែង អ្នកវៀរចាកអាហារហើយ ឈ្មោះថា ចូលទៅរក្សា ។ លោកពោលពាក្យថា **យេ ច សង្ខារា យា ច ឧបេក្ខា** ជាដើមទៀត ដោយការកើតនៃសង្ខារុបេក្ខាដែលតាំងនៅដោយអាការជាកណ្តាល ក្នុង

ការពិចារណាឃើញសង្ខារទាំងឡាយថា ជារបស់មិនទៀងជាដើម ហើយកាន់យកក្នុងការពិចារណាឃើញសង្ខារុបេក្ខា ដែលតាំងនៅដោយភាពជាកណ្ដាលដោយជារបស់មិនទៀងជាដើម ហើយកាន់យកសង្ខារុបេក្ខានោះ ។

[ ១២៤ ] ឥឡូវនេះ ព្រះសារីបុត្ត កាលនឹងសម្ដែងប្រភេទរបស់ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ទើបពោលបទថា **កតិហាការេហិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សង្ខារុបេក្ខាយ** ជាសត្តមីវិភត្តិ ប្រែថា ក្នុងសង្ខារុបេក្ខា ។ បទថា **ចិត្តស្ស អភិនីហារោ** បានដល់ ការនាំចិត្តចេញអំពីចិត្តដែលបានសង្ខារុបេក្ខាហើយនោះ ឲ្យឆ្ពោះទៅកាន់សង្ខារុបេក្ខាយ៉ាងពិតប្រាកដ របស់បុគ្គលដែលបានសង្ខារុបេក្ខាហើយ ។ **អភិ** សព្ទ ក្នុងបទថា **អភិនីហារោ** នេះ មានអត្ថថា ឆ្ពោះមុខ ។ **នី** សព្ទ មានអត្ថថា ពិតប្រាកដ ។ ព្រះសារីបុត្តបំណងនឹងដោះស្រាយពាក្យសួរដែលសួរថា **កតិហាការេហិ** ដោយអាការប៉ុន្មាន ដោយចម្លើយថា **អដ្ឋហាការេហិ** ដោយអាការ ៨ យ៉ាង ហើយសម្ដែងអាការទាំង ៨ នោះ ដោយដោះស្រាយពាក្យសួរប្រការទី ២ តែមិនសម្ដែងអាការទាំងនោះ បានតាំងពាក្យសួរថា **បុថុជ្ជនស្ស កតិហាការេហិ** ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជនដោយអាការប៉ុន្មានយ៉ាងជាដើម ។ ក្នុងបទថា **បុថុជ្ជនស្ស** នេះ មានគាថាព័ន្ធដូចតទៅនេះថា

ព្រះសម្ពុទ្ធ អ្នកមានផៅពង្សដូចជាព្រះអាទិត្យ ត្រាស់ដល់
បុថុជ្ជន ២ ពួក គឺអន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។

ក្នុងបុថុជ្ជន ២ ពួកនោះ ជនណាមិនមានការរៀន ការសាកសួរ ការ

ស្តាប់ ការទ្រទ្រង់ចាំ និងការពិចារណាជាដើម ក្នុងខន្ធ ធាតុ អាយតនៈជាដើម ជននេះ ជាអន្ធបុថុជ្ជន ជនណាមានការរៀនជាដើមនោះ ជននេះ ជាកល្យាណបុថុជ្ជន ។ កល្យាណបុថុជ្ជន ក៏មាន ២ ពួក ដូចគាថាថា

ឈ្មោះថា បុថុជ្ជន ដោយហេតុមានកិលេសក្រាស់កើតឡើង
ជាដើម ជននេះ ឈ្មោះថា បុថុជ្ជន ព្រោះឈមចុះខាងក្នុង
របស់ជន ដែលមានកិលេសក្រាស់ ។

ឈ្មោះថា បុថុជ្ជន ព្រោះហេតុញ៉ាំងកិលេសជាដើមដ៏ក្រាស់ មានប្រការផ្សេងៗ ឲ្យកើតជាដើម ដូចលោកពោល ( ក្នុងខុទ្ទកនិកាយ មហានិទ្ទេស ) ថា ឈ្មោះថា បុថុជ្ជន ព្រោះញ៉ាំងកិលេសក្រាស់ឲ្យកើត ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកមានសក្កាយទិដ្ឋិដ៏ក្រាស់ មិនទាន់លះបង់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកពោលប្តេជ្ញាចំពោះមុខសាស្តាទាំងឡាយច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ក្រាស់ ចាក់ស្រែះ ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវឱឃៈផ្សេងៗ ដ៏ក្រាស់បន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះក្តៅក្រហាយដោយកម្តៅផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះរោលរាលដោយកម្តៅរោលរាលផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រេកអរញ៉ាម ជាប់ចិត្ត ជ្រប់ ងល់ងប់ ជាប់ជំពាក់ ចាក់ស្រែះ រួបរឹតក្នុងកាមគុណ ៥ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ ៥ ដ៏ក្រាស់ចាក់ស្រែះ រួបរឹត គ្របសង្កត់ សន្ធប់ បិទបាំង សណ្តំជាប់ ។ ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា បុថុជ្ជន ព្រោះឈមចុះខាងក្នុងជនដែលមានកិលេស ហួសនឹងរាប់ បែរខ្នងដាក់ធម៌របស់ព្រះអរិយៈ ប្រព្រឹត្តធម៌ថោកទាប ម្យ៉ាងទៀត ឈ្មោះថា បុថុជ្ជន ព្រោះជាបុគ្គលប្រកបដោយកិលេស ជាគ្រឿងជាប់ មិនរាប់អានព្រះអរិយៈដែលប្រកបដោយគុណ មានសីល និងសុតៈជាដើម ។ ក្នុងបុថុជ្ជន ២ ពួកនោះ ក្នុងទីនេះ លោកបំណងយកកល្យាណបុថុជ្ជន ព្រោះជនក្រៅអំពីនេះ មិនមានការចម្រើនភាវនាឡើយ ។

ក្នុងបទថា **សេក្ខស្ស** នេះ បានដល់ ព្រះសេក្ខៈ ៧ ពួក គឺអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល និងអរហត្តមគ្គ ។ ឈ្មោះថា សេក្ខៈ ព្រោះលោកទាំងនោះនៅសិក្សាសិក្ខា ៣ ។ ក្នុងព្រះសេក្ខៈទាំងនោះ ក្នុងទីនេះ លោកបំណងយកព្រះសេក្ខៈ ៣ ពួក ដែលតាំងនៅក្នុងសោតាបត្តិផល សកទាគាមិផល និងអនាគាមិផល ព្រោះលោកអ្នកដែលតាំងនៅក្នុងមគ្គ មិនបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ។

ក្នុងបទថា **វីតរាគស្ស** នេះ ឈ្មោះថា វីតរាគៈ ព្រោះអត្ថថា មានរាគៈប្រាសទៅហើយ ដោយប្រាសទៅដោយសមុច្ឆេទប្បហាន ។ បទនេះ ជាឈ្មោះរបស់ព្រះអរហត្ត ។ សូម្បីក្នុង ៣ បទនោះ លោកក៏ធ្វើឲ្យជាឯកវចនៈ ដោយកាន់យកជាតិ ។

[ ១២៥ ] បទថា **សង្ខារុបេក្ខំ អភិនន្ទតិ** សេចក្តីថា កាលបានសញ្ញាក្នុងធម៌ជាគ្រឿងនៅជាសុខ ក្នុងធម៌ជាគ្រឿងនៅ គឺឧបេក្ខានោះហើយ ជាអ្នក

មានមុខឆ្ពោះទៅកាន់សង្ខារុបេក្ខា ដោយការពេញចិត្តក្នុងសុខវិហារធម៌ រមែង រីករាយ គឺធ្វើតណ្ហាដែលមានបីតិឲ្យកើតឡើង ។ បទថា **វិបស្សតិ** បានដល់ បុថុជ្ជនរមែងឃើញច្បាស់ដោយការមិនទៀងជាដើម ដើម្បីបានសោតាបត្តិមគ្គ ព្រះសេក្ខៈ រមែងឃើញច្បាស់ដើម្បីមគ្គជាន់ខ្ពស់ លោកអ្នកដែលប្រាសចាក រាគៈហើយ រមែងឃើញច្បាស់ដើម្បីនៅជាសុខក្នុងទិដ្ឋធម៌ ។ បទថា **បដិ-សង្ខាយ** បានដល់ ចូលទៅពិចារណា ដោយអំណាចការមិនទៀងជាដើម ។ ម្យ៉ាងទៀត ព្រោះព្រះអរិយៈទាំងឡាយ មានព្រះសោតាបន្នជាដើម ចូលផល-សមាបត្តិរបស់ខ្លួន បើមិនឃើញច្បាស់ វិបស្សនាញាណ ៩ មានឧទយព្វ-យញ្ញាណជាដើម ក៏មិនអាចចូលផលសមាបត្តិបាន ហេតុនោះ ទើបលោក ពោលថា **បដិសង្ខាយ វា ផលសមាបត្តិ សមាបជ្ជតិ** ដូច្នេះ ។

ដើម្បីសម្តែងការប្រព្រឹត្តទៅនៃផលសមាបត្តិ ទើបមានបញ្ហាកម្មរបស់ព្រះ អរិយបុគ្គលទាំងនោះដូចតទៅនេះថា

ផលសមាបត្តិ គឺអ្វី នរណាចូលសមាបត្តិនោះ នរណាមិនចូលសមាបត្តិ ព្រោះហេតុអ្វី ទើបត្រូវចូលសមាបត្តិ ការចូលសមាបត្តិនោះដូចម្តេច ការតាំង នៅដូចម្តេច ការចេញដូចម្តេច អ្វីជាលំដាប់នៃផល ផលជាលំដាប់នៃអ្វី ។

ក្នុងបញ្ហាកម្មនោះ សំណួរថា ផលសមាបត្តិ គឺអ្វី ឆ្លើយថា អប្បនាក្នុង និរោធរបស់អរិយផល គឺផលសមាបត្តិ សំណួរថា អ្នកណាចូលសមាបត្តិ នោះ អ្នកណាមិនចូលសមាបត្តិ ( នោះ ) ឆ្លើយថា បុថុជ្ជនទាំងអស់ ចូល សមាបត្តិមិនបាន ។ ព្រោះហេតុអ្វី ព្រោះនៅមិនទាន់សម្រេច ។ ចំណែកព្រះ

អរិយៈទាំងអស់ចូលសមាបត្តិបាន ។ ព្រោះហេតុអ្វី ព្រោះសម្រេចហើយ ។ ចំណែកព្រះអរិយៈថ្នាក់ខ្ពស់មិនចូលសមាបត្តិថ្នាក់ទាប ព្រោះស្ងប់រម្ងាប់ហើយដោយការចូលដល់លំដាប់ថ្នាក់បុគ្គល ។ ព្រះអរិយបុគ្គលជាន់ទាប ក៏មិនចូលសមាបត្តិថ្នាក់ខ្ពស់ ព្រោះមិនទាន់សម្រេច ។ តែលោកទាំងអស់ក៏ចូលសមាបត្តិដែលជាផលរបស់ខ្លួននោះឯង ព្រោះហេតុនោះ ទើបពាក្យនេះ សម្រេចក្នុងសេចក្តីនេះបាន ។

តែអាចារ្យពួកខ្លះពោលថា សូម្បីព្រះសោតាបន្ន ព្រះសកទាគាមី ក៏មិនចូលសមាបត្តិ ព្រះអរិយៈ ២ ពួកខាងលើរមែងចូលសមាបត្តិ ។ នេះជាហេតុរបស់ព្រះអរិយៈទាំងនោះ ដ្បិតថា ព្រះអរិយៈទាំងនោះ ជាអ្នកធ្វើឲ្យបរិបូរក្នុងសមាធិ ។ នុះមិនមែនជាហេតុ ព្រោះសូម្បីបុថុជ្ជន ក៏ចូលលោកិយសមាធិដែលខ្លួនបានហើយបាន ។ ក្នុងទីនេះ តើមានប្រយោជន៍អ្វី ដោយការគិតដល់ហេតុ និងមិនមែនហេតុ ។ ក្នុងការឆ្លើយបញ្ហាទាំងនេះថាសង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចវិបស្សនា តើដូចម្តេច និងថាគោត្រភូធម៌ ១០ ដូចម្តេចខ្លះកើតឡើងដោយអំណាចវិបស្សនា លោកពោលសមាបត្តិផ្សេងគ្នា ក្នុងបាលីគម្ពីរនេះឯងថា ដើម្បីប្រយោជន៍ការចូលសោតាបត្តិផល ដើម្បីប្រយោជន៍ការចូលសកទាមិផលហើយ មិនមែនឬ ព្រោះហេតុនោះ ព្រះអរិយៈទាំងអស់ ក៏រមែងចូលសមាបត្តិដែលជាផលរបស់ខ្លួន ព្រោះហេតុនោះ គប្បីដល់នូវការសម្រេចបានក្នុងទីនេះ ។

សំណួរថា ព្រោះហេតុអ្វី ទើបត្រូវចូលសមាបត្តិ ឆ្លើយថា ដើម្បីនៅជាសុខ

ក្នុងទិដ្ឋធម៌ ដូចព្រះរាជាទាំងឡាយ រមែងសោយសុខក្នុងរាជសម្បត្តិ ពពួកទេវតារមែងសោយទិព្វសុខ យ៉ាងណា ព្រះអរិយៈទាំងឡាយ ក៏យ៉ាងនោះ ធ្វើការកំណត់រយៈកាលថា អញនឹងសោយលោកុត្តរសុខ ហើយចូលផលសមាបត្តិក្នុងខណៈដែលខ្លួនប្រាថ្នា ។

សំណួរថា ការចូលសមាបត្តិនោះដូចម្ដេច ការតាំងនៅដូចម្ដេច ការចេញដូចម្ដេច ឆ្លើយថា ការចូលសមាបត្តិនោះរមែងមានដោយអាការ ២ យ៉ាង គឺមិនធ្វើទុកក្នុងចិត្តដល់អារម្មណ៍ដទៃ ក្រៅពីនិព្វាន ១ ធ្វើទុកក្នុងចិត្តដល់និព្វាន ១ ដូចព្រះសារីបុត្ត ពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិមានបច្ច័យ ២ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ដូច្នេះ ។ នេះជាលំដាប់នៃការចូលសមាបត្តិ ក្នុងទីនេះ ។ ពិតហើយ ព្រះអរិយសាវកអ្នកត្រូវការដោយផលសមាបត្តិ ទៅក្នុងទីស្ងាត់ពួនសម្ងំ គប្បីពិចារណាសង្ខារទាំងឡាយដោយអនុបស្សនាញាណ មានឧទយព្វយានុបស្សនាញាណជាដើម ។ ចិត្តរបស់ព្រះអរិយសាវកនោះ ដែលពិចារណាតាមលំដាប់ដែលប្រព្រឹត្តទៅហើយ រមែងចុះស៊ប់ក្នុងនិរោធ ដោយអំណាចផលសមាបត្តិក្នុងលំដាប់នៃគោត្រភូញាណ ដែលមានសង្ខារជាអារម្មណ៍ ។ ក្នុងទីនេះ ព្រោះចិត្តបង្អោនទៅក្នុងផលសមាបត្តិ ផលប៉ុណ្ណោះរមែងកើតដល់ព្រះសេក្ខៈ មិនមែនមគ្គកើត ។ ជនពួកណាពោលថា ព្រះសោតាបន្នផ្ដើមតាំងវិបស្សនា ដោយគិតថា អញនឹងចូលផលសមាបត្តិ ហើយជាព្រះសក-

ទាគាមី ឯព្រះសកទាគាមី ក៏ជាព្រះអនាគាមី ក៏គួរពោលនឹងជនទាំងនោះថា កាលបើយ៉ាងនេះ ព្រះអនាគាមីក៏នឹងជាព្រះអរហន្ត ព្រះអរហន្តក៏នឹងជាព្រះបច្ចេកពុទ្ធ ឯព្រះបច្ចេកពុទ្ធក៏នឹងជាព្រះសម្មាសម្ពុទ្ធ ។ ព្រោះហេតុនោះ ទើបពាក្យនេះមិនមានប្រយោជន៍សោះ ឯលោកក៏បដិសេធហើយ ដោយអំណាចបាលីនោះឯង ព្រោះហេតុនោះ ទើបគួរកាន់យក ។ តែពាក្យនេះប៉ុណ្ណោះ គួរជឿកាន់យក ផលប៉ុណ្ណោះរមែងកើតដល់ព្រះសេក្ខៈ មិនមែនមគ្គកើតឡើយ ។ ម្យ៉ាងទៀត បើព្រះសេក្ខៈនេះ សម្រេចមគ្គដែលប្រកបដោយបឋមជ្ឈាន ផលដែលប្រកបដោយបឋមជ្ឈាននោះឯង រមែងកើតឡើងដល់ព្រះសេក្ខៈនោះ បើសម្រេចមគ្គដែលប្រកបដោយឈានឯណានីមួយ ក្នុងទុតិយជ្ឈានជាដើម ផលដែលប្រកបដោយឈានឯណានីមួយ ក្នុងទុតិយជ្ឈានជាដើម រមែងកើតឡើងដូចគ្នា ព្រោះហេតុនោះ ការចូលសមាបត្តិនោះ រមែងមានបានដោយប្រការដូច្នេះ ។

សមាបត្តិនោះ តាំងនៅដោយអាការ ៣ ព្រោះបាលី ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ គឺការមិនយកចិត្តទុកដាក់ ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុ ដែលប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងពីខាងដើម ១ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ការបានតាក់តែងពីខាងដើម បានដល់ ការកំណត់វេលាមុនចូលសមាបត្តិ ការតាំងនៅរបស់សមាបត្តិនោះ រមែងមាន

ដរាបអស់កាលនោះដែលមិនទាន់មកដល់ ព្រោះកំណត់ថា អញនឹងចេញក្នុងវេលានោះ ដូច្នេះ ។ ការតាំងនៅរបស់សមាបត្តិនោះ រមែងមានយ៉ាងនេះ ។

សមាបត្តិនោះចេញដោយអាការ ២ យ៉ាង ព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិ មាន ២ ប្រការ គឺការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការមិនយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលមិនមានអារម្មណ៍ ១ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា អារម្មណ៍ទាំងពួង បានដល់ រូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត និងវិញ្ញាណនិមិត្ត ។ ម្យ៉ាងទៀត សូម្បីមិនធ្វើទុកក្នុងចិត្តដល់និមិត្តទាំងអស់ ដោយចំណែកមួយក៏ពិត តែលោកក៏ពោលពាក្យថា អារម្មណ៍ទាំងពួងនេះ ដោយអំណាចសង្គ្រោះចូលជាមួយគ្នាទាំងអស់ ព្រោះហេតុនោះ កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តដល់វត្ថុដែលជាអារម្មណ៍នៃភវង្គ ចិត្តក៏ជាការចេញចាកផលសមាបត្តិ ព្រោះហេតុនោះ គប្បីជ្រាបការចេញចាកសមាបត្តិនោះយ៉ាងនេះ ។

សំណួរថា អ្វីជាលំដាប់របស់ផល ឯផលជាលំដាប់របស់អ្វី ឆ្លើយថា ផលនោះឯង ឬភវង្គជាលំដាប់របស់ផល ។ ឯផលក្នុងលំដាប់មគ្គក៏មាន ក្នុងលំដាប់ផលក៏មាន ក្នុងលំដាប់គោត្រភូក៏មាន ក្នុងលំដាប់នេវសញ្ញានាសញ្ញាយតនៈក៏មាន ។ ក្នុងលំដាប់ទាំងនោះ ផលក្នុងលំដាប់នៃមគ្គ មានក្នុងវិថីនៃមគ្គនោះ ផលក្រោយៗ មានក្នុងលំដាប់ផលមុនៗ ក្នុងផលសមាបត្តិផលមុនៗ មានក្នុងលំដាប់គោត្រភូ ។

ម្យ៉ាងទៀត ក្នុងបទនេះ អនុលោមញ្ញាណ គប្បីជ្រាបថាជាគោត្រភូ ដូចលោកពោលក្នុងបដ្ឋានថា អនុលោមរបស់ព្រះអរហន្ត ( ជាបច្ច័យ ) នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ និងថា អនុលោមរបស់ពួកសេក្ខបុគ្គល ជាបច្ច័យនៃផលសមាបត្តិដោយអនន្តរប្បច្ច័យ ដូច្នេះ ។ ការចេញចាកនិរោធរមែងមានដោយផលណា ផលនោះ រមែងមានក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈ ។ ក្នុងបទនោះ ផលទាំងអស់ដ៏សេស វៀរផលដែលកើតឡើងក្នុងមគ្គវិថិ ឈ្មោះថា ប្រព្រឹត្តទៅហើយដោយអំណាចនៃផលសមាបត្តិ ។ ផលនេះប្រព្រឹត្តទៅហើយ ដោយការកើតឡើងក្នុងមគ្គវិថិក្តី ក្នុងផលសមាបត្តិក្តី ដោយប្រការដូច្នេះ ។ លោកពោលជាគាថាថា

សាមញ្ញផលដែលមានសេចក្តីក្រវល់ក្រវាយរម្ងាប់ហើយ មាន
អមតៈជាអារម្មណ៍ជាសុខ ខ្ជាក់ចោលលោកាមិសៈហើយស្ងប់
ឧត្តម ។

នេះជាផលសមាបត្តិកថា ក្នុងនិទ្ទេសនេះ ។

បទថា **តទជ្ឈុបេក្ខិត្វា** បានដល់ ព្រងើយនៃសង្ខារុបេក្ខានោះ ដោយវិបស្សនាញាណបែបនោះយ៉ាងដទៃ ។ ក្នុងបទថា **សុញ្ញតវិហារេន វា** ជាដើម មានន័យដូចតទៅនេះ ការនៅដោយវិបស្សនា ៣ របស់ព្រះអរហន្តដែលបំណងនឹងនៅដោយវិបស្សនាវិហារ វៀរផលសមាបត្តិ ឃើញការប្រកាន់ខ្ជួនដោយភាពជាភ័យ បង្អោនទៅក្នុងភាពទទេ ឃើញសេចក្តីវិនាសក្នុងសង្ខារុបេក្ខា ឈ្មោះថា សុញ្ញតវិហារ ។

ការនៅដោយវិបស្សនា ៣ របស់លោកអ្នកឃើញសង្ខារនិមិត្តដោយភាពជាភ័យ ហើយបង្អោនទៅក្នុងការមិនមាននិមិត្ត ឃើញការវិនាសក្នុងសង្ខារុបេក្ខា ឈ្មោះថា អនិមិត្តវិហារ ។ ការនៅដោយវិបស្សនា ៣ របស់លោកអ្នកឃើញការតាំងនៅនៃតណ្ហាដោយភាពជាភ័យ ហើយបង្អោនទៅក្នុងការមិនតាំងនៅ ឃើញនូវការវិនាស ក្នុងសង្ខារុបេក្ខា ឈ្មោះថា អប្បណិហិតវិហារ ។ ដូចលោកពោលខាងមុខថា បុគ្គលកាលពិចារណាឃើញនូវអភិនិវេសៈ ( ការប្រកាន់មាំ ) ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកកិលេស ឈ្មោះថា សុញ្ញតវិហារធម៌ ( សភាវៈជាទីសម្រាកសូន្យចាកអត្តា ) ។ បុគ្គលកាលពិចារណាឃើញនូវនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ដែលមិនមាននិមិត្ត ឈ្មោះថា អនិមិត្តវិហារធម៌ ( សភាវៈជាទីសម្រាកមិនមានកិលេសជានិមិត្ត ) បុគ្គលកាលពិចារណា ឃើញនូវបណិធិ ( ធម្មជាតមានកិលេសជាទីតាំង ) ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមានកិលេសជាទីតាំង ឈ្មោះថា អប្បណិហិតវិហារធម៌ ( សភាវៈជាទីសម្រាកមិនមានកិលេសជាទីតាំង )[១] ចិត្តរបស់ព្រះអរហន្តនោះឯង រមែងប្រព្រឹត្តទៅក្នុងអំណាចដោយអាការទាំងពួង ដោយមានធម្មវត្តិបេក្ខា

---

១- បិដកខ្មែរ ភាគ ៦៩ ឃ្នាប ២០២ និមិត្តនៅក្នុងលំដាប់ខាងដើម បណិធិនៅក្នុងលំដាប់កណ្តាល អភិនិវេសៈនៅក្នុងលំដាប់ខាងចុង តែក្នុងទីនេះ យើងកាន់យកតាមបាលីក្នុងអដ្ឋកថា ។

និងដោយមានវិហារធម៌ មានការសម្គាល់ក្នុងវត្ថុបដិកូលថា មិនជាបដិកូលជាដើម បន្ទាប់ពីនោះ លោកអធិប្បាយថា ធម៌ជាគ្រឿងនៅ គឺវិបស្សនានេះរមែងសម្រេចដល់ព្រះអរហន្តប៉ុណ្ណោះ ។ ក្នុងបទនេះថា **វិតរាគោ សង្ខារុបេក្ខំ វិបស្សតិ វា** មានសេចក្ដីថា វិបស្សនាដែលមិនដល់ភ័យ ៣ យ៉ាង និងអធិមុត្តិ ( ការបង្អោនចិត្ត ) ៣ យ៉ាង គប្បីជ្រាបថាជាវិបស្សនាត្រឹមតែម្យ៉ាង ។ កាលបើដូច្នោះរមែងមានសេចក្ដីវិសេសទាំងមុននិងក្រោយ ( ផលសមាបត្តិ ) ។

[ ១២៦ ] ឥឡូវនេះ ព្រះសារីបុត្តបំណាងនឹងសម្ដែងប្រភេទនៃភាពតែមួយនិងភាពផ្សេងគ្នានៃសង្ខារុបេក្ខាដោយអំណាចបុគ្គល ២-៣ ប្រភេទ ទើបពោលបទថា **កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ចិត្តស្ស អភិនីហារោ ឯកត្តំ ហោតិ** បានដល់ជាសភាពដូចគ្នាតែមួយ ។ គប្បីជ្រាបថាជាពាក្យសម្ដែងភាវៈ ប្រើក្នុងអត្ថថាជាខ្លួនឯង ។ លោកពោលថា **ឥទប្បច្ចយតា** ក៏ដូច **ឥទប្បច្ចយា** យ៉ាងណា **ឯកត្តំ** ក៏ដូច **ឯកោ** យ៉ាងនោះ ។

បទថា **អភិនីហារោ** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ អធិប្បាយថា នៃការបង្អោនទៅ ។ គប្បីជ្រាបថា លោកធ្វើវិភត្តិវិបល្លាស ដូចក្នុងបទថា **សោ ទេសោ សម្មជ្ជិតោ** បោសប្រទេសនោះហើយ ។

បទថា **ចិត្តំ កិលិស្សតិ** អធិប្បាយថា ចិត្តសៅហ្មង ក្ដៅក្រហាយ លំបាកដោយកិលេស គឺលោភៈ ពោលគឺការជាប់ចិត្តក្នុងវិបស្សនា ។ បទថា **ភាវនាយ**

**បរិបន្ថោ ហោតិ** បានដល់ កម្ចាត់វិបស្សនាភាវនាដែលបានហើយ ។ បទថា **បដិវេធស្ស អន្តរាយោ ហោតិ** បានដល់ ជាការអន្តរាយដល់ការបានសច្ចៈបដិវេធដែលគួរបានដោយវិបស្សនាភាវនា ។ បទថា **អាយតឹ បដិសន្ធិយា បច្ចយោ ហោតិ** សេចក្ដីថា កាលកម្មនោះឯងឲ្យសុគតិបដិសន្ធិ ព្រោះកម្មដែលសម្បយុត្តដោយសង្ខារុបេក្ខាមានកម្លាំងកិលេស គឺលោភៈ ពោលគឺការត្រេកអរ រមែងជាបច្ច័យដល់សុគតិបដិសន្ធិក្នុងកាមាវចរនាអនាគត ។ ព្រោះកម្មមានកិលេសជាសម្លាញ់ រមែងញ៉ាំងវិបាកឲ្យកើត ហេតុនោះ ទើបកម្មជាជនកបច្ច័យ កិលេសជាឧបត្ថម្ភកបច្ច័យ ។ ម្យ៉ាងទៀត បទថា **ឧត្តរិបដិវេធស្ស** បានដល់ នៃសច្ចបដិវេធដោយអំណាចសកទាគាមិមគ្គជាដើម របស់ព្រះសេក្ខៈ ។ បទថា **អាយតឹ បដិសន្ធិយា បច្ចយោ ហោតិ** គប្បីជ្រាបថា ក្នុងព្រះសេក្ខៈទាំងឡាយសម្រាប់ព្រះសោតាបន្ន និងព្រះសកទាគាមីជាដើម ដែលមិនទាន់សម្រេចឈាន កិលេស គឺការត្រេកអរជាបច្ច័យដល់សុគតិ បដិសន្ធិក្នុងកាមាវចរ ដែលសង្ខារុបេក្ខាកម្មឲ្យផល ចំណែកកិលេស គឺការត្រេកអររបស់ព្រះសោតាបន្ន និងព្រះសកទាគាមីដែលបានឈាន និងរបស់ព្រះអនាគាមី រមែងជាបច្ច័យដោយជាបដិសន្ធិ ក្នុងព្រហ្មលោកនោះឯង កិលេសនេះឯង ជាបច្ច័យដល់បដិសន្ធិដែលគោត្រភូដែលជាអនុលោមឲ្យផល ។

[ ១២៧ ] បទថា **អនិច្ចតោ** បានដល់ ឈ្មោះថា **អនិច្ចតោ** ព្រោះអត្ថថា មានហើយបែរជាមិនមាន ព្រោះមានការមិនទៀងជាទីបំផុត ព្រោះមានខាងដើម និងទីបំផុត ។ បទថា **ទុក្ខតោ** បានដល់ ឈ្មោះថា **ទុក្ខតោ** ព្រោះ

អត្ថថា បៀតបៀនរឿយៗ ព្រោះបៀតបៀនដោយការកើត និងការវិនាស និង ព្រោះជាទីតាំងនៃទុក្ខ ។ បទថា **អនត្តតោ** បានដល់ ឈ្មោះថា **អនត្តតោ** ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ និងព្រោះមិនមានម្ចាស់ មិនមានបុគ្គលអាស្រ័យ មិនមានអ្នកធ្វើ និងមិនមាន អ្នកសោយ ។ ឈ្មោះថា **អនុបស្សនដ្ឋេន** បានដល់ ដោយសភាពនៃការតាម ពិចារណាឃើញ ដោយភាពជារបស់មិនទៀងជាដើម ។

[ ១២៨ ] បទថា **អភិនីហារោ ញាណត្តំ ហោតិ** គប្បីជ្រាបថា ការ បង្អោនចិត្តទៅផ្សេងគ្នា ឬសភាពផ្សេងគ្នានៃការបង្អោនចិត្តទៅ ។ ឈ្មោះថា **កុសលា** ព្រោះអត្ថថា មិនមានរោគ ព្រោះអត្ថថា មិនមានទោស និងព្រោះ អត្ថថា កើតអំពីការឈ្លាស ។ បទថា **អព្យាកតា** បានដល់ ប្រាប់មិនបានថា ជាកុសល ឬអកុសល ។

[ ១២៩ ] បទថា **កិញ្ចិកាលេ សុវិទិតា** បានដល់ ក្នុងកាលបំពេញ វិបស្សនាប្រាកដច្បាស់ ។ បទថា **កិញ្ចិកាលេ ន សុវិទិតា** បានដល់ ក្នុង វេលាត្រេកអរ មិនប្រាកដច្បាស់ ។ បទថា **អច្ចន្តំ សុវិទិតា** បានដល់ ប្រាកដល្អដោយចំណែកមួយ ព្រោះលះការត្រេកអរបានហើយ ។ ក្នុងបទនេះ ថា **វិទិតដ្ឋេន ច អវិទិតដ្ឋេន ច** មានសេចក្ដីថា សភាពដែលសង្ខារុបេក្ខា ប្រាកដល្អ ដល់បុថុជ្ជន និងព្រះសេក្ខៈក្ដី សភាពដែលសង្ខារុបេក្ខា ប្រាកដល្អ ដោយចំណែកមួយ ដល់លោកអ្នកដែលប្រាសចាករាគៈក្ដី ជាសភាពប្រាកដ ទាំងអស់ សភាពដែលសង្ខារុបេក្ខាប្រាកដមិនល្អ ដល់បុថុជ្ជន និងព្រះសេក្ខៈ

ទាំង ២ ក៏ជាសភាពមិនប្រាកដទាំងអស់ ។

[ ១៣០ ] បទថា **អតិត្ថត្តា** បានដល់ ព្រោះនៅមិនទាន់សម្រេចកិច្ចដែលគួរធ្វើនៃវិបស្សនា គឺនៅមិនទាន់ប្រណីត ។ ឈ្មោះថា **តិត្ថត្តា** ព្រោះផ្ទុយជាមួយបទថា **អតិត្ថត្តា** នោះ ។

[ ១៣១ ] បទថា **តិណ្ណំ សញ្ញោជនានំ បហានាយ** បានដល់ ដើម្បីលះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ។ ព្រះពោធិសត្វ សូម្បីមានភពចុងក្រោយ ក៏សង្គ្រោះចូលក្នុងបទនេះដូចគ្នា ។ តែព្រះពោធិសត្វដែលមិនមានភពចុងក្រោយ ញុំាងវិបស្សនាឲ្យដល់សង្ខារុបេក្ខាហើយផ្អាកនៅ ។ បទថា **សោតាបត្តិមគ្គំ បដិលាភត្ថាយ** អាចារ្យទាំងឡាយមិនពោលសមាស តែបើពោលសមាសល្អជាង ។ បទថា **សេក្ខោ តិណ្ណំ សញ្ញោជនានំ បហីនត្តា** លោកពោលដោយភាពស្មើគ្នានៃព្រះសោតាបន្នៈ ព្រះសកទាគាមី និងព្រះអនាគាមី ។ ពិតហើយ សំយោជនៈទាំងនោះ សូម្បីព្រះសកទាគាមី និងព្រះអនាគាមីក៏លះបានហើយ ។ បទថា **ឧត្តរិបដិលាភត្ថាយ** បានដល់ ដើម្បីបាននូវមគ្គជាន់លើ ។ បទថា **ទិដ្ឋធម្មសុខវិហារត្ថាយ** បានដល់ ដើម្បីការនៅជាសុខក្នុងបច្ចុប្បន្ននោះឯង គឺក្នុងអត្តភាពដែលប្រចក្ស ។

[ ១៣២ ] បទថា **វិហារសមាបត្តដ្ឋេន** បានដល់ ដោយសភាពនៃផលសមាបត្តិ របស់ព្រះសេក្ខៈ ឬដោយសភាពនៃផលសមាបត្តិ ដែលជាគ្រឿងនៅ ដែលឃើញច្បាស់របស់លោកអ្នកប្រាសចាករាគៈ ។

[ ១៣៣ ] ឥឡូវនេះ ព្រះសារីបុត្ត កាលនឹងសម្ដែងការកំណត់ដោយចំនួននៃសង្ខារុបេក្ខា ទើបពោលបទថា **កតិ សង្ខារុបេក្ខា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សមថវសេន** បានដល់ ដោយអំណាចសមាធិ ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **នីវរណេ បដិសង្ខា** បានដល់ កំណត់នីវរណៈ ៥ ដោយការៈដែលគួរលះ ។ បទថា **សន្តិដ្ឋនា** បានដល់ ការតាំងមាំ ព្រោះបំណងលះនីវរណៈទាំងឡាយ ព្រោះព្រងើយដោយចូលដល់ការមិនខ្វល់ខ្វាយក្នុងការលះនីវរណៈទាំងនោះ ។ បទថា **សង្ខារុបេក្ខាសុ** បានដល់ ការសម្ងឹងសង្ខារទាំងឡាយ ពោលគឺនីវរណៈ ដោយការមិនធ្វើការខ្វល់ខ្វាយក្នុងការលះនីវរណៈ ។ ក្នុងវិតក្កវិចារជាដើម និងក្នុងឧប្បាទជាដើម ក៏មានន័យនេះ ។ ក្នុងសមថៈ ញាណសម្រេចដោយការនៅដែលមានកម្លាំង ក្នុងចំណែកខាងដើម ដែលជិតអប្បនាវីថិ ឈ្មោះថា **សង្ខារុបេក្ខា** ។

[ ១៣៤ ] ក្នុងវារៈនៃមគ្គ ៤ មានបទថា **សោតាបត្តិមគ្គំ បដិលាភត្ថាយ** ជាដើម រមែងបានមគ្គឯណានីមួយនៃសុញ្ញតមគ្គ អនិមិត្តមគ្គ និងអប្បណិហិតមគ្គ ។ ក្នុងវារៈនៃផល ៤ មានបទថា **សោតាបត្តិផលសមាបត្តត្ថាយ** ជាដើម គប្បីជ្រាបផលសមាបត្តិថាជាអប្បណិហិត ។ ព្រោះហេតុអ្វី ព្រោះលោកពោលដល់ផលសមាបត្តិ ២ យ៉ាងក្រៅអំពីនេះ គឺ **សុញ្ញតវិហារសមាបត្តត្ថាយ ១ អនិមិត្តវិហារសមាបត្តត្ថាយ ១** ដោយឡែក ។ ដោយន័យព្រះសូត្រនោះឯង គប្បីជ្រាបអនិមិត្តមគ្គ ដោយអំណាចការចេញចាកអនិច្ចានុបស្សនា គប្បីជ្រាបអនិមិត្តផលសមាបត្តិក្នុងកាលនៃផលសមាបត្តិ

ដូចយ៉ាងនោះឯង គប្បីជ្រាបអប្បណិហិតមគ្គ និងអប្បណិហិតផលសមាបត្តិ ដោយអំណាចការចេញដោយទុក្ខានុបស្សនា គប្បីជ្រាបសុញ្ញតមគ្គ និងសុញ្ញតផលសមាបត្តិ ដោយអំណាចការចេញដោយអនត្តានុបស្សនា ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនេះ ក្នុងវារៈនៃមគ្គ ៤ លោកពោលដល់ពាក្យដែលជាមូលហេតុ ៥ មានពាក្យថា **ឧប្បាទំ** ជាដើម និងពាក្យនៃវេវចនៈ ១០ មានពាក្យថា **គតឹ** ជាដើម រួមជា ១៥ ពាក្យ ។ ចំណែកវារៈក្នុងផលសមាបត្តិ ៦ លោកពោលបទដែលជាមូលហេតុ ៥ ប៉ុណ្ណោះ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី ទើបលោកពោលយ៉ាងនោះ ។ ឆ្លើយថា កាលសង្ខារុបេក្ខាមានសភាពចាស់ក្លា ដើម្បីសម្តែងដល់សេចក្តីចាស់ក្លានៃសង្ខារុបេក្ខានោះ ព្រោះមានមគ្គដែលមានអំណាចក្នុងការលះកិលេស ទើបលោកពោលបទដែលជាមូលហេតុ ធ្វើឲ្យមាំជាមួយបទដែលជាវេវចនៈ ។ ដើម្បីសម្តែងថា សង្ខារុបេក្ខាសូម្បីទន់ខ្សោយក៏ជាបច្ច័យដល់ផល ព្រោះផលមានសភាពស្ងប់ដោយការអស់ភាពឧស្សាហ៍ និងព្រោះផលទាក់ទងមកអំពីមគ្គ គប្បីជ្រាបថា លោកពោលដល់បទដែលជាមូលហេតុប៉ុណ្ណោះ ។

[ ១៣៥ ] ឥឡូវនេះ ព្រះសារីបុត្តដើម្បីសួរដោយអំណាចជាតិ ហើយឆ្លើយដោយអំណាចតាមដែលរកបាន ទើបពោលពាក្យថា **កតិ សង្ខារុបេក្ខា កុសលា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **បណ្ណរស សង្ខារុបេក្ខា** បានដល់ មាន ៨ ដោយអំណាចសមថៈ និងមាន ៧ ដោយអំណាចមគ្គ ៤ ផល ៣ រួមជា ១៥ ។ គប្បីជ្រាបថា លោកមិនពោលភាពដែលសង្ខារុបេក្ខាទាំង

នោះជាអព្យាក្រឹត ព្រោះអធិប្បាយថា សង្ខារុបេក្ខា ៨ ដោយអំណាចសមថៈ មិនសមដល់ឈ្មោះថា **សង្ខារុបេក្ខា** ព្រោះព្រះអរហន្តមិនមានការពិចារណានីវរណៈ និងព្រោះវៀរសេចក្តីខ្វល់ខ្វាយក្នុងការលះ ក៏លះវិតក្កវិចារជាដើម បានដោយងាយ ។ ម្យ៉ាងទៀត ព្រះអរហន្តដែលចូលផលសមាបត្តិ វៀរសង្ខារុបេក្ខាហើយ មិនអាចចូលសមាបត្តិបាន ព្រោះហេតុនោះ ទើបលោកពោលថា សង្ខារុបេក្ខា ៣ ជាអព្យាកតៈ ។ ពិតហើយ ឈ្មោះថា សង្ខារុបេក្ខា ៣ របស់ព្រះអរហន្ត រមែងមានដោយអំណាចអប្បណិហិត សុញ្ញត និងអនិមិត្ត ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយ ៣ ដែលលោកពោលដោយអំណាចការពណ៌នាដល់សង្ខារុបេក្ខាដូចតទៅ

បទថា **បដិសង្ខាសន្តិដ្ឋនា បញ្ញា** បានដល់ សង្ខារុបេក្ខា ។ បទថា **អដ្ឋ ចិត្តស្ស គោចរា** សេចក្តីថា សង្ខារុបេក្ខា ៨ ដែលលោកពោលដោយអំណាចសមថៈជាអារម្មណ៍ គឺជាភូមិរបស់សមាធិ ។ លោកអធិប្បាយដល់សមាធិ ដោយមាតិកាថា ចិត្ត ដូចក្នុងប្រយោគជាដើមថា **ចិត្តំ បញ្ញញ្ច ភាវយំ** ចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា លោកសម្តែងអារម្មណ៍ **គោចរ** សព្ទ ដូចក្នុងប្រយោគជាដើមថា **គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិសយេ** ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយត្រាច់ទៅក្នុងទីជាទីគោចរជាដែននៃបិតារបស់ខ្លួនចុះ ។ វត្ថុណាទាក់ទងដោយវត្ថុណា វត្ថុនោះ ហៅថា អារម្មណ៍របស់វត្ថុនោះ ។ បទថា **បុថុជ្ជនស្ស ទ្វេ** បានដល់ ដោយអំណាចនៃសមថៈ និងវិបស្សនា ។ បទថា **តយោ សេក្ខស្ស** បានដល់ ដោយអំណាចនៃសមថៈ

វិបស្សនា និងសមាបត្តិ ។

បទថា **តយោ ច វិតរាគស្ស** បានដល់ ដោយអំណាចនៃផលសមាបត្តិ ដែលជាអប្បណិហិត សុញ្ញត និងអនិមិត្ត ។ កាលគួរពោលថា **តិស្សោ** តែធ្វើជាលិង្គវិបល្លាសថា **តយោ**។ ឬគប្បីប្រកបថា **តយោ សង្ខារុបេក្ខា ធម្មា** ធម៌ គឺសង្ខារុបេក្ខា ៣ យ៉ាង ។

បទថា **យេហិ ចិត្តំ វិវដ្ដតិ** សេចក្ដីថា ចិត្តចេញចាកវិតក្កវិចារជាដើម ឬចិត្តចេញចាកការកើតឡើងជាដើមដោយធម៌ គឺសង្ខារុបេក្ខាពួកណា លោកអធិប្បាយថា ព្រោះសូម្បីបុគ្គលប្រាសចាករាគៈ ក៏នៅមានសង្ខារុបេក្ខា ចិត្តចេញចាកសង្ខារហើយ រមែងស្ទុះទៅកាន់ព្រះនិព្វាន ។

បទថា **អដ្ឋ សមាធិស្ស បច្ចយា** បានដល់ បច្ច័យ ៨ ដែលលោកពោលដោយអំណាចសមថៈ ជាបច្ច័យដល់អប្បនាសមាធិ ព្រោះឲ្យដល់អប្បនា ។ បទថា **ទស ញាណស្ស គោចរា** បានដល់ ជាភូមិ ១០ នៃមគ្គញ្ញាណ និងផលញ្ញាណ លោកពោលដោយអំណាចនៃវិបស្សនា ។ បទថា **តិណ្ណំ វិមោក្ខាន បច្ចយា** បានដល់ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យដល់សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ។ បទថា **នានាទិដ្ឋីសុ ន កម្បតិ** បានដល់ រមែងមិនញាប់ញ័រក្នុងទិដ្ឋិមានប្រការផ្សេងៗ មានសស្សតទិដ្ឋិជាដើម ដោយមិនលះបង់ការបែកធ្លាយ ហើយពិចារណាឃើញសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម ។០៚

**អដ្ឋកថាសង្ខារុបេក្ខាញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៣៦ ] បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថា គោត្រភូញាណ តើដូចម្តេច ។ ញាណគ្របសង្កត់នូវការកើតឡើង ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវនិមិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការប្រមូលមក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវបដិសន្ធិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវគតិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការវិលកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការប្រព្រឹត្តនៃវិបាក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវជាតិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវជរា ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវព្យាធិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវមរណៈ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវសោក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការខ្សឹកខ្សួល ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណស្ទុះទៅកាន់ការមិនផ្តើមកើតឡើង ហេតុនោះ ឈ្មោះថា គោត្រភូ ។បេ។ ញាណស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការកើតឡើង ហើយស្ទុះទៅកាន់ការមិនកើតឡើង ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវការប្រព្រឹត្ត ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្ត

ហេតុនោះ ឈ្មោះថា គោត្រភូ ញាណគ្របសង្កត់នូវនិមិត្ត ហើយស្ទុះទៅកាន់អនិមិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ។បេ។ ញាណគ្របសង្កត់នូវសង្ខារនិមិត្តខាងក្រៅ ហើយស្ទុះទៅកាន់និព្វាន ជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថា គោត្រភូ ។

[ ១៣៧ ] ញាណចេញចាកការកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកនិមិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រមូលមក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកបដិសន្ធិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកគតិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការវិលកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រព្រឹត្តនៃវិបាក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកជាតិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកជរា ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកព្យាធិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកមរណៈ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកសោក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការខ្សឹកខ្សួល ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណស្ទុះទៅកាន់ការមិនកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណស្ទុះទៅកាន់ ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ។បេ។ ញាណស្ទុះទៅកាន់និព្វាន ជាគ្រឿងរលត់

*ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការកើត ហើយស្ទុះទៅកាន់ការ មិនកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រព្រឹត្ត ហើយ ស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាក និមិត្ត ហើយស្ទុះទៅកាន់អនិមិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញ ចាកការប្រមូលមក ហើយស្ទុះទៅកាន់ការមិនប្រមូលមក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកបដិសន្ធិ ហើយស្ទុះទៅកាន់ការមិនបដិសន្ធិ ហេតុ នោះ ឈ្មោះថា គោត្រភូ ញាណចេញចាកគតិ ហើយស្ទុះទៅកាន់អគតិ ហេតុ នោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការវិលកើត ហើយស្ទុះទៅកាន់ការ មិនវិលកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រព្រឹត្តនៃ វិបាក ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្តនៃវិបាក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកជាតិ ហើយស្ទុះទៅកាន់ការមិនមានជាតិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកជរា ហើយស្ទុះទៅកាន់ការមិនមានជរា ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកព្យាធិ ហើយស្ទុះទៅកាន់ការមិនមានព្យាធិ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកមរណៈ ហើយស្ទុះទៅកាន់អមតៈ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកសោក ហើយស្ទុះទៅកាន់ការ មិនមានសោក ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកសេចក្តីខ្សឹក ខ្សួល ហើយស្ទុះទៅកាន់ការមិនមានសេចក្តីខ្សឹកខ្សួល ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកសេចក្តីចង្អៀតចង្អល់ចិត្ត ហើយស្ទុះទៅកាន់ការមិន មានសេចក្តីចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាក*

សង្ខារនិមិត្តខាងក្រៅ ហើយស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណត្រឡប់ចាកការកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណត្រឡប់ចាកការប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ។បេ។ ញាណត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណស្ទុះទៅកាន់ការមិនកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ។បេ។ ញាណស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថា គោត្រភូ ញាណត្រឡប់ចាកការកើត ហើយស្ទុះទៅកាន់ការមិនកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណត្រឡប់ចាកការប្រព្រឹត្ត ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ។បេ។ ញាណត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ហើយស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថា គោត្រភូ ។

[ ១៣៨ ] គោត្រភូធម៌ប៉ុន្មាន កើតឡើងដោយអំណាចសមថៈ គោត្រភូធម៌ប៉ុន្មាន កើតឡើងដោយអំណាចវិបស្សនា ។ គោត្រភូធម៌ ៨ កើតឡើងដោយអំណាចសមថៈ គោត្រភូធម៌ ១០ កើតឡើងដោយអំណាចវិបស្សនា ។

[ ១៣៩ ] គោត្រភូធម៌ ៨ ដូចម្តេចខ្លះ កើតឡើងដោយអំណាចសមថៈ ។ ធម៌គ្របសង្កត់នូវនីវរណៈ ដើម្បីប្រយោជន៍ដល់ការបាននូវបឋមជ្ឈាន ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវវិតក្ក និងវិចារ ដើម្បីប្រយោជន៍ដល់ការបាននូវទុតិយជ្ឈាន ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវបីតិ ដើម្បីប្រយោជន៍ដល់ការបាននូវតតិយជ្ឈាន ហេតុនោះ ឈ្មោះថា

គោត្រភូ ១ ធម៌គ្របសង្កត់នូវសុខ និងទុក្ខ ដើម្បីប្រយោជន៍ដល់ការបាននូវចតុត្ថជ្ឈាន ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវអាកាសានញ្ចាយតនសមាបត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវអាកាសានញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវវិញ្ញាណញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវអាកិញ្ចញ្ញាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ១ នេះគោត្រភូធម៌ ៨ យ៉ាង កើតឡើងដោយអំណាចសមថៈ ។

[ ១៤០ ] គោត្រភូធម៌ ១០ ដូចម្តេចខ្លះ កើតឡើងដោយអំណាចវិបស្សនា ។ ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្តិ និមិត្ត ការប្រមូលមកបដិសន្ធិ គតិ ការវិលកើត ការប្រព្រឹត្តិនៃវិបាក ជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវៈ ឧបាយាសៈ និងសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការបាននូវសោតាបត្តិមគ្គ ហេតុនោះ ឈ្មោះថា គោត្រភូ ១ ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្តិ និមិត្ត ការប្រមូលមក បដិសន្ធិ ដើម្បីប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ១ ដើម្បីប្រយោជន៍ដល់ការបាននូវសកទាគាមិមគ្គ ។បេ។ ១ ដើម្បីប្រយោជន៍ដល់សកទាគាមិផលសមាបត្តិ ។បេ។ ១ ដើម្បីប្រយោជន៍ដល់ការបាននូវអនាគាមិមគ្គ ១

ដើម្បីប្រយោជន៍ដល់អនាគាមិផលសមាបត្តិ ១ ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្តិ និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលកើត ការប្រព្រឹត្តិនៃវិបាក ជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវៈ ឧបាយាសៈ និងសង្ខារ-និមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការបាននូវអរហត្តមគ្គ ហេតុនោះ ឈ្មោះថា គោត្រភូ ១ ដើម្បីប្រយោជន៍ដល់អរហត្តផលសមាបត្តិ ។បេ។ ១ ដើម្បីប្រយោជន៍ដល់ សុញ្ញតវិហារសមាបត្តិ ។បេ។ ១ ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្តិ និមិត្ត ការប្រមូលមក បដិសន្ធិ ដើម្បីប្រយោជន៍ដល់អនិមិត្ត-វិហារសមាបត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ១ នេះគោត្រភូធម៌ ១០ កើតឡើងដោយអំណាចវិបស្សនា ។

[ ១៤១ ] គោត្រភូធម៌ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ គោត្រភូធម៌ជាកុសល ១៥ គោត្រភូធម៌ជាអព្យាក្រឹត ៣ ឯគោត្រ-ភូធម៌ជាអកុសលមិនមានទេ ។

[ ១៤២ ] គោត្រភូញាណ ៨ គឺគោត្រភូញាណប្រកបដោយអាមិសៈ ១ មិនមានអាមិសៈ ១ មានទីតាំង ( នៃសេចក្តីត្រេកអរ ) ១ មិនមានទីតាំង ១ ប្រកប ( ដោយសេចក្តីត្រេកអរ ) ១ មិនប្រកប ១ ចេញហើយ ( ចាកសេចក្តីត្រេក-អរ ) ១ មិនទាន់ចេញហើយ ១ គោត្រភូធម៌ ៨ ជាបច្ច័យនៃសមាធិ គោត្រភូធម៌ ១០ ជាគោចរនៃញាណ គោត្រភូធម៌ ១៨ ជាបច្ច័យនៃវិមោក្ខ ៣ អាការទាំង ១៨ នេះ ព្រះយោគី

នោះ សន្សំហើយដោយប្រាជ្ញា ព្រះយោគីអ្នកឈ្លាសវៃ រមែងមិនញាប់ញ័រ ក្នុងការប្រាសចាកវដ្តៈ ក្នុងការចេញ ( ចាកអកុសល ) និងក្នុងទិដ្ឋិផ្សេងៗ ឡើយ ។

ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថា គោត្រភូញាណ ។

## អដ្ឋកថា
## គោត្រភូញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងគោត្រភូញាណនិទ្ទេសដូចតទៅនេះ

[ ១៣៦-១៤០ ] បទថា **អភិភុយ្យតិ** បានដល់ រមែងគ្របសង្កត់ រមែងឈានកន្លង ។ បទថា **ពហិទ្ធា សង្ខារនិមិត្តំ** បានដល់ សង្ខារនិមិត្ត ដែលជាខាងក្រៅចាកកុសលក្ខន្ធដែលប្រព្រឹត្តទៅហើយក្នុងសន្តានរបស់ខ្លួន ។ ពិតហើយ សង្ខារដែលជាលោកិយ លោកពោលថា ជានិមិត្ត ព្រោះជាគ្រឿងសម្គាល់នៃកិលេសទាំងឡាយ ឬព្រោះប្រាកដដោយអាការជាគ្រឿងសម្គាល់ ។ បទថា **អភិភុយ្យតីតិ គោត្រភូ** លោកពោលដល់ភាពជាគោត្រភូ ព្រោះគ្របសង្កត់គោត្ររបស់បុថុជ្ជន ។ បទថា **បក្ខន្ទតីតិ គោត្រភូ** លោកពោលដល់ភាពជាគោត្រភូ ព្រោះធ្វើគោត្រព្រះអរិយៈ ឲ្យចម្រើន ។ បទថា **អភិភុយ្យិត្វា បក្ខន្ទតីតិ គោត្រភូ** លោកពោលសង្ខេបសេចក្តីទាំងពីរ ។

ក្នុងមាតិកាថា **វុដ្ឋាតីតិ គោត្រភូ** និង **វិវដ្ដតីតិ គោត្រភូ** លោកពោលដល់អត្ថថា គ្របសង្កត់បុថុជ្ជនគោត្តដោយសមគួរដល់បទថា **វុដ្ឋាន** គឺចេញចាក **វិវដ្ដន** គឺត្រឡប់ចាក ។ គប្បីជ្រាបអត្ថថា ឈ្មោះថា **គោត្រភូ** ព្រោះគ្របសង្កត់គោត្ត មាននីវរណៈជាដើម នៃគោត្រភូដូចពោលហើយដោយអំណាចសមថៈ ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់គោត្ត មានការកើតឡើងជាដើមក្នុងវារៈនៃសមាបត្តិ ៦ មាន **សោតាបត្តិផលសមាបត្តត្ថាយ** ជាដើម ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់គោត្ត មានសោតាបន្នជាដើម ក្នុងវារៈ

នៃមគ្គ ៣ មាន **សកទាគាមិមគ្គំ បដិលាភត្ថាយ** ជាដើម ។

ម្យ៉ាងទៀត ក្នុងបទថា **គោត្រភូ** នេះ មានអត្ថថា គោត្ត និងមានអត្ថថា ពូជ ។ បានឮថា ក្នុងវត្តនិបករណ៍ លោកពោលថា និព្វាន ហៅថា គោត្ត ព្រោះការពារនូវអន្តរាយទាំងពួង ឈ្មោះថា គោត្រភូ ព្រោះប្រព្រឹត្តទៅកាន់និព្វាននោះ និងពោលថា សមាបត្តិ ៨ ក៏ឈ្មោះថា គោត្ត ព្រោះការពារនូវអន្តរាយដល់គោត្រភូ ។ ឈ្មោះថា គោត្រភូ ព្រោះប្រព្រឹត្តទៅកាន់គោត្ត ។ អាចារ្យទាំងឡាយពោលថា គោត្រភូនៃមគ្គ ៤ នោះឯងមាននិព្វានជាអារម្មណ៍ គោត្រភូនៃផលសមាបត្តិ ៤ មានសង្ខារជាអារម្មណ៍ ព្រោះបង្អោនទៅក្នុងផលសមាបត្តិ ។ ដូចលោកពោលទៅក្នុងវិសុទ្ធិមគ្គថា ចិត្តរបស់ព្រះយោគាវចរ អ្នកបានឃើញច្បាស់តាមលំដាប់ដែលប្រព្រឹត្តទៅហើយនោះ រមែងចុះស៊ប់ក្នុងនិរោធ ដោយអំណាចនៃផលសមាបត្តិ ក្នុងរវាងគោត្រភូញាណដែលមានសង្ខារជាអារម្មណ៍ ដោយហេតុនោះឯង ក្នុងនិទ្ទេសនេះ គប្បីជ្រាបថា លោកមិនធ្វើពាក្យថា សង្ខារនិមិត្តខាងក្រៅ ដែលធ្វើជាលំដាប់ទី ១៦ ក្នុងវារៈនៃមគ្គក្នុងលំដាប់ទី ៦ ក្នុងវារៈនៃសមាបត្តិ ។ ពិតហើយ កាលពោលដោយប្រការក្រៅអំពីនេះ គប្បីកាន់យកពាក្យដែលជាមូលហេតុ ។

[ ១៤១ ] អាចារ្យពួកដទៃពោលថា ការចងចិត្តគ្រាដំបូង គឺការប្រមូលមកគ្រាដំបូងក្នុងនិព្វាន ហៅថា គោត្រភូ ។ ពាក្យនោះ សំដៅដល់ផលហើយ រមែងមិនត្រឹមត្រូវ ។

ក្នុងបទនេះថា **បណ្ណរស គោត្រភូធម្មា កុសលា** គប្បីជ្រាបថា លោក

មិនពោលគោត្រភូធម៌ ( ដែលជាកុសល ១៥ ) ថា ជាអព្យាកតៈ ព្រោះអធិប្បាយថា គោត្រភូធម៌រមែងមិនសមគួរនឹងឈ្មោះថា គោត្រភូ ដោយអត្ថថា គ្របសង្កត់ ព្រោះព្រះអរហន្តមិនមានទីវរណៈដែលគួរគ្របសង្កត់ និងព្រោះលោកលះវិតក្កវិចារជាដើមបានឆាយ ។ ម្យ៉ាងទៀត ព្រះអរហន្ត កាលនឹងចូលផលសមាបត្តិ មិនគ្របសង្កត់សង្ខារទាំងឡាយហើយ មិនអាចចូលសមាបត្តិបាន ព្រោះហេតុនោះ ទើបលោកពោលថា គោត្រភូធម៌ជាអព្យាក្រឹត ៣ ។ តែអាចារ្យពួកខ្លះពោលថា សមាបត្តិ ៨ ប្រព្រឹត្តទៅក្នុងចំណែកនៃការចាក់ធ្លុះនោះឯង ក្នុងទីនេះ ដោយអំណាចអរិយមគ្គដែលលោកសម្តែងហើយ ព្រោះហេតុនោះ ទើបគោត្រភូនៃសមាបត្តិ ៨ ជាកុសល ។ ម្យ៉ាងទៀត ក្នុងសង្ខារុបេក្ខា ក៏គប្បីជ្រាបយ៉ាងនោះ ។

[ ១៤២ ] គប្បីជ្រាបអធិប្បាយក្នុងគាថាជាដើមថា **សាមិសញ្ច** ដូចតទៅនេះ បណ្តា **វដ្តាមិស លោកាមិស កិលេសាមិស** គោត្រភូញាណមានអាមិសៈដោយកិលេសាមិសៈ ព្រោះនៅមានសេចក្តីប្រាថ្នា ។ នោះគឺអ្វី គឺសមថគោត្រភូញាណ ៨ យ៉ាង ។ ក្នុងពាក្យថា វដ្តាមិសៈ លោកាមិសៈ និងកិលេសាមិសៈនេះ ពាក្យថា **វដ្តាមិស** បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះឯង ពាក្យថា **លោកាមិស** បានដល់ កាមគុណ ៥ ពាក្យថា **កិលេសាមិស** បានដល់ កិលេសទាំងឡាយនោះឯង ។ បទថា **និរាមិសំ** បានដល់ វិបស្សនាគោត្រភូញាណ ១០ យ៉ាង ព្រោះមិនមានសេចក្តីប្រាថ្នា ។ ពិតហើយ ព្រះអរិយៈទាំងឡាយ មិនធ្វើសេចក្តីប្រាថ្នាក្នុងគោត្រភូ ។

អាចារ្យទាំងឡាយរេចនាក្នុងគម្ពីរថា **សាមិសញ្ច** នោះ មិនល្អឡើយ ។

គប្បីជ្រាបគោត្រភូញាណមានទីតាំង និងមិនមានទីតាំង មានគ្រឿងប្រកប និងមិនមានគ្រឿងប្រកប មានការចេញ និងមិនមានការចេញ យ៉ាងនេះឯង ។ ឈ្មោះថា **បណិហិតំ** អធិប្បាយថា ដែលគួរប្រាថ្នា ព្រោះជាទីតាំងនៃការជាប់ចិត្ត ។ ឈ្មោះថា **អប្បណិហិតំ** ព្រោះមិនមានទីតាំងនៃការជាប់ចិត្តនោះ ។ ឈ្មោះថា **សញ្ញុត្តំ** ព្រោះប្រកបដោយការជាប់ចិត្តនោះឯង ។ ឈ្មោះថា **វិសញ្ញុត្តំ** ព្រោះមិនមានការប្រកបដោយការជាប់ចិត្តនោះ ។

បទថា **វុដ្ឋិតំ** បានដល់ គោត្រភូញាណ ដែលជាវិបស្សនានោះឯង ។ ពិតហើយ គោត្រភូញាណនោះ ឈ្មោះថា **វុដ្ឋិតំ** ព្រោះកាត់នូវការជាប់ចិត្ត ។ ក្រៅអំពីនេះ ឈ្មោះថា **អវុដ្ឋិតំ** ។ ម្យ៉ាងទៀត ឈ្មោះថា **វុដ្ឋិតំ** ព្រោះចេញទៅខាងក្រៅ ។ គប្បីជ្រាបថា សូម្បីផលគោត្រភូ ក៏ឈ្មោះថា មានការចេញអំពីសង្ខារនិមិត្តខាងក្រៅ ព្រោះបែរមុខកាន់និព្វានដោយអំណាចមានអធ្យាស្រ័យក្នុងនិព្វាន ។ ក្នុងវារៈ **អភិកុយ្យតិ វុដ្ឋាតិ** និង **វិវដ្តតិ** ផលគោត្រភូក៏គប្បីជ្រាបថា គ្របសង្កត់ ចេញចាក ត្រឡប់ចាក ព្រោះផ្ដោះមុខទៅកាន់និព្វានដោយអំណាចជាអធ្យាស្រ័យ ។

បទថា **តិណ្ណំ វិមោក្ខានំ បច្ចយោ** បានដល់ សមថគោត្រភូជាបកតូ-បនិស្សយប្បច្ច័យដល់លោកុត្តរវិមោក្ខ ៣ វិបស្សនាគោត្រភូ ជាអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ បទថា **បញ្ញា យស្ស បរិចិតា** បានដល់ ព្រះយោគាវចរណាអប់រំហើយ គឺសន្សំហើយនូវបញ្ញា ដែលជា

ចំណែកខាងដើម ។ បទថា **កុសលោ វិវដ្ដេ វុដ្ឋានេ** បានដល់ ជាអ្នកឈ្លាស ជាអ្នកមុតស្រួចក្នុងគោត្រភូញាណ ពោលគឺវិវដ្ដៈដោយការមិនវង្វេងនោះឯង ឬជាអ្នកឈ្លាសដោយញាណដែលជាចំណែកខាងដើម ។ បទថា **នានាទិដ្ឋីសុ ន កម្បតិ** បានដល់ មិនញាប់ញ័រក្នុងទិដ្ឋិមានប្រការផ្សេងៗ ដែលលះបាន ហើយ ដោយសមុច្ឆេទប្បហាន ។៚

## អដ្ឋកថា គោត្រភូញាណនិទ្ទេស ចប់

# ក្បាលទី ៥៦

# សុត្តន្តបិដក ចាលីប្រែ ~ ៦៩

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

## បឋមភាគ

### សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| សុត្តន្តបិដក មាតិកា .......... .......... .......... .......... .... | ២ |
| អដ្ឋកថាគន្ថារម្ភកថា .......... .......... .......... .......... ..... | ៦ |
| អដ្ឋកថាឧទ្ទេសនៃញាណ ៧៣ មានសុតមយញ្ញាណជាខាងដើម និងមានអនាវរណញ្ញាណជាទីបំផុត .......... .......... .......... .......... ..... | ២៧ |
| អត្ថរបស់ សោត សព្ទ .......... .......... .......... .......... ..... | ២៧ |
| អត្ថរបស់ សុត សព្ទ .......... .......... .......... .......... ..... | ៣០ |
| អត្ថរបស់ ធម្ម សព្ទ .......... .......... .......... .......... ..... | ៤១ |
| អត្ថរបស់ ភូមិ សព្ទ .......... .......... .......... .......... ..... | ៨៤ |
| អត្ថរបស់ អារម្ភ សព្ទ .......... .......... .......... .......... .... | ១១៧ |


### មហាវគ្គ ញាណកថា


| | |
|---|---|
| សុត្តន្តបិដក ញាណកថា .......... .......... .......... .......... .... | ១៦២ |
| អដ្ឋកថាសុតមយញ្ញាណនិទ្ទេស .......... .......... .......... .......... .... | ១៦៤ |
| អត្ថរបស់ សច្ច សព្ទ .......... .......... .......... .......... .... | ១៧២ |

សុត្តន្តបិដក .......... .......... .......... .......... .... ១៧៣

អដ្ឋកថាអភិញ្ញេយ្យនិទ្ទេស .......... .......... .......... .......... .... ១៩២

សុត្តន្តបិដក .......... .......... .......... .......... .... ២៦១

អដ្ឋកថាអភិញ្ញេយ្យនិទ្ទេស (ត) .......... .......... .......... .......... .... ២៧៤

សុត្តន្តបិដក .......... .......... .......... .......... ..... ៣០៩

អដ្ឋកថាបរិញ្ញេយ្យនិទ្ទេស .......... .......... .......... .......... ....... ៣១៦

សុត្តន្តបិដក .......... .......... .......... .......... ..... ៣៣០

អដ្ឋកថាបហាតព្វនិទ្ទេស .......... .......... .......... .......... ..... ៣៣៣

សុត្តន្តបិដក .......... .......... .......... .......... ..... ៣៤៩

អដ្ឋកថាភាវេតព្វនិទ្ទេស .......... .......... .......... .......... .... ៣៦៤

អត្ថរបស់ សហគត សព្ទ .......... .......... .......... .......... .... ៣៦៤

អត្ថរបស់ កុសល សព្ទ .......... .......... .......... .......... .... ៣៧៥

សុត្តន្តបិដក .......... .......... .......... .......... .... ៣៨៩

អដ្ឋកថាសច្ឆិកាតព្វនិទ្ទេស .......... .......... .......... .......... ...... ៣៩៤

អដ្ឋកថាហានភាគិយចតុក្កនិទ្ទេស .......... .......... .......... .......... ..... ៤០៤

សុត្តន្តបិដក .......... .......... .......... .......... ..... ៤០៨

អដ្ឋកថាលក្ខណត្តិកនិទ្ទេស .......... .......... .......... .......... ....... ៤០៩

សុត្តន្តបិដក .......... .......... .......... .......... ..... ៤១១

អដ្ឋកថាទុក្ខសច្ចនិទ្ទេស .......... .......... .......... .......... ....... ៤១៦

សុត្តន្តបិដក .......... .......... .......... .......... ..... ៤៤៦

អដ្ឋកថាសមុទយសច្ចនិទ្ទេស .......... .......... .......... .......... ..... ៤៤៨

| | | |
|---|---|---|
| សុត្តន្តបិដក | .......... .......... .......... .......... ...... | ៤៥១ |
| អដ្ឋកថានិរោធសច្ចនិទ្ទេស | .......... .......... .......... .......... ........ | ៤៥២ |
| សុត្តន្តបិដក | .......... .......... .......... .......... ...... | ៤៥៧ |
| អដ្ឋកថាមគ្គសច្ចនិទ្ទេស | .......... .......... .......... .......... ....... | ៤៦០ |
| អដ្ឋកថាសច្ចបកិណ្ណកៈ | .......... .......... .......... .......... .. | ៥៣០ |
| សុត្តន្តបិដក | .......... .......... .......... .......... ... | ៥៣៩ |
| អដ្ឋកថាសីលមយញ្ញាណនិទ្ទេស | .......... .......... .......... .......... ...... | ៥៥១ |
| ព្រះតថាគត ៨ យ៉ាង | .......... .......... .......... .......... ......... | ៥៥៩ |
| អត្ថរបស់ បរិក្ខារ សព្ទ | .......... .......... .......... .......... ......... | ៦០៣ |
| សុត្តន្តបិដក | .......... .......... .......... ........ | ៦០៨ |
| អដ្ឋកថាសមាធិភាវនាមយញ្ញាណនិទ្ទេស | .......... .......... .......... ... | ៦១២ |
| សុត្តន្តបិដក | .......... .......... .......... ....... | ៦៣០ |
| អដ្ឋកថាធម្មដ្ឋិតិញ្ញាណនិទ្ទេស | .......... .......... .......... ....... | ៦៣៦ |
| សុត្តន្តបិដក | .......... .......... .......... ........ | ៦៤៩ |
| អដ្ឋកថាសម្មសនញ្ញាណនិទ្ទេស | .......... .......... .......... ......... | ៦៥២ |
| សុត្តន្តបិដក | .......... .......... .......... ......... | ៦៦៧ |
| អដ្ឋកថាឧទយព្វយញ្ញាណនិទ្ទេស | .......... .......... .......... ........ | ៦៧៣ |
| សុត្តន្តបិដក | .......... .......... .......... ........ | ៦៨៣ |
| អដ្ឋកថាកង្ខានុបស្សនាញាណនិទ្ទេស | .......... .......... .......... ......... | ៦៨៦ |
| សុត្តន្តបិដក | .......... .......... .......... ....... | ៦៩៤ |
| អដ្ឋកថាអាទីនវញ្ញាណនិទ្ទេស | .......... .......... .......... ....... | ៦៩៧ |
| សុត្តន្តបិដក | .......... .......... .......... ..... | ៧០២ |

អដ្ឋកថាសង្ខារុបេក្ខាញាណនិទ្ទេស .......... .......... .......... ...... ៧១២
សុត្តន្តបិដក .......... .......... .......... ..... ៧៣១
អដ្ឋកថា គោត្រភូញាណនិទ្ទេស .......... .......... .......... ...... ៧៣៨